សៀវភៅណែនាំសម្រាប់
វគ្គបណ្តុះបណ្តាលជាក្រុម ស្តីពី

# អភិបាលកិច្ចមូលដ្ឋាន ~ ការរៀបចំតាក់តែងគោលនយោបាយ និងសង្គមស៊ីវិល

J0600932

ឆ្នាំសារពើពន្ធ ២០០៧

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន
ស្ថាប័នឯកទេសស្វ័យភាពមូលដ្ឋាន

NCDD Library
000462

អភិបាលកិច្ចមូលដ្ឋាន (ការរៀបចំតាក់តែងគោលនយោបាយ
និងសង្គមស៊ីវិល)
ឆ្នាំសារពើពន្ធ ២០០៧

# ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននៅប្រទេសជប៉ុន

## ~មាតិកា~


**ជំពូកទី ១ : ប្រវត្តិនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន**

១. ការចាប់កំណើតនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានសម័យទំនើប ........ ១

២. រដ្ឋាភិបាលមូលដ្ឋានក្រោមរដ្ឋធម្មនុញ្ញរាជាធិរាជ ( មុនសង្គ្រាមលោកលើកទី ២) ........ ១

៣. ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ( សករាជក្រោយសង្គ្រាម ) ........ ៣

៤. ភាពចាំបាច់នៃ "វិមជ្ឈការថ្មី" ........ ៥

**ជំពូកទី ២ : ការបង្កើតរដ្ឋាភិបាលមូលដ្ឋាន**

១. ឋានៈស្របច្បាប់នៃរដ្ឋាភិបាលមូលដ្ឋាន : រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ........ ៧

២. ធាតុសំខាន់ៗនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ........ ៨

៣. អង្គការរបស់រដ្ឋាភិបាលមូលដ្ឋាន ........ ១៦

៤. ប្រជាធិបតេយ្យមូលដ្ឋាន ........ ២៨

**ជំពូកទី ៣ : ទំនួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋាន**

១. ទំនួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋាន : "ភារកិច្ចស្វ័យត" និង " ភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់" ........ ៣១

២. ភារកិច្ចចម្បងដែលបំពេញដោយរដ្ឋាភិបាលមូលដ្ឋាន ........ ៣២

**ជំពូកទី ៤ : ទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន**

១. ទំនាក់ទំនងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ........ ៤៥

២. កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលមូលដ្ឋាន ........ ៤៧



354.968 POL
Sh= Training

# ជំពូកទី ១ : ប្រវត្តិនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន

## ១. ការចាប់កំណើតនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានសម័យទំនើប

មុននឹងបើកចំហទៅរកបស្ចិមប្រទេសក្នុងឆ្នាំ១៨៦០ ប្រព័ន្ធរដ្ឋាភិបាលជប៉ុនជារបបសក្តិភូមិទំនើបកម្ម ដោយមានមេផ្តាច់ការយោធាដែលត្រួតត្រាលើពួកស្តេចត្រាញ់ទាំងអស់ ហើយពួកស្តេចត្រាញ់ប្រមូលយកថ្លៃឈ្នួលពីអ្នកភូមិ ។ ទោះបីជារដ្ឋបាលមូលដ្ឋានត្រូវបានរៀបចំឡើងចេញពីទស្សនៈនៃស្ថិរភាពក្រោមប្រព័ន្ធសក្តិភូមិក៏ដោយ ក៏អ្នកភូមិនៅតែជា "អង្គភាពពិតប្រាកដ" : មេភូមិដើរតួនាទីជាអន្តរការីរវាងស្តេចត្រាញ់ និងសហគមន៍ ដោយធានានូវការប្រមូលថ្លៃឈ្នួលដែលមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចជាតិក្នុងរបបសក្តិភូមិ ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍបណ្តាញពាណិជ្ជកម្មថ្នាក់ជាតិ បានពង្រឹងស្ថានភាពទីក្រុង ទោះបីជាស្វ័យភាពរបស់ប្រជាពលរដ្ឋមានលក្ខណៈទន់ខ្សោយ ក្រោមការត្រួតពិនិត្យពីសក្តិភូមិក៏ដោយ ។

ប្រត្យាស្ថាប័នអធិរាជម៉ីជី (ឆ្នាំ១៨៦៧) បានផ្លាស់ប្តូរទាំងស្រុងនូវស្ថានភាពរបស់ភូមិ ។ ដោយភ័យខ្លាចរបបអាណានិគម រដ្ឋាភិបាលបានប្រញាប់ប្រញាល់ដើរតាមអោយទាន់បណ្តាបស្ចិមប្រទេសនានា ។ ក្នុងការដាក់បញ្ចូលនូវសញ្ញាណ "ប្រជាជាតិ" មេដឹកនាំប្រត្យាស្ថាប័នបានជំនួសអភិបាលកិច្ចសក្តិភូមិដោយប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានទំនើប ដោយផ្អែកលើការបែងចែកដែនដីជាខេត្ត មុននឹងប្រកាសអោយប្រើរដ្ឋធម្មនុញ្ញរាជាធិរាជ។ តាមរយៈមធ្យោបាយនេះ "អង្គភាពពិតប្រាកដ" បានចាប់ផ្តើមប្រែក្លាយទៅជាអាជ្ញាធរមូលដ្ឋានរដ្ឋបាលទំនើប ។

នៅឆ្នាំ១៨៧៨ *សាន-ស៊ិនប៉ូ* (ព្រះរាជបញ្ញត្តិថ្មីបី) គឺជាជំហានដំបូងនៅក្នុងប្រវត្តិនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានទំនើប ។ ព្រះរាជបញ្ញត្តិបង្កើតទីក្រុងបានបែងចែកខេត្តជាតំបន់ *(ហ្គុន)* និងទីក្រុង (*គូ*) ហើយបែងចែកស្រុកជាឃុំ និងភូមិ *(ចូ* និង*សុន)* ។ ការបែងចែកទាំងបីនេះ *គូ ចូ* និង*សុន* មានចរិតលក្ខណៈពីរនៃអង្គភាពសាធារណៈមូលដ្ឋាន និងមណ្ឌលរដ្ឋបាលជាតិ ។ ព្រះរាជបញ្ញត្តិស្តីពីសភាខេត្ត ដែលដាក់បញ្ចូលនូវសភាខេត្តនានាមានសមាសភាពសមាជិកជ្រើសតាំងដោយការបោះឆ្នោត និងព្រះរាជបញ្ញត្តិស្តីពីអាករមូលដ្ឋាន ដែលចែងអំពីនីតិវិធីសម្រាប់ការប្រមូលអាករមូលដ្ឋាន និងផ្តល់អោយខេត្តនូវលក្ខណៈពិសេសជាអាជ្ញាធរមូលដ្ឋាន ក្នុងកម្រិតខ្លះ ។

ព្រះរាជបញ្ញត្តិទាំងនេះបង្ហាញនូវធាតុផ្សំជាមូលដ្ឋានគ្រឹះមួយចំនួននៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជប៉ុន ដែលនៅបន្តរហូតមកដល់សព្វថ្ងៃនេះ ។ ប៉ុន្តែ ធាតុផ្សំទាំងនេះមិនអាចមិនផ្លាស់ប្តូរបានឡើយ នៅក្នុងកំឡុងពេលនៃអន្តរកាលដ៏ឆាប់រហ័សនេះ ហើយភាពវឹកវរនៃបញ្ហានយោបាយបានបង្ខំអោយមេដឹកនាំសម័យកាលស្វែងរកប្រព័ន្ធរដ្ឋបាលមូលដ្ឋានដែលកាន់តែមានស្ថិរភាពជាងមុន ។

## ២. រដ្ឋាភិបាលមូលដ្ឋានក្រោមរដ្ឋធម្មនុញ្ញរាជាធិរាជ (មុនសង្គ្រាមលោកលើកទី ២)

ក្រោយពីព្រះរាជបញ្ញត្តិរាជាធិរាជក្នុងឆ្នាំ១៨៨១ ដែលចែងអំពីការបង្កើតរដ្ឋសភាក្នុងឆ្នាំ១៨៩០ រដ្ឋាភិបាលព្យាយាមបង្កើតប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានពេញលេញ មុននឹងការបើកចំហរដ្ឋសភាក្នុងគោលដៅធ្វើអោយសាធារណជនមានការជ្រួតជ្រាបអំពីលទ្ធិប្រជាធិបតេយ្យទំនើប ។ ប្រការនេះមិនមែនមិនអើពើនឹងការរីកចម្រើននៃចលនាប្រជាធិបតេយ្យភាវូបនីយកម្ម ដែលលេចឡើងច្បាស់នៅថ្នាក់មូលដ្ឋាន និងការអភិវឌ្ឍនៃប្រព័ន្ធគណបក្សនយោបាយឡើយ ។

នៅឆ្នាំ១៨៨៨ ច្បាប់ស្តីពីរដ្ឋាភិបាលក្រុងត្រូវបានប្រកាសអោយប្រើប្រាស់ ។ ច្បាប់នេះត្រូវបានធ្វើសេចក្តីព្រាង និងយកគំរូតាម ជាពិសេស ប្រព័ន្ធមូលដ្ឋានរបស់ប្រទេសអាល្លឺម៉ង់ ដោយយកចិត្តទុកដាក់ទៅលើសង្គមប្រពៃណីជប៉ុន ។ តាមការពិត ការបង្កើតជប៉ុនទំនើបបានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីច្បាប់របស់ប្រទេសអាល្លឺម៉ង់ ដែលត្រូវបានវិនិច្ឆ័យដោយមេដឹកនាំសម័យកាលម៉ីជីថាមានភាពសមស្របជាងគេបំផុតក្នុងចំណោមគំរូច្បាប់ទាំងឡាយនៅអឺរ៉ុប ចំពោះវត្តមានរដ្ឋាភិបាលដ៏សំខាន់ ។

ច្បាប់នេះចែងអំពីសភាក្រុង មានសមាសភាពសមាជិកជ្រើសតាំងដោយការបោះឆ្នោត ដែលមានឋានៈកិត្តិយសជាអង្គការនីតិបញ្ញត្តិរបស់ក្រុង ។ មេឃុំ និងមេភូមិត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកសភា ចំណែកឯអភិបាលក្រុងត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយជ្រើសរើសចេញពីបញ្ជីបេក្ខជនដែលរៀបចំឡើងដោយសភាខ្លួនឯង ។ អភិបាលក្រុងក៏ជាគណៈកម្មាធិការសមាជិកក្រុមប្រឹក្សា (មេឃុំ មេឃុំរង និងសមាជិកកិត្តិយសនៃគណៈ-កម្មាធិការ) ផងដែរ ។

ស្របគ្នាទៅនឹងការចែងនេះ រដ្ឋាភិបាលអនុវត្តវិធានការពីថ្នាក់លើដល់ថ្នាក់ក្រោម ដើម្បីរំលាយក្រុងបញ្ចូលគ្នា ។ នៅពេលចាប់ផ្តើមដំបូង "អង្គភាពពិតប្រាកដ" នៅមានជីវិត ដោយអនុម័តយកក្របខ័ណ្ឌនៃប្រព័ន្ធមូលដ្ឋានទំនើបកម្ម ប៉ុន្តែ ភាពចាំបាច់នៃឯកសណ្ឋានភាពផ្នែករដ្ឋបាលមិនបានអនុញ្ញាតអោយសហគមន៍តូចៗនៅជាសហគមន៍ដូចដែលធ្លាប់មានអស់រយៈពេលជាច្រើនទសវត្សមកហើយនោះទេ ។ អាស្រ័យហេតុនេះ ចំនួនក្រុងបានថយចុះមួយភាគប្រាំ ។

ផ្ទុយទៅវិញ ខេត្ត និងស្រុក ដែលត្រូវបានកំណត់ជាថ្មី នៅក្នុងច្បាប់ស្តីពីរដ្ឋាភិបាលខេត្ត និងច្បាប់ស្តីពីរដ្ឋាភិបាលស្រុក ឆ្នាំ១៨៩០ មានចរិតលក្ខណៈគ្របដណ្តប់នៃតំបន់រដ្ឋបាលជាតិដោយមានអភិបាលខេត្តមួយរូប អភិបាលស្រុកមួយរូបតែងតាំងដោយក្រសួងមហាផ្ទៃ (ទោះបីជាមានវត្តមាននៃសភាដែលត្រូវបោះឆ្នោតជ្រើសតាំងជាសាធារណៈក៏ដោយ) ។ ចំនួននៃខេត្តត្រូវបានកាត់បន្ថយពី ៣០៥ (៣ *ហ្វូ* និង ៣០២ *កេន*) ក្នុងឆ្នាំ១៨៧១ ទៅ ៤៦ (៣ *ហ្វូ* និង ៤៣ *កេន*) ក្នុងឆ្នាំ១៨៩០ ដែលស្ទើរតែមិនមានការផ្លាស់ប្តូររហូតមកដល់បច្ចុប្បន្ននេះ ។

សម័យកាលរវាងទសវត្សរ៍ឆ្នាំ១៨៩០ និងទសវត្សរ៍ឆ្នាំ១៩២០ អាចត្រូវបានសង្ខេបថាជាដំណាក់កាលវិវត្តន៍នៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានក្រោមរដ្ឋធម្មនុញ្ញរាជាធិរាជ ។ ការរង្គោះរង្គើនៃ "ប្រជាធិបតេយ្យតៃស្យូ" បានជំរុញអោយរដ្ឋា-ភិបាលពង្រីកការបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត ដល់បុរសទាំងអស់ដែលមានអាយុលើសពី ២០ ឆ្នាំ ឡើងទៅ (ដោយសេរីវប្រព័ន្ធបោះឆ្នោតក្នុងឆ្នាំ១៩២១ និងឆ្នាំ១៩២៦) : ខេត្តត្រូវបានអនុញ្ញាតអោយចេញបទបញ្ជា នៅក្នុងឆ្នាំ១៩២៩ ដោយមានការពង្រឹងខ្លះៗនៃអំណាចផ្សេងទៀត (ឧទាហរណ៍ ការបង្កើនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត) ។ ម្យ៉ាងវិញទៀត តំបន់ *(ហ្គុន)* ត្រូវបានយល់ឃើញថាមិនមានភាពចាំបាច់សម្រាប់អភិបាលកិច្ចមូលដ្ឋាន ហើយត្រូវបានលុបបំបាត់ជាស្ថាពរនៅក្នុងឆ្នាំ១៩២៦ ។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏កង្វល់ពីសង្គ្រាមក្រោយឆ្នាំ១៩២៩ បានធ្វើអោយកើតមាននូវវិធានការបន្ទាន់ជាច្រើន ហើយមជ្ឈការកម្មមុខងាររដ្ឋបាលបានកាត់ផ្តាច់សិទ្ធិស្វ័យភាពពីអាជ្ញាធរមូលដ្ឋាន ។ ស្ថានភាពនេះមានភាពតានតឹងឡើងនៅក្នុងឆ្នាំ១៩៤៣ ដោយអង្គភាពមូលដ្ឋានអាចអនុវត្តអំណាចក្នុងកម្រិតអប្បបរមាប៉ុណ្ណោះ ។

### ៣. ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន (សករាជក្រោយសង្គ្រាម)

បរាជ័យរបស់ប្រទេសជប៉ុននៅក្នុងសង្គ្រាមលោកលើកទី ២ (ឆ្នាំ១៩៤៥) ជំរុញអោយមានការពិនិត្យឡើងវិញទាំងស្រុងនៃប្រព័ន្ធរដ្ឋាភិបាលជាតិ និងរដ្ឋាភិបាលមូលដ្ឋាន ហើយច្បាប់ដែលមានស្រាប់អំពីប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានមិនអាចប្រើប្រាស់ទៀតបានឡើយ ។ ដំណាក់កាលដំបូងនៃកំណែទម្រង់បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៤៦ ហើយឈានទៅដល់ការប្រកាសអោយប្រើនូវច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានក្នុងឆ្នាំ១៩៤៧ នៅថ្ងៃដែលរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យថ្មីត្រូវបានអនុម័ត ។

ច្បាប់នេះបង្កើតនូវគោលការណ៍មួយក្នុងចំណោមគោលការណ៍ធម្មនុញ្ញចម្បង : ស្វ័យភាពមូលដ្ឋាន ។ ដោយយកគំរូតាមប្រព័ន្ធអាមេរិក ច្បាប់នេះមានលក្ខណៈដូចខាងក្រោម :

ក) ដែនទំនួលខុសត្រូវកាន់តែធំឡើងសម្រាប់អាជ្ញាធរមូលដ្ឋាន ជាមួយនឹងអំណាចកាន់តែច្រើនឡើងដែលផ្តល់ជូនក្រុមប្រឹក្សា និងមានការត្រួតពិនិត្យពីថ្នាក់កណ្តាលកាន់តែតិចទៅៗ ។

ខ) ប្រជាធិបតេយ្យរឹងមាំជាមួយនឹងការដាក់បញ្ចូលនូវការបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សា អភិបាលខេត្ត និងអភិបាលក្រុង និងមធ្យោបាយជាច្រើនទៀតសម្រាប់ការដកហូតមុខដំណែង និងគំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ និង

គ) រដ្ឋបាលមានប្រសិទ្ធភាព ជាមួយនឹងការបង្កើតអង្គភាពរដ្ឋបាល និងសវនករជាច្រើន ។

ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃប្រព័ន្ធរដ្ឋាភិបាលកណ្តាលបានដំណើរការចាប់តាំងពីសម័យកាលនោះ រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៥០ ។ ច្បាប់ស្តីពីនគរបាល ច្បាប់ស្តីពីការរៀបចំការការពារអគ្គីភ័យ និងច្បាប់ស្តីពី គណៈកម្មាធិការអប់រំ ដែលត្រូវបានបង្កើតឡើងនៅចន្លោះឆ្នាំ១៩៤៧ និងឆ្នាំ១៩៤៨ បានផ្ទេរកិច្ចការនគរបាល ការការពារអគ្គីភ័យ និងការអប់រំ ដែលកាលពីមុនត្រូវបានចាត់ទុកថាជាភារកិច្ចរបស់រដ្ឋាភិបាលកណ្តាល ទៅអោយអាជ្ញាធរមូលដ្ឋាន ។ ចំពោះហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបានបញ្ជាក់យ៉ាងច្បាស់អំពីគោលការណ៍គ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន និងទំនាក់ទំនងហិរញ្ញវត្ថុរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ដោយរដ្ឋាភិបាលទាំងនេះមានទំនួលខុសត្រូវហិរញ្ញវត្ថុមានកម្រិតចំពោះភារកិច្ចដែលតម្រូវដោយច្បាប់ជាតិ ។

ក្នុងកំឡុងសម័យកាលនោះ យើងត្រូវកត់សម្គាល់អំពីសារៈសំខាន់នៃរបាយការណ៍ស្ងូប ក្នុងឆ្នាំ១៩៤៩ ដែលផ្តល់នូវមូលដ្ឋានទ្រឹស្តីដល់ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជប៉ុន ដោយអោយតម្លៃស្វ័យភាពក្រុងជាងការគ្រប់គ្រងក្រុង ។ របាយការណ៍នេះផ្តោតជាសំខាន់លើការបែងចែកឡើងវិញអោយបានសមស្របនូវភារកិច្ចដល់រដ្ឋាភិបាលមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងការពង្រឹងធនធានហិរញ្ញវត្ថុសម្រាប់អាជ្ញាធរមូលដ្ឋាន ។ ឥទ្ធិពលនៃរបាយការណ៍នេះអាចមើលឃើញនៅក្នុងកំណែទម្រង់ទ្រង់ទ្រាយធំនៃប្រព័ន្ធអាករមូលដ្ឋាន និងការបង្កើតឧបត្ថម្ភធនសមកម្មហិរញ្ញវត្ថុដល់រដ្ឋាភិបាលមូលដ្ឋាន ។

នៅពេលជាមួយគ្នានោះផងដែរ កំណែទម្រង់ដ៏សំខាន់ផ្សេងទៀតត្រូវបានអនុវត្ត ដូចជា ប្រព័ន្ធមុខងារសាធារណៈមូលដ្ឋាន (ដោយច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ក្នុងឆ្នាំ១៩៥០) និងប្រព័ន្ធសហគ្រាសសាធារណៈមូលដ្ឋាន (ដោយច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ក្នុងឆ្នាំ១៩៥២) ។

ក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៥០ ដោយសារភាពខ្វះបទពិសោធន៍របស់រដ្ឋាភិបាលមូលដ្ឋាន ប្រទេសជប៉ុនត្រូវធ្វើការស្វែងរកសនិទានភាព និងប្រសិទ្ធភាពនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន នៅកម្រិតរៀបចំ និងសារពើពន្ធ ។

នៅក្នុងវិស័យនគរបាល និងអប់រំ លក្ខណៈនៃអង្គភាពក្នុងវិស័យទាំងពីរនេះបានផ្លាស់ប្តូរយ៉ាងខ្លាំង ។ ប្រព័ន្ធនគរបាលក្រុងត្រូវបានជំនួសដោយប្រព័ន្ធនគរបាលខេត្ត ក្នុងឆ្នាំ១៩៥៤ ហើយសមាជិកក្រុមប្រឹក្សាអប់រំលែងត្រូវបានបោះឆ្នោតជ្រើសតាំងជាសាធារណៈទៀតហើយ ប៉ុន្តែ ត្រូវបានតែងតាំងដោយប្រធានអង្គភាពសាធារណៈមូលដ្ឋាន ដោយសារមានវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្នុងឆ្នាំ១៩៥៦ ។

ការស្នើសុំអោយមានរដ្ឋបាលមូលដ្ឋានកាន់តែមានសនិទានភាព បណ្តាលអោយមានការបង្កើតច្បាប់ស្តីពីការជំរុញការរំលាយក្រុងបញ្ចូលគ្នានៅក្នុងឆ្នាំ១៩៥៣ ។ យោងតាមច្បាប់នេះ មានការរៀបចំឡើងវិញទាំងស្រុងនូវក្រុង ហើយជាលទ្ធផល មានការកាត់បន្ថយក្រុងចំនួនមួយភាគបី (ពី២៨៦ ក្រុង និង ៩.៥៨២ ឃុំ ឬភូមិ ទៅ ៥៩៤ ក្រុង និង ៣.៤៧៧ ឃុំ ឬភូមិ) ក្នុងរយៈពេលបីឆ្នាំ ។

ភាពទ្រុឌទ្រោមជាទូទៅនៃហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបានលេចឡើងច្បាស់ នៅក្នុងឆ្នាំ១៩៥៤ ដោយមានអាជ្ញាធរមូលដ្ឋានចំនួនមួយភាគបីស្ថិតក្នុងឱនភាព ។ ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នេះ ច្បាប់វិធានការពិសេសស្តីពីការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៥ ហើយសម្រេចបានលទ្ធផលល្អៗខាងការកសាងឡើងវិញនូវហិរញ្ញវត្ថុមូលដ្ឋានមានស្ថិរភាព ក្នុងរយៈពេលប្រាំឆ្នាំ ដោយសារតែការជួយបង្កើនចំណូលខាងអាករមួយផ្នែក ដែលជាផ្លែផ្កានៃកំណើនសេដ្ឋកិច្ចវិសាមញ្ញ ។

តាមរយៈកំណែទម្រង់ទាំងនេះ ការពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន និងទំនាក់ទំនងរវាងខេត្ត និងក្រុង អាចសង្កេតឃើញមានយ៉ាងទូលំទូលាយតាមរយៈសកម្មភាពមិនប្រើអំណាចផ្តាច់ការ ។

កំណើនសេដ្ឋកិច្ច ដែលប្រទេសជប៉ុនទទួលបាន នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បណ្តាលអោយមានការប្រមូលផ្តុំឧស្សាហកម្ម និងប្រជាជន នៅក្នុងទីក្រុងធំៗ ហើយការបំផ្លាញតំបន់ជនបទបានក្លាយជាបញ្ហាក្នុងស្រុកដ៏ធំបំផុតមួយ ។ ភាពចាំបាច់នៃការអភិវឌ្ឍមានតុល្យភាពនូវប្រទេសជាតិទាំងមូល និងការត្រួតពិនិត្យលំហូរច្រើនហួសប្រមាណនៃប្រជាជននៅក្នុងតំបន់ទីក្រុង បណ្តាលអោយមានការបង្កើតច្បាប់សម្រាប់ទីក្រុងឧស្សាហកម្មថ្មីៗដែលលើកស្ទួយការអភិវឌ្ឍជនបទជាមួយនឹងគំនិតផ្តួចផ្តើមរបស់អាជ្ញាធរមូលដ្ឋាន ។

ក្នុងពេលជាមួយគ្នានេះដែរ ដោយសារតែតម្រូវការសម្រាប់ "រដ្ឋបាលកម្រិតតំបន់" រួមទាំងក្រុង កំពុងត្រូវបានផ្តោតការយកចិត្តទុកដាក់ "តំបន់ធំៗសម្រាប់កិច្ចសហប្រតិបត្តិការក្រុង" ត្រូវបានបង្កើតឡើង ដោយផ្អែកលើតម្រូវការនៃជីវភាពប្រចាំថ្ងៃនៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទ ។

ឥទ្ធិពលបន្ទាប់បន្សំជាអវិជ្ជមានផ្សេងទៀតនៃកំណើតសេដ្ឋកិច្ច គឺបញ្ហាសម្លេង និងការបំពុល ដែលកាន់តែមានទ្រង់ទ្រាយធំឡើងៗ ចាប់តាំងពីពាក់កណ្តាលចុងក្រោយនៃទសវត្សរ៍ឆ្នាំ១៩៦០ ។ បញ្ហានេះតម្រូវអោយមានការផ្លាស់ប្តូរពីការអភិវឌ្ឍទៅការការពារបរិស្ថាន និងសុខុមាលភាពសង្គមសម្រាប់ប្រជាពលរដ្ឋ ។ ប៉ុន្តែ ប្រតិកម្មតបរបស់រដ្ឋាភិបាលកណ្តាលមានភាពយឺតយ៉ាវជាទីបំផុត ប៉ុន្តែ អាជ្ញាធរមូលដ្ឋានបានបង្ហាញនូវការយកចិត្តទុកដាក់ទៅលើបញ្ហានេះ ដែលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ អាជ្ញាធរមូលដ្ឋានបានចេញដីកាសម្រាប់ការត្រួតពិនិត្យការបំពុលមុនពេលមានច្បាប់ជាតិ ។

វិបត្តិប្រេងនៅក្នុងឆ្នាំ១៩៧៣ បង្ហាញអំពីការបញ្ចប់នៃកំណើនសេដ្ឋកិច្ចដ៏រុងរឿងនៃទសវត្សរ៍ឆ្នាំ១៩៦០ ហើយល្បឿននៃការវិវត្តន៍កាន់តែថយចុះថែមទៀត ក្រោយឆ្នាំ១៩៧៥ ។ ព្រឹត្តិការណ៍នេះបានបំផ្លាញហិរញ្ញវត្ថុសាធារណៈថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ហើយរដ្ឋាភិបាលបានចេញប័ណ្ណប្រាក់សាធារណៈក្នុងទំហំដ៏ធំសំបើម ដើម្បីដោះស្រាយបញ្ហាឱនភាពនៃសារពើពន្ធ ហើយជាលទ្ធផល បង្កអោយមានភាពទ្រុឌទ្រោមដល់រចនាសម្ព័ន្ធហិរញ្ញវត្ថុជាតិ ។

ទោះបីជាមានការខូចខាតខាងសារពើពន្ធក៏ដោយ ក៏ភាពចាស់ទុំនៃស្វ័យភាពមូលដ្ឋានបានធ្វើអោយរដ្ឋាភិបាលមូលដ្ឋានកាន់តែមានសមត្ថភាពជាងមុន ហើយរដ្ឋាភិបាលមូលដ្ឋានចាប់ផ្តើមអនុវត្តការបង្កើនអំណាច និងស្តារឡើងវិញនូវឯកត្តភាពនៃវប្បធម៌មូលដ្ឋាន ។ ចលនានេះ ដែលត្រូវបានហៅថា "សករាជនៃមូលដ្ឋាន" ត្រូវបានគាំទ្រតិច ឬច្រើនដោយវិធានការថ្នាក់ជាតិជាច្រើន ដូចជា គោលនយោបាយនិវេសដ្ឋានចំរុះ និងផែនការទីក្រុងជនបទ ។

## ៤. ភាពចាំបាច់នៃ "វិមជ្ឈការថ្មី"

ទសវត្សរ៍ឆ្នាំ១៩៨០ ត្រូវបានសម្គាល់ដោយកំណែទម្រង់ហិរញ្ញវត្ថុ និងរដ្ឋបាល ទោះបីជាមានឱនភាពដ៏ខ្លាំងក្លាក៏ដោយ ។ គណៈរដ្ឋមន្ត្រីបានកោះប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់ពិសេសអំពីកំណែទម្រង់រដ្ឋបាល បីដង ដែលបានផ្តល់អនុសាសន៍អោយធ្វើសនិទានកម្មរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន ។

ទោះបីជាមានការកម្រិតអោយមាន "ការកាត់បន្ថយចំនួនបុគ្គលិក" ក៏ដោយ ក៏និន្នាការសម្រាប់អាជ្ញាធរមូលដ្ឋានក្នុងការឈានឆ្ពោះទៅរក "ស្វ័យភាពមូលដ្ឋានពិតប្រាកដ" កាន់តែគួរអោយកត់សម្គាល់ខ្លាំងឡើងៗ ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីរំដោះខ្លួនចេញពីការពឹងផ្អែកខាងហិរញ្ញវត្ថុទៅលើឧបត្ថម្ភធនជាតិ ដែលមានខនៃល័ក្ខខ័ណ្ឌរាប់រយដែលបង្កលក្ខណៈងាយស្រួលដល់ឯកសណ្ឋានភាពយ៉ូរអង្វែងនៃរដ្ឋបាលមូលដ្ឋាន តាមរយៈប្រភេទការងារជាច្រើននៃសេវារដ្ឋបាលដែលផ្តួចផ្តើមគំនិតដោយរដ្ឋាភិបាលមូលដ្ឋាន ។

នៅក្នុងកម្រិតនៃភាពអាចប្រើប្រាស់បានយ៉ាងប៉ិនប្រសប់ រដ្ឋាភិបាលមូលដ្ឋានជួបប្រទះនូវបញ្ហាប្រឈម ។ រដ្ឋាភិបាលមូលដ្ឋាន ដែលមានការគាំទ្រពីការរីកលូតលាស់សេដ្ឋកិច្ចខ្លាំងនៅចុងទសវត្សរ៍ឆ្នាំ៨០ បានផ្លាស់ប្តូរគោលនយោបាយឯកសណ្ឋានរបស់ខ្លួន ទៅជាគោលនយោបាយផ្សេងៗ ដែលជំរុញ និងបង្កើតអោយមានភាពចំរុះថ្នាក់តំបន់ ។

ការថយចុះបន្ទាប់ពីការដួលរលំនៃ "សន្ទុះសេដ្ឋកិច្ច" នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ បានប្រឈមមុខនឹងបញ្ហារចនាសម្ព័ន្ធទាំងអស់ដែលកើនឡើងតាំងពីពេលចប់សង្គ្រាមលោកលើកទី ២ រួចមក ហើយប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានក៏មិនខុសគ្នាពីនេះដែរ ។ វិធានការបន្ធូរបន្ថយ និងបណ្តោះអាសន្នសម្រាប់វិមជ្ឈការ ត្រូវបានធ្វើឡើង សម្រាប់រយៈពេលវែង ប៉ុន្តែសម្ព័ន្ធភាពនយោបាយនៃគណៈបក្សជាច្រើន ចាប់តាំងពីឆ្នាំ១៩៩៣ បានធ្វើកំណែទម្រង់រចនាសម្ព័ន្ធសម្រាប់ធ្វើវិមជ្ឈការបញ្ហាចម្បងៗរបស់រដ្ឋាភិបាល និងសភា ។

នៅក្នុងឆ្នាំ១៩៩៥ ច្បាប់ស្តីពីការជំរុញវិមជ្ឈការត្រូវបានបង្កើតឡើង ក្នុងគោលដៅកំណត់អំពីគោលការណ៍នៃវិមជ្ឈការ និងបញ្ជាក់អោយបានច្បាស់អំពីនីតិវិធីក្នុងការសម្រេចគោលការណ៍ទាំងនេះ ដោយបង្កើតអោយមានជាគណៈកម្មាធិការជំរុញវិមជ្ឈការ ។ ខុសពីក្រុមប្រឹក្សាសាមញ្ញរបស់រដ្ឋាភិបាល សកម្មភាពមិនត្រូវបានកម្រិតត្រឹមតួនាទីផ្តល់យោបល់ធម្មតានោះទេ ។ គណៈកម្មាធិការនេះបង្កើតនូវទស្សនាទានថ្មីៗនៃភារកិច្ច ពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ហើយធ្វើចំណែកថ្នាក់បញ្ហានីមួយៗទៅតាមប្រភេទ (ឧទាហរណ៍ វិធានទូទៅ

ថ្មី១នៃការប្ដេជ្ញាជាតិ នីតិវិធីបណ្ដឹងតវ៉ារដ្ឋបាល ។ល។ ជាមួយនឹងលទ្ធផលដែលបានព្រាងក្នុងទម្រង់ជាអនុសាសន៍ដល់រដ្ឋាភិបាល (អនុសាសន៍បែបនេះចំនួនប្រាំត្រូវបានដាក់ជូននៅក្នុងឆ្នាំ១៩៩៨) ។ ដោយគោរពតាមយ៉ាងពេញលេញនូវអនុសាសន៍ទាំងនេះ រដ្ឋាភិបាលបានរៀបចំផែនការជំរុញវិមជ្ឈការ ដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំវិធានការច្បាប់នាពេលក្រោយ ។

នៅក្នុងខែឧសភា ឆ្នាំ១៩៩៨ រដ្ឋាភិបាលបានតាក់តែងផែនការជំរុញវិមជ្ឈការនេះចប់ជាស្ថាពរ និងបានដាក់ជូនទៅរដ្ឋសភា ។ ផែនការនេះស្របនឹងអនុសាសន៍ដែលធ្វើឡើងដោយគណៈកម្មាធិការជំរុញវិមជ្ឈការ ។ ទិដ្ឋភាពធំជាងគេបំផុតគឺការលុបបំបាត់ "ការងារជាទីភ្នាក់ងារទទួលប្រតិភូកម្ម" ដែលបានចាប់ផ្តើមតាំងពីសករាជមុនសង្គ្រាម នៅពេលដែលរដ្ឋបានផ្ទេរភារកិច្ចដល់អភិបាលខេត្តដែលបានតែងតាំង និង "អំណាចពេញលេញ ដឹកនាំ និងត្រួតពិនិត្យ" នៃរដ្ឋាភិបាលពាក់ព័ន្ធទៅនឹងភារកិច្ចនេះ ។ ផែនការនេះក៏តម្រូវអោយមានការកាត់បន្ថយ និងការរៀបចំឡើងវិញនូវឧបត្ថម្ភធនដែលផ្ដល់ជូនរដ្ឋាភិបាលមូលដ្ឋានសម្រាប់គោលបំណងពិសេស ដែលជាមធ្យោបាយផ្សេងទៀតដែលរដ្ឋប្រើប្រាស់ ដើម្បីធ្វើអន្តរាគមន៍នៅក្នុងរដ្ឋាភិបាលមូលដ្ឋាន ។ កញ្ចប់កំណែទម្រង់ដែលមានជាង ៥០០ ពាក់ព័ន្ធទៅនឹងវិសោធនកម្មច្បាប់ត្រូវបានដាក់ជូនសម័យប្រជុំសាមញ្ញរបស់គណៈរដ្ឋមន្ត្រី ដែលចាប់ផ្ដើមក្នុងខែមករា ឆ្នាំ១៩៩៩ ហើយរដ្ឋាភិបាលអនុវត្តកញ្ចប់នៃកំណែទម្រង់ចាប់ពីខែមេសា ឆ្នាំ២០០០ ។

នៅក្នុងចន្លោះពេលនោះ ទំហំនៃអាជ្ញាធរមូលដ្ឋានក៏ត្រូវបានពិនិត្យផងដែរ ។ ក្រៅពីការពង្រឹងកិច្ចសហប្រតិបត្តិការក្រុងដោយការបង្កើត "សហភាពកម្រិតតំបន់" ក្នុងឆ្នាំ១៩៩៤ ការសេរីច្បាប់ស្តីពីវិធានការពិសេសសម្រាប់ការរំលាយក្រុងបញ្ចូលគ្នា នៅក្នុងឆ្នាំ១៩៩៥ និងឆ្នាំ១៩៩៩ បានបង្កើត និងពង្រឹងគំនិតផ្ដួចផ្ដើមសម្រាប់ការប្រមូលផ្តុំក្រុមប្រឹក្សាចំរុះសម្រាប់ការរំលាយ និងជំនួយសារពើពន្ធសម្រាប់ការរំលាយ ។

ជាលទ្ធផល ក្រុមប្រឹក្សាចំរុះចំនួន ៥៨១ បានសម្រេចធ្វើការបញ្ចូលគ្នា នៅខែមីនា ឆ្នាំ២០០៥ ដែលជាកាលកំណត់នៃច្បាប់ស្តីពីវិធានការពិសេសសម្រាប់ការរំលាយក្រុងបញ្ចូលគ្នា ហើយចំនួនក្រុងមាន ១៨២១ នៅខែមីនា ឆ្នាំ២០០៦ ។ បន្ទាប់ពីផុតកំណត់ច្បាប់ស្តីពីវិធានការពិសេសសម្រាប់ការរំលាយក្រុងបញ្ចូលគ្នា ច្បាប់ថ្មីស្តីពីវិធានការពិសេសសម្រាប់ការរំលាយក្រុងបញ្ចូលគ្នាត្រូវបានបង្កើតឡើង និងដាក់អោយអនុវត្តចាប់តាំងពីខែមេសា ឆ្នាំ២០០៥ ។

រដ្ឋាភិបាលនឹងនៅតែបន្តជំរុញការរំលាយក្រុងបញ្ចូលគ្នា ក្នុងរយៈពេល ៥ ឆ្នាំទៀត ស្របតាមច្បាប់នេះ ។

ការផ្លាស់ប្តូរសង្គម និងកាលៈទេសៈនយោបាយ/សេដ្ឋកិច្ច តម្រូវអោយមានកំណែទម្រង់ក្នុងទ្រង់ទ្រាយធំនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជប៉ុន ។ វាមានសារៈសំខាន់សម្រាប់រដ្ឋបាលប្រកបដោយប្រសិទ្ធភាពក្នុងការពិនិត្យមើលទំនាក់ទំនង រវាងរដ្ឋ ខេត្ត និងក្រុង ហើយការរៀបចំអាជ្ញាធរមូលដ្ឋាន ដែលចូលរួមចំណែកប្រកបដោយអត្ថន័យនៅក្នុងសុខុមាលភាពរបស់ប្រជាពលរដ្ឋ មានសារៈសំខាន់ណាស់ ។

## ជំពូកទី ២ : ការបង្កើតរដ្ឋាភិបាលមូលដ្ឋាន

ជាលទ្ធផលនៃប្រវត្តិដែលយើងបានក្រឡេកមើលនៅក្នុងជំពូកទី ១ គោលការណ៍ដើមនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជប៉ុនត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីទស្សនាទានអាមេរិក ដោយមានការត្រួតពិនិត្យ និងតុល្យភាព រវាងអង្គការនីតិបញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ និងដោយមានវត្តមាននៃគណៈកម្មាធិការរដ្ឋបាលសម្រាប់ភារកិច្ចពិសេស ។ នៅទីនេះ

យើងពិនិត្យមើលការបង្កើតរដ្ឋាភិបាលមូលដ្ឋាន ទិដ្ឋភាពរៀបចំអាជ្ញាធរមូលដ្ឋានជប៉ុន : ជាដំបូង គឺឋានៈស្របច្បាប់ មានន័យថារដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន (១) បន្ទាប់មកទៀត គឺប្រភេទនៃអង្គភាពសាធារណៈមូលដ្ឋាន (២) និងអង្គការផ្ទៃក្នុងនៃអង្គភាពសាធារណៈមូលដ្ឋាន (៣) ។ ជាការពិតណាស់ដែលថា យើងមិនត្រូវមើលរំលងនូវធាតុដ៏សំខាន់មួយទៀតរបស់រដ្ឋាភិបាលមូលដ្ឋានឡើយ គឺប្រជាធិបតេយ្យមូលដ្ឋាន (៤) ។

## ១. ឋានៈស្របច្បាប់នៃរដ្ឋាភិបាលមូលដ្ឋាន : រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន

ដូចបានសង្កេតរួចមកហើយនៅក្នុងជំពូកទី ១ លើកដំបូងដែលប្រទេសជប៉ុនទទួលស្គាល់ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានថាជាប្រព័ន្ធមួយដែលផ្អែកលើគោលការណ៍ធម្មនុញ្ញ គឺនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៦ ។ ជំពូកទី ៨ នៃរដ្ឋធម្មនុញ្ញ (មាត្រា ៩២ ដល់មាត្រា ៩៥) ចែងអំពីគោលការណ៍នៃស្វ័យភាពមូលដ្ឋាន ។

មាត្រា ៩២ ចែងថា "បទបញ្ញាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសាធារណៈមូលដ្ឋានត្រូវកំណត់ដោយច្បាប់ ស្របទៅនឹងគោលការណ៍នៃស្វ័យភាពមូលដ្ឋាន" ។

លទ្ធិដែលមានការទទួលស្គាល់ជាទូទៅចែងថា សញ្ញាណនៃ "ស្វ័យភាពមូលដ្ឋាន" មានគោលការណ៍ពីរ : ស្វ័យភាពរបស់អាជ្ញាធរ មូលដ្ឋាន (១) និងស្វ័យភាពរបស់ប្រជាពលរដ្ឋ (២) ។ គោលការណ៍ទីមួយទាមទារនូវឯករាជ្យភាពរបស់អាជ្ញាធរមូលដ្ឋានពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលមូលដ្ឋាន ចំណែកគោលការណ៍ទីពីរផ្តោតលើស្វ័យគ្រប់គ្រងអាជ្ញាធរមូលដ្ឋានទាំងនេះដោយប្រជាពលរដ្ឋ ក្រោមទំនួលខុសត្រូវរៀង១ខ្លួន ។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ អង្គភាពមូលដ្ឋានមិនអាចផ្តាច់ចេញពីកម្រិតខ្លះនៃការត្រួតពិនិត្យស្របច្បាប់ដោយរដ្ឋាភិបាលមូលដ្ឋានកណ្តាលបានឡើយ ។ មាត្រា ៩២ បានបញ្ជាក់យ៉ាងច្បាស់អំពីចំណុចនេះ ដោយចែងថា ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរមូលដ្ឋានត្រូវកំណត់ដោយច្បាប់ ។

មាត្រា ៩៣ ចែងអំពីអង្គការផ្ទៃក្នុងរបស់អង្គភាពមូលដ្ឋាន : "អង្គភាពសាធារណៈមូលដ្ឋានត្រូវបង្កើតសភា ជាអង្គការធ្វើសេចក្តីសម្រេចរបស់ខ្លួនស្របតាមច្បាប់ ។ នាយកប្រតិបត្តិទាំងឡាយនៃអង្គភាពសាធារណៈមូលដ្ឋាន សមាជិកនៃសភារបស់ខ្លួន និងមន្ត្រីរាជការមូលដ្ឋានផ្សេងទៀត ដូចបានកំណត់ដោយច្បាប់ ត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ពីប្រជាជន នៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួនរៀង១ខ្លួន" ។

មាត្រានេះចែងអំពីធាតុសំខាន់១នៃ "ស្វ័យភាពរបស់ប្រជាពលរដ្ឋ" ដោយចែងថាសេចក្តីសម្រេចដែលធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន ស្ថិតនៅក្នុងកណ្តាប់ដៃរបស់សភាដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ ពីប្រជាពលរដ្ឋ ហើយមិនត្រឹមតែអ្នកតាក់តែងច្បាប់ប៉ុណ្ណោះទេ នាយកប្រតិបត្តិក៏ត្រូវបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋដែរ ។

ចំណែកឯ "ស្វ័យភាពរបស់អង្គភាពសាធារណៈមូលដ្ឋាន" មាត្រា ៩៤ ធានានូវសមត្ថកិច្ចរបស់អង្គភាពទាំងនោះ (ចំណុចនេះនឹងត្រូវវិភាគនៅក្នុងជំពូកបន្ទាប់) ។ "អង្គភាពសាធារណៈមូលដ្ឋានត្រូវមានសិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ កិច្ចការ និងរដ្ឋបាលរបស់ខ្លួន ហើយមានសិទ្ធិក្នុងការចេញបទបញ្ជារបស់ខ្លួនស្របតាមច្បាប់" ។

មាត្រា ៩៥ ចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើប្រជាមតិក្នុងមូលដ្ឋាន ពាក់ព័ន្ធនឹងការអនុម័ត ច្បាប់ពិសេសដែលអាចអនុវត្តបានតែចំពោះអង្គភាពសាធារណៈមូលដ្ឋានមួយប៉ុណ្ណោះ ។

រដ្ឋធម្មនុញ្ញបានទុកព័ត៌មានលម្អិតអំពីប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជាច្រើន ក្នុងការថែងអំពីច្បាប់ដែលអនុម័តដាច់ដោយឡែកពីគ្នា ហើយជាការពិត មានច្បាប់ជាច្រើនដែលពាក់ព័ន្ធដោយផ្ទាល់នឹងប្រព័ន្ធនេះ ។ ក្នុងចំណោមច្បាប់ទាំងនេះ ច្បាប់ដ៏សំខាន់ជាងគេបំផុតមួយគឺ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ដែលកំណត់អំពីរចនាសម្ព័ន្ធជាមូលដ្ឋានគ្រឹះ ( ប្រភេទ ការរៀបចំ ដែនសមត្ថកិច្ច និងទំនាក់ទំនងជាមួយរដ្ឋាភិបាលកណ្តាល) នៃអង្គភាពសាធារណៈមូលដ្ឋាន ។ នៅជុំវិញច្បាប់ "ពាក់កណ្តាលរដ្ឋធម្មនុញ្ញ" នេះ ច្បាប់ផ្សេងទៀតគ្រប់គ្រងវិស័យពិសេស១ដូចខាងក្រោម :

- ច្បាប់ស្តីពីមុខងារសាធារណៈមូលដ្ឋាន : លក្ខន្តិកៈ និងល័ក្ខខ័ណ្ឌរបស់មន្ត្រីរាជការសម្រាប់មុខងារសាធារណៈមូលដ្ឋាន ។
- ច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋាន : ទំនាក់ទំនងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន តាមរយៈហិរញ្ញវត្ថុមូលដ្ឋាន ។
- ច្បាប់ស្តីពីពន្ធដារមូលដ្ឋាន : ប្រភេទផ្សេង១ និងការប្រមូលពន្ធដារក្នុងស្រុក ។
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងមន្ត្រីរាជការ : ការបោះឆ្នោតជ្រើសតាំងមន្ត្រីរាជការមូលដ្ឋាន ( សមាជិកសភា នាយកប្រតិបត្តិ ។ល។) និង
- ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន : ក្របខ័ណ្ឌនៃសហគ្រាសសាធារណៈមូលដ្ឋាន ។

ប្រភេទបញ្ហាក់ផ្សេងទៀតដែលផ្តល់ជូនដល់កាលៈទេសៈផ្សេងទៀត នឹងត្រូវវិភាគនៅក្នុងជំពូកទី ៣ ។ ឥឡូវនេះ សូមអនុញ្ញាតអោយយើងខ្ញុំបន្តពិនិត្យរចនាសម្ព័ន្ធជាមូលដ្ឋានគ្រឹះនៃអាជ្ញាធរមូលដ្ឋានជប៉ុន ជាពិសេស នៅក្នុងព្រំដែននៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន (LAL) ។

## ២. ធាតុសំខាន់១នៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន

នៅពេល "អង្គភាពសាធារណៈមូលដ្ឋាន" ត្រូវបានពិភាក្សា ជាដំបូង ត្រូវកំណត់និយមន័យរបស់វា ។ ជាការពិតណាស់ដែលថា អង្គភាពទាំងនោះជានីតិបុគ្គល ប៉ុន្តែ វាខុសគ្នាពីសាជីវកម្មឯកជនសាមញ្ញដែលមានគោលដៅស្វែងរកប្រាក់ចំណេញ ។ អង្គភាពទាំងនោះមិនអាចទទួលបាននូវអធិបតេយ្យភាពពេញលេញជាដរាបឡើយ ហើយបើមិនអីចឹងទេ ក៏មិនមានសញ្ញាណនៃ "អង្គភាពសាធារណៈមូលដ្ឋាន" ឡើយ ។

លទ្ធិបានរៀបរាប់ធាតុផ្សំបីនៃអង្គភាពសាធារណៈមូលដ្ឋាន ដែលជានីតិបុគ្គលសាធារណៈពិសេស ដូចខាងក្រោម :

- ជាសាជីវកម្មដែលត្រូវបានបង្កើតឡើងដោយផ្អែកលើតំបន់ពិសេស នៅក្នុងដែនដីជាតិ ។
- សមាជិកភាពនៃអង្គភាពនេះត្រូវបានផ្តល់ជូនប្រជាពលរដ្ឋរបស់ខ្លួន និង
- មុខងារជាមូលដ្ឋានគ្រឹះនៃអង្គភាពនេះ គឺត្រួតពិនិត្យរដ្ឋបាលសាធារណៈនៅក្នុងតំបន់ ដើម្បីជាប្រយោជន៍សាធារណៈរបស់ប្រជាពលរដ្ឋរបស់ខ្លួន ។

ឧបម្រុងផ្សេងទៀតត្រូវបន្ថែមទៅលើធាតុផ្សំទាំងនេះ គឺថាសមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋានត្រូវផ្អែកលើសិទ្ធិនៃស្វ័យភាព ដូចដែលបានទទួលស្គាល់ដោយរដ្ឋាភិបាលកណ្តាល ដែលមានន័យជាស្ថាពរថាជាឧត្តមភាពរបស់រដ្ឋលើអាជ្ញាធរមូលដ្ឋាន (ជាការពិតដែលថា មិនមែនមានន័យថា នៅគ្រប់ពេលទាំងអស់ រដ្ឋត្រូវបានអនុញ្ញាតអោយមិនយកចិត្តទុកដាក់លើស្វ័យភាពមូលដ្ឋាននោះទេ) ។ នៅប្រទេសជប៉ុន អង្គភាពសាធារណៈមូលដ្ឋានគឺជានីតិបុគ្គល យោងតាមមាត្រា ២ នៃ

ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ។ មានប្រភេទធំៗពីរនៃអង្គភាពសាធារណៈមូលដ្ឋាន : អង្គភាពសាធារណៈមូលដ្ឋានសាមញ្ញ និងអង្គភាពសាធារណៈមូលដ្ឋានពិសេស ។ រូបភាពទី ១ សង្ខេបអំពីបំណែងចែកជាផ្នែកតូចៗនៃអាជ្ញាធរមូលដ្ឋានជប៉ុន ។

**រូបភាពទី ១ : អង្គភាពមូលដ្ឋាននៅប្រទេសជប៉ុន (ខែមេសា ឆ្នាំ២០០៧)**

| | | |
|---|---|---|
| **អង្គភាពមូលដ្ឋានសាមញ្ញ** | | |
| ខេត្ត | ៤៧ | |
| តូ (ទីក្រុងតូក្យូ) | | ១ |
| ដូ (ហុកកៃដូ) | | ១ |
| ហ្វូ (អូសាកា ក្យូតូ) | | ២ |
| កេន | | ៤៣ |
| ក្រុង | ១.៨០៤ | |
| ស៊ី (ទីក្រុង) | ៧៨២ | |
| ទីក្រុងចាត់តាំង | | ១៧ |
| ទីក្រុងស្នូល | | ៣៥ |
| ទីក្រុងពិសេស | | ៤៤ |
| ទីក្រុងសាមញ្ញ | | ៦៨៦ |
| ចូ (ឃុំ) | ៨២៧ | |
| សុន (ភូមិ) | ១៩៥ | |
| **អង្គភាពមូលដ្ឋានពិសេស** | | |
| សង្កាត់ពិសេស | ២៣ | |
| សហករណ៍របស់អាជ្ញាធរមូលដ្ឋាន | ២.៥០៩ | |
| សហព័ន្ធទូទាំងតំបន់ (ត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៦) | | ៦៣ |
| សហករណ៍ដោយផ្នែក (ត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៦) | | ១.៧៩១ |
| សហករណ៍ពេញលេញ | | ០ |
| សហករណ៍ការិយាល័យរួមគ្នា | | ០ |
| ទ្រព្យសម្បត្តិសហគមន៍ (ត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៣) | ៤.២១៩ | |
| សាជីវកម្មអភិវឌ្ឍន៍មូលដ្ឋាន | ១ | |
| មណ្ឌលពិសេសនៅក្នុងក្រុងរំលាយបញ្ចូលគ្នា (ត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥) | ៦ | |

ក. អង្គភាពមូលដ្ឋានសាមញ្ញ : ខេត្ត និងក្រុង

ប្រទេសជប៉ុនជ្រើសយករដ្ឋាភិបាលពីរកម្រិត (មាត្រា ១ ដល់មាត្រា ៣ នៃច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន) ។ កម្រិតខ្ពស់រួមមាន *តូ ដូ ហ្វូ* និង*កេន* (ទាំងអស់នេះហៅថា "ខេត្ត") កម្រិតទាបមាន *ស៊ី ចូ* និង*សុន* (ទាំងអស់នេះហៅថាក្រុង) ។ ទស្សនាទាននៃការបែងចែកជាពីរកម្រិតនេះកើតមានឡើងតាំងពីឆ្នាំ១៩២១ ទោះបីជាមានការជជែកពិភាក្សាអោយមានការកែទម្រង់ក៏ដោយ ។

១) ក្រុង

ក្រុងជាអង្គភាពសាធារណៈមូលដ្ឋានកម្រិតទីមួយ ដែលទទួលបន្ទុកលើរាល់រដ្ឋបាលមូលដ្ឋានទាំងអស់ ជាជាងភារកិច្ចដែលបានប្រគល់ជូនខេត្ត (ចំណុចនេះបង្ហាញយ៉ាងច្បាស់អំពីទស្សនៈវិជ្ជានៃច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន) ។

ការហៅខេត្តត្រូវបានបែងចែកជាបីប្រភេទ : ស៊ី (ទីក្រុង) ចូ (ឃុំ) និងសុន (ភូមិ) ។ ដើម្បីទទួលបានងារជា "ទីក្រុង" ត្រូវបំពេញតាមល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ (មាត្រា ៨ នៃច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន) :

- ប្រជាជនច្រើនជាង ៥០.០០០ នាក់ (ដែលត្រូវកាត់បន្ថយមកត្រឹម ៣០.០០០ នាក់ សម្រាប់ក្រុងដែលបានរំលាយបញ្ចូលគ្នា ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ - មាត្រា ៧ នៃច្បាប់ស្ដីពីវិធានការពិសេសសម្រាប់ការរំលាយទីក្រុងបញ្ចូលគ្នា) ។
- លំនៅដ្ឋានចំនួនសរុបជាង ៦០% មានទីតាំងនៅក្នុងតំបន់ទីក្រុងកណ្ដាល ។
- ប្រជាជនជាង ៦០% (ឬមនុស្សក្នុងបន្ទុករបស់ពួកគេ) ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម ឬសកម្មភាពទីក្រុងផ្សេងទៀត និង
- ល័ក្ខខ័ណ្ឌផ្សេងទៀតដែលបន្ថែមដោយដីកាខេត្ត ។

ដោយយោងលើហេតុផលប្រវត្តិសាស្ត្រ ដែនសមត្ថកិច្ចរបស់ក្រុងត្រូវបានកំណត់ដោយផ្អែកលើគោលការណ៍សមភាព។ ចំពោះការរៀបចំ មានលក្ខណៈពិសេសផ្អែកស្ថាប័នមួយចំនួននៃទីក្រុងមានលក្ខណៈខុសពីឃុំ ឬភូមិ ។ ឧទាហរណ៍ ចំនួនច្រើនជាងនៃសមាជិកក្រុមប្រឹក្សា និងការបង្កើតការិយាល័យសុខុមាលភាពសង្គម ដែលចំណុចនីមួយៗឆ្លុះបញ្ចាំងអំពីចរិតលក្ខណៈនគរូបនីយកម្មនៃទីក្រុង ។

ការប្រមូលផ្ដុំនៃចំនួនប្រជាជនដ៏ច្រើននៅក្នុងតំបន់ទីក្រុងតម្រូវអោយមានវិធានការ ពិសេសដើម្បីផ្ដល់អោយទីក្រុងដែលមានទំហំជាក់លាក់មួយចំនួននូវអំណាចដែលជាធម្មតាត្រូវបានបម្រុងទុកសម្រាប់ខេត្ត ។ ដូចនេះ ប្រព័ន្ធទីក្រុងពិសេសដែលមានស្រាប់នៅប្រទេសជប៉ុន មានសមាសភាពដូចខាងក្រោម :

- "ទីក្រុងចាត់តាំង" *(ស៊ីតៃ-តូស៊ី)* : ទីក្រុងដែលមានប្រជាជនច្រើនជាង ៥០០.០០០ នាក់ ដែលចាត់តាំងដោយលិខិតបង្គាប់ការរបស់គណៈរដ្ឋមន្ត្រី ត្រូវបានហៅថាទីក្រុងចាត់តាំង ហើយដែនសមត្ថកិច្ចជាច្រើនដែលជាធម្មតាត្រូវប្រគល់ជូនខេត្តត្រូវបានអនុញ្ញាតិទាំងនៅកម្រិតរៀបចំ និងកម្រិតមុខងារ (មាត្រា២៥២-១៩ នៃច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន) ។ បច្ចុប្បន្ននេះ ទីក្រុងចំនួន ១៧ ត្រូវបានចាត់តាំងជាទីក្រុងប្រភេទនេះ ។

- "ទីក្រុងស្នូល" *(ជូកាគុ-ស៊ី)* : បង្កើតឡើងនៅឆ្នាំ១៩៩៤ ការចាត់ជាប្រភេទនេះមានគោលដៅអនុញ្ញាតអោយទីក្រុងតូចជាង "ទីក្រុងចាត់តាំង" មានទំនួលខុសត្រូវខេត្តតិចជាង (មាត្រា២៥២-២២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ (លក្ខណៈវិនិច្ឆ័យសម្រាប់ចាត់តាំងជា "ទីក្រុងស្នូល" គឺទីក្រុងដែលមានប្រជាជនតិចជាង ៥០០.០០០ នាក់ (មាត្រា២៥២-២៣ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ទីក្រុងចំនួន ៣៥ ត្រូវបានចាត់តាំងថាជាទីក្រុងប្រភេទនេះ) ។
- "ទីក្រុងពិសេស" *(តូគូរ៉ៃ-ស៊ី)* : បង្កើតឡើងនៅឆ្នាំ២០០០ ត្រូវបានចាត់ទុកជា "ទីក្រុងពិសេស" គឺទីក្រុងទាំងឡាយណាដែលតូចជាង "ទីក្រុងស្នូល" នឹងត្រូវបានអនុញ្ញាតអោយមានទំនួលខុសត្រូវខេត្តមួយចំនួនក្នុងកម្រិតតិចតួចជាង ។ លក្ខណៈវិនិច្ឆ័យសម្រាប់ចាត់តាំងជាទីក្រុងពិសេស គឺទីក្រុងដែលមានប្រជាជនច្រើនជាង ២០០.០០០ នាក់ (មាត្រា២៥២-២៦-៣ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ការចាត់ប្រភេទនេះបានចាប់ផ្តើមកាលពីចុងឆ្នាំ២០០០ ។ គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ទីក្រុងចំនួន ៤៤ ត្រូវបានចាត់តាំងថាជាទីក្រុងប្រភេទនេះ ។

២) ខេត្ត

ខេត្តគឺជាអង្គភាពសាធារណៈមូលដ្ឋានកម្រិតខ្ពស់ដែលរួមមានក្រុង។ ទោះបីជាមានឈ្មោះខុសគ្នាពីមួយទៅមួយ (*តូ* (សម្រាប់តែទីក្រុងតូក្យូប៉ុណ្ណោះ) *ដូ* (សម្រាប់តែទីក្រុងហុកកៃដូ) *ហ្វូ* (អូសាកា និងក្យូតូ) និង *កេន* (សម្រាប់ ៤៣ ខេត្តទៀតដែលនៅសល់)) (សូមមើលរូបភាពទី ១) ភាពខុសគ្នានេះគឺដោយសារតែមូលហេតុប្រវត្តិសាស្ត្រប៉ុណ្ណោះ និងមិនបានចង្អុលបង្ហាញអំពីភាពខុសគ្នាពិសេសអ្វីនោះទេ (លើកលែងតែប្រព័ន្ធសង្កាត់ពិសេសនៅទីក្រុងតូក្យូប៉ុណ្ណោះ) ។

ទោះបីជាខេត្តមានកម្រិតខ្ពស់ជាងក្រុងដែលជាសមាសភាពខេត្តក៏ដោយ ក៏ខេត្តមិនអាចអនុវត្តអំណាចឋានានុក្រម ឬអំណាចផ្តាច់ការលើក្រុងបានដែរ ។ ខេត្ត និងក្រុងមានភារកិច្ចផ្សេងពីគ្នា ប៉ុន្តែកម្រិតទាំងពីរត្រូវធ្វើកិច្ចសហប្រតិបត្តិការដោយស្មើភាពគ្នាក្នុងឋានៈជាអង្គភាពមូលដ្ឋាន ។ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានបានបែងចែកភារកិច្ចរបស់ខេត្តជាបីប្រភេទ (មាត្រា ២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) :

- ភារកិច្ចដែលគ្របដណ្តប់លើផ្ទៃកដ៏ទូលំទូលាយជាងដែនដីក្រុង ។
- ភារកិច្ចដែលតម្រូវអោយមានកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួលរវាងក្រុងជាច្រើន ។
- ភារកិច្ចដែលហួសពីសមត្ថកិច្ចរបស់ក្រុង សម្រាប់ការអនុវត្តអោយមានប្រសិទ្ធភាព ។

ខ. អង្គភាពមូលដ្ឋានពិសេស

ទោះបីជាសេវាសាធារណៈមូលដ្ឋានត្រូវរ៉ាប់រងដោយខេត្ត ឬក្រុងក៏ដោយក៏តថភាពនៃស្ថានភាពសហគមន៍ ជូនកាលធ្វើអោយមានការលំបាកដល់ស្វ័យគ្រប់គ្រងដោយការអនុវត្តធម្មតានៃកម្រិតពីរថ្នាក់ឯកសណ្ឋាន ។ ហេតុនេះហើយទើបមាន "អង្គភាពសាធារណៈមូលដ្ឋានពិសេស" ។ អង្គភាពទាំងនេះត្រូវបានបង្កើតឡើងសម្រាប់គោលបំណងពិសេសមួយ ឬគោលបំណងផ្សេងទៀត ដើម្បីអោយការរៀបចំ និងមុខងាររបស់វាមានកម្រិត បើប្រៀបធៀបទៅនឹងអង្គភាពមូលដ្ឋានសាមញ្ញ ។

**រូបភាពទី ២ : ប្រជាជនខេត្ត និងផ្ទៃដី (គិតមកត្រឹមខែមេសា ឆ្នាំ២០០៦)**

| ខេត្ត | ប្រជាជន | ផ្ទៃដី (គម²) | រាជធានី/ទីក្រុងចាត់តាំង |
|---|---|---|---|
| តំបន់ហុកកៃដូ | | | |
| ១. ហុកកៃដូ | ៥.៦២៩.៩៧០ | ៨៣.៤៥៥,៧៣ | ⊙ សាប៉ូរ៉ូ |
| តំបន់តូហូគូ | | | |
| ២. អៅម៉ូរី | ១.៤៦០.១៨៤ | ៩.៦០៦,៨៨ | អៅម៉ូរី |
| ៣. អ៊ីវ៉ាតេ | ១.៣៣៨.១៦៤ | ១៥.២៧៨,៧១ | ម៉ូរីយ៉ូកា |
| ៤. មីយ៉ាហ្គី | ២.៣៤៤.៥៦៩ | ៧.២៨៥,៦០ | ⊙ សេនដៃ |
| ៥. អាគីតា | ១.១៥៦.៣៥៦ | ១១.៦១២,២២ | អាគីតា |
| ៦. យ៉ាម៉ាហ្គាតា | ១.២១២.១៦៣ | ៩.៣២៣,៣៩ | យ៉ាម៉ាហ្គាតា |
| ៧. ហ្វូគូស៊ីម៉ា | ២.១០០.៨៥១ | ១៣.៧៨២,៧៥ | ហ្វូគូស៊ីម៉ា |
| តំបន់កាន់តូ | | | |
| ៨. អ៊ីបារ៉ាគី | ២.៩៨៨.៥៣៣ | ៦.០៩៥,៦៨ | មីតូ |
| ៩. តូស៊ីជី | ២.០០៩.៤៩៨ | ៦.៤០៨,២៨ | អ៊ុតស៊ុយណូមីយ៉ា |
| ១០. ហ្គុនម៉ា | ២.០២០.០៣៧ | ៦.៣៦៣,១៦ | ម៉ាអេបាស៊ី |
| ១១. សៃតាម៉ា | ៧.០១៩.៩១៩ | ៣.៧៩៧,២៥ | ⊙ សៃតាម៉ា |
| ១២. ស៊ីបា | ៦.០៣៥.៦៥៨ | ៥.១៥៦,៥៨ | ⊙ ស៊ីបា |
| ១៣. តូក្យូ | ១២.២៧៣.៣៧៦ | ២.១៨៧,១១ | |
| ១៤. កាណាហ្គាវ៉ា | ៨.៦៩៣.៣៧៣ | ២.៤១៥,៨៤ | ⊙ យ៉ូកូហាម៉ា<br>• កាវ៉ាសាគី |
| តំបន់ហូគូរិគុយ | | | |
| ១៥. នីអ៊ីហ្គាតា | ២.៤៣៨.៤៨២ | ១២.៥៨៣,៣២ | នីអ៊ីហ្គាតា |
| ១៦. តូយ៉ាម៉ា | ១.១១៤.៧១៤ | ៤.២៤៧,៣៩ | តូយ៉ាម៉ា |
| ១៧. អ៊ីស៊ីកាវ៉ា | ១.១៧១.១០៦ | ៤.១៨៥,៤៦ | កាណាសាវ៉ា |
| ១៨. ហ្វូគុយអ៊ី | ៨២១.០៧៣ | ៤.១៨៩,២៥ | ហ្វូគុយអ៊ី |
| តំបន់ជូប៊ុយ-តូកៃ | | | |
| ១៩. យ៉ាម៉ាណាស៊ី | ៨៧៩.២៣៩ | ៤.៤៦៥,៣៧ | កូហ្វុយ |
| ២០. ណាហ្គាណូ | ២.១៩០.៨៧៤ | ១៣.៥៦២,២៣ | ណាហ្គាណូ |
| ២១. ជីហ្វុយ | ២.១០៥.០១១ | ១០.៦២១,១៧ | ជីហ្វុយ |
| ២២. ស៊ីស៊ុយអូកា | ៣.៧៧៥.៩០៣ | ៧.៧៨០,០៣ | ⊙ ស៊ីស៊ុយអូកា<br>• ហាម៉ាម៉ាត់ស៊ុយ |

| | | | |
|---|---|---|---|
| ២៣. អៃជី | ៧.១០៦.៥៨៥ | ៥.១៦៤.០២ | ⊙ ណាហ្គោយ៉ា |
| ២៤. មីអេ | ១.៨៥៧.៤៥៦ | ៥.៧៧៦.៦៨ | ត្សុយ |

| ខេត្ត | ប្រជាជន | ផ្ទៃដី (គម²) | រាជធានី/ទីក្រុងចាត់តាំង |
|---|---|---|---|
| តំបន់គិនគី | | | |
| ២៥. ស៊ីហ្គា | ១.៣៦៥.៣៩៣ | ៤.០១៧.៣៦ | អូតស៊ុយ |
| ២៦. ក្យូតូ | ២.៥៦៦.៤២០ | ៤.៦១៣.០០ | ⊙ ក្យូតូ |
| ២៧. អូសាកា | ៨.៦៦៣.៧១៩ | ១.៨៥៤.៣១ | ⊙ អូសាកា<br>• សាកៃ |
| ២៨. ហ៊ីយ៉ូហ្គោ | ៥.៥៧៦.៧៨៤ | ៨.៣៩៤.៩២ | ⊙ កូបេ |
| ២៩. ណារ៉ា | ១.៤៣០.៣៦៦ | ៣.៦៩១.០៩ | ណារ៉ា |
| ៣០. វ៉ាកាយ៉ាម៉ា | ១.០៦១.៥៥៥ | ៤.៧២៦.០៨ | វ៉ាកាយ៉ាម៉ា អាគីតា |
| តំបន់ជូហ្គោគុយ | | | |
| ៣១. តូតូរី | ៦១០.៤៣៤ | ៣.៥០៧.២៥ | តូតូរី |
| ៣២. ស៊ីម៉ាណេ | ៧៤៤.៦៧៧ | ៦.៧០៧.៥៦ | ម៉ាល់ស៊ុយអេ |
| ៣៣. អូកាយ៉ាម៉ា | ១.៩៥៤.៩១៩ | ៧.១១២.៧៣ | អូកាយ៉ាម៉ា |
| ៣៤. ហ៊ីរ៉ូស៊ីម៉ា | ២.៨៧០.៩០៧ | ៨.៤៧៧.៩២ | ⊙ ហ៊ីរ៉ូស៊ីម៉ា |
| ៣៥. យ៉ាម៉ាហ្គូជី | ១.៤៩៩.០០២ | ៦.១១១.៩១ | យ៉ាម៉ាហ្គូជី |
| តំបន់ស៊ីកូគុយ | | | |
| ៣៦. តូគូស៊ីម៉ា | ៨១៦.៣២១ | ៤.១៤៥.៣៣ | តូគូស៊ីម៉ា |
| ៣៧. កាហ្គាវ៉ា | ១.០២៦.០៨៨ | ១.៨៧៦.៤១ | តាកាម៉ាត់ស៊ុយ |
| ៣៨. អេហ៊ីម៉េ | ១.៤៨៦.៩៤៦ | ៥.៦៧៧.១២ | ម៉ាត់ស៊ុយយ៉ាម៉ា |
| ៣៩. កូជី | ៧៩៩.១២១ | ៧.១០៥.០១ | កូជី |
| តំបន់ក្យូស៊ុយ | | | |
| ៤០. ហ្វុយគូអូកា | ៥.០២៨.០២៦ | ៤.៩៧៦.១២ | ⊙ ហ្វុយគូអូកា<br>• គីតាក្យូស៊ុយ |
| ៤១. សាហ្គា | ៨៧២.៣០២ | ២.៤៣៩.៥៨ | សាហ្គា |
| ៤២. ណាហ្គាសាគី | ១.៤៩៤.៨៧៩ | ៤.០៩៤.៧៦ | ណាហ្គាសាគី |
| ៤៣. គូម៉ាម៉ូតុ | ១.៨៥៨.៩២២ | ៧.៤០៤.៨៣ | គូម៉ាម៉ូតុ |
| ៤៤. អូអ៊ីតា | ១.២២១.៧៤១ | ៦.៣៣៩.៣២ | អូអ៊ីតា |
| ៤៥. មីយ៉ាសាគី | ១.១៧២.៤០២ | ៧.៧៣៤.៧៧ | មីយ៉ាសាគី |

| | | | |
|---|---|---|---|
| ៤៦. កាហ្គោស៊ីម៉ា | ១.៧៩៩.៦៥០ | ៩.១៨៧,៦៩ | កាហ្គោស៊ីម៉ា |
| ៤៧. អូគីណាវ៉ា | ១.៣៨១.៨២០ | ២.២៧៤,៥៩ | ណាហា |
| សរុប | ១២៧.៧៥៦.៨១៥ | ៣៧៧.៨៥៣,៧៦ | |

○ រដ្ឋធានីខេត្ត

⊙ ទីក្រុងចាត់តាំង

• រដ្ឋធានីដែលមានសិទ្ធិដូចជាទីក្រុងចាត់តាំង

តួលេខនៅក្នុងរង្វង់ក្រចកបង្ហាញអំពីផ្ទៃដីសរុបរបស់ប្រទេសជប៉ុន រួមទាំងផ្ទៃដីឧនាភិវឌ្ឍ ។

១) សង្កាត់ពិសេស

ដោយសារភាពចាំបាច់ ទីក្រុងតូក្យូ (ដែលជារាជធានីនៃប្រទេសជប៉ុនដែលមានប្រជាជនជាង ១០ លាននាក់) ២៣ សង្កាត់ពិសេស *(តូគូបេតស៊ុយ-គូ)* នៅក្នុងតំបន់កណ្ដាល (មាត្រា ២៨១ នៃច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន) ។ ដោយមាន "តំបន់រដ្ឋបាល" ច្រើនជាងអាជ្ញាធរមូលដ្ឋាន ដូចជាទីក្រុងសាមញ្ញដែរ បច្ចុប្បន្ននេះ សង្កាត់ពិសេសទាំងនេះបានផ្ដល់អំណាចអោយមានចៅសង្កាត់ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ ដែនសមត្ថកិច្ចមួយចំនួនស្ថិតនៅក្នុងកណ្ដាប់ដៃរបស់រដ្ឋាភិបាលក្រុងតូក្យូ ដូចជា ការបង្ហូរទឹកស្អុយ និងការប្រមូលសំរាម ។

អាស្រ័យហេតុនេះ តាមរយៈវិសោធនកម្មច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាននៅក្នុងខែមេសា ឆ្នាំ១៩៩៨ កំណែទម្រង់ស្ថាប័នជាច្រើនត្រូវបានធ្វើឡើងក្នុងសង្កាត់ពិសេស ។ ជាដំបូង សេវាសាធារណៈជាច្រើន ដែលត្រូវផ្ដល់នៅកម្រិតនៅជិតនឹងប្រជាពលរដ្ឋ ប៉ុន្តែ បច្ចុប្បន្ន ត្រូវបានរក្សាទុកក្នុងសង្កាត់ពិសេស ដូចជា ការប្រមូលសំរាម ត្រូវផ្ទេរពីរដ្ឋាភិបាលក្រុងតូក្យូទៅអោយសង្កាត់ពិសេស ។ ខពិសេសមួយចំនួននៃច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន ដែលអនុវត្តសម្រាប់តែសង្កាត់ពិសេស ត្រូវបានលុបចោល ឬពិនិត្យមើលឡើងវិញ ។ លើសពីនេះទៅទៀត សង្កាត់ពិសេសត្រូវបានផ្ដល់ឋានៈស្របច្បាប់យ៉ាងជាក់លាក់ថាជាអង្គភាពសាធារណៈមូលដ្ឋាន "គ្រឹះ" ដូចជាក្រុងដែរ ។ កំណែទម្រង់ទាំងនេះត្រូវបានអនុវត្តនៅខែមេសា ឆ្នាំ២០០០ ។

ផ្ទុយទៅវិញ វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា "សង្កាត់" *(គូ)* ដែលមានស្រាប់នៅក្នុងទីក្រុងចាត់តាំង គ្រាន់តែជាតំបន់រដ្ឋបាលធម្មតាប៉ុណ្ណោះ ។

២) សហករណ៍របស់អាជ្ញាធរមូលដ្ឋាន

ភារកិច្ចរបស់រដ្ឋាភិបាលមូលដ្ឋានកាន់តែមានលក្ខណៈស្មុគស្មាញខ្លាំងឡើង ហើយជួនកាល រដ្ឋាភិបាលមូលដ្ឋានអាចធ្វើសកម្មភាពហួសពីសមត្ថភាពជាក្រុងតែមួយ ក្នុងការគ្រប់គ្រងវិស័យមួយចំនួននៃភារកិច្ចទាំងនេះ ។ ដោយសារមូលហេតុនេះហើយទើបខេត្ត និងក្រុងអាចបង្កើតសហករណ៍របស់អាជ្ញាធរមូលដ្ឋាន *(គូមីអៃ)* ដើម្បីបំពេញភារកិច្ចរបស់

ខ្លួនអោយមានប្រសិទ្ធភាព ។ យោងតាមមុខងាររបស់ខ្លួន ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានអនុញ្ញាតអោយមានសហករណ៍បួនប្រភេទខុសគ្នា ( មាត្រា ២៨៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) :

- សហករណ៍ពេញលេញ *(ហ៊្សេនប៊ូ-ជីមូ-គូមីអៃ)* : អាជ្ញាធរជាសមាជិកផ្ទេរកិច្ចការទាំងអស់របស់ខ្លួនទៅអោយសហករណ៍នេះ (បច្ចុប្បន្ននេះ សហករណ៍ប្រភេទនេះមិនមានទៀតទេ) ។
- សហករណ៍មុខងាររួម *(យ៉ាគូបា-ជីមូ-គូមីអៃ)* : អាជ្ញាធរជាសមាជិកប្រមូលផ្តុំមុខងារប្រតិបត្តិរបស់ខ្លួន (បច្ចុប្បន្ននេះ សហករណ៍ប្រភេទនេះមិនមានទៀតទេ) ។
- សហករណ៍ដោយផ្នែក *(អ៊ីជីប៊ូ-ជីមូ-គូមីអៃ)* : មានប្រជាប្រិយជាងគេក្នុងចំណោមសហករណ៍ទាំងបួនប្រភេទនេះផ្ទេរដែនសេវាជាក់លាក់មួយចំនួនទៅអោយសហករណ៍ ដូចជា ការប្រមូលសំរាម ការការពារអគ្គិភ័យ និងការអប់រំជាកាតព្វកិច្ច និង
- "សហភាពថ្នាក់តំបន់" *(កូអ៊ីគី-រ៉េនហ្គោ)* : ទើបតែបង្កើតថ្មី១នៅក្នុងឆ្នាំ១៩៩៤ សហករណ៍នេះមិនមែនទទួលបន្ទុកតែលើអ្វីដែលប្រគល់អោយវានៅក្នុង"ផែនការថ្នាក់តំបន់" ដោយអាជ្ញាធរសមាជិកប៉ុណ្ណោះទេ ថែមទាំងបំពេញភារកិច្ចដែលផ្ទេរអោយដោយរដ្ឋាភិបាលកណ្តាល
 ឬខេត្តដែលមិនចូលរួមក្នុងសហករណ៍ទៀតផង (មាត្រា ២៩១-២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ សហភាពថ្នាក់តំបន់ក៏មានចរិតលក្ខណៈនៃ ទំនាក់ទំនងកាន់តែរឹងមាំ និងចូលរួមជាមួយប្រជាពលរដ្ឋ ពាក់ព័ន្ធទៅនឹងល័ក្ខខ័ណ្ឌនៃគំនិតផ្តួចផ្តើមបង្កើតសហភាព ( មាត្រា ២៩១-៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

៣) អង្គភាពពិសេសផ្សេងទៀត

ទ្រព្យសម្បត្តិសហគមន៍ប្រហែលជាកើតមានឡើង តាំងពីសម័យសក្តិភូមិមកម្ល៉េះ ប៉ុន្តែ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានបានចែងអំពីវត្តមាននៃ "សង្កាត់ទ្រព្យសម្បត្តិ" ដែលកាន់កាប់ដោយខេត្ត ( មាត្រា ២៩៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ "ទ្រព្យសម្បត្តិ" អាចមានដូចជា ព្រៃឈើ វាលភក់ ប្រឡាយស្រោចស្រព កន្លែងស្ពង់កម្តៅ វាលបញ្ចុះសព ។ល។

ប្រភេទមួយទៀតនៃអង្គភាពពិសេសគឺសាជីវកម្មអភិវឌ្ឍមូលដ្ឋាន ដែលបង្កើតឡើងរួមគ្នាដោយអាជ្ញាធរមូលដ្ឋានជាច្រើនដើម្បីអភិវឌ្ឍវិស័យសេវាសាធារណៈជាក់លាក់ ។ បច្ចុប្បន្ននេះ មិនសូវមានការប្រើប្រាស់ស្ថាប័នប្រភេទនេះឡើយ ( មាត្រា ២៩៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

លើសពីនេះទៅទៀត តាមរយៈវិសោធនកម្មច្បាប់ស្តីពីវិធានការពិសេសសម្រាប់រំលាយក្រុងបញ្ចូលគ្នា ក្នុងឆ្នាំ ២០០៤ មណ្ឌលពិសេសមួយនៅក្នុងក្រុងដែលត្រូវបានរំលាយបញ្ចូលគ្នា (ហ្គាប៉ៃ-តូគូរ៉េ-គូ) ត្រូវបានបង្កើតឡើងដើម្បីជំរុញការរំលាយក្រុងបញ្ចូលគ្នា ។ មណ្ឌលនេះអាចត្រូវបានបង្កើតឡើងដោយផ្អែកលើផ្ទៃដីនៃក្រុងកំពុងរំលាយមួយ ឬច្រើន សម្រាប់រយៈពេលប្រាំឆ្នាំ ឬតិចជាងប្រាំឆ្នាំ តាមរយៈការពិគ្រោះយោបល់គ្នាទៅវិញទៅមកក្នុងចំណោមក្រុងរំលាយទាំងអស់ ។ មណ្ឌលនេះអាចទទួលបន្ទុកកិច្ចការដែលផ្តល់ដោយកិច្ចព្រមព្រៀងដែលធ្វើឡើងរវាងក្រុង សម្រាប់រយៈពេលកំណត់មួយ (តិចជាងប្រាំឆ្នាំ) បន្ទាប់ពីការរំលាយទីក្រុងបញ្ចូលគ្នា ។

## ៣. អង្គការរបស់រដ្ឋាភិបាលមូលដ្ឋាន

កំណែទម្រង់សំខាន់ជាងគេនៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន នៅក្រោយសង្គ្រាមលោកលើកទី ២ គឺដូចដែលយើងបានឃើញរួចមកហើយ ការបង្កើត "របបប្រធាននិយម" នៅក្នុងអភិបាលកិច្ចមូលដ្ឋាន ។ តុល្យភាពនៃអំណាចខាងស្ថាប័នរវាងសមាជិកក្រុមប្រឹក្សាដែលបានជ្រើសតាំង និងនាយកប្រតិបត្តិមានភាពថ្មីស្រឡាង មិនមែនតែចំពោះប្រជាជនជប៉ុនប៉ុណ្ណោះទេ ប៉ុន្តែគឺចំពោះប្រទេសដទៃទៀតស្ទើរតែទាំងអស់នៅក្នុងពិភពលោកផងដែរ ជាពិសេស នៅពេលយើងពិនិត្យមើលការអនុវត្តឯកសណ្ឋានទៅលើខេត្ត និងក្រុង ។

ទិដ្ឋភាពគ្មានពីរមួយទៀតនៃរចនាសម្ព័ន្ធ គឺវត្តមាននៃក្រុមប្រឹក្សារដ្ឋបាល ដែលឯករាជ្យពីនាយកប្រតិបត្តិ។ ដោយយកតាមទស្សនាទានអាមេរិក ក្រុមប្រឹក្សានេះមានគោលដៅបង្ការកុំអោយមានការប្រមូលផ្តុំអំណាចច្រើនពេកទៅអោយអភិបាលខេត្ត ឬអភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន និងដើម្បីសម្រេចបានការអនុវត្តផ្នែករដ្ឋបាលដោយត្រឹមត្រូវ និងយុត្តិធម៌ ។

ក. អង្គនីតិបញ្ញត្តិ : ក្រុមប្រឹក្សាអាជ្ញាធរមូលដ្ឋាន

១) ការរៀបចំ

i) សមាជិកក្រុមប្រឹក្សា

ក្រុមប្រឹក្សាមានសមាជិកក្រុមប្រឹក្សាដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋ ។ ចំនួនអតិបរមានៃសមាជិកក្រុមប្រឹក្សាអាស្រ័យលើចំនួនប្រជាជននៃអាជ្ញាធរមូលដ្ឋាន ។ ចំពោះខេត្ត ចំនួនសមាជិកក្រុមប្រឹក្សាគឺមានពី ៤០ ទៅ ១២០ (ទីក្រុងតូក្យូជាករណីលើកលែង មានចំនួន ១៣០) (មាត្រា ៩០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) : ទីក្រុងមានចំនួនពី២៦ ទៅ ៩៦ និងឃុំ និងភូមិមានចំនួនពី ១២ ទៅ ២៦ (មាត្រា ៩១ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ អាជ្ញាធរមូលដ្ឋានជាអ្នកកំណត់ចំនួន តាមរយៈដីកា ដោយគោរពតាមចំនួនអតិបរមានេះ ។

អាណត្តិសម្រាប់សមាជិកក្រុមប្រឹក្សាត្រូវបានកំណត់ចំនួន ៤ ឆ្នាំ (មាត្រា ៩៣ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ក្នុងរយៈពេលនៃអាណត្តិនេះ សមាជិកក្រុមប្រឹក្សាត្រូវបានហាមឃាត់មិនអោយធ្វើជាសមាជិករដ្ឋសភា ក្នុងពេលតែមួយ (សភាតំណាងរាស្ត្រ ឬសភាក្រុមប្រឹក្សា) ឬជាសមាជិកក្រុមប្រឹក្សានៅក្នុងអាជ្ញាធរមូលដ្ឋានណាមួយផ្សេងទៀត ។ លើសពីនេះទៀត សមាជិកក្រុមប្រឹក្សាមិនអាចកាន់មុខដំណែងក្នុងមុខងារសាធារណៈ នៅក្នុងរដ្ឋបាលមូលដ្ឋានណាមួយបានឡើយ (មាត្រា ៩២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ការដាក់កំហិតទាំងនេះមានគោលដៅធានាអោយសមាជិកក្រុមប្រឹក្សាបំពេញភារកិច្ចប្រកបដោយសីលធម៌ និងចរិយាធម៌ ។

ការតស៊ូប្រឆាំងនឹងភាពអយុត្តិធម៌ ឬអំពើពុករលួយ ក៏ត្រូវបានស្តែងឡើងផងដែរ តាមរយៈការហាមឃាត់មិនអោយមានទំនាក់ទំនងកិច្ចសន្យារវាងសមាជិកក្រុមប្រឹក្សា និងអាជ្ញាធរមូលដ្ឋានដែលសមាជិកក្រុមប្រឹក្សារូបនោះស្ថិតនៅ ឬការតែងតាំងសមាជិកក្រុមប្រឹក្សាជាប្រធានក្រុមហ៊ុន ដែលមានទំនាក់ទំនងកិច្ចសន្យាជាមួយអាជ្ញាធរមូលដ្ឋានរបស់ខ្លួន (មាត្រា ៩២-២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ សមាជិកក្រុមប្រឹក្សាអាចត្រូវបានដកហូតពីមុខដំណែងក្រោយពីចាញ់ក្នុងការឈរឈ្មោះអោយគេបោះឆ្នោត ។

ii) សម័យប្រជុំ និងគណៈកម្មាធិការនៅក្នុងក្រុមប្រឹក្សា

ប្រសិនបើក្រុមប្រឹក្សាត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ធ្វើសេចក្តីសម្រេច ក្របខ័ណ្ឌនៃសកម្មភាពត្រូវតែមានភាពច្បាស់លាស់ ។

ក្រុមប្រឹក្សាបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធាន ក្នុងចំណោមសមាជិករបស់ខ្លួន (មាត្រា ១០៣ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ប្រធានក្រុមប្រឹក្សាតំណាងអោយសភានៅក្នុងសកម្មភាពខាងក្រៅរបស់សភា និងធ្វើជាអធិបតីភាពនៅក្នុងសម័យប្រជុំពេញអង្គ ដោយរក្សាសណ្តាប់ធ្នាប់ និងគ្រប់គ្រងដំណើរការ (មាត្រា ១០៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទាំងអស់ត្រូវធ្វើឡើង តាមរយៈការពិភាក្សានៅក្នុងសម័យប្រជុំពេញអង្គ ហើយប្រធានបទនៃការពិភាក្សានៅក្នុងសភារបស់អាជ្ញាធរមូលដ្ឋាននៅតែបន្តកើនឡើង ហើយកាន់តែមានលក្ខណៈស្មុគស្មាញឡើងផងដែរ ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាត្រូវបានរៀបចំដោយមានការរួមផ្សំនៃសម័យប្រជុំពេញអង្គ និងគណៈកម្មាធិការជាច្រើន ។

ខាងក្រោមនេះ មានគណៈកម្មាធិការបីប្រភេទ គឺគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការដឹកនាំ និងគណៈ-កម្មាធិការពិសេស ។

- គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើង ដើម្បីពិភាក្សាលើវិស័យរដ្ឋបាលនីមួយៗ (ឧទាហរណ៍ គណៈកម្មាធិការអចិន្ត្រៃយ៍កិច្ចការទូទៅ ឬគណៈកម្មាធិការអចិន្ត្រៃយ៍សាធារណការ) (មាត្រា ១០៩ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ចំនួនគណៈកម្មាធិការអចិន្ត្រៃយ៍មានកំណត់ ដោយយោងទៅតាមចំនួនប្រជាជននៃអាជ្ញាធរមូលដ្ឋាន ។ គណៈកម្មាធិការអចិន្ត្រៃយ៍ធ្វើការស៊ើបអង្កេត និងពិនិត្យសេចក្តីព្រាងច្បាប់ និងពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន ។
- គណៈកម្មាធិការដឹកនាំជាអ្នកគ្រប់គ្រងសម័យប្រជុំ ឧទាហរណ៍ បទបញ្ជាស្តីពីការប្រជុំក្រុមប្រឹក្សា ការទទួលយកសេចក្តីព្រាងច្បាប់ ការស៊ើបអង្កេតលើពាក្យបណ្តឹង (មាត្រា ១១០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។
- គណៈកម្មាធិការពិសេសត្រូវបានបង្កើតឡើង ដើម្បីពិភាក្សាលើបញ្ហានានាដែលពាក់ព័ន្ធនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើន និងលើប្រធានបទសំខាន់ៗជាក់លាក់មួយចំនួន (មាត្រា ១១០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

២) ដែនសមត្ថកិច្ច

ទំនួលខុសត្រូវសំខាន់ជាងគេបំផុតរបស់ក្រុមប្រឹក្សាគឺការធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធទៅនឹងបញ្ហាសំខាន់ៗរបស់អាជ្ញាធរមូលដ្ឋាន ។

អំណាចធ្វើសេចក្តីសម្រេចនេះត្រូវបានចែងដោយច្បាប់ពាក់ព័ន្ធនឹងបញ្ហាដូចខាងក្រោម (មាត្រា ៩៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) :

- ប្រកាសអោយប្រើ កែប្រែ ឬធ្វើមោឃភាពដីកា ។ យោងតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ អាជ្ញាធរមូលដ្ឋាន អាចប្រកាសអោយប្រើដីកា (មាត្រា ១៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ដែលមានសុពលភាពដូចគ្នា ទៅនឹងច្បាប់ជាតិ តែក្នុងករណីដែលដីកាទាំងនោះត្រូវស្ថិតនៅក្រោមច្បាប់ជាតិ ។
- រៀបចំកំណត់ថវិកា ។
- អនុញ្ញាតការទូទាត់គណនី ។
- កំណត់ពន្ធ ឬប្រមូលអាករមូលដ្ឋាន បន្ទុក ឬសោហ៊ុយចំណាយផ្សេងៗ (លើកលែងតែអ្វីដែលកំណត់ដោយ បទបញ្ជាថ្នាក់ជាតិ) ។
- អនុញ្ញាតអោយចុះកិច្ចសន្យា ។
- អនុញ្ញាតអោយប្រើប្រាស់ ឬគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ (ការប្តូរទំនិញ ការវិនិយោគ កិច្ចសន្យាជួល អនុប្បទាន សហគ្រាសប្រមូលផ្តុំ ។ល។) និង
- អនុញ្ញាតការដាក់ពាក្យបណ្តឹង ឬបណ្តឹងឧទ្ធរណ៍រដ្ឋបាល ។

ដែនសមត្ថកិច្ចមួយទៀតដែលចាំបាច់ដោយខានមិនបានចំពោះក្រុមប្រឹក្សា គឺសិទ្ធិអធិការកិច្ច ដែលតាមរយៈសិទ្ធិនេះ ក្រុមប្រឹក្សាអាចធ្វើអធិការកិច្ចលើឯកសារ និងសៀវភៅនានាដែលពាក់ព័ន្ធទៅនឹងកិច្ចការរបស់អាជ្ញាធរមូលដ្ឋាន និងស្នើសុំរបាយការណ៍រដ្ឋបាល និងហិរញ្ញវត្ថុពីនាយកប្រតិបត្តិ (មាត្រា ៩៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ក្រុមប្រឹក្សាក៏មានសិទ្ធិស៊ើបអង្កេតពាក់ព័ន្ធនឹងកិច្ចការរបស់អាជ្ញាធរមូលដ្ឋានរបស់ខ្លួន ដោយតម្រូវអោយមានវត្តមាន និងការបញ្ជាក់អះអាងរបស់សាក្សី ឬការបង្ហាញអំពីកំណត់ត្រាផ្សេងៗ (មាត្រា ១០០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

៣) ដំណើរការនៅក្នុងសម័យប្រជុំ

ជាគោលការណ៍ ក្រុមប្រឹក្សាត្រូវបានតម្រូវអោយមានសម័យប្រជុំជាទៀងទាត់ ដែលត្រូវកោះ នៅពេលវេលាដូចមានកំណត់នៅក្នុងដីកា ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើចាំបាច់ សម័យប្រជុំពិសេសអាចត្រូវបានកោះឡើងនៅពេលត្រូវការ ដោយមានរបៀបវារៈជាក់លាក់ (មាត្រា ១០២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

ជាគោលការណ៍ ការកោះប្រជុំគឺជាសិទ្ធិរបស់អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន ទោះបីជាពួកគេត្រូវបានតម្រូវអោយកោះប្រជុំពិសេស ប្រសិនបើមានសំណូមពរពីសមាជិកក្រុមប្រឹក្សាយ៉ាងហោចណាស់មួយភាគបួននៃសមាជិកសរុប (មាត្រា ១០១ នៃច្បាប់ ស្តីពីស្វ័យភាពមូលដ្ឋាន) ។

ការដាក់សេចក្តីព្រាងច្បាប់គឺសិទ្ធិរបស់អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន និងសមាជិកក្រុមប្រឹក្សា (ដោយមានការព្រមព្រៀងពីសមាជិកក្រុមប្រឹក្សាយ៉ាងហោចណាស់មួយភាគដប់ពីរនៃសមាជិកសរុប) (មាត្រា ១១២ និងមាត្រា ១៤៩ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាមួយចំនួនត្រូវបានចាត់ទុកថាមានបុព្វសិទ្ធិរបស់អង្គនីតិបញ្ញត្តិ ឬនាយកប្រតិបត្តិ ដែលជាទូទៅអាស្រ័យទៅតាមប្រភេទនៃប្រធានបទ ។ ឧទាហរណ៍ ការដាក់ផែនការថវិកាដើមត្រូវបានបម្រុងទុកសម្រាប់អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន (មាត្រា ៩៧

នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ម្យ៉ាងវិញទៀត ការអនុវត្តបានបង្ហាញថា ការដាក់សំណើបង្កើតលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្ថិតនៅក្រោមអំណាចផ្តាច់មុខរបស់សមាជិកក្រុមប្រឹក្សា ។

ខ. អង្គនីតិប្រតិបត្តិ : អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន និងក្រុមប្រឹក្សារដ្ឋបាល

អង្គនីតិប្រតិបត្តិរបស់អាជ្ញាធរមូលដ្ឋានរួមមាន នាយកប្រតិបត្តិ ដែលជាអភិបាលខេត្ត (ក្នុងករណីខេត្ត) និងអភិបាលក្រុង (ក្នុងករណីក្រុង) និងក្រុមប្រឹក្សារដ្ឋបាលសម្រាប់វិស័យជាក់លាក់នីមួយៗ ។ ជាការពិតណាស់ដែលថា ពួកគេមានក្រុមមន្ត្រីរាជការសម្រាប់បំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃ ។

១) នាយកប្រតិបត្តិ : អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន

លក្ខណៈពិសេសមួយរបស់នាយកប្រតិបត្តិនៅក្នុងអាជ្ញាធរមូលដ្ឋានជប៉ុន គឺថា ពួកគេត្រូវបានជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ ដាច់ដោយឡែកពីការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សា ។ នីតិវិធីផ្តល់អោយអភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាននូវធម្មានុរូបភាពដែលឯករាជ្យពីក្រុមប្រឹក្សា ។

អាណត្តិរបស់ នាយកប្រតិបត្តិត្រូវបានកំណត់ចំនួនបួនឆ្នាំ (មាត្រា ១៤០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ដែលស្មើគ្នាទៅនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សា ។ នាយកប្រតិបត្តិរូបនោះអាចត្រូវបានដកហូតពីមុខដំណែង ដោយសារការបាត់បង់ភាពអាចឈរឈ្មោះអោយគេបោះឆ្នោតដែលត្រូវការ ដែលជាដំណោះស្រាយនៃការមិនទុកចិត្ត និងការព្រមានដោយប្រជាពលរដ្ឋ ។ ចំពោះការប្រមូលផ្តុំច្រើននូវមុខដំណែងសាធារណៈ ឬទំនាក់ទំនងកិច្ចសន្យាជាមួយអាជ្ញាធរមូលដ្ឋានរបស់ខ្លួន ការហាមឃាត់ដូចគ្នាត្រូវបានអនុវត្តចំពោះនាយកប្រតិបត្តិ (មាត្រា ១៤១ និងមាត្រា ១៤២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋានតំណាងអាជ្ញាធរមូលដ្ឋានរបស់ខ្លួន និងរៀបចំរាល់កិច្ចការទាំងអស់របស់អាជ្ញាធរ ដើម្បីធានាអោយបាននូវរដ្ឋបាលពេញលេញ និងមានស្ថិរភាព (មាត្រា ១៤៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ច្បាស់ជាងនេះទៅទៀត តួនាទីចម្បងរបស់ នាយកប្រតិបត្តិមានដូចខាងក្រោម (មាត្រា ១៤៨ និងមាត្រា ១៤៩ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) :

- ប្រកាសអោយប្រើបទបញ្ជា ។
- ដាក់សេចក្តីព្រាងច្បាប់ជូនក្រុមប្រឹក្សា ។
- រៀបចំ និងអនុវត្តថវិកាខេត្ត/ក្រុង ។
- កំណត់ និងប្រមូលអាករមូលដ្ឋាន បន្ទុក ឬសោហ៊ុយចំណាយ និង
- គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។

២) ក្រុមប្រឹក្សារដ្ឋបាល

ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានបានកំណត់បញ្ជីក្រុមប្រឹក្សារដ្ឋបាលដែលត្រូវរក្សាទុកនៅថ្នាក់ខេត្ត ឬក្រុង (មាត្រា ១៨៥-៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ) (សូមមើលរូបភាពទី ៣) ។ ក្រុមប្រឹក្សារដ្ឋបាលទាំងអស់ត្រូវធានានូវកម្រិត

ខ្លះនៃឯករាជ្យភាពពីការដឹកនាំរួមដោយនាយកប្រតិបត្តិ ក៏ដូចជាសមត្ថភាពខ្ពស់ក្នុងបញ្ហាជាក់លាក់ ។ ឯករាជ្យភាពនេះត្រូវបានកម្រិតដោយការដាក់កំហិតលើដែនសមត្ថកិច្ចរបស់ខ្លួន ដោយសារក្រុមប្រឹក្សារដ្ឋបាលមួយអាចធ្វើសេចក្តីព្រាង ឬអនុវត្តថវិកាដោយឯករាជ្យ មិនអាចដាក់សេចក្តីព្រាងច្បាប់ ប្រមូលអាករមូលដ្ឋាន ។ល។ ( មាត្រា ១៨០-៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

ខាងក្រោមនេះជាឧទាហរណ៍អំពីក្រុមប្រឹក្សារដ្ឋបាល :

- ក្រុមប្រឹក្សាអប់រំមានសមាជិកប្រាំរូបដែលមានអាណត្តិបួនឆ្នាំ ដែលតែងតាំងដោយនាយកប្រតិបត្តិដោយមានការព្រមព្រៀងពីក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាអប់រំទទួលបន្ទុកកិច្ចការ ដូចជា ការបង្កើត និងគ្រប់គ្រងសាលារៀន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធអប់រំផ្សេងទៀត និងការឧទ្ទេសនាមគ្រូបង្រៀន ។
- គណៈកម្មាធិការបុគ្គលិកមានសមាជិកបីរូប ដែលតែងតាំងក្នុងល័ក្ខខ័ណ្ឌតែមួយដូចសមាជិកក្រុមប្រឹក្សាអប់រំដែរ ។ គណៈកម្មាធិការបុគ្គលិកស៊ើបអង្កេត ស្រាវជ្រាវ និងធ្វើសេចក្តីព្រាងផែនការ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការដំឡើងឋានន្តរស័ក្តិបុគ្គលិក ។

<u>**រូបភាពទី ៣ : ក្រុមប្រឹក្សារដ្ឋបាលនៅក្នុងអាជ្ញាធរមូលដ្ឋាន**</u>

| (ខេត្ត និងក្រុង) | (ខេត្ត) |
|---|---|
| ក្រុមប្រឹក្សាអប់រំ | គណៈកម្មាធិការសន្តិសុខសាធារណៈ |
| គណៈកម្មាធិការរៀបចំការបោះឆ្នោត | គណៈកម្មាធិការការងារមូលដ្ឋាន |
| គណៈកម្មាធិការបុគ្គលិក | គណៈកម្មាធិការអស្សាមិករណ៍ |
| សវនករ | គណៈកម្មាធិការមជ្ឈត្តវិនិច្ឆ័យជលផល |
| | គណៈកម្មាធិការគ្រប់គ្រងជលផល |
| | (ក្រុង) |
| | គណៈកម្មាធិការកសិកម្ម |
| | គណៈកម្មាធិការវាយតម្លៃអចលនទ្រព្យ |

- គណៈកម្មាធិការសន្តិសុខសាធារណៈត្រូវបានបង្កើតឡើងតែនៅតាមបណ្តាខេត្តប៉ុណ្ណោះ និងមានសមាជិកដែលមានអាណត្តិបីឆ្នាំ ។ គណៈកម្មាធិការសន្តិសុខសាធារណៈត្រួតពិនិត្យលើស្នងការដ្ឋាននគរបាលខេត្ត ។
- គណៈកម្មាធិការរៀបចំការបោះឆ្នោត មានសមាជិកបួនរូបដែលមានអាណត្តិបួនឆ្នាំ ( ត្រូវបានជ្រើសតាំងដោយអ្នកបោះឆ្នោតដោយក្រុមប្រឹក្សា) ចូលរួមក្នុងការគ្រប់គ្រងរាល់ការបោះឆ្នោតថ្នាក់មូលដ្ឋានទាំងអស់ក៏ដូចជាការបោះឆ្នោតថ្នាក់ជាតិផងដែរ ហើយ
- សវនករក៏ត្រូវបានអោយកាន់កាប់មុខដំណែងរដ្ឋបាលឯករាជ្យ ដូចគ្នាទៅនឹងក្រុមប្រឹក្សារដ្ឋបាលផងដែរ ។ ដោយត្រូវបានតែងតាំងជាពិសេស ដោយនាយកប្រតិបត្តិ ក្នុងចំណោមស្ត្រី/បុរស ដែលមានសុភវិនិច្ឆ័យ

ពាក់ព័ន្ធនឹងរដ្ឋបាលសាធារណៈ និងសមាជិកក្រុមប្រឹក្សាដែលអាចជ្រើសតាំងបាន សវនករទទួលបន្ទុកលើសវនកម្មហិរញ្ញវត្ថុមូលដ្ឋាន និងត្រួតពិនិត្យការអនុវត្តកិច្ចការមូលដ្ឋាន ។

៣) អង្គការជំនួយ និងមន្ត្រីរាជការក្នុងអាជ្ញាធរមូលដ្ឋាន

ការគាំទ្រដោយផ្ទាល់ចំពោះភារកិច្ចរបស់ អភិបាលខេត្ត/អភិបាលក្រុងរបស់អាជ្ញាធរមូលដ្ឋាន ត្រូវបានប្រគល់ទៅអោយអង្គការជំនួយ គឺអភិបាលខេត្តរង/អភិបាលក្រុងរង និងប្រធានគណនេយ្យ/ហេរញ្ញិក (មាត្រា១៦១ និងមាត្រា ១៦៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ចំនួនអភិបាលខេត្តរង/អភិបាលក្រុងរងអាចកើនឡើង តាមរយៈដីកា ហើយទីក្រុងដែលមានប្រជាជនតិចជាង ១០០.០០០ នាក់ ឃុំ ឬភូមិ អាចមិនមានមុខដំណែងហេរញ្ញិក ។ បុគ្គលទាំងអស់នេះត្រូវតែងតាំងដោយនាយកប្រតិបត្តិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សា ដែលមានអាណត្តិបួនឆ្នាំ ។ អាណត្តិនេះអាចផ្អាក ហើយមន្ត្រីនោះអាចត្រូវបានដកហូតមុខដំណែងនៅពេលណាក៏បាន ប្រសិនបើនាយកប្រតិបត្តិយល់ថាសមរម្យ (មាត្រា ១៦៣ និងមាត្រា ១៦៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

- អភិបាលខេត្តរង/អភិបាលក្រុងរងទទួលបន្ទុកគាំទ្រដល់នាយកប្រតិបត្តិ ក្នុងការត្រួតពិនិត្យមន្ត្រីរាជការជាសហសេវិករបស់ខ្លួន ។ ក្នុងករណីអវត្តមានអភិបាលខេត្ត/អភិបាលក្រុង អភិបាលខេត្តរង/អភិបាលក្រុងរងមានទំនួលខុសត្រូវលើការងាររបស់អភិបាលខេត្ត/អភិបាលក្រុង (មាត្រា ១៦៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។
- ប្រធានគណនេយ្យ/ហេរញ្ញិកគ្រប់គ្រងគណនីរបស់អាជ្ញាធរមូលដ្ឋាន ដូចជា វិក្កយបត្រ និងការបើកប្រាក់ទំនិញ ឬឥណទាន (មាត្រា ១៧០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ កម្រិតខ្លះនៃឯករាជ្យភាពពីនាយកប្រតិបត្តិត្រូវបានធានាជូនផ្នែកដែលគ្រប់គ្រងគណនី ។

ទោះបីជាក្របខ័ណ្ឌ និងល័ក្ខខ័ណ្ឌការងារសម្រាប់មន្ត្រីរាជការមូលដ្ឋាន ត្រូវបានចែងដោយច្បាប់ស្តីពីមុខងារសាធារណៈមូលដ្ឋានក៏ដោយ ក៏ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានចែងថា ការិយាល័យខេត្ត/ក្រុងត្រូវបង្កើតឡើងដោយដីកា ហើយការិយាល័យដទៃទៀតត្រូវបង្កើតឡើងដោយអភិបាលខេត្ត/អភិបាលក្រុង (មាត្រា ១៥៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។

រូបភាពទី ៤ និងរូបភាពទី ៥ បង្ហាញពីឧទាហរណ៍នៃរចនាសម្ព័ន្ធរៀបចំខេត្ត និងក្រុង សម្រាប់អង្គនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។

## រូបភាពទី ៤ : ឧទាហរណ៍នៃការរៀបចំរដ្ឋបាលខេត្ត

| | | | |
|---|---|---|---|
| អភិបាល | អភិបាលរង | នាយកដ្ឋានកិច្ចការទូទៅ | ផ្នែកបុគ្គលិក<br>ផ្នែកប្រជាពលរដ្ឋខេត្ត<br>ផ្នែកហិរញ្ញវត្ថុ<br>ផ្នែកថែរក្សាទ្រព្យសម្បត្តិ<br>ផ្នែកកាលប្បវត្តិ និងកិច្ចការអប់រំ<br>ផ្នែកពន្ធដារ<br>ផ្នែកកិច្ចការមូលដ្ឋាន<br>ផ្នែកស្ថិតិ<br>ការិយាល័យលេខាធិការ |
| | | នាយកដ្ឋានផែនការ និងអភិវឌ្ឍន៍ | ផ្នែកផែនការ<br>ផ្នែកអភិវឌ្ឍតំបន់<br>ផ្នែកគ្រប់គ្រងព័ត៌មាន |
| | | នាយកដ្ឋានសុខុមាលភាព | ផ្នែកសុខុមាលភាព<br>ផ្នែកស្ត្រី និងកុមារ<br>ផ្នែកគាំពារ |
| | | នាយកដ្ឋានសុខាភិបាល | ផ្នែកកិច្ចការវេជ្ជសាស្ត្រ<br>ផ្នែកសុខភាពសាធារណៈ<br>ផ្នែកអនាម័យបរិស្ថាន<br>ផ្នែកកិច្ចការឱសថ |
| | | នាយកដ្ឋានបរិស្ថាន | ផ្នែកផែនការ និងសម្របសម្រួល<br>ផ្នែកត្រួតពិនិត្យការបំពុលខ្យល់<br>ផ្នែកត្រួតពិនិត្យការបំពុលទឹក |

| | | | |
|---|---|---|---|
| | | នាយកដ្ឋានពាណិជ្ជកម្ម ឧស្សាហកម្ម និងការងារ | ផ្នែករដ្ឋបាលពាណិជ្ជកម្ម<br>ផ្នែកអភិវឌ្ឍន៍ឧស្សាហកម្ម<br>ផ្នែកទេសចរណ៍<br>ផ្នែកណែនាំសហគ្រាសធុនតូច និងមធ្យម<br>ផ្នែកកិច្ចការការងារ<br>ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | | នាយកដ្ឋានកសិកម្ម និងរុក្ខាប្រមាញ់ | ផ្នែកកិច្ចការកសិកម្ម<br>ផ្នែកសេដ្ឋកិច្ចកសិកម្ម<br>ផ្នែកបណ្តុះបណ្តាល និងអប់រំ<br>ផ្នែកសាកវប្បកម្មកសិកម្ម<br>ផ្នែកបសុសត្វ<br>ផ្នែកដីធ្លីកសិកម្ម<br>ផ្នែកជលផល<br>ផ្នែករុក្ខាប្រមាញ់<br>ផ្នែកគ្រប់គ្រងទឹកជំនន់ និងដាំដើមឈើ |

| | | | |
|---|---|---|---|
| | | នាយកដ្ឋានសាធារណការ | ផ្នែកគ្រប់គ្រង<br>ផ្នែកសាងសង់ផ្លូវថ្នល់<br>ផ្នែកពង្រឹងផ្លូវថ្នល់<br>ផ្នែកទន្លេ<br>ផ្នែកត្រួតពិនិត្យដីល្បប់<br>ផ្នែកកំពង់ផែ និងទីសំចត<br>ផ្នែកនគរូបនីយកម្ម<br>ផ្នែកស្ថាបត្យកម្ម<br>ផ្នែកលំនៅដ្ឋាន |
| ប្រធានគណនេយ្យ | | ការិយាល័យគណនេយ្យ | ផ្នែកគណនេយ្យ<br>ផ្នែកផ្គត់ផ្គង់ |

| | | | |
|---|---|---|---|
| ប្រធានសហគ្រាសសាធារណៈ | ការិយាល័យសហគ្រាសសាធារណៈ | នាយកដ្ឋានគ្រប់គ្រង | ផ្នែកកិច្ចការទូទៅ<br>ផ្នែកគ្រប់គ្រងសារពើពន្ធ |
| | | នាយកដ្ឋានប្រតិបត្តិការ | ផ្នែកអគ្គិសនី<br>ផ្នែកទឹកឧស្សាហកម្ម |
| | | នាយកដ្ឋានសំណង់ | ផ្នែកផែនការ<br>ផ្នែកការងារសាងសង់ |
| ក្រុមប្រឹក្សាអប់រំ | | អធិការ | ផ្នែកលេខាធិការ<br>និងផែនការ<br>ផ្នែកកិច្ចការទូទៅ<br>ផ្នែកកិច្ចការអប់រំ<br>ផ្នែកណែនាំ<br>ផ្នែកសុខភាព<br>និងអប់រំកាយ<br>ផ្នែកសុខុមាលភាព |
| គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោត | | លេខាធិការដ្ឋាន | |
| គណៈកម្មាធិការបុគ្គលិក | | លេខាធិការដ្ឋាន | ផ្នែកកិច្ចការទូទៅ<br>ផ្នែកត្រួតពិនិត្យ |
| សវនករ | | លេខាធិការដ្ឋាន | ផ្នែកទី ១<br>ផ្នែកទី ២ |

| | | | |
|---|---|---|---|
| គណៈកម្មាធិការសុវត្ថិភាពសាធារណៈ | ស្នងការដ្ឋាននគរបាលខេត្ត | នាយកដ្ឋានកិច្ចការនគរបាល | ផ្នែកលេខាធិការ<br>ផ្នែកកិច្ចការនគរបាល<br>ផ្នែកមន្ត្រីអធិការកិច្ច<br>ផ្នែកបណ្តុះបណ្តាល<br>ផ្នែកគណនេយ្យ |

| | | | |
|---|---|---|---|
| | | នាយកដ្ឋានឧក្រិដ្ឋកម្ម | ផ្នែកស៊ើបអង្កេតឧក្រិដ្ឋកម្មទី ១<br>ផ្នែកស៊ើបអង្កេតឧក្រិដ្ឋកម្មទី ២<br>ផ្នែកបង្ការឧក្រិដ្ឋកម្ម<br>ផ្នែកអត្តសញ្ញាណកម្មឧក្រិដ្ឋកម្ម |
| | | នាយកដ្ឋានការពារជាតិ | ផ្នែកសន្តិសុខសាធារណៈ<br>ផ្នែកការពារជាតិ<br>ផ្នែកយាមល្បាត<br>អង្គភាពយានយន្តនគរបាលពិសេស |
| | | នាយកដ្ឋានចរាចរណ៍ | ផ្នែកកិច្ចការទូទៅ<br>ផ្នែកណែនាំ<br>ផ្នែកប័ណ្ណបើកបរ |
| គណៈកម្មាធិការការងារមូលដ្ឋាន | | លេខាធិការដ្ឋាន | ផ្នែកកិច្ចការទូទៅ<br>ផ្នែកសម្របសម្រួល<br>ផ្នែកស៊ើបអង្កេត |

| | | | |
|---|---|---|---|
| សភាខេត្ត | | | |
| ប្រធាន | អនុប្រធាន | លេខាធិការដ្ឋាន | |

## រូបភាពទី ៥ : ឧទាហរណ៍នៃការរៀបចំរដ្ឋបាលក្រុង (ទីក្រុង)

| | | | |
|---|---|---|---|
| អភិបាល | អភិបាលរង | នាយកដ្ឋានកិច្ចការទូទៅ | ផ្នែករដ្ឋបាល<br>ផ្នែកហិរញ្ញវត្ថុ |
| | | នាយកដ្ឋានផែនការ | ផ្នែកផែនការ<br>ផ្នែកគ្រប់គ្រងព័ត៌មាន |
| | | នាយកដ្ឋានកិច្ចការពន្ធដារ | ផ្នែកកំណត់ពន្ធដារទី ១<br>ផ្នែកកំណត់ពន្ធដារទី ២<br>ផ្នែកចំណូលអាករ |

| | | | |
|---|---|---|---|
| | | នាយកដ្ឋានកិច្ចការកសិកម្ម | ផ្នែកជំរុញវិស័យកសិកម្ម<br>ផ្នែកកែលម្អដីធ្លី<br>ផ្នែកដីធ្លីកសិកម្ម |
| | | នាយកដ្ឋានពាណិជ្ជកម្ម និងទេសចរណ៍ | ផ្នែកពាណិជ្ជកម្ម និងទេសចរណ៍<br>ផ្នែកអភិវឌ្ឍន៍ |
| | | នាយកដ្ឋានប្រជាពលរដ្ឋ | ផ្នែកសេវាកម្ម<br>ផ្នែកចុះបញ្ជីការ<br>ផ្នែកសោធន |
| | | នាយកដ្ឋានសុខាភិបាល និងអនាម័យ | ផ្នែកធានារ៉ាប់រងសុខភាពជាតិ<br>ផ្នែកសុខាភិបាល<br>ផ្នែកអនាម័យបរិស្ថាន |
| | | នាយកដ្ឋានសំណង់ | ផ្នែកគ្រប់គ្រង<br>ផ្នែកវិស្វកម្ម<br>ផ្នែកនគរូបនីយកម្ម |
| | | ហេដ្ឋារចនាសម្ព័ន្ធចម្រោះអនាម័យ | |
| | ហេរញ្ញិក | នាយកដ្ឋានគណនេយ្យ | ផ្នែកគណនេយ្យ<br>ផ្នែកគ្រប់គ្រងសារពើពន្ធ |
| | | ការិយាល័យ សុខុមាលភាពសង្គម | ផ្នែកកិច្ចការទូទៅ<br>ផ្នែកគាំពារ |

| | | | |
|---|---|---|---|
| ក្រុមប្រឹក្សាអប់រំ | | ស្នងការ | លេខាធិការដ្ឋាន |
| គណៈកម្មាធិការរៀបចំការបោះឆ្នោត | | | លេខាធិការដ្ឋាន |
| គណៈកម្មាធិការបុគ្គលិក | | | លេខាធិការដ្ឋាន |
| សវនករ | | | លេខាធិការដ្ឋាន |
| គណៈកម្មាធិការកសិកម្ម | | | |
| គណៈកម្មាធិការវាយតម្លៃអចលនទ្រព្យ | | | |

| | | | |
|---|---|---|---|
| សភាក្រុង | | | |
| ប្រធាន | អនុប្រធាន | លេខាធិការដ្ឋាន | |

គ. ទំនាក់ទំនងរវាងអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ

ទាំងក្រុមប្រឹក្សា និងនាយកប្រតិបត្តិ ត្រូវបានគាំទ្រ តាមរយៈការបោះឆ្នោតដោយផ្ទាល់ និងស្របច្បាប់ ហើយមានឯករាជ្យភាពពីគ្នាទៅវិញទៅមកក្នុងការបំពេញភារកិច្ច ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកភារកិច្ចអាចនឹងពិបាកក្នុងការបែងចែកគ្នាអោយដាច់ស្រឡះ ។ អាស្រ័យហេតុនេះ ប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាព មានភាពចាំបាច់ក្នុងការផ្តល់អត្ថប្រយោជន៍ដល់ភាគីនីមួយៗដូចខាងក្រោម (សូមមើលរូបភាពទី ៦) :

- ការពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច : នាយកប្រតិបត្តិអាចផ្ញើត្រឡប់ទៅអោយក្រុមប្រឹក្សាវិញនូវសេចក្តីសម្រេច (ការប្រកាសអោយប្រើ ឬការលុបចោលដីកា ថវិកា ។ល។) សម្រាប់ការពិនិត្យមើលឡើងវិញ (មាត្រា ១៧៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ម្យ៉ាងវិញទៀត ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានចែងអំពីនីតិវិធីផ្សេងទៀតក្នុងការពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចខុសច្បាប់ ដែលតាមរយៈនេះក្រុមប្រឹក្សា និងនាយកប្រតិបត្តិអាចប្តឹងទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ឬទៅតុលាការ (មាត្រា ១៧៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ នីតិវិធីនេះដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសិទ្ធិវេតូ កម្រមានការប្រើប្រាស់ណាស់ ។ ព្រមទាំង
- ញត្តិដកសេចក្តីទុកចិត្ត (មាត្រា ១៧៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) : សភាអាចបោះឆ្នោតដកសេចក្តីទុកចិត្តពីនាយកប្រតិបត្តិ ។ ប្រសិនបើសមាជិកក្រុមប្រឹក្សាសរុប ៣/៤ មានវត្តមានក្នុងកូរ៉ុមច្រើនជាង ២/៣ បោះឆ្នោតយល់ព្រម នាយកប្រតិបត្តិអាចរំលាយសភា ក្នុងរយៈពេលដប់ថ្ងៃ ក្នុងលក្ខណៈជាប្រតិវិធានការ ឬបើមិនដូច្នោះទេ ត្រូវបាត់បង់មុខដំណែងរបស់ខ្លួន ។ លើសពីនេះទៅទៀត ប្រសិនបើក្រុមប្រឹក្សាបង្ហាញអំពីឯកភាពរួមគ្នាច្បាស់លាស់ក្នុងការបោះឆ្នោតដកសេចក្តីទុកចិត្ត នាយកប្រតិបត្តិមិនអាចរំលាយក្រុមប្រឹក្សាបានឡើយ ហើយត្រូវបាត់បង់មុខដំណែងរបស់ខ្លួនដោយស្វ័យប្រវត្តិ ។

តាមពិតទៅ ទំនាក់ទំនងរវាងអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិកម្រនឹងក្លាយជាគូបដិបក្សនឹងគ្នាណាស់ ចំពោះការប្រើប្រាស់វិធានការខាងលើនេះ ។ ក្រុមប្រឹក្សាអាចប្រគល់នូវបញ្ហាមិនសូវមានវិវាទបដិវាទ ក្នុងដែនទំនួលខុសត្រូវរបស់ខ្លួនទៅអោយនាយកប្រតិបត្តិ (មាត្រា ១៨០ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ សមាជិកទាំងឡាយនៃអង្គនីតិប្រតិបត្តិត្រូវចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សា ព្រមទាំងផ្តល់ការពន្យល់បកស្រាយនានាដែលស្នើឡើងដោយប្រធានក្រុមប្រឹក្សា (មាត្រា ១២១ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ដើម្បីអោយភាគីទាំងពីរយល់ពីគោលបំណងរបស់ភាគីម្ខាងទៀត ។

## ៤. ប្រជាធិបតេយ្យមូលដ្ឋាន

ប្រសិនបើទស្សនៃស្វ័យភាពមូលដ្ឋានត្រូវបានរកឃើញនៅក្នុង "ស្វ័យភាពរបស់ប្រជាពលរដ្ឋ" យើងមិនត្រូវបំភ្លេចទិដ្ឋភាពនៃប្រជាធិបតេយ្យមូលដ្ឋានឡើយ ។ ជាការពិតណាស់ដែលថា គោលការណ៍ចម្បងនៃប្រជាធិបតេយ្យ គឺការបោះឆ្នោតដោយផ្ទាល់ ដើម្បីជ្រើសរើសមេដឹកនាំ ហើយនៅថ្នាក់មូលដ្ឋាន លទ្ធភាពក្នុងការចូលរួមដោយផ្ទាល់ដោយប្រជាពលរដ្ឋអាចមានភាពបើកចំហជាងនៅថ្នាក់ជាតិ ដោយសារប្រភេទនៃភារកិច្ចដែលប្រគល់ជូនអាជ្ញាធរមូលដ្ឋាន និងកំហិតជិតនៃបញ្ហាដែលមាននៅក្នុងដៃ ។ រូបភាពទី ៦ បង្ហាញអំពីទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ។

តាមរយៈវិសោធនកម្មច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានកាលពីឆ្នាំ២០០៤ ស្រុកមានស្វ័យភាពសហគមន៍ (ជីអ៊ីគី-ជីជី-គូ) ត្រូវបានបង្កើតឡើងដើម្បីលើកស្ទួយស្វ័យភាពរបស់ប្រជាពលរដ្ឋ ។ ក្រុងមួយអាចបង្កើតស្រុកដោយផ្អែកលើផ្ទៃដីខ្លះនៃក្រុង តាមរយៈដីកា ។ ស្រុកមានគណៈកម្មាធិការសហគមន៍មួយ ដែលក្នុងនោះប្រជាពលរដ្ឋពិភាក្សាអំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងស្រុក ។

**<u>រូបភាពទី ៦ : ទំនាក់ទំនងរវាងប្រជាពលរដ្ឋ អង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ</u>**

អង្គនីតិប្រតិបត្តិ

<table>
<tr><td>អភិបាលខេត្ត<br>អភិបាលក្រុង</td><td colspan="2">បោះឆ្នោត<br>ស្នើសុំប្រកាសអោយប្រើ ឬកែប្រែដីកា<br>ស្នើសុំបញ្ឈប់បុគ្គលិក</td><td rowspan="8">ប្រជាពលរដ្ឋ</td></tr>
<tr><td>អំណាចក្នុងការរំលាយក្រុមប្រឹក្សា<br>អំណាចវេតូ</td><td colspan="2">អភិបាលខេត្តរង<br>អភិបាលក្រុងរង<br>ប្រធានគណនេយ្យ<br>ហេរញ្ញិក</td></tr>
<tr><td>បោះឆ្នោតដកសេចក្តីទុកចិត្ត</td><td colspan="2">តែងតាំង</td></tr>
<tr><td></td><td>ក្រុមប្រឹក្សាអប់រំ</td><td></td></tr>
<tr><td></td><td>សវនករ</td><td>ស្នើអោយមានការធ្វើសវនកម្ម</td></tr>
<tr><td></td><td>គណៈកម្មាធិការសុវត្ថិភាពសាធារណៈ<br>គណៈកម្មាធិការបុគ្គលិក</td><td></td></tr>
<tr><td></td><td>គណៈកម្មាធិការរៀបចំការបោះឆ្នោត</td><td>ស្នើសុំរំលាយក្រុមប្រឹក្សា</td></tr>
<tr><td>បោះឆ្នោត</td><td></td><td>ស្នើសុំដកហូតមុខដំណែងអភិបាលខេត្ត<br>អភិបាលក្រុង និងសមាជិកក្រុមប្រឹក្សា</td></tr>
<tr><td>ក្រុមប្រឹក្សាខេត្ត<br>ក្រុមប្រឹក្សានីតិបញ្ញត្តិក្រុង</td><td colspan="2">បោះឆ្នាត</td></tr>
</table>

ក. ប្រព័ន្ធបោះឆ្នោត

នៅប្រទេសជប៉ុន ប្រជាពលរដ្ឋដែលមានអាយុលើសពី ២០ ឆ្នាំ ហើយមានសញ្ជាតិជប៉ុន មានសិទ្ធិបោះឆ្នោតនៅគ្រប់ការបោះឆ្នោតថ្នាក់ជាតិទាំងអស់ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋានដើម្បីជ្រើស-តាំងអភិបាលខេត្ត អភិបាលក្រុង និងសមាជិកក្រុមប្រឹក្សា កត្តាមួយទៀតត្រូវបានបន្ថែម គឺតម្រូវអោយស្នាក់នៅក្នុងក្រុង

ពិសេសណាមួយបានរយៈពេលលើសពីបីខែ ។ ប៉ុន្តែ ជនទាំងឡាយណាដែលត្រូវបានវិនិច្ឆ័យថាអសមត្ថភាព ឬផ្តន្ទាទោសអោយជាប់ពន្ធនាគារ ( មិនទាន់បានទទួលទោសអស់) ពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ ។

អ្នកដែលមានសិទ្ធិបោះឆ្នោតត្រូវបានចុះឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតដែលគ្រប់គ្រងដោយក្រុង ។ រហូតមកដល់ខែកញ្ញា ឆ្នាំ២០០៥ អ្នកបោះឆ្នោតដែលបានចុះឈ្មោះមានចំនួន ១០៣.២៧៦.៤៨២ ( បុរស ៥០.០០២.៩៨០ នាក់ និងស្ត្រី ៥៣.២៧៣.៥០២ នាក់) ដែលត្រូវនឹងប្រហែល ៨០% នៃប្រជាជនសរុបទូទាំងប្រទេស ។

ចំពោះការឈរឈ្មោះជាបេក្ខជនសម្រាប់មុខងារសាធារណៈមូលដ្ឋាន លក្ខណៈវិនិច្ឆ័យមានការប្រែប្រួលអាស្រ័យទៅតាមប្រភេទនៃការបោះឆ្នោត :

- ចំពោះការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាខេត្ត និងក្រុង បេក្ខជន-បេក្ខនារីត្រូវតែជាប្រជាពលរដ្ឋជប៉ុនដែលមានអាយុលើសពី ២៥ ឆ្នាំ និងស្នាក់នៅក្នុងក្រុងនោះបានរយៈពេលច្រើនជាងបីខែ មុនការបោះឆ្នោត ។
- ចំពោះការបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិ មិនមានគិតអំពីរយៈពេលស្នាក់នៅឡើយ ។ ប៉ុន្តែ ចំពោះការបោះឆ្នោតជ្រើសតាំងអភិបាលខេត្ត បេក្ខជន-បេក្ខនារីត្រូវតែជាប្រជាពលរដ្ឋជប៉ុនដែលមានអាយុលើសពី ៣០ ឆ្នាំ ហើយចំពោះការបោះឆ្នោតជ្រើសតាំងអភិបាលក្រុងវិញ លក្ខខណ្ឌអាយុអប្បបរមាត្រូវបានបន្ថយនៅត្រឹម ២៥ ឆ្នាំ ។

ខ. ការចូលរួមដោយផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋ

នៅក្នុងលទ្ធិប្រជាធិបតេយ្យតំណាង ប្រជាពលរដ្ឋបញ្ចេញទស្សនៈនយោបាយរបស់ខ្លួនដោយបោះឆ្នោតជ្រើសតាំងតំណាង ហើយពួកគេត្រូវបានកាត់ផ្តាច់ចេញពីដំណើរការធ្វើសេចក្តីសម្រេចចិត្តចំពោះបញ្ហាពិសេសៗ។ ប៉ុន្តែ ប្រជាធិបតេយ្យដ៏ពិតប្រាកដមួយមិនអាចសម្រេចបានដោយគ្មានវិធានការមួយចំនួន ដោយប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យសកម្មភាពរបស់តំណាងរបស់ខ្លួនឡើយ ។ អាស្រ័យហេតុនេះ ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជប៉ុនបានបញ្ចូលនូវនីតិវិធីមួយចំនួនដែលផ្តល់ជូនប្រជាពលរដ្ឋនូវលទ្ធភាពក្នុងការចូលដល់រដ្ឋបាលមូលដ្ឋាន ដើម្បីកែកំហុសម្តងម្កាលនៅក្នុងប្រជាធិបតេយ្យតំណាង ។

១) គំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានចែងអំពីប្រភេទជាច្រើននៃគំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ ។ ប្រភេទមួយចំនួនផ្តោតគោលដៅលើការធ្វើសេចក្តីសម្រេចចិត្ត ។ ប្រភេទផ្សេងទៀតសម្រាប់ដកហូតមុខដំណែងអ្នកបង្កើតច្បាប់ ឬនាយកប្រតិបត្តិ នៅពាក់កណ្តាលអាណត្តិរបស់ខ្លួន :

- គំនិតផ្តួចផ្តើមសម្រាប់ការប្រកាសអោយប្រើប្រាស់ កែប្រែ លុបចោលដីកា ( មាត្រា ៧៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) : ចាំបាច់ត្រូវមានហត្ថលេខារបស់អ្នកបោះឆ្នោតចំនួនច្រើនជាង ១/៥០ សម្រាប់ការស្នើសុំការប្រកាសអោយប្រើប្រាស់ កែប្រែ ឬលុបចោលដីកា ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាមិនត្រូវបានហាមឃាត់ក្នុងការចាត់វិធានការក្នុងការឆ្លើយតបទៅនឹងលទ្ធផលឡើយ ។

- គំនិតផ្តួចផ្តើមសម្រាប់សវនកម្មលើបញ្ហារបស់រដ្ឋាភិបាលមូលដ្ឋាន (មាត្រា ៧៥ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) : ចាំបាច់ត្រូវមានហត្ថលេខារបស់អ្នកបោះឆ្នោតចំនួនច្រើនជាង ១/៥០ សម្រាប់ការស្នើសុំអោយមានការធ្វើសវនកម្មលើកិច្ចការរដ្ឋបាលមូលដ្ឋាន ។ ពេលនោះ សវនករត្រូវធ្វើសវនកម្មលើបញ្ហា និងផ្សព្វផ្សាយលទ្ធផលដែលរកឃើញ ។
- គំនិតផ្តួចផ្តើមសម្រាប់ការរំលាយក្រុមប្រឹក្សា (មាត្រា ៧៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) : ចាំបាច់ត្រូវមានហត្ថលេខារបស់អ្នកបោះឆ្នោតចំនួនច្រើនជាង ១/៣ សម្រាប់ការរំលាយក្រុមប្រឹក្សា ។ នៅពេលគំនិតផ្តួចផ្តើមនេះត្រូវបានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ចាំបាច់ត្រូវមានការបោះឆ្នោតពីប្រជាពលរដ្ឋ ។ ប្រសិនបើសម្លេងភាគច្រើនរបស់អ្នកមានសិទ្ធិបោះឆ្នោត យល់ព្រមអោយមានការរំលាយ សមាជិកក្រុមប្រឹក្សានីមួយៗនឹងបាត់បង់មុខដំណែងរបស់ខ្លួន ហើយការបោះឆ្នោតថ្មីនឹងត្រូវធ្វើឡើង ។
- ការដកហូតមុខដំណែងសមាជិកក្រុមប្រឹក្សា នាយកប្រតិបត្តិ និងមន្ត្រីសំខាន់ៗផ្សេងទៀត (មាត្រា ៨០ មាត្រា ៨១ និងមាត្រា ៨៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) : ចាំបាច់ត្រូវមានហត្ថលេខារបស់អ្នកបោះឆ្នោតចំនួនច្រើនជាង១/៣ សម្រាប់ការស្នើសុំដកហូតមុខដំណែងនាយកប្រតិបត្តិ សមាជិកក្រុមប្រឹក្សា និងមន្ត្រីៗផ្សេងទៀត (អភិបាលខេត្តរង/អភិបាលក្រុងរង ប្រធានគណនេយ្យ/ហេរញ្ញិក ។ល។) ។ ក្នុងករណីមន្ត្រីដែលបោះឆ្នោតជ្រើសតាំង ប្រសិនបើសម្លេងភាគច្រើនយល់ព្រមអោយមានការដកហូតពីមុខដំណែងដោយការបោះឆ្នោត មន្ត្រីរូបនោះត្រូវដកហូតពីមុខដំណែង ។ ក្នុងករណីមុខដំណែងតែងតាំង ក្រុមប្រឹក្សាត្រូវសម្រេចចិត្តថាតើមន្ត្រីនោះត្រូវដកហូតពីមុខដំណែងដោយការបោះឆ្នោតពីសមាជិកក្រុមប្រឹក្សាឬទេ ។

២) ប្រជាមតិ

នៅប្រទេសជប៉ុន នីតិវិធីស្របច្បាប់សម្រាប់ប្រជាមតិមានចែងតែនៅក្នុងមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញប៉ុណ្ណោះ នៅក្នុងបរិបទនៃការអនុម័តច្បាប់ពិសេសពាក់ព័ន្ធនឹងអាជ្ញាធរមូលដ្ឋានតែមួយប៉ុណ្ណោះ ។ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានមិនបានបញ្ជាក់អោយបានច្បាស់លាស់ថាប្រជាមតិមាន "សុពលភាព" ស្របច្បាប់ នៅក្នុងប្រជាធិបតេយ្យតំណាងឡើយ។ ប៉ុន្តែអាជ្ញាធរមូលដ្ឋានជាច្រើនបានបង្កើតដីការបស់ខ្លួន តាមរយៈប្រជាមតិពិគ្រោះយោបល់លើបញ្ហាជាក់លាក់មួយចំនួន ដូចជាការសាងសង់រោងចក្រថាមពលនុយក្លេអ៊ែរ ឬវត្តមាននៃមូលដ្ឋានយោធា ។ល។

៣) ការស្នើសុំអោយមានការធ្វើសវនកម្មសារពើពន្ធ និងបណ្តឹងរបស់ប្រជាពលរដ្ឋ

ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានជប៉ុនអនុញ្ញាតអោយប្រជាពលរដ្ឋមិនត្រឹមតែធ្វើសកម្មភាពជាសមូហភាព ដើម្បីសម្តែងមតិយោបល់របស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងអនុញ្ញាតអោយធ្វើសកម្មភាពជាឯកត្តបុគ្គល តាមរយៈការស្នើសុំអោយមានការធ្វើសវនកម្មសារពើពន្ធទៀតផង ។ ប្រសិនបើប្រជាពលរដ្ឋណាម្នាក់មានមូលដ្ឋានដែលអាចធ្វើអោយជឿបានថាមានអនីត្យានុកូលភាព ឬភាពមិនត្រឹមត្រូវ នៅក្នុងការគ្រប់គ្រងមូលនិធិសាធារណៈ ឬទ្រព្យសម្បត្តិសាធារណៈ និងការចុះ ឬអនុវត្តកិច្ចសន្យា ប្រជាពលរដ្ឋនោះអាចទាមទារអោយសវនកររបស់អាជ្ញាធរមូលដ្ឋានធ្វើសវនកម្មលើបញ្ហានោះ និងចាត់វិធានការដើម្បីកែតម្រូវ ប្រសិនបើចាំបាច់ (មាត្រា ២៤២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន)។ ក្នុងករណីមិនពេញចិត្ត

ចំពោះលទ្ធផលនៃសវនកម្ម ប្រជាពលរដ្ឋរូបនោះអាចដាក់ពាក្យបណ្តឹង (មាត្រា ២៤២-២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ ករណីនេះត្រូវបានហៅថា "បណ្តឹងរបស់ប្រជាពលរដ្ឋ" ដែលជារបៀបរបស់ប្រទេសជប៉ុននៃរឿងក្តីរបស់អ្នកជាប់ពន្ធ ដែលផ្តល់នូវប្រភពដ៏សំបូរបែបនៃយុត្តិសាស្ត្ររដ្ឋបាល ។

## ជំពូកទី ៣ : ទំនួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋាន

រដ្ឋមិនអាចសម្រេចគោលបំណងរបស់ខ្លួន ដោយមិនប្រគល់សេវាសាធារណៈមួយចំនួន ទៅអោយសហគមន៍ស្វ័យតមូលដ្ឋានបានឡើយ ដោយឈរលើទស្សនៈទាំងផ្នែកបរិមាណ និងគុណភាព ។ វត្តមានរបស់អាជ្ញាធរមូលដ្ឋានគឺសម្រាប់តម្រូវការនៅកៀកនឹងប្រជាពលរដ្ឋ និងសម្រាប់ប្រសិទ្ធភាពនៅក្នុងរដ្ឋបាលសាធារណៈ ។ អាស្រ័យហេតុនេះអង្គភាពសាធារណៈមូលដ្ឋានទទួលបន្ទុកលើសេវាសាធារណៈជាច្រើនប្រភេទ ដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ លើកលែងតែចំពោះកិច្ចការ "ជាតិ" សុទ្ធសាធមួយចំនួន ដូចជា ការទូត ការពារជាតិ ប្រព័ន្ធច្បាប់ ឬការបោះពុម្ពក្រដាសប្រាក់ ស្ទើរតែគ្រប់សេវាទាំងអស់ជាទំនួលខុសត្រូវរបស់មូលដ្ឋាន ។ នៅក្នុងជំពូកនេះ យើងនឹងពិនិត្យជាបឋមទៅលើដែនសមត្ថកិច្ចទូទៅ ឬភារកិច្ចរបស់រដ្ឋាភិបាលមូលដ្ឋាន តាមបែបទ្រឹស្តី និងបន្ទាប់មកទៀត យើងនឹងក្រឡេកមើលលើភារកិច្ចចម្រុះៗដែលបំពេញដោយរដ្ឋាភិបាលមូលដ្ឋាន ។

### ១. ទំនួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន : "ភារកិច្ចស្វ័យត" និង "ភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់"

រហូតមកដល់ខែមីនា ឆ្នាំ២០០០ មានភារកិច្ចរបស់រដ្ឋាភិបាលមូលដ្ឋានពីរប្រភេទ ។ ប្រភេទទីមួយគឺ "ភារកិច្ចផ្ទាល់" និងមួយទៀត "ភារកិច្ចជាទីភ្នាក់ងារទទួលប្រតិភូកម្ម" ។ អាជ្ញាធរមូលដ្ឋានអាចគ្រប់គ្រង "ភារកិច្ចផ្ទាល់" របស់ខ្លួនដោយសេរីក្នុងកម្រិតតិច ឬច្រើន លើកលែងតែនីត្យានុកូលភាពត្រូវបានរំលោភ ។ ផ្ទុយទៅវិញ ក្នុងការគ្រប់គ្រង "ភារកិច្ចជាទីភ្នាក់ងារទទួលប្រតិភូកម្ម" ជាភារកិច្ចរបស់រដ្ឋដែលបានធ្វើប្រតិភូកម្មជូនអង្គនីតិប្រតិបត្តិរបស់អាជ្ញាធរមូលដ្ឋាន អាជ្ញាធរមូលដ្ឋានត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យទាំងស្រុងពីរដ្ឋ ។ "ភារកិច្ចជាទីភ្នាក់ងារទទួលប្រតិភូកម្ម" មានប្រហែល ៣០% ទៅ ៤០% នៃភារកិច្ចរបស់ក្រុង និង ៧០% ទៅ ៨០% នៃភារកិច្ចរបស់ខេត្ត ។

ប្រព័ន្ធប្រតិភូកម្មដោយផ្នែកនេះដែលកើតមានតាំងពីរជ្ជកាលអធិរាជម៉ីជី មានអត្ថិភាពយូរអង្វែង ដោយសារតែរដ្ឋយល់ឃើញថាវាមានអត្ថប្រយោជន៍ ។ ទោះជាយ៉ាងណាក៏ដោយអត្ថិភាពរបស់ "ភារកិច្ចជាទីភ្នាក់ងារទទួលប្រតិភូកម្ម" និងអន្តរាគមន៍ជាតិដ៏រឹងមាំជាប់ជាមួយ ត្រូវបានរិះគន់ថាខ្វះភាពបត់បែន និងអប្រក្រតីភាព ។

ហេតុនេះហើយបានជាកញ្ចប់កំណែទម្រង់ដើម្បីជំរុញវិមជ្ឈការបានលុបបំបាត់ "ភារកិច្ចជាទីភ្នាក់ងារទទួលប្រតិភូកម្ម" និងធ្វើអោយរដ្ឋាភិបាលមូលដ្ឋានទាំងអស់មានតែ "ភារកិច្ចផ្ទាល់" ។ សព្វថ្ងៃនេះ មានប្រភេទថ្មីចំនួនពីរ នៅក្នុង "ភារកិច្ចផ្ទាល់" ដែលមានចែងនៅក្នុងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន : "ភារកិច្ចស្វ័យត" និង "ភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់" ។

- ភារកិច្ចស្វ័យត : អាជ្ញាធរមូលដ្ឋានអាចបំពេញភារកិច្ចទាំងនេះ ដោយឯករាជ្យពីការត្រួតពិនិត្យរបស់រដ្ឋជាងភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់ ពីព្រោះច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានអនុញ្ញាតអោយមានអន្តរាគមន៍ពីរដ្ឋ ក្នុងភារកិច្ចស្វ័យត តាមរបៀបបង្គាប់បញ្ជាតិចតួចជាង ។

- ភារកិច្ចអនុញ្ញាតតាមច្បាប់ ៖ ទោះបីជាអាជ្ញាធរមូលដ្ឋានមានទំនួលខុសត្រូវក្នុងការបំពេញកិច្ចការទាំងនេះក៏ដោយ ក៏កិច្ចការទាំងនេះជាកិច្ចការផ្ទៃក្នុងរបស់ជាតិ ដែលត្រូវការជាមូលដ្ឋានគ្រឹះនូវឯកសណ្ឋានភាព នៅទូទាំងប្រទេសជប៉ុន ។ អាស្រ័យហេតុនេះ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានអនុញ្ញាតអោយមានការចូលរួមរបស់ជាតិក្នុងកិច្ចការទាំងនេះ តាមរបៀបមានអំណាចជាង ។ កិច្ចការទាំងនេះត្រូវពិនិត្យមើលឡើងវិញជាប្រចាំ ដើម្បីលើកស្ទួយវិមជ្ឈការ ។

## ២. ភារកិច្ចចម្បងដែលបំពេញដោយរដ្ឋាភិបាលមូលដ្ឋាន

ដូចបានរៀបរាប់ខាងលើរួចមកហើយ ការបែងចែករវាងការងារផ្ទាល់ និងការងារទទួលប្រតិភូកម្ម តាមពិតជារឿងឥតប្រយោជន៍ ហើយវិស័យនីមួយៗនៃរដ្ឋបាលសាធារណៈដែលនៅប្រកៀកនឹងប្រជាពលរដ្ឋ ត្រូវបានទទួលរ៉ាប់រងដោយរដ្ឋាភិបាលមូលដ្ឋាន ។ ជាបន្តទៅនេះ ជាការចាំបាច់ដែលត្រូវក្រឡេកមើលភារកិច្ចចម្បងដែលបំពេញនៅក្នុងអាជ្ញាធរមូលដ្ឋាន ដោយរដ្ឋបាលប្រភេទនីមួយៗ ។

ក. ការអប់រំ

ការអប់រំគឺជាភារកិច្ចដ៏សំខាន់ជាងគេរបស់អាជ្ញាធរមូលដ្ឋាន ។ ដូចរូបភាពទី ៧ បានបង្ហាញ ប្រព័ន្ធអប់រំបច្ចុប្បន្ន មានរយៈពេល ៩ ឆ្នាំសម្រាប់ការអប់រំជាកាតព្វកិច្ច (៦ ឆ្នាំនៅបឋមសិក្សា និង ៣ ឆ្នាំនៅអនុវិទ្យាល័យ) និងប្រភេទផ្សេងៗជាច្រើននៅឧត្តមសិក្សា (ជាពិសេស ៣ ឆ្នាំនៅវិទ្យាល័យ និង ៤ ឆ្នាំនៅសាកលវិទ្យាល័យ) ។

ការចំណាយសរុបដោយអាជ្ញាធរមូលដ្ឋានសម្រាប់ការអប់រំនៅក្នុងឆ្នាំសារពើពន្ធ ២០០៥ មាន ១៦.៥៧៨ ពាន់លានយ៉េន ដែល ៤៨.២% ត្រូវបានបែងចែកសម្រាប់ការអប់រំជាកាតព្វកិច្ច និង ១៥.១% សម្រាប់វិទ្យាល័យ (សូមមើលរូបភាពទី៨) ។

## រូបភាពទី ៧ : ប្រព័ន្ធអប់រំបច្ចុប្បន្ន



## រូបភាពទី ៨ : បំណែងចែកការចំណាយលើវិស័យអប់រំ

( ឆ្នាំសារពើពន្ធ២០០៥ គិតជាលានយ៉េន)

| | សរុបសុទ្ធ | ខេត្ត | ក្រុង |
|---|---|---|---|
| ផ្សេងៗ | ៧.៧% | ៨.២% | ៦.៦% |
| កិច្ចការទូទៅខាងអប់រំ | ១៣.៩% | ១៤.៩% | ១២.២% |
| សុខភាព និងអប់រំកាយ | ៧.៣% | ១.១% | ២០.៩% |
| អប់រំសង្គម | ៧.៨% | ១.៩% | ២០.៧% |
| វិទ្យាល័យ | ១៥.១% | ២០.៤% | ៣.៥% |
| អនុវិទ្យាល័យ | ១៧.៤% | ១៩.៣% | ១៣.០% |
| សាលាបឋមសិក្សា | ៣០.៨% | ៣៤.២% | ២៣.១% |
| | ១៦.៥៧៧.៨៣៩យ៉េន | ១១.៣៣៧.៧៥៦ យ៉េន | ៥.៣០៦.៦៦១យ៉េន |
| | (១០០.០%) | (១០០.០%) | (១០០.០%) |

ដើម្បីបំពេញភារកិច្ចអប់រំរបស់ខ្លួនប្រកបដោយប្រជាធិបតេយ្យក្រោមគំនិតផ្តួចផ្តើមរបស់ខ្លួន ក្រុង និងខេត្តត្រូវបានតម្រូវអោយបង្កើតក្រុមប្រឹក្សាអប់រំមួយ ។ ភារកិច្ចនៃការអប់រំជាកាតព្វកិច្ចបង្កើតបានជាមុខងារជាមូលដ្ឋានគ្រឹះមួយរបស់អាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធនឹងទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ។

ក្រុងមានទំនួលខុសត្រូវជាចម្បងក្នុងការបង្កើតសាលាបឋមសិក្សា និងអនុវិទ្យាល័យដែលត្រូវការ ។ម្យ៉ាងវិញទៀត វិទ្យាល័យអាចត្រូវបានបង្កើតឡើងដោយរដ្ឋ ខេត្ត និងក្រុង ឬដោយ "អាជ្ញាធរតំបន់គ្រប់គ្រងសាលារៀន" ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលមានគោលបំណងបង្កើត និងគ្រប់គ្រងសាលារៀន ។ ក្នុងចំណោមស្ថាប័នទាំងបួន ខេត្តមានចំនួនវិទ្យាល័យច្រើនជាងគេ ។

តារាងទី ១ បង្ហាញពីចំនួនសាលារៀន និងសិស្ស/និស្សិត ។ សាលាបឋមសិក្សាមានប្រហែល ២៣.០០០ ដែលទទួលចុះឈ្មោះសិស្សជិត ៧.២០០.០០០ នាក់ និងអនុវិទ្យាល័យមានប្រហែល ១១.០០០ ដែលផ្តល់ការអប់រំដល់សិស្សប្រហែល ៣.៦៣០.០០០ នាក់ ។ សាលាភាគច្រើនដំណើរការដោយក្រុង ។

ចំពោះវិទ្យាល័យ មានប្រហែល ៥.៤០០ ដែលទទួលចុះឈ្មោះសិស្សជិត ៣.៦១០.០០០ នាក់ ។ ភាគរយនៃសិស្សរៀនចប់អនុវិទ្យាល័យហើយចុះឈ្មោះចូលរៀនវិទ្យាល័យ មានកម្រិតខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ ក្នុងមធ្យមភាគជាតិខ្ពស់ជាង ៩៧% ។

## **តារាងទី ១ : ចំនួនសាលារៀន និងសិស្ស/និស្សិត**

(គិតទាំងសាលារដ្ឋ និងសាលាឯកជន)

(គិតមកដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៦)

| | ចំនួនសាលារៀន | ចំនួនសិស្ស |
|---|---|---|
| សាលាបឋមសិក្សា | ២២.៨៧៨ | ៧.១៨៧.៤១៧ |
| អនុវិទ្យាល័យ | ១០.៩៩២ | ៣.៦០១.៥២៧ |
| វិទ្យាល័យ | ៥.៣៨៥ | ៣.៤៩៤.៥១៣ |
| សាកលវិទ្យាល័យ | ៧៤៤ | ២.៨៥៩.២១២ |
| មហាវិទ្យាល័យពីរឆ្នាំ | ៤៦៨ | ២០២.២៥៤ |
| សាលាបច្ចេកទេសជាន់ខ្ពស់ | ៦៤ | ៥៩.៣៨០ |
| សាលាមត្តេយ្យ | ១៣.៨៣៥ | ១.៧២៦.៥២០ |

"ការអប់រំសង្គម" ក៏ជាកិច្ចការដ៏សំខាន់មួយរបស់អាជ្ញាធរមូលដ្ឋានផងដែរ ។ ជាពិសេស កិច្ចការនេះរួមមានការបង្កើត និងគ្រប់គ្រងបណ្ណាល័យ សារមន្ទីរ ទីតាំងសាធារណៈ ។ល។ បន្ថែមពីលើហេដ្ឋារចនាសម្ព័ន្ធទាំងនេះ អាជ្ញាធរមូលដ្ឋានក៏ត្រូវលើកស្ទួយសកម្មភាពកីឡា និងវប្បធម៌ផងដែរ ។

ខ. សាធារណការ

ការចំណាយសម្រាប់សាធារណការដោយអាជ្ញាធរមូលដ្ឋាន គឺអស់ ១៤.៤១៧ ពាន់លានយ៉េន ក្នុងឆ្នាំសារពើពន្ធ ២០០៥ ។ វិស័យដែលបានរៀបរាប់នៅក្នុងរូបភាពទី ៩ បង្ហាញថាទាំងផ្លូវថ្នល់ និងការអភិវឌ្ឍទីក្រុង មួយៗ មានប្រហែល ១/៣ នៃការចំណាយសរុប ដោយការចំណាយសម្រាប់បាតទន្លេ និងឆ្នេរសមុទ្រតាមប្រកៀកពីក្រោយ ។

## **រូបភាពទី ៩ : បំណែងចែកចំណាយសាធារណការ**

(ឆ្នាំសារពើពន្ធ២០០៥ គិតជាលានយ៉េន)

| | សរុបសុទ្ធ | ខេត្ត | ក្រុង |
|---|---|---|---|
| ផ្សេងៗ | ៦.៥% | ៦.១% | ៦.៦% |
| លំនៅដ្ឋាន | ៨.៤% | ៧.៩% | ៩.១% |
| ការអភិវឌ្ឍទីក្រុង | ៣៨.០% | ២០.៦% | ៥៤.៧% |
| កំពង់ផែ | ៣.៣% | ៤.៤% | ២.៥% |
| ទន្លេ និងឆ្នេរសមុទ្រ | ១១.៤% | ២០.៥% | ២.៨% |
| ផ្លូវថ្នល់ | ៣២.៤% | ៤០.៥% | ២៤.៣% |
| | ១៤.៤១៧.៣៦៧ យ៉េន | ៧.១៧២.៣១៣ យ៉េន | ៧.៤៩១.៨៨០ យ៉េន |
| | (១០០.០%) | (១០០.០%) | (១០០.០%) |

១) ផ្លូវថ្នល់

គិតមកត្រឹមឆ្នាំ២០០៥ ផ្លូវថ្នល់នៅប្រទេសជប៉ុនមានប្រវែងសរុបប្រហែល ១.១៨៥.០០០ គីឡូម៉ែត្រ ដោយ ៥៤.០០០ គីឡូម៉ែត្រ ជាផ្លូវជាតិ ១២៩.០០០ គីឡូម៉ែត្រ ជាផ្លូវខេត្ត និង១.០០២.០០០ ជាផ្លូវក្រុង។ បច្ចុប្បន្ននេះ ផ្លូវជាតិត្រូវបានរៀបចំយ៉ាងល្អដោយមានទំហំធំ ប៉ុន្តែ ការកែលម្អផ្លូវក្រុងនៅតែជាបញ្ហាប្រឈមដែលត្រូវជំនះអោយបាន ។ ផែនការរយៈពេលវែងសម្រាប់កែលម្អផ្លូវថ្នល់ត្រូវបានរៀបចំដោយរដ្ឋ ។ "ផែនការប្រាំឆ្នាំ" លើកទី ១៣ ដែលគ្របដណ្តប់ឆ្នាំសារពើពន្ធ២០០៣-២០០៧ ត្រូវប្រើប្រាស់ទឹកប្រាក់អស់ ៣៨.០០០ ពាន់លានយ៉េននៃចំណាយប៉ាន់ស្មានសរុប ។

២) ការអភិវឌ្ឍទីក្រុង

គិតមកត្រឹមឆ្នាំ២០០៥ ទីក្រុងចំនួន ៧២២ ព្រមទាំងឃុំ និងភូមិចំនួន ៦៥៤ បានអនុវត្តគម្រោងរៀបចំក្រុងស្របតាមច្បាប់ស្តីពីការរៀបចំក្រុង។ ប្រជាជនជប៉ុនជាង ៩៣% រស់នៅក្នុង "តំបន់រៀបចំក្រុង" ដែលនៅទីនោះ ច្បាប់នេះត្រូវអនុវត្ត ហើយសង្ឃឹមថាកិច្ចការរៀបចំក្រុងនឹងក្លាយជាភារកិច្ចដ៏ចម្បងមួយរបស់ក្រុង ។

គម្រោងរៀបចំក្រុងផ្តោតគោលដៅលើការប្រើប្រាស់តាមផែនការនូវដីធ្លីក្នុងទីក្រុង និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដើម្បីលើកកំពស់លក្ខខណ្ឌរស់នៅក្នុងតំបន់ទីក្រុង និងជំរុញវិស័យឧស្សាហកម្ម ។ គម្រោងទាំងនេះរួមមានការងារជាច្រើន ដូចជា ការកែលម្អផ្លូវថ្នល់ ការរៀបចំដីធ្លីឡើងវិញ ការកែលម្អផ្លូវទឹក ការសាងសង់ចំណតយានយន្ត ការសាងសង់ប្រព័ន្ធបង្ហូរទឹកស្អុយ និងការអភិវឌ្ឍលំនៅដ្ឋាន ។ ការប្រមូលផ្តុំប្រជាជននៅតំបន់ដែលបានធ្វើនគរូបនីយកម្មរួចធ្វើអោយមានភាពចាំបាច់ជាបន្ទាន់ក្នុងការពង្រីកផ្លូវថ្នល់ ជំរុញអោយមានការសាងសង់អាគារខ្ពស់ៗ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈបន្ថែមទៀត និងផ្តល់នូវប្រព័ន្ធបង្ហូរទឹកស្អុយ ។ ក្នុងចំណោមការងារទាំងនេះ ប្រព័ន្ធបង្ហូរទឹកស្អុយត្រូវបានចាត់ទុកថាជាសេវាជាមូលដ្ឋានក្នុងតំបន់ទីក្រុង ហើយកាលពីពេលថ្មីៗកន្លងទៅនេះ ត្រូវបានចាត់ថ្នាក់ថាជាគម្រោងសាធារណការដែលមានអាទិភាពខ្ពស់ជាងគេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សេវាបង្ហូរទឹកស្អុយនៅតែមានអត្រា ៨០.៩% នៃប្រជាជន នៅចុងឆ្នាំសារពើពន្ធ ២០០៥ ហើយចាំបាច់ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីពង្រីកតំបន់សេវាបង្ហូរទឹកស្អុយនេះ ។

៣) វិស័យហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត

នៅក្នុងវិស័យសាងសង់លំនៅដ្ឋាន ផ្នែកដែលស្ថិតនៅក្រោមទំនួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន មានជាពិសេសការសាងសង់លំនៅដ្ឋានសម្រាប់គ្រួសារដែលមានចំណូលទាប ។ ក្នុងឆ្នាំសារពើពន្ធ២០០៥ អាជ្ញាធរមូលដ្ឋានបានសាងសង់ផ្ទះចំនួន ១៩.២ ពាន់ ហើយបច្ចុប្បន្ននេះ កំពុងទទួលបន្ទុកលើលំនៅដ្ឋានសាធារណៈប្រហែល ២.២ លានផ្ទះ ។

ការចំណាយសម្រាប់សាធារណការដោយអាជ្ញាធរមូលដ្ឋាន ក៏ប្រើប្រាស់សម្រាប់ការថែទាំ និងកែលម្អទន្លេ និងឆ្នេរសមុទ្រ ការសាងសង់ទំនប់ពហុប្រយោជន៍ និងការថែទាំ ឬការសាងសង់កំពង់ផែ និងអាកាសយានដ្ឋាន ។

គ. សុខុមាលភាពសង្គម

ការងារសុខុមាលភាពសង្គមជាភារកិច្ចដ៏សំខាន់ដែលរួមមាន : ការថែទាំមនុស្សចាស់ស្របតាមកម្រិតជីវភាព និងសុខភាពរបស់ពួកគាត់ ការថែទាំអនីតិជន (សាលាមត្តេយ្យ និងមជ្ឈមណ្ឌលស្តារយុវនីតិសម្បទា) ជំនួយសម្រាប់ជនពិការកាយសម្បទា និងជនបាត់បង់សិទ្ធិ ។ល។

រូបភាពទី ១០ បង្ហាញអំពីការបែងចែកការចំណាយសម្រាប់សុខុមាលភាពសង្គម ។ ការចំណាយបានប្រើប្រាស់អស់ថវិកាសរុបចំនួន ១៥.៦៩៣ ពាន់លានយ៉េន នៅក្នុងឆ្នាំសារពើពន្ធ២០០៥ ។ ទំហំទឹកប្រាក់ពិតប្រាកដដែលចំណាយដោយខេត្ត គឺ ៤.៤១០ ពាន់លានយ៉េន ចំណែកឯក្រុង គឺ ១២.៨១៤ ពាន់លានយេន ដែលបង្ហាញអំពីបំណែកដ៏ធំដែលចំណាយដោយក្រុង ។ ចំពោះខ្ទង់ចំណាយវិញ សុខុមាលភាពកុមារមានស្មើរតែ ២៩.៩% នៃចំណាយសរុប ហើយសុខុមាលភាពសង្គម សុខុមាលភាពមនុស្សចាស់ សុខុមាលភាពសង្គម និងសាធារណៈសង្គ្រោះ នៅពីក្រោយតរៀងគ្នា ។

ក្នុងចំណោមការងារសុខុមាលភាពសង្គម រដ្ឋទទួលបន្ទុកក្នុងការកសាងស្តង់ដារជាតិសម្រាប់សុខុមាលភាព និងបែងចែកឧបត្ថម្ភធនជំនួយសម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធ ទោះបីជាស្ទើរតែទាំងស្រុងនៃការងារពិតប្រាកដត្រូវបានធ្វើដោយអាជ្ញាធរមូលដ្ឋានក៏ដោយ ។ កាលពីពេលថ្មីៗកន្លងទៅនេះ មានការយកចិត្តទុកដាក់ខ្ពស់ទៅលើហេដ្ឋារចនាសម្ព័ន្ធសុខុមាលភាព (សម្រាប់កុមារ មនុស្សចាស់ និងជនពិការ) ប៉ុន្តែ ការបង្កើតបណ្តាញសហគមន៍សម្រាប់ការគាំទ្រដល់សុខុមាលភាពក៏មានភាពចាំបាច់ផងដែរ ។ មានឧទាហរណ៍ជាច្រើនអំពីសកម្មភាពទាំងនេះរបស់ក្រុង ដោយលើកទឹកចិត្តដល់អង្គការស្ម័គ្រចិត្ត និងជំរុញសកម្មភាពរបស់ពួកគេ ។

**រូបភាពទី ១០ : បំណែងចែកចំណាយសម្រាប់សុខុមាលភាព**

(ឆ្នាំសារពើពន្ធ២០០៥ គិតជាលានយ៉េន)

| | សរុបសុទ្ធ | ខេត្ត | ក្រុង |
|---|---|---|---|
| ការសង្គ្រោះគ្រោះមហន្តរាយ | ០.១% | ០.៣% | ០.១% |
| សាធារណៈសង្គ្រោះ | ១៨.០% | ៦.៧% | ២០.១% |
| សុខុមាលភាពកុមារ | ២៩.៩% | ១៩.៨% | ៣២.៦% |
| សុខុមាលភាពមនុស្សចាស់ | ២៥.២% | ៤១.៧% | ២០.៩% |
| សុខុមាលភាពសង្គម | ២៦.៧% | ៣១.៥% | ២៦.៣% |
| | ១៥.៦៩២.៧០៥ យ៉េន | ៤.៤១០.០៣៩ យ៉េន | ១២.៨១៣.៥១៥យ៉េន |
| | (១០០.០%) | (១០០.០%) | (១០០.០%) |

ឃ. សុខភាព និងអនាម័យ

នៅក្នុងវិស័យសុខភាព និងអនាម័យ រដ្ឋាភិបាលកណ្តាលទទួលបន្ទុកលើការប្រឡងថ្នាក់ជាតិ ដើម្បីជ្រើសរើសវេជ្ជបណ្ឌិត និងគិលានុប្បដ្ឋាក/យិកា ការចេញអាជ្ញាប័ណ្ណដល់ផលិតផលឱសថ ការរៀបចំផែនការទូទៅ និងសេចក្តីណែនាំ។

ស្ទើរតែទាំងស្រុងនៃរដ្ឋបាលពិតប្រាកដ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រជាពលរដ្ឋ ត្រូវបានទទួលរ៉ាប់រងដោយខេត្ត និងក្រុង ។

រូបភាពទី ១១ បង្ហាញអំពីការបែងចែកការចំណាយសម្រាប់សុខភាព និងអនាម័យ ។ ការចំណាយសរុបមានចំនួន ៥.៧០៧ ពាន់លានយ៉េនក្នុងឆ្នាំសារពើពន្ធ២០០៥ ហើយភាគចំណែកដែលប្រើប្រាស់ដោយក្រុង គឺ ៣ ដងលើសភាគចំណែករបស់ខេត្ត។ សុខភាពសាធារណៈមានជាង ៨៦% នៃការចំណាយសរុបរបស់ក្រុង។ ម្យ៉ាងវិញទៀត ក្នុងករណីក្រុង ការចំណាយសម្រាប់ការប្រមូលសំរាម ការបង្ហូរទឹកស្អុយ និងការសម្អាតផ្លូវថ្នល់ មានជាង ៥១% នៃចំណាយសរុប ។

**រូបភាពទី ១០ : បំណែងចែកចំណាយសម្រាប់សុខភាព និងអនាម័យ**

(ឆ្នាំសារពើពន្ធ២០០៥ គិតជាលានយ៉េន)

| | សរុបសុទ្ធ | ខេត្ត | ក្រុង |
|---|---|---|---|
| ការប្រមូលសំរាម ការបង្ហូរទឹកស្អុយ និង ការសម្អាតផ្លូវថ្នល់ | ៤០,០% | ៣,៥% | ៥១,៩% |
| មណ្ឌលសុខភាពសាធារណៈ | ៤,៣% | ៩,២% | ២,៥% |
| ការបង្ការជំងឺរបេង | ០,៤% | ០,៤% | ០,៤% |
| សុខភាពសាធារណៈ | ៥៥,៣% | ៨៦,៩% | ៤៥,២% |
| | ៥.៧០៦,៦៨៣ យ៉េន | ១.៤៨៤,៧៩៨ យ៉េន | ៤.៣៩៥,១៨៥ យ៉េន |
| | (១០០,០%) | (១០០,០%) | (១០០,០%) |

ការផ្តល់សេវាសុខភាព និងអនាម័យភាគច្រើនអនុវត្តដោយមណ្ឌលសុខភាពសាធារណៈ និងមណ្ឌលសុខភាពក្រុង (សូមមើលតារាងទី ២) ។ មណ្ឌលសុខភាពសាធារណៈ (បច្ចុប្បន្ននេះ មាន ៥៣៥ មណ្ឌល) ត្រូវបានបង្កើតឡើងដោយខេត្ត ទីក្រុងចាត់តាំង ទីក្រុងស្នូល ឬសង្កាត់ពិសេស ។ល។ ភារកិច្ចចម្បងរបស់មណ្ឌលសុខភាពទាំងនេះមានដូចខាងក្រោម :

- ការបង្ការជំងឺរបេង និងជំងឺឆ្លងផ្សេងទៀត
- ការណែនាំអំពីសុខភាពមាតា និងទារក
- ការប្រឹក្សាសុខភាពផ្លូវចិត្ត
- ការអប់រំប្រជាពលរដ្ឋអំពីការប្រតិបត្តិអនាម័យល្អ និង
- អធិការកិច្ច និងត្រួតពិនិត្យផ្សេងៗសម្រាប់រក្សាសុខភាពសាធារណៈ នៅក្នុងភោជនីយដ្ឋាន ហាងហែលទឹកសាធារណៈ ហាងកាត់សក់ ។ល។

**តារាងទី ២ ៖ ការប្រៀបធៀបរវាងមណ្ឌលសុខភាពសាធារណៈ និងមណ្ឌលសុខភាពក្រុង**

(គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៦)

| | មណ្ឌលសុខភាពសាធារណៈ (សរុប ៥៣៥ មណ្ឌល) | មណ្ឌលសុខភាពក្រុង (សរុប ២.៣២៣ មណ្ឌល គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៤) |
|---|---|---|
| មូលដ្ឋានច្បាប់ | ច្បាប់ស្តីពីសុខភាពតំបន់ | (សេចក្តីជូនដំណឹងរបស់នាយកប្រតិបត្តិ ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព) |
| អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ | ខេត្ត ក្រុងចាត់តាំង សង្កាត់ពិសេស | ក្រុងសាមញ្ញ |
| បុគ្គលិក | នាយក (មានឋានៈជា វេជ្ជ.)<br>វេជ្ជបណ្ឌិត ទន្តពេទ្យ គីមីវិទូ បសុពេទ្យ<br>គិលានុប្បដ្ឋាក/យិកាសុខភាពសាធារណៈ<br>បោសនាករ វិស្វករពិនិត្យអនាម័យ | គិលានុប្បដ្ឋាក/យិកាសុខភាពសាធារណៈ<br>។ល។ |
| ភារកិច្ច | ចេញសេចក្តីណែនាំអំពី ៖<br>- ការបង្ការជំងឺ ។<br>- សុវត្ថិភាពមាតា ។<br>- សុវត្ថិភាពសុខភាពកុមារ ។<br>ផ្តល់សេវាអនាម័យខាង ៖<br>- អនាម័យបរិស្ថាន ។<br>- អនាម័យចំណីអាហារ ។<br>- ការបង្ការការបំពុល ។ | ផ្តល់សកម្មភាពលើកកំពស់សុខភាពសម្រាប់ប្រជាពលរដ្ឋ<br><br>ផ្តល់សេវាខាង ៖<br>- ការបង្ការជំងឺ ។<br>- សុវត្ថិភាពមាតា ។<br>- សុវត្ថិភាពសុខភាពកុមារ ។ |

ការប្រមូលសំរាម និងកាកសំណល់តាមផ្ទះ គឺជាការងារឯករាជ្យរបស់អាជ្ញាធរមូលដ្ឋាន ។ ដូចដែលបានបង្ហាញក្នុងរូបភាពទី ១១ ការចំណាយសម្រាប់ការប្រមូលសំរាម ការបង្ហូរទឹកស្អុយ និងការសម្អាតផ្លូវថ្នល់ មានជាងពាក់កណ្តាលនៃការចំណាយសរុបសម្រាប់សុខភាព និងអនាម័យក្រុង ដែលក្នុងនោះ ក្រុងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាបំផុត ។ បរិមាណសំរាមមានការកើនឡើង ដោយសារកម្រិតជីវភាពកើនឡើងដែរ ហើយក្រុងកំពុងព្យាយាមយ៉ាងខ្លាំងក្លា ក្នុងការដោះស្រាយបញ្ហាសំរាមអោយមានប្រសិទ្ធភាពបំផុត តាមដែលអាចធ្វើទៅបាន ។ ការបង្ហូរទឹកស្អុយផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងការរក្សាល័ក្ខខ័ណ្ឌអនាម័យអោយបានល្អ និងការធានាអោយទន្លេ និងបឹងមានអនាម័យស្អាត ។ អាស្រ័យហេតុនេះ ជាការចាំបាច់ដែលត្រូវមានរោងចក្រកែច្នៃកាកសំណល់ដែលមានសមត្ថភាពគ្រប់គ្រាន់ ។

ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ក្រុងមានទំនួលខុសត្រូវតែទៅលើការប្រមូលសំរាមផ្ទះបាយប៉ុណ្ណោះ ។ ផលិតករត្រូវមានទំនួលខុសត្រូវចំពោះកំទេចកាកសំណល់ឧស្សាហកម្មរបស់ខ្លួន ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ភាពស្មុគស្មាញនៃបញ្ហាបានបង្ខំអាជ្ញាធរមូលដ្ឋានអោយបង្ហាញអំពីការប្តេជ្ញាចិត្តក្នុងវិស័យនេះ ដូចមានបង្ហាញក្នុងតារាងទី៣ ។

**តារាងទី ៣ : ការប្រមូលកាកសំណល់ : តួនាទីរបស់រដ្ឋាភិបាលកណ្តាល**
**រដ្ឋាភិបាលខេត្ត និងរដ្ឋាភិបាលក្រុង**

| | ប្រភេទកាកសំណល់ | |
|---|---|---|
| | កាកសំណល់មិនមែនឧស្សាហកម្ម (សំរាម និងទឹកស្អុយ) | កាកសំណល់ឧស្សាហកម្ម |
| រដ្ឋាភិបាលកណ្តាល | ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ខេត្ត និងក្រុង | |
| ខេត្ត | ជំនួយផ្នែកបច្ចេកទេសដល់ក្រុង | ព្រាងផែនការប្រមូលកាកសំណល់ឧស្សាហកម្ម ។ ជំនួយផ្នែកបច្ចេកទេសដល់ក្រុង ។ តាមដានក្រុមហ៊ុនប្រមូលកាកសំណល់ឧស្សាហកម្មដោយផ្ទាល់ ។ (ការប្រមូលកាកសំណល់ឧស្សាហកម្ម) |
| ក្រុង | ព្រាងផែនការប្រមូលកាកសំណល់មិនមែនឧស្សាហកម្ម ។ ការប្រមូលកាកសំណល់មិនមែនឧស្សាហកម្ម ។ | (ការប្រមូលកាកសំណល់ឧស្សាហកម្មដែលអាចធ្វើរួមគ្នាជាមួយកាកសំណល់មិនមែនឧស្សាហកម្ម) |

ង. កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម

រដ្ឋាភិបាលមូលដ្ឋានក៏ទទួលបន្ទុកក្នុងការជំរុញវិស័យកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ដើម្បីធានាភាពមានការងារធ្វើ ព្រមទាំងបង្កើនចំណូល និងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋផងដែរ ។

១) កសិកម្ម

ការចំណាយសម្រាប់កសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំនួន ៣.៩៧៨ ពាន់លានយ៉េននៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ។ ភាគចំណែករបស់ខេត្តមានជិតពីរដងនៃភាគចំណែករបស់ក្រុង ។ ការបែងចែកនៅក្នុងរូបភាពទី ១២ បង្ហាញថាការចំណាយសម្រាប់ដីស្រែចំការមាន ៣៩.៧% និងការចំណាយសម្រាប់កសិកម្មមានប្រហែល ២៤.៥% ។ ចំណែកដ៏ធំនៃការចំណាយសម្រាប់ដីស្រែចំការត្រូវបានប្រើប្រាស់ទៅលើគម្រោងកែលម្អដីចំការ ចំណែកឯការចំណាយសម្រាប់កសិកម្មត្រូវបានប្រើប្រាស់ទៅលើគម្រោងកែលម្អកសិកម្ម និងការកែលម្អរចនាសម្ព័ន្ធ ។

ចំណែកដ៏សំខាន់នៃការចំណាយសម្រាប់រុក្ខាប្រមាញ់ ត្រូវបានប្រើប្រាស់ទៅលើការកែលម្អផ្លូវដែលកាប់ដើមឈើ និងផ្នែកដ៏ធំនៃការចំណាយសម្រាប់នេសាទត្រូវបានប្រើប្រាស់ទៅលើការកែលម្អកំពង់ផែនេសាទ ។

## រូបភាពទី ១២ : បំណែងចែកចំណាយសម្រាប់កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(ឆ្នាំសារពើពន្ធ២០០៥ គិតជាលានយ៉េន)

| | សរុបសុទ្ធ ៣.៩៧៨.៣១៦ យ៉េន (១០០.០%) | ខេត្ត ៣.០៣០.៦១៦ យ៉េន (១០០.០%) | ក្រុង ១.៤៨៥.១១៥ យ៉េន (១០០.០%) |
|---|---|---|---|
| នេសាទ | ១១.០% | ១១.៦% | ១០.០% |
| រុក្ខាប្រមាញ់ | ២០.៦% | ២៣.៤% | ១២.២% |
| ដីធ្លីកសិកម្ម | ៣៩.៧% | ៤១.៦% | ៣៩.០% |
| បសុសត្វ | ៤.២% | ៤.១% | ៤.០% |
| កសិកម្ម | ២៤.៥% | ១៩.៣% | ៣៤.៩% |

២) ឧស្សាហកម្ម និងពាណិជ្ជកម្ម

ការចំណាយសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មមានចំនួន ៤.៦២៦ ពាន់លានយ៉េន ក្នុងឆ្នាំសារពើពន្ធ២០០៥ ។ ប្រហែល ៣/៤ គឺជាមូលនិធិកម្ចី និង ៩.៨% ជាឧបត្ថម្ភកធនជំនួយ ។ ក្រៅពីវិធានការទាំងនេះ អាជ្ញាធរមូលដ្ឋានត្រូវអនុវត្តវិធានការពិសេសៗដោយខ្លួនឯងដើម្បីលើកទឹកចិត្ត ឬធ្វើទំនើបកម្មដល់សហគ្រាសធុនតូច/មធ្យម តាមរយៈសេវាពិគ្រោះយោបល់ ឬគម្រោងស្រាវជ្រាវ (សូមមើលរូបភាពទី ១៣) ។

## រូបភាពទី ១៣ : បំណែងចែកចំណាយសម្រាប់ពាណិជ្ជកម្ម និងឧស្សាហកម្ម

(ឆ្នាំសារពើពន្ធ២០០៥ គិតជាលានយ៉េន)

| | កម្ចី | សាធារណការសាមញ្ញ | ឧបត្ថម្ភកធន | ការចំណាយសម្រាប់បុគ្គលិក | ផ្សេងៗ |
|---|---|---|---|---|---|
| សរុបសុទ្ធ ៤.៦២៥.៩៥៤ យ៉េន (១០០.០%) | ៧៤.៤% | ៤.០% | ៩.៨% | ៥.៣% | ៦.៥% |
| ខេត្ត ៣.០៥៥.៤៦២ យ៉េន (១០០.០%) | ៨១.៥% | ២.៤% | ៩.២% | ៣.៦% | ៣.៣% |
| ក្រុង ១.៦១២.២២៥ យ៉េន (១០០.០%) | ៥៩.៣% | ៧.៨% | ១២.២% | ៨.២% | ១២.៥% |

ច. សុវត្ថិភាពសាធារណៈ : ការការពារអគ្គីភ័យ និងនគរបាល

សុវត្ថិភាព និងសន្តិសុខសាធារណៈមានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងសង្គមដែលមានអរិយធម៌រុងរឿង។ ជាការពិតណាស់ដែលថាអាជ្ញាធរមូលដ្ឋានចូលរួមក្នុងសកម្មភាពទាំងនេះក្នុងទម្រង់ជាការការពារអគ្គីភ័យ និងកងកម្លាំងនគរបាល ។

១) ការការពារអគ្គីភ័យ

ផ្ទុយទៅនឹងសម័យកាលមុនសង្គ្រាមដែលរដ្ឋមានទំនួលខុសត្រូវលើការការពារអគ្គីភ័យ ក្រុងទទួលបន្ទុកលើការការពារអគ្គីភ័យនៅសករាជក្រោយសង្គ្រាម ។ ទំនួលខុសត្រូវនេះរួមមានភារកិច្ចជាច្រើនដូចជា ការបង្ការអគ្គីភ័យ ការពន្លត់អគ្គីភ័យ សកម្មភាពសង្គ្រោះនៅពេលមានគ្រោះមហន្តរាយធម្មជាតិ និងសេវាគិលានសង្គ្រោះ ។

នៅក្នុងឆ្នាំ២០០៥ មានអគ្គីភ័យកើតឡើងចំនួន ៥៧.៤៦០ ករណី ដែលបណ្តាលអោយបាត់បង់ទ្រព្យសម្បត្តិជាទឹកប្រាក់ស្មើនឹង ១៣០.០៩៨ លានយ៉េន ។ រូបភាពទី ១៤ បង្ហាញអំពីនិន្នាការថ្មីៗពាក់ព័ន្ធនឹងអគ្គីភ័យ ។

**រូបភាពទី ១៤ : និន្នាការអគ្គីភ័យ**

(ពីឆ្នាំ១៩៩១ ដល់ឆ្នាំ២០០៥)




ដោយសារក្រុងមិនមានលទ្ធភាពអាចដោះស្រាយគ្រោះមហន្តរាយកម្រិតធំ ដូចជា គ្រោះមហន្តរាយដែលបង្កឡើងដោយការរញ្ជួយដី ខ្យល់ព្យុះទីហ្វុង ឬគ្រោះថ្នាក់នៅក្នុងគ្រឹះស្ថានឧស្សាហកម្មតេលសិលាតីមី មានបណ្តាញនៃកិច្ចសហប្រតិបត្តិការទៅវិញទៅមកក្នុងចំណោមក្រុង នគរបាល និងកងកម្លាំងស្វ័យការពារ ។

២) នគរបាល

វិស័យនគរបាលក៏ជាការងារដែលប្រគល់ជូនអាជ្ញាធរមូលដ្ឋានផងដែរនៅក្នុងសករាជក្រោយសង្គ្រាម ហើយខេត្ត មានទំនួលខុសត្រូវជាពិសេស ចំពោះវិស័យនេះ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តម្រូវការខាងសុវត្ថិភាពទាមទារអោយមានរចនាសម្ព័ន្ធនគរបាលតាមឋានានុក្រម ចាប់ពីរដ្ឋរហូតដល់ខេត្ត ។ គណៈកម្មាធិការជាតិទទួលបន្ទុកសុវត្ថិភាពសាធារណៈគ្រប់គ្រងកិច្ចការនគរបាល ហើយក្រោម ឱវាទរបស់គណៈកម្មាធិការនេះ ទីភ្នាក់ងារនគរបាលជាតិអាចរៀបចំប្រព័ន្ធសម្របសម្រួលរវាងខេត្ត និងខេត្ត ។ លើសពី នេះទៅទៀត ខេត្តនីមួយៗមានគណៈកម្មាធិការសុវត្ថិភាពសាធារណៈ និងស្នងការដ្ឋាននគរបាលផ្ទាល់របស់ខ្លួន ហើយនៅ ក្រោមស្ថាប័នទាំងពីរនេះ មានអធិការដ្ឋាននគរបាល ឬប៉ុស្តិ៍នគរបាល *(កូបាន)* ។

នាយកដ្ឋាននគរបាលទទួលបន្ទុកលើការងារជាច្រើន ដូចជា ការស៊ើបអង្កេតឧក្រិដ្ឋកម្ម ការបង្ការបទល្មើសរបស់ អនីតិជន ក្រុមសីលធម៌នគរបាល ការត្រួតពិនិត្យចរាចរណ៍ និងសកម្មភាពប្រឆាំងអំពើភេរវកម្ម ។ កាលពីពេលថ្មីៗកន្លង ទៅនេះ សារៈសំខាន់នៃការពង្រឹងបទបញ្ជាចរាចរណ៍បានកើនឡើងគួរអោយកត់សម្គាល់ ។

នៅក្នុងឆ្នាំ២០០៦ មានគ្រោះថ្នាក់ចរាចរណ៍ចំនួន ៨៨៦.៨៦៤ ករណី និងមានជនរងគ្រោះចំនួន ១.១០៤.៥៥១ នាក់ ក្នុងនោះជនរងគ្រោះចំនួន ៦.៣៥២ នាក់បានស្លាប់ ។ រូបភាពទី ១៥ បង្ហាញអំពីនិន្នាការខាងគ្រោះថ្នាក់ចរាចរណ៍ នៅក្នុងរយៈពេល ២៩ ឆ្នាំកន្លងទៅនេះ ។

**<u>រូបភាពទី ១៥ : និន្នាការគ្រោះថ្នាក់ចរាចរណ៍</u>**

(ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ២០០៦)



ឆ. សហគ្រាសសាធារណៈមូលដ្ឋាន និងក្រុមហ៊ុនផ្តល់សេវាកម្ម

១) សហគ្រាសសាធារណៈមូលដ្ឋាន

អាជ្ញាធរមូលដ្ឋានទទួលបន្ទុកលើសហគ្រាសសាជីវកម្មជាច្រើនប្រភេទដូចជា : ការផ្គត់ផ្គង់ទឹក និងថាមពល ទឹកស្អុយ ការដឹកជញ្ជូនសាធារណៈ និងការថែទាំសុខភាព ។ វិស័យទាំងអស់នេះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

សេវាទាំងនេះត្រូវបានផ្តល់ដោយ "សហគ្រាសសាធារណៈមូលដ្ឋាន" ។ ឧទាហរណ៍មួយចំនួនមានដូចជា : ការផ្គត់ផ្គង់ទឹកសម្រាប់លំនៅដ្ឋាន មន្ទីរពេទ្យ ការផ្គត់ផ្គង់អគ្គិសនី ឬហ្គាស ។ សេវាទាំងនេះត្រូវបានធ្វើឡើង ដើម្បីលើកស្ទួយសុខុមាលភាពរបស់ប្រជាពលរដ្ឋ ប៉ុន្តែ ក្នុងពេលជាមួយគ្នានេះ សេវាទាំងនេះមានឯករាជ្យភាពដូចជាសហគ្រាសដែលមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

សហគ្រាសសាធារណៈមូលដ្ឋានត្រូវបានដំណើរការដោយប្រធានសាជីវកម្ម ហើយវិធីសាស្ត្រគណនេយ្យមានភាពខុសគ្នាពីថវិកាសាមញ្ញ ។ ជាគោលការណ៍ តម្លៃនៃសេវាទាំងនោះត្រូវគ្របដណ្តប់ដោយប្រាក់ថ្លៃសេវាដែលប្រមូលបាន ។

នៅក្នុងឆ្នាំសារពើពន្ធ២០០៥ សហគ្រាសផ្តល់សេវាទឹកស្អុយមានចំនួនច្រើនជាងគេបង្អស់ ហើយសេវាផ្គត់ផ្គង់ទឹកមានចំនួនច្រើនជាងគេលំដាប់ទីពីរ ។

បុគ្គលិកមានចំនួនសរុប ៣៩២.៤៤១ នាក់ ដោយភាគច្រើនបម្រើការងារនៅក្នុងមន្ទីរពេទ្យ ។

២) ក្រុមហ៊ុនផ្តល់សេវាកម្ម

ក្រៅពីសហគ្រាសសាធារណៈ តម្រូវការអោយមានសេវាសាធារណៈកាន់តែទំនើបជាងមុន ជំរុញអោយអាជ្ញាធរមូលដ្ឋានដកពិសោធន៍ជាមួយ "ក្រុមហ៊ុនផ្តល់សេវាកម្ម" ។ ដោយមិនមែនជាកម្មសិទ្ធិរបស់វិស័យសាធារណៈ ឬវិស័យឯកជន ក្រុមហ៊ុនទាំងនេះត្រូវបានបង្កើតឡើងដោយមូលនិធិពីអាជ្ញាធរមូលដ្ឋាន និងសហគ្រាសឯកជន ។

នៅក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងពេលតមកទៀត រលកនៃកំណែទម្រង់រដ្ឋបាល និង "ការធ្វើអោយសកម្ម" នូវវិស័យឯកជន បានជំរុញអោយមានការប្រើប្រាស់ប្រព័ន្ធនេះនៅក្នុងវិស័យអភិវឌ្ឍកន្លែងកំសាន្ត ឬសេវាដឹកជញ្ជូន ។

កាលពីពេលថ្មីៗកន្លងទៅនេះ វិស័យសេវាកម្មនេះបានជួបប្រទះនឹងបញ្ហានានានៅក្នុងការគ្រប់គ្រងក្រុមហ៊ុន ហើយក្រុមហ៊ុនមួយចំនួនបានទទួលបរាជ័យខាងពាណិជ្ជកម្ម ។

## ជំពូកទី ៤ : ទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន

ដូចបានបកស្រាយបំភ្លឺនៅក្នុងជំពូកទី ២ រួចមកហើយ តាមទ្រឹស្តីអាជ្ញាធរមូលដ្ឋានមិនអាចកើតមាន ដោយគ្មានរដ្ឋនោះទេ ហើយចាប់តាំងពីរដ្ឋតំណាងអោយ "ឆន្ទៈសាធារណៈជាតិ" ក្នុងការធានានូវនីត្យានុកូលភាព នៅក្នុងដែនដី និងសម្រាប់ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋានមិនអាចធ្វេសប្រហែសចំពោះវិធានដ៏សំខាន់នេះបានឡើយនៅក្នុងសង្គមដែលមានអរិយធម៌រុងរឿង ។ ម្យ៉ាងវិញទៀត ទោះជាយ៉ាងណាក៏ដោយ អន្តរាគមន៍ច្រើនហួសហេតុរបស់រដ្ឋាភិបាលកណ្តាលអាចធ្វើអោយសហគមន៍មូលដ្ឋានបាត់បង់នូវស្មារតីស្វ័យភាព និងបង្កឧបសគ្គរាំងស្ទះដល់ការគ្រប់គ្រងល្អនៃសេវាសាធារណៈ

មូលដ្ឋាន ដែលផ្តល់ជូនប្រជាពលរដ្ឋដោយផ្ទាល់ ។ អាស្រ័យហេតុនេះ វិន័យស្ថាប័នមានភាពចាំបាច់សម្រាប់បង្កើតប្រព័ន្ធទំនាក់ទំនងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ។

យើងក៏ត្រូវយកចិត្តទុកដាក់ដូចគ្នាផងដែរទៅលើទំនាក់ទំនងក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋាន ។ ខេត្តត្រូវធ្វើកិច្ច-សហប្រតិបត្តិការជាមួយក្រុង ដើម្បីផ្តល់សេវាសាធារណៈអោយបានល្អបំផុតដល់ប្រជាពលរដ្ឋ ។ ការលំបាកនៃរដ្ឋបាលសមរម្យដោយក្រុងតូចៗទាមទារអោយមានប្រភេទផ្សេងៗនៃកិច្ចសហប្រតិបត្តិការ (ទោះបីជានៅមុនដំណាក់កាលរំលាយក្រុងបញ្ចូលគ្នាក៏ដោយ) ។ ជាការពិតណាស់ យើងមិនត្រូវភ្លេចទេថា ការចូលរួមរបស់ខេត្តជាមួយក្រុងត្រូវធ្វើឡើង ដោយផ្អែកលើច្បាប់ ឬបទបញ្ជារបស់រដ្ឋាភិបាលទៅតាមច្បាប់ ។

ទោះបីជានៅពេលអាជ្ញាធរមូលដ្ឋានជានីតិបុគ្គលដែលមានឯករាជ្យភាពពីគ្នាទៅវិញទៅមក និងមានឯករាជ្យភាពពីរដ្ឋាភិបាលកណ្តាលក៏ដោយ ក៏វត្តមាននៃទំនាក់ទំនងរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន មិនអាចត្រូវបានព្រងើយកន្តើយឡើយ ។ អាស្រ័យហេតុនេះ ជំពូកចុងក្រោយនៃអត្ថបទនេះនឹងរៀបរាប់អំពីទំនាក់ទំនងរវាងរដ្ឋាភិបាលទាំងពីរថ្នាក់នេះ ។

## ១. ទំនាក់ទំនងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន

ដូចយើងបានឃើញនៅក្នុងជំពូកទី ៣ រួចមកហើយ ប្រភេទនៃភារកិច្ចរបស់រដ្ឋាភិបាលមូលដ្ឋានមានភាពខុសគ្នាពីភារកិច្ចដើមរបស់ខ្លួន ។ ភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់តម្រូវអោយមាន "ការត្រួតពិនិត្យ" លើការអនុវត្ត ច្រើនជាងការងារស្វ័យត ពាក់ព័ន្ធទៅនឹងវត្តមានរបស់រដ្ឋ ។ ភាពខុសគ្នានេះឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាននៅក្នុងប្រភេទការងារនីមួយៗ ។ មធ្យោបាយនៃការចូលរួមត្រូវបានពង្រឹងចំពោះភារកិច្ចទទួលប្រតិភូកម្ម ។

នៅថ្នាក់ក្រុង ដែនត្រួតពិនិត្យរបស់រដ្ឋាភិបាលកណ្តាលជាទូទៅត្រូវបានប្រគល់ជូនអភិបាលខេត្ត ។ តាមពិតទៅការចូលរួមដូចខាងក្រោមត្រូវបានអនុវត្តចំពោះអភិបាលខេត្ត ។

ទិដ្ឋភាពដ៏សំខាន់នៃច្បាប់ថ្មីស្តីពីស្វ័យភាពមូលដ្ឋាន ឆ្នាំ២០០០ គឺការដាក់កំហិតការចូលរួមរបស់រដ្ឋាភិបាលកណ្តាល ឬរដ្ឋាភិបាលខេត្តទៅក្នុងការគ្រប់គ្រងកិច្ចការមូលដ្ឋាន អោយនៅត្រឹមកម្រិតអប្បបរមា ដែលចាំបាច់ដល់ការសម្រេចគោលដៅ និងការធ្វើបញ្ជីប្រភេទជាមូលដ្ឋានទាំងអស់នៃការចូលរួមនៅក្នុងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ។

### ក. គោលការណ៍គ្រឹះនៃការចូលរួម

ការចូលរួមតម្រូវអោយមាន ដោយផ្អែកលើច្បាប់ ឬបទបញ្ជារបស់រដ្ឋាភិបាលស្របតាមច្បាប់ ។ ការចូលរួមបែបនេះរួមមានមិនត្រឹមតែមធ្យោបាយបង្គាប់បញ្ជា ដូចជា ការអនុញ្ញាត ឬសេចក្តីណែនាំ ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមធ្យោបាយមិនបង្គាប់បញ្ជាទៀតផង ដូចជា ការផ្តល់យោបល់ និងអនុសាសន៍ ។ ដើម្បីអោយការចូលរួមមានតម្លាភាព និងយុត្តិធម៌ ភាគីដែលចូលរួមត្រូវផ្សព្វផ្សាយឯកសារ ដែលរៀបរាប់អំពីអត្ថន័យនៃការចូលរួមរបស់ខ្លួន នៅពេលភាគីផ្សេងទៀតត្រូវការ ។ លក្ខណៈវិនិច្ឆ័យត្រួតពិនិត្យសម្រាប់ការអនុញ្ញាតត្រូវបង្កើតឡើង ហើយត្រូវកំណត់រយៈពេលដំណើរការស្តង់ដារ ។

ខ. ប្រភេទជាមូលដ្ឋាននៃការចូលរួម

ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានចែងអំពីប្រភេទជាមូលដ្ឋាននៃការចូលរួម ដែលត្រូវអនុវត្តតាមដែលអាចធ្វើទៅបាន។

ចំពោះការងារស្វ័យត ការផ្តល់យោបល់ និងអនុសាសន៍ ការស្នើសុំដាក់ឯកសារ ការពិគ្រោះយោបល់ និងការស្នើសុំវិធានការកែតម្រូវ គឺជាប្រភេទជាមូលដ្ឋាន ។ ចំពោះភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់ វិធានការដែលមានលក្ខណៈបង្គាប់បញ្ជាខ្លាំង ដូចជាកិច្ចព្រមព្រៀង ការអនុញ្ញាត សេចក្តីណែនាំ និងការអនុវត្តដោយសិទ្ធិប្រទាន ត្រូវបានដាក់បន្ថែមទៅក្នុងបញ្ជីខាងលើ ។

គ. ការចូលរួមផ្អែកតាមច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន

ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានរួមបញ្ចូលបទបញ្ញត្តិខាងក្រោមនេះ ដែលអាចជាមូលដ្ឋានសម្រាប់ការចូលរួមដោយរដ្ឋមន្ត្រី និងអង្គនីតិប្រតិបត្តិថ្នាក់ជាតិផ្សេងទៀត ។

១) ការផ្តល់យោបល់បច្ចេកទេស និងអនុសាសន៍ ការស្នើសុំដាក់ឯកសារ ( មាត្រា ២៤៥-៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន )

រដ្ឋមន្ត្រី និងស្ថាប័នផ្សេងទៀតត្រូវផ្តល់នូវយោបល់បច្ចេកទេសសមស្រប និងអនុសាសន៍ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងកិច្ចការមូលដ្ឋាន ហើយរដ្ឋមន្ត្រី និងស្ថាប័នក៏ត្រូវស្នើសុំឯកសារចាំបាច់សម្រាប់ការផ្តល់យោបល់ និងអនុសាសន៍ផងដែរ ។ ម្យ៉ាងវិញទៀត អង្គភាពសាធារណៈមូលដ្ឋានមានសិទ្ធិស្នើសុំយោបល់ និងអនុសាសន៍ពីរដ្ឋមន្ត្រី និងស្ថាប័នទាំងនោះ ។

២) ការស្នើសុំវិធានការកែតម្រូវ ( មាត្រា ២៤៥-៥ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន )

ប្រសិនបើមានការរំលោភច្បាប់នៅក្នុងការគ្រប់គ្រងភារកិច្ចស្វ័យតរបស់អង្គភាពសាធារណៈមូលដ្ឋាន ត្រូវមានការកែតម្រូវដោយស្ម័គ្រចិត្ត ។ ប៉ុន្តែ ក្នុងករណីពិសេសដែលវិធានការកែតម្រូវដោយស្ម័គ្រចិត្ត មិនត្រូវបានអនុវត្ត រដ្ឋមន្ត្រី និងស្ថាប័នផ្សេងទៀតត្រូវស្នើសុំវិធានការកែតម្រូវដើម្បីរក្សាការអនុវត្តរដ្ឋបាលសមស្រប ។

៣) សេចក្តីណែនាំកែតម្រូវ ( មាត្រា ២៤៥-៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន )

រដ្ឋមន្ត្រី និងស្ថាប័នផ្សេងទៀតត្រូវចេញសេចក្តីណែនាំកែតម្រូវ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងខុសច្បាប់នៃភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់ ។ សេចក្តីណែនាំកែតម្រូវអាចរួមមានវិធានការជាក់ស្តែងជាអនុសាសន៍ដែលត្រូវអនុវត្ត ដែលការស្នើសុំវិធានការកែតម្រូវមិនអាចឡើយ ។

៤) ការអនុវត្តដោយសិទ្ធិប្រទាន ( មាត្រា ២៤៥-៨ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន )

ប្រសិនបើវិធានការខាងលើមិនមានប្រសិទ្ធភាព នៅក្នុងការកែតម្រូវការគ្រប់គ្រងភារកិច្ចអនុញ្ញាតតាមផ្លូវច្បាប់ដោយរដ្ឋាភិបាលខេត្តនោះទេ រដ្ឋមន្ត្រី និងស្ថាប័នផ្សេងទៀតអាចអនុវត្តភារកិច្ចសិទ្ធិប្រទាន ។ ប្រការនេះអាចកើតមានឡើងតែនៅពេលខេត្តធ្វើមិនដឹងមិនឮអំពីដីកាតុលាការដែលបង្គាប់ខេត្តអោយចាត់វិធានការកែតម្រូវ ។

រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍មានមុខងារពិសេសផ្សេងទៀតដែលចែងដោយច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន : យោបល់បច្ចេកទេស និងអនុសាសន៍ពាក់ព័ន្ធទៅនឹងការធ្វើអោយមានប្រសិទ្ធិភាពការរៀបចំ និងការគ្រប់គ្រងអង្គភាពមូលដ្ឋានសាធារណៈ ( មាត្រា ២៥២-១៧-៥ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) និងអធិការកិច្ចបញ្ហាហិរញ្ញវត្ថុមូលដ្ឋាន ( មាត្រា ២៥២-១៧-៦ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ) ។

ឃ. ការដោះស្រាយវិវាទរវាងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ឬថ្នាក់ខេត្ត និងថ្នាក់ក្រុង

ច្បាប់ថ្មីស្តីពីស្វ័យភាពមូលដ្ឋានបានបង្កើតនូវយន្តការដោះស្រាយវិវាទថ្មីរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងអង្គភាពសាធារណៈមូលដ្ឋានដើម្បីធានាប្រកបដោយប្រសិទ្ធភាពនូវភាពជាដៃគូរ និងទំនាក់ទំនងសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរនេះ និងការចូលរួមសម្រុះសម្រួលដោយរដ្ឋាភិបាលជាតិ ។

ប្រសិនបើអង្គនីតិប្រតិបត្តិនៃអង្គភាពសាធារណៈមូលដ្ឋាន មានការមិនពេញចិត្តចំពោះការចូលរួមដោយរដ្ឋាភិបាលជាតិ អង្គនីតិប្រតិបត្តិនោះអាចប្តឹងអោយមានការពិនិត្យរឿងក្តីប្រឆាំងនឹងសិទ្ធិអំណាចចូលរួម ទៅគណៈកម្មាធិការទទួលបន្ទុកដោះស្រាយវិវាទរវាងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ ប្រភេទនៃអន្តរាគមន៍ដែលគណៈកម្មាធិការនេះអាចពិនិត្យ មានដូចជា ការអនុវត្តអំណាចរបស់រដ្ឋាភិបាល ការលុបចោល ឬការពិគ្រោះយោបល់ ។

ប្រសិនបើគណៈកម្មាធិការពិនិត្យឃើញថាការចូលរួមក្នុងការងារស្វ័យតមានភាពខុសច្បាប់ ឬមិនសមហេតុផលដោយសារតែរដ្ឋាភិបាលជាតិមិនអើពើនឹងស្វ័យភាព និងឯករាជ្យភាពរបស់មូលដ្ឋាន ឬពិនិត្យឃើញថាកិច្ចការអនុញ្ញាតតាមផ្លូវច្បាប់មានភាពខុសច្បាប់ គណៈកម្មាធិការអាចស្នើអោយរដ្ឋាភិបាលជាតិចាត់វិធានការចាំបាច់ ។

អាជ្ញាធរដែលទទួលបានការស្នើសុំត្រូវតែចាត់វិធានការចាំបាច់ ។ ប្រសិនបើអង្គភាពសាធារណៈមូលដ្ឋាននៅតែមិនពេញចិត្តចំពោះវិធានការទាំងនេះ អង្គភាពសាធារណៈមូលដ្ឋានអាចបញ្ជូនរឿងក្តីនេះទៅតុលាការ ។

ប្រព័ន្ធស្នងការទទួលបន្ទុកដោះស្រាយវិវាទមូលដ្ឋាន ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងការចូលរួមដោយរដ្ឋាភិបាលខេត្ត ។ ស្នងការត្រូវពិនិត្យរឿងក្តីដែលប្តឹងដោយរដ្ឋាភិបាលក្រុង ដែលមានការមិនពេញចិត្តចំពោះការចូលរួមរបស់រដ្ឋាភិបាលខេត្ត ហើយប្រសិនបើចាំបាច់ ស្នើអោយរដ្ឋាភិបាលខេត្តចាត់វិធានការចាំបាច់ ។

## ២. កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលមូលដ្ឋាន

ដូចតារាងទី ៤ បានបង្ហាញ ប្រជាជន និងទំហំនៃអាជ្ញាធរមូលដ្ឋាន (ជាពិសេសរបស់ក្រុង) មានភាពខុសគ្នាពីមួយទៅមួយទៀត ។ ជាញឹកញាប់ ឃុំ និងភូមិតូចៗបង្ហាញនូវអសមត្ថភាពក្នុងស្វ័យគ្រប់គ្រង អាស្រ័យហេតុនេះហើយបានជាការរំលាយក្រុងបញ្ចូលគ្នាត្រូវបានជំរុញយ៉ាងខ្លាំង ។

ទោះជាយ៉ាងណាក៏ដោយ តម្រូវការអោយមានរដ្ឋបាលប្រកបដោយប្រសិទ្ធភាព ឆ្លងកាត់ព្រំដែនរបស់អាជ្ញាធរមូលដ្ឋាន ហើយទោះបីជាមានការគោរពឯកត្តភាពសម្រាប់ក្រុងនីមួយៗក៏ដោយ ក៏ការងារជាច្រើនត្រូវតែបំពេញក្នុងទម្រង់ជាកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋាន ។ ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានចែងអំពីវិធានការសហប្រតិបត្តិការជាច្រើន ទោះជាធូររលុង ឬតឹងរ៉ឹងក៏ដោយ ដើម្បីអោយតំបន់នីមួយៗប្រើប្រាស់នូវវិធានការសមស្របបំផុត នៅពេលសម្របទៅនឹងតម្រូវការរដ្ឋបាល វប្បធម៌ និងសង្គម ។

វិធីសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គភាពមូលដ្ឋានមានដូចខាងក្រោម :

- ការបញ្ជូនបុគ្គលិក ( មាត្រា ២៥២-៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ) : អង្គនីតិប្រតិបត្តិរបស់អាជ្ញាធរមូលដ្ឋានអាចស្នើសុំអោយអាជ្ញាធរផ្សេងទៀតបញ្ជូនបុគ្គលិកសម្រាប់ការគ្រប់គ្រង និងអនុវត្តការងារ ។
- ការបង្កើតរួមគ្នានូវអង្គនីតិប្រតិបត្តិ ( មាត្រា ២៥៧-៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ) : អាជ្ញាធរមូលដ្ឋានជាច្រើនអាចព្រមព្រៀងគ្នាបង្កើតអង្គនីតិប្រតិបត្តិមួយចំនួន ( ក្រុមប្រឹក្សារដ្ឋបាល ឬអង្គការសាមញ្ញ) រួមគ្នា ។
- ការផ្ទេរការងារ ( មាត្រា ២៥២-១៤ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ) : អាជ្ញាធរមូលដ្ឋានអាចផ្ទេរការងាររបស់ខ្លួនមួយផ្នែកទៅអោយអង្គភាពមួយផ្សេងទៀត តាមកការព្រមព្រៀងគ្នាទៅវិញទៅមក និង
- ក្រុមប្រឹក្សាអង្គភាពសាធារណៈមូលដ្ឋាន ( មាត្រា ២៥២-២ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ) : អាជ្ញាធរមូលដ្ឋានជាច្រើនអាចព្រមព្រៀងគ្នាបង្កើតក្រុមប្រឹក្សាមួយ ក្នុងគោលដៅរដ្ឋបាល សម្របសម្រួលសកម្មភាពរបស់ខ្លួនរួមគ្នា និងរៀបចំផែនការតំបន់ ។ ការរៀបចំប្រភេទនេះត្រូវមានទម្រង់បែបបទជាច្រើន ហើយអង្គភាពមូលដ្ឋានទំនងជាចូលចិត្ត កិច្ចប្រជុំពិគ្រោះយោបល់ តាមភាពជាក់ស្តែង ដែលគ្មានឋានៈផ្លូវច្បាប់ ។

## តារាងទី ៤ : ប្រជាជន និងផ្ទៃដីរបស់អាជ្ញាធរមូលដ្ឋាន (ខែមីនា ឆ្នាំ២០០៧)

ាជន

| ប្រជាជន | ខេត្ត | ប្រជាជន | ទីក្រុង | សង្កាត់ពិសេស | ប្រជាជន | ឃុំ/ភូមិ |
|---|---|---|---|---|---|---|
| ៃសពី ១០ លាននាក់ | ១ | លើសពី ១ លាននាក់ | ១០ | | លើសពី ៤០.០០០ នាក់ | ២១ |
| ទៅ ១០ លាននាក់ | ៨ | ៥០០.០០០ ទៅ ១ លាននាក់ | ១៥ | ៧ | ៣០.០០០ ទៅ ៤០.០០០ នាក់ | ៥៩ |
| ទៅ ៥ លាននាក់ | ១ | ៣០០.០០០ ទៅ ៥០០.០០០ នាក់ | ៤៦ | ៦ | ២០.០០០ ទៅ ៣០.០០០ នាក់ | ១៥១ |
| ទៅ ៣ លាននាក់ | ១០ | ២០០.០០០ ទៅ ៣០០.០០០ នាក់ | ៣៨ | ៤ | ១០.០០០ ទៅ ២០.០០០ នាក់ | ៣១៨ |
| ទៅ ២ លាននាក់ | ២០ | ១០០.០០០ ទៅ ២០០.០០០ នាក់ | ១៥១ | ៥ | ៥.០០០ ទៅ ១០.០០០ នាក់ | ២៦៨ |
| ជាង ១ លាននាក់ | ៧ | ៥០.០០០ ទៅ ១០០.០០០ នាក់ | ២៧៧ | ០ | ១.០០០ ទៅ ៥.០០០ នាក់ | ២០៣ |
| | | ៣០.០០០ ទៅ ៥០.០០០ នាក់ | ១៨៦ | ១ | តិចជាង ១.០០០ នាក់ | ២៤ |
| | | តិចជាង ៣០.០០០ នាក់ | ៥៤ | | | |
| សរុប | ៤៧ | សរុប | ៧៧៧ | ២៣ | សរុប | ១.០៤៤ |

ផ្ទៃដី

| ផ្ទៃដី | ខេត្ត | ផ្ទៃដី | ទីក្រុង | សង្កាត់ពិសេស | ឃុំ/ភូមិ |
|---|---|---|---|---|---|
| លើសពី ១០.០០០ គម$^{២}$ | ៧ | លើសពី ១.០០០ គម$^{២}$ | ១៨ | | ៨ |
| ៥.០០០ ទៅ ១០.០០០ គម$^{២}$ | ២១ | ៥០០ ទៅ ១.០០០ គម$^{២}$ | ១១៩ | | ៥៧ |
| ៣.០០០ ទៅ ៥.០០០ គម$^{២}$ | ១៣ | ៣០០ ទៅ ៥០០ គម$^{២}$ | ៩៧ | | ៨៥ |
| ២.០០០ ទៅ ៣.០០០ គម$^{២}$ | ៤ | ២.០០ ទៅ ៣០០ គម$^{២}$ | ១១៨ | | ១១៩ |
| ១.០០០ ទៅ ២.០០០ គម$^{២}$ | ២ | ១០០ ទៅ ២០០ គម$^{២}$ | ១៦៤ | | ២០២ |
| | | ៥០ ទៅ ១០០ គម$^{២}$ | ១១៨ | ៣ | ២១៤ |
| | | ២៥ ទៅ ៥០ គម$^{២}$ | ៧២ | ៦ | ១៨១ |
| | | តិចជាង ២៥ គម$^{២}$ | ៧១ | ១៤ | ១៧៨ |
| សរុប | ៤៧ | សរុប | ៧៧៧ | ២៣ | ១.០៤៤ |

អ្វីដែលមិនត្រូវបំភ្លេចគឺប្រភេទផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការដែលមានអត្តសញ្ញាណស្របច្បាប់ ហើយមានភាពតឹងរ៉ឹងជាងវិធីសាស្ត្រដែលបានរៀបរាប់ខាងលើរួមមាន សហករណ៍របស់អាជ្ញាធរមូលដ្ឋាន ឬសាជីវកម្មអភិវឌ្ឍមូលដ្ឋាន ។ ការប្រើប្រាស់សហករណ៍ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ហើយសហករណ៍ទាំងនោះផ្តល់នូវលទ្ធភាពល្អប្រសើរជាច្រើន ។ បច្ចុប្បន្ននេះ មានសហករណ៍ប្រហែល ២.៦២៦ ដែលភាគច្រើនត្រូវបានបង្កើតឡើងដោយក្រុង ។ ផ្ទុយទៅវិញ មានសាជីវកម្មអភិវឌ្ឍមូលដ្ឋានតែមួយប៉ុណ្ណោះនាពេលបច្ចុប្បន្ននេះ ប្រហែលដោយសារវត្ថុបំណងនៅមានកម្រិត ដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬលទ្ធកម្មដីធ្លីជាដើម ។

អភិបាលកិច្ចមូលដ្ឋាន (ការរៀបចំតាក់តែងគោលនយោបាយ
និងសង្គមស៊ីវិល)
ឆ្នាំសារពើពន្ធ ២០០៧

# ប្រព័ន្ធបុគ្គលិកសេវាសាធារណៈមូលដ្ឋាន
# នៅក្នុងប្រទេសជប៉ុន

~មាតិកា~


**ជំពូកទី ១ ៖ សេចក្ដីផ្ដើម**

១. ការបង្កើតប្រព័ន្ធសេវាសាធារណៈមូលដ្ឋាននៅក្នុងប្រទេសជប៉ុន ............ ១

២. ប្រភេទ ចំណាត់ថ្នាក់ និងចំនួនសេវាសាធារណៈមូលដ្ឋាន............ ២

៣. វចនាសម្ព័ន្ធច្បាប់អនុវត្តចំពោះបុគ្គលិករាជការមូលដ្ឋាន............ ៥

**ជំពូកទី ២ ៖ ទីភ្នាក់ងារបុគ្គលិក**

១. ប្រភេទទីភ្នាក់ងារបុគ្គលិក............ ៦

២. អាជ្ញាធរតែងតាំង............ ៦

៣. គណៈកម្មាធិការបុគ្គលិក និងគណៈកម្មាធិការសមភាព ............ ៦

**ជំពូកទី ៣ ៖ ការតែងតាំង និងការបំពេញភារកិច្ច**

១. ការតែងតាំងបុគ្គលិកសេវាសាធារណៈមូលដ្ឋាន............ ៨

២. ភារកិច្ចរបស់បុគ្គលិក ............ ១១

៣. វិធានការពាក់ព័ន្ធនឹងការផ្លាស់ប្ដូរឋានៈ និងវិធានការបទវិន័យ ............ ១៦

៤. ប្រព័ន្ធកម្រិតអាយុចូលនិវត្តន៍............ ២០

**ជំពូកទី ៤ ៖ សំណង និងលក្ខខណ្ឌការងារផ្សេងៗ**

១. សំណង ............ ២២

២. ម៉ោងធ្វើការ ថ្ងៃឈប់សម្រាក និងច្បាប់ឈប់សម្រាក ............ ២៥

៣. ប្រព័ន្ធជួយគ្នាទៅវិញទៅមក............ ២៨

៤. ប្រព័ន្ធទូទាត់សងចំពោះគ្រោះថ្នាក់ក្នុងសេវាសាធារណៈមូលដ្ឋាន ............ ៣០

**ជំពូកទី ៥ ៖ សិទ្ធិរបស់កម្មករ-និយោជិត**

១. សិទ្ធិបង្កើតអង្គការ............ ៣១

២. សិទ្ធិចរចារួម ............ ៣២

៣. ការហាមឃាត់វិធានការវិវាទ............ ៣២

**ជំពូកទី ៦ ៖ សុវត្ថិភាពនៃអត្ថប្រយោជន៍របស់បុគ្គលិក**

១. ការដាក់ពាក្យសុំវិធានការស្ដីពីលក្ខខណ្ឌការងារ ............ ៣៣

២. ការដាក់បណ្ដឹងជំទាស់ប្រឆាំងនឹងវិធានការអវិជ្ជមាន............ ៣៣

# ជំពូកទី ១ : សេចក្តីផ្តើម

## ១. ការបង្កើតប្រព័ន្ធសេវាសាធារណៈមូលដ្ឋាននៅក្នុងប្រទេសជប៉ុន

### (១) បុគ្គលិករាជការមូលដ្ឋាន ជាអ្នកបម្រើរបស់សហគមន៍ទាំងមូល

រដ្ឋធម្មនុញ្ញនៃប្រទេសជប៉ុន មាត្រា ១៥ កថាខ័ណ្ឌទី ២ ចែងថា មន្ត្រីរាជការទាំងអស់គឺជាអ្នកបម្រើរបស់សហគមន៍ទាំងមូល មិនមែនរបស់ក្រុមមានផលប្រយោជន៍ពិសេសណាមួយនៃសហគមន៍នោះឡើយ ។ បញ្ញត្តិនេះបង្ហាញអំពីគោលការណ៍ធម្មជាតិដែលបុគ្គលិករដ្ឋាភិបាលមាន ជាពិសេសអំពីចរិតលក្ខណៈមូលដ្ឋានគ្រឹះជាអ្នកបម្រើរបស់ប្រជាជនទាំងអស់ដែលជាម្ចាស់អំណាចនៅក្នុងរដ្ឋប្រជាធិបតេយ្យ ។ លទ្ធិដដែលនេះមានចែងនៅក្នុងមាត្រា ៣០ នៃច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ដែលជាច្បាប់គ្រឹះសម្រាប់ប្រព័ន្ធសេវាសាធារណៈមូលដ្ឋាន ដែលចែងថា មន្ត្រីរាជការមូលដ្ឋានគ្រប់រូប ក្នុងឋានៈជាអ្នកបម្រើរបស់សហគមន៍ទាំងមូលត្រូវបំពេញភារកិច្ចរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់សាធារណជន និងប្រឹងអោយអស់សមត្ថភាពដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

### (២) មន្ត្រីរាជការមូលដ្ឋានជាកម្មករ-និយោជិត

មន្ត្រីរាជការមូលដ្ឋានគឺជា "កម្មករ-និយោជិត" ដែលចិញ្ចឹមជីវិតដោយប្រាក់បៀវត្សរ៍ដែលត្រូវបានបង់ជាការតបស្នងសម្រាប់ការងាររបស់ពួកគេក្នុងឋានៈជាមន្ត្រីរាជការ ។ ប៉ុន្តែ មានភាពខុសគ្នាយ៉ាងខ្លាំងពីកម្មករ-និយោជិតឯកជន ។ សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ ពលករដែលកម្មករ-និយោជិតឯកជនទទួលបានមានកំហិតចំពោះមន្ត្រីរាជការ ។ ឧទាហរណ៍ មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញជប៉ុនចែងថា កម្មករ-និយោជិតមានសិទ្ធិបង្កើតអង្គការ ចរចា និងធ្វើសកម្មភាពរួមគ្នា ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន ប៉ុន្តែសិទ្ធិទាំងនោះ ត្រូវបានដាក់កំហិតចំពោះមន្ត្រីរាជការ ។

ហេតុផលគឺថា មន្ត្រីរាជការមានចរិតលក្ខណៈពិសេសជាអ្នកបម្រើរបស់ប្រជាជន ។

### (៣) ឱកាសស្មើភាពគ្នាដើម្បីចូលបម្រើការងារជាមន្ត្រីរាជការ និងប្រព័ន្ធគុណសម្បត្តិ

នៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ មន្ត្រីរាជការទាំងអស់ត្រូវធ្វើជាអ្នកតំណាងរបស់ប្រជាជនទាំងអស់ ឬនៅពេលខ្លះរបស់អ្នករស់នៅក្នុងមូលដ្ឋាន ។ ដូច្នេះ មុខដំណែងក្នុងមុខងារសាធារណៈមិនត្រូវកាន់កាប់ផ្តាច់មុខដោយបុគ្គលមានបុព្វសិទ្ធិឡើយ ។ ឱកាសដើម្បីចូលបម្រើការងារក្នុងមុខងារសាធារណៈ ត្រូវបើកចំហចំពោះប្រជាពលរដ្ឋគ្រប់រូប ។ វិធាននេះមានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងជាមួយគោលការណ៍ប្រជាធិបតេយ្យ ដែលផ្អែកលើសមភាពគ្រឹះនៃប្រជាពលរដ្ឋទាំងអស់ ។ ក្នុងពេលជាមួយគ្នានេះផងដែរ ការតែងតាំង ឬការដំឡើងឋានៈ ត្រូវសម្រេចដោយផ្អែកលើការវាយតម្លៃឥតលម្អៀងលើស្នាដៃការងារ ដើម្បីធានាការអនុវត្តកិច្ចការ សាធារណៈប្រកបដោយប្រសិទ្ធភាព ។ ដូច្នេះ "ប្រព័ន្ធគុណ-សម្បត្តិ" ក៏ត្រូវបានអនុម័តយក និងអនុវត្តចំពោះបញ្ហាមួយចំនួនដូចជា ការទទួលអោយបម្រើការងារ ការដំឡើងឋានៈ ការដំឡើងប្រាក់បៀវត្សរ៍ ។ល។

(៤) <u>សុវត្ថិភាពនៃអព្យាក្រឹត្យភាពផ្នែកនយោបាយ</u>

ទ្រង់ទ្រាយមួយទៀតនៃប្រព័ន្ធបុគ្គលិករាជការមូលដ្ឋានទំនើប គឺទាក់ទងនឹងការធានាអព្យាក្រឹត្យភាពផ្នែកនយោបាយនៃបុគ្គលិករាជការថ្នាក់មូលដ្ឋាន ។ ចំណុចនេះត្រូវបានតម្រូវដោយយោងលើមូលហេតុពីរយ៉ាងគឺ : មូលហេតុទីមួយគឺដើម្បីធានាស្ថិរភាព និងនិរន្តរភាពនៃរដ្ឋបាលសាធារណៈ តាមរយៈការបែងចែករដ្ឋបាលសាធារណៈអោយដាច់គ្នាពីនយោបាយ ។ ស្ថិរភាពនៃ រដ្ឋបាលសាធារណៈអាចធានាបានតែដោយសារការបែងចែកសេវាសាធារណៈជាពីរប្រភេទគឺ : នយោបាយ និងរដ្ឋបាល ។ អ្នកនយោបាយកាន់មុខដំណែងសម្រាប់អាណត្តិជាក់លាក់ណាមួយ ចំណែកអ្នករដ្ឋបាល មិនស្ថិតក្រោមការផ្លាស់ប្តូរ ដោយសារការបោះឆ្នោតផ្នែកនយោបាយឡើយ ។

មូលហេតុទីពីរគឺដើម្បីធានាការងារ និងឋានៈរបស់បុគ្គលិករាជការ តាមរយៈការធានាអព្យាក្រឹត្យភាពផ្នែកនយោបាយ ហើយជាលទ្ធផល ការពារពួកគេពីការបាត់បង់ការងារក្នុងប្រព័ន្ធបកស្បែក ។ ប្រសិនបើមន្ត្រីរាជការបានចូលរួមក្នុងសកម្មភាពនយោបាយ ការងារ ឬដំណែងរបស់ពួកគេ នឹងត្រូវប្រែប្រួលដោយសារការផ្លាស់ប្តូរផ្នែកនយោបាយ ។

## ២. ប្រភេទ ចំណាត់ថ្នាក់ និងចំនួនសេវាសាធារណៈមូលដ្ឋាន

(១) <u>ដែនបុគ្គលិករាជការមូលដ្ឋាន</u>

បុគ្គលិកទាំងអស់ដែលធ្វើការអោយអង្គភាពមូលដ្ឋាន ហៅថាបុគ្គលិករាជការមូលដ្ឋាន ( មាត្រា ២ នៃច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន) ។

ប៉ុន្តែ ចំណុចនេះមិនសុទ្ធតែច្បាស់លាស់រាល់ពេលឡើយ ថាតើកម្មករ-និយោជិតម្នាក់គឺជាបុគ្គលិករាជការមូលដ្ឋាន ឬយ៉ាងណានោះទេ ព្រោះដែននៃបុគ្គលិករាជការមូលដ្ឋាន មានភាពទំលំទូលាយណាស់ ។

ចំណុចទាំងបីខាងក្រោមនេះ គឺជាស្តង់ដារទូទៅដើម្បីកំណត់ថាតើអ្នកធ្វើការម្នាក់គឺជាបុគ្គលិករាជការមូលដ្ឋាន ឬមិនមែន ។

ប្រសិនបើអ្នកធ្វើការបំពេញតាមស្តង់ដារទាំងបីខាងក្រោមនេះ មានន័យថាគាត់គឺជាបុគ្គលិករាជការមូលដ្ឋាន ។

(ក) ចរិតលក្ខណៈនៃការងារ

បុគ្គលនោះបានចូលធ្វើការងារក្នុងអង្គភាពមូលដ្ឋាន ។

(ខ) របៀបនៃការតែងតាំង

បុគ្គលនេះត្រូវបានតែងតាំងដោយផ្នែកទទួលខុសត្រូវនៃអង្គភាពមូលដ្ឋាន ។

(គ) ប្រភពនៃប្រាក់បៀវត្សរ៍

ប្រាក់បៀវត្សរ៍ ( ប្រាក់តបស្នង) ត្រូវបើកអោយដោយអង្គភាពមូលដ្ឋាន ដើម្បីជាលាភការសម្រាប់ការងារ ។

(២) <u>សេវាពិសេស និងសេវាធម្មតានៅក្នុងរដ្ឋាភិបាលមូលដ្ឋាន</u>

សេវាសាធារណៈមូលដ្ឋានត្រូវចាត់ថ្នាក់ថាជា "សេវាសាធារណៈធម្មតា" និង "សេវាសាធារណៈពិសេស" ។ មូលហេតុដែលការចាត់ថ្នាក់នេះមានភាពសំខាន់ គឺដោយសារច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន អនុវត្តតែចំពោះបុគ្គលិក

រាជការមូលដ្ឋានដែលបានចូលរួមក្នុងសេវាសាធារណៈធម្មតាប៉ុណ្ណោះ ។ សេវាសាធារណៈធម្មតា រួមមានមុខដំណែងទាំងអស់នៅក្នុងសេវាសាធារណៈមូលដ្ឋាន ផ្សេងពីមុខដំណែងនៅក្នុងសេវាសាធារណៈពិសេស ។ សេវាសាធារណៈពិសេស រួមមានមុខដំណែង ដូចខាងក្រោម ៈ

(ក) មុខដំណែងដែលត្រូវការការបោះឆ្នោតជាសាធារណៈ ឬការបោះឆ្នោត សេចក្តីសម្រេច ឬការយល់ព្រមពីសភានៃរដ្ឋាភិបាលមូលដ្ឋាន ។

(ខ) មុខដំណែងជាប្រធានក្រុមប្រឹក្សានាយក នាយក និងសវនករសហគ្រាសអភិវឌ្ឍន៍មូលដ្ឋាន

(គ) មុខដំណែងជាអគ្គនាយកសហគ្រាសសាធារណៈមូលដ្ឋាន និងនាយកសហជីពសហគ្រាសនោះ

(ឃ) មុខដំណែងបណ្តោះអាសន្ន ឬក្រៅម៉ោងរបស់ស្ថងការ ឬក្រុមប្រឹក្សា (រួមទាំង ក្រុមប្រឹក្សា និងអង្គភាពផ្សេងទៀតក្នុងប្រភេទដូចគ្នា) ត្រូវបានបង្កើតឡើងដោយច្បាប់ និងបទបញ្ជា ដីកា បញ្ញត្តិនៃអង្គភាពមូលដ្ឋាន ឬវិធានដែលកំណត់ដោយទីភ្នាក់ងារនៃអង្គភាពមូលដ្ឋាន

(ង) មុខដំណែងពេញម៉ោងរបស់ស្ថងការទំនាក់ទំនងវិជ្ជាជីវៈសាលាខេត្ត

(ច) មុខដំណែងបណ្តោះអាសន្ន ឬក្រៅម៉ោងជាអ្នកផ្តល់ប្រឹក្សាជំនាញ អ្នកពិគ្រោះយោបល់ អ្នកស៊ើបអង្កេត បុគ្គលិកមិនទៀងទាត់ និងមុខដំណែងផ្សេងទៀតក្នុងប្រភេទដូចគ្នា

(ឆ) លេខាធិការរបស់នាយកប្រតិបត្តិ របស់ប្រធានសភា ឬទីប្រឹក្សារបស់អង្គភាពមូលដ្ឋាន និងប្រធានទីភ្នាក់ងារផ្សេងទៀតនៃរដ្ឋាភិបាលមូលដ្ឋាន ដែលចាត់តាំងដោយដីកា

(ជ) សមាជិកក្រុមពន្លត់អគ្គីភ័យស្ម័គ្រចិត្តក្រៅម៉ោង និងក្រុមកងពលតូចគ្រោះទឹកជំនន់ និង

(ឈ) នាយក ឬមន្ត្រីទីភ្នាក់ងាររដ្ឋបាលមូលដ្ឋានដែលបានកំណត់ ។

ភាពខុសគ្នាជាស្តង់ដាររវាងសេវាធម្មតា និងសេវាពិសេស មានដូចខាងក្រោម ៈ

(ក) ប្រព័ន្ធគុណសម្បត្តិ

ប្រព័ន្ធនេះអនុវត្តចំពោះសេវាសាធារណៈធម្មតា ទាក់ទងនឹងការតែងតាំង និងការដំឡើងឋានៈ ។ល។ ដែលផ្អែកលើការពិនិត្យបញ្ជី និងសម្រេចសមិទ្ធផលការងារ ។ម្យ៉ាងទៀត បុគ្គលិកសេវាសាធារណៈពិសេស ត្រូវបានតែងតាំងដោយការបោះឆ្នោតជាសាធារណៈ ការយល់ព្រមរបស់សភាថ្នាក់មូលដ្ឋាន ឬផ្អែកលើចំណេះដឹង និងបទពិសោធន៍ពិសេស ។

(ខ) ការងារអស់មួយជីវិត

ចំពោះបុគ្គលិកសេវាសាធារណៈធម្មតា ក្រោយពេលពួកគេត្រូវបានតែងតាំង ជាធម្មតា ពួកគេនឹងមិនត្រូវបានបណ្តេញចេញដោយសារមូលហេតុណាផ្សេងពីវិធានការបទវិន័យ ។ល។ ឡើយ ។ ម្យ៉ាងទៀត បុគ្គលិកសេវាសាធារណៈពិសេស ដែលត្រូវបានតែងតាំងសម្រាប់រយៈពេលជាក់លាក់នៃភារកិច្ចមិនរំពឹងថាអាចបម្រើការងារអស់មួយជីវិតបានឡើយ ។

(៣) <u>ការចាត់ថ្នាក់បុគ្គលិក</u>

បុគ្គលិកត្រូវបានបែងចែកជាច្រើនប្រភេទតាមទិដ្ឋភាពនៃប្រភេទភារកិច្ចរបស់ពួកគេ ។ ពួកគេត្រូវបានចាត់ថ្នាក់ដូចខាងក្រោម ៈ

(ក) បុគ្គលិកដែលចូលបម្រើមុខងារសាធារណៈធម្មតា

(ខ) បុគ្គលិកអប់រំសាធារណៈ

(គ) បុគ្គលិកនគរបាល

(ឃ) បុគ្គលិកពន្លត់អគ្គីភ័យ

(ង) បុគ្គលិកសហគ្រាសសាធារណៈមូលដ្ឋាន

(ច) បុគ្គលិកការងារគ្មានជំនាញ និង

(ឆ) បុគ្គលិកទីភ្នាក់ងាររដ្ឋបាលមូលដ្ឋានជាក់លាក់

ការចាត់ថ្នាក់នេះសមស្របណាស់ ព្រោះក្រុមទាំងនេះត្រូវបានចាត់ចែងជាលក្ខណៈបច្ចេកទេស តាមមធ្យោបាយផ្សេងគ្នា ។ ចំណុចលម្អិតនឹងត្រូវពិភាក្សានៅពេលក្រោយ ។

(៤) <u>ចំនួនបុគ្គលិកសេវាសាធារណៈមូលដ្ឋាន</u>

ចំនួនបុគ្គលិកសេវាសាធារណៈមូលដ្ឋានសរុបដែលបម្រើការងារនៅក្នុងអង្គភាពមូលដ្ឋានក្នុងប្រទេសជប៉ុន មានបង្ហាញជូននៅក្នុងតារាង ១ ។

**តារាង ១ : ចំនួនបុគ្គលិកសេវាសាធារណៈមូលដ្ឋាន នៅក្នុងសេវាធម្មតា**

| ពេញម៉ោង | | សរុប | ខេត្ត | ក្រុង |
|---|---|---|---|---|
| សរុប | | ២.៩៥៨.៤០២ | ១.៥៥៦.៣០៥ | ១.៤០២.០៩៧ |
| សេវាធម្មតា | រដ្ឋបាលទូទៅ | ៦១៣.៨០១ | ២០៤.៩០៧ | ៤០៨.៨៩៤ |
| | សុខុមាលភាព | ៤១៣.៣២៧ | ៦៦.៩៥២ | ៣៤៦.៣៧៥ |
| ពន្លត់អគ្គីភ័យ | | ១៥៦.៣១៥ | ១៨.៤៩១ | ១៣៧.៨២៤ |
| អប់រំ | | ១.១២៥.៧១៥ | ៩៣៤.៨៣៤ | ១៩០.៨៨១ |
| នគរបាល | | ២៧៧.៥៤៣ | ២៧៧.៥៤៣ | ០ |
| សហគ្រាសសាធារណៈ | មន្ទីរពេទ្យ | ២២២.៤៦០ | ៦៦.៣៩៨ | ១៥៦.០៦២ |
| | ផ្គត់ផ្គង់ទឹក | ៥៧.០៥៩ | ៨.៩១៦ | ៤៨.១៤៣ |
| | ដឹកជញ្ជូន | ៣១.៥២៦ | ៧.០១៦ | ២៤.៥១០ |
| | សហគ្រាសសាធារណៈផ្សេងទៀត | ១០០.៦៥៦ | ១១.២៤៨ | ៨៩.៤០៨ |

(គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៦)

## ៣. រចនាសម្ព័ន្ធច្បាប់អនុវត្តចំពោះបុគ្គលិករាជការមូលដ្ឋាន

ឋានៈ និងការប្រព្រឹត្តរបស់បុគ្គលិករាជការមូលដ្ឋានត្រូវបានចែងជាស្វ័យប្រវត្តិដោយច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន និងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ដែលតាមទិដ្ឋភាពរចនាសម្ព័ន្ធអង្គការនៃរដ្ឋាភិបាលមូលដ្ឋាន ហើយក៏មានបញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងបុគ្គលិករាជការមូលដ្ឋានផងដែរ ។ ច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន បង្កើតបានជាក្របខ័ណ្ឌនៃប្រព័ន្ធសេវាសាធារណៈមូលដ្ឋាន ។

ដោយចែកដាច់ដោយឡែកពីគ្នា បញ្ញត្តិពិសេសត្រូវបានចែងនៅក្នុងច្បាប់ពិសេស១ជាច្រើន ។ បញ្ញត្តិខ្លះចែងសម្រាប់បុគ្គលិកអប់រំសាធារណៈនៅក្នុងច្បាប់ពិសេស ចំពោះបុគ្គលិកអប់រំសាធារណៈ និងច្បាប់ទាក់ទងនឹងការបង្កើតអង្គការ និងការប្រព្រឹត្តទៅនៃរដ្ឋបាលអប់រំមូលដ្ឋាន ។ ចំពោះបុគ្គលិកនគរបាល ដោយច្បាប់ស្តីពីនគរបាល ។ ចំពោះបុគ្គលិកពន្លត់អគ្គីភ័យ ដោយច្បាប់ស្តីពីអង្គភាពពន្លត់អគ្គីភ័យ ។ ចំពោះបុគ្គលិកសហគ្រាសសាធារណៈមូលដ្ឋាន និងកម្មករ-និយោជិតគ្មានជំនាញ ដោយច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន និងច្បាប់ពាក់ព័ន្ធនឹងទំនាក់ទំនងវិជ្ជាជីវៈនៃសហគ្រាសសាធារណៈមូលដ្ឋាន ។ល។ លើសពីនេះទៀត បញ្ញត្តិខ្លះនៃច្បាប់ស្តីពីស្តង់ដារការងារ និងច្បាប់ផ្សេងទៀត ក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈឯកជន អនុវត្តចំពោះបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ក្នុងកម្រិតដែលបញ្ញត្តិទាំងនោះ ត្រូវបានចាត់ទុកថាអនុលោមតាមគោលការណ៍នៃប្រព័ន្ធបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ។

ដីកា និងបទបញ្ជានៃរដ្ឋាភិបាលមូលដ្ឋាននីមួយៗ រួមមានផ្នែកសំខាន់មួយនៃរចនាសម្ព័ន្ធច្បាប់នៃ ប្រព័ន្ធសេវា-សាធារណៈមូលដ្ឋាន ។ ច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ប្រគល់ដល់អង្គភាពមូលដ្ឋាន នូវភារកិច្ចប្រកាសអោយប្រើដីកា និងបទបញ្ជា ស្តីពីកិច្ចការសំខាន់១ជាច្រើន សម្រាប់ឋានៈ និងការប្រព្រឹត្តិរបស់បុគ្គលិករបស់ពួកគេផ្ទាល់ ។ ក្នុងករណីខ្លះ ការប្រកាសអោយប្រើដីកា និងបទបញ្ជានោះ មានភាពចាំបាច់ដោយខានមិនបាន ។

ច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន តទៅនេះ ហៅថា "ច្បាប់" ។

## ជំពូកទី ២ : ទីភ្នាក់ងារបុគ្គលិក

### ១. ប្រភេទទីភ្នាក់ងារបុគ្គលិក

នៅក្នុងរដ្ឋាភិបាលមូលដ្ឋានទីភ្នាក់ងារបុគ្គលិក ដែលមានអំណាច និងទំនួលខុសត្រូវរដ្ឋបាលចុងក្រោយនៃការគ្រប់គ្រងបុគ្គលិក គឺជាអាជ្ញាធរតែងតាំង និងគណៈកម្មាធិការបុគ្គលិក (ឬគណៈកម្មាធិការសមភាព) ។

អាជ្ញាធរតែងតាំងគឺជាទីភ្នាក់ងារមួយ ដែលអនុវត្តដោយផ្ទាល់នូវសិទ្ធិគ្រប់គ្រងបុគ្គលិក រួមទាំងការតែងតាំង វិធានការពាក់ព័ន្ធនឹងការផ្លាស់ប្តូរឋានៈ និងវិធានការវិន័យ ។ល។ម្យ៉ាងទៀត គណៈកម្មាធិការបុគ្គលិក និងគណៈកម្មាធិការ-សមភាព គឺជាទីភ្នាក់ងារឯកទេស និងមិនលម្អៀង ក្រោមប្រព័ន្ធក្រុមប្រឹក្សា ដែលផ្តល់យោបល់ដល់អាជ្ញាធរតែងតាំង អោយអនុវត្តដោយយុត្តិធម៌នូវសិទ្ធិនៃការគ្រប់គ្រងបុគ្គលិក និងពិនិត្យមើលស្ថានភាពឡើងវិញជាប្រចាំ ។

### ២. អាជ្ញាធរតែងតាំង

នៅក្នុងរដ្ឋាភិបាលមូលដ្ឋាន នាយកប្រតិបត្តិនៃអង្គភាព ប្រធានសភា គណៈកម្មការរដ្ឋបាល ។ល។ អាចជាអាជ្ញាធរ-តែងតាំង ។ អាជ្ញាធរទាំងនេះនីមួយៗត្រូវបានជ្រើសរើសឡើងស្របតាមអំណាច និងទំនួលខុសត្រូវរដ្ឋបាលចុងក្រោយនៃរដ្ឋបាលបុគ្គលិក ។ ច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន រាយឈ្មោះអាជ្ញាធរតែងតាំងដូចខាងក្រោម : នាយកប្រតិបត្តិនៃរដ្ឋាភិបាលមូលដ្ឋាន ប្រធានសភា គណៈកម្មាធិការ រដ្ឋបាលបោះឆ្នោត ស្នងការអធិការកិច្ចតំណាង ក្រុមប្រឹក្សាអប់រំ គណៈកម្មាធិការបុគ្គលិក គណៈកម្មាធិការសមភាព អគ្គស្នងការនៃនាយកដ្ឋាននគរបាលក្រុងតូក្យូ ប្រធានកងកម្លាំងនគរបាលខេត្ត ប្រធានអង្គភាពការពារអគ្គីភ័យក្រុង ។ល។

### ៣. គណៈកម្មាធិការបុគ្គលិក និងគណៈកម្មាធិការសមភាព

(១) <u>អំណាចរបស់គណៈកម្មាធិការបុគ្គលិក និងគណៈកម្មាធិការសមភាព</u>

អំណាចរបស់គណៈកម្មាធិការបុគ្គលិកអាចចាត់ចូលក្នុងអាជ្ញាធរស្មើរនីតិបញ្ញត្តិ ស្មើរតុលាការ និងរដ្ឋបាល ស្របតាមលក្ខណៈនៃអំណាច ។ ដែនអំណាចនីមួយៗនៃអាជ្ញាធរ ខុសៗគ្នាដូចខាងក្រោម :

(ក) អាជ្ញាធរស្មើរនីតិបញ្ញត្តិ

គណៈកម្មាធិការបុគ្គលិកទទួលខុសត្រូវចំពោះបញ្ហាផ្នែកឯកទេស និងបច្ចេកទេស ក្នុងនាមជាអង្គភាពជំនាញមួយនៅក្នុងទម្លាប់អនុវត្តរបស់រដ្ឋបាលបុគ្គលិក ។ ដូច្នេះ គណៈកម្មាធិការបុគ្គលិកអាចបង្កើតបទបញ្ជារបស់គណៈកម្មាធិការបុគ្គលិកពាក់ព័ន្ធនឹងបញ្ហា អាស្រ័យនឹងសិទ្ធិអំណាចរបស់ខ្លួនស្របតាមច្បាប់ និងដីកា ។

(ខ) អាជ្ញាធរស្មើរតុលាការ

ក្នុងនាមជាអង្គភាពមិនលម្អៀង និងអព្យាក្រឹត្យ គណៈកម្មាធិការបុគ្គលិកជាស្ថាប័នគ្រប់គ្រងអាជ្ញាធរស្មើរតុលាការ ឧទាហរណ៍ សិទ្ធិអំណាចពិនិត្យ និងវិនិច្ឆ័យការជំទាស់នឹងវិធានការអវិជ្ជមានទាក់ទងនឹងបុគ្គលិក ព្រមទាំងពិនិត្យពាក្យបណ្តឹងទាក់ទងនឹង ស្ថានភាពការងារ ។

(គ) អាជ្ញាធររដ្ឋបាល

គណៈកម្មាធិការបុគ្គលិកអនុវត្តអំណាចរដ្ឋបាលដូចតទៅ ។ គណៈកម្មាធិការបុគ្គលិកផ្តល់យោបល់ដល់សភា និងនាយកប្រតិបត្តិ ទាក់ទងនឹងការប្រកាសអោយប្រើ ការកែប្រែ និងការធ្វើនិរាករណ៍ដីកាទាំងឡាយ ដែលពាក់ព័ន្ធនឹងបុគ្គលិក ។ គណៈកម្មាធិការនេះផ្តល់អនុសាសន៍ដល់អាជ្ញាធរតែងតាំង ដើម្បីប្រតិបត្តិរដ្ឋបាលបុគ្គលិកដោយសមភាព ។ គណៈកម្មាធិការនេះធ្វើការសិក្សា និងរាយការណ៍អំពីប្រព័ន្ធទាក់ទងនឹងរដ្ឋបាលបុគ្គលិក ព្រមទាំងអនុវត្តការប្រឡងប្រជែង ការជ្រើសរើស និងការធ្វើធុរកិច្ចដែលទាក់ទងនឹងប្រព័ន្ធនោះ ។

ម្យ៉ាងទៀត អំណាចរបស់គណៈកម្មាធិការសមភាពមានកម្រិត បើធៀបនឹងអំណាចរបស់គណៈកម្មាធិការ-បុគ្គលិក ។

(២) <u>ការបង្កើតគណៈកម្មាធិការបុគ្គលិក និងគណៈកម្មាធិការសមភាព</u>

មាត្រា ៧ នៃច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ចែងអំពីការបង្កើតគណៈកម្មាធិការបុគ្គលិក ឬគណៈកម្មាធិការ-សមភាព ដូចខាងក្រោម ស្របតាមផ្នែកក្រុម និងវិសាលភាព : ខេត្ត និងក្រុងដែលបានកំណត់ ត្រូវបង្កើតគណៈកម្មាធិការ-បុគ្គលិក ។ ក្រុងដែលមានប្រជាជនលើសពី ១៥០.០០០ នាក់ និងមានមណ្ឌលបោះឆ្នោតពិសេសតូក្យូ ត្រូវបង្កើតគណៈកម្មាធិការបុគ្គលិក ឬគណៈកម្មាធិការសមភាព ។ ទីក្រុងដែលមានប្រជាជនតិចជាង ១៥០.០០០ នាក់ ក្រុង និងភូមិ ព្រមទាំងសមាគមអង្គភាពសាធារណៈមូលដ្ឋានត្រូវបង្កើតគណៈកម្មាធិការសមភាពមួយ ។ លើសពីនេះទៀត ដើម្បីអោយរដ្ឋាភិបាលមូលដ្ឋានតូចៗជាងនេះ អាចគ្រប់គ្រងកិច្ចការសាធារណៈដោយសមញ្ញ និងមានប្រសិទ្ធភាព រដ្ឋាភិបាលតូចៗទាំងនេះ អាចបង្កើតគណៈកម្មាធិការសមភាពរួមគ្នា ឬធ្វើប្រតិភូកម្មកិច្ចការសាធារណៈរបស់គណៈកម្មាធិការសមភាពទៅអោយគណៈកម្មាធិការបុគ្គលិកផ្សេងទៀត ។

## ជំពូកទី ៣ : ការតែងតាំង និងការបំពេញភារកិច្ច

### ១. ការតែងតាំងបុគ្គលិកសេវាសាធារណៈមូលដ្ឋាន

មាត្រា ១៥ នៃច្បាប់នេះ ចែងជាវិធានទូទៅថា ការតែងតាំងបុគ្គលិកត្រូវធ្វើឡើង ដោយអនុលោមតាមបញ្ញត្តិច្បាប់ ដោយផ្អែកលើកំណត់ត្រាពិន្ទុប្រឡង ភាពសក្តិសមក្នុងការបំពេញភារកិច្ច ឬការបង្ហាញអំពីសមត្ថភាពផ្សេងទៀតរបស់បុគ្គលម្នាក់ៗ ។ មាត្រានេះមានភាពសំខាន់ខ្លាំង ព្រោះវាចែងអំពីការប្រើប្រាស់ប្រព័ន្ធគុណសម្បត្តិ ក្នុងការតែងតាំងដើម្បីទទួលបានប្រសិទ្ធភាពកាន់តែខ្ពស់ក្នុងការបំពេញភារកិច្ចនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន ។

ការតែងតាំងត្រូវបានចែកចេញជាបួនប្រភេទ :

(ក) ការតែងតាំងដំបូង : តែងតាំងបុគ្គលមិនមែនបុគ្គលិកអោយកាន់មុខដំណែងជាបុគ្គលិក ។

(ខ) ការដំឡើងដំណែង : តែងតាំងបុគ្គលិកអោយមានកម្រិតភារកិច្ច ឬឋានៈខ្ពស់ជាងមុន នៅក្នុងអង្គភាព ។

(គ) ការទម្លាក់ដំណែង : តែងតាំងបុគ្គលិកអោយមានកម្រិតភារកិច្ច ឬឋានៈទាបជាងមុន នៅក្នុងអង្គភាព ។

(ឃ) ការផ្ទេរ : តែងតាំងបុគ្គលិកទៅកាន់មុខដំណែងផ្សេងទៀត តាមរយៈមធ្យោបាយក្រៅពីការដំឡើងដំណែង ឬការទម្លាក់ដំណែង ។

ក្នុងចំណោមប្រភេទទាំងបួននេះ ការតែងតាំងដំបូង និងការដំឡើងដំណែងមិនអាចត្រូវបានធ្វើឡើងដោយគ្មានការប្រឡងប្រជែង ឬការជ្រើសរើសសម្រិតសម្រាំង ដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ។

ការប្រឡងប្រជែងគឺជាវិធីសាស្រ្ត ដែលតាមរយៈនេះ បុគ្គលត្រូវបានជ្រើសរើសសម្រាប់មុខដំណែងជាក់លាក់តាមមធ្យោបាយប្រកួតប្រជែង ។ ការជ្រើសរើសសម្រិតសម្រាំងគឺជាវិធីសាស្រ្ត ដែលតាមរយៈនេះ គុណសម្បត្តិរបស់បុគ្គលជាក់លាក់ណាម្នាក់ ត្រូវបានកំណត់សម្រាប់មុខដំណែងជាក់លាក់ណាមួយ ។ ទោះជាយ៉ាងណាក៏ដោយគោលបំណងនៃការប្រឡងប្រជែង និងការជ្រើសរើសសម្រិតសម្រាំងត្រូវកំណត់អំពីលទ្ធភាពក្នុងការបំពេញភារកិច្ចផ្លូវការជាបុគ្គលិក ហើយជាការមិនត្រឹមត្រូវឡើយដែលថា វិធីសាស្រ្តមួយមានភាពតឹងតែងជាងវិធីសាស្រ្តមួយទៀតឡើយ ។ វិធីសាស្រ្តទាំងពីរត្រូវបានចាត់ទុកថាមាន ភាពខុសគ្នាតែនៅក្នុងដំណើរការប៉ុណ្ណោះ ។

អង្គភាពដែលទទួលខុសត្រូវធ្វើការរៀបចំការប្រឡងប្រជែង ឬការជ្រើសរើសសម្រិតសម្រាំង គឺគណៈកម្មការបុគ្គលិក (រួមទាំងគណៈកម្មការសមភាព ដែលរៀបចំការប្រឡងប្រជែង) ក្នុងករណីរដ្ឋាភិបាលមូលដ្ឋានដែលមានគណៈកម្មការបុគ្គលិក និងអាជ្ញាធរតែងតាំង ក្នុងករណីរដ្ឋាភិបាលមូលដ្ឋាន គ្មានគណៈកម្មការបុគ្គលិក ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មការបុគ្គលិក ឬអាជ្ញាធរតែងតាំងអាចរៀបចំការប្រឡងប្រជែង ឬការជ្រើសរើស សម្រិតសម្រាំងរួមគ្នាជាមួយទីភ្នាក់ងារណាមួយនៃរដ្ឋាភិបាលមូលដ្ឋានផ្សេងទៀត តាមរយៈការពិគ្រោះយោបល់ ឬប្រគល់ភារកិច្ចទាំងនេះអោយទៅទីភ្នាក់ងារណាមួយនៃរដ្ឋាភិបាលជាតិ ឬនៃរដ្ឋាភិបាលមូលដ្ឋានផ្សេងទៀត តាមរយៈកិច្ចព្រមព្រៀងជាមួយទីភ្នាក់ងារនោះ ។

នៅពេលគណៈកម្មការបុគ្គលិករៀបចំការប្រឡងប្រជែង គណៈកម្មការនេះ ត្រូវបានតម្រូវអោយរៀបចំ "បញ្ជី-ភាពអាចជាប់ការជ្រើសរើសអោយចូលបម្រើការងារ" មួយដែលក្នុងនោះ ឈ្មោះពេញ និងពិន្ទុរបស់អ្នកដែលបានទទួលពិន្ទុ

ត្រឹមជាប់ ឬខ្ពស់ជាង មានរាយទៅតាមលំដាប់លេខរៀង ស្របតាមពិន្ទុរបស់ពួកគេ ។ អាជ្ញាធរតែងតាំងនីមួយៗ ត្រូវធ្វើការតែងតាំងដំបូង ឬការដំឡើងដំណែង ពីក្នុងចំណោមបេក្ខជនដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះរបស់គណៈកម្មការបុគ្គលិក ។

(២) ការងារមានល័ក្ខខ័ណ្ឌ

រាល់ការតែងតាំងបុគ្គលិកដំបូង ផ្សេងពីការតែងតាំងបណ្ដោះអាសន្ន ឬការតែងតាំងក្នុងមុខដំណែងក្រៅម៉ោង គឺជាការតែងតាំងមានល័ក្ខខ័ណ្ឌ ដូចមានចែងដោយច្បាប់ និងអាចក្លាយជាផ្លូវការតែនៅពេលបុគ្គលិកបានបម្រើការងារក្នុងមុខដំណែងរបស់ខ្លួនក្រោមឋានៈមានល័ក្ខខ័ណ្ឌបានរយៈពេលប្រាំមួយខែ (រយៈពេលនេះអាចពន្យាររហូតដល់ត្រឹមដប់ពីរខែក្នុងករណីខ្លះ) និងបានបំពេញភារកិច្ចរបស់ខ្លួន គួរជាទីពេញចិត្តក្នុងកំឡុងរយៈពេលនេះ ។ ចំណុចនេះផ្ដោតលើការបង្ហាញដោយត្រឹមត្រូវអំពីលទ្ធភាព តាមរយៈការបំពេញភារកិច្ចបន្ថែមលើលទ្ធផលនៃការប្រឡងប្រជែង ឬការជ្រើសរើសសម្រិតសម្រាំង មុនពេលធ្វើការតែងតាំង ។

មន្ត្រីណាម្នាក់នៅក្នុងរយៈពេលមានល័ក្ខខ័ណ្ឌនៃការតែងតាំងដំបូងត្រូវបញ្ឈប់ពីការងារ និងប្រឈមមុខនឹងវិធានការឋានៈផ្សេងទៀតប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ទោះបីជាមូលហេតុមានចែង ឬមិនមានចែងនៅក្នុងច្បាប់ ឬដីកាក៏ដោយ ។ នៅពេលមន្ត្រីនេះត្រូវប្រឈមមុខនឹងវិធានការនោះ មន្ត្រីនោះមិនអាចលើកឡើងអំពីការជំទាស់ណាមួយ ក្រោមច្បាប់ស្ដីពីបណ្ដឹងឧទ្ធរណ៍រដ្ឋបាល ទៅគណៈកម្មការបុគ្គលិក ឬគណៈកម្មការសមភាពឡើយ ។ មន្ត្រីនោះមិនត្រូវបានធានាអំពីឋានៈរបស់ខ្លួនឡើយ ក្នុងខណៈដែលខ្លួនស្ថិតក្នុងឋានៈមានល័ក្ខខ័ណ្ឌ ។

(៣) ការតែងតាំងបណ្ដោះអាសន្ន

នៅពេលអាជ្ញាធរតែងតាំងនៃរដ្ឋាភិបាលមូលដ្ឋាន ធ្វើការតែងតាំងបុគ្គលិក ជាគោលការណ៍ បុគ្គលិកត្រូវបានតែងតាំងក្នុងការងារជាអចិន្ត្រៃយ៍ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបន្ទាន់ ។ល។ ឬការតែងតាំងក្នុងការងារបណ្ដោះអាសន្នរយៈពេលខ្លី បុគ្គលិកអាចត្រូវបានតែងតាំងជាបណ្ដោះអាសន្ន សម្រាប់រយៈពេលរហូតដល់មួយឆ្នាំ (ជាគោល-ការណ៍ រយៈពេលគឺប្រាំមួយខែ ប៉ុន្តែរយៈពេលនេះអាចបន្លាយរហូតដល់ប្រាំមួយខែ ក្រោយពេលចប់រយៈពេលដំបូង) ។ បញ្ញត្តិនៃការធានាឋានៈក្នុងច្បាប់ស្ដីពីសេវាសាធារណៈមូលដ្ឋាន មិនអនុវត្តចំពោះការតែងតាំងបុគ្គលិកជាបណ្ដោះអាសន្នឡើយ ។

(៤) ការតែងតាំងសម្រាប់រយៈពេលមានកំណត់

អាជ្ញាធរតែងតាំងអាចជួលបុគ្គលិកសម្រាប់រយៈពេលមានកំណត់ សម្រាប់ការងារដែលគួរត្រូវបានអនុវត្តដោយបុគ្គលិកដែលមានជំនាញ និងបទពិសោធន៍ជាក់លាក់ ព្រមទាំងការងារដែលនឹងត្រូវបញ្ចប់ក្នុងរយៈពេលជាក់លាក់ណាមួយ ។ល។

ក្នុងករណីធម្មតា រយៈពេលតែងតាំងវែងបំផុតគឺ ៥ ឆ្នាំ សម្រាប់បុគ្គលិកដែលមានជំនាញ និងបទពិសោធន៍ និង ៣ ឆ្នាំសម្រាប់បុគ្គលិកដែលបានចូលបម្រើការងារក្នុងរយៈពេលជាក់លាក់ណាមួយ ។

(៥) បញ្ញត្តិព្យួរ

ពលរដ្ឋជប៉ុនទាំងអស់ត្រូវទទួលបាននូវការយកចិត្តទុកដាក់ស្មើៗគ្នា ពាក់ព័ន្ធនឹងលទ្ធភាពរបស់ពួកគេ និងឱកាសស្មើភាពគ្នា ដើម្បីបម្រើមុខងារសាធារណៈក្រោមច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ គេចាត់ទុកថាជាការសមហេតុផលដែលមិនផ្តល់ឱកាសនោះដល់បុគ្គលដែលមានកេរ្តិ៍ឈ្មោះមិនសូវល្អ ប្រសិនបើយើងផ្តោតលើលទ្ធផលនៃការអនុវត្តភារកិច្ចគ្រប់គ្រាន់ ។ មាត្រា ១៦ នៃច្បាប់នេះ ចែងថា បុគ្គលម្នាក់ដែលស្ថិតក្នុងចំណុចណាមួយដូចខាងក្រោមមិនអាចក្លាយជាបុគ្គលិកផ្លូវការ ឬចូលរួមនៅក្នុងដំណើរការប្រឡងប្រជែង ឬការជ្រើសរើសសម្រិតសម្រាំងឡើយ លើកលែងករណីដែលមានចែងដោយដីកា :

(ក) បុគ្គលដែលពេញអាយុក្រោមអាណាព្យាបាលភាព នៅក្នុងជំនួយ ដែលត្រូវបានវិនិច្ឆ័យដោយស្របច្បាប់ថាគ្មានសមត្ថភាព ឬស្ទើរតែគ្មានសមត្ថភាព

(ខ) បុគ្គលដែលធ្លាប់ត្រូវបានកាត់ទោសធ្ងន់ជាងទោសជាប់ពន្ធនាគារ ដោយគ្មានការងារធ្ងន់ធ្ងរ ហើយដែលការកាត់ទោសនេះ មិនត្រូវបានបញ្ចប់ ឬក្លាយជាមិនអាចអនុវត្តបាន

(គ) បុគ្គលដែលត្រូវបានប្តឹងដោយរដ្ឋាភិបាលមូលដ្ឋានដែលពាក់ព័ន្ធ ពីការបញ្ឈប់ពីការងារជាបទវិន័យ ចាប់ពីកាលបរិច្ឆេទ ដែលក្នុងចំណោមនោះរយៈពេលពីរឆ្នាំមិនទាន់កន្លងផុត

(ឃ) បុគ្គលដែលពេលកំពុងបំពេញតួនាទីជាសមាជិកម្នាក់នៃគណៈកម្មការបុគ្គលិក ឬគណៈកម្មការសមភាព បានប្រព្រឹត្តបទល្មើសណាមួយដែលចែងនៅក្នុងជំពូកទី ៥ នៃច្បាប់នេះ និងត្រូវបានកាត់ទោស ឬ

(ង) បុគ្គលដែលនៅពេល ឬក្រោយកាលបរិច្ឆេទប្រកាសអោយប្រើប្រាស់រដ្ឋធម្មនុញ្ញជប៉ុន បានបង្កើត ឬចូលរួមក្នុងគណបក្សនយោបាយណាមួយ ឬអង្គភាពមួយផ្សេងទៀតដែលតស៊ូមតិជំរុញអោយមានការផ្តួលរំលំដោយអំពើហិង្សានូវរដ្ឋធម្មនុញ្ញជប៉ុន ឬរដ្ឋាភិបាលដែលបានបង្កើតឡើងក្រោមរដ្ឋធម្មនុញ្ញនេះ ។

ក្នុងករណីបុគ្គលិកបច្ចុប្បន្នខកខាន ក្រោមចំណុចណាមួយខាងលើ បុគ្គលិកនោះនឹងបាត់បង់ ដោយស្វ័យប្រវត្តិនូវមុខដំណែងរបស់ខ្លួន លើកលែងតែករណីចែងជាពិសេសផ្សេងពីនេះដោយដីកា (មាត្រា ២៨ កថាខ័ណ្ឌទី ៤) ។ ដើម្បីអោយបុគ្គលម្នាក់នៅតែបន្តធ្វើជាសមាជិកបុគ្គលិក (ដូចក្នុងការចូលធ្វើជាបុគ្គលិក) ជាការចាំបាច់ដែលថាបុគ្គលរូបនោះមិនដែលខកខានក្រោមចំណុចណាមួយនៃបញ្ញត្តិទាំងនេះឡើយ ។

លើសពីនេះទៀត បុគ្គលដែលមិនមានសញ្ជាតិជប៉ុនមិនអាចទទួលការតែងតាំងក្នុងមុខដំណែងអនុវត្តអំណាចលើភាពជាពលរដ្ឋ ឬការសម្រេចចិត្តនៅក្នុងរដ្ឋាភិបាលមូលដ្ឋានឡើយ ។

(៦) ការលាឈប់របស់បុគ្គលិក

ការលាឈប់របស់បុគ្គលិកមានន័យថា បុគ្គលិកបាត់បង់មុខដំណែងរបស់ខ្លួន ។ ទម្រង់បែបបទនៃការលាឈប់មានដូចខាងក្រោម :

(ក) ការលាឈប់ដោយការព្យួរ : ការដកហូតមុខដំណែងដោយសារការអនុវត្តបញ្ញត្តិសុំព្យួរជាទូទៅ ។

(ខ) ការផុតកំណត់រយៈពេលតែងតាំង : ការដកហូតមុខដំណែងដោយការផុតកំណត់នៃរយៈពេលតែងតាំង ។

(គ) ការចូលនិវត្តន៍ពេលដល់អាយុចូលនិវត្តន៍ : ចូលនិវត្តន៍ដោយស្វ័យប្រវត្តិ នៅពេលដល់អាយុជាក់លាក់ លើកលែងក្នុងករណីពិសេសណាមួយ ។

(ឃ) ការលាឈប់ដោយសារវិធានការបទវិន័យ ឬការលាឈប់ដោយវិធានការងារ : ការដកហូតមុខដំណែងប្រឆាំងនឹងឆន្ទៈរបស់បុគ្គលិក ដោយសារការខកខានក្រោមល័ក្ខខ័ណ្ឌសម្រាប់ការលាឈប់នៃវិធានការងារ ឬវិធានការបទវិន័យ ។

(ង) ការចូលនិវត្តន៍ធម្មតា : ការលាឈប់ដោយស្ម័គ្រចិត្តដោយសារមូលហេតុផ្សេងៗគ្នា ។

## ២. ភារកិច្ចរបស់បុគ្គលិក

(១) ស្តង់ដារគ្រឹះសម្រាប់ការបំពេញភារកិច្ច និងការសច្ចាប្រណិធាននៃភារកិច្ច

មន្ត្រីម្នាក់ ក្នុងឋានៈជាអ្នកបម្រើរបស់សហគមន៍ទាំងមូលចាំបាច់ត្រូវបំពេញភារកិច្ចរបស់ខ្លួន ដើម្បីប្រយោជន៍របស់សាធារណជន និងខិតខំប្រឹងប្រែងអោយអស់ពីលទ្ធភាពរបស់ខ្លួនក្នុងការបំពេញភារកិច្ចទាំងអស់ (មាត្រា ៣០) ។ នេះគឺជាស្តង់ដារគ្រឹះនៃការបំពេញភារកិច្ចសម្រាប់បុគ្គលិករាជការមូលដ្ឋាន ដែលក្លាយមកពីចរិកលក្ខណៈពិសេសនៃឋានៈរបស់ពួកគេ ។

ផ្អែកតាមទិដ្ឋភាពប្រវត្តិសាស្ត្រ មន្ត្រីរាជការនៅក្នុងសម័យមុនសង្គ្រាមលោកលើកទី២ ត្រូវបានចាត់ទុកថាជាអ្នកបម្រើរបស់ព្រះចៅអធិរាជ្យ ប៉ុន្តែនៅក្នុងសម័យក្រោយសង្គ្រាម រដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសជប៉ុន បានចែងថា មន្ត្រីរាជការត្រូវធ្វើអ្នកបម្រើរបស់សហគមន៍ទាំងមូល ក្នុងរបៀបមួយដែលមន្ត្រីរាជការគួរអនុវត្តនៅក្នុងរដ្ឋប្រជាធិបតេយ្យ ។

មន្ត្រីទាំងអស់ ដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ត្រូវធ្វើសម្បថសច្ចាប្រណិធានដើម្បីបំពេញភារកិច្ចនៅពេលចាប់ផ្តើមការងារ ។ តាមធម្មតា មន្ត្រីតែងតាំងថ្មី ត្រូវចុះហត្ថលេខាដោយដាក់ឈ្មោះរបស់ខ្លួននៅលើសម្បថសច្ចាប្រណិធាន នៅចំពោះមុខអាជ្ញាធរតែងតាំង ឬបុគ្គលិកដែលបានប្រគល់ភារកិច្ចរបស់ខ្លួន ។ ជាធម្មតា សម្បថសច្ចាប្រណិធានមានខ្លឹមសារថា : "ខ្ញុំសូមស្បថយ៉ាងមោះមុតថានឹងគោរព និងប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃប្រទេសជប៉ុន ដែលប្រកាសទទួលស្គាល់អំណាចអធិបតេយ្យដែលជាកម្មសិទ្ធរបស់ប្រជាជន ។ ខ្ញុំសូមទទួលស្គាល់គោលការណ៍នៃស្វ័យភាព-មូលដ្ឋាន និងយល់ដឹងយ៉ាងស៊ីជម្រៅអំពីការទទួលខុសត្រូវលើការបំពេញភារកិច្ចសាធារណៈប្រកបដោយលក្ខណៈប្រជាធិប-តេយ្យ និងប្រសិទ្ធភាព ។ ខ្ញុំសូមស្បថថានឹងអនុវត្តភារកិច្ចសាធារណៈរបស់ខ្ញុំ ក្នុងឋានៈជាអ្នកបម្រើសហគមន៍ទាំងមូលតាមរបៀបមួយប្រកបដោយមនសិការ និងយុត្តិធម៌ " ។ គ្មានមន្ត្រីណាម្នាក់ អាចចាប់ផ្តើមបំពេញភារកិច្ចរបស់ខ្លួនមុនពេលចុះហត្ថលេខាលើសម្បថសច្ចាប្រណិធាននេះឡើយ ។

(២) ភារកិច្ចគោរពដីកា និងបទបញ្ជា ព្រមទាំងសេចក្តីណែនាំរបស់ថ្នាក់លើ

នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីម្នាក់ៗត្រូវតែគោរពតាមច្បាប់ជាតិ បទបញ្ជាខុទ្ទកាល័យ បទបញ្ជាក្រសួង ដីកា និងបទប្បញ្ញត្តិដែលកំណត់ដោយទីភ្នាក់ងារនៃរដ្ឋាភិបាលមូលដ្ឋាន និងគោរពដោយសុទ្ធចិត្តតាមបទបញ្ជា និងសេចក្តីណែនាំរបស់ថ្នាក់លើ លើបញ្ហាទាក់ទងនឹងការបំពេញភារកិច្ចរបស់ខ្លួន (មាត្រា ៣២) ។

នេះគឺដោយសារគោលការណ៍ច្បាប់ដែលរដ្ឋបាលត្រូវផ្អែកលើច្បាប់ដែលឆ្លុះបញ្ចាំងអំពីឆន្ទៈរបស់មនុស្ស និងប្រជាជន ។ លើសពីនេះទៀត ដើម្បីអោយអង្គភាពធ្វើជារដ្ឋាភិបាលមូលដ្ឋាន បទបញ្ជា និងសេចក្តីណែនាំរបស់ថ្នាក់លើត្រូវគោរពតាម ។

(៣) <u>ការហាមឃាត់នូវទង្វើធ្វើអោយខូចកេរ្តិ៍ឈ្មោះ</u>

មន្ត្រីម្នាក់ត្រូវតែធ្វើសកម្មភាពតាមរបៀបដែលមិនធ្វើអោយខូចកេរ្តិ៍ឈ្មោះនៃមុខដំណែងរបស់ខ្លួន ឬឆ្លុះបញ្ចាំងជាអវិជ្ជមានលើមុខដំណែងរបស់បុគ្គលិកទាំងមូល (មាត្រា ៣៣) ។ តាមធម្មតា ហេតុផលនៃចំណុចនេះគឺថា បុគ្គលិកក្នុងមុខងារសាធារណៈ អនុវត្តមុខងារសាធារណៈ ដោយមានទំនុកចិត្តពីប្រជាជនក្នុងមូលដ្ឋាន ។ បុគ្គលិកត្រូវបានតម្រូវអោយប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតនៃអាកប្បកិរិយាជាមន្ត្រីរាជការ ។ ការប្រព្រឹត្តិមិនគប្បីក្នុងប្រភេទណាមួយដោយបុគ្គលិកម្នាក់ បង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិត្តិនាម និងកិត្តិស័ព្ទនៃបុគ្គលិកទាំងអស់ ។

ទោះជានៅក្នុងករណីទង្វើដែលកើតឡើងនៅក្នុងជីវភាពរស់នៅឯកជនក៏ដោយ ដូចជាការបើកបរនៅពេលស្រវឹង (នេះមិនទាន់និយាយដល់ទង្វើជាបទល្មើស ដូចជាការស៊ីសំណូកទេ) ទង្វើដែលក្បត់នឹងទំនុកចិត្តរបស់ប្រជាជនត្រូវបានចាត់ទុកថាជាការបង្កការខូចកេរ្តិ៍ឈ្មោះ ។

(៤) <u>ភារកិច្ចរក្សាការសម្ងាត់</u>

មន្ត្រីមិនត្រូវផ្សព្វផ្សាយបញ្ហាសម្ងាត់ណាមួយដែលខ្លួនអាចដឹង ក្នុងកំឡុងពេលបំពេញភារកិច្ចរបស់ខ្លួន ។ ចំណុចនេះក៏អនុវត្តផងដែរក្រោយពេលចូលនិវត្តន៍ពីមុខដំណែង (មាត្រា ៣៤ ចំណុច ១) ។ មានករណីជាច្រើន ដែលតាមរយៈនោះ ការផ្សព្វផ្សាយព័ត៌មានសំខាន់នឹងប្រឆាំងនឹងឧត្តមប្រយោជន៍របស់សាធារណជនទូទៅ ឬប្រជាពលរដ្ឋម្នាក់ៗ ។ ដោយហេតុនេះ ច្បាប់ដាក់បុគ្គលិកក្រោមកាតព្វកិច្ចការពារព័ត៌មានបែបនោះ និងដាក់ទោសឧក្រិដ្ឋ (សេរីភាពព្រហ្មទណ្ឌមិនលើសពីមួយឆ្នាំ ឬផាកពិន័យមិនលើសពីបីម៉ឺនយេន) ព្រមទាំងបណ្តឹងបទវិន័យ ចំពោះអ្នករំលោភបំពាន ។

ក្នុងករណីដែលបញ្ហាការសម្ងាត់ផ្លូវការចាំបាច់ត្រូវបញ្ចេញអោយដឹង ក្រោយពេលក្លាយជាសាក្សី ឬសាក្សីជំនាញ ។ល។ យោងតាមច្បាប់ និងបទបញ្ជា ចាំបាច់ត្រូវមានការអនុញ្ញាតរបស់អាជ្ញាធរតែងតាំង (ឬក្នុងករណីបុគ្គលដែលបានចូលនិវត្តន៍ពីមុខដំណែង អាជ្ញាធរតែងតាំងពីលើមុខដំណែងដែលបុគ្គលនោះចូលនិវត្តន៍ ឬមុខដំណែងដែលពាក់ព័ន្ធ) ។ ជាទូទៅ អាជ្ញាធរតែងតាំងមិនអាចបដិសេធការអនុញ្ញាតបែបនោះឡើយ លើកលែងតែក្នុងករណីមានចែងផ្សេងពីនេះដោយច្បាប់ ។

(៥) <u>ភារកិច្ចលះបង់ចំពោះសេវា</u>

លើកលែងតែក្នុងករណីត្រូវបានចែងជាពិសេសដោយច្បាប់ ឬដីកា មន្ត្រីត្រូវតែលះបង់ពេលវេលាធ្វើការទាំងស្រុងរបស់ខ្លួន និងការយកចិត្តទុកដាក់លើមុខងារ ក្នុងការបំពេញទំនួលខុសត្រូវផ្លូវការរបស់ពួកគេ និងបំពេញមុខងារទាំងនោះដោយផ្ទាល់ ដែលរដ្ឋាភិបាលមូលដ្ឋានជាអ្នកទទួលខុសត្រូវ (មាត្រា ៣៥) ។ ជាទូទៅ ពួកគេត្រូវធ្វើដូច្នេះ ទោះបីជាមិនត្រូវបានតម្រូវអោយធ្វើដូច្នោះដោយច្បាប់ក៏ដោយ ។ នេះគឺជាភារកិច្ចដែលចែងដោយច្បាប់សាធារណៈ ដោយផ្អែកលើឋានៈរបស់ពួកគេជាមន្ត្រីរាជការ ក្នុងខណៈដែលភារកិច្ចរបស់បុគ្គលិកក្រុមហ៊ុនឯកជន ផ្អែកលើកិច្ចសន្យាបុគ្គល ។

ការលើកលែងពីភារកិច្ចលះបង់ចំពោះសេវា ត្រូវតែចែងដោយច្បាប់ ឬដីកា ។ ករណីសម្រាប់ការលើកលែងនេះគឺ :

(ក) ការចូលនិវត្តន៍បណ្តោះអាសន្ន ដោយសារវិធានការងារ
(ខ) ការចូលនិវត្តន៍បណ្តោះអាសន្នរបស់បុគ្គលិកដែលបំពេញកិច្ចការរបស់អង្គភាពបុគ្គលិកដែលចុះបញ្ជី ស្របតាមមាត្រា ៥៥-២ នៃច្បាប់នេះ
(គ) ការព្យួរដោយសារវិធានការបទវិន័យ
(ឃ) ថ្ងៃឈប់សម្រាកបុណ្យជាតិ និងច្បាប់ឈប់សម្រាក
(ង) ការបណ្តុះបណ្តាលពេលបំពេញការងារ
(ច) ចូលរួមនៅក្នុងសកម្មភាពកំសាន្តដែលរៀបចំឡើងដោយអាជ្ញាធរតែងតាំង ។ល។

នៅពេលខ្លះ ប្រាក់បៀវត្សរ៍ត្រូវបានបង់សម្រាប់រយៈពេលនៃការលើកលែង ប៉ុន្តែនៅក្នុងករណីផ្សេងទៀត ការបើកប្រាក់ត្រូវបានកាត់ទុក ។ ចំណុចនេះអាស្រ័យលើមូលហេតុសម្រាប់ការលើកលែង ។ បញ្ហានៃការបើកប្រាក់ត្រូវបានវិនិច្ឆ័យ ផ្អែកលើមូលដ្ឋានដាច់ដោយឡែកពីគ្នាមួយ ។

(៦) <u>ការដាក់កំហិតនៃសកម្មភាពនយោបាយ</u>

អព្យាក្រឹត្យភាពផ្នែកនយោបាយនៃមុខងារសាធារណៈត្រូវបានតម្រូវអោយមានជាដាច់ខាត ដូចមានចែងពីមុន១ តាមទិដ្ឋភាពនៃគំនិតមូលដ្ឋាននៃប្រព័ន្ធបុគ្គលិករាជការទំនើប ។ ចំណុចនេះកើតឡើងដោយសារ :

(ក) មន្ត្រីរាជការទាំងអស់គឺជាអ្នកបម្រើរបស់សហគមន៍ទាំងមូល មិនមែនជារបស់ក្រុមពិសេសណាមួយនៃសហគមន៍នេះឡើយ (រដ្ឋធម្មនុញ្ញ មាត្រា ១៥ កថាខ័ណ្ឌ ២)
(ខ) មន្ត្រីរាជការគួរត្រូវបានការពារពីឥទ្ធិពលនយោបាយណាមួយ និងត្រូវបានធានាចំពោះឋានៈរបស់ពួកគេ ។

ម្យ៉ាងទៀត មន្ត្រីរាជការទាំងអស់គួរត្រូវបានធានាអំពីសិទ្ធិនយោបាយរបស់ខ្លួនក្នុងឋានៈជាពលរដ្ឋម្នាក់ ។ ដូច្នេះ ច្បាប់នេះចែងអំពីការដាក់កំហិតលើសកម្មភាពនយោបាយរបស់មន្ត្រីរាជការ ក្នុងកម្រិតអប្បបរមា ដែលចាំបាច់ដើម្បីអោយមានការសម្រុះសម្រួលរវាងតម្រូវការទាំងនេះ ។

សកម្មភាពនយោបាយដែលដាក់កំហិតដោយមាត្រា ៣៦ នៃច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន មានដូចខាងក្រោម :

(ក) សកម្មភាពទាក់ទងនឹងការបង្កើតគណបក្សនយោបាយ ។ល។
    ក. ការចូលរួមនៅក្នុងការបង្កើតគណបក្សនយោបាយណាមួយ ឬនៅក្នុងអង្គភាពនយោបាយផ្សេងទៀត ។
    ខ. ការក្លាយជាមន្ត្រីនៃគណបក្សនយោបាយ ឬអង្គភាពនយោបាយផ្សេងទៀត
    គ. ការធ្វើយុទ្ធនាការឃោសនាសាធារណជនអោយក្លាយ (ឬមិនអោយក្លាយជា) សមាជិកនៃគណបក្សនយោបាយ ឬអង្គភាពនយោបាយផ្សេងទៀតណាមួយ ។

(ខ)　សកម្មភាពនយោបាយពិសេសជាមួយនឹងគោលបំណងនយោបាយពិសេស

ក.　គោលបំណងនយោបាយពិសេសមានដូចខាងក្រោម :

(i)　ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយពិសេស ឬអង្គភាពនយោបាយផ្សេងទៀតណាមួយ ទីស្តីការពិសេសណាមួយ ឬអង្គភាពប្រតិបត្តិនៃរដ្ឋាភិបាលមូលដ្ឋាន និង

(ii)　ដើម្បីគាំទ្រ ឬប្រឆាំងនឹងបុគ្គល ឬករណីពិសេសណាមួយ នៅក្នុងការបោះឆ្នោតជាសាធារណៈ ។

ខ.　សកម្មភាពនយោបាយពិសេស មានដូចខាងក្រោម :

(i)　ដើម្បីធ្វើយុទ្ធនាការឃោសនាអ្នកផ្សេងអោយបោះឆ្នោត (ឬមិនអោយបោះឆ្នោត) នៅក្នុងការបោះឆ្នោតជាសាធារណៈ ឬការបោះប្រជាមតិ ។

(ii)　ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងយុទ្ធនាការប្រមូលហត្ថលេខាណាមួយ តាមរយៈការធ្វើផែនការការឧបត្ថម្ភ ។ល។

(iii)　ដើម្បីចូលរួមនៅក្នុងការរៃអង្គាសអំណោយ ប្រាក់ ឬអ្វីផ្សេងទៀតដែលមានតម្លៃជាសាច់ប្រាក់

(iv)　ដើម្បីបិទផ្សាយ ឬអនុញ្ញាតអោយបិទផ្សាយនូវអក្សរ ឬរូបគំនូរនៅក្នុងអាគាររដ្ឋាភិបាលណាមួយ ឬគ្រឿងបរិក្ខាររបស់រដ្ឋាភិបាលមូលដ្ឋាន ឬការប្រើប្រាស់ ឬការអនុញ្ញាតអោយប្រើប្រាស់អាគាររដ្ឋាភិបាលណាមួយ គ្រឿងបរិក្ខារ សម្ភារៈ ឬមូលនិធិនៃរដ្ឋាភិបាលមូលដ្ឋាន និង

(v)　ក្រៅពីកិច្ចការដែលបានរៀបរាប់នៅក្នុងចំណុចខាងលើ សកម្មភាពនយោបាយដែលបានកំណត់ដោយដីកា ។

ក្នុងចំណោមសកម្មភាពទាំងនោះ សកម្មភាពនៅក្នុងចំណុច (i) (ii) (iii) និង (v) ត្រូវបានហាមឃាត់តែនៅក្នុងព្រំដែននៃរដ្ឋាភិបាលមូលដ្ឋានដែលពាក់ព័ន្ធប៉ុណ្ណោះ ។ (សកម្មភាពទាំងនេះត្រូវបានហាមឃាត់ ចំពោះបុគ្គលិកដែលធ្វើការនៅទីស្នាក់ការសាខា ឬទីស្នាក់ការមូលដ្ឋាននៃខេត្តណាមួយ ឬនៅទីស្នាក់ការមណ្ឌលបោះឆ្នោតនៃក្រុង ដែលបានចាត់តាំងណាមួយ តែនៅក្នុងព្រំដែនគតិយុត្តិនៃទីស្នាក់ការនេះប៉ុណ្ណោះ ។)

វិធាននេះមានករណីលើកលែងចំនួនពីរ : បុគ្គលិកភាគច្រើននៃសហគ្រាសសាធារណៈមូលដ្ឋាន និងបុគ្គលិកការងារគ្មានជំនាញ មិនស្ថិតនៅក្រោមការដាក់កំហិតណាមួយទាក់ទងនឹងសកម្មភាពនយោបាយឡើយ ។ ម្យ៉ាងទៀត បុគ្គលិកអប់រំត្រូវស្ថិតក្រោមការដាក់កំហិតដូចបុគ្គលិករាជការជាតិដែរ ទាក់ទងនឹងសកម្មភាពនយោបាយ ។

សកម្មភាពនយោបាយ ដែលហាមឃាត់ដោយច្បាប់បោះឆ្នោតជ្រើសរើសមុខងារសាធារណៈសម្រាប់បុគ្គលិក មានដូចខាងក្រោម :

(ក) មន្ត្រីរាជការ (រួមទាំងនាយក និងបុគ្គលិកនៃទីភ្នាក់ងាររដ្ឋបាលថ្នាក់មូលដ្ឋានជាក់លាក់ណាមួយ) មិនអាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រ ឬទីស្តីការគណៈរដ្ឋមន្ត្រី ឬធ្វើជាសមាជិកសភានៃរដ្ឋាភិបាល-មូលដ្ឋាន ឬប្រមុខរដ្ឋាភិបាលមូលដ្ឋានឡើយ ។ មន្ត្រីទាំងអស់ត្រូវបានចាត់ទុកថាបានលាឈប់ពីសេវាសាធារណៈនៅកាលបរិច្ឆេទចូលរួមក្នុងការបោះឆ្នោតនោះ ។

(ខ) សមាជិកក្រុមប្រឹក្សាគ្រប់គ្រងការបោះឆ្នោត មន្ត្រីនគរបាល និងមន្ត្រីប្រមូលពន្ធនៃរដ្ឋាភិបាលជាតិ និងមូលដ្ឋានត្រូវបានហាមឃាត់មិនអោយចូលរួមនៅក្នុងយុទ្ធនាការបោះឆ្នោតឡើយក្នុងកំឡុងពេលបំពេញមុខងាររបស់ខ្លួន ។

(គ) មន្ត្រីរាជការមិនអាចធ្វើយុទ្ធនាការដោយប្រើប្រាស់មុខដំណែងរបស់ខ្លួន ។

(ឃ) ប្រសិនបើមន្ត្រីរាជការម្នាក់ ដែលសង្ឃឹមក្លាយជាសមាជិកសភាតំណាងរាស្ត្រ ឬសមាជិកសភាក្រុមប្រឹក្សា ត្រូវស្វែងរកការគាំទ្រសម្រាប់ការបោះឆ្នោតដោយមិនបាច់លាឈប់ជាមុនពីសេវាសាធារណៈ បង្ហាញ ឬចែកចាយអក្សរ ឬរូបគំនូរសម្រាប់ការបោះឆ្នោត ឬមានឥទ្ធិពលលើមណ្ឌលបោះឆ្នោតរបស់ខ្លួន សកម្មភាពទាំងនេះត្រូវបានចាត់ទុកថាជាយុទ្ធនាការមុនបោះឆ្នោត ហើយត្រូវបានហាមឃាត់ដោយច្បាប់បោះឆ្នោតមន្ត្រីរាជការ ។

### (៧) ការហាមឃាត់មិនអោយធ្វើកូដកម្ម និងបង្កវិវាទផ្សេងៗ

បុគ្គលិកសេវាសាធារណៈត្រូវបានហាមឃាត់មិនអោយធ្វើកូដកម្ម និងចូលរួមនៅក្នុងមធ្យោបាយវិវាទផ្សេងៗ ។ លើសពីនេះទៀត គ្មានអ្នកណាម្នាក់ រួមទាំងបុគ្គលិក ធ្វើផែនការសកម្មភាពខុសច្បាប់នោះ ឬសមគំនិត ញុះញង់ ឬផ្តើមការអនុវត្តសកម្មភាពខុសច្បាប់នោះឡើយ ។

នៅក្នុងប្រទេសជប៉ុន សិទ្ធិមូលដ្ឋានរបស់កម្មករ-និយោជិត ដូចជា ការបង្កើតអង្គភាព ការតវ៉ា និងការធ្វើសកម្ម-ភាពរួមគ្នា ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ប៉ុន្តែបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ព្រមទាំងបុគ្គលិកសេវា សាធារណៈជាតិ ត្រូវបានហាមឃាត់មិនអោយធ្វើសកម្មភាពវិវាទ ដោយសារពួកគេធ្វើការដើម្បីប្រយោជន៍សាធារណៈ ក្នុងនាមជាអ្នកបម្រើរបស់សហគមន៍ទាំងមូល ។ ចំណុចលម្អិតត្រូវពិភាក្សាគ្នានៅពេលក្រោយ ។

### (៨) ការដាក់កំហិតលើការចូលរួមក្នុងសហគ្រាសរកប្រាក់ចំណេញ

មន្ត្រីទាំងអស់ត្រូវបានដាក់កំហិតមិនអោយចូលរួមនៅក្នុងសហគ្រាសរកប្រាក់ចំណេញណាមួយ តាមទស្សនៈនៃការធានាការអនុវត្តមុខងារសាធារណៈប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវ ។ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរតែងតាំង សកម្មភាពដូចខាងក្រោមត្រូវបានហាមឃាត់ :

(ក) កាន់កាប់មុខដំណែងមានសិទ្ធិអំណាចបច្ចុប្បន្នណាមួយពីលើមន្ត្រីជាន់ខ្ពស់នៃក្រុមហ៊ុន ឬអង្គភាពផ្សេងទៀតដែលមានគោលបំណងគ្រប់គ្រងសហគ្រាសឯកជនដើម្បីប្រាក់ចំណេញ

(ខ) គ្រប់គ្រងសហគ្រាសឯកជនដើម្បីប្រាក់ចំណេញ ដោយឯករាជ្យ និង

(គ) ចូលរួមនៅក្នុងកិច្ចការអាជីវកម្មណាមួយ ឬធ្វើការងារដើម្បីទទួលបានប្រាក់បៀវត្សរ៍ ។

ការដាក់កំហិតទាំងនេះត្រូវបានបង្កើតឡើងដើម្បីជៀសវាងស្ថានភាព ដែលអាចជះឥទ្ធិពលអវិជ្ជមានលើការបំពេញការតព្វកិច្ចសេវាសាធារណៈ ទោះបីជាសហគ្រាសនៅក្រៅម៉ោងធ្វើការក៏ដោយ និងដើម្បីអោយបុគ្គលិករាជការថ្នាក់មូលដ្ឋាន

អាចផ្តោតអារម្មណ៍លើភារកិច្ចផ្លូវការរបស់ខ្លួន ។ លើសពីនេះទៀត ការបំពេញដោយមិនលម្អៀងនូវកាតព្វកិច្ចសេវា-សាធារណៈ មិនត្រូវរំខានដោយផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ ការអនុញ្ញាតអោយចូលរួមនៅក្នុងសហគ្រាសរកប្រាក់ចំណេញ អាចត្រូវបានផ្តល់អោយដោយអាជ្ញាធរតែងតាំង លុះត្រាតែមានភាពច្បាស់លាស់ថា ពុំមានហានិភ័យដែលនឹងបំផ្លាញដល់ការទទួលខុសត្រូវផ្លូវការរបស់បុគ្គលិករាជការ ។

## ៣. វិធានការពាក់ព័ន្ធនឹងការផ្លាស់ប្តូរឋានៈ និងវិធានការវិន័យ

(១) ឋានៈរបស់បុគ្គលិក

ជាការចាំបាច់ដែលត្រូវការពារមន្ត្រីពីការបណ្តេញចោល និងការប្រព្រឹត្តមិនត្រឹមត្រូវផ្សេងទៀត ដោយកម្លាំងខាងក្រៅជាពិសេសឥទ្ធិពលនយោបាយ តាមទិដ្ឋភាពនៃការធានាអព្យាក្រឹត្យភាព និងស្ថិរភាពនៅក្នុងការបំពេញមុខងារសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ វាផ្ទុយនឹងប្រសិទ្ធភាពនៃមុខងារសាធារណៈដែលត្រូវធានាឋានៈជាមន្ត្រីរាជការ សម្រាប់មន្ត្រីណាដែលមិនអាចបំពេញភារកិច្ចរបស់ខ្លួនគួរជាទីពេញចិត្តទេ ។ ដូច្នេះ ច្បាប់នេះអនុញ្ញាតអោយអាជ្ញាធរតែងតាំងចាត់វិធានការទាក់ទងនឹងឋានៈរបស់អ្នកក្រោមឱវាទរបស់ខ្លួន ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ក្នុងករណីពួកគេស្ថិតក្នុងល័ក្ខខ័ណ្ឌណាមួយដែលចែងដោយច្បាប់ ។ ច្បាប់នេះ នៅពេលខ្លះ ការពារបុគ្គលិករាជការពីការបណ្តេញចេញ និងការផ្លាស់ប្តូរផ្សេងទៀតចំពោះឋានៈរបស់ខ្លួន ដោយផ្តល់ដំណឹងដល់អាជ្ញាធរតែងតាំងអោយចាត់វិធានការ ណាមួយប្រឆាំងនឹងឆន្ទៈរបស់ពួកគេ នៅក្នុងករណីផ្សេងទៀត ( មាត្រា ២៧ កថាខ័ណ្ឌ ២ មាត្រា ២៨) ។

វិធានការឋានៈចំនួនបួនប្រភេទអាចត្រូវបានចាត់ ដូចជា ការបណ្តេញចេញ ការដាក់អោយចូលនិវត្តន៍បណ្តោះ-អាសន្ន ការទម្លាក់ដំណែង និងការកាត់បន្ថយប្រាក់បៀវត្សរ៍ ។ ឥទ្ធិពលនៃវិធានការឋានៈនីមួយៗមានដូចខាងក្រោម :

(ក) ការបណ្តេញចេញ : វិធានការបណ្តេញបុគ្គលិកចេញពីមុខដំណែងរបស់ពួកគេ

(ខ) ការដាក់អោយចូលនិវត្តន៍ជាបណ្តោះអាសន្ន : វិធានការរារាំងបុគ្គលិកមិនអោយបំពេញភារកិច្ចរបស់ខ្លួនសម្រាប់រយៈពេលជាក់លាក់ណាមួយ

(គ) ការទម្លាក់ដំណែង : វិធានការតែងតាំងបុគ្គលិកទៅកាន់មុខដំណែងទាបជាងមុន

(ឃ) ការបន្ថយប្រាក់បៀវត្សរ៍ : វិធានការកំណត់ប្រាក់បៀវត្សរ៍ទាបជាងមុន ។

វិធានការទម្លាក់ដំណែង និងបណ្តេញចេញអាចត្រូវបានអនុវត្ត ក្នុងករណីមន្ត្រីណាម្នាក់ខកខានមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយដូចខាងក្រោម :

(ក) ពេលការបំពេញភារកិច្ចរបស់គាត់មិនគួរជាទីពេញចិត្ត

(ខ) ពេលគាត់មិនអាច ឬគ្មានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ដោយសារអសមត្ថភាពផ្នែកស្មារតី ឬរាងកាយ

(គ) ក្រៅពីករណីដែលមានចែងនៅក្នុងកថាខ័ណ្ឌទាំងពីរខាងលើ ពេលគាត់ខ្វះលក្ខណៈសម្បត្តិសម្រាប់សមត្ថភាពដែលត្រូវការសម្រាប់មុខដំណែងរបស់ខ្លួន និង

(ឃ) ពេលគាត់ក្លាយជាបុគ្គលិកលើសចំនួន ហើយមុខដំណែងរបស់គាត់ត្រូវបានរំលាយចោលដោយសារវិសោធនកម្ម ឬការធ្វើនិរាករណ៍នៃបទប្បញ្ញត្តិស្តីពីការរៀបចំការងារ ឬនៃដីកាស្តីពីចំនួនបុគ្គលិកដែលបានកំណត់ ឬដោយសារកាត់បន្ថយថវិកា ។

ការដាក់អោយចូលនិវត្តន៍ជាបណ្តោះអាសន្នអាចត្រូវបានជ្រើសរើសយក ប្រឆាំងនឹងឆន្ទៈរបស់មន្ត្រីទាក់ទងនឹងករណី ពេលគាត់ :

(ក) ស្នើសុំពន្យាររយៈពេលនៅសល់ ដោយសារអសមត្ថភាពផ្នែកស្មារតី ឬរាងកាយ

(ខ) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ និង/ឬ

(គ) ខកខានមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយដែលមានចែងដោយដីកា

ការកាត់បន្ថយប្រាក់បៀវត្សរ៍អាចធ្វើឡើងប្រឆាំងនឹងឆន្ទៈរបស់មន្ត្រីណាម្នាក់ ក្នុងករណីមន្ត្រីនោះខកខានមិនបានបំពេញ តាមល័ក្ខខ័ណ្ឌដែលចែងដោយដីកា ។ នីតិវិធី និងឥទ្ធិពលនៃការទម្លាក់ដំណែង ការបណ្តេញចេញ ការដាក់អោយចូលនិវត្តន៍ជាបណ្តោះអាសន្ន ឬការបន្ថយប្រាក់បៀវត្សរ៍ប្រឆាំងនឹងឆន្ទៈរបស់មន្ត្រីណាម្នាក់ត្រូវតែកំណត់ដោយដីកា ។

ចំនួនបុគ្គលិកដែលត្រូវស្ថិតក្រោមវិធានការឋានៈ ក្នុងឆ្នាំ២០០៥ មានដូចខាងក្រោម ។

**តារាងទី ២ : ចំនួនបុគ្គលិកដែលត្រូវស្ថិតក្រោមវិធានការឋានៈដែលត្រូវបានចាត់ថ្នាក់តាមល័ក្ខខ័ណ្ឌសម្រាប់វិធានការឋានៈ (គិតត្រឹមឆ្នាំ២០០៥)**

(នាក់)

| ប្រភេទនៃវិធានការឋានៈ / ល័ក្ខខ័ណ្ឌ | ការទម្លាក់ដំណែង | ការបណ្តេញចេញ | ការដាក់អោយចូលនិវត្តន៍ជាបណ្តោះអាសន្ន | ការកាត់បន្ថយប្រាក់បៀវត្សរ៍ | សរុប |
|---|---|---|---|---|---|
| ករណីការបំពេញភារកិច្ចមិនគួរជាទីពេញចិត្ត | ២៣ | ៣១ | - | - | ៥៤ |
| ករណីមានវិបត្តិផ្នែកស្មារតី ឬកាយសម្បទា | ៤៨ | ៣០ | ៣៧.២៨៧ | - | ៣៦៥ |
| ករណីខ្វះលក្ខណៈសម្បត្តិផ្នែកសមត្ថភាពដែលត្រូវការសម្រាប់មុខដំណែង | ៧៣ | ២៦ | - | - | ៩៩ |
| ករណីលើសចំនួន ដោយសារការធ្វើវិសោធនកម្ម ឬការលុបបទប្បញ្ញត្តិស្តីពីការរៀបចំការងារ ។ល។ | ២៩ | ៨៥ | - | - | ១១៤ |
| ករណីត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ | - | - | ៦៩ | - | ៦៩ |
| ករណីដោយសារល័ក្ខខ័ណ្ឌដែលចែងដោយដីកា | - | - | ២៧៥ | - | ២៧៥ |
| សរុប | ១៧៣ | ១៧២ | ៣៧.៦៣១ | - | ៣៧.៩៧៦ |

(២) <u>វិធានការវិន័យ</u>

ពេលមន្ត្រីរាជការណាម្នាក់ប្រព្រឹត្តអំពើជាកំហុសរំលោភបំពានលើភារកិច្ច ឬទំនួលខុសត្រូវរបស់ខ្លួន អាជ្ញាធរតែង-តាំងអាចចាត់វិធានការវិន័យប្រឆាំងនឹងឆន្ទៈរបស់មន្ត្រីនោះ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងវិន័យនៅក្នុងមុខងារសាធារណៈ

(មាត្រា ២៩) ។ វិធានការទាក់ទងនឹងឋានៈ ដូចមានចែងពីខាងដើម មិនត្រូវធ្វើអោយមន្ត្រីណាម្នាក់អាប់ឱនកិត្តិយស ដោយសារភាពទន់ខ្សោយ ឬការភ័ន្តច្រលំឡើយ ។ វិធានការនេះត្រូវបានអនុវត្តតែដើម្បីរក្សាប្រសិទ្ធភាពនៅក្នុងមុខងារសាធារណៈប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ វិធានការវិន័យធ្វើការស្តីបន្ទោសមន្ត្រីណាម្នាក់ ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវ ឬកំហុសឆ្គងរបស់ខ្លួន ដូចជាការរំលោភបំពានលើភារកិច្ចជាដើម ។

មានវិធានការវិន័យបួនប្រភេទ ដូចជា ការស្តីបន្ទោស ការកាត់ប្រាក់បៀវត្សរ៍ ការព្យួរការងារ និងការបណ្តេញចោល ។

ចំណុចលម្អិតនៃវិធានការវិន័យនីមួយៗ មានដូចខាងក្រោម :

(ក) វិធានការស្តីបន្ទោស : វិធានការដែលបញ្ជាក់ពីទំនួលខុសត្រូវចំពោះការរំលោភបំពានបទបញ្ជាដោយបុគ្គលិក និងដែលអមមកជាមួយនូវការព្រមាននាពេលក្រោយ

(ខ) ការកាត់ប្រាក់បៀវត្សរ៍ជាបទវិន័យ : វិធានការបើកប្រាក់បៀវត្សរ៍របស់បុគ្គលិកក្នុងចំនួនមួយដែលបានកាត់បន្ថយ (ជាទូទៅ មិនច្រើនជាងមួយភាគដប់ឡើយ) ក្នុងកំឡុងរយៈពេលជាក់លាក់ណាមួយ (ជាទូទៅ មិនច្រើនជាងប្រាំមួយខែឡើយ)

(គ) ការព្យួរពីភារកិច្ចជាបទវិន័យ : វិធានការដែលព្យួរបុគ្គលិកពីភារកិច្ច ក្នុងកំឡុងរយៈពេលជាក់លាក់ណាមួយ (ជាទូទៅ មិនច្រើនជាងប្រាំមួយខែឡើយ) ។ (ក្នុងកំឡុងរយៈពេលព្យួរ ប្រាក់បៀវត្សរ៍មិនត្រូវបានបង់ជូនឡើយ)

(ឃ) ការបណ្តេញចេញ : វិធានការបណ្តេញបុគ្គលិកចេញពីឋានៈជាបុគ្គលិករាជការ ។ (វិភាជន៍ចូលនិវត្តន៍មិនត្រូវបានបង់ជូនឡើយ ។)

មូលហេតុនៃការដាក់ទណ្ឌកម្មវិន័យត្រូវបានបញ្ចូលទាំងស្រុងនៅក្នុងករណីដូចខាងក្រោម ដែលចែងដោយច្បាប់ :

(ក) ពេលបុគ្គលិកបានប្រព្រឹត្តផ្ទុយនឹងច្បាប់នេះ ឬច្បាប់ផ្សេងទៀតដែលចែងអំពីអញ្ញត្រកម្មចំពោះច្បាប់នេះ ឬដីកា ឬបទប្បញ្ញត្តិដែលអង្គភាពសាធារណៈមូលដ្ឋាន ឬអង្គភាពរបស់ខ្លួនប្រកាសអោយប្រើក្រោមច្បាប់ខាងលើ

(ខ) ពេលបុគ្គលិកបានប្រព្រឹត្តផ្ទុយនឹងភារកិច្ចនៃមុខដំណែងរបស់ខ្លួន ឬបានធ្វេសប្រហែសនឹងភារកិច្ចរបស់ខ្លួន និង

(គ) ពេលបុគ្គលិកត្រូវបានរកឃើញថាមានទោសអំពីការប្រព្រឹត្តនូវកំហុសនោះ ដែលត្រូវបានចាត់ទុកថាមិនអាចធ្វើជាអ្នកបម្រើរបស់សហគមន៍ទាំងមូលបាន ។

នីតិវិធី និងផលប៉ះពាល់នៃវិធានការវិន័យត្រូវបានស្នើអោយកំណត់ដោយដីកា លើកលែងតែករណីដែលត្រូវបានចែងជាពិសេសដោយច្បាប់ ។

ច្បាប់ស្តីពីស្តង់ដារការងារត្រូវអនុវត្តចំពោះបុគ្គលិករាជការ ប្រសិនបើយើងផ្តោតលើបទប្បញ្ញត្តិទាក់ទងនឹងរយៈពេលអវត្តមានដែលអាចអនុញ្ញាតបាន ក្នុងករណីមានជំងឺ របួស ឬការឈប់សម្រាកមាតុភាព ។ ការកំណត់ពេលវេលានៃការជូនដំណឹងនៃការ បណ្តេញចេញ និងប្រាក់ឧបត្ថម្ភ ដូចមានចែងនៅក្នុងវិធានការវិន័យ ។

ចំនួនបុគ្គលិកដែលបានទទួលវិធានការវិន័យ នៅក្នុងឆ្នាំ២០០៥ មានដូចខាងក្រោម :

## តារាងទី ៣ : ចំនួនបុគ្គលិកដែលបានទទួលវិធានការវិន័យ (ឆ្នាំ២០០៥)

| មូលហេតុ | ស្តីបន្ទោស | កាត់ប្រាក់បៀវត្សរ៍ | ព្យួរពីភារកិច្ច | បណ្តេញចេញ | សរុប | (សូមមើល) ការព្រមាន ។ល។ |
|---|---|---|---|---|---|---|
| ការរំលោភច្បាប់ និង/ឬបទបញ្ជា | ៩២៦ | ៦១៩ | ៤៧២ | ១៨៩ | ២.២០៦ | ៤.៧០៩ |
| ការរំលោភភារកិច្ច ស្តីពីកិច្ចការអាជីវកម្ម ឬការធ្វេសប្រហែសលើភារកិច្ច | ៩៦៧ | ៧៣៣ | ១៣៥ | ៣៥ | ១.៨៧០ | ៧.៧៦១ |
| កំហុសដែលធ្វើអោយមិនអាចធ្វើជាអ្នកបម្រើរបស់សហគមន៍ទាំងមូលបាន | ៦១៦ | ៤៨៨ | ៤១៣ | ២៥៣ | ១.៧៧០ | ៣.២៤៦ |
| សរុប | ២.៥០៩ | ១.៨៤០ | ១.០២០ | ៤៧៧ | ៥.៨៤៦ | ១៥.៧១៦ |

## តារាងទី ៤ : មូលហេតុជាក់លាក់សម្រាប់បុគ្គលិកដែលបានទទួលវិធានការវិន័យ (គិតត្រឹមឆ្នាំ២០០៥)

| មូលហេតុ | ស្តីបន្ទោស | កាត់ប្រាក់បៀវត្សរ៍ | ព្យួរពីភារកិច្ច | បណ្តេញចេញ | សរុប | ព្រមាន ។ល។ |
|---|---|---|---|---|---|---|
| ១. ការទទួលយកសំណូកដោយមិនស្របច្បាប់ | ៣១ | ១០ | ៦ | ៤ | ៥១ | ១២៤ |
| ២. វិវាទ | ៧៤ | ១ | ៧៦ | ០ | ១៥១ | ១១៩ |
| ៣. សកម្មភាពរៀបចំបង្កើតអង្គភាពបុគ្គលិកដោយមិនស្របច្បាប់ | ០ | ០ | ០ | ០ | ០ | ០ |
| ៤. ការរំលោភភារកិច្ចរក្សាការសម្ងាត់ | ១២ | ៩ | ៤ | ០ | ២៥ | ៥៥ |
| ៥. ការរំលោភភារកិច្ចលះបង់ចំពោះសេវា | ១៦៩ | ១៦៥ | ១៣ | ៤ | ៣៥១ | ៤៥៩ |
| ៦. ការរំលោភការដាក់កំហិតលើសកម្មភាពនយោបាយ | ០ | ០ | ១ | ០ | ១ | ៤ |
| ៧. ការរំលោភការដាក់ | ១២ | ១៧ | ៦ | ០ | ៣៥ | ៥៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កំហិតលើការចូលរួមនៅក្នុងសហគ្រាសពាណិជ្ជកម្ម ។ល។ | | | | | | |
| ៨. | អវត្តមាន ភាពយឺតយ៉ាវ ការចេញមុនម៉ោង ឥរិយាបថធ្វើការមិនល្អ | ៩៣ | ៦៨ | ៤៨ | ៩ | ១៧៨ | ៩៣ |
| ៩. | ការរំលោភច្បាប់បោះឆ្នោតមុខងារសាធារណៈ | ០ | ១ | ០ | ០ | ១ | ៧ |
| ១០. | ការរំលោភទូទៅផ្សេងទៀតនៃសេវា | ៧១២ | ៥១៣ | ២៦១ | ៨១ | ១.៥៦៧ | ៤.៧០៣ |
| ១១. | ការរំលោភជាបទព្រហ្មទណ្ឌ ឬបទឧក្រិដ្ឋផ្សេងទៀតនៅក្នុងភារកិច្ច | ១២១ | ២១៧ | ២៥១ | ១៩២ | ៧៨១ | ៦៥៦ |
| ១២. | បទឧក្រិដ្ឋនៅក្នុងសេវាសាធារណៈ ដូចជា ការទទួលសំណូក ឬការកេងប្រវ័ញ្ច | ៧ | ១១ | ៤ | ១១៧ | ១៣៩ | ១៣ |
| ១៣. | ការរំលោភច្បាប់ចរាចរណ៍ផ្លូវគោក | ៨៩៥ | ៤៦៦ | ៣៤៥ | ៧០ | ១.៧៧៦ | ៥.០៧២ |
| ១៤. | ការខកខាននៅក្នុងការត្រួតពិនិត្យទំនួលខុសត្រូវ | ៤២៣ | ៣៦២ | ៥ | ០ | ៧៩០ | ៤.៣៩៥ |
| សរុប | | ២.៥០៩ | ១.៨៤០ | ១.០២០ | ៤៧៧ | ៥.៨៤៦ | ១៥.៧១៦ |

## ៤. ប្រព័ន្ធកម្រិតអាយុចូលនិវត្តន៍

(១) <u>អាយុចូលនិវត្តន៍</u>

ប្រព័ន្ធកម្រិតអាយុចូលនិវត្តន៍សម្រាប់មន្ត្រីរាជការ ដែលចែងថាបុគ្គលិកត្រូវចូលនិវត្តន៍ដោយស្វ័យប្រវត្តិពេលដល់អាយុជាក់លាក់ណាមួយ បានចាប់ផ្តើមនៅឆ្នាំ១៩៨៥ ។

ប្រព័ន្ធនេះគឺជាវិធានការឋានៈមួយប្រភេទនៅក្នុងន័យទូលំទូលាយ ។ ការកម្រិតអាយុចូលនិវត្តន៍មានគោលបំណងរក្សា និងកែលម្អប្រសិទ្ធភាពការងារ ដោយលើកកម្ពស់ការផ្លាស់ប្តូរបុគ្គលិក និងធានាការគ្រប់គ្រងភារកិច្ចផ្លូវការប្រកបដោយស្ថិរភាព ដោយធានាឋានៈ និងរបបចិញ្ចឹមជីវិតរបស់មន្ត្រីរាជការរហូតដល់អាយុដែលបានកំណត់ ។

ប្រព័ន្ធកម្រិតអាយុចូលនិវត្តន៍ផ្តោតលើការងារអស់មួយជីវិត ដើម្បីអោយប្រព័ន្ធនេះអនុវត្តចំពោះបុគ្គលិកពេញម៉ោងក្រោមការតែងតាំងជាធម្មតា ហើយមិនអនុវត្តចំពោះបុគ្គលិកបណ្តោះអាសន្នជាមួយនឹងរយៈពេលតែងតាំង ដែលបានកំណត់ជាមុន បុគ្គលិកដែលត្រូវបានតែងតាំងមានរយៈពេលកំណត់ និងបុគ្គលិកក្រៅម៉ោង ដែលបំពេញមុខដំណែងមិនទៀងទាត់ ។

សេចក្ដីបរិយាយនៃប្រព័ន្ធចូលនិវត្តន៍សម្រាប់បុគ្គលិករាជការថ្នាក់មូលដ្ឋានមានដូចខាងក្រោម :

(ក) អាយុចូលនិវត្តន៍ត្រូវកំណត់ដោយដីកាផ្អែកលើស្តង់ដារដែលត្រូវកំណត់ចំពោះបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ជាគោលការណ៍ គឺ ៦០ ឆ្នាំ ប៉ុន្តែត្រូវនៅចន្លោះ ៦០ និង ៦៥ ឆ្នាំសម្រាប់ប្រភេទមន្ត្រីដែលបានកំណត់ ។

(ខ) មន្ត្រីម្នាក់ត្រូវចូលនិវត្តន៍ ដូចបានកំណត់ដោយដីកាវវាងថ្ងៃដែលគាត់ឈានដល់អាយុចូលនិវត្តន៍ដែលបានកំណត់ និងថ្ងៃទី៣១ ខែមីនា បន្ទាប់ ។

(គ) ពេលមានភារកិច្ច និងទំនួលខុសត្រូវពិសេស ឬមានការលំបាកក្នុងការបំពេញមុខដំណែងទំនេរអាយុចូលនិវត្តន៍ ពិសេសអាចត្រូវបានកំណត់ដោយដីកា ។

(២) <u>ការពន្យារអាយុចូលនិវត្តន៍</u>

ពេលមានមូលហេតុគ្រប់គ្រាន់ដើម្បីរំពឹងថាការលំបាកធ្ងន់ធ្ងរនឹងកើតឡើងនៅក្នុងការគ្រប់គ្រងភារកិច្ចផ្លូវការ ដោយសារការចូលនិវត្តន៍របស់បុគ្គលិក ដែលនឹងចូលនិវត្តន៍ជាធម្មតាដោយសារឈានដល់អាយុជាក់លាក់មួយ និងដោយសារ ប្រភេទពិសេសនៃភារកិច្ចរបស់ពួកគេ ឬមូលហេតុពិសេសទាក់ទងនឹងការបំពេញភារកិច្ចរបស់ពួកគេ អាជ្ញាធរតែងតាំងអាច ពន្យារអាយុចូលនិវត្តន៍សម្រាប់រយៈពេលមួយមិនលើសពីមួយឆ្នាំស្របតាមបញ្ញត្តិដែលបានចែង ។ សម្រាប់មូលហេតុ ដូចគ្នា ការពន្យារពេលអាចធ្វើឡើងម្តងហើយម្តងទៀតរហូតដល់បីឆ្នាំ ក្រោយពេលចូលនិវត្តន៍ ។

(៣) <u>ការតែងតាំងឡើងវិញ</u>

ចំពោះបុគ្គលិកដែលចូលនិវត្តន៍នៅអាយុចូលនិវត្តន៍ ឬក្រោយពេលពន្យារអាយុចូលនិវត្តន៍ ហើយក្រោយមក ត្រូវបានវិនិច្ឆ័យថាត្រូវការ (ជាពិសេស ដោយគិតអំពីលទ្ធភាព និងបទពិសោធន៍របស់ពួកគេសម្រាប់ការគ្រប់គ្រងប្រកប ដោយប្រសិទ្ធភាពនៃភារកិច្ចផ្លូវការ) អាជ្ញាធរតែងតាំងអាចតែងតាំងឡើងវិញនូវបុគ្គលិកនោះ សម្រាប់មុខដំណែងពេញម៉ោង ឬក្រៅម៉ោង សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំស្របតាមបញ្ញត្តិដែលចែងដោយដីកា ។

(៤) <u>ប្រព័ន្ធចូលនិវត្តន៍តាមការស្នើសុំ</u>

ទោះបីជាមិនមានចែងនៅក្នុងច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋានក៏ដោយ ផ្សេងពីប្រព័ន្ធកម្រិតអាយុចូលនិវត្តន៍ ប្រព័ន្ធចូលនិវត្តន៍មុនអាយុកើតមានឡើង ដែលក្នុងនោះអាជ្ញាធរតែងតាំងអាចស្នើអោយបុគ្គលិកចូលនិវត្តន៍មុនអាយុ ហើយបុគ្គលិកដែលយល់ព្រមទទួលយកការស្នើនោះចូលនិវត្តន៍តាមការផ្តួចផ្តើមផ្ទាល់របស់ខ្លួន ។ ការចូលនិវត្តន៍គឺជា ការជ្រើសរើសផ្ទាល់របស់បុគ្គលិក ទោះបីជាបុគ្គលិកនោះនឹងចូលនិវត្តន៍ឬអត់ ស្របតាមសំណើអោយចូលនិវត្តន៍មុនអាយុ ក៏ដោយហើយបុគ្គលិកមិនត្រូវបានបង្ខំអោយទទួលយកសំណើនោះឡើយ ។ ពេលបុគ្គលិកចូលនិវត្តន៍តាមសំណើអោយ ចូលនិវត្តន៍មុនអាយុ វិភាជន៍ចូលនិវត្តន៍របស់ពួកគេ នឹងកើនឡើងតាមសមាមាត្រ ។ បន្ថែមពីនេះទៀត អាជ្ញាធរ-មូលដ្ឋានខ្លះជួយបុគ្គលិក ចូលនិវត្តន៍អោយរកបានការងារធ្វើឡើងវិញនៅក្នុងវិស័យសាធារណៈ ឬឯកជនទៀតផង ។

# ជំពូកទី ៤ : សំណង និងល័ក្ខខ័ណ្ឌការងារផ្សេងៗ

## ១. សំណង

(១) <u>គោលការណ៍ផ្ដល់សំណង</u>

ច្បាប់ចែងថាការផ្ដល់សំណងរបស់បុគ្គលិករាជការថ្នាក់មូលដ្ឋានត្រូវស្របតាមភារកិច្ច និងទំនួលខុសត្រូវរបស់ពួកគេ ។ នេះគឺជាគោលការណ៍ "បៀវត្សរ៍ភារកិច្ច" គឺបៀវត្សរ៍សម្រាប់ភារកិច្ចដែលបានបំពេញ ។ ច្បាប់បានអនុម័តយកគោលការណ៍នេះ ទោះបីជាធ្លាប់មានទម្លាប់ដ៏មានឧត្តមានុភាពនៃ "បៀវត្សរ៍ឧបត្ថម្ភជីវភាព" ក៏ដោយ ។ ប៉ុន្តែតាមពិត វាមានការលំបាកណាស់ក្នុងការផ្លាស់ប្ដូរចរិតលក្ខណៈនៃបៀវត្សរ៍របស់មន្ត្រីរាជការ ក្នុងរយៈពេលដ៏ខ្លីនោះ ។ ដោយហេតុនេះច្បាប់យកគោលការណ៍នេះធ្វើជាការតម្រង់ទិសសម្រាប់ការផ្លាស់ប្ដូរបន្តិចម្ដងៗនៃប្រព័ន្ធបៀវត្សរ៍ ដែលរៀបរាប់ថា គោលបំណងនៃគោលការណ៍ ត្រូវសម្រេចអោយរួចរាល់អោយបានឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបាន ។ បច្ចុប្បន្ននេះ បៀវត្សរ៍មានចរិតរឹងមាំនៃបៀវត្សរ៍ឧបត្ថម្ភជីវភាព ហើយដោយសារវិសាលភាពនៃការបង់ប្រាក់បៀវត្សរ៍ គឺផ្អែកលើអតីតភាពការងារ គោលបំណងនៃច្បាប់នេះនៅតែមិនអាចសម្រេចបាន ។

សំណងរបស់បុគ្គលិកដែលមានចែងត្រូវតែកំណត់ឡើងដោយពិចារណាលើតម្លៃជីវភាព ស្ដង់ដារបៀវត្សរ៍របស់បុគ្គលិកនៅក្នុងរដ្ឋាភិបាលកណ្ដាល រដ្ឋាភិបាលមូលដ្ឋាន និងសហគ្រាសឯកជនផ្សេងទៀត និងកត្តាផ្សេងៗ ។ គោលការណ៍នេះ ហៅថា គោលការណ៍ "សមកម្ម" ។

ចំណុចទីបី គ្មានសំណងណាមួយអាចត្រូវបានធ្វើឡើងឡើយ លើកលែងតែផ្អែកលើច្បាប់ ឬដីកា ដែលត្រូវបានអនុញ្ញាតត្រឹមត្រូវដោយច្បាប់ ដូចមានចែងដោយច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន ។ គោលការណ៍នេះហៅថា គោលការណ៍ "បៀវត្សរ៍ដោយដីកា" ។ សំណងរបស់មន្ត្រីរាជការអាចត្រូវបានកំណត់តែដោយសភាថ្នាក់មូលដ្ឋានដែលតំណាងអោយប្រជាជននៅក្នុងមូលដ្ឋាន ព្រោះចំណាយសម្រាប់សំណងត្រូវរ៉ាប់រងដោយពួកគេ ។ ចំណុចនេះក៏មានន័យថា ស្ដង់ដារមួយចំនួននៃសំណង ត្រូវតែធានាដោយរដ្ឋាភិបាលមូលដ្ឋាន តាមរយៈដីកាសម្រាប់បុគ្គលិកដែលពុំមានសិទ្ធិក្នុងការចុះកិច្ចសន្យារួមគ្នាជាមួយនិយោជករបស់ពួកគេ ។

ជាករណីលើកលែងចំពោះគោលការណ៍ខាងលើ ចំណុចនេះមិនត្រូវបានអនុវត្តទាំងស្រុងចំពោះរបៀបដែលក្នុងនោះសំណងសម្រាប់កម្មករ-និយោជិត និងបុគ្គលិកគ្មានជំនាញនៃសហគ្រាសសាធារណៈថ្នាក់មូលដ្ឋានត្រូវបានកំណត់ឡើយ ។ ប្រភេទ និងគោលការណ៍ណែនាំនៃបៀវត្សរ៍របស់សមាជិកនៃក្រុមបុគ្គលិកទាំងនេះ ត្រូវតែកំណត់ដោយដីកា ប៉ុន្តែបញ្ហាផ្សេងទៀត ដែលទាក់ទងនឹងបៀវត្សរ៍ ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងគ្រប់គ្រងការងារទាក់ទងនឹងបៀវត្សរ៍ជាមួយនឹងអាជ្ញាធរមូលដ្ឋាន ឬអង្គភាពប្រតិបត្តិដែលពាក់ព័ន្ធ ។ បុគ្គលិកទាំងនោះត្រូវបានអនុញ្ញាតអោយចុះកិច្ចព្រមព្រៀងគ្រប់គ្រងការងារ (ទាក់ទងនឹងបៀវត្សរ៍) ជាមួយអាជ្ញាធរមូលដ្ឋាន ។

(២) <u>ប្រាក់បៀវត្សរ៍</u>

ប្រាក់បៀវត្សរ៍គឺជាប្រាក់ឈ្នួលការងារដែលបានបំពេញ នៅក្នុងម៉ោងធ្វើការទៀងទាត់ ។ ខ្លឹមសារ និងទម្រង់ប្រាក់បៀវត្សរ៍ខុសគ្នាពីរដ្ឋាភិបាលមូលដ្ឋាន ក្នុងទិដ្ឋភាពខ្លះ ប៉ុន្តែត្រូវបានរៀបរាប់ជារួមដូចខាងក្រោម :

ទឹកប្រាក់បៀវត្សរ៍ត្រូវបានកំណត់ជាកាំបៀវត្សរ៍ ដែលចែងស្របតាមប្រភេទនៃមុខងារសាធារណៈ ។ រដ្ឋាភិបាលកណ្តាលមានកាំបៀវត្សរ៍ផ្សេងៗគ្នាចំនួនដប់ប្រាំមួយសម្រាប់បុគ្គលិករបស់ខ្លួន ។ ដោយសារកម្រិត និងប្រព័ន្ធមុខដំណែងនៃរដ្ឋាភិបាលមូលដ្ឋាននីមួយៗខុសប្លែកគ្នា វាជាការមិនត្រឹមត្រូវដែលត្រូវអនុវត្តដោយផ្ទាល់នូវកាំបៀវត្សរ៍ សម្រាប់បុគ្គលិកសេវាសាធារណៈថ្នាក់ជាតិ និងបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ។ ជាឧទាហរណ៍ កាំបៀវត្សរ៍ជាប់ពន្ធ កាំបៀវត្សរ៍មុខងារ-ជាក់លាក់ ឬកាំបៀវត្សរ៍រដ្ឋបាលពិសេស ។ល។ ជាគោលការណ៍ មិនត្រូវបានប្រើនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន ទោះបីជារដ្ឋាភិបាលកណ្តាលមានកាំបៀវត្សរ៍ទាំងនេះក៏ដោយ ។ មានប្រភេទកម្រិតចាំបាច់នៅក្នុងរដ្ឋាភិបាលមូលដ្ឋាន នីមួយៗ ដូចជាកាំបៀវត្សរ៍សម្រាប់ស្មៀនរដ្ឋបាល គ្រូបង្រៀន មន្ត្រីនគរបាល បុគ្គលិកស្រាវជ្រាវ អ្នកវិជ្ជាជីវៈវេជ្ជសាស្ត្រ ។ល។

មានកម្រិតជាច្រើននៅក្នុងកាំបៀវត្សរ៍នីមួយៗ ដែលឆ្លុះបញ្ចាំងពីកម្រិតនៃភារកិច្ច និងទំនួលខុសត្រូវតាមលំដាប់ ។ រាល់មុខដំណែងទាំងអស់ត្រូវបានចាត់ថ្នាក់តាមកម្រិតនៅក្នុងបញ្ជីការងារស្តង់ដារ ជាមួយនឹងកាំបៀវត្សរ៍ដែលពួកគេមាន ។ ចំនួនបុគ្គលិកនៅក្នុងបញ្ជីការងារស្តង់ដារត្រូវបានកំណត់សម្រាប់កម្រិតនីមួយៗនៃកាំបៀវត្សរ៍ទាំងអស់ដើម្បីចាត់ថ្នាក់ បុគ្គលិកទាំងនោះ ។

កម្រិតនីមួយៗកំណត់ពីប្រាក់បៀវត្សរ៍ជាក់លាក់មួយ ។ មន្ត្រីរាជការនៅក្នុងកម្រិតជាក់លាក់មួយ មានប្រាក់-បៀវត្សរ៍ ខុសប្លែកគ្នានៅក្នុងថ្នាក់នៃកម្រិត ដោយសារពួកគេដំឡើងកម្រិតបទពិសោធន៍របស់ពួកគេ នៅក្នុងភារកិច្ច និងភាពប៉ិនប្រសប់របស់ពួកគេ ។

ក្នុងករណីរដ្ឋាភិបាលមូលដ្ឋានមានគណៈកម្មការបុគ្គលិក ច្បាប់អនុញ្ញាតអោយគណៈកម្មការធ្វើរបាយការណ៍អំពីកាំបៀវត្សរ៍ និងប្រសិនបើវាត្រូវបានចាត់ទុកថាមានសារៈសំខាន់ ផ្តល់អនុសាសន៍អំពីកាំបៀវត្សរ៍ជូននាយកប្រតិបត្តិ និងសភា ថ្នាក់មូលដ្ឋាន យ៉ាងហោចណាស់ម្តងជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យមើល និងរក្សាស្តង់ដារបៀវត្សរ៍ នៅក្នុងកម្រិតសមស្រប ។ សេវាគណៈកម្មការ គឺជាប្រព័ន្ធដើម្បីការពារផលប្រយោជន៍របស់បុគ្គលិក ។

នៅក្នុងរដ្ឋាភិបាលមូលដ្ឋានដែលគ្មានគណៈកម្មការបុគ្គលិក មានការទទួលស្គាល់ថាមន្ត្រីប្រធានប្រតិបត្តិ និងសភាថ្នាក់មូលដ្ឋានត្រូវចាត់វិធានការសមស្របទាក់ទងនឹងប្រាក់បៀវត្សរ៍របស់បុគ្គលិកដែលនៅក្រោមឱវាទរបស់ខ្លួន ។

(៣) <u>វិភាជន៍</u>

សំណងផ្សេងពីប្រាក់បៀវត្សរ៍ហៅថាវិភាជន៍ ។ ប្រភេទនៃវិភាជន៍ ត្រូវបានកំណត់និយមន័យដូចអ្វីដែលមានរៀបរាប់នៅក្នុងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ហើយអង្គភាពសាធារណៈមូលដ្ឋាននីមួយៗអាចបង្កើត និងបង់វិភាជន៍នៃប្រភេទដែលចាំបាច់នៅក្នុងបញ្ញត្តិនៃដីកា ។

ប្រភេទនៃវិភាជន៍ ដែលច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានអនុញ្ញាតអោយរដ្ឋាភិបាលមូលដ្ឋានបង្កើត មានដូចខាងក្រោម :

(ក) វិភាជន៍គ្រួសារ :

វិភាជន៍គ្រួសារត្រូវបង់អោយបុគ្គលិកដែលរស់នៅជាមួយប្តី/ប្រពន្ធរបស់ពួកគេ កូន ឬចៅអាយុក្រោម ២២ ឆ្នាំ (គិតត្រឹមថ្ងៃទី៣១ ខែមីនា ក្រោយពេលពួកគេមានអាយុគ្រប់ ២២ ឆ្នាំ) ឪពុកម្តាយ ឬជីដូនជីតា អាយុលើសពី ៦០ ឆ្នាំ ។ល។

(ខ)  វិភាជន៍តំបន់ :

វិភាជន៍តំបន់ត្រូវបង់អោយបុគ្គលិក ដែលធ្វើការនៅក្នុងតំបន់ដែលប្រាក់បៀវត្សរ៍នៅក្នុងសហគ្រាសឯកជន តម្លៃ និងថ្លៃជីវភាពមានកម្រិតខ្ពស់គួរអោយកត់សម្គាល់ (ទីក្រុងធំៗដូចជា តូក្យូ ឬអូសាកា និងតំបន់ជាយក្រុងនៃទីក្រុងទាំងនោះ) ។

(គ)  វិភាជន៍លំនៅដ្ឋាន :

វិភាជន៍លំនៅដ្ឋានត្រូវបង់អោយបុគ្គលិកដែលជួលផ្ទះស្នាក់នៅ ឬបុគ្គលិកដែលមានផ្ទះស្នាក់នៅខ្លួនឯង ។

(ឃ)  វិភាជន៍ធ្វើដំណើរ :

វិភាជន៍ធ្វើដំណើរត្រូវបង់ដើម្បីទូទាត់ថ្លៃធ្វើដំណើរ នៅក្នុងកម្រិតជាក់លាក់មួយ ។ ដោយសារចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់តាមសមាមាត្រនៃថ្លៃចំណាយលើថ្លៃជាក់ស្តែងនៃសំបុត្រមធ្យោបាយធ្វើដំណើរ ។ល។ ចំនួនទឹកប្រាក់ នេះគឺជាការទូទាត់សងចំពោះចំណាយជាក់ស្តែងទាំងនោះ ។

(ង)  វិភាជន៍ការងារពិសេស :

វិភាជន៍ការងារពិសេសត្រូវបង់សម្រាប់ភារកិច្ចពិសេសដែលមានជាឧទាហរណ៍ដូចជា ការងារប្រកបដោយគ្រោះថ្នាក់ ស្មោគគ្រោក ប៉ះពាល់ដល់សុខភាព លំបាក ។ល។ តាមការអនុវត្តជាក់ស្តែង វិភាជន៍ប្រភេទនេះតែងតែបង់អោយបុគ្គលិកដែលបម្រើការងារពាក់ព័ន្ធនឹងការបង្ការជំងឺ ការងារនៅទីកន្លែងខ្ពស់ ការងារជាមួយកាំរស្មី ។ល។

(ច)  វិភាជន៍ការងារនៅតំបន់ពិសេស :

វិភាជន៍ការងារនៅតំបន់ពិសេស ត្រូវបង់ដល់បុគ្គលិកដែលធ្វើការនៅកន្លែងមានភាពមិនអំណោយផលខ្លាំង ដូចជានៅកោះដាច់ស្រយាល ។

(ឆ)  វិភាជន៍លើសម៉ោង :

វិភាជន៍លើសម៉ោងត្រូវបង់ដល់បុគ្គលិកដែលត្រូវបានបង្គាប់អោយធ្វើការលើសម៉ោងធ្វើការធម្មតា ។

(ជ)  វិភាជន៍ចប់វគ្គ :

វិភាជន៍ចប់វគ្គត្រូវបង់អោយស្មើនឹងលាភការពិសេសនៅក្នុងសហគ្រាសឯកជន ដូចជាប្រាក់រង្វាន់បន្ថែម ហើយគឺជាប្រព័ន្ធរក្សាតុល្យភាពជាមួយកាលៈទេសៈជាក់ស្តែងនៃការបង់វិភាជន៍ប្រភេទនេះ នៅក្នុងសហគ្រាសឯកជន ។

(ឈ)  វិភាជន៍សម្រាប់ការប្រឹងប្រែង :

វិភាជន៍សម្រាប់ការប្រឹងប្រែងមានចរិតលក្ខណៈជាបៀវត្សរ៍លើកទឹកចិត្ត
ដែលធ្វើឡើងជាការតបស្នងចំពោះស្នាដៃការងារក្នុងកំឡុងរយៈពេលជាក់លាក់ណាមួយ ។

(ញ)  វិភាជន៍តំបន់ត្រជាក់ :

វិភាជន៍តំបន់ត្រជាក់ត្រូវបង់អោយបុគ្គលិកដែលធ្វើការនៅកន្លែងមានអាកាសធាតុត្រជាក់ និងធ្លាក់ព្រិលខ្លាំង ដូចជា នៅហុកកៃដូ ។

ទាំងនេះគឺជាវិភាជន៍តំណាង ចំណែកឯវិភាជន៍ផ្សេងទៀត មានវិភាជន៍ថ្នាក់លើ វិភាជន៍យាមយប់ ឬថ្ងៃ វិភាជន៍ភារកិច្ចមហន្តរាយ ។ល។

ចំនួនទឹកប្រាក់
និងរបៀបបង់វិភាជន៍ត្រូវចែងដោយដីកាតាមរបៀបដូចគ្នានឹងវិភាជន៍សម្រាប់រដ្ឋាភិបាលកណ្តាលដែរ ។

## ២. ម៉ោងធ្វើការ ថ្ងៃឈប់សម្រាក និងច្បាប់ឈប់សម្រាក

(១) ម៉ោងធ្វើការ

បុគ្គលិករាជការមូលដ្ឋាន ត្រូវតែលះបង់ខ្លួនដើម្បីការងាររបស់ខ្លួន ក្នុងកំឡុងម៉ោងធ្វើការ ។

ម៉ោងធ្វើការរបស់បុគ្គលិករាជការមូលដ្ឋាន ត្រូវតែកំណត់ដោយដីការបស់រដ្ឋាភិបាលមូលដ្ឋានស្របតាមស្តង់ដារគ្រឹះនៃច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ដោយគិតគូរយ៉ាងសមស្របដល់គោលការណ៍ ដែលម៉ោងធ្វើការមិនហួសពីសមាមាត្រជាមួយម៉ោងធ្វើការរបស់បុគ្គលិកនៅក្នុងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋានផ្សេងទៀត ។

លើសពីនេះទៀត ជាគោលការណ៍ ច្បាប់ស្តីពីស្តង់ដារការងារត្រូវអនុវត្តចំពោះបុគ្គលិករាជការមូលដ្ឋាន ។ ម៉ោងធ្វើការរបស់បុគ្គលិករាជការមូលដ្ឋាន ត្រូវមានដូចនៅក្នុងការកំណត់ដែលចែងដោយច្បាប់ស្តីពីស្តង់ដារការងារ ។ ម៉ោងធ្វើការត្រូវបានចែងជាមូលដ្ឋាន ដើម្បីកុំអោយលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ និង ៤០ ម៉ោងក្នុងមួយសប្តាហ៍ ។ ចំពោះមន្ត្រី និងបុគ្គលិករដ្ឋាភិបាលមូលដ្ឋាន ម៉ោងធ្វើការគឺ ៤០ ម៉ោងក្នុងមួយសប្តាហ៍ ក្រោមប្រព័ន្ធប្រាំថ្ងៃក្នុងមួយសប្តាហ៍ ។

និយោជកត្រូវតែផ្តល់ដល់មន្ត្រីរាជការមូលដ្ឋាននូវម៉ោងសម្រាកសរុបចំនួន ៤៥នាទី ក្នុងរយៈពេលប្រាំបីម៉ោងនៃថ្ងៃធ្វើការដូចមានចែងដោយច្បាប់ស្តីពីស្តង់ដារការងារ ។ ម៉ោងសម្រាកក៏ត្រូវបានផ្តល់អោយ ក្នុងកំឡុងម៉ោងធ្វើការធម្មតា ដើម្បីអោយបុគ្គលិកសម្រាកពីការនឿយហត់ ក្រោយពេលធ្វើការអស់រយៈពេលជាច្រើនម៉ោង និងបង្កើនប្រសិទ្ធភាពការងារផ្លូវការ ។

(២) ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ និងថ្ងៃឈប់បុណ្យជាតិ

ជាគោលការណ៍ មន្ត្រីរាជការមូលដ្ឋាន ត្រូវបានស្នើអោយបំពេញភារកិច្ចរបស់ខ្លួនដែលបានចាត់តាំងក្នុងរយៈពេលប្រាំថ្ងៃក្នុងមួយសប្តាហ៍ ។ ពួកគេមិនត្រូវបានស្នើអោយធ្វើការសម្រាប់ពីរថ្ងៃផ្សេងទៀតឡើយ ។ ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជាទូទៅគឺថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ប៉ុន្តែអាចប្តូរទៅថ្ងៃផ្សេងទៀត ប្រសិនបើការងារតម្រូវអោយធ្វើដូច្នោះ ។ លើសពីនេះទៀត ពួកគេមិនត្រូវបានស្នើអោយធ្វើការនៅថ្ងៃឈប់បុណ្យជាតិជប៉ុនឡើយ និងសម្រាប់រយៈពេលចាប់ពីថ្ងៃទី ២៩ ខែធ្នូ ដល់ថ្ងៃទី០៣ ខែមករា ។ ជាការពិតណាស់ ប្រសិនបើមានតម្រូវការសេវាជាបណ្តោះអាសន្ន ពួកគេអាចត្រូវបានបង្គាប់អោយធ្វើការនៅថ្ងៃឈប់សម្រាកបុណ្យទាំងនេះដោយមានការតបស្នង ។

(៣) ច្បាប់ឈប់សម្រាក

មន្ត្រីអាចទទួលបានច្បាប់ឈប់សម្រាកជាច្រើនថ្ងៃ (ជាទូទៅ ម្ភៃថ្ងៃ) ដោយមានបៀវត្សរ៍បន្តបន្ទាប់គ្នា ឬដាច់ដោយឡែកពីគ្នា រៀងរាល់ឆ្នាំសម្រាប់គោលបំណងលំហែកាយ ។ ច្បាប់ឈប់សម្រាកត្រូវតែផ្តល់អោយក្នុងកំឡុងរយៈពេលដែលស្នើសុំ លើកលែងតែការងារតម្រូវអោយបុគ្គលិកមានវត្តមាននៅពេលនោះ ។ ច្បាប់ឈប់សម្រាកនេះហៅថា ការឈប់សម្រាកប្រចាំឆ្នាំមានបៀវត្សរ៍ ។ លើសពីនេះទៀត ក៏មានច្បាប់ឈប់ដោយជំងឺ ច្បាប់ឈប់ពិសេស ច្បាប់ឈប់

សម្រាកមើលថែទាំ និងច្បាប់សម្រាកផ្សេងៗទៀតផងដែរ ។ ទម្រង់នៃច្បាប់ឈប់សម្រាកទាំងនេះជាទូទៅមានផ្តល់បៀវត្សរ៍ ។

ច្បាប់ឈប់ដោយជំងឺ ច្បាប់ឈប់ពិសេស និងច្បាប់ឈប់សម្រាកមើលថែទាំ មានពន្យល់នៅខាងក្រោម ។

(ក) ច្បាប់ឈប់ដោយជំងឺ

ច្បាប់ឈប់ដោយជំងឺគឺជាច្បាប់ឈប់សម្រាក ដែលគេអនុញ្ញាតអោយដើម្បីសម្រាកព្យាបាលជំងឺ ពេលបុគ្គលិកណាម្នាក់មិនអាចធ្វើការ ដោយសារជំងឺ ឬរបួស ។ ច្បាប់ឈប់ដោយជំងឺត្រូវផ្អែកលើភស្តុតាងពីវេជ្ជបណ្ឌិត ប្រសិនបើចាំបាច់ ហើយនឹងត្រូវយល់ព្រមសម្រាប់រយៈពេលដែលចាំបាច់អប្បបរមា ដែលត្រូវការសម្រាប់ព្យាបាលជំងឺ ។ ច្បាប់ឈប់ដោយជំងឺក៏អាចទទួលបានសម្រាប់ជំងឺធម្មតារយៈពេលខ្លី ដូចជា ផ្តាសាយ និងឈឺក្រពះ ប៉ុន្តែតាមការពិត ចំពោះជំងឺស្រាលៗទាំងនេះ បុគ្គលិកភាគច្រើនជ្រើសរើសប្រើសិទ្ធិឈប់ប្រចាំឆ្នាំមានបៀវត្សរ៍ ។

(ខ) ច្បាប់ឈប់ពិសេស

ច្បាប់ឈប់ពិសេស គឺជាសិទ្ធិឈប់ដែលគេយកមកអះអាងជាមូលហេតុពេលបុគ្គលិកគ្មានលទ្ធភាពបំពេញភារកិច្ចរបស់ខ្លួនដោយសារមូលហេតុផ្ទាល់ខ្លួន ឬកាតព្វកិច្ចសង្គម និងដែលត្រូវបានទទួលស្គាល់ថាជាប្រការដែលមិនអាចជៀសវាងបានសម្រាប់ហេតុផលមនុស្សធម៌ និងសង្គម និងត្រូវបានកំណត់និយមន័យស្របតាមដីកាដែលគ្រប់គ្រងល័ក្ខខ័ណ្ឌការងារ ឬបទបញ្ជាក្រុមប្រឹក្សាបុគ្គលិក ។ ដោយអនុលោមតាមប្រព័ន្ធជាតិ និងដោយផ្អែកលើច្បាប់ ឬបទបញ្ជា ច្បាប់ឈប់ពិសេសត្រូវបានកំណត់ចំពោះមូលហេតុដូចខាងក្រោម និងសម្រាប់តែពេលចាំបាច់ប៉ុណ្ណោះ :

ក) ច្បាប់ឈប់ពិសេសដែលផ្អែកលើច្បាប់ស្តីពីស្តង់ដារការងារ

ការអនុវត្តសិទ្ធិបោះឆ្នោត ឬសេរីភាពពលរដ្ឋផ្សេងទៀត (មាត្រា ៧) សម្រាប់បុគ្គលិកជាស្ត្រី ប្រាំមួយសប្តាហ៍មុនពេលសម្រាលកូន (ដប់បួនសប្តាហ៍ក្នុងករណីសម្រាលកូនច្រើន) និងប្រាំបីសប្តាហ៍ក្រោយពេលសម្រាលកូនរួច (មាត្រា ៦៥) ។ រយៈពេលសាមសិបនាទីពីរដងសម្រាប់ការមើលថែទាំកូនសម្រាប់បុគ្គលិកជាស្ត្រីដែលមើលថែទាំកូន ត្រូវបានផ្តល់អោយរហូតដល់កូនមានអាយុមួយឆ្នាំ (មាត្រា ៦៧) សិទ្ធិឈប់ពេលមានរដូវសម្រាប់បុគ្គលិកជាស្ត្រី (មាត្រា ៦៨) និងករណីផ្សេងទៀត ។

ខ) អលទ្ធភាពទៅធ្វើការដោយសារគ្រោះមហន្តរាយ

ការផ្អាកសេវាដឹកជញ្ជូន ដោយសារខ្យល់ព្យុះ ទឹកជំនន់ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងទៀត និងករណីផ្សេងទៀត ។

គ) កាលៈទេសៈដោយមានមូលហេតុសមហេតុផល ដោយធៀបនឹងទស្សនៈដែលទទួលស្គាល់ជាទូទៅ ដូចជា អាពាហ៍ពិពាហ៍ ប្រពន្ធសម្រាលកូន មរណៈទុក្ខ ថ្ងៃឈប់សម្រាករដូវក្តៅ និងករណីផ្សេងទៀត ។

ឃ) ករណីផ្សេងទៀត

អ្នកដែលអាចធ្វើជាសាក្សីបាន មាន សាក្សីជំនាញ ឬសាក្សីយោងនៅរដ្ឋសភា តុលាការ សភាមូលដ្ឋាន ឬការិយាល័យរដ្ឋាភិបាលផ្សេងទៀត ពាក្យសុំការធ្វើតេស្ត ឬការសម្រាកព្យាបាលសម្រាប់ការធ្វើអំណោយខួរឆ្អឹង ។

(គ) ច្បាប់ឈប់សម្រាកមើលថែទាំ

ច្បាប់ឈប់សម្រាកមើលថែទាំ ត្រូវបានអនុញ្ញាតនៅពេលបុគ្គលិកមានតម្រូវការមើលថែទាំប្តី/ប្រពន្ធ ឪពុកម្តាយ កូន ឪពុកម្តាយក្មេក ឬសមាជិកគ្រួសារផ្សេងទៀត (ជីដូនជីតា ឬបងប្អូនដែលរស់នៅជាមួយបុគ្គលិក) គឺគ្រប់គ្រាន់ដើម្បីអោយបុគ្គលិកត្រូវបានអនុញ្ញាតអោយសម្រាកពីការងារ ។

ដោយយកចិត្តទុកដាក់លើប្រជាជនចំណាស់ ការជំរុញអោយគ្រួសារមានថាមភាព និងការលើកស្ទួយស្ត្រីនៅក្នុងសង្គមនោះ ប្រសិនបើបុគ្គលិកណាម្នាក់ត្រូវមើលថែទាំសមាជិកគ្រួសារ ការមើលថែទាំ និងការងារដាក់បន្ទុកជូនគ្នាលើផ្នែករាងកាយ និងស្មារតីលើបុគ្គលម្នាក់ៗ ហើយប្រហែលជាអាចបណ្តាលអោយបាត់បង់បុគ្គលិកដ៏គួរអោយសោកស្តាយ ។

ច្បាប់ឈប់សម្រាកប្រភេទនេះនៅក្នុងផ្នែកឯកជន ជាទូទៅគឺជាច្បាប់ឈប់សម្រាកគ្មានបៀវត្សរ៍ ។ ដោយហេតុនេះពេលច្បាប់ឈប់សម្រាកត្រូវបានប្រើ បៀវត្សរ៍របស់បុគ្គលត្រូវបានកាត់ ។

(៤) ច្បាប់ស្តីពីច្បាប់ឈប់សម្រាកមើលថែទាំកូន និងករណីផ្សេងទៀតសម្រាប់មន្ត្រីរាជការមូលដ្ឋាន

ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩២មក ច្បាប់ស្តីពីច្បាប់ឈប់សម្រាកមើលថែទាំកូន និងករណីផ្សេងទៀតសម្រាប់មន្ត្រីរាជការមូលដ្ឋាន ត្រូវបានប្រកាសអោយប្រើ ។

សេចក្តីអធិប្បាយនៃច្បាប់នេះមានដូចខាងក្រោម :

(ក) ការអនុញ្ញាតច្បាប់ឈប់សម្រាកមើលថែទាំកូន

បុគ្គលិកអាចសុំច្បាប់ឈប់សម្រាក ដោយមានការយល់ព្រមពីមន្ត្រីថ្នាក់លើ ដើម្បីមើលថែទាំកូនរបស់ខ្លួន រហូតដល់កូនមានអាយុបីឆ្នាំ ។ បុគ្គលិកដែលស្នើសុំការអនុញ្ញាតច្បាប់ឈប់សម្រាកមើលថែទាំកូន ត្រូវធ្វើពាក្យសុំទៅមន្ត្រីថ្នាក់លើដោយបញ្ជាក់អោយបានច្បាស់លាស់អំពីកាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់នៃច្បាប់ឈប់សម្រាក ។ នៅពេលនោះមន្ត្រីថ្នាក់លើត្រូវចាត់វិធានការដោះស្រាយទំនួលខុសត្រូវរបស់បុគ្គលិកនោះ ក្នុងកំឡុងពេលអវត្តមាននេះ ហើយលើកលែងតែក្នុងករណីការលំបាកគួរអោយកត់សម្គាល់ ត្រូវផ្តល់ការអនុញ្ញាតច្បាប់ឈប់សម្រាក ។

(ខ) អានុភាពនៃច្បាប់ឈប់សម្រាកមើលថែទាំកូន

បុគ្គលិកដែលសុំច្បាប់ឈប់សម្រាកមើលថែទាំកូន នៅរក្សាមុខដំណែងរបស់ខ្លួន ប៉ុន្តែមិនបំពេញការងារទេ ។ រយៈពេលអវត្តមាន គឺជាច្បាប់ឈប់សម្រាកគ្មានបៀវត្សរ៍ ។ បុគ្គលិកនឹងមិនត្រូវបានគេប្រព្រឹត្តចំពោះខ្លួនដែលធ្វើអោយបាត់បង់អត្ថប្រយោជន៍ ដោយសារការឈប់សម្រាកឡើយ ។

(គ) ច្បាប់ឈប់សម្រាកដោយផ្នែក

បុគ្គលិកក៏អាចស្នើសុំច្បាប់ឈប់សម្រាកមាតុភាព ក្នុងផ្នែកណាមួយនៃថ្ងៃធ្វើការ ដើម្បីមើលថែទាំកូនរបស់ខ្លួនដែលមានអាយុចូលរៀនថ្នាក់មត្តេយ្យសិក្សា ។ ប្រសិនបើច្បាប់ឈប់សម្រាកនោះ មិនបានរាំងស្ទះដល់ដំណើរការធម្មតានៃការងារទេ មន្ត្រីថ្នាក់លើអាចផ្តល់ការអនុញ្ញាតដល់ច្បាប់ឈប់សម្រាកនោះ ស្របតាមដីកាដែលបានបង្កើត ។ ក្នុងករណីនេះ បៀវត្សរ៍នឹងត្រូវកាត់ ដូចបុគ្គលិករដ្ឋាភិបាលកណ្តាលដែរ ។

(៥) ច្បាប់ឈប់សម្រាកតាមផ្នែកដើម្បីសិក្សា

អាជ្ញាធរតែងតាំងអាចផ្តល់ការអនុញ្ញាតច្បាប់ឈប់សម្រាកដោយផ្នែកដើម្បីសិក្សាដល់បុគ្គលិក ប្រសិនបើគ្មានការរាំងស្ទះចំពោះការងារ ហើយច្បាប់ឈប់សម្រាកនោះអាចចូលរួមបង្កើនសមត្ថភាពរបស់បុគ្គលិក ។

(៦) ច្បាប់ឈប់សម្រាកដោយផ្ទែកសម្រាប់បុគ្គលិកចំណាស់

អាជ្ញាធរតែងតាំងអាចផ្តល់ការអនុញ្ញាតច្បាប់ឈប់សម្រាកដោយផ្ទែកសម្រាប់បុគ្គលិកចំណាស់ ដែលមានអាយុច្រើនជាង ៥៥ ឆ្នាំ ក្នុងករណីធម្មតា ស្របតាមដីកា ប្រសិនបើគ្មានការរាំងស្ទះដល់ការងារទេ ។

## ៣. ប្រព័ន្ធជួយគ្នាទៅវិញទៅមក

ការជួយគ្នាទៅវិញទៅមកគឺជាប្រព័ន្ធមួយដែលមានគោលបំណងផ្តល់អត្ថប្រយោជន៍សមស្រប ក្នុងករណីមានជំងឺ របួស ការសម្រាលកូន ការព្យួរកិច្ចការអាជីវកម្ម គ្រោះមហន្តរាយ ការចូលនិវត្តន៍ ពិការភាព ឬមរណភាពដែលកើតឡើងលើបុគ្គលិករាជការ ឬប្រសិនបើជំងឺ របួស ការសម្រាលកូន មរណភាព ឬគ្រោះមហន្តរាយ កើតឡើងចំពោះអ្នករស់នៅក្នុងបន្ទុករបស់ពួកគេ ។ ប្រការនេះផ្អែកលើច្បាប់ស្តីពីសមាគមជួយគ្នាទៅវិញទៅមកនៃសេវាសាធារណៈមូលដ្ឋាន ។

អង្គភាពនៃកម្មវិធីជួយគ្នាទៅវិញទៅមក ដែលបង្កើតឡើងស្របតាមច្បាប់ គឺជាសមាគមជួយគ្នាទៅវិញទៅមកដែលជាអង្គគតិយុត្តិមួយ ។ សមាគមនេះត្រូវបានរៀបចំឡើងតាមប្រភេទ ស្របតាមរដ្ឋាភិបាលមូលដ្ឋាន និងប្រភេទការងារ ហើយមានសមាសភាពមន្ត្រី និងបុគ្គលិកពេញម៉ោង រួមទាំងសេវាធម្មតា និងពិសេស ។ សហជីពសមាគមជួយគ្នាទៅវិញទៅមកត្រូវបានបង្កើតឡើងដើម្បីពង្រឹងគ្រឹះហិរញ្ញវត្ថុនៃសមាគមទាំងនេះ ដោយប្រមូលមូលនិធិរបស់ពួកគេ ។ បច្ចុប្បន្ននេះ សមាគមទាំងអស់បានចូលរួមនៅក្នុងសហជីព ។

អត្ថប្រយោជន៍ដែលសមាគមផ្តល់ដល់សមាជិករបស់ខ្លួនមានទ្វេដង : "អត្ថប្រយោជន៍រយៈពេលខ្លី" និង "អត្ថ-ប្រយោជន៍រយៈពេលវែង" ។ ប្រភេទ និងធាតុនៃអត្ថប្រយោជន៍រយៈពេលខ្លី មានដូចខាងក្រោម :

(ក) អត្ថប្រយោជន៍ធានារ៉ាប់រងវេជ្ជសាស្ត្រ

ការព្យាបាលជំងឺ ឬរបួសរបស់សមាជិកដែលកើតឡើង នៅពេលគ្មានភារកិច្ច ឬវិធានការចាំបាច់ផ្សេងទៀតដូចជា ការពិនិត្យវិជ្ជសាស្ត្រ ត្រូវបានផ្តល់ ដោយថ្លៃចំណាយ ៧០% ត្រូវរ៉ាប់រងដោយសមាគម ។ រហូតដល់ ៧០% (៩០% សម្រាប់អ្នកដែលមានអាយុច្រើនជាង ៧០ ឆ្នាំ និងក្រោម ៧៥ ឆ្នាំ ៨០% សម្រាប់កុមារអាយុតិចជាង ៣ ឆ្នាំ) នៃចំណាយសម្រាប់ជំងឺ ឬរបស់អ្នកនៅក្នុងបន្ទុករបស់ពួកគេ ត្រូវរ៉ាប់រងដោយសមាគម ។ លើសពីនេះទៀត ចំណាយលើការសម្រាលកូន ការចំណាយលើការសម្រាលកូនរបស់សមាជិកគ្រួសារ ការចំណាយលើការបញ្ចុះសព និងការចំណាយលើការបញ្ចុះសពរបស់សមាជិកគ្រួសារ ត្រូវបង់ដោយសមាគមផងដែរ ។

(ខ) អត្ថប្រយោជន៍ព្យួរភារកិច្ច

ក្នុងករណីមន្ត្រីសមាជិកមិនអាចធ្វើការដោយជំងឺ ឬរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ដែលកើតឡើងនៅក្រៅម៉ោងបំពេញភារកិច្ច ពីរភាគបីនៃបៀវត្សរ៍របស់ពួកគេ ត្រូវបង់ជាវិភាជន៍ជំងឺ/របួស ដោយសមាគម លើកលែងតែសាមីរដ្ឋា-ភិបាលមូលដ្ឋានបង់ប្រាក់បៀវត្សរ៍ទៀងទាត់ទាំងស្រុង ។ រយៈពេលកំណត់សម្រាប់អត្ថប្រយោជន៍នេះគឺ មួយឆ្នាំកន្លះ ។ ក្នុងករណីសម្រាលកូន មានរយៈពេល ៤២ ថ្ងៃមុន និង ៥៦ ថ្ងៃក្រោយពេលសម្រាលកូន ពីរភាគបីនៃបៀវត្សរ៍ត្រូវបង់ លើកលែងតែសាមីរដ្ឋាភិបាលមូលដ្ឋានបើកប្រាក់បៀវត្សរ៍ទៀងទាត់ ។ លើសពីនេះទៀត មានវិភាជន៍ព្យួរភារកិច្ច វិភាជន៍ឈប់សម្រាកមើលថែទាំកូន និងវិភាជន៍ឈប់សម្រាកមើលថែទាំ ។

(គ) អត្ថប្រយោជន៍គ្រោះមហន្តរាយ

មូលនិធិវិលែកទុក្ក មូលនិធិវិលែកទុក្ខសមាជិកគ្រួសារ និងមូលនិធិសមានចិត្តគ្រោះមហន្តរាយ ត្រូវបង់នៅក្នុងករណីមរណភាព និង/ឬគ្រោះថ្នាក់ផ្សេងទៀតដែលកើតឡើងចំពោះសមាជិក និង/ឬអ្នករស់នៅក្នុងបន្ទុករបស់ពួកគេ ។

ប្រភេទ និងធាតុនៃអត្ថប្រយោជន៍រយៈពេលយូរមានដូចខាងក្រោម :

ក) សោធននិវត្តន៍សុខុមាលភាពជួយគ្នាទៅវិញទៅមក

សោធននិវត្តន៍សុខុមាលភាពត្រូវបង់នៅពេលមន្ត្រីណាម្នាក់ដែលជាបានធ្វើការងារលើសពី ២៥ ឆ្នាំ មានអាយុដល់ ៦៥ ឆ្នាំ ក្រោយពេលចូលនិវត្តន៍ ឬពេលមន្ត្រីនោះចូលនិវត្តន៍ ក្រោយពេលមានអាយុ ៦៥ ឆ្នាំ ។

ចំនួនទឹកប្រាក់សោធននិវត្តន៍សុខុមាលភាពជួយគ្នាទៅវិញទៅមក គឺជាចំនួននៃ i) និង ii) ដូចខាងក្រោម :

(ក្នុងករណីបុគ្គលិកមានប្តី/ប្រពន្ធ ឬកូន ដែលបំពេញតាមល័ក្ខខ័ណ្ឌតម្រូវ ចំនួនទឹកប្រាក់នេះមានចំនួនច្រើនជាងនេះ ។)

i) រយៈពេលនៃសមាជិកភាពមុនថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣

១. ចំណែកដែលត្រូវនឹងអត្ថប្រយោជន៍ទាក់ទងនឹងប្រាក់សន្សំ

ប្រាក់បៀវត្សរ៍ប្រចាំខែជាមធ្យម × ៧,១២៥/១០០០ × ខែនៃរយៈពេលសមាជិកភាព × ០,៩៨៥

២. ចំណែកដែលត្រូវនឹងសោធនការងារ

ប្រាក់បៀវត្សរ៍ប្រចាំខែជាមធ្យម × ១,៤២៥/១០០០ (ក្នុងករណីរយៈពេលសមាជិកភាពតិចជាង ២០ ឆ្នាំ ០,៧១៣/១០០០) × ខែនៃរយៈពេលសមាជិកភាព × ០,៩៨៥

ii) រយៈពេលសមាជិកភាពក្រោយថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៣

១. ចំណែកដែលត្រូវនឹងអត្ថប្រយោជន៍ទាក់ទងនឹងប្រាក់សន្សំ

ប្រាក់បៀវត្សរ៍ប្រចាំខែជាមធ្យម × ៥,៤៨១/១០០០ × ខែនៃរយៈពេលសមាជិកភាព × ០,៩៨៥

២. ចំណែកដែលត្រូវនឹងសោធនការងារ :

ប្រាក់បៀវត្សរ៍ប្រចាំខែជាមធ្យម × ១,០៩៦/១០០០ ×ខែនៃរយៈពេលសមាជិកភាព (ក្នុងករណីរយៈពេលសមាជិកភាពតិចជាង ២០ ឆ្នាំ ០,៥៤៨/១០០០) × ០,៩៨៥

ដោយសារកំណែទម្រង់ប្រព័ន្ធ នៅពេលបញ្ញត្តិថ្មីចាប់ផ្តើមអនុវត្ត អាយុត្រូវបានដំឡើងពី ៦០ ទៅ ៦៥ ឆ្នាំ (ជាពិសេស លែងមានការលើកលែងចំពោះអ្នកដែលកើតក្រោយថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៦១) ។

ខ) សោធនសុខុមាលភាពពិការភាពជួយគ្នាទៅវិញទៅមក និងប្រាក់ពិការភាព

ក្នុងករណីមន្ត្រីណាម្នាក់ចូលនិវត្តន៍ពីសេវាសាធារណៈ នៅក្នុងស្ថានភាពពិការធ្ងន់ធ្ងរ ដែលបណ្តាលមកពីជំងឺ ឬរបួស ដែលកើតឡើងពេលបំពេញភារកិច្ច ឬមិនបំពេញភារកិច្ច មន្ត្រីនោះត្រូវទទួលបានសោធនសុខុមាលភាពពិការភាពជួយគ្នាទៅវិញទៅមក ឬប្រាក់ពិការភាព ។

គ) សោធនជួយគ្នាទៅវិញទៅមកសម្រាប់អ្នកនៅរស់

ក្នុងករណីមន្ត្រី ឬមន្ត្រីចូលនិវត្តន៍ណាម្នាក់ទទួលមរណភាព សមាជិកគ្រួសាររបស់មន្ត្រីនោះត្រូវទទួលបានសោធនជួយគ្នាទៅវិញទៅមកសម្រាប់អ្នកនៅរស់ ដើម្បីធានាការចំណាយជីវភាពរបស់ពួកគេ ។

ការចំណាយសម្រាប់អត្ថប្រយោជន៍ទាំងនេះ និងការគ្រប់គ្រងការិយាល័យសមាគមត្រូវរ៉ាប់រងដោយសាមីរដ្ឋាភិបាលមូលដ្ឋាន និងសមាជិកសមាគម ក្នុងទម្រង់ជាបន្ទុក និងថ្លៃសេវា ។

## ៤. ប្រព័ន្ធទូទាត់សងចំពោះគ្រោះថ្នាក់ក្នុងសេវាសាធារណៈមូលដ្ឋាន

ការទូទាត់សងត្រូវបានផ្តល់ដល់មន្ត្រីរាជការណា ដែលបានទទួលរងជំងឺ ឬរបួស ដែលជាផ្នែកមួយភារកិច្ច ឬក្នុងពេលធ្វើដំណើរ ។

ប្រព័ន្ធទូទាត់សំណងត្រូវបានបង្កើតឡើងច្បាប់ស្តីពីការទូទាត់សំណងគ្រោះថ្នាក់ក្នុងសេវាសាធារណៈមូលដ្ឋាន ។ ការទូទាត់សងសម្រាប់មន្ត្រីធ្វើការពេញម៉ោងត្រូវបានផ្តល់ដោយមូលនិធិសំណងគ្រោះថ្នាក់ក្នុងសេវាសាធារណៈមូលដ្ឋាន ស្របតាមច្បាប់ដែលបានរៀបរាប់នេះ ចំណែកសម្រាប់មន្ត្រីធ្វើការក្រៅម៉ោង លើកលែងតែនាយកទីភ្នាក់ងាររដ្ឋបាលមូលដ្ឋាន ដែលបង្កើតឡើងជាក់លាក់ ត្រូវបានផ្តល់ដោយរដ្ឋាភិបាលមូលដ្ឋានរៀងខ្លួន ស្របតាមបទបញ្ជា និងដីការបស់រដ្ឋាភិបាលមូលដ្ឋាន ។

ប្រភេទនៃការទូទាត់សំណងមាន : សំណងឱសថ សំណងព្យួរសេវា សោធនពិការភាពរយៈពេលយូរ សំណងពិការភាព (សោធនសំណងពិការភាព ឬវិភាជន៍សំណងពិការភាព) សំណងថែទាំ សំណងគ្រួសារកាន់មរណទុក្ខ (សោធនសំណងគ្រួសារកាន់មរណទុក្ខ ឬវិភាជន៍សំណងគ្រួសារកាន់មរណទុក្ខ) និងសំណងបញ្ចុះសព ។

ធាតុនៃទម្រង់សំណងទាំងនេះស្រដៀងគ្នានឹងទម្រង់នៃប្រព័ន្ធទូទាត់សំណង ដែលអនុវត្តចំពោះបុគ្គលិករាជការថ្នាក់ជាតិ (ច្បាប់ស្តីពីសំណងគ្រោះថ្នាក់ក្នុងសេវាសាធារណៈថ្នាក់ជាតិ) និងបុគ្គលិកក្រុមហ៊ុនឯកជន (ច្បាប់ស្តីពីធានារ៉ាប់រងសំណងគ្រោះថ្នាក់កម្មករ-និយោជិត) ផងដែរ ។

## ជំពូកទី ៥ : សិទ្ធិរបស់កម្មករ-និយោជិត

### ១. សិទ្ធិបង្កើតអង្គការ

(១) សិទ្ធិរបស់បុគ្គលិករាជការមូលដ្ឋានក្នុងការបង្កើតអង្គការ

បុគ្គលិករាជការមូលដ្ឋានទាំងអស់ លើកលែងតែបុគ្គលិករាជការក្នុងកងកម្លាំងនគរបាល ឬសេវាពន្លត់អគ្គីភ័យ មានសិទ្ធិបង្កើតអង្គការ ប៉ុន្តែមានភាពខុសគ្នារវាងប្រភេទផ្សេងៗនៃបុគ្គលិក ទាក់ទងនឹងធាតុជាក់លាក់នៃសិទ្ធិ ។ បុគ្គលិកនៅក្នុងសហគ្រាសសាធារណៈមូលដ្ឋាន និងកម្មករ-និយោជិតក្នុងការងារគ្មានជំនាញ អាចបង្កើតសហជីព ស្របតាមច្បាប់ស្តីពីទំនាក់ទំនងវិជ្ជាជីវៈសហគ្រាសសាធារណៈមូលដ្ឋាន និងច្បាប់ស្តីពីសហជីព ចំណែកឯបុគ្គលិកផ្សេងទៀតអាចបង្កើតអង្គការបុគ្គលិក ។ មានតែកម្មករ-និយោជិតនៅក្នុងការងារគ្មានជំនាញប៉ុណ្ណោះដែលអាចបង្កើតជាបន្ថែម ឬចូលរួមក្នុងអង្គការបុគ្គលិកបាន ។

(២) អង្គការបុគ្គលិក

អង្គការបុគ្គលិកគឺជាអង្គការ ឬសហព័ន្ធអង្គការ ដែលត្រូវបានបង្កើតឡើងដោយបុគ្គលិករាជការមូលដ្ឋាន ដើម្បីរក្សា និងកែលម្អល័ក្ខខ័ណ្ឌការងាររបស់ពួកគេ ( មាត្រា ៥២ កថាខ័ណ្ឌ ១) ។

មន្ត្រីរាជការអាច ឬមិនអាចបង្កើត និងអាច ឬមិនអាចចូលរួមក្នុងអង្គការបុគ្គលិក ។ ទោះជាយ៉ាងក៏ដោយ មន្ត្រីដែលកាន់កាប់មុខងារគ្រប់គ្រង ឬត្រួតពិនិត្យ ឬមន្ត្រីដែលបំពេញការងារសម្ងាត់ (តទៅនេះហៅថា "បុគ្គលិកគ្រប់គ្រង និងបុគ្គលិកស្រដៀង") មិនអាចបង្កើត ឬចូលរួមក្នុងអង្គការបុគ្គលិករួមគ្នាជាមួយនឹងមន្ត្រីផ្សេងទៀតឡើយ ។ ហេតុផលនៃការបែងចែកនេះ គឺដើម្បីបង្ការកុំអោយបុគ្គលិកគ្រប់គ្រង និងបុគ្គលិកស្រដៀងដែលមានដូចជានិយោជកជាដើម រារាំងដល់ប្រតិបត្តិការរបស់អង្គការបុគ្គលិក ។ ក្របខ័ណ្ឌរបស់បុគ្គលិកគ្រប់គ្រង និងបុគ្គលិកស្រដៀង មានចែងដោយបទបញ្ជារបស់គណៈកម្មាធិការបុគ្គលិក ឬគណៈកម្មាធិការសមភាព ។

អង្គការបុគ្គលិកអាចចុះបញ្ជីនៅក្នុងគណៈកម្មាធិការបុគ្គលិក ឬគណៈកម្មាធិការសមភាព ប្រសិនបើអង្គការនេះមានសមាសភាពតែមន្ត្រីនៅក្នុងរដ្ឋាភិបាលមូលដ្ឋានទោល ហើយលើកលែងតែក្នុងករណីមួយចំនួន អាចសម្រេចចិត្តលើវត្ថុបំណងសំខាន់ៗរបស់ខ្លួនតាមរយៈនីតិវិធីប្រជាធិបតេយ្យ និងមានធម្មនុញ្ញ រួមទាំងបញ្ញត្តិសម្រាប់បញ្ហាទាំងនោះ ដែលតម្រូវដោយច្បាប់ ដើម្បីធានាអោយមានដំណើរការប្រកបដោយភាពរលូននៃអង្គការ ។ ការចុះបញ្ជីអង្គការបុគ្គលិកគឺជាប្រព័ន្ធ ដើម្បីអោយមានការទទួលស្គាល់ជាផ្លូវការ ។ ជាការពិតណាស់ គ្មានភាពខុសគ្នារវាងអង្គការចុះបញ្ជី និងអង្គការមិនចុះបញ្ជី នៅក្នុងសកម្មភាពជាក់លាក់ណាមួយឡើយ ទោះបីជាអង្គការចុះបញ្ជីអាចទទួលបានអត្ថប្រយោជន៍បន្ថែមទៀត តាមរយៈការទទួលបានឋានៈសាជីវកម្មក៏ដោយ ។ អង្គការបុគ្គលិកមានសិទ្ធិពេញលេញក្នុងការជ្រើសរើសមន្ត្រីគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ដោយគ្មានការហាមឃាត់ និងអាចតែងតាំងបុគ្គលដែលមិនមែនជាបុគ្គលិកអោយធ្វើជាមន្ត្រីគ្រប់គ្រងប្រសិនបើខ្លួនចង់បាន ។

(៣) <u>សហជីព</u>

បុគ្គលិកនៅក្នុងសហគ្រាសសាធារណៈមូលដ្ឋាន និងកម្មករ-និយោជិតក្នុងការងារគ្មានជំនាញអាចបង្កើត ឬចូលរួមក្នុងសហជីព ប៉ុន្តែ ដូចបានរៀបរាប់ពីខាងដើម បុគ្គលិកគ្រប់គ្រង និងបុគ្គលិកស្រដៀង មិនអាចធ្វើដូច្នេះបានទេ ។ ការរៀបចំ និងការគ្រប់គ្រងសហជីពគឺស្ទើរតែដូចគ្នាទៅនឹងសហជីពនៃបុគ្គលិកក្រុមហ៊ុនឯកជន លើកលែងតែពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដែលមាននៅពេលបន្ទាប់ ។

## ២. សិទ្ធិចរចារួម

(១) <u>ការចរចាជាមួយអង្គការបុគ្គលិក</u>

អង្គការបុគ្គលិកត្រូវបានអនុញ្ញាតអោយចរចាជាមួយអាជ្ញាធរទទួលខុសត្រូវនៃរដ្ឋាភិបាលមូលដ្ឋាន ទាក់ទងនឹងប្រៀវត្សរ៍របស់បុគ្គលិក ម៉ោងធ្វើការ និងកត្តាផ្សេងៗទៀត ដែលប៉ះពាល់ល័ក្ខខ័ណ្ឌការងារ និងបញ្ហាពាក់ព័ន្ធផ្សេងៗរបស់ពួកគេ ។ ក្នុងកំឡុងពេលចរចា អង្គការបុគ្គលិកអាចចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយអាជ្ញាធរមូលដ្ឋាន ប្រសិនបើកិច្ចព្រមព្រៀងនេះមិនផ្ទុយពីច្បាប់ បទបញ្ជា ដីកា បទប្បញ្ញត្តិ ។ល។ ទោះជាយ៉ាងណាក៏ដោយ ផ្ទុយពីកិច្ចព្រមព្រៀងរួមក្នុងករណីសហជីព កិច្ចព្រមព្រៀងនេះមិនត្រូវទទួលបានឋានៈជាចាំបាច់នោះទេ ។

(២) <u>ការចរចាជាមួយសហជីព</u>

សហជីពបុគ្គលិករាជការ អាចធ្វើការចរចារួមជាមួយអាជ្ញាធរមូលដ្ឋានទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ និងអាចចុះកិច្ចព្រមព្រៀងរួមជាមួយអាជ្ញាធរទាំងនោះលើបញ្ហាទាំងនេះក្រោមការចរចា ។ ប៉ុន្តែ ក្នុងករណីកិច្ចព្រមព្រៀងនេះ រួមមានបញ្ញត្តិផ្ទុយពីដីកា ឬក្នុងករណីកិច្ចព្រមព្រៀងនេះបង្កអោយមានចំណាយលើសពីដែនកំណត់នៃថវិកាបច្ចុប្បន្ន ឬលើសពីមូលនិធិដែលមាននៅក្នុងរដ្ឋាភិបាលមូលដ្ឋាន កិច្ចព្រមព្រៀងនេះត្រូវមានប្រសិទ្ធភាពតែក្នុងកម្រិតដែលកិច្ចព្រមព្រៀងនេះមិនផ្ទុយពីដីកាប៉ុណ្ណោះ រហូតដល់ស្ថានភាពនេះត្រូវបានដោះស្រាយរួច ។ កិច្ចព្រមព្រៀងនេះអាចមានប្រសិទ្ធភាពតែនៅពេលដែលសភាមូលដ្ឋានចាត់ការ ឬអនុម័តវិសោធនកម្ម ឬការលុបចោលដីកា ឬថវិកាដែលពាក់ព័ន្ធប៉ុណ្ណោះ ។ ក្នុងករណីនេះ ការសម្រេចចិត្តត្រូវធ្វើឡើងដោយសភាមូលដ្ឋាន ដោយហេតុថាសភាមូលដ្ឋានគឺជាតំណាងផលប្រយោជន៍របស់ប្រជាជនក្នុងមូលដ្ឋាន ទាក់ទងនឹងបញ្ហាទាំងនោះ ។

## ៣. ការហាមឃាត់វិធានការវិវាទ

បុគ្គលិករាជការមូលដ្ឋានទាំងអស់ត្រូវបានហាមឃាត់មិនអោយធ្វើកូដកម្ម ឬការបង្អាក់ដំណើរការ ឬចាត់វិធានការណាមួយផ្សេងទៀតដែលរំខានដល់ប្រតិបត្តិការជាធម្មតានៃសេវាសាធារណៈមូលដ្ឋាន ។ ពួកគេក៏ត្រូវបានហាមឃាត់មិនអោយប៉ុនប៉ង សមគំនិត ចូលរួម ឬញុះញង់អោយមានសកម្មភាពបែបនេះផងដែរ ។ ការធ្វើដូច្នេះ គឺដោយសារក្នុងឋានៈជាមន្ត្រីរាជការ ពួកគេត្រូវបានតម្រូវអោយធ្វើការដើម្បីបម្រើផលប្រយោជន៍របស់សហគមន៍ទាំងមូល ។

បុគ្គលិករាជការមូលដ្ឋានណាមួយដែលប្រព្រឹត្តសកម្មភាពហាមឃាត់ខាងលើមួយ ឬច្រើន ត្រូវទទួលវិធានការវិន័យ ដោយអាជ្ញាធរតែងតាំង ។ បុគ្គលណាម្នាក់ដែលប៉ុនប៉ង សមគំនិត ចូលរួម ឬញុះញង់អោយមានសកម្មភាពបែបនោះ ដែលធ្វើឡើងដោយមន្ត្រីរាជការមូលដ្ឋាន ត្រូវទទួលទណ្ឌកម្ម ស្របតាមក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ៦ : សុវត្ថិភាពនៃអត្ថប្រយោជន៍របស់បុគ្គលិក

### ១. ការដាក់ពាក្យសុំវិធានការស្តីពីលំក្ខខណ្ឌការងារ

មន្ត្រីគ្រប់រូបអាចស្នើអោយគណៈកម្មាធិការបុគ្គលិក ឬគណៈកម្មាធិការសមភាព ស្នើទៅអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ចាត់វិធានការត្រឹមត្រូវទាក់ទងនឹងបៀវត្សរ៍ ម៉ោងធ្វើការ និងល័ក្ខខ័ណ្ឌការងារផ្សេងទៀត ។ ពេលពាក្យសុំនេះត្រូវបាន ដាក់មក គណៈកម្មាធិការត្រូវតែធ្វើការពិនិត្យករណីនេះ តាមរយៈការសាកសួរផ្ទាល់មាត់ ឬមធ្យោបាយផ្សេងទៀត ធ្វើ ការវិនិច្ឆ័យលើបញ្ហា ហើយដោយឈរលើមូលដ្ឋាននៃលទ្ធផលនៃការវិនិច្ឆ័យនេះ ចាត់វិធានការតាមការយល់ឃើញផ្ទាល់ របស់ខ្លួន និងផ្តល់អនុសាសន៍ចាំបាច់ដល់អាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ជាមួយបញ្ហាក្រោមយុត្តាធិការ របស់អាជ្ញាធរនោះ ។

### ២. ការដាក់បណ្តឹងជំទាស់ប្រឆាំងនឹងវិធានការអវិជ្ជមាន

មន្ត្រីដែលត្រូវទទួលវិធានការវិន័យ ឬវិធានការអវិជ្ជមានផ្សេងទៀត ដែលចាត់ទុកថាប្រឆាំងនឹងឆន្ទះរបស់ពួក គេ អាចដាក់បណ្តឹងជំទាស់ទៅគណៈកម្មាធិការបុគ្គលិក ឬគណៈកម្មាធិការសមភាព ។ បន្ទាប់មក គណៈកម្មការត្រូវ សម្រេចចិត្តថាតើត្រូវយល់ព្រមតាមបណ្តឹងជំទាស់ ឬក៏អត់ ។ ប្រសិនបើគណៈកម្មាធិការសម្រេចចិត្តយល់ព្រម បណ្តឹង ជំទាស់នោះត្រូវតែពិនិត្យភ្លាមៗ ។ ការពិនិត្យត្រូវតែធ្វើឡើងក្នុងទម្រង់ជាសវនាការជាសាធារណៈ ប្រសិនបើមន្ត្រីនោះ ស្នើអោយធ្វើដូច្នោះ ។ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យ គណៈកម្មាធិការត្រូវឯកភាព ពិនិត្យមើលឡើងវិញ ឬលុប ចោលនូវវិធានការដើម ។ តាមវិធាន និងជាគោលការណ៍ មន្ត្រីមិនអាចដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីសុំ និរាករណ៍ចំពោះវិធានការអវិជ្ជមានបានឡើយ រហូតដល់ក្រោយពេលគណៈកម្មាធិការបានបញ្ចប់ការពិនិត្យ និងវិនិច្ឆ័យលើ បណ្តឹងជំទាស់រួចរាល់ជាស្ថាពរ ។

## ការប្រៀបធៀបចំនួនបុគ្គលិកសេវាសាធារណៈថ្នាក់កណ្ដាល និងបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ក្នុងចំណោមប្រទេសជឿនលឿន (ឆ្នាំសារពើពន្ធ២០០១) (ក្នុងប្រជាជន ១.០០០ នាក់)




កំណត់សម្គាល់ : តួលេខ "បុគ្គលិកសេវាសាធារណៈ" សំដៅចំពោះចំនួនសរុបនៃបុគ្គលិកសេវាសាធារណៈថ្នាក់កណ្ដាល បុគ្គលិកសេវាសាធារណៈមូលដ្ឋាន និងបុគ្គលិកសហគ្រាសសាធារណៈ ។

## ការប្រៀបធៀបចំនួនបុគ្គលិកនៅក្នុងផ្នែកសាធារណៈ និងផ្នែកឯកជន



# ចំនួនបុគ្គលិករាជការមូលដ្ឋាន

(នាក់)

| | | ឆ្នាំសារពើពន្ធ១៩៤៧ | ឆ្នាំសារពើពន្ធ១៩៥០ | ឆ្នាំសារពើពន្ធ១៩៥៣ | ១៩៥៨.៥.៣១ | ១៩៦៣.៥.៣១ | ១៩៦៨.៤.១ | ១៩៧៣.៤.១ | ១៩៧៨.៤.១ | ១៩៨៣.៤.១ |
|---|---|---|---|---|---|---|---|---|---|---|
| គណនីធម្មតា | សរុប | ១.៣៣៧.៣៥១ | ១.៤១៩.៥៥៨ | ១.៤១០.៩៩៨ | ១.៥៨៣.១២៨ | ១.៨៥០.៩៦១ | ២.០៥៤.៣៧៦ | ២.៤០០.៥៨៨ | ២.៦៩៣.១៦៣ | ២.៨៤០.៩២៨ |
| | រដ្ឋបាលទូទៅ | ៥៩០.៥២១ | ៦០៣.៥០២ | ៦៣៤.៣២២ | ៥៧២.៦០៩ | ៧៤៣.៩៤៣ | ៨១៩.៩៨៧ | ១.០០៤.៤២២ | ១.១១៦.៤៦៨ | ១.១៤៨.០៣៨ |
| | ខេត្ត | ២៥១.១៤០ | ២៤៩.៥៦៣ | ២៦៥.១០៤ | ២២៧.១៥១ | ២៩៣.៣៣៩ | ៣២១.៥៦៨ | ៣៦២.១៧២ | ៣៣៨.៦០៣ | ៣៣០.៩៩៥ |
| | ក្រុង | ៣៣៩.៣៨១ | ៣៥៣.៩៣៩ | ៣៦៩.២១៨ | ៣៤៥.៤៥៨ | ៤៥០.៦០៤ | ៤៩៨.៤១៩ | ៦៤២.២៥០ | ៧៧៧.៨៦៥ | ៨១៧.០៤៣ |
| | អប់រំ | ៦២៦.៣០២ | ៦៨៥.២០៩ | ៦៩៥.៩៦៣ | ៧៥៦.៧៣៩ | ៨៥៧.៥៦២ | ៩៧២.៩៣៩ | ១.០៧៦.២៨០ | ១.២១៧.៨២១ | ១.៣១២.០១១ |
| | គ្រូបង្រៀន | - | - | - | ៦៩៩.៣៤៤ | ៧១៦.៨៨៨ | ៧៦៥.៨៦៧ | ៨២៨.០៤០ | ៩២៦.០៣៥ | ១.០០១.៩៤៧ |
| | ផ្សេងៗ | - | - | - | ៥៧.៣៩៥ | ១៤០.៦៧៤ | ២០៧.០៧២ | ២៤៨.២៤០ | ២៩១.៧៨៦ | ៣១០.០៦៤ |
| | នគរបាល | ៥៨.៨៤៩ | ១០៤.៦៦៤ | ៨៨.៧៤៣ | ១៤០.៨៥៩ | ១៥៧.៨៣៣ | ១៨៤.១៤០ | ២១៣.៩៦២ | ២៣៣.០៤៣ | ២៤៥.០៤៧ |
| | មន្ត្រីនគរបាល | - | ៩៣.៥៧៨ | - | ១២១.៩៦១ | ១៣៧.១២៩ | ១៦០.៦៩៦ | ១៨៨.៣៥៦ | ២០២.៨៧៤ | ២១៥.១៣៨ |
| | ផ្សេងៗ | - | ១១.០៨៦ | - | ១៨.៨៩៨ | ២០.៧០៤ | ២៣.៤៤៤ | ២៥.៦០៦ | ៣០.១៦៩ | ២៩.៩០៩ |
| | បង្ការអគ្គិភ័យ | ២១.៦៨៣ | ២៦.១៨៣ | ១៣១.៩៧០ | ៣៤.៧៧១ | ៤៣.៩០៧ | ៥៧.៥៥៤ | ៩០.៣១៥ | ១១៤.៥០១ | ១២៧.២០៩ |
| | (បុគ្គលិកបណ្តោះអាសន្ន ឬក្រៅម៉ោង) | - | - | - | ៧៨.១៥០ | ៤៧.៧១៦ | ១៩.៧៥៦ | ១៥.៦១៩ | ១១.៣៣០ | ៨.៦២៣ |
| សហគ្រាសសាធារណៈមូលដ្ឋាន | | - | - | - | - | - | ៣០១.៨៥១ | ៣៤៤.៣៧១ | ៣៧២.៥១១ | ៣៩០.៧២២ |
| សរុប | | - | - | - | - | - | ២.៣៥៦.២២៧ | ២.៧៤៤.៩៥៩ | ៣.០៦៥.៦៧៤ | ៣.២៣១ |

| | | ១៩៨៨.៤.១ | ១៩៩៣.៤.១ | ១៩៩៨.៤.១ | ២០០១.៤.១ | ២០០២.៤.១ | ២០០៣.៤.១ | ២០០៤.៤.១ | ២០០៥.៤.១ | ២០០៦.៤.១ |
|---|---|---|---|---|---|---|---|---|---|---|
| គណនីធម្មតា | សរុប | ២.៨១៤.៥៦៤ | ២.៨៦៩.៣៦៨ | ២.៨១៧.០៩៦ | ២.៧២០.៧៨៩ | ២.៦៩៨.១១០ | ២.៦៧៥.៥២០ | ២.៦៤៩.៦៨២ | ២.៦១៨.៥០៧ | ២.៥៨៦.៧០១ |
| | រដ្ឋបាលទូទៅ | ១.១២២.៨៩៥ | ១.១៦៤.១៩៥ | ១.១៦៣.៣៨៩ | ១.១១១.៥៧៧ | ១.១០០.០៣៩ | ១.០៨៥.៥៨៥ | ១.០៦៩.១៥១ | ១.០៤៨.៨៦០ | ១.០២៧.១២៨ |
| | ខេត្ត | ៣១៩.៤២៨ | ៣២៤.២៧៤ | ៣១៨.៥៩៤ | ២៩៦.៩៥៣ | ២៩២.៤១៣ | ២៨៧.២៨៤ | ២៨២.៣៩៤ | ២៧៦.៩៨៨ | ២៧១.៨៥៩ |
| | ក្រុង | ៨០៣.៤៦៧ | ៨៣៩.៩២១ | ៨៤៤.៧៩៥ | ៨១៤.៦២៤ | ៨០៧.៦២៦ | ៧៩៨.៣០១ | ៧៨៦.៧៥៧ | ៧៧១.៨៧២ | ៧៥៥.២៦៩ |
| | អប់រំ | ១.៣០៣.៨៣៨ | ១.២៨៤.៦០៤ | ១.២៣៨.០៦៨ | ១.១៥២.៥៧៧ | ១.១៨១.៣០៧ | ១.១៦៨.៤៣១ | ១.១៥៤.៤១៦ | ១.១៣៩.៦៨៣ | ១.១២៥.៧១៥ |
| | គ្រូបង្រៀន | ១.០០៣.២៦១ | ៩៧០.៣៦០ | ៩២៩.៨៥៧ | ៩០០.៥០៨ | ៩១០.៥២០ | ៨៨៩.៨៥៥ | ៨៨៣.៦៥៩ | ៨៧៧.០៨៧ | ៨៧២.៣៩០ |
| | ផ្សេងៗ | ៣០០.៥៧៧ | ៣១៤.២៤៤ | ៣០៨.២១១ | ២៥២.០៦៩ | ២៧០.៧៨៧ | ២៧៨.៥៧៦ | ២៧០.៧៥៧ | ២៦២.៥៩៦ | ២៥៣.៣២៥ |
| | នគរបាល | ២៥០.២៤០ | ២៥៣.៥៥២ | ២៥៩.១៤៨ | ២៥៨.៨០៨ | ២៦២.៤៥៣ | ២៦៦.៧២៩ | ២៧០.៨៧០ | ២៧៤.២៧១ | ២៧៧.៥៤៣ |
| | មន្ត្រីនគរបាល | ២២០.៣៩៣ | ២២៣.២៩១ | ២២៩.៨៤៨ | ២២៩.៨៧១ | ២៣៣.៥៨៥ | ២៣៧.៩៦៣ | ២៤១.៩១៣ | ២៤៥.៣៧៤ | ២៤៨.៨៣៤ |
| | ផ្សេងៗ | ២៩.៨៤៧ | ៣០.២៦១ | ២៩.៣០០ | ២៨.៩៣៧ | ២៨.៨៦៨ | ២៨.៧៦៦ | ២៨.៩៥៧ | ២៨.៨៩៧ | ២៨.៧០៩ |
| | បង្ការអគ្គិភ័យ | ១៣១.៦៦១ | ១៦១.៩៨៣ | ១៥២.២២៩ | ១៥៣.៩០៧ | ១៥៤.៣១១ | ១៥៤.៧៧៥ | ១៥៥.២៤៥ | ១៥៥.៦៩៣ | ១៥៦.៣១៥ |
| | (បុគ្គលិកបណ្តោះអាសន្ន ឬក្រៅម៉ោង) | ៥.៩៣០ | ៥.០៣៤ | ៤.២៦២ | ៣.៥២០ | ៤.៧៨១ | ៤.៦៤៨ | ៤.៤៦២ | ៣.៦១៩ | ២.៩៣៦ |
| សហគ្រាសសាធារណៈមូលដ្ឋាន | | ៤០០.៩០៦ | ៤២១.៤៣១ | ៤៣២.៣៥៨ | ៤៥០.៧៤៣ | ៤៤៦.២១៣ | ៤៤១.៤៨៤ | ៤៣៣.៩១៥ | ៤២៣.៦១៥ | ៤១១.៧០១ |
| សរុប | | ៣.២១៥.៤៧០ | ៣.២៩០.៧៩៩ | ៣.២៤៩.៤៥៤ | ៣.១៧១.៥៣២ | ៣.១៤៤.៣២៣ | ៣.១១៧.០០៤ | ៣.០៨៣.៥៩៧ | ៣.០៤២.១២២ | ២.៩៩៨.៤០២ |

កំណត់សម្គាល់ : ១ : តួលេខនៅក្នុងរង្វង់ក្រចក ត្រង់ "ខេត្ត" សំដៅចំពោះចំនួនបុគ្គលិករាជការថ្នាក់កណ្តាលដែលធ្វើការ នៅរដ្ឋាភិបាលថ្នាក់ខេត្ត ។

២ : តួលេខពីឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៦៨ មិនបញ្ចូលចំនួនបុគ្គលិករាជការ នៅ Okinawa ទេ (oref.)

អភិបាលកិច្ចមូលដ្ឋាន (ការរៀបចំគាក់តែងគោលនយោបាយ
និងសង្គមស៊ីវិល)
ឆ្នាំសារពើពន្ធ ២០០៧

# ប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសជប៉ុន

# មាតិកា


ជំពូកទី ១ ~ គោលការណ៍គ្រឹះនៃប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសជប៉ុន ..... ១

ជំពូកទី ២ ~ ច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ ..... ២

ជំពូកទី ៣ ~ អង្គភាពគ្រប់គ្រងការបោះឆ្នោត ..... ៤

ជំពូកទី ៤ ~ យោបល់បច្ចេកទេស អនុសាសន៍ ឧលខ នៃការបោះឆ្នោត ..... ៥

ជំពូកទី ៥ ~ សិទ្ធិបោះឆ្នោត ..... ៦

ជំពូកទី ៦ ~ សិទ្ធិឈរឈ្មោះបោះឆ្នោត ..... ៧

ជំពូកទី ៧ ~ មណ្ឌលបោះឆ្នោត ..... ៨

ជំពូកទី ៨ ~ បញ្ជីឈ្មោះអ្នកបោះឆ្នោត ..... ១២

ជំពូកទី ៩ ~ បេក្ខភាព ~ ការឈរឈ្មោះបោះឆ្នោត ..... ១៤

ជំពូកទី ១០ ~ ការដាក់សន្លឹកឆ្នោត ..... ១៨

ជំពូកទី ១១ ~ ការរាប់សន្លឹកឆ្នោត និងការកំណត់បុគ្គលជាប់ឆ្នោត ..... ២៤

ជំពូកទី ១២ ~ យុទ្ធនាការឃោសនាបោះឆ្នោត ..... ២៧

ជំពូកទី ១៣ ~ ចំណូល និងចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោត ..... ៣៥

ជំពូកទី ១៤ ~ បណ្ដឹង ..... ៣៩

ជំពូកទី ១៥ ~ បទល្មើសក្នុងការបោះឆ្នោត ..... ៤០

ជំពូកទី ១៦ ~ បទបញ្ញត្តិពីការផ្ដល់ហិរញ្ញវត្ថុដល់សកម្មភាពនយោបាយ ..... ៤២

ជំពូកទី ១៧ ~ ឧបត្ថម្ភកធនសម្រាប់គណបក្សនយោបាយ ..... ៤៦

# ជំពូកទី ១ ~ គោលការណ៍គ្រឹះនៃប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសជប៉ុន

រដ្ឋធម្មនុញ្ញប្រទេសជប៉ុនអនុម័តយកគោលការណ៍ប្រជាធិបតេយ្យតំណាង និងធានាអោយមានការបោះឆ្នោតជាសកល សមភាពនៃសម្លេងឆ្នោត និងភាពសម្ងាត់នៃការបោះឆ្នោត ធ្វើជាគោលការណ៍គ្រឹះនៃប្រព័ន្ធបោះឆ្នោត ។ គោលការណ៍ទាំងនេះ មានចែងនៅក្នុងជំពូកស្តីពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាជន ដែលអនុវត្តចំពោះការបោះឆ្នោតជ្រើសរើសសមាជិកសភាជាតិ ព្រមទាំងការបោះឆ្នោតជ្រើសរើសសមាជិកសភាមូលដ្ឋាន និងប្រធានអាជ្ញាធរមូលដ្ឋាន ។

## ១. ការបោះឆ្នោតជាសកល

ការបោះឆ្នោតជាសកលសម្រាប់មុខតំណែងសាធារណៈ ត្រូវបានធានាចំពោះប្រជាជនជប៉ុនទាំងអស់ដែលមានអាយុ ២០ ឆ្នាំឡើងទៅ ( មាត្រា ១៥ នៃរដ្ឋធម្មនុញ្ញជប៉ុន សូមមើលមាត្រា ៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ) ។ ដោយហេតុនេះ ចាប់តាំងពីឆ្នាំ១៩៤៥មក ការបោះឆ្នោតលែងមានការរើសអើងភេទ ពូជសាសន៍ វណ្ណៈសង្គម ទ្រព្យសម្បត្តិ ឬបរិមាណពន្ធដែលបានបង់ទៀតហើយ ។ លក្ខខណ្ឌតម្រូវទាក់ទងនឹងបរិមាណពន្ធដែលបានបង់ជូនរតនាគារជាតិ ដែលត្រូវបានធ្វើអោយស្របច្បាប់នៅក្នុងអតីតច្បាប់ស្តីពីការបោះឆ្នោត ក្រោមរដ្ឋធម្មនុញ្ញ Meiji ត្រូវបានលុបចោលទាំងស្រុងនៅក្នុងឆ្នាំ១៩២៥ ហើយក្រោយសង្គ្រាមលោកលើកទី២ ក្នុងឆ្នាំ១៩៤៥ នៅទីបំផុត ស្ត្រីបានទទួលសិទ្ធិបោះឆ្នោត ។

## ២. សមភាពនៃសម្លេងឆ្នោត

ប្រជាជនជប៉ុនទាំងអស់មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហើយមិនត្រូវមានការរើសអើងផ្នែកនយោបាយ សេដ្ឋកិច្ច ឬការប្រព្រឹត្តផ្នែកសង្គមដោយសារពូជសាសន៍ ជំនឿ ភេទ វណ្ណៈសង្គម ឬដើមកំណើតគ្រួសារឡើយ ( មាត្រា ១៤ នៃរដ្ឋធម្មនុញ្ញនៃប្រទេសជប៉ុន) ។ ហើយមិនត្រូវមានការរើសអើងលើលក្ខណៈសម្បត្តិសម្រាប់អ្នកបោះឆ្នោតនៃសមាជិកសភាទាំងពីរថ្នាក់ ដោយសារពូជសាសន៍ ជំនឿ ភេទ វណ្ណៈសង្គម ដើមកំណើតគ្រួសារ កម្រិតវប្បធម៌ ទ្រព្យសម្បត្តិ ឬចំណូល ( មាត្រា ៤៤) ឡើយ ។ ចេញពីគោលការណ៍នេះ យើងអាចធ្វើការសន្និដ្ឋានយ៉ាងងាយស្រួលថា សម្លេងឆ្នោតរបស់អ្នកបោះឆ្នោតទាំងអស់ក៏មានតម្លៃស្មើគ្នាផងដែរ ។ បើយោងតាមយុត្តិសាស្ត្រតុលាការ រដ្ឋធម្មនុញ្ញធានាអោយមានសមភាព មិនត្រឹមតែលើឱកាសទៅបោះឆ្នោតប៉ុណ្ណោះទេ តែថែមទាំងលើតម្លៃរបស់សម្លេងឆ្នោតនីមួយៗផងដែរ ។

## ៣. ភាពសម្ងាត់នៅក្នុងការបោះឆ្នោត

ការបោះឆ្នោតដោយសម្ងាត់ក៏ត្រូវបានធានាអោយមានផងដែរ ។ អ្នកបោះឆ្នោតពុំចាំបាច់ធ្វើការផ្សព្វផ្សាយជាសាធារណៈ ឬជាលក្ខណៈឯកជនអំពីការជ្រើសរើសរបស់ខ្លួននៅក្នុងការបោះឆ្នោតឡើយ ( មាត្រា ១៥) ។

## ៤. ការបោះឆ្នោតដែលផ្អែកលើគោលការណ៍ប្រជាធិបតេយ្យតំណាង

បុគ្គលទាំងឡាយណាដែលជាប់ឆ្នោតតាមរយៈការបោះឆ្នោតជាសាធារណៈ មិនមែនជាអ្នកតំណាងអោយប្រជាជនក្នុងសង្កាត់ពិសេសណាមួយ ដូចជា វណ្ណៈពិសេស គណបក្សនយោបាយ ឬប្រជាជនក្នុងមណ្ឌលបោះឆ្នោតឡើយ តែជាអ្នកតំណាងអោយប្រជាជនទាំងអស់ ។ រដ្ឋធម្មនុញ្ញចែងថា សភាជាតិត្រូវរួមមានសមាជិកជាប់ឆ្នោត ពោលគឺតំណាងរបស់ប្រជាជនទាំងអស់ ( មាត្រា ៤៣) ។

## ជំពូកទី ២ ~ ច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ ធ្វើអោយគោលការណ៍នានាដែលមានក្នុងរដ្ឋធម្មនុញ្ញក្លាយជាការពិត ដោយបានចែងអំពីចំណុចគ្រឹះដែលទាក់ទងនឹងការបោះឆ្នោតជ្រើសរើសមុខតំណែងថ្នាក់ជាតិ និងសាធារណៈមូលដ្ឋាន ។ កាលពីមុន គ្មានច្បាប់ឯកភាពទាក់ទងនឹងការបោះឆ្នោតទេ ។ ការបោះឆ្នោតនីមួយៗ នៅថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋាន ត្រូវបានធ្វើឡើងក្រោមវិធាននៃច្បាប់រៀងៗខ្លួន (ច្បាប់ស្តីពីការបោះឆ្នោតសភាជាន់ទាប ច្បាប់ស្តីពីការបោះឆ្នោតសភាជាន់ខ្ពស់ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះឆ្នោតអាជ្ញាធរមូលដ្ឋាន នៅក្នុងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន) ។ នៅក្នុងឆ្នាំ១៩៥០ ច្បាប់ទាំងនេះទាំងអស់ត្រូវបានពង្រឹងទៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ ដែលយើងនឹងពិនិត្យមើលនៅក្នុងជំពូកខាងក្រោម ។

ប្រភេទ និងចំនួនមុខតំណែងបោះឆ្នោតថេរ ក្រោមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ មានដូចខាងក្រោម ៖

## ប្រភេទនៃមុខតំណែងជ្រើសរើសតាមការបោះឆ្នោត និងចំនួនមុខតំណែងថេរ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦

| ប្រភេទមុខតំណែងជ្រើសរើសតាមការបោះឆ្នោត | ចំនួនអសនៈថេរ (ថ្នាក់ជាតិ) |
|---|---|
| សមាជិកសភាតំណាងរាស្ត្រ | ៤៨០ |
| - បុគ្គលទាំងឡាយណាដែលជាប់ឆ្នោតក្រោមប្រព័ន្ធឯកត្តនាម | ៣០០ |
| - បុគ្គលទាំងឡាយណាដែលជាប់ឆ្នោតក្រោមប្រព័ន្ធសមាមាត្រ | ១៨០ |
| សមាជិកសភាក្រុមប្រឹក្សា | ២៤២ |
| - បុគ្គលទាំងឡាយណាដែលជាប់ឆ្នោតក្រោមប្រព័ន្ធតំណាងក្នុងមូលដ្ឋាន | ១៤៦ |
| - បុគ្គលទាំងឡាយណាដែលជាប់ឆ្នោតក្រោមប្រព័ន្ធសមាមាត្រ | ៩៦ |
| អភិបាលខេត្ត | ៤៧ |
| សមាជិកសភាខេត្ត | ២.៨៧៤ |
| អភិបាលក្រុង (រួមទាំងក្រុងចាត់តាំងទាំង ១៥) | ៧៧៩ |
| សមាជិកសភាក្រុង (រួមទាំងក្រុងចាត់តាំងទាំង ១៥) | ២៤.០៥៧ |
| មេឃុំ និងមេភូមិ | ១.០៣៨ |
| សមាជិកសភាឃុំ និងសភាភូមិ | ១៦.៣៥៨ |
| ប្រធានសង្កាត់ពិសេស (ក្នុងក្រុងតូក្យូ) | ២៣ |
| សមាជិកសភាសង្កាត់ពិសេស (ក្នុងក្រុងតូក្យូ) | ៩២៧ |

កំណត់សម្គាល់ : ចំនួនសមាជិកសភាអាជ្ញាធរមូលដ្ឋានមានចែងនៅក្នុងដីកាខេត្ត/ក្រុង មិនលើសពីចំនួនសមាជិកអតិបរមា ស្របតាមចំនួនប្រជាជននៃអាជ្ញាធរមូលដ្ឋាននីមួយៗ ដែលចែងនៅក្នុងមាត្រា ៩០ (ខេត្ត) និងមាត្រា ៩១ (ក្រុង) នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ។

## ជំពូកទី ៣ ~ អង្គភាពគ្រប់គ្រងការបោះឆ្នោត

ប្រភេទ ទំនួលខុសត្រូវ និងសមាសភាពនៃអង្គភាពគ្រប់គ្រងការបោះឆ្នោតមានដូចខាងក្រោម :

| ប្រភេទ | ទំនួលខុសត្រូវ | សមាសភាព និងរយៈពេលកាន់មុខតំណែង | វិធីសាស្ត្រនៃការជ្រើសរើស |
|---|---|---|---|
| ក្រុមប្រឹក្សាគ្រប់គ្រងការបោះឆ្នោតថ្នាក់កណ្តាល | ទំនួលខុសត្រូវទាក់ទងនឹងការបោះឆ្នោតជ្រើសរើស<br>- សមាជិកដែលផ្អែកលើសមាមាត្រនៃសភាតំណាងរាស្ត្រ<br>- សមាជិកដែលផ្អែកលើសមាមាត្រនៃសភាក្រុមប្រឹក្សា | ៥ នាក់<br>៣ ឆ្នាំ | តែងតាំងដោយនាយករដ្ឋមន្ត្រី ដោយផ្អែកលើការតែងតាំងដោយសភាជាតិ |
| គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតថ្នាក់ខេត្ត | ទំនួលខុសត្រូវទាក់ទងនឹងការបោះឆ្នោតជ្រើសរើស<br>- សមាជិកឯកត្តនាមសភាតំណាងរាស្ត្រ<br>- សមាជិកមណ្ឌលបោះឆ្នោតនៃសភាក្រុមប្រឹក្សា<br>- អភិបាលខេត្ត<br>- សមាជិកសភាខេត្ត | ៤ នាក់<br>៤ ឆ្នាំ | ជ្រើសរើសដោយសភាខេត្ត |
| គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតថ្នាក់ក្រុង (ក្រុង ឃុំ និងភូមិ) | ទំនួលខុសត្រូវទាក់ទងនឹងការបោះឆ្នោតជ្រើសរើស<br>- អភិបាលក្រុង<br>- សមាជិកសភាក្រុង | ៤ នាក់<br>៤ ឆ្នាំ | ជ្រើសរើសដោយសភាក្រុង |

កំណត់សម្គាល់ : ក្រៅពីអ្វីដែលបានរៀបរាប់ខាងលើ គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតត្រូវបង្កើតឡើងនៅក្នុងសង្កាត់ពិសេសនៃរដ្ឋាភិបាលក្រុងតូក្យូ និងក្រុមរដ្ឋបាលនៃក្រុងចាត់តាំងទាំង ១៧ ។

បន្ថែមទៅលើគណៈកម្មាធិការដែលបានរៀបរាប់ខាងលើ មានអង្គភាពគ្រប់គ្រងការបោះឆ្នោតផ្សេងទៀត ដូចជា :

- អ្នកទទួលខុសត្រូវពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬរាប់សន្លឹកឆ្នោត
- អ្នកសង្កេតមើលការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត
- កិច្ចប្រជុំរៀបចំការបោះឆ្នោត (ទទួលបន្ទុករៀបចំសេចក្តីប្រកាសរបស់អ្នកឈ្នះនៅក្នុងការបោះឆ្នោត)
- កិច្ចប្រជុំវងការបោះឆ្នោត (ទទួលបន្ទុករាប់សន្លឹកឆ្នោតនៅក្នុងខេត្ត នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ និងសភាក្រុមប្រឹក្សា តាមប្រព័ន្ធសមាមាត្រ)

## ជំពូកទី ៤ ~ យោបល់បច្ចេកទេស អនុសាសន៍ ១៧១ នៃការបោះឆ្នោត

យោបល់បច្ចេកទេស អនុសាសន៍ ។ល។ នៃការបោះឆ្នោត មានដូចខាងក្រោម :

### ១. យោបល់បច្ចេកទេស អនុសាសន៍ ។ល។ ដោយក្រុមប្រឹក្សាគ្រប់គ្រងការបោះឆ្នោតថ្នាក់កណ្តាល (មាត្រា ៥-៣ ដល់ ៥-៥ នៃច្បាប់ស្តីពីការបោះឆ្នោត)

ក្រុមប្រឹក្សាគ្រប់គ្រងការបោះឆ្នោតថ្នាក់កណ្តាល ផ្តល់ដល់ខេត្ត ក្រុង ឃុំ និងភូមិ នូវយោបល់បច្ចេកទេស អនុសាសន៍ ។ល។ ព្រមទាំងការណែនាំដើម្បីអោយមានការគ្រប់គ្រងដោយស្របច្បាប់ និងត្រឹមត្រូវនៃការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ និងសភាក្រុមប្រឹក្សា ដោយផ្អែកលើប្រព័ន្ធសមាមាត្រ ។

### ២. យោបល់បច្ចេកទេស អនុសាសន៍ ។ល។ ដោយរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ (មាត្រា ២៤៥-៤ ដល់ ២៤៥-៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន)

រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ទទួលសិទ្ធិអំណាចក្នុងការផ្តល់អោយខេត្ត ក្រុង ឃុំ និងភូមិ នូវយោបល់បច្ចេកទេស អនុសាសន៍ ។ល។ ព្រមទាំងការណែនាំដើម្បីអោយមានការគ្រប់គ្រងដោយស្របច្បាប់ និងត្រឹមត្រូវនៃការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ តាមប្រព័ន្ធឯកត្តនាម និងសមាជិកសភាក្រុមប្រឹក្សាតាមប្រព័ន្ធអ្នកបោះឆ្នោតមូលដ្ឋាន ព្រមទាំងសមាជិកអាជ្ញាធរមូលដ្ឋាន ។

### ៣. យោបល់បច្ចេកទេស អនុសាសន៍ ។ល។ ដោយគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត (មាត្រា ២៤៥-៤ ដល់ ២៤៥-៧ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន)

គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត ក៏ផ្តល់អោយគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង នូវយោបល់បច្ចេកទេស អនុសាសន៍ ។ល។ ផងដែរ ។

# ជំពូកទី ៥ ~ សិទ្ធិបោះឆ្នោត

**១.	សិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសរើសសភាជាតិ ( មាត្រា ៩ កថាខ័ណ្ឌ ១ នៃច្បាប់ស្តីពីការបោះឆ្នោត)**

ពលរដ្ឋជប៉ុនទាំងអស់ដែលមានអាយុម្ភៃឆ្នាំឡើងទៅ មានសិទ្ធិទៅបោះឆ្នោតជ្រើសរើសសភាជាតិ ។

**២.	សិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតនៅក្នុងអាជ្ញាធរមូលដ្ឋាន ( មាត្រា ៩ កថាខ័ណ្ឌ ២)**

ពលរដ្ឋជប៉ុនទាំងអស់ដែលមានអាយុម្ភៃឆ្នាំឡើងទៅ ហើយបានរស់នៅដោយស្របច្បាប់នៅក្នុងតំបន់រដ្ឋបាលពិតប្រាកដណាមួយលើសពីបីខែ មានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសរើសអភិបាល ប្រធាន និងសមាជិកសភានៃអាជ្ញាធរមូលដ្ឋាន នៅក្នុងតំបន់នោះ ។

**៣.	ការព្យួរសិទ្ធិបោះឆ្នោត ( មាត្រា ១១, ២៥២ ។ល ។)**

សិទ្ធិបោះឆ្នោតរបស់បុគ្គលទាំងឡាយណាដែលគ្រប់អាយុក្រោមអាណាព្យាបាលភាពនៅក្នុងជំនួយ ដែលត្រូវបានវិនិច្ឆ័យថាអសមត្ថភាព របស់បុគ្គលទាំងឡាយណាដែលត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារ និងរបស់បុគ្គលទាំងឡាយណាដែលត្រូវបានកាត់ទោសដាក់ទណ្ឌកម្មទាក់ទងនឹងការទទួលយកសំណូក ឧក្រិដ្ឋកម្មមួយចំនួនដែលទាក់ទង នឹងការបោះឆ្នោត ឬមូលនិធិនយោបាយ (ឧទាហរណ៍ ការទិញសន្លឹកឆ្នោត ការរំលោភយុទ្ធនាការឃោសនាបោះឆ្នោតធ្ងន់ធ្ងរ ។ល ។) អាចត្រូវបានព្យួរ ។

# ជំពូកទី ៦ ~ សិទ្ធិឈរឈ្មោះបោះឆ្នោត

## ១. សិទ្ធិឈរឈ្មោះបោះឆ្នោត ( មាត្រា ១០ នៃច្បាប់ស្តីពីការបោះឆ្នោត)

ពលរដ្ឋជប៉ុនទាំងអស់មានសិទ្ធិឈរឈ្មោះបោះឆ្នោត ស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

| | |
|---|---|
| (១) សមាជិកសភាតំណាងរាស្ត្រ | អ្នកដែលមានអាយុ ២៥ ឆ្នាំឡើងទៅ |
| (២) សមាជិកសភាក្រុមប្រឹក្សា | អ្នកដែលមានអាយុ ៣០ ឆ្នាំឡើងទៅ |
| (៣) សមាជិកសភាខេត្ត/ក្រុង | អ្នកដែលមានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសរើសសភាខេត្ត/ក្រុង និងដែលមានអាយុ ២៥ ឆ្នាំឡើងទៅ |
| (៤) អភិបាលខេត្ត | អ្នកដែលមានអាយុ ៣០ ឆ្នាំឡើងទៅ |
| (៥) អភិបាលក្រុង | អ្នកដែលមានអាយុ ២៥ ឆ្នាំឡើងទៅ |

## ២. ការព្យួរសិទ្ធិឈរឈ្មោះបោះឆ្នោត ( មាត្រា ១១, ១១-២, ២៥២ ។ល ។)

ដូចនៅក្នុងករណីសិទ្ធិបោះឆ្នោតដែរ ការព្យួរសិទ្ធិឈរឈ្មោះបោះឆ្នោត អាចត្រូវបានធ្វើឡើង ចំពោះបុគ្គល ទាំងឡាយណាដែលត្រូវបានវិនិច្ឆ័យថាអសមត្ថភាព ឬកាត់ទោសអោយទទួលទណ្ឌកម្មជាក់លាក់ណាមួយ ។ (សូមមើលជំពូកទី៥ ខាងលើ ។)

# ជំពូកទី ៧ ~ មណ្ឌលបោះឆ្នោត

មណ្ឌលបោះឆ្នោតនៅក្នុងប្រទេសជប៉ុន ត្រូវបានកំណត់ព្រំដែនផ្សេងៗគ្នា សម្រាប់ការបោះឆ្នោតនីមួយៗ ។

## ១. មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ

សមាជិកសភាតំណាងរាស្ត្រ (សរុបមានចំនួន ៤៨០ នាក់) ចែកចេញជាពីរក្រុម ដែលត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងប្រព័ន្ធអ្នកបោះឆ្នោតផ្សេងគ្នា ប៉ុន្តែស្មើគ្នា ដូចខាងក្រោម (មាត្រា ៤ កថាខ័ណ្ឌ ១ នៃច្បាប់ស្តីពីការបោះឆ្នោត) :

(១) ប្រព័ន្ធមណ្ឌលបោះឆ្នោតឯកត្តនាម

ក្នុងចំណោមសមាជិកទាំង ៤៨០ រូប សមាជិកចំនួន ៣០០ រូប ត្រូវបានបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធមណ្ឌលបោះឆ្នោតឯកត្តនាម ពោលគឺ ប្រទេសជប៉ុនទាំងមូលត្រូវបានបែងចែកជា ៣០០ មណ្ឌលបោះឆ្នោតតូចៗ ដែលមានតែសមាជិកមួយរូបប៉ុណ្ណោះត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ ។ (មាត្រា ១៣ កថាខ័ណ្ឌ ១ និងបញ្ជីឧបសម្ព័ន្ធ ១ នៃច្បាប់ស្តីពីការបោះឆ្នោត)

ផែនការកំណត់ព្រំដែនមណ្ឌលបោះឆ្នោតឯកត្តនាម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាពិភាក្សាសម្រេចការកំណត់ព្រំដែនមណ្ឌលបោះឆ្នោត សម្រាប់សភាតំណាងរាស្ត្រ ហើយបន្ទាប់មក ស្នើដល់នាយករដ្ឋមន្ត្រីដែលរាយការណ៍អំពីផែនការនេះដល់សភា ។ ដោយផ្អែកលើសំណើរបស់ផែនការនេះ ការពិនិត្យមើលឡើងវិញនូវច្បាប់ស្តីពីការបោះឆ្នោត ត្រូវបានធ្វើអោយស្របច្បាប់ ដើម្បីកែប្រែព្រំដែនរបស់មណ្ឌលបោះឆ្នោត ។

នៅពេលធ្វើផែនការ ក្រុមប្រឹក្សានេះត្រូវតែពិចារណាជាចម្បងថា វិសមភាពអតិបរមានៅក្នុងចំនួនប្រជាជនក្នុងចំណោមអ្នកបោះឆ្នោត ត្រូវតិចជាងពីរ ។ បន្ថែមពីលើនេះ ក្រុមប្រឹក្សានេះត្រូវពិចារណាអំពីព្រំដែនតំបន់រដ្ឋបាល ព្រមទាំងស្ថានភាពភូមិសាស្ត្រ និងស្ថានភាពដឹកជញ្ជូន (មាត្រា ៣ កថាខ័ណ្ឌ ១ នៃច្បាប់ស្តីពីការបង្កើតក្រុមប្រឹក្សាពិភាក្សាសម្រេចអំពីការកំណត់ព្រំដែនមណ្ឌលបោះឆ្នោត) ។

ចំនួនមណ្ឌលបោះឆ្នោតសម្រាប់ខេត្តនីមួយៗ ត្រូវបានកំណត់ដូចខាងក្រោម ។ ខេត្តនីមួយៗនៃខេត្តទាំង ៤៧ មានមណ្ឌលបោះឆ្នោតមួយ ហើយមណ្ឌលបោះឆ្នោតដែលនៅសល់ទាំង ២៥៣ ត្រូវបានបែងចែកស្របតាមចំនួនប្រជាជននៃមណ្ឌលនោះ ។ (មាត្រា ៣ កថាខ័ណ្ឌ ២ នៃច្បាប់ស្តីពីការបង្កើតក្រុមប្រឹក្សាពិភាក្សាសម្រេចអំពីការកំណត់ព្រំដែនមណ្ឌលបោះឆ្នោត) ។

(២) ប្រព័ន្ធសមាមាត្រ

សមាជិកនៅសល់ទាំង ១៨០ រូបក្នុងចំណោមសមាជិកទាំង ៤៨០ រូប ត្រូវបានបោះឆ្នោតជ្រើសរើសតាមប្រព័ន្ធសមាមាត្រ ។ ឯកតានៃមណ្ឌលបោះឆ្នោតគឺតំបន់ទាំងមូល ពោលគឺ តំបន់ទាំងមូលនៃប្រទេសជប៉ុនត្រូវបានបែងចែកជា ១១ មណ្ឌលបោះឆ្នោត ។

អាសនៈទាំង ១៨០ ត្រូវបានបែងចែកទៅមណ្ឌលបោះឆ្នោតនីមួយៗ ទៅតាមចំនួនប្រជាជន ។ (មាត្រា ១៣ កថាខ័ណ្ឌ ២ និងបញ្ជីឧបសម្ព័ន្ធ ២ នៃច្បាប់ស្តីពីការបោះឆ្នោត)

មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតសភាតំណាងរាស្ត្រ

( ប្រព័ន្ធសមាមាត្រ)

| ឈ្មោះមណ្ឌលបោះឆ្នោត | ខេត្តដែលបញ្ចូលក្នុងមណ្ឌលបោះឆ្នោត | ចំនួនអាសនៈថេរ |
|---|---|---|
| ១) ហុកកៃដូ | ហុកកៃដូ | ៨ |
| ២) តូហូគូ | អាអូម៉ូរី អ៊ីវ៉ាត មីយ៉ាគី អាគីតា យ៉ាម៉ាកាតា ហ្វូគូស៊ីម៉ា | ១៤ |
| ៣) កង់តូ (ជើង) | អ៊ីបារ៉ាគី តូជីជី ហ្គុនណា សៃតាម៉ា | ២០ |
| ៤) កង់តូ (ត្បូង) | ជីបា កាណាកាវ៉ា យ៉ាម៉ាណាស៊ិ | ២២ |
| ៥) តូក្យូ | តូក្យូ | ១៧ |
| ៦) ហុកគូរីគូ-ស៊ីនអេស៊ូ | នីអ៊ីកាតា តូយ៉ាម៉ា អ៊ីស៊ីកាវ៉ា ហ្វូគូអ៊ីណាហ្គាណូ | ១១ |
| ៧) តូកៃ | ហ្ស៊ីហ្វូ ស៊ីហ្សូអូកា អៃជី មី | ២១ |
| ៨) គីនគី | ស៊ីកា ក្យូតូ អូសាកា ហ៊ីយ៉ូកូ ណារ៉ា វ៉ាកាយ៉ាម៉ា | ២៩ |
| ៩) ជូកូគូ | តូតតូរី ស៊ីម៉ានិ អូកៃយ៉ាម៉ា ហ៊ីរ៉ូស៊ីម៉ា យ៉ាម៉ាគូជី | ១១ |
| ១០) ស៊ិកូគូ | តូគុយស៊ីម៉ា កាហ្គាវ៉ា អេហ៊ីមិ កូជី | ៦ |
| ១១) គីយូស៊ុយ | ហ្វូគូអូកា ស្ទាកា ណាកាសាគី គូម៉ាម៉ូតូ អូអ៊ីតា មីយ៉ាសាគី កាកូស៊ីម៉ា អូគីណាវ៉ា | ២១ |
| សរុប | | ១៨០ |

**២. មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា**

សមាជិកសភាក្រុមប្រឹក្សា (សរុបមានចំនួន ២៤២ រូប) ចែកចេញជាពីរក្រុមដែលបោះឆ្នោតជ្រើសរើស ក្រោមប្រព័ន្ធដូចខាងក្រោម (មាត្រា ៤ កថាខ័ណ្ឌ ២) ។

(១) ប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន

ក្នុងចំណោមសមាជិកទាំង ២៤២ រូប មានសមាជិកចំនួន ១៤៦ រូប ត្រូវបានបោះឆ្នោតជ្រើសរើសក្រោមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋានតាមខេត្ត ។ ព្រំដែននៃមណ្ឌលបោះឆ្នោតទាំងនេះដូចគ្នានឹងព្រំដែនខេត្តដែរ ។ ចំនួនថេរនៃសមាជិកសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ មានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោត ដែលត្រូវបានបែងចែកស្របតាមចំនួនប្រជាជន នៅក្នុងខេត្តនីមួយៗ (ពី ២ អាសនៈ ទៅ ១០ អាសនៈ ។ សូមមើលមាត្រា ១៤ និងបញ្ជីឧបសម្ព័ន្ធ ៣) ។

(២) ប្រព័ន្ធសមាមាត្រ

សមាជិកនៅសល់ចំនួន ៩៦ រូបក្នុងចំណោមសមាជិកចំនួន ២៤២ រូប ត្រូវបានបោះឆ្នោតជ្រើសរើសក្នុងទូទាំងប្រទេស ក្រោមប្រព័ន្ធសមាមាត្រ ។

## ៣. មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកសភាអាជ្ញាធរមូលដ្ឋាន

ចំនួនសមាជិកសភាអាជ្ញាធរមូលដ្ឋាន មានចែងនៅក្នុងដីកាខេត្ត/ក្រុង នៅក្នុងចំណោមចំនួនសមាជិកអតិបរមាស្របតាមចំនួនប្រជាជននៃអាជ្ញាធរមូលដ្ឋាននីមួយៗ ដែលមានចែងនៅក្នុងមាត្រា ៩០ (ខេត្ត) និង ៩១ (ក្រុង) នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ។ ពាក់ព័ន្ធនឹងអង្គភាពកំណត់ព្រំដែន មានលក្ខណៈវិនិច្ឆ័យផ្សេងៗគ្នា សម្រាប់កម្រិតនីមួយៗនៃអាជ្ញាធរមូលដ្ឋាន (មាត្រា ១៥) ។

(១) សភាខេត្ត

តំបន់នៃភូមិភាគមួយ (ហៅថា "*Gun*" : តំបន់ដែលរួមមានឃុំ និងភូមិជាច្រើន) ឬក្រុងត្រូវបានចាត់តាំងជាមណ្ឌលបោះឆ្នោត ដែលមានសមាជិកមួយរូប ឬច្រើន ។ ចំនួនសមាជិកថេរត្រូវបានបែងចែកស្របតាមចំនួនប្រជាជននៃមណ្ឌលបោះឆ្នោតនីមួយៗ ។ ប្រសិនបើប្រជាជននៃតំបន់មួយចំនួន មានចំនួនតិចជាងប្រជាជនក្នុងសមាជិកម្នាក់ ប្រជាជនក្នុងតំបន់នោះត្រូវបូកបញ្ចូលជាមួយប្រជាជននៃមណ្ឌលបោះឆ្នោតផ្សេងទៀតដើម្បីបង្កើតជាមណ្ឌលបោះឆ្នោតថ្មី ដែលជាប្រការចាំបាច់ ឬបន្ទាប់បន្សំ ។

(២) សភាក្រុង

តំបន់ទាំងមូលនៃក្រុងមួយ (ក្រុង ឃុំ ឬភូមិ) ត្រូវបានចាត់តាំងជាមណ្ឌលបោះឆ្នោតមួយ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុងមួយអាចបង្កើតមណ្ឌលបោះឆ្នោតពីរ ឬច្រើន តាមរយៈដីកាក្រុង ប្រសិនបើក្រុងមានតម្រូវការពិសេស ។

មណ្ឌលបោះឆ្នោតនៅក្នុងក្រុងចាត់តាំង ត្រូវគ្នានឹងមណ្ឌលរដ្ឋបាល ។

## សូមមើល ចំនួនថេរនៃអាសនៈសភាអាជ្ញាធរមូលដ្ឋាន

## (មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន)

| ប្រភេទអាជ្ញាធរមូលដ្ឋាន | ប្រជាជន | កម្រិតអតិបរមានៃចំនួនអាសនៈ |
|---|---|---|
| ខេត្ត<br>(មិនរាប់ក្រុងតូក្យូ) | ~ ៧៤៩.៩៩៩<br>៧៥0.000 ~ ៩៩៩.៩៩៩<br>១.000.000 ~ | ៤០<br>៤០+[(X-៧00.000)/៥0.000]<br>៤៥+[(X-៩៣0.000)/៧0.000]<br>(អតិបរមា ១២០) |
| តូក្យូ | ~ ៧៤៩.៩៩៩<br>៧៥.000 ~ ៩៩៩.៩៩៩<br>១.000.000 ~ | ៤០+(Y/១.000.000)<br>៤០+[(X-៧00.000)/៥0.000]<br>+(Y/១.000.000)<br>៤៥+[(X-៩៣0.000)/៧0.000]<br>+(Y/១.000.000)<br>(អតិបរមា ១៣០) |
| ក្រុង | ~ ៤៩.៩៩៩<br>៥0.000 ~ ៩៩.៩៩៩<br>១00.000 ~ ១៩៩.៩៩៩<br>២00.000 ~ ២៩៩.៩៩៩<br>៣00.000 ~ ៤៩៩.៩៩៩<br>៥00.000 ~ ៨៩៩.៩៩៩<br>៩00.000 | ២៦<br>៣០<br>៣៤<br>៣៨<br>៤៦<br>៥៦<br>៥៦+៨×[(X-៥00.000)/៤00.000]<br>(អតិបរមា ៩៦) |
| ឃុំ និងភូមិ | ~ ១.៩៩៩<br>២.000 ~ ៤.៩៩៩<br>៥.000 ~ ៩.៩៩៩<br>១០.000 ~ ១៩.៩៩៩<br>២០.000 ~ | ១២<br>១៤<br>១៨<br>២២<br>២៦ |

កំណត់សម្គាល់ : X = ប្រជាជននៃអាជ្ញាធរមូលដ្ឋានសាមី

Y = ប្រជាជនសរុបនៃសង្កាត់ពិសេស

ចំនួនដែលគណនានៅក្នុង [ ] ត្រូវកាត់ខ្ទង់ចុះក្រោម ។

អាជ្ញាធរមូលដ្ឋានកំណត់ចំនួនអាសនៈ តាមរយៈដីកា តាមលំដាប់នៃកម្រិតអតិបរមានៃចំនួន ។

# ជំពូកទី ៨ ~ បញ្ជីឈ្មោះអ្នកបោះឆ្នោត

## ១. បញ្ជីឈ្មោះអ្នកបោះឆ្នោតអចិន្ត្រៃយ៍

អ្នកទាំងឡាយណាដែលមិនបានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត មិនអាចបោះឆ្នោតបានឡើយ ទោះបីជាពួកគេមានសិទ្ធិបោះឆ្នោតក៏ដោយ ( មាត្រា ៤២ នៃច្បាប់ស្តីពីការបោះឆ្នោត) ។

បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវបានរៀបចំ និងរក្សាទុកក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតនៃក្រុងនីមួយៗ ។ នៅក្នុងបញ្ជីឈ្មោះនេះ ត្រូវមានឈ្មោះ អាសយដ្ឋាន ភេទ ថ្ងៃខែឆ្នាំកំណើត ។ល។ របស់អ្នកបោះឆ្នោតនីមួយៗ ( មាត្រា ២០) ។

ក្រោយពេលអ្នកបោះឆ្នោតម្នាក់បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះ ការចុះឈ្មោះនេះនៅតែមានសុពលភាពជាអចិន្ត្រៃយ៍ រហូតដល់គាត់ត្រូវបានលុបឈ្មោះចេញពីបញ្ជី ដោយសារមរណភាព ការបាត់បង់សញ្ជាតិ ឬនៅក្រោយរយៈពេល ៤ ខែបន្ទាប់ពីពេលដែលគាត់ផ្ទេរទៅរស់នៅក្រុងផ្សេងទៀត ។

ពលរដ្ឋជប៉ុនដែលមានអាយុលើស ២០ ឆ្នាំ ហើយរស់នៅក្នុងតំបន់ដែលស្ថានកុងស៊ុលដែលត្រួតពិនិត្យមើលអាសយដ្ឋានរបស់ពលរដ្ឋនោះ អនុវត្តយុត្តាធិការលើតំបន់នោះ អាចស្នើសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅបរទេសបាន ( មាត្រា ៣០-៥) ។

ពលរដ្ឋនេះអាចត្រូវបានចុះឈ្មោះនៅក្នុងបញ្ជី នៅពេលពលរដ្ឋនេះរស់នៅក្នុងតំបន់ដែលស្ថានកុងស៊ុល ដែលត្រួតពិនិត្យមើលអាសយដ្ឋានរបស់ពលរដ្ឋនោះ អនុវត្តយុត្តាធិការ សម្រាប់យ៉ាងហោចណាស់ក្នុងរយៈពេលប៉ុន្មានខែនេះជាប់ៗគ្នា ( មាត្រា ៣០-៤) ។

## ២. នីតិវិធីសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោត

(១) ការចុះឈ្មោះ

គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង ទទួលសិទ្ធិអំណាចក្នុងការចុះឈ្មោះជាសមាជិកពេញសិទ្ធិនូវពលរដ្ឋជប៉ុនណាដែលមានអាយុ ២០ ឆ្នាំឡើងទៅ មានទីលំនៅនៅក្នុងតំបន់នៃក្រុងសាមី ហើយឈ្មោះត្រូវបានកត់ត្រានៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រឹះនៃប្រជាជននៃក្រុងនោះ អស់រយៈពេលច្រើនជាងបីខែជាប់ៗគ្នា ចាប់ពីថ្ងៃចុះឈ្មោះក្នុងសៀវភៅ ឬសម្រាប់បុគ្គលដែលទើបតែបានរើទៅរស់នៅក្នុងក្រុងនោះ ចាប់ពីថ្ងៃធ្វើការផ្ទេរបញ្ជី ។ ( មាត្រា ២១) ។

ការចុះឈ្មោះមានពីរប្រភេទ : ទីមួយគឺការចុះបញ្ជីប្រចាំត្រីមាស ដែលធ្វើឡើងនៅក្នុងខែមីនា ឧសភា កញ្ញា និងធ្នូ ទីពីរត្រូវបានធ្វើឡើងជាពិសេស សម្រាប់ការបោះឆ្នោតនីមួយៗ ( មាត្រា ១៩ និងមាត្រា ២២) ។

ម្យ៉ាងទៀត ការចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅបរទេស ត្រូវបានធ្វើឡើងទៅតាមការស្នើសុំ ( មាត្រា ៣០-៤) ។

(២) ការដាក់បង្ហាញ ការជំទាស់ផ្លូវការ និងបណ្តឹង

ក្រោយពេលចុះឈ្មោះ គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតនៃក្រុងនីមួយៗ ត្រូវបានស្នើអោយបង្ហាញដល់សាធារណជននូវឈ្មោះ អាសយដ្ឋាន និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោត ដែលបានចុះក្នុងបញ្ជីឈ្មោះ ( មាត្រា ២៣) ។ នៅពេលអ្នកបោះឆ្នោតមានការជំទាស់ ទាក់ទងនឹងការចុះឈ្មោះរបស់ខ្លួនផ្ទាល់ ឬរបស់អ្នកដទៃ អ្នកបោះឆ្នោតនោះអាចដាក់លិខិតជំទាស់ទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុងសាមីក្នុងកំឡុងរយៈពេលដាក់បង្ហាញ ( មាត្រា ២៤) ។ អ្នកបោះឆ្នោតទាំងឡាយណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចលើលិខិតជំទាស់របស់ខ្លួន អាចដាក់ពាក្យបណ្តឹងបាន ( មាត្រា ២៥) ។

( ៣) ការបញ្ជាក់ និងមោឃកម្ម

ក្នុងករណីអ្នកបោះឆ្នោតត្រូវបានដកហូតសិទ្ធិបោះឆ្នោត ស្របតាមបទប្បញ្ញត្តិច្បាប់ ឬអ្នកបោះឆ្នោតបានរើចេញពីក្រុងជាក់លាក់ណាមួយ គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុងសាមី ត្រូវធ្វើការបញ្ជាក់ភ្លាមៗអំពីឥទ្ធិពលនោះលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង ត្រូវលុបឈ្មោះរបស់អ្នកបោះឆ្នោតពីបញ្ជីឈ្មោះអោយបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ប្រសិនបើអ្នកបោះឆ្នោតនោះស្លាប់ បាត់បង់សញ្ជាតិជប៉ុន ឬបានផ្លាស់ទីលំនៅពីក្រុងសាមី អស់រយៈពេលបួនខែជាប់ៗគ្នា ( មាត្រា ២៨) ។

## ជំពូកទី ៩ ~ បេក្ខភាព ~ ការឈរឈ្មោះបោះឆ្នោត

### ១. លិខិតជូនដំណឹងអំពីបេក្ខភាព

(១) ការជូនដំណឹងអំពីប្រព័ន្ធឯកត្តនាម សម្រាប់សភាតំណាងរាស្ត្រ

គណបក្សនយោបាយដែល យ៉ាងហោចណាស់ សមាជិកសភា ៥ រូបមកពីគណបក្សនោះ ឬដែលទទួលបានសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស យ៉ាងហោចណាស់ ២% នៅក្នុងការបោះឆ្នោត* ជាក់លាក់ថ្មីបំផុតមួយ អាចប្រកាសឈ្មោះបេក្ខជនរបស់ខ្លួន សម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ ជូនទៅប្រធានកិច្ចប្រជុំស្តីពីការបោះឆ្នោតប្រចាំមណ្ឌលបោះឆ្នោតនោះ ។ លើសពីនេះទៀត ការជូនដំណឹងដែលធ្វើឡើងដោយបេក្ខជនស្ម័គ្រចិត្ត និងការជូនដំណឹងអំពីបេក្ខជនដែលបានតែងតាំង ដែលធ្វើឡើងដោយអ្នកតែងតាំង ក៏អាចទទួលយកបានដែរ ( មាត្រា ៨៦ នៃច្បាប់ស្តីពីការបោះឆ្នោត) ។

* នៅក្នុងបរិបទនៃជំពូកនេះ "ការបោះឆ្នោតជាក់លាក់" សំដៅដល់ការបោះឆ្នោតថ្នាក់ជាតិណាមួយដូចតទៅ : ការបោះឆ្នោតទូទៅក្រោមប្រព័ន្ធឯកត្តនាម និងក្រោមប្រព័ន្ធសមាមាត្រ សម្រាប់សភាតំណាងរាស្ត្រ ការបោះឆ្នោតទៀងទាត់ក្រោមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន និងក្រោមប្រព័ន្ធសមាមាត្រសម្រាប់សភាក្រុមប្រឹក្សា ។

(២) ការជូនដំណឹងអំពីប្រព័ន្ធសមាមាត្រ សម្រាប់សភាតំណាងរាស្ត្រ

មិនត្រឹមតែគណបក្សនយោបាយ (១) ខាងលើប៉ុណ្ណោះទេ តែថែមទាំងអង្គការនយោបាយទាំងអស់ដែលត្រៀមខ្លួនជាស្រេចក្នុងការបង្ហាញបេក្ខជន ដែលស្មើនឹងយ៉ាងហោចណាស់ ២០ ភាគរយនៃចំនួនថេរនៅក្នុងមណ្ឌលបោះឆ្នោតភូមិភាគ អាចដាក់បញ្ជីឈ្មោះបេក្ខជន-បេក្ខនារីរបស់ខ្លួន តាមលំដាប់អាទិភាពដើម្បីទទួលការជ្រើសរើស ( មាត្រា ៨៦-២) ។

នៅក្នុងការបោះឆ្នោតក្រោមប្រព័ន្ធសមាមាត្រ សម្រាប់សភាតំណាងរាស្ត្រ គណបក្សនយោបាយ (១) ខាងលើ ជាករណីលើកលែង អាចរាយឈ្មោះបេក្ខជនសម្រាប់ជ្រើសរើសក្រោមប្រព័ន្ធសមាមាត្រ ទោះបីជាគណបក្សនយោបាយទាំងនោះ ជូនដំណឹងដល់បេក្ខជនដដែលនេះ សម្រាប់ការបោះឆ្នោតដែលរៀបចំឡើងនៅក្នុងពេលតែមួយ នៅក្នុងមណ្ឌលបោះឆ្នោតឯកត្តនាម រួមទាំងនៅក្នុងមណ្ឌលបោះឆ្នោតភូមិភាគក៏ដោយ (ហៅថា "បេក្ខភាពឌុប" មាត្រា ៨៦-២ កថាខ័ណ្ឌ ៤) ។

ច្បាប់ស្តីពីការបោះឆ្នោត កំណត់ចំនួនអតិបរមានៃបេក្ខជននៅក្នុងការបោះឆ្នោតភូមិភាគនីមួយៗទៅតាមចំនួនអាសនៈថេរ ទោះបីជាបេក្ខជនដែលបានដាក់បេក្ខភាពឌុប មិនបានរាប់បញ្ចូលក៏ដោយ ( មាត្រា ៨៦-២ កថាខ័ណ្ឌ ៥) ។ គណបក្ស (១) ខាងលើ ក៏អាចបញ្ជូនបេក្ខជនដែលដាក់បេក្ខភាពឌុប នៅក្នុងអាទិភាពដូចគ្នា នៅក្នុងបញ្ជីផងដែរ ( មាត្រា ៨៦-២ កថាខ័ណ្ឌ ៦) ។

(៣) ការជូនដំណឹងអំពីប្រព័ន្ធសមាមាត្រសម្រាប់សភាក្រុមប្រឹក្សា

គណបក្សនយោបាយដែលយ៉ាងហោចណាស់សមាជិកសភា ៥ រូបមកពីគណបក្សនោះ ឬដែលទទួលបានសន្លឹកឆ្នោតបានការសរុបទូទាំងប្រទេស យ៉ាងហោចណាស់ ២% នៅក្នុងការបោះឆ្នោតថ្នាក់ជាតិថ្មីបំផុត

មួយ ហើយអង្គការនយោបាយដែលត្រៀមខ្លួនរួចជាស្រេចដើម្បីបង្ហាញបេក្ខជនរបស់ខ្លួនយ៉ាងហោចណាស់ ១០ រូបនៅក្នុងការបោះឆ្នោតទៀងទាត់ រួមទាំងការបោះឆ្នោតសម្រាប់មណ្ឌលបោះឆ្នោតមូលដ្ឋាន អាចដាក់បញ្ជីឈ្មោះបេក្ខជនទូទាំងប្រទេសរបស់ខ្លួន ។ ( មាត្រា ៨៦-៣)

បេក្ខភាពឌុបនៅក្នុងការបោះឆ្នោតណាមួយផ្សេងទៀត ត្រូវបានហាមឃាត់ ។

(៤) ការជូនដំណឹងអំពីការបោះឆ្នោតក្រៅពី (១), (២) និង (៣)

បេក្ខជនខ្លួនឯងផ្ទាល់ ឬអ្នកតែងតាំងរបស់ខ្លួនអាចប្រកាសឈ្មោះរបស់បេក្ខជន ( មាត្រា ៨៦-៤) ។

## ២. រយៈពេលជូនដំណឹង

ការជូនដំណឹងអំពីបេក្ខភាពត្រូវតែធ្វើឡើងនៅថ្ងៃដែលកាលបរិច្ឆេទបោះឆ្នោតត្រូវបានប្រកាសជាសាធារណៈ ។

## ៣. ការហាមឃាត់ និងការដាក់កំហិតបេក្ខភាព

បុគ្គលម្នាក់ត្រូវបានហាមឃាត់មិនអោយឈរឈ្មោះជាបេក្ខជន នៅក្នុងការបោះឆ្នោតច្រើនជាងមួយ តែមួយលើក ( លើកលែងស្ថានភាពបេក្ខភាពឌុប ដែលបានរៀបរាប់រួចហើយ) ហើយបុគ្គលម្នាក់ដែលគ្មានសិទ្ធិបោះឆ្នោត មិនអាចឈរឈ្មោះជាបេក្ខជនឡើយ ( មាត្រា ៨៦-៨ ៨៧) ។

ក៏មានការដាក់កំហិតមួយចំនួនផងដែរទាក់ទងនឹងបេក្ខភាពរបស់មន្ត្រីរាជការ (ដោយមានអញ្ញត្រកម្មមួយចំនួន) ផងដែរ ហើយបុគ្គលិកនៅក្នុងការិយាល័យដែលទាក់ទងនឹងការបោះឆ្នោត ( មាត្រា ៨៨ និង ៨៩) ។

## ៤. ប្រាក់តម្កល់

ជាមួយនឹងការលើកលែងនៃការបោះឆ្នោតសម្រាប់សមាជិកសភាឃុំ/ភូមិ បេក្ខជន អ្នកតែងតាំង ឬគណបក្សនយោបាយ ត្រូវបានស្នើអោយដាក់ប្រាក់តម្កល់ ក្នុងចំនួនទឹកប្រាក់ជាក់លាក់មួយ នៅពេលពួកគេប្រកាសអំពីបេក្ខភាពរបស់ពួកគេ ឬឈ្មោះរបស់បេក្ខជនរបស់ពួកគេ ( មាត្រា ៩២) ។

ប្រាក់តម្កល់អាចបង្វែរចូលរតនាគារជាតិ ឬអាជ្ញាធរមូលដ្ឋានសាមី ក្នុងករណីចំនួនសន្លឹកឆ្នោតដែលបេក្ខជនទទួលបាននៅក្នុងការបោះឆ្នោតណាមួយ មិនដល់កម្រិតចំនួនអប្បបរមាជាក់លាក់ណាមួយ ( មាត្រា ៩៣) ។ នៅក្នុងករណីការបោះឆ្នោតក្រោមប្រព័ន្ធសមាមាត្រនៃសភាទាំងពីរ ចំនួនទឹកប្រាក់ដែលត្រូវបង្វែរចូល ត្រូវបានគណនាដោយប្រើ "ចំនួនបេក្ខជនដែលជាប់ឆ្នោត" ពីបញ្ជីឈ្មោះរបស់គណបក្ស និង "ចំនួនបេក្ខជននៅក្នុងបញ្ជីជាប់ឆ្នោត" ( មាត្រា ៩៤) ។

# ប្រាក់តម្កល់សម្រាប់ការបោះឆ្នោត

| ប្រភេទការបោះឆ្នោត | ចំនួនប្រាក់តម្កល់ |
|---|---|
| សមាជិកសភាតំណាងរាស្ត្រ : | |
| - បេក្ខជនក្នុងប្រព័ន្ធឯកត្តនាម | ៣.០០០.០០០ យេន ក្នុងម្នាក់ |
| - គណបក្សនយោបាយក្នុងប្រព័ន្ធសមាមាត្រ | សម្រាប់មណ្ឌលបោះឆ្នោតភូមិភាគនីមួយៗ : ៣.០០០.០០០ យេន ×α+៦.០០០.០០០ យេន ×β |
| សមាជិកសភាក្រុមប្រឹក្សា | |
| - បេក្ខជនក្នុងប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន | ៣.០០០.០០០ យេន ក្នុងម្នាក់ |
| - គណបក្សនយោបាយក្នុងប្រព័ន្ធសមាមាត្រ | ៦.០០០.០០០ យេន × γ |
| សមាជិកសភាខេត្ត | ៦០០.០០០ យេន ក្នុងម្នាក់ |
| អភិបាលខេត្ត | ៣.០០០.០០០ យេន ក្នុងម្នាក់ |
| សមាជិកសភាក្រុងចាត់តាំង | ៥០០.០០០ យេន ក្នុងម្នាក់ |
| អភិបាលក្រុងចាត់តាំង | ២.៤០០.០០០ យេន ក្នុងម្នាក់ |
| សមាជិកសភាក្រុង (មិនរាប់បញ្ចូលក្រុងចាត់តាំង និងរួមទាំងសង្កាត់ពិសេស) | ៣០០.០០០ យេន ក្នុងម្នាក់ |
| អភិបាលក្រុង (មិនរាប់បញ្ចូលក្រុងចាត់តាំង និងរួមទាំងសង្កាត់ពិសេស) | ១.០០០.០០០ យេន ក្នុងម្នាក់ |
| មេឃុំ /មេភូមិ | ៥០០.០០០ យេន ក្នុងម្នាក់ |

កំណត់សម្គាល់ : α : ចំនួនបេក្ខជនមានបេក្ខភាពឧប

β : ចំនួនបេក្ខជនដែលមិនមែនជាបេក្ខជន នៅក្នុងមណ្ឌលបោះឆ្នោតឯកត្តនាម

γ : ចំនួនបេក្ខជន

## វិធីគណនាការបែងចែកមូលនិធិ

| ប្រភេទនៃការបោះឆ្នោត | ការគណនា |
|---|---|
| សភាតំណាងរាស្ត្រ : | |
| - មណ្ឌលបោះឆ្នោតឯកត្តនាម | ប្រសិនបើ X<១/១០×Y ប្រាក់តម្កល់ទាំងអស់ត្រូវរឹបអូស |
| - សមាមាត្រ | ប្រសិនបើ ($X_1$×៣.000.000) + ($X_2$×2×៦.000.000) = S<D<br>D-S ត្រូវរឹបអូស |
| សភាក្រុមប្រឹក្សា : | |
| - មណ្ឌលបោះឆ្នោតមូលដ្ឋាន | ប្រសិនបើ X<១/៨×(Y÷N) ប្រាក់តម្កល់ទាំងអស់ត្រូវរឹបអូស |
| - សមាមាត្រ | ប្រសិនបើ (X៣×២)<$X_4$<br>៦.000.000 × ($X_4$-$X_3$×2) ត្រូវរឹបអូស |
| សភាមូលដ្ឋាន :<br>(ខេត្ត ឬក្រុង) | ប្រសិនបើ X<១/១០×(Y÷N) ប្រាក់តម្កល់ទាំងអស់ត្រូវរឹបអូស |
| អភិបាល :<br>(ខេត្ត ឬក្រុង) | ប្រសិនបើ X<១/១០ × Y ប្រាក់តម្កល់ទាំងអស់ត្រូវរឹបអូស |

កំណត់សម្គាល់ : X : ចំនួនសន្លឹកឆ្នោតដែលបេក្ខជនទទួលបាន

Y : ចំនួនសន្លឹកឆ្នោតត្រឹមត្រូវនៃមណ្ឌលបោះឆ្នោត

N : ចំនួនថេរនៃអាសនៈមណ្ឌលបោះឆ្នោត

D : ចំនួនប្រាក់តម្កល់

$X_1$ : ចំនួនបេក្ខជនជាប់ឆ្នោត (បេក្ខជនទាំងឡាយណាដែលចុះក្នុងបញ្ជីជាបេក្ខភាពឧប និងជាប់ឆ្នោតក្រោមប្រព័ន្ធឯកត្តនាម)

$X_2$ : ចំនួនបេក្ខជនជាប់ឆ្នោត (មិនរាប់បញ្ចូល $X_1$)

$X_3$ : ចំនួនបេក្ខជនជាប់ឆ្នោត

$X_4$ : ចំនួនបេក្ខជន

# ជំពូកទី ១០ ~ ការដាក់សន្លឹកឆ្នោត

## ១. គោលការណ៍ដាក់សន្លឹកឆ្នោត

ការបោះឆ្នោតត្រូវបានធ្វើឡើងតាមរយៈការដាក់សន្លឹកឆ្នោត ។ ខាងក្រោមនេះ យើងនឹងពិនិត្យមើលឡើងវិញ ហើយផ្តល់ការពន្យល់បន្ថែមអំពីគោលការណ៍ដាក់សន្លឹកឆ្នោត ។

(១) គោលការណ៍បោះឆ្នោត :

ការដាក់សន្លឹកឆ្នោតត្រូវតែធ្វើឡើងដោយអ្នកបោះឆ្នោតដោយខ្លួនឯងនៅថ្ងៃបោះឆ្នោត និងនៅការិយាល័យបោះឆ្នោតដែលបានចាត់តាំង ។

(២) ការដាក់សន្លឹកឆ្នោតដោយស្ម័គ្រចិត្ត :

វាគឺជាសិទ្ធិរបស់អ្នកបោះឆ្នោតទាំងស្រុងក្នុងការសម្រេចថាតើត្រូវដាក់សន្លឹកឆ្នោតឬអត់ ។

(៣) ការធានាអំពីការសម្ងាត់ :

ការសម្ងាត់នៅក្នុងការដាក់សន្លឹកឆ្នោតត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ (ផ្នែកទី ៤ មាត្រា ១៥ នៃរដ្ឋធម្មនុញ្ញ)

(៤) គោលការណ៍មនុស្សម្នាក់សន្លឹកឆ្នោតមួយសន្លឹក ប្រព័ន្ធសន្លឹកឆ្នោតមួយ :

បុគ្គលម្នាក់ដែលមានសិទ្ធិបោះឆ្នោតអាចដាក់សន្លឹកឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ នៅក្នុងការបោះឆ្នោតនីមួយៗ ។ នៅក្នុង "ការបោះឆ្នោត" ដែលនិយាយនៅទីនេះ ការបោះឆ្នោតថ្នាក់ជាតិនីមួយៗនៃសភាទាំងពីរ ត្រូវបានបែងចែកជាការបោះឆ្នោតពីរដាច់ដោយឡែកពីគ្នា : មួយក្រោមប្រព័ន្ធមណ្ឌលបោះឆ្នោត និងមួយទៀត ក្រោមប្រព័ន្ធសមាមាត្រ (មាត្រា ៣៦ នៃច្បាប់ស្តីពីការបោះឆ្នោត) ។

# ទម្រង់សន្លឹកឆ្នោត

១)　ទម្រង់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសភាទាំងពីរក្រោមប្រព័ន្ធមណ្ឌលបោះឆ្នោត

ផ្នែកខាងមុខ

(ផ្គត់)

| | |
|---|---|
| សន្លឹកឆ្នោតសម្រាប់<br>ការបោះឆ្នោត... | ខេត្ត (ក្រុង) (ក្រុម) (ឃុំ) (ភូមិ)<br>គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោត<br>(ត្រាស្នូតរដ្ឋ) |

ផ្នែកខាងក្រោយ

- ការណែនាំ

១. សូមសរសេរឈ្មោះរបស់បេក្ខជនមួយរូបនៅក្នុងចន្លោះខាងក្រោម ។

២. សូមកុំសរសេរឈ្មោះរបស់បុគ្គលដែលមិនមែនជាបេក្ខជន ។

(ផ្គត់)

ឈ្មោះរបស់បេក្ខជន

២)　ទម្រង់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសភាតំណាងរាស្ត្រ ក្រោមប្រព័ន្ធសមាមាត្រ

ផ្នែកខាងមុខ

(ផ្គត់)

| | |
|---|---|
| សន្លឹកឆ្នោតសម្រាប់<br>ការបោះឆ្នោត... | ខេត្ត (ក្រុង) (ក្រុម) (ឃុំ) (ភូមិ)<br>គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោត<br>(ត្រាស្នូតរដ្ឋ) |

ផ្នែកខាងក្រោយ

- ការណែនាំ

សូមសរសេរឈ្មោះ ឬអក្សរកាត់របស់គណបក្សនយោបាយមួយ ឬអង្គការនយោបាយមួយ ។

(ផ្គត់)

ឈ្មោះ ឬអក្សរកាត់របស់គណបក្សនយោបាយ<br>ឬអង្គការនយោបាយ

៣)　ទម្រង់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសភាក្រុមប្រឹក្សា ក្រោមប្រព័ន្ធសមាមាត្របញ្ជីបើក

ផ្នែកខាងមុខ

(ផ្នត់)

| | |
|---|---|
| សន្លឹកឆ្នោតសម្រាប់<br>ការបោះឆ្នោត... | ខេត្ត (ក្រុង) (ក្រុម) (ឃុំ) (ភូមិ)<br>គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោត<br>(ត្រាស្ទួតរដ្ឋ) |

ផ្នែកខាងក្រោយ

- ការណែនាំ

១. សូមសរសេរឈ្មោះរបស់បេក្ខជនមួយរូបនៅក្នុងចន្លោះខាងក្រោម ។

២. លោកអ្នកអាចសរសេរឈ្មោះ ឬអក្សរកាត់របស់គណបក្សនយោបាយមួយ ឬអង្គការនយោបាយមួយ នៅក្នុងចន្លោះខាងក្រោម ជំនួសអោយឈ្មោះរបស់បេក្ខជនមួយរូប ។

(ផ្នត់)

ឈ្មោះ ឬអក្សរកាត់របស់គណបក្សនយោបាយ ឬអង្គការនយោបាយ

អ្នកបោះឆ្នោតត្រូវសរសេរឈ្មោះរបស់បេក្ខជនតែមួយរូបប៉ុណ្ណោះ (ក្នុងករណីការបោះឆ្នោតសភាតំណាងរាស្ត្រក្រោមប្រព័ន្ធសមាមាត្រ ឈ្មោះ ឬអក្សរកាត់របស់គណបក្សនយោបាយ ឬអង្គការនយោបាយតែមួយប៉ុណ្ណោះ និងក្នុងករណីបោះឆ្នោតសភាក្រុមប្រឹក្សា ក្រោមប្រព័ន្ធសមាមាត្រ ឈ្មោះរបស់បេក្ខជនតែមួយរូបប៉ុណ្ណោះ ដែលចុះនៅក្នុងបញ្ជីឈ្មោះបេក្ខជននៃសភាក្រុមប្រឹក្សា ឬឈ្មោះ ឬអក្សរកាត់របស់គណបក្សនយោបាយ ឬអង្គការនយោបាយតែមួយប៉ុណ្ណោះ) នៅលើសន្លឹកឆ្នោត (មាត្រា ៤៦ យោងមាត្រា ៦៨) ។

អ្នកបោះឆ្នោតត្រូវសរសេរឈ្មោះរបស់បេក្ខជន ឬគណបក្សដោយខ្លួនឯងផ្ទាល់ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកបោះឆ្នោតពិការផ្នែករាងកាយ ឬមិនចេះអក្សរ បុគ្គលជាក់លាក់ម្នាក់អាចជួយគាត់បាន ។ ការបោះឆ្នោតដោយប្រើអក្សរប្រាយសម្រាប់មនុស្សខ្វាក់ ត្រូវបានអនុញ្ញាតអោយប្រើចំពោះមនុស្សខ្វាក់ (មាត្រា ៤៧ និង មាត្រា ៤៨) ។

នៅក្នុងករណីបោះឆ្នោតជ្រើសរើសប្រមុខរដ្ឋាភិបាលមូលដ្ឋាន ឬសមាជិកសភាមូលដ្ឋាន (ជាបុព្វសិទ្ធិចែងដោយដីកា មាត្រា ៤៦-២) សន្លឹកឆ្នោតមានឈ្មោះរបស់បេក្ខជនដែលបានបោះពុម្ពជាស្រេច អាចត្រូវបានប្រើប្រាស់ ហើយអ្នកបោះឆ្នោតអាចគ្រាន់តែគូសយកមួយក្នុងចំណោមបេក្ខជនទាំងអស់ ។

## ២. មណ្ឌលបោះឆ្នោត និងការិយាល័យបោះឆ្នោត

តំបន់ឯកភាពមួយសម្រាប់បោះឆ្នោត ហៅថា "មណ្ឌលបោះឆ្នោត" ។ ជាធម្មតា តំបន់នៃក្រុងត្រូវបានបែងចែកជាមណ្ឌលបោះឆ្នោតជាច្រើន តាមការស្នើសុំតាមកាលៈទេសៈ ។ នៅក្នុងពេលបោះឆ្នោតទូទៅដើម្បីជ្រើសរើសសភាតំណាងរាស្ត្រ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៥ ចំនួនមណ្ឌលបោះឆ្នោតសរុបក្នុងទូទាំងប្រទេស មានចំនួន ៥៣.០២១ មណ្ឌល ។

មណ្ឌលបោះឆ្នោតនីមួយៗមានការិយាល័យបោះឆ្នោតមួយ ។

នៅក្នុងករណីភាគច្រើនបំផុត ការិយាល័យបោះឆ្នោតត្រូវបានបង្កើតឡើងនៅក្នុងសាលាក្រុង សាលារៀន ឬសាលសាធារណៈ ។ល។

## ៣. អ្នកត្រួតពិនិត្យមើលការបោះឆ្នោត និងអ្នកសង្កេតការណ៍

អ្នកត្រួតពិនិត្យមើលការបោះឆ្នោត ទទួលខុសត្រូវលើការគ្រប់គ្រងការដាក់សន្លឹកឆ្នោត ។ ពួកគេត្រូវបានជ្រើសរើសឡើងដោយគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង ពីក្នុងចំណោមប្រជាជនដែលមានសិទ្ធិបោះឆ្នោត សម្រាប់ការបោះឆ្នោតដែលពាក់ព័ន្ធ ( មាត្រា ៣៧) ។

អ្នកសង្កេតការណ៍ ធ្វើការសង្កេតមើលការគ្រប់គ្រងការដាក់សន្លឹកឆ្នោត ដើម្បីធានាថា ការបោះឆ្នោតត្រូវបានធ្វើឡើងដោយយុត្តិធម៌ ។ បុគ្គលពីពីរ ទៅប្រាំរូប ត្រូវបានជ្រើសរើសដោយគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង ( មាត្រា ៣៨) ។

## ៤. ពេលវេលាបោះឆ្នោត

ជាធម្មតា ការបោះឆ្នោតត្រូវធ្វើឡើងចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៨:០០ ល្ងាចនៅថ្ងៃបោះឆ្នោត ។ នៅក្នុងកាលៈទេសៈពិសេស ម៉ោងចាប់ផ្តើមអាចកែតម្រូវទៅមុខ ឬថយក្រោយ ដោយគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង ( ដោយមានការយល់ព្រមជាមុនពីគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត) នៅក្នុងរយៈពេលកំណត់ពីរម៉ោង ។ ម៉ោងបិទក៏អាចត្រូវបានកែតម្រូវទៅមុខ នៅក្នុងរយៈពេលកំណត់បួនម៉ោងផងដែរ ( មាត្រា ៤០) ។

## ៥. ការបោះឆ្នោតជាមុន និងការបោះឆ្នោតតាមលិខិតឆ្លើយឆ្លង ( មាត្រា ៤៨-២ និងមាត្រា ៤៩)

ជាគោលការណ៍ អ្នកបោះឆ្នោតត្រូវមកបោះឆ្នោតនៅការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។ ប៉ុន្តែអ្នកបោះឆ្នោតដែលមិនអាចធ្វើដំណើរទៅកន្លែងបោះឆ្នោតបាន នៅថ្ងៃបោះឆ្នោត ដោយសារការងារ ជំងឺ និងមូលហេតុជាក់លាក់ផ្សេងទៀត អាចបោះឆ្នោតនៅចន្លោះពីថ្ងៃក្រោយពេលប្រកាសជាសាធារណៈ ដល់ថ្ងៃមុនការបោះឆ្នោត តាមរយៈប្រព័ន្ធបោះឆ្នោតជាមុន ឬប្រព័ន្ធបោះឆ្នោតតាមលិខិតឆ្លើយឆ្លង ។

លើសពីនេះទៀត អ្នកបោះឆ្នោតដែលពិការរាងកាយធ្ងន់ធ្ងរ ត្រូវបានអនុញ្ញាតអោយប្រើសេវាប្រៃសណីយ៍ ដើម្បីធ្វើការបោះឆ្នោតតាមលិខិតឆ្លើយឆ្លង ។

## ៦. ការបោះឆ្នោតតាមលិខិតឆ្លើយឆ្លងពីបរទេស ( មាត្រា ៤៩)

ការបោះឆ្នោតតាមលិខិតឆ្លើយឆ្លងពីបរទេស អនុញ្ញាតអោយសមាជិកអង្គការដែលផ្ទេរទៅបរទេសជាក់លាក់ អាចបោះឆ្នោតបាន ។ ប្រព័ន្ធនេះ ត្រូវបានបង្កើតឡើងនៅក្នុងវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត នៅខែមិថុនា ឆ្នាំ២០០៦ ។ អ្នកបោះឆ្នោតដែលស្ថិតនៅក្នុងអង្គការដែលផ្ទេរទៅបរទេសជាក់លាក់ និងដែលមិនអាចធ្វើដំណើរទៅកាន់ការិយាល័យបោះឆ្នោតបាន នៅថ្ងៃបោះឆ្នោត ដោយសារការងារ ឬមូលហេតុជាក់លាក់ផ្សេងទៀត អាចបោះឆ្នោតនៅចន្លោះពីថ្ងៃក្រោយការប្រកាសជាសាធារណៈ ដល់ថ្ងៃមុនការបោះឆ្នោត តាមរយៈប្រព័ន្ធបោះឆ្នោតតាមលិខិតឆ្លើយឆ្លង ។

## ៧. ការបោះឆ្នោតនៅមហាសមុទ្រ ( មាត្រា ៤៩)

ការបោះឆ្នោតនៅមហាសមុទ្រ អនុញ្ញាតអោយក្រុមនាវិកដែលបើកនៅក្នុងលំហសមុទ្រ អាចធ្វើការបោះឆ្នោតតាមទូរសារ ។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងនៅក្នុងវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត នៅខែមេសា ឆ្នាំ១៩៩៩ ដែលមានគោលបំណងដោះស្រាយការលំបាកនៃការប្រគល់សន្លឹកឆ្នោតរបស់ក្រុមនាវិកមកកាន់មាតុប្រទេស តាមប្រព័ន្ធបោះឆ្នោតជាមុន ឬប្រព័ន្ធបោះឆ្នោតតាមលិខិតឆ្លើយឆ្លងដែលមានស្រាប់ ។ ការបោះឆ្នោតនៅមហាសមុទ្រ អាចមាននៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា និងអាចមានសម្រាប់ក្រុមនាវិកដែលកំពុងធ្វើដំណើរលើមហាសមុទ្រ ដែលរំពឹងថានឹងធ្វើអាជីវកម្មរបស់ខ្លួននៅថ្ងៃបោះឆ្នោត ។

## ៨. ការបោះឆ្នោតនៅទ្វីបអង់តាក់ទិក ( មាត្រា ៤៩)

ការបោះឆ្នោតនៅទ្វីបអង់តាក់ទិក អនុញ្ញាតអោយសមាជិកស្ថាប័នដែលធ្វើការអង្កេតវិទ្យាសាស្ត្ររបស់ប្រទេសជប៉ុន នៅជុំវិញតំបន់អង់តាក់ទិក ធ្វើការបោះឆ្នោតតាមទូរសារ ។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើង នៅក្នុងវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតនៅខែមិថុនា ឆ្នាំ២០០៦ ដែលមានគោលបំណងដោះស្រាយការលំបាកនៃការប្រគល់សន្លឹកឆ្នោតរបស់សមាជិកទាំងនោះមកកាន់មាតុប្រទេស តាមប្រព័ន្ធបោះឆ្នោតជាមុន ឬប្រព័ន្ធបោះឆ្នោតតាមលិខិតឆ្លើយឆ្លងដែលមានស្រាប់ ។ ការបោះឆ្នោតនៅទ្វីបអង់តាក់ទិកត្រូវបានអនុវត្តចំពោះការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា ហើយអាចប្រើបានសម្រាប់សមាជិករបស់គណបក្សដែលធ្វើការអង្កេតនៅទ្វីបអង់តាក់ទិកនៅស្ថាប័ននៃប្រទេសជប៉ុន ដែលត្រូវបានប្រើសម្រាប់កិច្ចការអង្កេតវិទ្យាសាស្ត្រពាក់ព័ន្ធ ឬនៅលើនាវាដែលធ្វើការទំនាក់ទំនងជាមួយគណបក្សអង្កេតពាក់ព័ន្ធ នៅចន្លោះពីថ្ងៃក្រោយការប្រកាសជាសាធារណៈ ដល់ថ្ងៃមុនការបោះឆ្នោត ។

## ៩. ការបោះឆ្នោតនៅបរទេស ( មាត្រា ៤៩-២)

អ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅបរទេស អាចចូលរួមក្នុងការបោះឆ្នោតថ្នាក់ជាតិបាន ។ ពលរដ្ឋជប៉ុនដែលបានរស់នៅក្រោមយុត្តាធិការនៃស្ថានកុងស៊ុលជាក់លាក់ណាមួយ អស់រយៈពេលយ៉ាងហោចណាស់បីខែជាប់ៗគ្នា អាចដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីនេះ ( មាត្រា ៣០-៤) ។

(១) ការបោះឆ្នោតនៅស្ថាប័នការទូតនៅបរទេស

អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅបរទេស អាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយដែលត្រួតពិនិត្យដោយប្រធានស្ថាប័នការទូតនៅបរទេស ។ តាមរយៈក្រសួងការបរទេស សន្លឹកឆ្នោតត្រូវបានប្រគល់ដល់មណ្ឌលបោះឆ្នោតចាត់តាំងនៃក្រុងដែលអ្នកបោះឆ្នោតបានចុះឈ្មោះ ។

(២) ការបោះឆ្នោតតាមប្រៃសណីយ៍

អ្នកបោះឆ្នោតនៅបរទេស ដែលមានការលំបាកក្នុងការបោះឆ្នោតនៅស្ថាប័នការទូត អាចបោះឆ្នោតតាមប្រៃសណីយ៍បាន ។ ពួកគេអាចយកសន្លឹកឆ្នោតពីក្រុង ដែលពួកគេបានចុះឈ្មោះ ហើយផ្ញើសន្លឹកឆ្នោតនេះទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុងវិញ ។

(៣) ការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងស្រុក

អ្នកបោះឆ្នោតនៅបរទេសដែលត្រឡប់មកប្រទេសជប៉ុនវិញមួយរយៈពេលខ្លី ក្នុងរយៈពេលបោះឆ្នោត ឬដែលមិនបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ក្រោយពេលត្រឡប់មកប្រទេសជប៉ុនវិញ អាចបោះឆ្នោតតាមការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ការបោះឆ្នោតជាមុន ឬការបោះឆ្នោតតាមលិខិតឆ្លើយឆ្លង នៅក្នុងប្រទេសជប៉ុន ។

## ១០. ការបោះឆ្នោតតាមកុំព្យូទ័រ

ដោយពិចារណាអំពីការអភិវឌ្ឍសង្គមព័ត៌មានវិទ្យា ប្រព័ន្ធបោះឆ្នោតតាមកុំព្យូទ័រត្រូវបានបង្កើតឡើងដោយច្បាប់លើកលែងនៃច្បាប់ស្តីពីការបោះឆ្នោត នៅខែធ្នូ ឆ្នាំ២០០១ ។ ប្រព័ន្ធនេះ អនុញ្ញាតអោយអ្នកបោះឆ្នោតប្រើប្រាស់ការបោះឆ្នោតអេឡិចត្រូម៉ាញេទិច ដែលកត់ត្រាព័ត៌មាននៅក្នុងការដាក់សន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសរើសអាជ្ញាធរមូលដ្ឋាន ក្រោមដីកាមូលដ្ឋាន ។ ការបោះឆ្នោតតាមកុំព្យូទ័រអាចមាននៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកសភា និងប្រធានអាជ្ញាធរមូលដ្ឋាន ។ លទ្ធផល ដូចជា ការរាប់សន្លឹកឆ្នោតបានឆាប់រហ័ស និងកាត់បន្ថយសន្លឹកឆ្នោតមិនបានការត្រូវបានរំពឹងថាអាចទទួលបាន តាមរយៈប្រព័ន្ធនេះ ។ ការបោះឆ្នោតតាមអេឡិចត្រូម៉ាញេទិចដែលកត់ត្រាព័ត៌មាននៅក្នុងប្រព័ន្ធនេះ គឺជាការបោះឆ្នោតតែមួយដែលអាចកត់ត្រាថាតើបេក្ខជនណាមួយដែលខ្លួនបោះឆ្នោតអោយ ។ បន្ថែមលើនេះ ដើម្បីធានាភាពត្រឹមត្រូវនៃការបោះឆ្នោត ព័ត៌មានត្រូវតែស្របតាមលក្ខខណ្ឌតម្រូវ ដូចជាព័ត៌មានដែលអ្នកបោះឆ្នោតមិនអាចបោះឆ្នោតលើសពី ២ សន្លឹក ដែលការបោះឆ្នោតសម្ងាត់មិនត្រូវបានបោកបញ្ឆោត និងដែលទិន្នន័យការបោះឆ្នោតដែលបានកត់ត្រាទុក នៅក្នុងការបោះឆ្នោតតាមអេឡិចត្រូម៉ាញេទិច ដែលកត់ត្រាជាមធ្យមត្រូវបានការពារ ។

# ជំពូកទី ១១ ~ ការរាប់សន្លឹកឆ្នោត និងការកំណត់បុគ្គលជាប់ឆ្នោត

## ១. ការរាប់សន្លឹកឆ្នោត

អ្នកត្រួតពិនិត្យមើលការរាប់សន្លឹកឆ្នោត ត្រូវបានតែងតាំង សម្រាប់ការបោះឆ្នោតនីមួយៗ ដើម្បីគ្រប់គ្រងការរាប់សន្លឹកឆ្នោត ។ ការរាប់សន្លឹកឆ្នោតត្រូវបានធ្វើឡើងជាមួយអ្នកសង្កេតការណ៍ដែលមានវត្តមាន ។ តាមធម្មតា មណ្ឌលរាប់សន្លឹកឆ្នោតមានចំនួនស្មើនឹងតំបន់នៃក្រុងមួយ ( មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោត) ។

អ្នកត្រួតពិនិត្យមើលការរាប់សន្លឹកឆ្នោត ត្រូវរាយការណ៍ទៅប្រធានអង្គប្រជុំរៀបចំការបោះឆ្នោត អំពីចំនួនសន្លឹកឆ្នោតដែលបេក្ខជននីមួយៗទទួលបាន និងអំពីលទ្ធផលផ្សេងទៀតនៃការបោះឆ្នោត នៅពេលការរាប់សន្លឹកឆ្នោតបានបញ្ចប់ ( មាត្រា ៦៦) ។

## ២. ការកំណត់បុគ្គលជាប់ឆ្នោត

ប្រធានអង្គប្រជុំរៀបចំការបោះឆ្នោត រៀបចំកិច្ចប្រជុំរៀបចំការបោះឆ្នោត ដើម្បីកំណត់បុគ្គលជាប់ឆ្នោត ដោយផ្អែកលើលទ្ធផលនៃការរាប់សន្លឹកឆ្នោត ។ វិធីសាស្ត្រនៃការកំណត់ ខុសគ្នាពីប្រព័ន្ធមណ្ឌលបោះឆ្នោត និងប្រព័ន្ធសមាមាត្រ ។

(១) ប្រព័ន្ធមណ្ឌលបោះឆ្នោត ( មាត្រា ៩៥)

នៅក្នុងមណ្ឌលបោះឆ្នោតឯកត្តនាម (ការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ ក្រោមប្រព័ន្ធឯកត្តនាម ការបោះឆ្នោតជ្រើសរើសប្រធានអាជ្ញាធរមូលដ្ឋាន ។ល។) បេក្ខជនណាមួយដែលទទួលបានចំនួនសន្លឹកឆ្នោតច្រើនបំផុត ត្រូវបានប្រកាសថាជាអ្នកឈ្នះ ផ្ទុយទៅវិញ នៅក្នុងប្រព័ន្ធពហុនាម អ្នកឈ្នះត្រូវបានកំណត់ទៅតាមលំដាប់នៃចំនួនសន្លឹកឆ្នោតដែលពួកគេទទួលបាន ។ ទោះជាយ៉ាងណាក៏ដោយ មុនពេលត្រូវបានជាប់ឆ្នោតជាផ្លូវការ បេក្ខជនចាំបាច់ត្រូវទទួលបានសន្លឹកឆ្នោតច្រើនជាងចំនួនអប្បបរមាស្របច្បាប់ដែលចាំបាច់ ។

### ចំនួនសន្លឹកឆ្នោតអប្បបរមាស្របច្បាប់ដែលត្រូវមាន

| ប្រភេទនៃការបោះឆ្នោត | ការគណនា |
|---|---|
| ជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ ( ប្រព័ន្ធឯកត្តនាម) | ចំនួនសន្លឹកឆ្នោតបានការសរុប × $\frac{១}{៦}$ |
| ជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា ( ប្រព័ន្ធមណ្ឌល បោះឆ្នោតមូលដ្ឋាន) | $\frac{\text{ចំនួនសន្លឹកឆ្នោតបានការសរុប}}{\text{ចំនួនសមាជិកដែលត្រូវជាប់ឆ្នោតនៅក្នុងការបោះឆ្នោតសាមញ្ញ នៅក្នុងមណ្ឌលបោះឆ្នោត}}$ × $\frac{១}{៦}$ |

| | |
|---|---|
| | (នៅពេលដែលចំនួនសមាជិកដែលត្រូវជាប់ឆ្នោតនៅក្នុង មណ្ឌលបោះឆ្នោត នៅក្នុងការបោះឆ្នោតដែលពាក់ព័ន្ធ មានចំនួនច្រើនជាងចំនួនសមាជិកដែលត្រូវជាប់ឆ្នោត នៅក្នុងការបោះឆ្នោតសមញ្ញ ចំនួនមុននៅរក្សាទុកដដែល) |
| ជ្រើសរើសសមាជិកសភាអាជ្ញាធរមូលដ្ឋាន | $\frac{\text{ចំនួនសន្លឹកឆ្នោតបានការសរុប}}{\text{ចំនួនសមាជិកដែលត្រូវជាប់ឆ្នោត នៅក្នុងមណ្ឌលបោះឆ្នោត}} \times \frac{១}{៤}$<br>(ប្រសិនបើគ្មានមណ្ឌលបោះឆ្នោតទេ ត្រូវយកចំនួនសមាជិកសរុបដែលត្រូវជ្រើសរើស) |
| ប្រធានអាជ្ញាធរមូលដ្ឋាន | ចំនួនសន្លឹកឆ្នោតបានការសរុប $\times \frac{១}{៤}$ |

ប្រសិនបើមានបេក្ខជនច្រើនជាងមួយរូបទទួលបានចំនួនសន្លឹកឆ្នោតស្មើគ្នា សម្រាប់អាសនៈចុងក្រោយ ប្រធានអង្គប្រជុំរៀបចំការបោះឆ្នោត មានសិទ្ធិកំណត់អ្នកឈ្នះតាមរយៈការចាប់ឆ្នោត ។

(២) ប្រព័ន្ធសមាមាត្រ (មាត្រា ៩៥-៣)

ក្រោមប្រព័ន្ធនេះ អាសនៈត្រូវបានបែងចែកដល់គណបក្សនយោបាយ តាមសមាមាត្រនៃចំនួនសន្លឹកឆ្នោត សម្រាប់គណបក្សនីមួយៗ (ក្នុងករណីសភាតំណាងរាស្ត្រ នៅក្នុងមណ្ឌលបោះឆ្នោតភូមិភាគ ក្នុងករណីសភាក្រុមប្រឹក្សា នៅទូទាំងប្រទេស) ។ មធ្យោបាយបែងចែកគឺ រូបមន្ត Hondt ដែលកំណត់ពីការបែងចែកដល់គណបក្សនីមួយៗ ស្របតាមផលចែកដែលទទួលបានពីការចែកចំនួនសន្លឹកឆ្នោតដែលគេបោះអោយគណបក្សនីមួយៗនឹងចំនួនគត់ដាច់ខាត ។ ឧទាហរណ៍ ដើម្បីពិពណ៌នាករណីជាក់លាក់នៃគណបក្សបី (ក, ខ និង គ) នៅក្នុងការបែងចែកតាមភូមិភាគនូវអាសនៈចំនួន ១០ ការបែងចែកសម្រាប់គណបក្សទាំងបី មានដូចខាងក្រោម :

| សន្លឹកឆ្នោតដែលបានបោះ | គណបក្ស ក | គណបក្ស ខ | គណបក្ស គ |
|---|---|---|---|
| | ២៧០.០០០ | ៣៥៤.០០០ | ១៤០.០០០ |
| ចែក នឹង១ | ២) ២៧០.០០០ | ១) ៣៥៤.០០០ | ៤) ១៤០.០០០ |
| នឹង២ | ៥) ១៣៥.០០០ | ៣) ១៧៧.០០០ | ១០) ៧០.០០០ |
| នឹង៣ | ៧) ៩០.០០០ | ៦) ១១៨.០០០ | ៤៦.៦៦៧ |
| នឹង៤ | ៦៧.៥០០ | ៨) ៨៨.៥០០ | ៣៥.០០០ |
| នឹង៥ | ៥៤.០០០ | ៩) ៧០.៨០០ | ២៨.០០០ |
| នឹង៦ | ៤៥.០០០ | ៥៩.០០០ | ២៣.៣៣៣ |
| ការបែងចែក | ៣ អាសនៈ | ៥ អាសនៈ | ២ អាសនៈ |

អាសនៈដែលឈ្នះដោយគណបក្សជាក់លាក់ណាមួយ ត្រូវបានប្រគល់ដល់បេក្ខជនរបស់គណបក្សនោះ តាមលំដាប់លេខរៀងនៅក្នុងបញ្ជី ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីការបោះឆ្នោតសភាក្រុមប្រឹក្សា ក្រោមប្រព័ន្ធសមាមាត្រ អ្នកឈ្នះត្រូវបានកំណត់ តាមលំដាប់ចំនួនសន្លឹកឆ្នោតដែលពួកគេបានទទួល ដោយផ្អែក

លើបញ្ជីឈ្មោះបេក្ខជននៃសភា ដោយសារវាគឺជាប្រព័ន្ធសមាមាត្របញ្ជីបើក ។ ប្រសិនបើមានមុខតំណែងទំនេរកើតឡើង អ្នកមានឈ្មោះនៅបន្ទាប់ក្នុងបញ្ជី ត្រូវទទួលបានអាសនៈ ។

នៅក្នុងករណីការបោះឆ្នោតសភាតំណាងរាស្ត្រ ប្រសិនបើអនុញ្ញាតអោយមានបេក្ខភាពឌុប បេក្ខជនជាប់ឆ្នោតនៅក្នុងប្រព័ន្ធឯកត្តនាម ត្រូវលុបចេញពីបញ្ជីតំណាងសមាមាត្រ ។ ដើម្បីកំណត់បេក្ខជនដាក់បេក្ខភាពឌុបដែលជាប់ឆ្នោត គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត ត្រូវតែជូនដំណឹងអំពីលទ្ធផលចុងក្រោយនៃការបោះឆ្នោតតាមប្រព័ន្ធឯកត្តនាមដល់ក្រុមប្រឹក្សាគ្រប់គ្រងការបោះឆ្នោតកណ្តាល នៅពេលដែលការបោះឆ្នោតក្នុងប្រព័ន្ធទាំងពីរ ត្រូវរៀបចំឡើងដំណាលគ្នា (មាត្រា ១០១) ។

(៣) ប្រព័ន្ធសមាមាត្របញ្ជីបើក (មាត្រា ៩៥-៣)

ប្រព័ន្ធនេះត្រូវបានប្រើនៅក្នុងការបោះឆ្នោតជ្រើសរើសអាសនៈចំនួន ៩៦ នៃអាសនៈសរុបចំនួន ២៤២ នៃសភាក្រុមប្រឹក្សា ។ នៅក្នុងប្រព័ន្ធនេះ អ្នកបោះឆ្នោតអាចសរសេរឈ្មោះរបស់បេក្ខជន ឬឈ្មោះរបស់គណបក្ស ។ ដូចប្រព័ន្ធសមាមាត្រដែរ អាសនៈត្រូវបានបែងចែកដល់គណបក្សនយោបាយ តាមសមាមាត្រនឹងចំនួនសន្លឹកឆ្នោតសម្រាប់គណបក្សនីមួយៗតាមរូបមន្ត Hondt ។ ប៉ុន្តែ នៅក្នុងប្រព័ន្ធបញ្ជីបើកនេះ បុគ្គលជាប់ឆ្នោតត្រូវបានកំណត់តាមលំដាប់ចំនួនសន្លឹកឆ្នោតនៅក្នុងគណបក្សនីមួយៗ ។ ឧទាហរណ៍ ករណីដែលរៀបរាប់ខាងក្រោមគឺជាការប្រគល់អាសនៈចំនួន ៥ ដល់គណបក្សចំនួន ២ (គណបក្ស ក និងគណបក្ស ខ) ហើយចំនួនសន្លឹកឆ្នោតសរុបរបស់គណបក្ស ក គឺ ៤.០០០.០០០ ចំណែក ចំនួនសន្លឹកឆ្នោតសរុបរបស់គណបក្ស ខ គឺ ៣.០០០.០០០ ។

| គណបក្ស ក (សន្លឹកឆ្នោតសរុប : ៤.០០០.០០០) | | | |
|---|---|---|---|
| បានទទួល/ មិនបានទទួល | លេខរៀង | ឈ្មោះ | ចំនួនសន្លឹកឆ្នោត |
| បានទទួល | ១ | គ | ១.២០០.០០០ |
| បានទទួល | ២ | ឃ | ១.០០០.០០០ |
| បានទទួល | ៣ | ង | ៨០០.០០០ |
| មិនបានទទួល | ៤ | ច | ៦០០.០០០ |
| សន្លឹកឆ្នោតសម្រាប់គណបក្ស | | | ៤០០.០០០ |

| គណបក្ស ខ (សន្លឹកឆ្នោតសរុប : ៣.០០០.០០០) | | | |
|---|---|---|---|
| បានទទួល/ មិនបានទទួល | លេខរៀង | ឈ្មោះ | ចំនួនសន្លឹកឆ្នោត |
| បានទទួល | ១ | ឆ | ៩០០.០០០ |
| បានទទួល | ២ | ជ | ៧០០.០០០ |
| មិនបានទទួល | ៣ | ឈ | ៥០០.០០០ |
| មិនបានទទួល | ៤ | ញ | ៣០០.០០០ |
| សន្លឹកឆ្នោតសម្រាប់គណបក្ស | | | ៦០០.០០០ |

ឧបមាថា យើងអាចបែងចែក ៣ អាសនៈដល់គណបក្ស ក និង ២ អាសនៈដល់គណបក្ស ខ ដោយប្រើរូបមន្ត Hondt បេក្ខជនត្រូវបានរៀបតាមលំដាប់ចំនួនសន្លឹកឆ្នោតនៅក្នុងគណបក្សនីមួយៗ ។ មានន័យថា នៅក្នុងករណីគណបក្ស ក លំដាប់នេះ គឺ គ, ឃ, ង, ច ហើយបុគ្គលជាប់ឆ្នោតត្រូវបានកំណត់តាមលំដាប់នោះ ។

បន្ថែមពីលើនេះ នៅក្នុងការបោះឆ្នោតជ្រើសរើសមាជិកសភាក្រុមប្រឹក្សា បេក្ខភាពឌុបមិនត្រូវបានអនុញ្ញាតឡើយ ។

# ជំពូកទី ១២ ~ យុទ្ធនាការឃោសនាបោះឆ្នោត

ទោះបីជាមានការដាក់កំហិតផ្សេងៗលើយុទ្ធនាការឃោសនាបោះឆ្នោត ក្នុងគោលបំណងធានាអោយមានការបោះឆ្នោតដោយយុត្តិធម៌ និងស្មើភាពក៏ដោយ យុទ្ធនាការឃោសនាបោះឆ្នោតប្រភេទខ្លះ ត្រូវបានគ្រប់គ្រង ឬឧបត្ថម្ភជាសាធារណៈ សម្រាប់ហេតុផលដូចគ្នា ។ ពេលនេះ យើងនឹងពិនិត្យមើលចំណុចលម្អិតនៃប្រព័ន្ធនេះ ។

ដូចប្រព័ន្ធផ្សេងទៀតដែលបានពន្យល់រួចហើយ មានភាពខុសគ្នាមួយចំនួនរវាងការធ្វើយុទ្ធនាការតាមប្រព័ន្ធមណ្ឌលបោះឆ្នោត និងតាមប្រព័ន្ធសមាមាត្រ ។ តាមប្រព័ន្ធសមាមាត្រ ពោលគឺតួអង្គសំខាន់នៃយុទ្ធនាការឃោសនា គឺគណបក្សនយោបាយ ។ ហើយយើងត្រូវបន្ថែមថា នៅក្នុងបរិបទនៃយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សនយោបាយដែលដាក់បេក្ខជនតាមមណ្ឌលឯកត្តនាមសម្រាប់ការបោះឆ្នោតសភាតំណាងរាស្ត្រ តែងតែធ្វើសកម្មភាពជាតួអង្គសំខាន់ ។ នៅទីនេះ យើងប្រើពាក្យ "គណបក្សនយោបាយ" ដើម្បីសំដៅគណបក្សខាងលើ ។

## ១. ការដាក់កំហិតពាក់ព័ន្ធនឹងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោត

ជាគោលការណ៍ ការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតត្រូវបានអនុញ្ញាតតែសម្រាប់រយៈពេលចាប់ពីថ្ងៃជូនដំណឹងអំពីបេក្ខភាព ដល់ថ្ងៃមុនថ្ងៃបោះឆ្នោតប៉ុណ្ណោះ (មាត្រា ១២៩ នៃច្បាប់ស្តីពីការបោះឆ្នោត) ។ រយៈពេលនេះខុសៗគ្នាទៅតាមប្រភេទនៃការបោះឆ្នោត (មាត្រា ៣១ ដល់មាត្រា ៣៤) ប៉ុន្តែគ្មានយុទ្ធនាការឃោសនាបោះឆ្នោតណាត្រូវបានអនុញ្ញាតអោយធ្វើមុនការជូនដំណឹងអំពីបេក្ខភាពឡើយ ។

**រយៈពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត**

| ប្រភេទនៃការបោះឆ្នោត | រយៈពេល |
|---|---|
| ជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា និងអភិបាលខេត្ត | ១៧ ថ្ងៃ |
| ជ្រើសរើសអភិបាលក្រុងចាត់តាំង | ១៤ ថ្ងៃ |
| ជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ | ១២ ថ្ងៃ |
| ជ្រើសរើសសមាជិកសភាខេត្ត និងសភាក្រុងចាត់តាំង | ៩ ថ្ងៃ |
| ជ្រើសរើសសមាជិកសភា និងអភិបាល (ក្រុង) | ៧ ថ្ងៃ |
| ជ្រើសរើសសមាជិកសភា និងប្រធាន (ឃុំ/ភូមិ) | ៥ ថ្ងៃ |

## ២. ការដាក់កំហិតលើយុទ្ធនាការឃោសនាបោះឆ្នោតពាក់ព័ន្ធនឹងបុគ្គលិកដែលទាក់ទងនឹងការបោះឆ្នោត

ដើម្បីធានាអោយមានការបោះឆ្នោតដោយយុត្តិធម៌ និងស្មើភាព បុគ្គលិកសេវាសាធារណៈមួយចំនួន ព្រមទាំងប្រជាជនក្នុងប្រភេទផ្សេងទៀត ត្រូវបានហាមឃាត់មិនអោយចូលរួមនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតដូចខាងក្រោម :

(១) បុគ្គលិកថ្នាក់ដឹកនាំដែលទទួលខុសត្រូវរៀបចំការបោះឆ្នោត

អ្នកត្រួតពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ព្រមទាំងប្រធានអង្គប្រជុំរៀបចំការបោះឆ្នោត ឬប្រធានអនុអង្គប្រជុំរៀបចំការបោះឆ្នោត មិនត្រូវបានអនុញ្ញាតអោយដឹកនាំយុទ្ធនាការឃោសនាបោះឆ្នោត នៅក្នុងតំបន់ដែលខ្លួនបំពេញមុខតំណែងនោះឡើយ ( មាត្រា ១៣៥ ) ។

(២) បុគ្គលិកសេវាសាធារណៈជាក់លាក់

បុគ្គលិកសេវាសាធារណៈដែលបានរៀបរាប់ខាងក្រោម ត្រូវបានហាមឃាត់មិនអោយដឹកនាំយុទ្ធនាការឃោសនាបោះឆ្នោត ក្នុងកំឡុងអាណត្តិរបស់ខ្លួនក្នុងមុខតំណែងនោះ ( មាត្រា ១៣៦ ) :

- សមាជិកគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតថ្នាក់កណ្តាល មន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងតមនាគមន៍ដែលចូលរួមក្នុងការងារពាក់ព័ន្ធនឹងគណៈកម្មាធិការខាងលើ សមាជិកគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោត និងបុគ្គលិកលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ
- ចៅក្រម
- ព្រះរាជអាជ្ញា
- សវនករ
- សមាជិកគណៈកម្មាធិការសុវត្ថិភាពសាធារណៈ
- មន្ត្រីនគរបាល
- មន្ត្រីប្រមូលពន្ធដារនៃរដ្ឋាភិបាលជាតិ/មូលដ្ឋាន

(៣) បុគ្គលិករាជការផ្សេងទៀត

មន្ត្រីរដ្ឋាភិបាលជាតិ/មូលដ្ឋាន និងមន្ត្រីនៃក្រុមហ៊ុនរដ្ឋជាក់លាក់ផ្សេងទៀត មិនអាចចូលរួមនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ដោយប្រើមុខតំណែងបច្ចុប្បន្នរបស់ខ្លួនបានឡើយ ( មាត្រា ១៣៦-២ ) ។ ក្រោមច្បាប់ស្តីពីបុគ្គលិកសេវាសាធារណៈជាតិ សកម្មភាពនយោបាយស្ទើរតែត្រូវបានហាមឃាត់ទាំងស្រុងចំពោះបុគ្គលិករដ្ឋាភិបាលជាតិទាំងអស់ ( មាត្រា ១០២ នៃច្បាប់នេះ ) ចំណែកឯនៅក្នុងករណីបុគ្គលិករដ្ឋាភិបាលមូលដ្ឋាន យុទ្ធនាការប្រភេទខ្លះ ត្រូវបានអនុញ្ញាតតែនៅក្រៅតំបន់រដ្ឋបាលដែលពាក់ព័ន្ធ ( មាត្រា ៣៦ នៃច្បាប់ស្តីពីបុគ្គលិកសេវាសាធារណៈមូលដ្ឋាន ) ។

(៤) ប្រភេទផ្សេងទៀត

ការដាក់កំហិតក៏ត្រូវធ្វើឡើងចំពោះអ្នកអប់រំ អនីតិជន ( បុគ្គលអាយុក្រោម ២០ ឆ្នាំ ) និងអ្នកទាំងឡាយណាដែលសិទ្ធិបោះឆ្នោតត្រូវបានព្យួរដោយសារបទល្មើសលើការបោះឆ្នោត ឬការរំលោភច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយផងដែរ ( មាត្រា ១៣៧ ដល់ មាត្រា ១៣៧-៣ នៃច្បាប់ស្តីពីការបោះឆ្នោត ) ។

## ៣. ការនិយាយជាសាធារណៈនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត

ការនិយាយជាសាធារណៈ គឺជាវិធីសាស្ត្រមូលដ្ឋានបំផុតមួយ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ប៉ុន្តែមានការដាក់កំហិតផ្សេងៗក្រោមច្បាប់ស្តីពីការបោះឆ្នោត ។

(១) ការថ្លែងសុន្ទរកថាដោយបេក្ខជននីមួយៗ ឬគណបក្ស

បេក្ខជននីមួយៗអាចថ្លែងសុន្ទរកថានៅតាមទីសាធារណៈមួយចំនួន (សាលារៀន សាលាក្រុង ។ល។) (មាត្រា ១៦១) ។ ការធ្វើបែបនេះ គឺមិនមានគិតប្រាក់អ្វីឡើយ នៅទីសាធារណៈនីមួយៗ (មាត្រា ១៦៤) ។

មិនត្រឹមតែសុន្ទរកថារបស់បេក្ខជននីមួយៗប៉ុណ្ណោះទេ វេទិកាដែលរៀបចំឡើងដោយគណបក្សនយោបាយនានាដែលដាក់បេក្ខជននៅក្នុងការបោះឆ្នោត ក៏ត្រូវបានអនុញ្ញាតអោយធ្វើឡើងនៅក្នុងទីសាធារណៈណាមួយដូចដែលបានរៀបរាប់នៅលើផងដែរ (មាត្រា ១៦១) ។

គ្មានការថ្លែងសុន្ទរកថាណាមួយសម្រាប់យុទ្ធនាការឃោសនា ត្រូវបានអនុញ្ញាតសម្រាប់ការបោះឆ្នោតសភាក្រុមប្រឹក្សា តាមប្រព័ន្ធសមាមាត្រឡើយ ។

(២) ការប្រមូលផ្តុំគ្នានៅតាមផ្លូវ

ការប្រមូលផ្តុំគ្នាដែលរៀបចំឡើងដោយបេក្ខជន ឬដោយគណបក្សរបស់ពួកគេ ត្រូវបានអនុញ្ញាតតែចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ៨:០០ ល្ងាចប៉ុណ្ណោះ ។ មានដែនកំណត់មួយចំនួន ដូចជាចំនួនបុគ្គលិកធ្វើយុទ្ធនាការត្រូវមានកំណត់ ហើយពួកគេត្រូវពាក់ប៉ាន់ដៃ នៅពេលដែលបេក្ខជនរៀបចំការប្រមូលផ្តុំគ្នា ។ (មាត្រា ១៦៤-៥ ដល់ មាត្រា ១៦៤-៧) ។

(៣) ការផ្សព្វផ្សាយ

នៅក្នុងការបោះឆ្នោតថ្នាក់ជាតិ ព្រមទាំងនៅក្នុងការបោះឆ្នោតជ្រើសរើសអភិបាលខេត្តអាចប្រើប្រាស់ប្រព័ន្ធសម្រាប់ការធ្វើយុទ្ធនាការតាមវិទ្យុ និង/ឬទូរទស្សន៍បាន ។ ការផ្សព្វផ្សាយខ្លះអាចត្រូវបានចាត់ថ្នាក់ជាពីរប្រភេទ : ការបញ្ចេញមតិនយោបាយ និងការបង្ហាញសេចក្តីសង្ខេបអំពីអាជីពរបស់បេក្ខជន ។

- ការបញ្ចេញមតិនយោបាយ : បេក្ខជន (ក្នុងករណីបោះឆ្នោតជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា តាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន និងបោះឆ្នោតជ្រើសរើសអភិបាលខេត្ត) ឬគណបក្សនយោបាយ (ចំពោះការបោះឆ្នោតប្រភេទផ្សេងទៀត) អាចបញ្ចេញទស្សនៈនយោបាយដោយមិនគិតថ្លៃ តាមវិទ្យុ និងទូរទស្សន៍ ដោយប្រើប្រាស់បរិក្ខាររបស់ NHK (សមាគមផ្សព្វផ្សាយរបស់ប្រទេសជប៉ុន) ឬស្ថានីយផ្សព្វផ្សាយឯកជនផ្សេងៗ ។ ក្នុងករណីការផ្សព្វផ្សាយធ្វើឡើងដោយគណបក្សនយោបាយ គណបក្សទាំងនេះក៏អាចណែនាំបេក្ខជនរបស់ខ្លួន តាមរយៈវិទ្យុ និងទូរទស្សន៍ផងដែរ (មាត្រា ១៥០) ។
- ការបង្ហាញសេចក្តីសង្ខេបអំពីអាជីពរបស់បេក្ខជន : ស្ថានីយផ្សព្វផ្សាយ ត្រូវបានតម្រូវអោយជួយដល់បេក្ខជន (លើកលែងបេក្ខជននៅក្នុងការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រ) ដោយផ្សព្វផ្សាយឈ្មោះ អាយុ ប្រវត្តិរូប និងព័ត៌មានផ្សេងទៀតរបស់ពួកគេ តាមវិទ្យុ និងទូរទស្សន៍ (មាត្រា ១៥១) ។

(៤) សុន្ទរកថាចន្លោះឈុត បទសម្ភាសន៍ផ្ទាល់ខ្លួន ការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតតាមទូរស័ព្ទ និងការស្រែកពាក្យស្លោកម្តងហើយម្តងទៀត

គ្មានការដាក់កំហិតលើការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ដោយការនិយាយទៅកាន់អ្នកស្តាប់ក្នុងកំឡុងពេលចន្លោះឈុតនៅរោងភាពយន្ត និងមហោស្រព ពេលជួបជុំមិត្តភក្តិ និងការជួបជុំផ្សេងទៀតនៅតាមដងវិថី ឬការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតដោយប្រើទូរស័ព្ទឡើយ ។

ការស្រែកពាក្យស្លោកម្តងហើយម្តងទៀត ការនិយាយចេញនូវឃ្លាជាក់លាក់មួយចំនួនម្តងហើយម្តងទៀតនៅក្នុងរយៈពេលខ្លី ត្រូវបានហាមឃាត់ (មាត្រា ១៤០-២) លើកលែងតែត្រូវបានធ្វើឡើងនៅទីកន្លែងដែលត្រូវបានចាត់តាំងអោយធ្វើដូច្នោះ ឬត្រូវបានធ្វើឡើងតាមរយៈរថយន្តធ្វើយុទ្ធនាការចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៨:០០ ល្ងាច ប៉ុណ្ណោះ ។

## ៤. យុទ្ធនាការឃោសនាបោះឆ្នោតដោយប្រើខិត្តប័ណ្ណ និងរូបភាពយុទ្ធនាការ

ការប្រើប័ណ្ណប្រកាស បរិយាយប័ណ្ណ និងប័ណ្ណប្រៃសណីយ៍ គឺជាវិធីសាស្ត្រមូលដ្ឋានបំផុត សម្រាប់ការធ្វើយុទ្ធនាការ ។ ដើម្បីរក្សាអោយនូវភាពត្រឹមត្រូវ ការដាក់កំហិតតឹងរ៉ឹងត្រូវបានធ្វើឡើងចំពោះការប្រើប្រាស់វិធីសាស្ត្រទាំងនេះ ។ មធ្យោបាយផ្សេងពីអ្វីដែលចែងដោយច្បាប់ស្តីពីការបោះឆ្នោត ត្រូវបានហាមឃាត់តាមផ្លូវច្បាប់មិនអោយប្រើនៅក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ។

(១) ការដាក់កំហិតលើការចែកខិត្តប័ណ្ណយុទ្ធនាការ

ការចែកខិត្តប័ណ្ណយុទ្ធនាការមិនត្រូវបានអនុញ្ញាតឡើយ លើកលែងចំពោះប័ណ្ណប្រៃសណីយ៍ និងបរិយាយប័ណ្ណស្តង់ដារក្នុងទំហំដែលបានកំណត់ ដូចមានរៀបរាប់នៅក្នុងតារាងខាងក្រោមប៉ុណ្ណោះ (មាត្រា ១៤២) ។ គណបក្សទាំងឡាយដែលដាក់បេក្ខជននៅក្នុងការបោះឆ្នោតសភាតំណាងរាស្ត្រ ក្រោមប្រព័ន្ធសមាមាត្រ ត្រូវបានអនុញ្ញាតអោយប្រើតែបរិយាប័ណ្ណពីរប្រភេទប៉ុណ្ណោះ ។ គណបក្សទាំងឡាយដែលដាក់បេក្ខជននៅក្នុងការបោះឆ្នោតសភាតំណាងរាស្ត្រក្រោមប្រព័ន្ធឯកត្តនាម ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ប័ណ្ណប្រៃសណីយ៍ និងបរិយាប័ណ្ណស្តង់ដារ ។

ជំនួសអោយការអនុវត្តដូចពោលខាងលើ ក្នុងករណីការបោះឆ្នោតទូទៅសម្រាប់សភាតំណាងរាស្ត្រ និងការបោះឆ្នោតសាមញ្ញនៃសភាក្រុមប្រឹក្សា គណបក្សនានាត្រូវបានអនុញ្ញាតអោយប្រើសៀវភៅស្តើង ។ល។ ដែលសរសេរអំពីគោលនយោបាយសំខាន់ៗទាក់ទងនឹងរដ្ឋបាលថ្នាក់ជាតិ សម្រាប់ការធ្វើយុទ្ធនាការ (មាត្រា ១៤២-២) ។

បេក្ខជននីមួយៗត្រូវបានអនុញ្ញាតអោយប្រើបរិយាយប័ណ្ណ តែនៅក្នុងករណីបោះឆ្នោតសភាទាំងពីរថ្នាក់ និងការបោះឆ្នោតជ្រើសរើសនាយកប្រតិបត្តិអង្គភាពមូលដ្ឋានប៉ុណ្ណោះ ។ ប័ណ្ណប្រៃសណីយ៍ដែលបេក្ខជននីមួយៗត្រូវបានអនុញ្ញាតអោយប្រើ អាចមកយកបានដោយឥតគិតថ្លៃ ។

## ចំនួនប័ណ្ណប្រៃសណីយ៍ និងបរិយាយប័ណ្ណដែលត្រូវចែក

| ប្រភេទនៃការបោះឆ្នោត | ចំនួនប័ណ្ណប្រៃសណីយ៍ដែលអនុញ្ញាត | ចំនួនបរិយាយប័ណ្ណដែលអនុញ្ញាត |
|---|---|---|
| ការបោះឆ្នោតសភាតំណាងរាស្ត្រ : | | |
| មណ្ឌលបោះឆ្នោតឯកត្តនាម | | |
| - បេក្ខជន | ៣៥.០០០ | ៧០.០០០ (រហូតដល់ ២ ប្រភេទ) |
| - គណបក្សនយោបាយ | ២០.០០០ × M សម្រាប់ខេត្តសាមីនីមួយៗ | ៤០.០០០ × M សម្រាប់ខេត្តសាមីនីមួយៗ (មិនច្រើនជាង ៤០.០០០ សម្រាប់មណ្ឌលបោះឆ្នោតសាមីនីមួយៗ) |
| តំណាងសមាមាត្រ | | |
| - គណបក្សនយោបាយ | ត្រូវបានហាមឃាត់ | មិនកំណត់ចំនួន នៅក្នុងមណ្ឌលបោះឆ្នោតសាមី (រហូតដល់ ២ ប្រភេទ) |
| ការបោះឆ្នោតសភាក្រុមប្រឹក្សា : | | |
| មណ្ឌលបោះឆ្នោត | ៣៥.០០០ + ២.៥០០ × (N-១) | ១០០.០០០ + ១៥.០០០ × (N-១) (អតិបរមា ៣០០.០០០ រហូតដល់ ២ ប្រភេទ) |
| តំណាងសមាមាត្រ | ១៥០.០០០ | ២៥០.០០០ (រហូតដល់ ២ ប្រភេទ) |
| អភិបាលខេត្ត | ៣៥.០០០ + ២.៥០០ × (N-១) | ១០០.០០០ + ១៥.០០០ × (N-១) (អតិបរមា ៣០០.០០០ រហូតដល់ ២ ប្រភេទ) |
| សមាជិកសភាខេត្ត | ៨.០០០ | ត្រូវបានហាមឃាត់ |
| អភិបាលក្រុងចាត់តាំង | ៣៥.០០០ | ៧០.០០០ (រហូតដល់ ២ ប្រភេទ) |
| សមាជិកសភាក្រុងចាត់តាំង | ៤.០០០ | ត្រូវបានហាមឃាត់ |
| អភិបាលក្រុង | ៨.០០០ | ១៦.០០០ (រហូតដល់ ២ ប្រភេទ) |
| សមាជិកសភាក្រុង | ២.០០០ | ត្រូវបានហាមឃាត់ |
| ប្រធានឃុំ/ភូមិ | ២.៥០០ | ៥.០០០ (រហូតដល់ ២ ប្រភេទ) |
| សមាជិកសភាឃុំ/ភូមិ | ៨០០ | ត្រូវបានហាមឃាត់ |

កំណត់សម្គាល់ :

M = ចំនួនបេក្ខជនសម្រាប់មណ្ឌលបោះឆ្នោតឯកត្តនាម នៅក្នុងខេត្តសាមី ។

N = ចំនួនមណ្ឌលបោះឆ្នោតឯកត្តនាម (ការបោះឆ្នោតសភាតំណាងរាស្ត្រ) នៅក្នុងខេត្តសាមី ។

(២) ការតាំងខិត្តប័ណ្ណ និងរូបភាពយុទ្ធនាការ

ការតាំងខិត្តប័ណ្ណ និងរូបភាពយុទ្ធនាការត្រូវបានហាមឃាត់ ខុសពីប័ណ្ណដែលរាយឈ្មោះដូចខាងក្រោម ។ ក៏មានការដាក់កំហិតលើទំហំ និងចំនួននៃប័ណ្ណផងដែរ ( មាត្រា ១៤៣) ។

១) ប័ណ្ណប្រកាស បដា គោម និងប៉ាណូ ដែលត្រូវបានតាំងបង្ហាញ ដើម្បីប្រាប់អំពីការិយាល័យយុទ្ធនាការឃោសនាបោះឆ្នោត ។

២) ប័ណ្ណប្រកាស បដា គោម និងប៉ាណូដែលត្រូវបានតាំងបង្ហាញ នៅលើយានយន្ត ឬទូក ដែលត្រូវបានប្រើនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ។

៣) ខ្សែឆៀង និងប៉ាន់ដៃ ដែលពាក់ដោយបេក្ខជន ។

៤) ប័ណ្ណប្រកាស បដា គោម និងប៉ាណូ ដែលត្រូវបានប្រើនៅកន្លែងដែលសុន្ទរកថាត្រូវបានថ្លែង ។ នៅក្នុងការបោះឆ្នោតសភាតំណាងរាស្ត្រ ក្រោមប្រព័ន្ធឯកត្តនាម ការបោះឆ្នោតសភាក្រុមប្រឹក្សា ក្រោមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន និងការបោះឆ្នោតជ្រើសរើសអភិបាលខេត្ត បដា ឬប៉ាណូ ត្រូវតែតាំងបង្ហាញនៅខាងក្រៅកន្លែងប្រជុំកម្មវិធីនយោបាយ ហើយគ្មានខិត្តប័ណ្ណ និងរូបភាពផ្សេងទៀតណាមួយអាចត្រូវបានតាំងនៅទីនោះឡើយ ( មាត្រា ១៦៤-២ កថាខ័ណ្ឌ ១ និង ៤) ។

៥) ប័ណ្ណប្រកាសដែលប្រកាសអំពីកិច្ចប្រជុំកម្មវិធីនយោបាយដោយបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់សភាតំណាងរាស្ត្រ ក្រោមប្រព័ន្ធឯកត្តនាម សម្រាប់សភាក្រុមប្រឹក្សា តាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន និងសម្រាប់ការជ្រើសរើសអភិបាលខេត្ត ។

៦) ការប្រើប័ណ្ណប្រកាសនៅក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត តាមមធ្យោបាយផ្សេងៗ ។

គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុងនីមួយៗ នឹងផ្តល់ទីកន្លែងដើម្បីតាំងបង្ហាញប័ណ្ណប្រកាសយុទ្ធនាការដែលមានរៀបរាប់ខាងលើក្នុងចំណុច ៥) និង ៦) សម្រាប់ការបោះឆ្នោតសភាតំណាងរាស្ត្រ តាមប្រព័ន្ធឯកត្តនាម ការបោះឆ្នោតសភាក្រុមប្រឹក្សាតាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន និងការបោះឆ្នោតជ្រើសរើសអភិបាលខេត្ត ។ ការតាំងបង្ហាញប័ណ្ណប្រកាសទាំងនេះ នៅកន្លែងផ្សេងទៀតត្រូវបានហាមឃាត់ ។ ចំណែកការបោះឆ្នោតសភាមូលដ្ឋាន និងការបោះឆ្នោតជ្រើសរើសអភិបាលក្រុង រដ្ឋាភិបាលខេត្ត ឬក្រុងសាមីអាចផ្តល់កន្លែងសម្រាប់តាំងបង្ហាញប័ណ្ណប្រកាសទាំងនេះ ស្របតាមបញ្ញត្តិនៃដីការបស់ខ្លួនផ្ទាល់ ( មាត្រា ១៤៤-២) ។

ប័ណ្ណប្រកាសអាចបង្កើតឡើងដោយឥតគិតថ្លៃ ក្នុងព្រំដែនដែលមានចែងខាងលើ ក្នុងករណីការបោះឆ្នោតបេក្ខជនឯកត្តបុគ្គលសម្រាប់សភាតំណារាស្ត្រ តាមប្រព័ន្ធឯកត្តនាម និងសភាក្រុមប្រឹក្សាតាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន ( ប្រសិនបើមានចែងដោយដីកា ព្រមទាំងក្នុងករណីការបោះឆ្នោតខេត្ត និងក្រុង) ។

(៣) ការឃោសនាតាមសារព័ត៌មាន

បេក្ខជន ឬគណបក្សនយោបាយអាចប្រើការឃោសនាតាមសារព័ត៌មាន ក្នុងកំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត នៅក្នុងដែនកំណត់នៃច្បាប់ស្តីពីការបោះឆ្នោត ។ ការឃោសនានេះអាចធ្វើឡើងដោយមិនគិតថ្លៃ នៅក្នុងព្រំដែនដែលបានកំណត់ ក្នុងករណីការបោះឆ្នោតសភាទាំងពីរថ្នាក់ និងការបោះឆ្នោតជ្រើសរើសអភិបាលខេត្ត ( មាត្រា ១៤៩) ។

(៤) ព្រឹត្តិប័ត្រស្តីពីការបោះឆ្នោត

ព្រឹត្តិប័ត្រផ្លូវការដែលរួមមានឈ្មោះ ទស្សនៈនយោបាយ និងប្រវត្តិរូបរបស់បេក្ខជន ចេញផ្សាយនៅពេលបោះឆ្នោតសភាតំណាងរាស្ត្រ តាមប្រព័ន្ធឯកត្តនាម នៅពេលបោះឆ្នោតសភាក្រុមប្រឹក្សា តាមប្រព័ន្ធមណ្ឌលបោះឆ្នោត និងការបោះឆ្នោតជ្រើសរើសអភិបាលខេត្ត ។ ក្នុងករណីបោះឆ្នោតសភាទាំងពីរថ្នាក់ តាមប្រព័ន្ធសមាមាត្រ ព្រឹត្តិប័ត្រអំពីការបោះឆ្នោតដែលផ្តល់ព័ត៌មានអំពីឈ្មោះរបស់គណបក្សនយោបាយ ទស្សនៈនយោបាយរបស់គណបក្សទាំងនោះ ឈ្មោះរបស់បេក្ខជនដែលបានចុះបញ្ជី រួមជាមួយនឹងប្រវត្តិរូបសង្ខេបរបស់ពួកគេ និងលំដាប់លេខរៀងឈ្មោះដែលបានរំពឹង (របស់បេក្ខជន) ត្រូវបានបោះពុម្ពផ្សាយ (មាត្រា ១៦៧ ដល់ ១៧២-២) ។

ព្រឹត្តិប័ត្រនេះចេញផ្សាយដោយគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោត ហើយនៅក្នុងការបោះឆ្នោតសភាមូលដ្ឋាន ឬការបោះឆ្នោតជ្រើសរើសអភិបាលក្រុង អាចចេញផ្សាយបាន ប្រសិនបើមានចែងដោយដីកា ។

## ៥. ការត្រួតពិនិត្យ និងការដាក់កំហិតផ្សេងទៀតទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត

(១) ការហាមឃាត់ការចុះឃោសនាតាមផ្ទះ (មាត្រា ១៣៨)

មិនត្រឹមតែបេក្ខជន និងអ្នកធ្វើយុទ្ធនាការរបស់ពួកគេប៉ុណ្ណោះទេ អ្នកផ្សេងទៀតក៏ត្រូវបានហាមឃាត់មិនអោយចុះឃោសនាដល់លំនៅដ្ឋាន ការិយាល័យ ឬកន្លែងផ្សេងទៀតរបស់អ្នកបោះឆ្នោត ក្នុងគោលបំណងសុំសន្លឹកឆ្នោតរបស់ពួកគាត់ផងដែរ ។

(២) ការហាមឃាត់យុទ្ធនាការប្រមូលហត្ថលេខា (មាត្រា ១៣៨-២)

ការធ្វើយុទ្ធនាការប្រមូលហត្ថលេខាជាមួយអ្នកបោះឆ្នោត ក្នុងគោលបំណងជះឥទ្ធិពលលើការជ្រើសរើសរបស់ពួកគាត់ នៅក្នុងការបោះឆ្នោត ត្រូវបានហាមឃាត់ ។

(៣) ការហាមឃាត់ការបោះពុម្ពផ្សាយលទ្ធផលស្ទង់មតិអំពីប្រជាប្រិយភាព (មាត្រា ១៣៨-៣)

គ្មានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាតអោយបោះពុម្ពផ្សាយអំពីដំណើរការ ឬលទ្ធផលនៃការស្ទង់មតិអំពីប្រជាប្រិយភាពរបស់បេក្ខជន ដែលអាចនឹងកាន់មុខតំណែងសាធារណៈតាមរយៈការបោះឆ្នោតឡើយ ។

(៤) ការដាក់កំហិតលើការផ្គត់ផ្គង់អាហារ និងភេសជ្ជៈ (មាត្រា ១៣៩)

ពាក់ព័ន្ធនឹងការផ្គត់ផ្គង់អាហារ និងភេសជ្ជៈ អ្នកធ្វើយុទ្ធនាការឃោសនាបោះឆ្នោត និងបុគ្គលិកនៅការិយាល័យបោះឆ្នោត អាចទទួលបានតែតែ និងស្ករគ្រាប់ នៅក្នុងករណីទូទៅ និងបាយប្រអប់ក្នុងចំនួនកំណត់ណាមួយ នៅក្នុងការបោះឆ្នោតផ្សេងពីការបោះឆ្នោតសភាតំណាងរាស្ត្រតាមប្រព័ន្ធសមាមាត្រប៉ុណ្ណោះ ។

(៥) ការហាមឃាត់ការធ្វើក្បួនដង្ហែរជាសាធារណៈ (មាត្រា ១៤០)

ការធ្វើក្បួនដង្ហែរជាសាធារណៈត្រូវបានហាមឃាត់ទាំងស្រុងនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ។

(៦) ការដាក់កំហិតពាក់ព័ន្ធនឹងការប្រើប្រាស់យានយន្ត ទូក និងឧបករណ៍បំពងសម្លេង (មាត្រា ១៤១)

ការដាក់កំហិតដែលធ្វើឡើងចំពោះការប្រើប្រាស់យានយន្ត ទូក និងឧបករណ៍បំពងសម្លេង នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត មានដូចខាងក្រោម ៖

១)　នៅក្នុងការបោះឆ្នោតផ្សេងពីការបោះឆ្នោតសភាតំណាងរាស្ត្រ តាមប្រព័ន្ធសមាមាត្រ យានយន្ត ឬទូកមួយ ឬពីរគ្រឿង និងឧបករណ៍បំពងសម្លេងមួយ ឬពីរឈុត ត្រូវបានអនុញ្ញាតសម្រាប់បេក្ខជននីមួយៗ ។

នៅក្នុងការបោះឆ្នោតសភាតំណាងរាស្ត្រ តាមប្រព័ន្ធឯកត្តនាម និងការបោះឆ្នោតសភាក្រុមប្រឹក្សាតាមប្រព័ន្ធមណ្ឌលបោះឆ្នោត បេក្ខជនអាចប្រើប្រាស់យានយន្តដោយឥតគិតថ្លៃ ។

២)　នៅក្នុងការបោះឆ្នោតសភាតំណាងរាស្ត្រ គណបក្សនយោបាយអាចប្រើមធ្យោបាយទាំងនេះនៅក្នុងចំនួនដែលអនុញ្ញាត ផ្ទុយទៅវិញ នៅក្នុងការបោះឆ្នោតសភាក្រុមប្រឹក្សាតាមប្រព័ន្ធសមាមាត្រ គណបក្សទាំងអស់មិនត្រូវបានអនុញ្ញាតអោយប្រើមធ្យោបាយទាំងនេះឡើយ ។

(៧)　ការដាក់កំហិតពាក់ព័ន្ធនឹងសកម្មភាពឃោសនាក្រោយការបោះឆ្នោត ( មាត្រា ១៧៨)

សកម្មភាពក្រោយបោះឆ្នោតមួយចំនួន ត្រូវបានហាមឃាត់ រួមមាន ការចុះទៅសួរសុខទុក្ខអ្នកបោះឆ្នោតនៅតាមផ្ទះ ការចែកខិត្តប័ណ្ណ និងរូបភាព ការប្រើសារព័ត៌មាន និងទស្សនាវដ្តី និងការរៀបចំពិធីជប់លៀងអបអរសាទរ ។

## ៦.　យុទ្ធនាការឃោសនាបោះឆ្នោតដែលគ្រប់គ្រង និង/ឬឧបត្ថម្ភជាសាធារណៈ

ទោះបីជាមានការដាក់កំហិតផ្សេងៗទៅលើយុទ្ធនាការឃោសនាបោះឆ្នោត ដោយច្បាប់ស្តីពីការបោះឆ្នោតក៏ដោយ ចំនួនទឹកប្រាក់ដ៏ច្រើនដែលចាំបាច់សម្រាប់ការធ្វើយុទ្ធនាការ តែងតែនាំអោយមានអំពើពុករលួយ ។

ទម្រង់ពិសេសមួយនៃប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសជប៉ុន គឺប្រភេទផ្សេងៗនៃការគ្រប់គ្រងសាធារណៈ និងការឧបត្ថម្ភដល់យុទ្ធនាការឃោសនាបោះឆ្នោត ក្នុងកម្រិតទូលំទូលាយ ដើម្បីបង្ការអំពើពុករលួយ និងធានាអោយមានឱកាសស្មើភាពគ្នា ។ ឧទាហរណ៍ នៅក្នុងការបោះឆ្នោតទូទៅសម្រាប់សភាតំណាងរាស្ត្រ ដែលរៀបចំឡើងនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៥ ថវិកាសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតដែលបានគ្រប់គ្រង និង/ឬ ឧបត្ថម្ភជាសាធារណៈ មានចំនួនរហូតដល់ ២៤.៧០៥ លានយេន ។

## ជំពូកទី ១៣ ~ ចំណូល និងចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោត

### ១. ការដាក់កំហិតលើចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត

ដើម្បីលុបបំបាត់វិសមភាពនៅក្នុងយុទ្ធនាការដែលបណ្តាលមកពីកត្តាសេដ្ឋកិច្ច ព្រមទាំងសម្រាលបន្ទុកសេដ្ឋកិច្ចនោះ ចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតត្រូវបានកំណត់ត្រឹមចំនួនជាក់លាក់មួយចំនួន ( មាត្រា ១៩៤) ។ ការកំណត់បុគ្គលដែលជាប់ឆ្នោត ត្រូវទុកជានិរាករណ៍ ប្រសិនបើចំណាយលើយុទ្ធនាការរបស់បុគ្គលនោះបង្ហាញអោយឃើញថាលើសពីព្រំដែនកំណត់ ។

ព្រំដែននៃចំណាយ (ចំណាយលើយុទ្ធនាការដែលស្របច្បាប់) មានបង្ហាញជូននៅក្នុងតារាងខាងក្រោម ។

**ព្រំដែននៃចំណាយ**

| ប្រភេទនៃការបោះឆ្នោត | ចំណាយលើយុទ្ធនាការដែលស្របច្បាប់ សម្រាប់បេក្ខជននីមួយៗ |
|---|---|
| ជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ (បេក្ខជនក្នុងមណ្ឌលបោះឆ្នោតឯកត្តនាម) | ១៥ យេន × N + ១៩.១០០.០០០ យេន |
| ជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា (បេក្ខជនតាមប្រព័ន្ធសមាមាត្រ) | ៥២.០០០.០០០ យេន |
| ជ្រើសរើសសមាជិកសភាក្រុមប្រឹក្សា (បេក្ខជនតាមមណ្ឌលបោះឆ្នោតមូលដ្ឋាន) | (១៣ យេន ឬ ២០ យេន)* × N/M + ២៣.៧០០.០០០ យេន |
| ជ្រើសរើសសមាជិកសភាខេត្ត | ៨៣ យេន × N/M + ៣.៩០០.០០០ យេន |
| ជ្រើសរើសសមាជិកសភាក្រុងចាត់តាំង | ១៤៩ យេន × N/M + ៣.៧០០.០០០ យេន |
| ជ្រើសរើសសមាជិកសភាក្រុង (លើកលែងក្រុងចាត់តាំង) | ៥០១ យេន × N/M + ២.២០០.០០០ យេន |
| ជ្រើសរើសសមាជិកសភាឃុំ/ភូមិ | ១.១២០ យេន × N/M + ៩០០.០០០ យេន |
| ជ្រើសរើសអភិបាលខេត្ត | ៧ យេន × N + ២៤.២០០.០០០ យេន |
| ជ្រើសរើសអភិបាលក្រុងចាត់តាំង | ៧ យេន × N + ១៤.៥០០.០០០ យេន |
| ជ្រើសរើសអភិបាលក្រុង (លើកលែងក្រុងចាត់តាំង) | ៨១ យេន × N + ៣.១០០.០០០ យេន |
| ជ្រើសរើសមេឃុំ/ភូមិ | ១១០ យេន × N + ១.៣០០.០០០ យេន |

កំណត់សម្គាល់ :

* នៅពេលដែលចំនួនអាសនៈនៅក្នុងមណ្ឌលបោះឆ្នោតមូលដ្ឋានមានចំនួន ២ តម្លៃឯកតាគឺ ១៣ យេន ហើយនៅក្នុងករណីផ្សេងទៀត គឺ ២០ យេន

M : ចំនួនសមាជិកដែលត្រូវបោះឆ្នោតជ្រើសរើស នៅក្នុងមណ្ឌលបោះឆ្នោត

N : ចំនួនអ្នកបោះឆ្នោតដែលបានចុះបញ្ជី នៅក្នុងមណ្ឌលបោះឆ្នោត

បញ្ញត្តិខាងលើនេះមិនអនុវត្តចំពោះការបោះឆ្នោតសភាតំណាងរាស្ត្រ តាមប្រព័ន្ធសមាមាត្រឡើយ ។

## ២. គណនេយ្យករយុទ្ធនាការ

បេក្ខជន ឬអ្នកតែងតាំងរបស់ខ្លួន ត្រូវបានតម្រូវអោយតែងតាំងបុគ្គលម្នាក់ដែលត្រូវទទួលខុសត្រូវរៀបចំចំណូល និងចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត (មាត្រា ១៨០) ។ ចំណាយណាមួយដែលចាំបាច់សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ជាគោលការណ៍ត្រូវចាយវាយដោយគណនេយ្យករយុទ្ធនាការនេះ (មាត្រា ១៨៧) ។

គណនេយ្យករយុទ្ធនាការត្រូវរក្សាកំណត់ត្រាចំណូលទាំងអស់ រួមទាំងវិភាគទាន និងចំណាយ ហើយរាយការណ៍អំពីស្ថានភាពចំណូល និងការចាយវាយផ្សេងៗដល់គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតសាមី តាមកាលបរិច្ឆេទជាក់លាក់ណាមួយ ( មាត្រា ១៨៩) ។ សេចក្តីសង្ខេបនៃរបាយការណ៍នេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ ( មាត្រា ១៩២) ។

## ៣. ការដាក់កំហិតលើវិភាគទាន

ការដាក់កំហិតផ្សេងៗត្រូវបានធ្វើឡើងទៅលើវិភាគទាន ដែលពាក់ព័ន្ធនឹងការបោះឆ្នោត ឬសកម្មភាពនយោបាយផ្សេងទៀត ដើម្បីធានាអោយបាននូវប្រព័ន្ធបោះឆ្នោតត្រឹមត្រូវ និងការគ្រប់គ្រងដោយយុត្តិធម៌ ។

(១) ការហាមឃាត់ការធ្វើវិភាគទាន ដោយបុគ្គលណាដែលទាក់ទងយ៉ាងជិតស្និទ្ធនឹងអាជ្ញាធរជាតិ ឬមូលដ្ឋាន

វិភាគទានទាក់ទងនឹងការបោះឆ្នោត ឬសកម្មភាពនយោបាយផ្សេងទៀត ដោយបុគ្គលខាងក្រោម ។ល។ ត្រូវបានហាមឃាត់ :

ក) បុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយអាជ្ញាធរជាតិ ឬមូលដ្ឋានពាក់ព័ន្ធនឹងកិច្ចសន្យា ឬបញ្ហាផ្សេងទៀត ( មានតែវិភាគទានដែលត្រូវបានធ្វើឡើងទាក់ទងនឹងការបោះឆ្នោតប៉ុណ្ណោះ ត្រូវបានហាមឃាត់ ។) ( មាត្រា ១៩៩ កថាខ័ណ្ឌ ១)

ខ) ក្រុមហ៊ុន និងសាជីវកម្មដែលទទួលបានឧបត្ថម្ភធនពីអាជ្ញាធរជាតិ ឬមូលដ្ឋាន ( មាត្រា ២២-៣ កថាខ័ណ្ឌ ១ និង ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយ)

គ) ក្រុមហ៊ុន និងសាជីវកម្មដែលទទួលបានមូលទុន ឬវិភាគទានពីអាជ្ញាធរជាតិ ឬមូលដ្ឋាន ( មាត្រា ២២-៣ កថាខ័ណ្ឌ ២ និង ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយ)

ឃ) ក្រុមហ៊ុន និងសាជីវកម្មដែលត្រូវបានផ្តល់ផ្គង់កម្ចី ដែលអ្នកផ្តល់កម្ចីនោះ បានទទួលឧបត្ថម្ភធនសម្រាប់ការទូទាត់ការប្រាក់ ទាក់ទងនឹងកម្ចីពីអាជ្ញាធរជាតិ ឬមូលដ្ឋាន ( មាត្រា ១៩៩ កថាខ័ណ្ឌ ២ នៃច្បាប់ស្តីពីការបោះឆ្នោត)

(២) ការហាមឃាត់ការធ្វើវិភាគទានដោយបេក្ខជន

បេក្ខជន ឬបុគ្គលណាមួយដែលត្រៀមឈរឈ្មោះបោះឆ្នោត ត្រូវបានហាមឃាត់មិនអោយផ្តល់វិភាគទានដល់បុគ្គល ឬអង្គការណាមួយ នៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួន ។ ដូចគ្នាដែរ វិភាគទានក្នុងឈ្មោះរបស់បេក្ខជន ឬបុគ្គលណាមួយដែលត្រៀមឈរឈ្មោះបោះឆ្នោត ត្រូវបានហាមឃាត់ ( មាត្រា ១៩៩-២) ។

(៣) ការដាក់កំហិតលើវិភាគទានផ្សេងទៀត

វិភាគទានដែលផ្តល់ដល់បុគ្គល ឬក្រុមហ៊ុនណាមួយ នៅក្នុងមណ្ឌលបោះឆ្នោតរបស់បេក្ខជន ឬបុគ្គលណាមួយដែលត្រៀមឈរឈ្មោះបោះឆ្នោត ដោយក្រុមហ៊ុន ឬសាជីវកម្មផ្សេងទៀត ដែលបុគ្គលនោះ គឺជាមន្ត្រីប្រតិបត្តិ ឬដោយអង្គការដែលគាំទ្របុគ្គលនោះ ត្រូវបានហាមឃាត់ ឬដាក់កំហិត ( មាត្រា ១៩៩-៣ និងមាត្រា ១៩៩-៥) ។

(៤) ការហាមឃាត់ការទទួលយកវិភាគទានពីជនបរទេស

ការទទួលយកវិភាគទានទាក់ទងនឹងការបោះឆ្នោត ឬសកម្មភាពនយោបាយផ្សេងទៀត ពីជនបរទេស សាជីវកម្មបរទេស ឬអង្គការបរទេសណាមួយ មិនត្រូវបានអនុញ្ញាតឡើយ (មាត្រា ២២-៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយ) ។

(៥) ការហាមឃាត់លើវិភាគទានអនាមិក

ហាមផ្តល់ ឬទទួលវិភាគទានអនាមិក ទាក់ទងនឹងការបោះឆ្នោត ឬសកម្មភាពនយោបាយផ្សេងទៀត (មាត្រា ២២-៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយ) ។

# ជំពូកទី ១៤ ~ បណ្តឹង

បណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតត្រូវចាត់ថ្នាក់ជាពីរប្រភេទ : បណ្តឹងដែលពាក់ព័ន្ធនឹងសុពលភាពនៃការបោះឆ្នោត និងបណ្តឹងដែលពាក់ព័ន្ធនឹងការកំណត់បុគ្គលដែលជាប់ឆ្នោត ។

## ១. បណ្តឹងពាក់ព័ន្ធនឹងសុពលភាពនៃការបោះឆ្នោត

កម្មវត្ថុនៃបណ្តឹងប្រភេទនេះ គឺសុពលភាពនៃការបោះឆ្នោតទាំងមូល ឬមួយផ្នែក ។ ដើមបណ្តឹងគឺ បេក្ខជន ឬអ្នកបោះឆ្នោត ។

(១) បណ្តឹងនៅកម្រិតក្រុង ( មាត្រា ២០២)

នៅពេលមានភាពមិនច្បាស់លាស់ទាក់ទងនឹងសុពលភាពនៃការបោះឆ្នោត ដែលរៀបចំឡើងនៅក្នុងក្រុងណាមួយ បណ្តឹងជំទាស់ត្រូវតែដាក់ទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតក្រុង ដោយអ្នកបោះឆ្នោត ឬបេក្ខជនសាមី ។ ពាក្យសុំពិនិត្យមើល អាចធ្វើទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត ប្រសិនបើដើមបណ្តឹងមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការក្រុង ។ ប្រសិនបើមិនពេញចិត្តនឹងលទ្ធផលនៃការពិនិត្យមើល បណ្តឹងអាចដាក់ទៅតុលាការកំពូល ។

(២) បណ្តឹងនៅកម្រិតខេត្ត ( មាត្រា ២០៣)

បេក្ខជន ឬអ្នកបោះឆ្នោតអាចដាក់បណ្តឹងជំទាស់ទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត ហើយបន្ទាប់មកដាក់បណ្តឹងទៅតុលាការកំពូល ប្រសិនបើមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការខេត្ត ។

(៣) បណ្តឹងនៅកម្រិតជាតិ ( មាត្រា ២០៤)

បេក្ខជន (រួមទាំងគណបក្សនយោបាយដែលដាក់បេក្ខជនរបស់ខ្លួន នៅក្នុងករណីបោះឆ្នោតសភាតំណាងរាស្ត្រតាមប្រព័ន្ធឯកត្តនាម ក្នុងករណីបោះឆ្នោតសភាតំណាងរាស្ត្រតាមប្រព័ន្ធសមាមាត្រ គណបក្សនយោបាយដែលដាក់បញ្ជីបេក្ខជនរបស់ខ្លួនក្នុងសភា ។ល។ ជំនួសអោយបេក្ខជន នៅក្នុងករណីបោះឆ្នោតសភាក្រុមប្រឹក្សា តាមប្រព័ន្ធសមាមាត្រ គណបក្សនយោបាយដែលដាក់បញ្ជីបេក្ខជនរបស់ខ្លួនក្នុងសភា ។ល។ ឬបេក្ខជននៅក្នុងបញ្ជី) ឬអ្នកបោះឆ្នោតដែលមានការជំទាស់ពាក់ព័ន្ធនឹងសុពលភាពនៃការបោះឆ្នោត អាចដាក់បណ្តឹងដោយផ្ទាល់ទៅតុលាការកំពូល ។

## ២. បណ្តឹងពាក់ព័ន្ធនឹងការកំណត់បុគ្គលដែលជាប់ឆ្នោត

នៅក្នុងបណ្តឹងទាំងនេះ សុពលភាពនៃការកំណត់បុគ្គលដែលជាប់ឆ្នោតគឺជាបញ្ហាមួយ ដែលផ្អែកតាមការសន្មតដែលថា ការបោះឆ្នោតត្រូវបានអនុវត្តដោយស្របច្បាប់ ។

ចំពោះការបោះឆ្នោតថ្នាក់មូលដ្ឋាន ដូចនៅក្នុងករណីបណ្តឹងពាក់ព័ន្ធនឹងសុពលភាពនៃការបោះឆ្នោត បេក្ខជន ឬអ្នកបោះឆ្នោតអាចធ្វើបណ្តឹងជំទាស់ ដាក់ពាក្យសុំពិនិត្យមើល និងដាក់បណ្តឹងទៅតុលាការកំពូល ( មាត្រា ២០៧) ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបោះឆ្នោតសភាទាំងពីរថ្នាក់ ដើមបណ្តឹង ឬដើមចោទត្រូវបានកម្រិតត្រឹមបេក្ខជនដែលមិនជាប់ឆ្នោត គណបក្សនយោបាយដែលដាក់បេក្ខជន គណបក្សនយោបាយដែលដាក់បញ្ជីបេក្ខជន ។ល។ (លើកលែងបេក្ខជនសម្រាប់សភាក្រុមប្រឹក្សា តាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន) ( មាត្រា ២០៨) ។

# ជំពូកទី ១៥ ~ បទល្មើសក្នុងការបោះឆ្នោត

នៅក្នុងប្រទេសជប៉ុន បទល្មើសក្នុងការបោះឆ្នោតត្រូវបានបែងចែកជាពីរប្រភេទ : បទល្មើសព្រហ្មទណ្ឌ និងបទល្មើសរដ្ឋបាល ។ បទល្មើសព្រហ្មទណ្ឌ មានលក្ខណៈអសីលធម៌ (ហៅថាបទល្មើស "ធម្មជាតិ") និងរួមមានអំពើពុករលួយ ការក្លែងបន្លំ ។ល។ បទល្មើសរដ្ឋបាល គឺជាបទល្មើសដែលរំលោភការដាក់កំហិតផ្នែករដ្ឋបាលផ្សេងៗ ដែលចែងទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត ដូចជា ការចែកចាយ ឬការដាក់តាំងបង្ហាញឯកសារនានា ។

## ១. និន្នាការនៃបទល្មើសបោះឆ្នោត

និន្នាការនាពេលថ្មីៗនេះ នៅក្នុងបទល្មើសបោះឆ្នោត ដូចមានភស្តុតាង នៅក្នុងការបោះឆ្នោតចុងក្រោយបំផុតនៃសភាតំណាងរាស្ត្រ (ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៥) មានដូចខាងក្រោម :

### បទល្មើសបោះឆ្នោតដែលបានប្រព្រឹត្តក្នុងកំឡុងពេលបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ

(រៀបចំឡើងនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៥)

| ប្រភេទនៃបទល្មើស | ចំនួនករណី | ចំនួនបុគ្គលដែលបានចាប់ខ្លួន |
|---|---|---|
| • អំពើពុករលួយ ការយកប្រាក់ចំណេញ | ១៤៦ | ៤២២ |
| • ការរំលោភលើសេរីភាពបោះឆ្នោត | ៣៤ | ៣២ |
| • ការឃោសនាតាមផ្ទះ | ១៤ | ២៥ |
| • ការរំលោភលើឯកសារ | ១៨ | ៤៣ |
| • ផ្សេងៗ | ៤៦ | ៥៣ |
| សរុប | ២៥៨ | ៥៧៥ |

## ២. ទណ្ឌកម្មចំពោះបទល្មើសបោះឆ្នោត

បន្ថែមពីលើទណ្ឌកម្មដែលចែងដាច់ដោយឡែកនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសមុខតំណែងសាធារណៈ ទណ្ឌកម្មបន្ថែមដែលត្រូវអនុវត្តចំពោះបទល្មើសបោះឆ្នោតមានដូចខាងក្រោម :

(១) ការធ្វើនិរាករណ៍លទ្ធផលបោះឆ្នោតរបស់បេក្ខជន និងការដកហូតសិទ្ធិបោះឆ្នោតដោយសារបទល្មើសបោះឆ្នោតប្រព្រឹត្តដោយបេក្ខជន (មាត្រា ២៥១ និងមាត្រា ២៥២)

ជាគោលការណ៍ លទ្ធផលបោះឆ្នោតរបស់បេក្ខជនត្រូវបានធ្វើអោយអសុពលភាព នៅពេលបុគ្គលដែលជាប់ឆ្នោតត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសបោះឆ្នោត ទាក់ទងនឹងការបោះឆ្នោត ដែលតាមរយៈការបោះឆ្នោតនោះបុគ្គលនោះបានជាប់ឆ្នោត ហើយត្រូវបានកាត់ទោស ។

ជាធម្មតា ជនល្មើសអាចត្រូវបានដកហូតលក្ខណៈសម្បត្តិដើម្បីបោះឆ្នោត និងដាក់បេក្ខភាពនាពេលអនាគត សម្រាប់រយៈពេលជាក់លាក់ណាមួយ ។

(២) ការធ្វើនិរាករណ៍ដោយសារបទល្មើសបោះឆ្នោត ដែលប្រព្រឹត្តដោយមន្ត្រីរាជការ ឬបុគ្គលដទៃទៀត (មាត្រា ២៥១-៤)

លទ្ធផលបោះឆ្នោតរបស់បុគ្គលដែលបានកាន់មុខតំណែងសាធារណៈ (ដោយមិនគិតភាពខុសគ្នារវាងកម្រិតជាតិ កម្រិតមូលដ្ឋាន ទីភ្នាក់ងាររដ្ឋបាលជាតិដែលបង្កើតឡើងជាក់លាក់ ទីភ្នាក់ងាររដ្ឋបាលមូលដ្ឋាន ដែលបង្កើតឡើងជាក់លាក់ ប្រៃសណីយ៍ជប៉ុន ឬសាជីវកម្មហិរញ្ញវត្ថុ) និងដែលជាប់ឆ្នោតនៅក្នុងការបោះឆ្នោតសភាណាមួយ ដែលរៀបចំឡើងក្នុងរយៈពេលបីឆ្នាំក្រោយការចូលនិវត្តរបស់គាត់ តាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋានដែលគាត់ឈរឈ្មោះជាបេក្ខជនជាលើកទីមួយ ក្រោយការចូលនិវត្តរបស់គាត់ ក្លាយជាអសុពលភាព នៅពេលបុគ្គលដទៃដែលចូលបម្រើសេវាតែមួយដូចគ្នានឹងគាត់ ហើយដែលបានទទួលសេចក្តីណែនាំ ឬសំណើពីគាត់ទាក់ទងនឹងការបោះឆ្នោត បានប្រព្រឹត្តបទល្មើសបោះឆ្នោត ដូចជា អំពើពុករលួយ ការយកប្រាក់ចំណេញ ។ល។ និងត្រូវទទួលការកាត់ទោស ។ល។

(៣) ទណ្ឌកម្មរួមគ្នា ដោយសារបទល្មើសបោះឆ្នោតដែលប្រព្រឹត្តដោយអគ្គនាយកយុទ្ធនាការឃោសនាបោះឆ្នោត គណនេយ្យករយុទ្ធនាការ នាយកយុទ្ធនាការមូលដ្ឋាន សាច់ញាតិ ឬលេខាធិការរបស់បេក្ខជន (មាត្រា ២៥១-២)

នៅពេលអគ្គនាយកយុទ្ធនាការឃោសនាបោះឆ្នោត គណនេយ្យករយុទ្ធនាការ នាយកយុទ្ធនាការមូលដ្ឋាន សាច់ញាតិ ឬលេខាធិការរបស់បេក្ខជនប្រព្រឹត្តបទល្មើសបោះឆ្នោត ដូចជា អំពើពុករលួយ ការយកប្រាក់ចំណេញ ។ល។ ឬរំលោភច្បាប់ទាក់ទងនឹងមូលនិធិបោះឆ្នោត (ក្នុងករណីគណនេយ្យករយុទ្ធនាការ) ហើយត្រូវបានកាត់ទោស លទ្ធផលបោះឆ្នោតរបស់បេក្ខជននោះក្លាយជាអសុពលភាព ហើយលក្ខណៈសម្បត្តិរបស់គាត់សម្រាប់ដាក់បេក្ខភាពត្រូវបានព្យួរ សម្រាប់រយៈពេលជាក់លាក់ណាមួយ ។

(៤) ទណ្ឌកម្មរួមគ្នាដោយសារបទល្មើសបោះឆ្នោត ដែលប្រព្រឹត្តដោយនាយក/អ្នកគ្រប់គ្រងយុទ្ធនាការឃោសនាបោះឆ្នោតរៀបជាបណ្តាញ (មាត្រា ២៥១-៣)

នៅពេលនាយក/អ្នកគ្រប់គ្រងយុទ្ធនាការឃោសនាបោះឆ្នោតរៀបជាបណ្តាញ ប្រព្រឹត្តបទល្មើសបោះឆ្នោត ដូចជា អំពើពុករលួយ ការយកប្រាក់ចំណេញ ។ល។ ហើយត្រូវបានកាត់ទោស លទ្ធផលបោះឆ្នោតរបស់បេក្ខជនក្លាយជាអសុពលភាព ហើយលក្ខណៈសម្បត្តិឈរឈ្មោះបោះឆ្នោតរបស់គាត់ត្រូវបានព្យួរ សម្រាប់រយៈពេលជាក់លាក់ណាមួយ ។

# ជំពូកទី ១៦ ~ បទបញ្ញត្តិស្តីពីការផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពនយោបាយ

ដោយសារគណបក្សនយោបាយ និងអង្គការនានា ស្វះស្វែងដើម្បីចូលរួមអោយកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត នៅក្នុងប្រព័ន្ធអំណាចនយោបាយ គណបក្សនយោបាយ និងអង្គការទាំងនោះត្រូវធ្វើសកម្មភាពនយោបាយប្រភេទផ្សេងៗដើម្បីអភិវឌ្ឍឋានៈប្រកបដោយឥទ្ធិពលបន្ថែមទៀតនៅក្នុងរចនាសម្ព័ន្ធ ។ ការធ្វើដូច្នេះ ធ្វើអោយមានការស្វែងរកថវិកា ដើម្បីផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពនយោបាយរបស់ខ្លួន ។ អ្នកនយោបាយក៏ចាំបាច់ត្រូវធ្វើយុទ្ធនាការនយោបាយ និងឃោសនាបោះឆ្នោតទាក់ទងនឹងការបោះឆ្នោតរបស់ខ្លួនផងដែរ ហើយដោយហេតុនេះ ពួកគេទំនងជាបង្កអោយមានសង្គ្រាមស្វែងរកមូលនិធិដ៏ក្តៅគគុក ដែលអាចឈានទៅដល់ការប្រព្រឹត្តមិនត្រឹមត្រូវក្នុងករណីខ្លះ ។

ដើម្បីបង្ការអំពើពុករលួយនយោបាយ និងរក្សាភាពយុត្តិធម៌នៅក្នុងសកម្មភាពនយោបាយ "ច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយ" ចែងអំពីបទបញ្ញាមួយសំណុំស្តីពីការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពនយោបាយ ។

## ១. ការកំណត់និយមន័យរបស់អង្គការនយោបាយ គណបក្សនយោបាយ និងអង្គភាពផ្សេងទៀត

(១) ការកំណត់និយមន័យរបស់អង្គការនយោបាយ (មាត្រា ៣ កថាខ័ណ្ឌ ១ នៃច្បាប់ស្តីពីការគ្រប់គ្រងមូលនិធិនយោបាយ)

យោងតាមច្បាប់នេះ អង្គការនយោបាយត្រូវបានកំណត់និយមន័យដូចខាងក្រោម :

១) ជាអង្គការដែលមានគោលបំណងដើម លើកកម្ពស់ គាំទ្រ ឬជំទាស់ទៅនឹងគោលការណ៍នយោបាយ ឬគោលនយោបាយ

២) ជាអង្គការដែលមានគោលបំណងដើម ផ្តល់អនុសាសន៍ គាំទ្រ ឬជំទាស់ទៅនឹងបេក្ខជនជាក់លាក់ណាមួយ

៣) ជាអង្គការដែលមានសកម្មភាពចម្បងដែលធ្វើឡើងតាមបែបអង្គការ និងជាបន្ត ស្របតាមលក្ខណៈណាមួយក្នុងចំណោមលក្ខណៈទាំងពីរខាងលើ

គណបក្សនយោបាយ អង្គការផ្តល់មូលនិធិនយោបាយ និងអង្គការគ្រប់គ្រងមូលនិធិ (មានពន្យល់តាមក្រោយ) គឺជាប្រភេទផ្សេងៗនៃអង្គការនយោបាយ ។ នៅក្នុងជំពូកនេះ ពាក្យថា "អង្គការនយោបាយ" សំដៅដល់ប្រភេទទាំងអស់នៃអង្គការនយោបាយទាំងនេះ ។

(២) ការកំណត់និយមន័យរបស់គណបក្សនយោបាយ (មាត្រា ៣ កថាខ័ណ្ឌ ២)

គណបក្សនយោបាយត្រូវបានកំណត់និយមន័យដូចខាងក្រោម និងត្រូវបានផ្តល់នូវបុព្វសិទ្ធិមួយចំនួនដែលនឹងរៀបរាប់តាមក្រោយ :

១) ជាអង្គការនយោបាយដែលមានសមាជិកសភាយ៉ាងតិច ៥ រូប

២) ជាអង្គការនយោបាយដែលទទួលបានសន្លឹកឆ្នោតទូទាំងប្រទេសយ៉ាងតិច ២% នៅក្នុងការបោះឆ្នោតមួយនៃការបោះឆ្នោតទាំងប្រាំមួយដូចខាងក្រោម :

- ការបោះឆ្នោតទូទៅលើកចុងក្រោយសម្រាប់សភាតំណាងរាស្ត្រ តាមប្រព័ន្ធឯកត្តនាម

- ការបោះឆ្នោតទូទៅលើកចុងក្រោយសម្រាប់សភាតំណាងរាស្ត្រ តាមប្រព័ន្ធសមាមាត្រ
- ការបោះឆ្នោតទៀងទាត់មួយក្នុងចំណោមការបោះឆ្នោតទៀងទាត់លើកចុងក្រោយចំនួនពីរ សម្រាប់សភាក្រុមប្រឹក្សា តាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន
- ការបោះឆ្នោតទៀងទាត់មួយក្នុងចំណោមការបោះឆ្នោតទៀងទាត់លើកចុងក្រោយចំនួនពីរ សម្រាប់សភាក្រុមប្រឹក្សា តាមប្រព័ន្ធសមាមាត្រ

(៣) អង្គការផ្តល់មូលនិធិនយោបាយ ( មាត្រា ៥)

- គណបក្សនយោបាយអាចចាត់តាំងអង្គការមួយអោយធ្វើជា "អង្គការផ្តល់មូលនិធិនយោបាយ" របស់ខ្លួន ។ អង្គការនេះផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គណបក្សនយោបាយ និងមានបុព្វសិទ្ធិដើម្បីទទួលវិភាគទាននយោបាយ ដែលមានរៀបរាប់តាមក្រោយ ។

(៤) អង្គការគ្រប់គ្រងមូលនិធិ ( មាត្រា ១៩)

អ្នកនយោបាយ បេក្ខជន និងបុគ្គលណាម្នាក់ដែលកំពុងត្រៀមខ្លួនឈរឈ្មោះបោះឆ្នោត អាចចាត់តាំងអង្គការនយោបាយមួយដែលខ្លួនជាតំណាង អោយធ្វើជា "អង្គការគ្រប់គ្រងមូលនិធិ" របស់ខ្លួន ដើម្បីគ្រប់គ្រងមូលនិធិនយោបាយរបស់ខ្លួន ។ អង្គការនេះក៏មានបុព្វសិទ្ធិដើម្បីទទួលវិភាគទាននយោបាយផងដែរ ។

## ២. បទបញ្ញត្តិពីហិរញ្ញវត្ថុរបស់សកម្មភាពនយោបាយ

(១) របាយការណ៍អំពីការបង្កើត ( មាត្រា ៦ និងមាត្រា ៨)

នៅពេលអង្គការនយោបាយមួយត្រូវបានបង្កើតឡើងថ្មី ឬត្រូវបានបង្កើតឡើងផ្សេងពីអង្គការ ( ពោលគឺមិនមែននយោបាយ) ធម្មតាដែលមានស្រាប់ អង្គការនយោបាយនោះត្រូវរាយការណ៍អំពីការបង្កើតរបស់ខ្លួនដល់គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត ឬដល់រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ក្នុងរយៈពេល ៧ ថ្ងៃ ចាប់ពីថ្ងៃបង្កើត ។

របាយការណ៍ទាក់ទងនឹងអង្គការនយោបាយ (លើកលែងគណបក្សនយោបាយ និងអង្គការផ្តល់មូលនិធិនយោបាយ នៅក្នុងកថាខ័ណ្ឌនេះ) ដែលធ្វើសកម្មភាពនយោបាយរបស់ខ្លួននៅក្នុងតំបន់នៃខេត្តណាមួយ ត្រូវដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្តសាមី ។ របាយការណ៍ទាក់ទងនឹងអង្គការនយោបាយដែលធ្វើសកម្មភាពនយោបាយរបស់ខ្លួន ហួសពីតំបន់នៃខេត្តមួយ ឬនៅក្រៅខេត្តនេះ ដែលទីស្នាក់ការធំរបស់ខ្លួនស្ថិតនៅ ត្រូវដាក់ជូនទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ តាមរយៈគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតរបស់ខេត្តដែលទីស្នាក់ការធំរបស់អង្គការនោះស្ថិតនៅ ។ របាយការណ៍ទាក់ទងនឹងអង្គការនយោបាយ និងអង្គការផ្តល់មូលនិធិនយោបាយ ក៏ត្រូវដាក់ជូនទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ តាមរយៈគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្តផងដែរ ។

អង្គការនយោបាយមិនអាចទទួលវិភាគទាននយោបាយ និងធ្វើចំណាយណាមួយសម្រាប់សកម្មភាពនយោបាយរបស់ខ្លួន រួមទាំងយុទ្ធនាការឃោសនាបោះឆ្នោត ដោយមិនដាក់របាយការណ៍នេះឡើយ ។

(២) ការបញ្ចេញអោយដឹងនូវរបាយការណ៍ហិរញ្ញវត្ថុ ( មាត្រា ១២ មាត្រា ២០ និងមាត្រា ២០-២)

អង្គការនយោបាយ ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃសកម្មភាពនយោបាយរបស់ខ្លួន ទៅគណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតខេត្ត ឬទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។ របាយការណ៍នេះត្រូវបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ នៅថ្ងៃទី៣០ ខែកញ្ញា រៀងរាល់ឆ្នាំ នៅក្នុងសៀវភៅកំណត់ត្រាផ្លូវការនៃរដ្ឋាភិបាលជាតិ ឬខេត្ត ។ ក្រោយការបោះពុម្ពផ្សាយ របាយការណ៍នេះនៅតែអាចរកបាន សម្រាប់ការពិនិត្យមើលជាសាធារណៈ សម្រាប់រយៈពេល ៣ ឆ្នាំ ។

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ អង្គការត្រូវកំណត់អំពីប្រភពនៃអ្នកផ្តល់វិភាគទានដែលបានផ្តល់វិភាគទានច្រើនជាង ៥០.០០០ យេន និងអំពីចំនួនវិភាគទានសរុបពីប្រភពនោះ ។ នៅពេលអង្គការបានទទួលច្រើនជាង ២០០.០០០ យេន ពីប្រភពមួយ ជាការទូទាត់ប្រាក់សម្រាប់កម្មវិធីផ្តល់មូលនិធិនយោបាយ* ប្រភព និងចំនួនទឹកប្រាក់សរុប ត្រូវតែកំណត់ ។

* កម្មវិធីផ្តល់មូលនិធិនយោបាយ សំដៅដល់ព្រឹត្តិការណ៍ដែលតម្រូវអោយមានការបង់ប្រាក់ចំពោះការចូលរួម ដែលប្រាក់ចំណូលនឹងត្រូវចំណាយសម្រាប់សកម្មភាពនយោបាយ ។ ជាគោលការណ៍ កម្មវិធីផ្តល់មូលនិធិនយោបាយ ត្រូវរៀបចំឡើងដោយអង្គការនយោបាយ ។

(៣) ការដាក់កំហិតលើវិភាគទាន ( មាត្រា ២០-២ រហូតដល់មាត្រា ២២)

ច្បាប់ស្តីពីការត្រួតពិនិត្យមូលនិធិនយោបាយចែងអំពីដែនកំណត់ផ្នែកបរិមាណ និងគុណភាពលើវិភាគទានទាក់ទងនឹងសកម្មភាពនយោបាយ ។

ដែនកំណត់ផ្នែកបរិមាណមួយ គឺថា ចំនួនសរុបនៃវិភាគទាននយោបាយ ដែលធ្វើឡើងដោយរូបវន្តបុគ្គល ក្រុមហ៊ុន សហជីព ។ល។ (លើកលែងអង្គការនយោបាយ) មិនអាចលើសពីព្រំដែនដែលចែងដោយច្បាប់ ("ដែនកំណត់សរុប") ឡើយ ។ ដែនកំណត់ផ្នែកបរិមាណផ្សេងទៀត ("ដែនកំណត់ឯកត្តបុគ្គល") គឺថា រូបវន្តបុគ្គលត្រូវបានហាមឃាត់មិនអោយផ្តល់វិភាគទានដល់អ្នកទទួលតែមួយ លើសពីព្រំដែនប្រចាំឆ្នាំ ដែលចែងដោយច្បាប់ ។ គេហាមឃាត់មិនអោយក្រុមហ៊ុន សហជីព និងអង្គការផ្សេងទៀត (លើកលែងអង្គការនយោបាយ) ផ្តល់វិភាគទានសម្រាប់សកម្មភាពនយោបាយ លើកលែងគណបក្សនយោបាយ និងអង្គការផ្តល់មូលនិធិនយោបាយ ។ ទោះបីជារូបវន្តបុគ្គលអាចផ្តល់វិភាគទានដល់សកម្មភាពនយោបាយ នៅក្នុងព្រំដែនសរុប និងនៅក្នុងកម្រិត ១.៥ លានយេនក្នុងមួយឆ្នាំដល់អ្នកនយោបាយនីមួយៗក៏ដោយ វិភាគទាននោះមិនត្រូវធ្វើឡើងជាសាច់ប្រាក់ ឬមូលធនប័ត្រឡើយ លើកលែងតែនៅពេលវិភាគទាននោះត្រូវបានធ្វើឡើងដើម្បីយុទ្ធនាការឃោសនាបោះឆ្នោត ។

បទបញ្ញាគុណភាពជាច្រើនទាក់ទងនឹងវិភាគទាននយោបាយ ត្រូវបានចែងនៅក្នុងច្បាប់ ដែលគ្រប់គ្រងវិភាគទានដែលធ្វើឡើងដោយសាជីវកម្ម ដែលទទួលឧបត្ថម្ភកធនពីរដ្ឋាភិបាលជាតិ ឬមូលដ្ឋាន ដោយសាជីវកម្មដែលទទួលរងឱនភាពហិរញ្ញវត្ថុ ឬដោយអនិកជនបរទេស ឬសាជីវកម្មបរទេស និងវិភាគទានដែលធ្វើឡើងជាអនាមិក ឬក្នុងឈ្មោះរបស់បុគ្គល ឬអង្គការផ្សេងៗ ។ល។ (សូមមើលជំពូកទី១៣ កថាខ័ណ្ឌ ៣)

# ដែនកំណត់ផ្នែកបរិមាណលើវិភាគទាននយោបាយប្រចាំឆ្នាំ

<table>
<tr><td colspan="2" rowspan="2">អ្នកផ្តល់វិភាគទាន<br><br>អ្នកទទួលវិភាគទាន</td><td colspan="2">រូបវន្តបុគ្គល</td><td colspan="2">ក្រុមហ៊ុន សហជីព ។ល។</td><td colspan="3">អង្គការនយោបាយ</td></tr>
<tr><td>សរុប</td><td>នីមួយៗ</td><td>សរុប</td><td>នីមួយៗ</td><td>គណបក្សនយោបាយ</td><td>អង្គការផ្តល់មូលនិធិនយោបាយ</td><td></td></tr>
<tr><td colspan="2"></td><td colspan="4"></td><td colspan="3">ដែនកំណត់ផ្នែកបរិមាណ</td></tr>
<tr><td rowspan="3">អង្គការនយោបាយ</td><td>គណបក្សនយោបាយ និងអង្គការផ្តល់មូលនិធិនយោបាយ</td><td>២០ លានយេនក្នុង ១ ឆ្នាំ</td><td>គ្មានដែនកំណត់</td><td>*៧.៥ - ១០០ លានក្នុង ១ ឆ្នាំ</td><td>គ្មានដែនកំណត់</td><td rowspan="4">គ្មានដែនកំណត់</td><td rowspan="3">គ្មានដែនកំណត់</td><td>គ្មានដែនកំណត់</td></tr>
<tr><td>អង្គការគ្រប់គ្រងមូលនិធិ</td><td rowspan="2">១០ លានយេនក្នុង ១ ឆ្នាំ</td><td rowspan="2">១.៥ លានយេនក្នុង ១ ឆ្នាំ</td><td rowspan="3">ហាមឃាត់</td><td rowspan="3">ហាមឃាត់</td><td rowspan="2">៥០ លានយេនក្នុង ១ឆ្នាំ (សម្រាប់អង្គការនយោបាយតែមួយ)</td></tr>
<tr><td>អង្គការនយោបាយផ្សេងទៀត</td></tr>
<tr><td colspan="2">រដ្ឋបុរស</td><td></td><td></td><td></td><td></td></tr>
</table>

កំណត់សម្គាល់ : * ចំនួនខ្ពស់បំផុតអាស្រ័យលើចំនួនទឹកប្រាក់មូលធន ចំនួនសមាជិកសហជីព ។ល។

ទឹកប្រាក់ និងមូលធនប័ត្រ ត្រូវបានហាមឃាត់ លើកលែងតែវិភាគទានត្រូវបានធ្វើឡើងទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត ។

នៅពេលអង្គការផ្តល់មូលនិធិនយោបាយគឺជាអ្នកផ្តល់វិភាគទាន ឬអ្នកទទួលវិភាគទាន វិភាគទានត្រូវកំហិតត្រឹមការផ្ទេរគណនេយ្យ ។

(លើកលែងចំពោះវិភាគទាន ដែលស្មើ ឬតិចជាង ១.០០០ យេន និងវិភាគទានដោយការផ្ទេរអចលនទ្រព្យ ឬកម្ចីរួមទាំងការកំណត់សិទ្ធិលើផ្ទៃដី)

ច្បាប់ស្តីពីឧបត្ថម្ភកធនរដ្ឋាភិបាលសម្រាប់គណបក្សនយោបាយ បានចូលជាធរមាននៅឆ្នាំ១៩៩៥ ដើម្បីបង្កើតប្រព័ន្ធមួយ ដែលក្នុងនោះ រដ្ឋាភិបាលជាតិផ្តល់ឧបត្ថម្ភកធនដល់គណបក្សនយោបាយ ដោយយោងលើសារៈសំខាន់នៃមុខងាររបស់គណបក្សនយោបាយ នៅក្នុងនយោបាយប្រជាធិបតេយ្យអាស្រ័យសភា ។ ច្បាប់នេះ ត្រូវបានបង្កើតឡើងដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍដោយរលូននៃនយោបាយប្រជាធិបតេយ្យ តាមរយៈការលើកកម្ពស់ការអភិវឌ្ឍដោយរលូននៃសកម្មភាពនយោបាយរបស់គណបក្សនយោបាយ និងតាមរយៈការធានាអោយមានសកម្មភាពស្របច្បាប់ និងយុត្តិធម៌របស់គណបក្សទាំងនោះ ( មាត្រា ១ នៃច្បាប់ស្តីពីឧបត្ថម្ភកធនរដ្ឋាភិបាល សម្រាប់គណបក្សនយោបាយ) ។

## ១. គណបក្សនយោបាយដែលមានសិទ្ធិទទួលឧបត្ថម្ភកធនគណបក្សនយោបាយ ( មាត្រា ២)

នៅក្នុងច្បាប់ស្តីពីឧបត្ថម្ភកធនរដ្ឋាភិបាល សម្រាប់គណបក្សនយោបាយ "គណបក្សនយោបាយ" ដែលមានសិទ្ធិទទួលឧបត្ថម្ភកធន ត្រូវបានកំណត់ថាជាអង្គការនយោបាយដូចខាងក្រោម ។

១) ជាអង្គការនយោបាយដែលមានសមាជិកសភាយ៉ាងតិច ៥ រូប

២) ជាអង្គការនយោបាយដែលមានសមាជិកសភាយ៉ាងតិច ១ រូប និងទទួលបានសន្លឹកឆ្នោតទូទាំងប្រទេសយ៉ាងតិច ២% នៅក្នុងការបោះឆ្នោតមួយនៃការបោះឆ្នោតទាំងប្រាំមួយដូចខាងក្រោម :

- ការបោះឆ្នោតទូទៅលើកចុងក្រោយសម្រាប់សភាតំណាងរាស្ត្រ តាមប្រព័ន្ធឯកត្តនាម
- ការបោះឆ្នោតទូទៅលើកចុងក្រោយសម្រាប់សភាតំណាងរាស្ត្រ តាមប្រព័ន្ធសមាមាត្រ
- ការបោះឆ្នោតទ្បេងទាត់មួយក្នុងចំណោមការបោះឆ្នោតទ្បេងទាត់លើកចុងក្រោយចំនួនពីរ សម្រាប់សភាក្រុមប្រឹក្សា តាមប្រព័ន្ធមណ្ឌលបោះឆ្នោតមូលដ្ឋាន
- ការបោះឆ្នោតទ្បេងទាត់មួយក្នុងចំណោមការបោះឆ្នោតទ្បេងទាត់លើកចុងក្រោយចំនួនពីរ សម្រាប់សភាក្រុមប្រឹក្សា តាមប្រព័ន្ធសមាមាត្រ

## ២. ការដាក់របាយការណ៍របស់គណបក្ស (របាយការណ៍ដោយគណបក្សនយោបាយ ដែលមានបំណងទទួលឧបត្ថម្ភកធន) ( មាត្រា ៥ និងមាត្រា ៦)

គណបក្សនយោបាយដែលមានបំណងទទួលឧបត្ថម្ភកធន ត្រូវរាយការណ៍អំពីបញ្ហាដែលរៀបរាប់ខាងលើ ត្រឹម "កាលបរិច្ឆេទមូលដ្ឋាន"* ក្នុងរយៈពេល ១៥ ថ្ងៃ ជារៀងរាល់ឆ្នាំ ទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។ ប្រសិនបើការបោះឆ្នោតទូទៅសម្រាប់សភាតំណាងរាស្ត្រ ឬការបោះឆ្នោតទ្បេងទាត់សម្រាប់សភាក្រុមប្រឹក្សា ត្រូវបានរៀបចំឡើង គណបក្សនយោបាយដែលមានបំណងទទួលឧបត្ថម្ភកធន ត្រូវដាក់របាយការណ៍អំពីបញ្ហាដែលបានរៀបរាប់ខាងលើត្រឹម "កាលបរិច្ឆេទមូលដ្ឋាននៃការបោះឆ្នោត"** ក្នុងរយៈពេល ១៥ ថ្ងៃ ទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

* កាលបរិច្ឆេទមូលដ្ឋាន គឺជាកាលបរិច្ឆេទបន្ទាប់នៃកាលបរិច្ឆេទខាងក្រោម :

១)　ថ្ងៃទី០១ ខែមករា

២)　កាលបរិច្ឆេទមូលដ្ឋាននៃការបោះឆ្នោត នៃការបោះឆ្នោតដែលរៀបចំឡើងនៅក្នុងឆ្នាំមុន

** កាលបរិច្ឆេទមូលដ្ឋាននៃការបោះឆ្នោត គឺជាកាលបរិច្ឆេទបន្ទាប់នៃកាលបរិច្ឆេទខាងក្រោម :

១)　ថ្ងៃក្រោយការបោះឆ្នោតទូទៅ ឬការបោះឆ្នោតទៀងទាត់

២)　ថ្ងៃទីមួយនៃអាណត្តិរបស់សមាជិកសភាដែលជាប់ឆ្នោតថ្មី

**៣.　ចំនួនទឹកប្រាក់ឧបត្ថម្ភកធនសរុប ( មាត្រា ៧)**

ចំនួនទឹកប្រាក់ឧបត្ថម្ភកធនសរុបត្រូវបានកំណត់នៅក្នុងថវិកាប្រចាំឆ្នាំ ដែលផ្អែកលើ ២៥០ យេន គុណនឹងចំនួនប្រជាជន (ចំនួនប្រជាជនដែលកំណត់ដោយជំរឿនជាតិលើកចុងក្រោយបំផុត និងមានបោះពុម្ពផ្សាយនៅក្នុងសៀវភៅកំណត់ត្រាផ្លូវការ) ។

ថវិកាសម្រាប់ឆ្នាំសារពើពន្ធ ២០០៧ មានចំនួន ៣១.៩៤១.៩៩៦ ពាន់យេន (២៥០ យេន × ១២៧.៧៦៧.៩៩៤) ។

**៤.　ការគណនាចំនួនទឹកប្រាក់នៃឧបត្ថម្ភកធនរបស់គណបក្សនយោបាយនីមួយៗ ( មាត្រា ៨ និងមាត្រា ៩)**

ចំនួនទឹកប្រាក់នៃឧបត្ថម្ភកធនរបស់គណបក្សនយោបាយនីមួយៗសម្រាប់មួយឆ្នាំ ត្រូវបានគណនាដោយផ្អែកលើចំនួនសមាជិកសភា និងសន្លឹកឆ្នោតដែលទទួលបានគិតត្រឹមកាលបរិច្ឆេទមូលដ្ឋាន ដូចខាងក្រោម :

<table>
<tr><th colspan="3">ប្រភេទ</th><th colspan="2">ការគណនា</th></tr>
<tr><td colspan="3">ចំនួនទឹកប្រាក់ដែលផ្អែកលើចំនួនសមាជិកសភា<br>(១/២ នៃឧបត្ថម្ភកធនសរុប)</td><td>ចំនួនទឹកប្រាក់ ដែលផ្អែកលើ ចំនួនសមាជិកសភា × (ចំនួនសមាជិកសភាដែលជាសមាជិករបស់គណបក្សនយោបាយ) / (ចំនួនសមាជិកសភា សរុបដែលជាសមាជិកគណបក្សនយោបាយ)</td><td>(១)</td></tr>
<tr><td rowspan="5">ចំនួនទឹកប្រាក់ ដែលផ្អែកលើ ចំនួនសន្លឹកឆ្នោត ដែលទទួលបាន (១/២ នៃឧបត្ថម្ភកធនសរុប)</td><td rowspan="2">ការបោះឆ្នោតទូទៅចុងក្រោយ ដើម្បីជ្រើសរើស សមាជិកសភា តំណាងរាស្ត្រ</td><td>ការបោះឆ្នោតឯកត្តនាម</td><td>(ចំនួនទឹកប្រាក់ផ្អែកលើចំនួនសន្លឹកឆ្នោតដែលទទួលបាន) × $\frac{១}{៤}$ × (ភាគរយនៃសន្លឹកឆ្នោតដែលទទួលបាន)</td><td>ក</td></tr>
<tr><td>ការបោះឆ្នោតសមាមាត្រ</td><td>(ចំនួនទឹកប្រាក់ផ្អែកលើចំនួនសន្លឹកឆ្នោតដែលទទួលបាន) × $\frac{១}{៤}$ × (ភាគរយនៃសន្លឹកឆ្នោតដែលទទួលបាន)</td><td>ខ</td></tr>
<tr><td rowspan="2">ការបោះឆ្នោតទៀងទាត់ចំនួនពីរ ចុងក្រោយដើម្បី ជ្រើសរើសសមាជិក សភាក្រុមប្រឹក្សា</td><td>ការបោះឆ្នោតមណ្ឌលបោះឆ្នោតមូលដ្ឋាន</td><td>(ចំនួនទឹកប្រាក់ផ្អែកលើចំនួនសន្លឹកឆ្នោតដែលទទួលបាន) × $\frac{១}{៤}$ × (ភាគរយជាមធ្យមនៃសន្លឹកឆ្នោតដែលទទួលបាននៅក្នុងការបោះឆ្នោតពីរលើកចុងក្រោយ)</td><td>គ</td></tr>
<tr><td>ការបោះឆ្នោតសមាមាត្រ</td><td>(ចំនួនទឹកប្រាក់ផ្អែកលើចំនួនសន្លឹកឆ្នោតដែលទទួលបាន) × $\frac{១}{៤}$ × (ភាគរយជាមធ្យមនៃសន្លឹកឆ្នោតដែលទទួលបាននៅក្នុងការបោះឆ្នោតពីរលើកចុងក្រោយ)</td><td>ឃ</td></tr>
<tr><td colspan="2">ចំនួនទឹកប្រាក់សរុបផ្អែកលើចំនួនសន្លឹកឆ្នោតដែលទទួលបាន</td><td>ក + ខ + គ + ឃ</td><td>(២)</td></tr>
<tr><td colspan="3">ចំនួនទឹកប្រាក់នៃឧបត្ថម្ភកធនរបស់គណបក្សនយោបាយ</td><td>(១) + (២)</td><td></td></tr>
</table>

ភាគរយនៃសន្លឹកឆ្នោតដែលទទួលបាន = $\frac{\text{ចំនួនសន្លឹកឆ្នោតដែលទទួលបានដោយគណបក្សនយោបាយ}}{\text{ចំនួនសន្លឹកឆ្នោតសរុបដែលទទួលបានដោយគណបក្សនយោបាយ}}$

ប្រសិនបើការបោះឆ្នោតទូទៅ ឬការបោះឆ្នោតទៀងទាត់ត្រូវរៀបចំឡើងនៅក្នុងកំឡុងពេលមួយឆ្នាំ ចំនួនទឹកប្រាក់ឧបត្ថម្ភកធនរបស់គណបក្សនយោបាយនីមួយៗសម្រាប់មួយឆ្នាំ ត្រូវបានគណនាដោយបូកចំនួនទឹកប្រាក់ក្នុងមួយខែតាមរបៀបដូចខាងក្រោម :

[ឧទាហរណ៍] ការបោះឆ្នោតទូទៅ ឬការបោះឆ្នោតទៀងទាត់ ត្រូវបានរៀបចំឡើង ហើយកាលបរិច្ឆេទបោះឆ្នោតជាមូលដ្ឋាន គឺនៅក្នុងខែកក្កដា ។

ចំនួនទឹកប្រាក់ក្នុងមួយខែសម្រាប់រយៈពេលពីខែមករា ដល់ខែកក្កដា = (X)

= ចំនួនទឹកប្រាក់ដែលគណនាគិតត្រឹមកាលបរិច្ឆេទមូលដ្ឋាន × ១/១២

ចំនួនទឹកប្រាក់ក្នុងមួយខែសម្រាប់រយៈពេលពីខែសីហា ដល់ខែធ្នូ = (Y)

= ចំនួនទឹកប្រាក់ដែលគណនាគិតត្រឹមកាលបរិច្ឆេទមូលដ្ឋាននៃការបោះឆ្នោត × ១/១២

ចំនួនទឹកប្រាក់ឧបត្ថម្ភកធនរបស់គណបក្សនយោបាយនីមួយៗសម្រាប់មួយឆ្នាំ = ៧ × (X) + ៥ × (Y)

ប្រសិនបើការបោះឆ្នោតទូទៅ ឬការបោះឆ្នោតទៀងទាត់ រៀបចំឡើងនៅក្នុងឆ្នាំក្រោយកាលបរិច្ឆេទមូលដ្ឋាននៃការបោះឆ្នោត ចំនួនទឹកប្រាក់ឧបត្ថម្ភកធនរបស់គណបក្សនយោបាយនីមួយៗ ត្រូវគណនាតាមរបៀបដូចគ្នានឹងរបៀបដែលបានរៀបរាប់ខាងលើ ។

## ៥. ការផ្តល់ឧបត្ថម្ភកធន (មាត្រា ១១)

ឧបត្ថម្ភកធនសម្រាប់គណបក្សនីមួយៗត្រូវបានផ្តល់ដូចតទៅ : ១/៤ នៃឧបត្ថម្ភកធននៅក្នុងខែមេសា ១/៣ នៃចំនួនទឹកប្រាក់ដែលនៅសល់នៅក្នុងខែកក្កដា ១/២ នៃចំនួនទឹកប្រាក់ដែលនៅសល់នៅក្នុងខែតុលា និងចំនួនទឹកប្រាក់ដែលនៅសល់នៅក្នុងខែធ្នូ ។ ឧបត្ថម្ភកធនត្រូវបានផ្ទេរទៅក្នុងគណនីធនាគាររបស់គណបក្ស ។

## ៦. ការដាក់របាយការណ៍អំពីចំណាយរបស់ឧបត្ថម្ភកធន (មាត្រា ១៧ និងមាត្រា ១៨)

គណនេយ្យករសម្រាប់គណបក្សនយោបាយ ចាំបាច់ត្រូវដាក់របាយការណ៍អំពីចំណាយឧបត្ថម្ភកធនរបស់គណបក្សសម្រាប់ឆ្នាំនោះ ជូនទៅរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។ គណនេយ្យករសម្រាប់សាខាគណបក្សនយោបាយក៏ត្រូវបានតម្រូវអោយដាក់របាយការណ៍អំពីចំណាយឧបត្ថម្ភកធនរបស់សាខានោះទៅគណនេយ្យករ នៅទីស្នាក់ការកណ្តាលរបស់គណបក្ស ឬសាខាដែលបានផ្តល់ដល់សាខានោះនូវឧបត្ថម្ភកធនរបស់គណបក្សនយោបាយ និងដល់គណៈកម្មាធិការគ្រប់គ្រងការបោះឆ្នោតនៃខេត្តដែលទីស្នាក់ការធំរបស់សាខានោះស្ថិតនៅ ។

នៅក្នុងរបាយការណ៍នេះ គណនេយ្យករត្រូវកំណត់អ្នកទទួលប្រាក់ចំនួន ៥០.០០០ យេន ឬច្រើនជាងនេះ ផ្សេងពីថ្លៃចំណាយផ្ទាល់ខ្លួន និងថ្លៃអំពូលភ្លើង កម្តៅ និងទឹក និងបញ្ហាដែលបានរៀបរាប់ផ្សេងទៀត ។

## ៧. ការបោះពុម្ពផ្សាយរបាយការណ៍ចំណាយ (មាត្រា ៣១ និងមាត្រា ៣២)

រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ជូនដំណឹងដល់សាធារណជនអំពីសេចក្តីសង្ខេបនៃរបាយការណ៍នៅក្នុងសៀវភៅកំណត់ត្រាផ្លូវការ នៅត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំដាក់របាយការណ៍ ។ រដ្ឋមន្ត្រីរក្សាទុករបាយការណ៍សម្រាប់រយៈពេល ៥ ឆ្នាំ គិតចាប់ពីថ្ងៃបោះពុម្ពផ្សាយនៅក្នុងសៀវភៅកំណត់ត្រាផ្លូវការ ។ របាយការណ៍ត្រូវបានដាក់អោយពិនិត្យមើលជាសាធារណៈ នៅក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ក្នុងរយៈពេលនេះ ។

អភិបាលកិច្ចមូលដ្ឋាន (ការរៀបចំតាក់តែងគោលនយោបាយ
និងសង្គមស៊ីវិល)
ឆ្នាំសារពើពន្ធ២០០៧

# ហិរញ្ញវត្ថុសាធារណៈមូលដ្ឋាននៅប្រទេសជប៉ុន

~មាតិកា~

## ជំពូកទី ១ : សេចក្តីសង្ខេបអំពីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន


១. សេចក្តីផ្តើមអំពីប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសជប៉ុន.......................................................... ១
២. វិសាលភាពនៃហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ..................................................................................... ១
៣. ហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន និងហិរញ្ញវត្ថុសាធារណៈជាតិ.......................................................... ៣
៤. កំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋាននៅក្រោយសង្គ្រាមលោកលើកទី ២.................................. ៥
៥. ការចំណាយរបស់រដ្ឋាភិបាលមូលដ្ឋាន........................................................................................ ១២
៦. ចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន............................................................................................ ១៣
៧. និន្នាការថ្មីៗនៅក្នុងហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន.............................................................................. ១៥
៨. តម្រូវការក្នុងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធសារពើពន្ធ ......................................................................... ១៥


## ជំពូកទី ២ : អាករមូលដ្ឋាន


១. ប្រភេទអាករមូលដ្ឋាន...................................................................................................១៨
២. ចំណូលពីអាករមូលដ្ឋាន.................................................................................................១៨
៣. បំណែងចែកចំណូលអាកររវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន .........................................២០
៤. ផលធៀបនៃបន្ទុកអាករ..................................................................................................... ២២


## ជំពូកទី ៣ : អាករវិភាជន៍មូលដ្ឋាន


១. មុខងារនៃអាករវិភាជន៍មូលដ្ឋាន.........................................................................................២៣
២. ប្រភពនៃអាករវិភាជន៍មូលដ្ឋាន..........................................................................................២៣
៣. អាករវិភាជន៍ធម្មតា និងអាករវិភាជន៍ពិសេស ........................................................................២៣
៤. ការផ្តល់អាករវិភាជន៍ធម្មតា..............................................................................................២៤
៥. ការផ្តល់អាករវិភាជន៍ពិសេស .............................................................................................២៥
៦. ទំហំទឹកប្រាក់នៃអាករវិភាជន៍មូលដ្ឋាន ................................................................................២៦
៧. ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន.....................................................................................២៦


## ជំពូកទី ៤ : ការបើកប្រាក់ពីរតនាគារជាតិ


១. ប្រភេទនៃការបើកប្រាក់ពីរតនាគារជាតិ................................................................................. ៣០
២. ចំណុចសំខាន់ៗនៃច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋាន .......................................................................... ៣១
៣. ផលធៀបនៃចំណូលរបស់អាជ្ញាធរមូលដ្ឋាន................................................................................... ៣១
៤. ការលំបាក និងកំណែទម្រង់នាពេលថ្មីៗ...................................................................................... ៣១

## ជំពូកទី ៥ : សញ្ញាប័ណ្ណ/កម្ចីរបស់អាជ្ញាធរមូលដ្ឋាន


១. សេវាដែលសញ្ញាប័ណ្ណ/កម្ចីរបស់អាជ្ញាធរមូលដ្ឋានអាចអនុវត្តបាន...... ៣៣

២. ប្រព័ន្ធពិគ្រោះយោបល់សម្រាប់សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន...... ៣៣

៣. តួនាទីរបស់សញ្ញាប័ណ្ណ/កម្ចី...... ៣៤

៤. ស្ថានភាពនៃសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន...... ៣៤

៥. មូលនិធិសម្រាប់សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន...... ៣៥

៦. កម្មវិធីសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន...... ៣៦


## ជំពូកទី ៦ : កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន


១. ការរៀបចំកម្មវិធីហិរញ្ញវត្ថុសាធារណៈ...... ៣៧

២. តួនាទីនៃកម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន...... ៣៧


## ជំពូកទី ៧ : សមាគ្រាសហិរញ្ញវត្ថុសាធារណៈ

## ជំពូកទី ៨ : ច្បាប់នានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ

## ជំពូកទី ១ : សេចក្តីសង្ខេបអំពីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន

### ១. សេចក្តីផ្តើមអំពីប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសជប៉ុន

(១) ប្រទេសជប៉ុនមានប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន "ពីរលំដាប់ថ្នាក់" បែងចែកជាខេត្ត និងក្រុង (ទីក្រុង ឃុំ និងភូមិ) ។ អាជ្ញាធរមូលដ្ឋាន (គឺខេត្ត និងក្រុង) មានចំនួនសរុប ១.៨១៥ គិតមកទល់ត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ដែលក្នុងនោះមាន ៤៧ ខេត្ត (រួមទាំងរាជធានីតូក្យូ) និង ១.៨០៤ ក្រុង ។ បន្ថែមពីលើនេះ មានអាជ្ញាធរមូលដ្ឋានពិសេស ដូចជាសហករណ៍អាជ្ញាធរមូលដ្ឋានសម្រាប់គោលបំណងជាក់លាក់ ដូចជា ការការពារអគ្គិភ័យ និងការប្រមូលកាកសំណល់ ។

(២) ជាធម្មតា អាជ្ញាធរមូលដ្ឋានប្រើគណនីលើសពីមួយ ។ គណនីសម្រាប់សេវារដ្ឋបាលទូទៅ ដូចជា អប់រំ និងនគរបាល ហៅថា "គណនីទូទៅ" ។ "គណនីពិសេស" ជាច្រើនក៏ត្រូវបានប្រើប្រាស់ផងដែរ សម្រាប់សេវាមួយចំនួន ដូចជា លំនៅដ្ឋានជាដើម ពីព្រោះការចំណាយសម្រាប់សេវាទាំងនេះ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយផ្នែក ដោយតម្លៃដែលបង់ដោយអត្ថគាហក ។ "គណនីទូទៅ" និង "គណនីពិសេស" របស់អាជ្ញាធរមូលដ្ឋាន ហៅថា "គណនីសាមញ្ញ" ។ សេវាសាធារណៈ ដូចជា ការផ្គត់ផ្គង់ទឹក និងការដឹកជញ្ជូនសាធារណៈ (ដែលហៅថា "សហគ្រាសសាធារណៈមូលដ្ឋាន") ត្រូវ រក្សាគណនីផ្ទាល់របស់ខ្លួន ("គណនីសហគ្រាស") ដែលមានភាពដាច់ដោយឡែកពីគណនីដទៃទៀត ។

អត្ថបទនេះផ្តល់នូវសេចក្តីពន្យល់ដោយសង្ខេបអំពីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ដូចមានបង្ហាញនៅក្នុង "គណនីសាមញ្ញ" របស់រដ្ឋាភិបាលមូលដ្ឋាន ។ នៅក្នុងគណនីសាមញ្ញ មិនមានភាពខុសគ្នារវាងចំណាយ និងចំណូលចរន្ត និងជាមូលធនទេ ។ អាស្រ័យហេតុនេះ ស្ថិតិដូចខាងក្រោមនេះគិតបញ្ចូលទាំងចំណាយ និងចំណូលទាំងពីរប្រភេទ ។

### ២. វិសាលភាពនៃហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន

(១) ចំណាយប្រចាំឆ្នាំសរុបនៅក្នុងគណនីសាមញ្ញរបស់រដ្ឋាភិបាលមូលដ្ឋានទាំងអស់ នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ (គិតចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦) មានចំនួន ៩០.៦៩៧,៣ ពាន់លានយ៉េន (សុទ្ធ) ដែលក្នុងនោះ អាជ្ញាធរខេត្តចំណាយអស់ ៤៧.៨៧៣,៣ ពាន់លានយ៉េន (ដុល) និងអាជ្ញាធរក្រុង រួមទាំងសង្កាត់នៅតូក្យូ ចំណាយអស់ ៤៩.០៦០,៧ ពាន់លានយ៉េន (ដុល) ។ វិសាលភាពនៃចំណាយដុលរបស់រដ្ឋាភិបាលមូលដ្ឋានមានកម្រិតជិតស្មើនឹងការចំណាយរបស់រដ្ឋាភិបាលកណ្តាល ។ ដូចមានបង្ហាញនៅក្នុងតារាងទី ១ ការចំណាយរបស់រដ្ឋាភិបាលមូលដ្ឋានមានការកើនឡើងលឿនជាងរដ្ឋាភិបាលកណ្តាល ក្រោយពីសង្គ្រាមលោកលើកទី ២ ហើយចាប់តាំងពីឆ្នាំសារពើពន្ធ ១៩៥៣ មក ចំណាយដុលរបស់រដ្ឋាភិបាលមូលដ្ឋានមានកម្រិតខ្ពស់ជាងរដ្ឋាភិបាលកណ្តាល ។

**តារាងទី ១ : ការប្រៀបធៀបរវាងចំណាយរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន**

**(ឆ្នាំសារពើពន្ធ ១៩៤៥ ដល់ ២០០៤ ដែលបានជ្រើសរើស)**

(គិតជាពាន់លានយ៉េន)

| ឆ្នាំសារពើពន្ធ | ចំណាយប្រចាំឆ្នាំ | | (ខ) × ១០០ |
|---|---|---|---|
| | រដ្ឋាភិបាលកណ្តាល (ក) | រដ្ឋាភិបាលមូលដ្ឋាន (ខ) | (ក) (%) |
| ១៩៤៥ | ២១,៥ | ៥,០ | ២៣,៣ |
| ១៩៥០ | ៦៣៣,៣ | ៥២២,៦ | ៨២,៥ |
| ១៩៥៣ | ១.០១៧,២ | ១.០៣៦,២ | ១០១,៩ |
| ១៩៦០ | ១.៧៥៨,៦ | ១.៩២៤,៩ | ១០៩,៥ |
| ១៩៧០ | ៨.៦២៦,៦ | ៩.៨១៤,៩ | ១១៣,៨ |
| ១៩៧៥ | ២២.៧៥៨,៤ | ២៥.៦៥៤,៥ | ១១២,៧ |
| ១៩៧៨ | ៣៦.៩៣៦,៦ | ៣៨.៣៤៧,០ | ១០៣,៨ |
| ១៩៨១ | ៤៨.៩៩១,៣ | ៤៩.១៦៥,៣ | ១០០,៣ |
| ១៩៨៥ | ៥៥.១៤៨,៣ | ៥៦.២៩៣,៥ | ១០២,១ |
| ១៩៨៧ | ៦០.៧២៩,៤ | ៦៣.២២០,១ | ១០៤,១ |
| ១៩៨៩ | ៧០.៨៥០,៨ | ៧២.៧២៩,០ | ១០២,៧ |
| ១៩៩០ | ៧៤.១៩០,៧ | ៧៨.៤៧៣,២ | ១០៥,៨ |
| ១៩៩១ | ៧៥.៦២៧,៤ | ៨៣.៨០៦,៥ | ១១០,៨ |
| ១៩៩២ | ៧៧.១៤០,៧ | ៨៩.៥៥៩,៧ | ១១៦,១ |
| ១៩៩៣ | ៧៩.៣៥២,៨ | ៩៣.០៧៦,៤ | ១១៧,៣ |
| ១៩៩៤ | ៧៩.៩៨៤,៩ | ៩៣.៨១៧,៨ | ១១៧,៣ |
| ១៩៩៥ | ៨៦.៤៧៩,៥ | ៩៨.៩៤៤,៥ | ១១៤,៤ |
| ១៩៩៦ | ៨៧.៣១៩,៤ | ៩៩.០២៦,១ | ១១៣,៤ |
| ១៩៩៧ | ៨៤.៩០៨,៥ | ៩៧.៦៧៣,៨ | ១១៥,០ |
| ១៩៩៨ | ៨៤.៣៩១,៨ | ១០០.១៩៧,៥ | ១១៨,៧ |
| ១៩៩៩ | ៨៩.០៣៧,៤ | ១០១.៦២៩,១ | ១១៤,១ |
| ២០០០ | ៨៩.៣២១,១ | ៩៧.៦១៦,៤ | ១០៩,៣ |
| ២០០១ | ៨៤.៨១១,១ | ៩៧.៤៣១,៧ | ១១៤,៩ |
| ២០០២ | ៨៣.៦៧៤,៣ | ៩៤.៨៣៩,៤ | ១១៣,៣ |
| ២០០៣ | ៨២.៤១៥,៩ | ៩២.៥៨១,៨ | ១១២,៣ |
| ២០០៤ | ៨៤.៨៩៦,៧ | ៩១.២៤៧,៩ | ១០៧,៥ |
| ២០០៥ | ៨៥.៥១៩,៥ | ៩០.៦៩៧,៣ | ១០៦,១ |

(២) តារាងទី ២ បង្ហាញអំពីការចំណាយប្រចាំឆ្នាំសុទ្ធរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ក្នុងរយៈពេលជាង ៦០ឆ្នាំ ។ អាស្រ័យហេតុនេះ យើងអាចឃើញថាផលធៀបការចំណាយរបស់រដ្ឋាភិបាលកណ្តាលពាក់ព័ន្ធទៅនឹងការចំណាយក្នុងស្រុកសរុបបានធ្លាក់ចុះពីកម្រិត "លើ-១០%" មុនសង្គ្រាមលោកលើកទី ២ មកដល់កម្រិត "ក្រោម-១០%" ចំណែកឯផលធៀបសម្រាប់រដ្ឋាភិបាលមូលដ្ឋានមានច្រើនជាង១០% លើកលែងសម័យកាលពិសេសមួយចំនួនក្នុងកំឡុងពេលមានសង្គ្រាម ។

(៣) ការកើនឡើងយ៉ាងខ្លាំងនូវចំណាយរបស់រដ្ឋាភិបាលមូលដ្ឋាន នៅក្រោយសង្គ្រាម មិនមែនត្រឹមតែបណ្តាលមកពីអតិផរណាប៉ុណ្ណោះទេ គឺបណ្តាលមកពីការពង្រីកដ៏ទូលំទូលាយនូវមុខងាររបស់រដ្ឋាភិបាលមូលដ្ឋានផងដែរ នៅក្នុងវិស័យជាច្រើន ដែលជួយជំរុញដោយការរីកសាយភាយនៃទស្សនាទាន "រដ្ឋសុខុមាលភាព" ។ ការពង្រីកចំបងៗត្រូវបានធ្វើឡើងនៅក្នុងវិស័យមួយចំនួនដូចខាងក្រោម :

(i) ការអប់រំ : (១) ការបន្ថែមរយៈពេល ៣ ឆ្នាំ សម្រាប់ការអប់រំជាកាតព្វកិច្ច គឺបឋមសិក្សា (៦ ឆ្នាំ) និងមធ្យមសិក្សា (៣ ឆ្នាំ) និង (២) ការកើនឡើងយ៉ាងខ្លាំងនូវចំនួនកុមារ និងសិស្សមធ្យមសិក្សា ។

(ii) និរភ័យសង្គម : ការអនុម័តច្បាប់ស្តីពីការគាំពារមធ្យោបាយចិញ្ចឹមជីវិត ច្បាប់ស្តីពីសុខុមាលភាពកុមារ ច្បាប់ស្តីពីសុខុមាលភាពមនុស្សចាស់ និងច្បាប់ផ្សេងៗទៀត ។

(iii) សេវាសុខភាពសាធារណៈ និង

(iv) សាធារណការ ដូចជា ការសាងសង់ផ្លូវថ្នល់ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធសង្គមផ្សេងៗទៀត ។

តួនាទីនៃសកម្មភាពរបស់រដ្ឋាភិបាលនៅក្នុងសេដ្ឋកិច្ចជាតិកាន់តែមានសារៈសំខាន់ខ្លាំងឡើងៗនៅក្នុងឆ្នាំទាំងនោះ ដោយសកម្មភាពសាធារណៈធំៗត្រូវបានអនុវត្តដោយរដ្ឋាភិបាលមូលដ្ឋាន ។

## ៣. ហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន និងហិរញ្ញវត្ថុសាធារណៈជាតិ

(១) ការបែងចែកទំនួលខុសត្រូវរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន

យោងតាមច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ដែនកំណត់នៃអំណាចរដ្ឋបាលសម្រាប់អង្គភាពសាធារណៈមូលដ្ឋានត្រូវបានរៀបរាប់ថា "ជាវិស័យទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងកិច្ចការ បញ្ហាសាធារណៈ របស់អង្គភាពសាធារណៈសាមញ្ញដូចមានចែងដោយច្បាប់ ឬបទបញ្ជារបស់គណៈរដ្ឋមន្ត្រី និងកិច្ចការរដ្ឋបាលផ្សេងទៀតនៅក្រោមយុត្តាធិការរបស់ខ្លួនដែលមិនស្ថិតនៅក្រោមអំណាចរបស់រដ្ឋាភិបាលកណ្តាល" ។

នៅប្រទេសជប៉ុន យោងទៅតាមប្រភេទនីមួយៗ ទំនួលខុសត្រូវក្នុងកិច្ចការរដ្ឋបាលសាធារណៈត្រូវបានបែងចែករវាងរដ្ឋាភិបាលកណ្តាល និងអង្គភាពមូលដ្ឋានសាធារណៈ ។ ការបែងចែកកិច្ចការរដ្ឋបាលនេះមានបង្ហាញនៅក្នុងតារាងទី ៣ ។ ការបែងចែកមានចែងនៅក្នុងច្បាប់ដែលពាក់ព័ន្ធ ។

<u>កិច្ចការពាក់ព័ន្ធនឹងសុវត្ថិភាព ។ល។</u> : ការទូត ការពារជាតិ ប្រព័ន្ធតុលាការ និងការផ្តន្ទាទោសព្រហ្មទណ្ឌ គឺជាបន្ទុករបស់រដ្ឋាភិបាលកណ្តាល ។ កងកម្លាំងនគរបាលត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលខេត្ត ។ ចំណែកឯ ការការពារអគ្គិភ័យ និងការចុះបញ្ជីគ្រួសារ គឺជាទំនួលខុសត្រូវរបស់រដ្ឋាភិបាលក្រុង ។

កិច្ចការពាក់ព័ន្ធនឹងការថែទាំមូលធនសង្គម : ផ្លូវថ្នល់ និងទន្លេដែលមានកម្រិតធំលាតសន្ធឹងទូទាំងតំបន់ ត្រូវថែទាំដោយរដ្ឋាភិបាលកណ្តាល ។ ផ្លូវថ្នល់ និងទន្លេផ្សេងទៀតស្ថិតនៅក្រោមទំនួលខុសត្រូវរបស់មូលដ្ឋាន ។ កំពង់ផែ និងលំនៅដ្ឋានសាធារណៈត្រូវបានគ្រប់គ្រងដោយខេត្ត និងក្រុង ។

កិច្ចការពាក់ព័ន្ធនឹងការអប់រំ : សាកលវិទ្យាល័យត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលកណ្តាល ។ វិទ្យាល័យ និងការអប់រំពិសេស ត្រូវបានគ្រប់គ្រងដោយខេត្ត ហើយអនុវិទ្យាល័យ សាលាបឋមសិក្សា និងមត្តេយ្យសិក្សា ត្រូវបានគ្រប់គ្រងដោយដោយក្រុង ។

កិច្ចការពាក់ព័ន្ធនឹងសុខុមាលភាព សុខភាព និងអនាម័យ : អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតត្រូវបានចេញដោយរដ្ឋាភិបាលកណ្តាល ។ សេវាជាក់ស្តែង ស្ថិតនៅក្រោមទំនួលខុសត្រូវរបស់មូលដ្ឋាន ។

កិច្ចការពាក់ព័ន្ធនឹងឧស្សាហកម្ម និងសេដ្ឋកិច្ច : បញ្ហាទាំងឡាយណាដែលប៉ះពាល់ដល់សង្គមជាតិទាំងមូលត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលកណ្តាល ។ ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ត្រូវបានប្រគល់អោយអាជ្ញាធរមូលដ្ឋាន ។

(២) ការបែងចែកលម្អិតនៃចំណាយរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន

ការបែងចែកលម្អិតនៃចំណាយរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋានមានបង្ហាញនៅក្នុងរូបភាពទី ១ ។

ស្ទើរតែគ្រប់ផ្នែកទាំងអស់ ការចំណាយរបស់រដ្ឋាភិបាលមូលដ្ឋានមានកម្រិតខ្ពស់ជាងការចំណាយរបស់រដ្ឋាភិបាលកណ្តាល ។ មានតែផ្នែកដែលចំណាយដោយរដ្ឋាភិបាលកណ្តាលតែឯងប៉ុណ្ណោះ ដែលជាករណីលើកលែង ដូចជាផ្នែកការពារជាតិជាដើម ។ ដូច្នេះ ប្រការនេះឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីចំណែកដ៏ធំនៃសេវារដ្ឋបាលដែលផ្តល់ដោយមូលដ្ឋាន ។ ក្នុងចំណោមសេវាទាំងនេះ ការចំណាយពាក់ព័ន្ធនឹងការអប់រំ (សាលារៀន ។ល។) ការចំណាយទៅលើសុខភាព និងអនាម័យ (ការប្រមូលសំរាម ។ល។) និងការចំណាយសម្រាប់អភិវឌ្ឍដីធ្លីជាតិ (ផ្លូវថ្នល់ នគរូបនីយកម្ម ។ល។) មូលដ្ឋានមានចំណែកក្នុងសមាមាត្រមួយដ៏ធំ ។

## តារាងទី ២ : ការប្រៀបធៀបចំណាយរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន
## (ឆ្នាំសារពើពន្ធ ១៩៣៤ ដល់ ២០០៥ ដែលបានជ្រើសរើស)

| ឆ្នាំសារពើពន្ធ | ការចំណាយក្នុងស្រុកសរុប | | ការចំណាយសរុប | | ផ្ទេរមកពី | | សុទ្ធ | |
|---|---|---|---|---|---|---|---|---|
| | | | ថ្នាក់កណ្តាល | ថ្នាក់មូលដ្ឋាន | ថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន | ថ្នាក់មូលដ្ឋានទៅថ្នាក់កណ្តាល | ថ្នាក់កណ្តាល | |
| | ទំហំទឹកប្រាក់ (ក) | សន្ទស្សន៍ | ទំហំទឹកប្រាក់ (ខ) | ទំហំទឹកប្រាក់ (គ) | ទំហំទឹកប្រាក់ (ឃ) | ទំហំទឹកប្រាក់ (ង) | (ខ)-(ឃ) (ច) | សន្ទស្សន៍ |
| ១៩៣៥ | ១៦.៧ | - | ២.២ | ២.១ | ០.៣ | ០.០ | ១.៩ | - |
| ១៩៤១ | ៤៤.៨ | - | ៨.១ | ៣.១ | ១.១ | ០.០ | ៧.០ | - |
| ១៩៦១ | ២០.១៧០.៨ | ១០០ | ២.១៦៤.៥ | ២.៣៩១.១ | ១.០២៧.៩ | ៣៨.១ | ១.១៣៦.៦ | ១០០ |
| ១៩៨១ | ២៦០.៣៣៤.៣ | ១២៩១ | ៤៨.៩៩១.៣ | ៤៩.១៦៥.៣ | ២០.១៦៥.៧ | ៤៧៩.៤ | ២៨.៨២៥.៦ | ២៥៣៦ |
| ១៩៩១ | ៤៧២.៦២៦.៦ | ២៣៤៣ | ៧៥.៦២៧.៤ | ៨៣.៨០៦.៥ | ២៨.៨០២.១ | ១.០៧២.៩ | ៤៦.៨២៥.៣ | ៤១២០ |
| ១៩៩២ | ៤៨៣.១៨៨.៦ | ២៣៩៥ | ៧៧.១៤០.៧ | ៨៩.៥៥៩.៧ | ៣០.៦២២.៣ | ១.២៧៤.៣ | ៤៦.៥១៨.៤ | ៤០៩៣ |
| ១៩៩៣ | ៤៨៧.៥២៧.៨ | ២៤១៧ | ៧៩.៣៥២.៨ | ៩៣.០៧៦.៤ | ៣១.១៩៣.៧ | ១.៣៧៩.២ | ៤៨.១៥៩.១ | ៤២៣៧ |
| ១៩៩៤ | ៤៩១.២៦៧.៥ | ២៤៣៦ | ៧៩.៩៨៤.៩ | ៩៣.៨១៧.៨ | ៣១.២៥៣.៨ | ១.១០៧.៩ | ៤៨.៧៣១.១ | ៤២៨៧ |
| ១៩៩៥ | ៤៩៩.៩៨៤.២ | ២៤៧៩ | ៨៦.៤៧៩.៥ | ៩៨.៩៤៤.៥ | ៣៣.១៦៨.០ | ១.៤៩៥.២ | ៥៣.៣១១.៥ | ៤៦៩០ |
| ១៩៩៦ | ៥០៨.៤៣២.៨ | ២៥២១ | ៨៧.៣១៥.៤ | ៩៩.០២៦.១ | ៣៣.៦៦៦.៩ | ១.២៦៩.៤ | ៥៣.៦៤៨.៥ | ៤៧២០ |
| ១៩៩៧ | ៥១៣.៣០៦.៤ | ២៥៤៥ | ៨៤.៥០៨.៥ | ៩៧.៦៧៣.៨ | ៣២.៥៨០.៥ | ១.២៥៤.៣ | ៥២.៣២៨.០ | ៤៦០៤ |
| ១៩៩៨ | ៥០៣.៣០៤.៤ | ២៤៩៥ | ៩២.៣១៣.១ | ១០០.១៩៧.៥ | ៣៤.៣៨៩.១ | ១.៧៣៨.៤ | ៥៧.៩២៤.០ | ៥០៩៦ |
| ១៩៩៩ | ៤៩៩.៥៤៤.៤ | ២៤៧៧ | ១០១.៩៣៤.៥ | ១០១.៦២៩.១ | ៣៨.៧១២.០ | ១.៦១០.៦ | ៦៣.២២២.៥ | ៥៥៦២ |
| ២០០០ | ៥០៤.១១៨.៨ | ២៤៩៩ | ១០០.៧២៦.៣ | ៩៧.៦១៦.៤ | ៣៧.៧៦៤.៩ | ១.៥៤៦.៧ | ៦២.៩៦១.៤ | ៥៥៣៩ |
| ២០០១ | ៤៩៣.៦៤៤.៧ | ២៤៤៧ | ៩៣.៩០៨.១ | ៩៧.៤៣១.៧ | ៣៦.៥០១.១ | ១.៥៣៤.៧ | ៥៧.៤០៧.០ | ៥០៥១ |
| ២០០២ | ៤៨៩.៨៧៥.២ | ២៤២៩ | ៩២.៤៩៤.១ | ៩៤.៨៣៩.៤ | ៣៥.០០៤.៥ | ១.៤៧៧.០ | ៥៧.៤៨៩.៦ | ៥.០៥៨ |
| ២០០៣ | ៤៩៣.៧៤៧.៥ | ២៤៤៨ | ៨៨.៧៩២.០ | ៩២.៥៨១.៨ | ៣២.៩៣៨.២ | ១.២៨១.២ | ៥៥.៨៥៣.៨ | ៤.៩១៤ |
| ២០០៤ | ៤៩៨.២៨០.៤ | ២៤៧០ | ៩១.៦៤៤.៦ | ៩១.២៤៧.៩ | ៣១.៧៤៨.៨ | ១.២៩៨.៧ | ៥៩.៨៩៥.៨ | ៥.២៧០ |
| ២០០៥ | ៥០៣.៣៦៦.៨ | ២៤៩៦ | ៩៣.៤៣៤.៧ | ៩០.៦៩៧.៣ | ៣២.២១៤.៥ | ១.២៧៣.១ | ៦១.២២០.២ | ៥.៣៨៦ |

កំណត់សម្គាល់ : ១. ចំណាយសរុបរបស់រដ្ឋាភិបាលកណ្តាលតំណាងអោយចំណាយសរុបនៃគណនីទូទៅ និងគណនីពិសេសមួយចំនួន ដូចជា គណនីពិសេសសម្រាប់អាករវិភាជន៍ និងអាករផ្ទេរ

២. "ការផ្ទេរពីថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន" គឺជាចំនួនទឹកប្រាក់សរុបនៃអាករវិភាជន៍មូលដ្ឋាន អាករផ្ទេរមូលដ្ឋាន និងការបើកប្រាក់ពីរដ្ឋាភិបាលកណ្តាលជូនអាជ្ញាធរមូលដ្ឋាន ។

(គិតជាពាន់លានយ៉េន %)

| ចំណាយ | | | | ចំណែកសុទ្ធ<br>ការចំណាយរបស់រដ្ឋាភិបាល | | ជាភាគរយនៃចំណាយក្នុងស្រុកសរុប | | |
|---|---|---|---|---|---|---|---|---|
| ថ្នាក់មូលដ្ឋាន | | សរុប | | ថ្នាក់កណ្ដាល | ថ្នាក់មូលដ្ឋាន | ថ្នាក់កណ្ដាល | ថ្នាក់មូលដ្ឋាន | សរុប |
| (គ)-(ង)<br>(ឆ) | សន្ទស្សន៍ | (ច)+(ឆ)<br>(ជ) | សន្ទស្សន៍ | (ច) × ១០០<br>(ជ) | (ឆ) × ១០០<br>(ជ) | (ច) × ១០០<br>(ក) | (ឆ) × ១០០<br>(ក) | (ជ) × ១០០<br>(ក) |
| ២.១ | - | ៤.០ | - | ៤៧.៥ | ៥២.៥ | ១១.៤ | ១២.៦ | ២៤.០ |
| ៣.១ | - | ១០.១ | - | ៦៩.៣ | ៣០.៧ | ១៥.៦ | ៦.៩ | ២២.៥ |
| ២.៣៥៣.០ | ១០០ | ៣.៤៨៩.៦ | ១០០ | ៣២.៦ | ៦៧.៤ | ៥.៦ | ១១.៧ | ១៧.៣ |
| ៤៨.៦៨៥.៩ | ២០៦៩ | ៧៧.៥១១.៥ | ២២២១ | ៣៧.២ | ៦២.៨ | ១១.១ | ១៨.៧ | ២៩.៨ |
| ៨២.៧៣៣.៦ | ៣៥១៦ | ១២៩.៥៥៨.៩ | ៣៧១៣ | ៣៦.១ | ៦៣.៩ | ៩.៩ | ១៧.៤ | ២៧.៣ |
| ៨៨.២៨៥.៤ | ៣៧៥២ | ១៣៤.៨០៣.៨ | ៣៨៦៣ | ៣៤.៥ | ៦៥.៥ | ៩.៦ | ១៨.៣ | ២៧.៩ |
| ៩១.៦៩៧.២ | ៣៨៩៧ | ១៣៩.៨៥៦.៣ | ៤០០៨ | ៣៤.៤ | ៦៥.៦ | ៩.៩ | ១៨.៨ | ២៨.៧ |
| ៩២.៧០៩.៩ | ៣៩៤០ | ១៤១.៤៤១.០ | ៤០៥៣ | ៣៤.៥ | ៦៥.៥ | ៩.៩ | ១៨.៨ | ២៨.៧ |
| ៩៧.៤៤៩.៣ | ៤១៤១ | ១៥០.៧៦០.៨ | ៤៣២០ | ៣៥.៤ | ៦៤.៦ | ១០.៦ | ១៩.៤ | ៣០.០ |
| ៩៧.៧៥៦.៧ | ៤១៥៥ | ១៥១.៤០៥.២ | ៤៣៣៩ | ៣៥.៤ | ៦៤.៦ | ១០.៦ | ១៩.២ | ២៩.៨ |
| ៩៦.៤១៩.៥ | ៤០៩៨ | ១៤៨.៧៤៧.៥ | ៤២៦៣ | ៣៥.២ | ៦៤.៨ | ១០.២ | ១៨.៨ | ២៩.០ |
| ៩៨.៤៥៩.១ | ៤១៨៤ | ១៥៦.៣៨៣.១ | ៤៤៨១ | ៣៧.០ | ៦៣.០ | ១១.៥ | ១៩.៦ | ៣១.១ |
| ១០០.០១៨.៥ | ៤២៥១ | ១៦៣.២៤១.០ | ៤៦៧៨ | ៣៨.៧ | ៦១.៣ | ១២.៧ | ២០.០ | ៣២.៧ |
| ៩៦.០៦៩.៧ | ៤០៨៣ | ១៥៩.០៣១.១ | ៤៥៥៧ | ៣៩.៦ | ៦០.៤ | ១២.៥ | ១៩.១ | ៣១.៥ |
| ៩៥.៨៩៧.០ | ៤០៧៦ | ១៥៣.៣០៤.០ | ៤៣៩៣ | ៣៧.៤ | ៦២.៦ | ១១.៦ | ១៩.៤ | ៣១.១ |
| ៩៣.៣៦២.៤ | ៣៩៦៨ | ១៥០.៨៥២.០ | ៤៣២៣ | ៣៨.១ | ៦១.៩ | ១១.៧ | ១៩.១ | ៣០.៨ |
| ៩១.៣០០.៦ | ៣.៨៨០ | ១៤៧.១៥៤.៤ | ៤.២១៧ | ៣៨.០ | ៦២.០ | ១១.៣ | ១៨.៥ | ២៩.៨ |
| ៨៩.៩៤៩.២ | ៣.៨២៣ | ១៤៩.៨៤៥.០ | ៤.២៩៤ | ៤០.០ | ៦០.០ | ១២.០ | ១៨.១ | ៣០.១ |
| ៨៩.៤២៤.២ | ៣.៨០០ | ១៥០.៦៤៤.៤ | ៤.៣១៧ | ៤០.៦ | ៥៩.៤ | ១២.២ | ១៧.៨ | ២៩.៩ |

កំណត់សម្គាល់ : ៣. "ការផ្ទេរពីថ្នាក់មូលដ្ឋានទៅថ្នាក់កណ្ដាល" គឺជាចំណែករបស់អាជ្ញាធរមូលដ្ឋាននៅក្នុងការចំណាយ សម្រាប់គម្រោងដែលអនុវត្តដោយរដ្ឋាភិបាលកណ្ដាល ។

**តារាងទី ៣ : បំណែងចែកកិច្ចការរដ្ឋបាល**

| ទំនួលខុសត្រូវ | | សុវត្ថិភាព | មូលធនសង្គម | អប់រំ | សុខុមាលភាព សុខភាព អនាម័យ | ឧស្សាហកម្ម សេដ្ឋកិច្ច |
|---|---|---|---|---|---|---|
| រដ្ឋាភិបាលកណ្តាល | | ការទូត<br>ប្រព័ន្ធតុលាការ<br>ការពារជាតិ<br>ការផ្តន្ទាទោសព្រហ្មទណ្ឌ | មហាវិថី<br>ផ្លូវជាតិ<br>ទន្លេ ( ចម្បង) | សាកលវិទ្យាល័យ | ធានារ៉ាប់រងសង្គម<br>ការចេញអាជ្ញាប័ណ្ណ<br>ដល់វេជ្ជបណ្ឌិត<br>ការចេញអាជ្ញាប័ណ្ណ<br>វេជ្ជសាស្ត្រ | ពាណិជ្ជកម្ម គយ<br>សេវាប្រៃសណីយ៍<br>ការចេញអាជ្ញាប័ណ្ណ<br>ដឹកជញ្ជូន<br>គោលនយោបាយសេដ្ឋកិច្ច |
| រដ្ឋាភិបាលមូលដ្ឋាន | ខេត្ត | នគរបាល | ផ្លូវថ្នល់មូលដ្ឋាន ,<br>ទន្លេ ( បន្ទាប់បន្សំ)<br>កំពង់ផែ<br>លំនៅដ្ឋានសាធារណៈ | វិទ្យាល័យ | សុខុមាលភាពកុមារ<br>មណ្ឌលសុខភាព<br>សាធារណៈ | ការអភិវឌ្ឍតំបន់<br>សន្តិសុខការងារ |
| | ក្រុង | ការការពារអគ្គិភ័យ<br>ការចុះបញ្ជីគ្រួសារ | នគរូបនីយកម្ម<br>ផ្លូវថ្នល់មូលដ្ឋាន<br>កំពង់ផែ<br>លំនៅដ្ឋានសាធារណៈ<br>ទឹកស្អុយ | អនុវិទ្យាល័យ<br>សាលាបឋមសិក្សា<br>សាលាមត្តេយ្យ | ធានារ៉ាប់រងសុខភាពជាតិ<br>ធានារ៉ាប់រងសុខភាព<br>រយៈពេលវែង<br>ការផ្គត់ផ្គង់ទឹក<br>ការប្រមូលកាកសំណល់<br>សុខុមាលភាពមនុស្សចាស់<br>ជំនួយហិរញ្ញវត្ថុសាធារណៈ | ការអភិវឌ្ឍតំបន់ |

**រូបភាពទី ១ : ការបែងចែកចំណាយរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ( ផ្លាសារពើពន្ធ ២០០៥)**




កំណត់សម្គាល់ : តួលេខនៅក្នុងរង្វង់ក្រចកបញ្ជាក់អំពីភាគរយនៃទំនួលខុសត្រូវរបស់រដ្ឋាភិបាលជាតិ និងរដ្ឋាភិបាលមូលដ្ឋាន អាស្រ័យទៅតាមគោលបំណង ។

## ៤. កំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋាននៅក្រោយសង្គ្រាមលោកលើកទី ២

(១) ក្រោយពីសង្គ្រាម រដ្ឋាភិបាលមូលដ្ឋានត្រូវបានរំពឹងថាបង្កើនការចំណាយរបស់ខ្លួន ដើម្បីជំរុញការស្ថាបនាប្រទេសដែលទទួលរងនូវការខូចខាតឡើងវិញ កែលម្អកម្រិតជីវភាព យកចិត្តទុកដាក់លើកងកម្លាំងនគរបាលដែលផ្ទេរពីរដ្ឋាភិបាលកណ្តាល ។ល។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ការខូចខាតយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិដែលបណ្តាលមកពីសង្គ្រាមធ្វើអោយអាជ្ញាធរមូលដ្ឋានប្រើប្រាស់អស់នូវប្រភពចំណូលរបស់ខ្លួន ។

(២) ដើម្បីសង្គ្រោះរដ្ឋាភិបាលមូលដ្ឋានពីស្ថានភាពនេះ រដ្ឋាភិបាលកណ្តាលបានចាត់វិធានការជាច្រើន ។ តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីអាករមូលដ្ឋាន នៅក្នុងឆ្នាំ១៩៤៧ និងឆ្នាំ១៩៤៨ ចំណូលជាអាកររបស់រដ្ឋាភិបាលមូលដ្ឋានត្រូវបានបង្កើនឡើង ។ នៅក្នុងឆ្នាំ ១៩៤៨ ប្រព័ន្ធអាករចែកចាយមូលដ្ឋានត្រូវបានបង្កើតឡើង ដើម្បីជួយដល់អាជ្ញាធរមូលដ្ឋានដែលទទួលរងនូវកង្វះខាតធនធានកម្រដែលជាប់ពន្ធ (ប្រព័ន្ធនេះគឺជាបុព្វាធិការីនៃប្រព័ន្ធអាករវិភាជន៍មូលដ្ឋានបច្ចុប្បន្ន) ។ នៅក្នុងឆ្នាំដដែលនេះ ការប៉ាន់ស្មានជាផ្លូវការនៃចំណាយ និងចំណូលជាទូទៅរបស់រដ្ឋាភិបាលមូលដ្ឋាន សម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ ត្រូវបានចាប់ផ្តើមដោយរដ្ឋាភិបាល (ការប៉ាន់ស្មាននេះគឺជាបុព្វាធិការីនៃ "កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន" បច្ចុប្បន្ន) ។

(៣) នៅក្នុងឆ្នាំ១៩៤៩ រដ្ឋាភិបាលកណ្តាលបានស្នើសុំអោយមានបេសកកម្មរបស់សហរដ្ឋអាមេរិកក្នុងការត្រួតពិនិត្យប្រព័ន្ធអាករជប៉ុន នៅប្រទេសជប៉ុន ដែលដឹកនាំដោយសាស្ត្រាចារ្យ C. S. Shoup ។ បេសកកម្មបានស្នើឡើងនូវផែនការមួយសម្រាប់កំណែទម្រង់ប្រព័ន្ធទាំងមូល ហើយស្របតាមអនុសាសន៍របស់លោកសាស្ត្រាចារ្យ (ហៅថា "អនុសាសន៍ Shoup") កំណែទម្រង់ដ៏សម្បើមនៃប្រព័ន្ធអាករមូលដ្ឋានត្រូវបានអនុវត្តនៅក្នុងឆ្នាំ១៩៥០ ។ នេះគឺជាកំណែទម្រង់ដើម្បីផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើគោលការណ៍ "ស្វ័យភាពមូលដ្ឋាន" ។ នៅក្នុងកំណែទម្រង់នេះ អាករមូលដ្ឋានលើចំណូល និងទ្រព្យសម្បត្តិត្រូវបានពង្រឹង អាករលើប្រតិបត្តិការអាជីកម្មត្រូវបានផ្ទេរជូនរដ្ឋាភិបាលកណ្តាល ហើយអាករលើការប្រើប្រាស់ និងសហគ្រាសត្រូវបានកាត់បន្ថយ ។ លើសពីនេះទៅទៀត រដ្ឋាភិបាលមូលដ្ឋានត្រូវបានផ្តល់សេរីភាពកាន់តែទូលំទូលាយក្នុងការកំណត់អាករមូលដ្ឋាន ។

(៤) ចំពោះការពិនិត្យមើលឡើងវិញនូវហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន កំណែទម្រង់សំខាន់មួយនៃប្រព័ន្ធសម្រាប់ផ្តល់ឧបត្ថម្ភធនរបស់រដ្ឋាភិបាលកណ្តាលត្រូវបានធ្វើឡើង ។ នៅក្នុងឆ្នាំ១៩៤៩ អាករចែកចាយមូលដ្ឋានត្រូវបានលុបបំបាត់ ហើយចាប់ពីឆ្នាំសារពើពន្ធ១៩៥០ ប្រព័ន្ធឧបត្ថម្ភធនសមកម្មហិរញ្ញវត្ថុមូលដ្ឋានត្រូវបានបង្កើតឡើង ។

(៥) ទោះបីជាប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំងដោយកំណែទម្រង់ខាងលើក៏ដោយ ក៏រដ្ឋាភិបាលមូលដ្ឋាននៅតែមិនទាន់អាចបង្កើនចំណូលបានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃសកម្មភាពរដ្ឋបាលរបស់ខ្លួនដែលមានការកើនឡើងគួរអោយកត់សម្គាល់ នៅក្នុងកំឡុងពេលខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចឡើងវិញ ។

អាស្រ័យហេតុនេះ រដ្ឋាភិបាលមូលដ្ឋានមានកាតព្វកិច្ចដោះស្រាយកង្វះខាតចំណូលសាមញ្ញដោយការខ្ចីប្រាក់ ដែលបណ្តាលអោយបំណុលកើនឡើងជាបន្តបន្ទាប់ និងជាចុងក្រោយ ស្ទើរតែដួលរលំប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋានទាំងមូល ។

(៦) នៅចុងឆ្នាំសារពើពន្ធ១៩៥២ អាជ្ញាធរមូលដ្ឋានទទួលរងនូវឱនភាពថវិកាចំនួន ១៨.៥០០ ពាន់លានយ៉េន ចំពោះតែឆ្នាំនោះប៉ុណ្ណោះ ។ ឱនភាពបានកើនឡើងដល់ ៣៥.៧០០ ពាន់លានយ៉េន នៅក្នុងឆ្នាំសារពើពន្ធ១៩៥៣ និង ៥៨.៣០០

ពាន់លានយ៉េន នៅក្នុងឆ្នាំសារពើពន្ធ១៩៥៤ ។ ដោយត្រូវនឹង ១៦% នៃចំណូលអាករសរុបប្រចាំឆ្នាំសារពើពន្ធរបស់ខ្លួន នេះគឺជាបន្ទុកដ៏ធ្ងន់ធ្ងរក្រៃលែងចំពោះអាជ្ញាធរមូលដ្ឋាន ។

ដើម្បីដោះស្រាយស្ថានភាពធ្ងន់ធ្ងរនេះ រដ្ឋាភិបាលបានសម្រេចផ្តល់ឧបត្ថម្ភធនពិសេសបណ្តោះអាសន្ន ក្នុងទឹកប្រាក់ចំនួន ១៦ ពាន់លានយ៉េន ដោយបានអនុម័ត "ច្បាប់ស្តីពីវិធានការពិសេសសម្រាប់ជំរុញការស្តារហិរញ្ញវត្ថុសាធារណៈមូលដ្ឋានឡើងវិញ" ។

ជាមួយគ្នានេះផងដែរ ប្រព័ន្ធឧបត្ថម្ភធនសមកម្មហិរញ្ញវត្ថុសាធារណៈត្រូវបានធ្វើកំណែទម្រង់ម្តងទៀត ដើម្បីធានានូវចំណូលកាន់តែមានស្ថិរភាព និងមានទំនុកចិត្តសម្រាប់រដ្ឋាភិបាលមូលដ្ឋាន ដែលជាប្រព័ន្ធអាករវិភាជន៍មូលដ្ឋានបច្ចុប្បន្ន ។

(៧) ចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៣ សេដ្ឋកិច្ចជាតិរបស់ប្រទេសជប៉ុនមានកំណើនយ៉ាងឆាប់រហ័សជារៀងរាល់ឆ្នាំ លើកលែងតែក្នុងឆ្នាំសារពើពន្ធ១៩៥៨ ១៩៦២ ១៩៦៥ និង១៩៧១ ។ ដោយសារកំណើនសេដ្ឋកិច្ចនេះ ទាំងរដ្ឋាភិបាលកណ្តាល និងអាជ្ញាធរមូលដ្ឋានបានទទួលនូវកំណើនខាងចំណូលពីអាករ ។ ចំណូលពីអាករមូលដ្ឋាន និងអាករវិភាជន៍មូលដ្ឋាន បានកើនឡើងយ៉ាងខ្លាំង នៅក្នុងកំឡុងពេលនោះ ហើយបានសង្គ្រោះរដ្ឋាភិបាលមូលដ្ឋានចេញពីការលំបាកខាងហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ ។ ទំហំនៃចំណាយរបស់រដ្ឋាភិបាលមូលដ្ឋានបានកើនឡើងយ៉ាងឆាប់រហ័ស ដោយសាររដ្ឋាភិបាលមូលដ្ឋានបានផ្តល់អាទិភាពដល់គម្រោងវិនិយោគមូលធន ដើម្បីផ្តល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ។

(៨) ទោះជាយ៉ាងណាក៏ដោយ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ សេដ្ឋកិច្ចជប៉ុនបានទទួលរងនូវអតិផរណាយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីឧបសគ្គឥតព្រាងទុកប្រឆាំងនឹងការនាំចេញ និងការកើនឡើងយ៉ាងគំហុកនូវតម្លៃប្រេង ។ លើសពីនេះទៅទៀត ការធ្លាក់ចុះនៃសេដ្ឋកិច្ចបានបណ្តាលអោយមានការថយចុះយ៉ាងខ្លាំងនូវចំណូលជាអាកររបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ។ រដ្ឋាភិបាលមូលដ្ឋានត្រូវប្រញាប់រូសរាន់លុបបំបាត់ភាពខុសគ្នារវាងចំណូល តិចតួចរបស់ខ្លួន និងការពង្រីកតម្រូវការសម្រាប់ការចំណាយកាន់តែច្រើនឡើង ។ ដើម្បីជាវិធានការសាកល្បង រដ្ឋាភិបាលបានអនុញ្ញាតអាជ្ញាធរមូលដ្ឋានអោយចេញសញ្ញាប័ណ្ណមូលដ្ឋានច្រើនជាងក្នុងឆ្នាំសាមញ្ញ ដោយក្នុងពេលជាមួយគ្នា នោះជំរុញអោយមានចំណាយមូលធន ដែលអាចបង្កើតតម្រូវការមានប្រសិទ្ធភាពគ្រប់គ្រាន់ និងទាញសេដ្ឋកិច្ចអោយរួចផុតពីភាពជាប់គាំង ។ ទោះជាយ៉ាងណាក៏ដោយ សញ្ញាប័ណ្ណសាធារណៈមូលដ្ឋានទាំងនេះគឺពឹងផ្អែកយ៉ាងខ្លាំងលើការផ្គត់ផ្គង់ប្រាក់ពីឯកជន ដូចជាមូលនិធិដែលប្រមូលដោយធនាគារពាណិជ្ជកម្ម និងក្រុមហ៊ុនមូលប័ត្រ ។ល។ (ដែលល័ក្ខខ័ណ្ឌមាន អត្ថប្រយោជន៍ចំពោះអាជ្ញាធរមូលដ្ឋានតិចជាងមូលនិធិរបស់រដ្ឋាភិបាល) ពីព្រោះមូលនិធិរបស់រដ្ឋាភិបាលដែលជាប្រភពដ៏ សំខាន់នៃប្រាក់កម្ចីរបស់អាជ្ញាធរមូលដ្ឋាន មានមិនគ្រប់គ្រាន់ ។ ដូច្នេះ រដ្ឋាភិបាលបានចាត់វិធានការដើម្បីកាត់បន្ថយបន្ទុករបស់រដ្ឋាភិបាលមូលដ្ឋាន ដោយផ្តល់ឧបត្ថម្ភធនដើម្បីលុបបំបាត់ភាពខុសគ្នានៃកម្ចី រវាងមូលនិធិរដ្ឋាភិបាល និងមូលនិធិឯកជន ។

(៩) ចាប់ពីឆ្នាំ១៩៧៥ មក ការចំណាយចាំបាច់សម្រាប់សាធារណការ និរភ័យសង្គម អប់រំ ។ល។ បានកើនឡើង ចំណែកឯកំណើននៃចំណូលជាអាករនៅនឹងថ្កល់ ។ ជាលទ្ធផល អតុល្យភាពយ៉ាងធ្ងន់ធ្ងរផ្នែករចនាសម្ព័ន្ធរវាងចំណាយ និងចំណូលជាហិរញ្ញវត្ថុ បានកើតមានឡើង ។

ចាប់ពីឆ្នាំសារពើពន្ធ ១៩៨០ មក រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន បានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនឡើងវិញ ដោយកាត់បន្ថយចំណាយយ៉ាងច្រើន ។ ទោះជាយ៉ាងណាក៏ដោយ អនិស្សរភាពនៃហិរញ្ញវត្ថុជាតិលើសញ្ញាប័ណ្ណសាធារណៈ មានច្រើនជាង ២០% ហើយអនិស្សរភាពរបស់រដ្ឋាភិបាលមូលដ្ឋានមានប្រហែល ១០% ដែលមាន

ច្រើនជាងពីរដងនៃកម្រិតដែលធ្លាប់ជួបប្រទះនៅក្នុងពាក់កណ្តាលទីពីរនៃទសវត្សរ៍ឆ្នាំ១៩៦០ ។ នៅដំណាច់ឆ្នាំសារពើពន្ធ ១៩៨៣ បំណុលដែលមិនទាន់សងនៅក្នុងគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន មានលើសពី ១១.៥ ពាន់លានយ៉េន ។ នៅក្នុងឆ្នាំសារពើពន្ធ១៩៨៤ មានការពិនិត្យមើលឡើងវិញនូវកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ហើយអត្ថន័យនៃការពិនិត្យមើលឡើងវិញនេះរួមមាន (១) ការបញ្ឈប់ខ្ចីប្រាក់ដោយគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន និង (២) ការចែករំលែកបំណុលមិនទាន់សងនៅក្នុងគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន ដោយរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ។ ការចាត់ចែងពិសេសមួយដែលបង្កើនទឹកប្រាក់នៃអាករវិភាជន៍មូលដ្ឋានត្រូវបានធ្វើឡើង សម្រាប់ជាមធ្យោបាយក្នុងការរ៉ាប់រងនូវឱនភាពខាងមូលនិធិនៃគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន ។

(១០) ចាប់ពីឆ្នាំ១៩៨៥ មក ដោយសារគោលនយោបាយខាងលើ និងកំណើនសេដ្ឋកិច្ចពិសេស (ក្រោយមកត្រូវបានស្គាល់ថាជា "សេដ្ឋកិច្ចមានសន្ទុះខ្លាំង") តុល្យភាពនៃការបង់ប្រាក់របស់ហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបានត្រឡប់ទៅរកចំណុចសមតាឡើងវិញ ។

កំណើននៃចំណូលជាអាករ ដែលបណ្តាលមកពីសេដ្ឋកិច្ចមានសន្ទុះខ្លាំងបានអនុញ្ញាតអោយរដ្ឋាភិបាលមូលដ្ឋានសងប្រាក់កម្ចីរបស់ខ្លួន ។ លើសពីនេះទៅទៀត មូលនិធិដែលខ្ចីដោយគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋានត្រូវបានសងអស់មុនកាលកំណត់ ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ១៩៩១ ក្រោយពីការផ្ទុះនូវ "ការរីកចម្រើនខ្លាំង" ហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបានចាប់ផ្តើមជួបប្រទះនូវកង្វះធនធានហិរញ្ញវត្ថុជាថ្មីម្តងទៀត ។ ស្រដៀងគ្នាទៅនឹងសេណារីយូក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដែលការចេញសញ្ញាប័ណ្ណសារធារណៈដើម្បីទ្រទ្រង់តុល្យភាពនៃការបង់ប្រាក់បានកើនឡើង ហើយការខ្ចីដោយគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋានបានកើតមានឡើង ។ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរបស់ហិរញ្ញវត្ថុសាធារណៈបានក្លាយជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរជាថ្មីម្តងទៀត ។

(១១) នៅក្នុងឆ្នាំ១៩៩៥ ច្បាប់មួយដែលជំរុញវិមជ្ឈការត្រូវបានប្រកាសអោយប្រើប្រាស់ ហើយប្រព័ន្ធរដ្ឋបាលមជ្ឈការជាប្រពៃណីត្រូវបានពិនិត្យមើលឡើងវិញ ដើម្បីអោយសេវា និងសិទ្ធិអំណាចដែលមានឥទ្ធិពលលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន អាចត្រូវបានផ្ទេរជូនរដ្ឋាភិបាលមូលដ្ឋានមួយកម្រិតថែមទៀត ។

ការពិនិត្យមើលឡើងវិញទាំងស្រុងនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបច្ចុប្បន្ន គឺមិនអាចជៀសផុតបានឡើយ ដើម្បីធានាបាននូវប្រព័ន្ធរដ្ឋបាលវិមជ្ឈការ ខាងផ្នែកហិរញ្ញវត្ថុ ។ ជាជំហានដំបូង ការបង្កើតអាករលើការប្រើប្រាស់មូលដ្ឋាននៅក្នុងឆ្នាំសារពើពន្ធ១៩៩៧ ត្រូវបានសម្រេចដាក់អោយអនុវត្ត ។

សេចក្តីព្រាងពាក់ព័ន្ធនឹងការបង្កើតច្បាប់ជំរុញវិមជ្ឈការត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៩ ។

(១២) ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ដើម្បីជំរុញវិមជ្ឈការបន្ថែមទៀត រដ្ឋាភិបាលជាតិបានធ្វើកំណែទម្រង់យ៉ាងខ្លាំងនូវប្រព័ន្ធឧបត្ថម្ភកធន ជាមួយនឹងការផ្ទេរប្រភពចំណូលជាអាករ និងកំណែទម្រង់ប្រព័ន្ធអាករវិភាជន៍មូលដ្ឋាន (ដែលមានឈ្មោះថា "កំណែទម្រង់មុខបី") ។

ជាលទ្ធផលនៃកំណែទម្រង់នេះ ឧបត្ថម្ភកធនក្នុងទឹកប្រាក់លើសពី ៤ សែនកោដិយ៉េនត្រូវបានកាត់បន្ថយ ការផ្ទេរធនធានអាករក្នុងកម្រិត ៣ សែនកោដិយ៉េនត្រូវបានអនុវត្ត ហើយទំហំទឹកប្រាក់សរុបនៃអាករវិភាជន៍មូលដ្ឋានត្រូវបានកាត់បន្ថយ ។

៣ពាន់លានយ៉េន នៅក្នុងឆ្នាំសារពើពន្ធ១៩៥៤ ។ ដោយត្រូវនឹង ១៦% នៃចំណូលអាករសរុបប្រចាំឆ្នាំសារពើពន្ធរបស់ខ្លួន នេះគឺជាបន្ទុកដ៏ធ្ងន់ធ្ងរក្រៃលែងចំពោះអាជ្ញាធរមូលដ្ឋាន ។

ដើម្បីដោះស្រាយស្ថានភាពធ្ងន់ធ្ងរនេះ រដ្ឋាភិបាលបានសម្រេចផ្តល់ឧបត្ថម្ភកធនពិសេសបណ្តោះអាសន្ន ក្នុងទឹកប្រាក់ចំនួន ១៦ ពាន់លានយ៉េន ដោយបានអនុម័ត "ច្បាប់ស្តីពីវិធានការពិសេសសម្រាប់ជំរុញការស្តារបនាហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ឡើងវិញ" ។

ជាមួយគ្នានេះផងដែរ ប្រព័ន្ធឧបត្ថម្ភកធនសមកម្មហិរញ្ញវត្ថុសាធារណៈត្រូវបានធ្វើកំណែទម្រង់ម្តងទៀត ដើម្បីធានានូវចំណូលកាន់តែមានស្ថិរភាព និងមានទំនុកចិត្តសម្រាប់រដ្ឋាភិបាលមូលដ្ឋាន ដែលជាប្រព័ន្ធអាករវិភាជន៍មូលដ្ឋានបច្ចុប្បន្ន ។

(៧) ចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៣ សេដ្ឋកិច្ចជាតិរបស់ប្រទេសជប៉ុនមានកំណើនយ៉ាងឆាប់រហ័សជារៀងរាល់ឆ្នាំ លើកលែងតែក្នុងឆ្នាំសារពើពន្ធ១៩៥៨ ១៩៦២ ១៩៦៥ និង១៩៧១ ។ ដោយសារកំណើនសេដ្ឋកិច្ចនេះ ទាំងរដ្ឋាភិបាលកណ្តាល និងអាជ្ញាធរមូលដ្ឋានបានទទួលនូវកំណើនខាងចំណូលពីអាករ ។ ចំណូលពីអាករមូលដ្ឋាន និងអាករវិភាជន៍មូលដ្ឋាន បានកើនឡើងយ៉ាងខ្លាំង នៅក្នុងកំឡុងពេលនោះ ហើយបានសង្គ្រោះរដ្ឋាភិបាលមូលដ្ឋានចេញពីការលំបាកខាងហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ ។ ទំហំនៃចំណាយរបស់រដ្ឋាភិបាលមូលដ្ឋានបានកើនឡើងយ៉ាងឆាប់រហ័ស ដោយសាររដ្ឋាភិបាលមូលដ្ឋានបានផ្តល់អាទិភាពដល់គម្រោងវិនិយោគមូលធន ដើម្បីផ្តល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ។

(៨) ទោះជាយ៉ាងណាក៏ដោយ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ សេដ្ឋកិច្ចជប៉ុនបានទទួលរងនូវអតិផរណាយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីឧបសគ្គគតព្រាងទុកប្រឆាំងនឹងការនាំចេញ និងការកើនឡើងយ៉ាងគំហុកនូវតម្លៃប្រេង ។ លើសពីនេះទៅទៀត ការធ្លាក់ចុះនៃសេដ្ឋកិច្ចបានបណ្តាលអោយមានការថយចុះយ៉ាងខ្លាំងនូវចំណូលជាអាកររបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ។ រដ្ឋាភិបាលមូលដ្ឋានត្រូវប្រញាប់រូសរាន់លុបបំបាត់ភាពខុសគ្នារវាងចំណូល តិចតួចរបស់ខ្លួន និងការពង្រីកតម្រូវការសម្រាប់ការចំណាយកាន់តែច្រើនឡើង ។ ដើម្បីជាវិធានការសាកល្បង រដ្ឋាភិបាលបានអនុញ្ញាតអាជ្ញាធរមូលដ្ឋានអោយចេញសញ្ញាប័ណ្ណមូលដ្ឋានច្រើនជាងក្នុងឆ្នាំសាមញ្ញ ដោយក្នុងពេលជាមួយគ្នា នោះជំរុញអោយមានចំណាយមូលធន ដែលអាចបង្កើតតម្រូវការមានប្រសិទ្ធភាពគ្រប់គ្រាន់ និងទាញសេដ្ឋកិច្ចអោយរួចផុតពីភាពជាប់គាំង ។ ទោះជាយ៉ាងណាក៏ដោយ សញ្ញាប័ណ្ណសាធារណៈមូលដ្ឋានទាំងនេះគឺពឹងផ្អែកយ៉ាងខ្លាំងលើការផ្គត់ផ្គង់ប្រាក់ពីឯកជន ដូចជាមូលនិធិដែលប្រមូលដោយធនាគារពាណិជ្ជកម្ម និងក្រុមហ៊ុនមូលប័ត្រ ។ល។ (ដែលល័ក្ខខ័ណ្ឌមាន អត្ថប្រយោជន៍ចំពោះអាជ្ញាធរមូលដ្ឋានតិចជាងមូលនិធិរបស់រដ្ឋាភិបាល) ពីព្រោះមូលនិធិរបស់រដ្ឋាភិបាលដែលជាប្រភពដ៏ សំខាន់នៃប្រាក់កម្ចីរបស់អាជ្ញាធរមូលដ្ឋាន មានមិនគ្រប់គ្រាន់ ។ ដូច្នេះ រដ្ឋាភិបាលបានចាត់វិធានការដើម្បីកាត់បន្ថយបន្ទុករបស់រដ្ឋាភិបាលមូលដ្ឋាន ដោយផ្តល់ឧបត្ថម្ភកធនដើម្បីលុបបំបាត់ភាពខុសគ្នានៃកម្ចី រវាងមូលនិធិរដ្ឋាភិបាល និងមូលនិធិឯកជន ។

(៩) ចាប់ពីឆ្នាំ១៩៧៥ មក ការចំណាយចាំបាច់សម្រាប់សាធារណការ និរភ័យសង្គម អប់រំ ។ល។ បានកើនឡើង ចំណែកឯកំណើននៃចំណូលជាអាករនៅនឹងថ្កល់ ។ ជាលទ្ធផល អតុល្យភាពយ៉ាងធ្ងន់ធ្ងរផ្នែករចនាសម្ព័ន្ធរវាងចំណាយ និងចំណូលជាហិរញ្ញវត្ថុ បានកើតមានឡើង ។

ចាប់ពីឆ្នាំសារពើពន្ធ ១៩៨០ មក រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន បានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនឡើងវិញ ដោយកាត់បន្ថយចំណាយយ៉ាងច្រើន ។ ទោះជាយ៉ាងណាក៏ដោយ អនិស្សរភាពនៃហិរញ្ញវត្ថុជាតិលើសញ្ញាប័ណ្ណសាធារណៈ មានច្រើនជាង ២០% ហើយអនិស្សរភាពរបស់រដ្ឋាភិបាលមូលដ្ឋានមានប្រហែល ១០% ដែលមាន

ច្រើនជាងពីរដងនៃកម្រិតដែលធ្លាប់ជួបប្រទះនៅក្នុងពាក់កណ្តាលទីពីរនៃទសវត្សរ៍ឆ្នាំ១៩៦០ ។ នៅដំណាច់ឆ្នាំសារពើពន្ធ ១៩៨៣ បំណុលដែលមិនទាន់សងនៅក្នុងគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន មានលើសពី ១១,៥ ពាន់លានយ៉េន ។ នៅក្នុងឆ្នាំសារពើពន្ធ១៩៨៤ មានការពិនិត្យមើលឡើងវិញនូវកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ហើយអត្ថន័យនៃការពិនិត្យមើលឡើងវិញនេះរួមមាន (១) ការបញ្ឈប់ខ្ចីប្រាក់ដោយគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន និង (២) ការចែករំលែកបំណុលមិនទាន់សងនៅក្នុងគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន ដោយរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ។ ការចាត់ចែងពិសេសមួយដែលបង្កើនទឹកប្រាក់នៃអាករវិភាជន៍មូលដ្ឋានត្រូវបានធ្វើឡើង សម្រាប់ជាមធ្យោបាយក្នុងការរ៉ាប់រងនូវឱនភាពខាងមូលនិធិនៃគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋាន ។

(១០) ចាប់ពីឆ្នាំ១៩៨៥ មក ដោយសារគោលនយោបាយខាងលើ និងកំណើនសេដ្ឋកិច្ចពិសេស (ក្រោយមកត្រូវបានស្គាល់ថាជា "សេដ្ឋកិច្ចមានសន្ទុះខ្លាំង") តុល្យភាពនៃការបង់ប្រាក់របស់ហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបានត្រឡប់ទៅរកចំណុចសមតាឡើងវិញ ។

កំណើននៃចំណូលជាអាករ ដែលបណ្តាលមកពីសេដ្ឋកិច្ចមានសន្ទុះខ្លាំងបានអនុញ្ញាតអោយរដ្ឋាភិបាលមូលដ្ឋានសងប្រាក់កម្ចីរបស់ខ្លួន ។ លើសពីនេះទៅទៀត មូលនិធិដែលខ្ចីដោយគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋានត្រូវបានសងអស់មុនកាលកំណត់ ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ១៩៩១ ក្រោយពីការផ្ទុះនូវ "ការរីកចម្រើនខ្លាំង" ហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបានចាប់ផ្តើមជួបប្រទះនូវកង្វះធនធានហិរញ្ញវត្ថុជាថ្មីម្តងទៀត ។ ស្រដៀងគ្នាទៅនឹងសេណារីយូក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដែលការចេញសញ្ញាប័ណ្ណសារធារណៈដើម្បីទ្រទ្រង់តុល្យភាពនៃការបង់ប្រាក់បានកើនឡើង ហើយការខ្ចីដោយគណនីពិសេសនៃអាករវិភាជន៍មូលដ្ឋានបានកើតមានឡើង ។ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរបស់ហិរញ្ញវត្ថុសាធារណៈបានក្លាយជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរជាថ្មីម្តងទៀត ។

(១១) នៅក្នុងឆ្នាំ១៩៩៥ ច្បាប់មួយដែលជំរុញវិមជ្ឈការត្រូវបានប្រកាសអោយប្រើប្រាស់ ហើយប្រព័ន្ធរដ្ឋបាលមជ្ឈការជាប្រពៃណីត្រូវបានពិនិត្យមើលឡើងវិញ ដើម្បីអោយសេវា និងសិទ្ធិអំណាចដែលមានឥទ្ធិពលលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន អាចត្រូវបានផ្ទេរជូនរដ្ឋាភិបាលមូលដ្ឋានមួយកម្រិតថែមទៀត ។

ការពិនិត្យមើលឡើងវិញទាំងស្រុងនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋានបច្ចុប្បន្ន គឺមិនអាចជៀសផុតបានឡើយ ដើម្បីធានាបាននូវប្រព័ន្ធរដ្ឋបាលវិមជ្ឈការ ខាងផ្នែកហិរញ្ញវត្ថុ ។ ជាជំហានដំបូង ការបង្កើតអាករលើការប្រើប្រាស់មូលដ្ឋាននៅក្នុងឆ្នាំសារពើពន្ធ១៩៩៧ ត្រូវបានសម្រេចដាក់អោយអនុវត្ត ។

សេចក្តីព្រាងពាក់ព័ន្ធនឹងការបង្កើតច្បាប់ជំរុញវិមជ្ឈការត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៩ ។

(១២) ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ដើម្បីជំរុញវិមជ្ឈការបន្ថែមទៀត រដ្ឋាភិបាលជាតិបានធ្វើកំណែទម្រង់យ៉ាងខ្លាំងនូវប្រព័ន្ធឧបត្ថម្ភកធន ជាមួយនឹងការផ្ទេរប្រភពចំណូលជាអាករ និងកំណែទម្រង់ប្រព័ន្ធអាករវិភាជន៍មូលដ្ឋាន (ដែលមានឈ្មោះថា "កំណែទម្រង់មុខបី") ។

ជាលទ្ធផលនៃកំណែទម្រង់នេះ ឧបត្ថម្ភកធនក្នុងទឹកប្រាក់លើសពី ៤ សែនកោដិយ៉េនត្រូវបានកាត់បន្ថយ ការផ្ទេរធនធានអាករក្នុងកម្រិត ៣ សែនកោដិយ៉េនត្រូវបានអនុវត្ត ហើយទំហំទឹកប្រាក់សរុបនៃអាករវិភាជន៍មូលដ្ឋានត្រូវបានកាត់បន្ថយ ។

**តារាងទី ៦ : សមាសភាពនៃចំណូលប្រចាំឆ្នាំសរុបសម្រាប់រដ្ឋាភិបាលមូលដ្ឋានទាំងអស់ ទៅតាមប្រភព នៅក្នុង "គណនីសាមញ្ញ" (ឆ្នាំសារពើពន្ធ២០០៥)**

(គិតជាពាន់លានយ៉េន)

| ចំណូល (តាមប្រភព) | ចំនួនទឹកប្រាក់ | (ជា%) |
|---|---|---|
| អាករមូលដ្ឋាន | ៣៤.៨០៤.៤ | ៣៧.៤ |
| អាករផ្ទេរមូលដ្ឋាន | ១.៨៤៩.០ | ២.០ |
| អាករវិភាជន៍មូលដ្ឋាន | ១៦.៩៥៨.៧ | ១៨.២ |
| ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន | ១.៥១៨.០ | ១.៦ |
| ការបើកប្រាក់ពីរតនាគាជាតិ | ១១.៨៨៨.៩ | ១២.៨ |
| ប្រាក់កម្ចី | ១០.៣៧៦.៣ | ១១.២ |
| ផ្សេងៗ | ១៥.៥៤១.២ | ១៦.៧ |
| សរុប | ៩២.៩៣៦.៥ | ១០០ |

ប្រភព : ការិយាល័យហិរញ្ញវត្ថុនៃរដ្ឋាភិបាលមូលដ្ឋាន

ក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍

## ៧. និន្នាការថ្មីៗនៅក្នុងហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គភាពសាធារណៈមូលដ្ឋានបានចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តគម្រោងដែលមិនផ្តល់ឧបត្ថម្ភកធនដោយរតនាគារជាតិ ក្នុងគោលដៅជំរុញការអភិវឌ្ឍមូលធនសង្គមដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន និងដើម្បីជំរុញការអភិវឌ្ឍរបស់មូលដ្ឋាន ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ។ រូបភាពទី២ ធ្វើការប្រៀបធៀបទឹកប្រាក់ដែលបានចំណាយលើគម្រោងដែលមានឧបត្ថម្ភកធនពីរតនាគារជាតិ និងគម្រោងដែលគ្មានឧបត្ថម្ភកធនពីរតនាគារជាតិ ។

ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច ចំណូលជាអាករបានធ្លាក់ចុះ ហើយមានការកើនឡើងនូវការចេញសញ្ញាប័ណ្ណមូលដ្ឋានជាច្រើន។ ជាការចាំបាច់មិនមែនចំពោះតែរដ្ឋាភិបាលកណ្តាលប៉ុណ្ណោះទេ ថែមទាំងចំពោះរដ្ឋាភិបាលមូលដ្ឋានផងដែរ ដែលត្រូវអនុម័តនូវវិធានការសារពើពន្ធជាច្រើន ដែលផ្តោតលើការពង្រីកការវិនិយោគសាធារណៈ ដើម្បីធ្វើអោយសេដ្ឋកិច្ចរស់ឡើងវិញ បន្ទាប់ពីការដួលរលំនៃ "សេដ្ឋកិច្ចមានសន្ទុះខ្លាំង" ។ ជាលទ្ធផល ប្រាក់កម្ចីបានកើនឡើង ហើយអង្គភាពសាធារណៈមូលដ្ឋានទាំងមូលត្រូវជំពាក់បំណុលច្រើនជាង ១៩៩ សែនកោដិយ៉េន នៅដំណាច់ឆ្នាំសារពើពន្ធ២០០៧ ។ រូបភាពទី ៣ បង្ហាញអំពីតុល្យភាពនៃប្រាក់កម្ចីដែលមានស្រាប់របស់អង្គភាពសាធារណៈមូលដ្ឋាន ចំពោះផលិតផលក្នុងស្រុកសរុប ។

## ៨. តម្រូវការក្នុងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធសារពើពន្ធ

ដូចមានបង្ហាញក្នុងរូបភាពទី ៣ បំណុលរយៈពេលវែងរបស់រដ្ឋាភិបាលមូលដ្ឋានបានកើនឡើងជិតពីរដងនៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ។

ការកើនឡើងខ្ពស់នូវបំណុលរយៈពេលវែងបណ្តាលអោយមានការកើនឡើងខ្ពស់នូវបន្ទុកសងប្រាក់ដើម និងការប្រាក់នៃបំណុល និងធ្វើអោយមិនអាចរៀបចំថវិកា ដោយដាក់បំណុលទៅក្នុងខ្ទង់ចំណាយ ។

ការកែលម្អស្ថានភាពពន្ធដារគឺជាកិច្ចការដែលមិនអាចខានបាន សម្រាប់ប្រទេសជប៉ុន ក្នុងការបង្កើតសង្គមដ៏រឹងមាំមួយក្នុងសតវត្សរ៍ទី ២១ ។

ស្ថានភាពសារពើពន្ធបច្ចុប្បន្នរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសជប៉ុន ស្ទើរតែជាស្ថានភាពដ៏អាក្រក់បំផុត ក្នុងចំណោមបស្ចិមប្រទេសសំខាន់ៗ ។

**តារាងទី ៦ : សមាសភាពនៃចំណូលប្រចាំឆ្នាំសរុបសម្រាប់រដ្ឋាភិបាលមូលដ្ឋានទាំងអស់ ទៅតាមប្រភព នៅក្នុង "គណនីសាមញ្ញ" (ឆ្នាំសារពើពន្ធ២០០៥)**

(គិតជាពាន់លានយ៉េន)

| ចំណូល (តាមប្រភព) | ចំនួនទឹកប្រាក់ | (ជា%) |
|---|---|---|
| អាករមូលដ្ឋាន | ៣៤.៨០៤.៤ | ៣៧.៤ |
| អាករផ្ទេរមូលដ្ឋាន | ១.៨៤៩.០ | ២.០ |
| អាករវិភាជន៍មូលដ្ឋាន | ១៦.៩៥៨.៧ | ១៨.២ |
| ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន | ១.៥១៨.០ | ១.៦ |
| ការបើកប្រាក់ពីរតនាគាជាតិ | ១១.៨៨៨.៩ | ១២.៨ |
| ប្រាក់កម្ចី | ១០.៣៧៦.៣ | ១១.២ |
| ផ្សេងៗ | ១៥.៥៤១.២ | ១៦.៧ |
| សរុប | ៩២.៩៣៦.៥ | ១០០ |

ប្រភព : ការិយាល័យហិរញ្ញវត្ថុនៃរដ្ឋាភិបាលមូលដ្ឋាន

ក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍

## ៧. និន្នាការថ្មីៗនៅក្នុងហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គភាពសាធារណៈមូលដ្ឋានបានចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តគម្រោង ដែលមិនផ្តល់ឧបត្ថម្ភកធនដោយរតនាគារជាតិ ក្នុងគោលដៅជំរុញការអភិវឌ្ឍមូលធនសង្គមដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន និងដើម្បីជំរុញការអភិវឌ្ឍរបស់មូលដ្ឋាន ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ។ រូបភាពទី២ ធ្វើការប្រៀបធៀបទឹកប្រាក់ដែលបានចំណាយលើគម្រោងដែលមានឧបត្ថម្ភកធនពីរតនាគារជាតិ និងគម្រោងដែលគ្មានឧបត្ថម្ភកធនពីរតនាគារជាតិ ។

ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច ចំណូលជាអាករបានធ្លាក់ចុះ ហើយមានការកើនឡើងនូវការចេញសញ្ញាប័ណ្ណមូលដ្ឋានជាច្រើន។ ជាការចាំបាច់មិនមែនចំពោះតែរដ្ឋាភិបាលកណ្តាលប៉ុណ្ណោះទេ ថែមទាំងចំពោះរដ្ឋាភិបាលមូលដ្ឋានផងដែរ ដែលត្រូវអនុម័តនូវវិធានការសារពើពន្ធជាច្រើន ដែលផ្តោតលើការពង្រីកការវិនិយោគសាធារណៈ ដើម្បីធ្វើអោយសេដ្ឋកិច្ចរស់ឡើងវិញ បន្ទាប់ពីការដួលរលំនៃ "សេដ្ឋកិច្ចមានសន្ទុះខ្លាំង" ។ ជាលទ្ធផល ប្រាក់កម្ចីបានកើនឡើង ហើយអង្គភាពសាធារណៈមូលដ្ឋានទាំងមូលត្រូវជំពាក់បំណុលច្រើនជាង ១៩៩ សែនកោដិលាន នៅដំណាច់ឆ្នាំសារពើពន្ធ២០០៧ ។ រូបភាពទី ៣ បង្ហាញអំពីតុល្យភាពនៃប្រាក់កម្ចីដែលមានស្រាប់របស់អង្គភាពសាធារណៈមូលដ្ឋាន ចំពោះផលិតផលក្នុងស្រុកសរុប ។

## ៨. តម្រូវការក្នុងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធសារពើពន្ធ

ដូចមានបង្ហាញក្នុងរូបភាពទី ៣ បំណុលរយៈពេលវែងរបស់រដ្ឋាភិបាលមូលដ្ឋានបានកើនឡើងជិតពីរដងនៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ។

ការកើនឡើងខ្ពស់នូវបំណុលរយៈពេលវែងបណ្តាលអោយមានការកើនឡើងខ្ពស់នូវបន្ទុកសងប្រាក់ដើម និងការប្រាក់នៃបំណុល និងធ្វើអោយមិនអាចរៀបចំថវិកា ដោយដាក់បំណុលទៅក្នុងខ្ទង់ចំណាយ ។

ការកែលម្អស្ថានភាពពន្ធដារគឺជាកិច្ចការដែលមិនអាចខានបាន សម្រាប់ប្រទេសជប៉ុន ក្នុងការបង្កើតសង្គមដ៏រឹងមាំមួយក្នុងសតវត្សរ៍ទី ២១ ។

ស្ថានភាពសារពើពន្ធបច្ចុប្បន្នរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសជប៉ុន ស្ទើរតែជាស្ថានភាពដ៏អាក្រក់បំផុត ក្នុងចំណោមបស្ចិមប្រទេសសំខាន់ៗ ។

## ជំពូកទី ២ : អាករមូលដ្ឋាន

នៅប្រទេសជប៉ុន រដ្ឋាភិបាលមូលដ្ឋានសាមញ្ញទាំងអស់ត្រូវបានច្បាប់ស្តីពីអាករមូលដ្ឋាន (ឆ្នាំ១៩៥០) អនុញ្ញាតអោយកំណត់ និងប្រមូលអាករមូលដ្ឋានជាច្រើនប្រភេទ ។

### ១. ប្រភេទអាករមូលដ្ឋាន

(១) ចំណាត់ថ្នាក់បច្ចុប្បន្ននៃអាករមូលដ្ឋានក្រោមច្បាប់ស្តីពីអាករមូលដ្ឋានមានបង្ហាញជូននៅក្នុងតារាងទី ៧ ។ អាករដែលកំណត់ដោយអាជ្ញាធរខេត្តហៅថា "អាករខេត្ត" ហើយអាករដែលកំណត់ដោយអាជ្ញាធរក្រុងហៅថា "អាករក្រុង" ។

(២) ក្នុងចំណោមអាករខេត្តដែលបានរៀបរាប់នៅក្នុងតារាងទី ៧ អាករលើការទិញរថយន្ត និងអាករលើការប្រគល់ប្រេងស្រាល ត្រូវបានសម្គាល់ថាជាអាករដែលចំណូលត្រូវបានតម្រូវអោយចំណាយសម្រាប់តែគោលបំណងដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងធនធានអាករតែប៉ុណ្ណោះ ។ ក្នុងចំណោមអាករក្រុង អាករនគរូបនីយកម្មត្រូវបានសម្គាល់តាមរបៀបដូចគ្នា ។

(៣) ចំណូលដែលបានមកពីអាករមូលដ្ឋានផ្សេងទៀត ហៅថា "អាករសាមញ្ញ" អាចត្រូវបានប្រើប្រាស់សម្រាប់គោល-បំណងរដ្ឋបាលរបស់រដ្ឋាភិបាលមូលដ្ឋាន ។

### ២. ចំណូលពីអាករមូលដ្ឋាន

(១) ទំហំទឹកប្រាក់សរុបនៃចំណូលពីអាករមូលដ្ឋាន និងទំហំទឹកប្រាក់នៃអាករឯកត្តជន នៅក្នុងឆ្នាំសារពើពន្ធ២០០៥ មានបង្ហាញជូននៅក្នុងតារាងទី ៧ ។

ទំហំទឹកប្រាក់សរុបមាន ៣៤.៨០៤.៤ ពាន់លានយ៉េន ដែលក្នុងនោះមាន ១៥.២២៦.៩ ពាន់លានយ៉េន ជាចំណូលពីអាករខេត្ត និង ១៩.៥៧៧.៥ ពាន់លានយ៉េន ជាចំណូលពីអាករក្រុង ។ ក្នុងចំណោមអាករខេត្ត អាករលើសហគ្រាសមានចំណែកធំជាងគេ គឺ ៣២.៣% ។ ចំពោះករណីអាករក្រុង អាករក្រុងលើទ្រព្យសកម្មរយៈពេលវែងមានចំណែកធំជាងគេ គឺ ៤៤.៧% នៃ ចំណូលពីអាករក្រុងសរុប ។

(២) ជាធម្មតា អាករលើទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់ដោយរដ្ឋាភិបាលក្រុង ប៉ុន្តែ រដ្ឋាភិបាលខេត្តអាចកំណត់អាករលើទ្រព្យសកម្មរយៈពេលវែងរំលោះខ្នាតធំមួយចំនួន ។

(៣) ការចូលរួមចំណែកនៃអាករមូលដ្ឋាននៅក្នុងចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន ក្នុងឆ្នាំសារពើពន្ធ២០០៥ មានបង្ហាញជូននៅក្នុងតារាងទី ៦ ។ ចំណូលពីការយកអាករមានចំនួន ៣៧.៤% នៃចំណូលសរុបរបស់រដ្ឋាភិបាលមូលដ្ឋាន ។

**តារាងទី ៧ : ការប្រមូលអាករមូលដ្ឋាន**

**(ឆ្នាំសារពើពន្ធ២០០៥)**

(គិតជាពាន់លានយ៉េន)

| ប្រភព | ចំនួនទឹកប្រាក់ | (ជា%) |
|---|---|---|
| **អាករខេត្ត** | | |
| • អាករលើប្រជាជនរស់នៅក្នុងខេត្ត | ៣.៥៨៥.៤ | ២៣.៥ |
| (ឯកត្តជន) | ២.២៥៤.៣ | ១៤.៨ |
| (សាជីវកម្ម) | ៩៦៦.១ | ៦.៣ |
| (អត្រាការប្រាក់) | ១៧៧.៤ | ១.២ |
| (អត្រាភាគលាភ អាត្រាចំណេញលើមូលធន) | ១៨៧.៦ | ១.២ |
| • អាករលើសហគ្រាស | ៤.៩១៤.២ | ៣២.៣ |
| អាករលើសហគ្រាសឯកបុគ្គល | ២១៥.៨ | ១.៤ |
| អាករលើសហគ្រាសសាជីវកម្ម | ៤.៦៩៨.៤ | ៣០.៩ |
| • អាករលើការទិញអចលនវត្ថុ | ៤៧៦.៧ | ៣.១ |
| • អាករលើថ្នាំជក់ក្រុង | ២៧៥.២ | ១.៨ |
| • អាករលើរថយន្ត | ១.៧៥២.៨ | ១១.៥ |
| • អាករលើការប្រើប្រាស់មូលដ្ឋាន | ២.៥៥១.២ | ១០.៨ |
| • អាករលើការទិញរថយន្ត | ៤៥២.៨ | ៣.០ |
| • អាករលើការប្រគល់ប្រេងស្រាល | ១.០៨៥.៩ | ៧.១ |
| • ផ្សេងៗ | ១៣២.៧ | ០.៩ |
| អនុសរុប (នៅមានត) | ១៥.២២៦.៩ | ១០០ |

កំណត់សម្គាល់ : ខេត្ត និងក្រុងអាចកំណត់អាករសាមញ្ញដែលមិនមានចែងនៅក្នុងច្បាប់ស្តីពីអាករមូលដ្ឋាន ដោយមានការព្រមព្រៀងពីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

## ជំពូកទី ២ ៖ អាករមូលដ្ឋាន

នៅប្រទេសជប៉ុន រដ្ឋាភិបាលមូលដ្ឋានសាមញ្ញទាំងអស់ត្រូវបានច្បាប់ស្តីពីអាករមូលដ្ឋាន (ឆ្នាំ១៩៥០) អនុញ្ញាតអោយកំណត់ និងប្រមូលអាករមូលដ្ឋានជាច្រើនប្រភេទ ។

### ១. ប្រភេទអាករមូលដ្ឋាន

(១) ចំណាត់ថ្នាក់បច្ចុប្បន្ននៃអាករមូលដ្ឋានក្រោមច្បាប់ស្តីពីអាករមូលដ្ឋានមានបង្ហាញជូននៅក្នុងតារាងទី ៧ ។ អាករដែលកំណត់ដោយអាជ្ញាធរខេត្តហៅថា "អាករខេត្ត" ហើយអាករដែលកំណត់ដោយអាជ្ញាធរក្រុងហៅថា "អាករក្រុង" ។

(២) ក្នុងចំណោមអាករខេត្តដែលបានរៀបរាប់នៅក្នុងតារាងទី ៧ អាករលើការទិញរថយន្ត និងអាករលើការប្រគល់ប្រេងស្រាល ត្រូវបានសម្គាល់ថាជាអាករដែលចំណូលត្រូវបានតម្រូវអោយចំណាយសម្រាប់តែគោលបំណងដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងធនធានអាករតែប៉ុណ្ណោះ ។ ក្នុងចំណោមអាករក្រុង អាករនគរូបនីយកម្មត្រូវបានសម្គាល់តាមរបៀបដូចគ្នា ។

(៣) ចំណូលដែលបានមកពីអាករមូលដ្ឋានផ្សេងទៀត ហៅថា "អាករសាមញ្ញ" អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងរដ្ឋបាលរបស់រដ្ឋាភិបាលមូលដ្ឋាន ។

### ២. ចំណូលពីអាករមូលដ្ឋាន

(១) ទំហំទឹកប្រាក់សរុបនៃចំណូលពីអាករមូលដ្ឋាន និងទំហំទឹកប្រាក់នៃអាករឯកត្តជន នៅក្នុងឆ្នាំសារពើពន្ធ២០០៥ មានបង្ហាញជូននៅក្នុងតារាងទី ៧ ។

ទំហំទឹកប្រាក់សរុបមាន ៣៤.៨០៤.៤ ពាន់លានយ៉េន ដែលក្នុងនោះមាន ១៥.២២៦.៩ ពាន់លានយ៉េន ជាចំណូលពីអាករខេត្ត និង ១៩.៥៧៧.៥ ពាន់លានយ៉េន ជាចំណូលពីអាករក្រុង ។ ក្នុងចំណោមអាករខេត្ត អាករលើសហគ្រាសមានចំណែកធំជាងគេ គឺ ៣២.៣% ។ ចំពោះករណីអាករក្រុង អាករក្រុងលើទ្រព្យសកម្មរយៈពេលវែងមានចំណែកធំជាងគេ គឺ ៤៤.៧% នៃ ចំណូលពីអាករក្រុងសរុប ។

(២) ជាធម្មតា អាករលើទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់ដោយរដ្ឋាភិបាលក្រុង ប៉ុន្តែ រដ្ឋាភិបាលខេត្តអាចកំណត់អាករលើទ្រព្យសកម្មរយៈពេលវែងរំលោះខ្នាតធំមួយចំនួន ។

(៣) ការចូលរួមចំណែកនៃអាករមូលដ្ឋាននៅក្នុងចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន ក្នុងឆ្នាំសារពើពន្ធ២០០៥ មានបង្ហាញជូននៅក្នុងតារាងទី ៦ ។ ចំណូលពីការយកអាករមានចំនួន ៣៧.៤% នៃចំណូលសរុបរបស់រដ្ឋាភិបាលមូលដ្ឋាន ។

## តារាងទី ៧ : ការប្រមូលអាករមូលដ្ឋាន
## (ឆ្នាំសារពើពន្ធ២០០៥)

(គិតជាពាន់លានយ៉េន)

| ប្រភព | ចំនួនទឹកប្រាក់ | (ជា%) |
|---|---|---|
| **អាករខេត្ត** | | |
| • អាករលើប្រជាជនរស់នៅក្នុងខេត្ត | ៣.៥៨៥.៤ | ២៣.៥ |
| (ឯកត្តជន) | ២.២៥៤.៣ | ១៤.៨ |
| (សាជីវកម្ម) | ៩៦៦.១ | ៦.៣ |
| (អត្រាការប្រាក់) | ១៧៧.៤ | ១.២ |
| (អត្រាភាគលាភ អាត្រាចំណេញលើមូលធន) | ១៨៧.៦ | ១.២ |
| • អាករលើសហគ្រាស | ៤.៩១៤.២ | ៣២.៣ |
| អាករលើសហគ្រាសឯកបុគ្គល | ២១៥.៨ | ១.៤ |
| អាករលើសហគ្រាសសាជីវកម្ម | ៤.៦៩៨.៤ | ៣០.៩ |
| • អាករលើការទិញអចលនវត្ថុ | ៤៧៦.៧ | ៣.១ |
| • អាករលើថ្នាំជក់ក្រុង | ២៧៥.២ | ១.៨ |
| • អាករលើរថយន្ត | ១.៧៥២.៨ | ១១.៥ |
| • អាករលើការប្រើប្រាស់មូលដ្ឋាន | ២.៥៥១.២ | ១០.៨ |
| • អាករលើការទិញរថយន្ត | ៤៥២.៨ | ៣.០ |
| • អាករលើការប្រគល់ប្រេងស្រាល | ១.០៨៥.៩ | ៧.១ |
| • ផ្សេងៗ | ១៣២.៧ | ០.៩ |
| អនុសរុប (នៅមានត) | ១៥.២២៦.៩ | ១០០ |

កំណត់សម្គាល់ : ខេត្ត និងក្រុងអាចកំណត់អាករសាមញ្ញដែលមិនមានចែងនៅក្នុងច្បាប់ស្តីពីអាករមូលដ្ឋាន ដោយមានការព្រមព្រៀងពីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

## ៤. ផលធៀបនៃបន្ទុកអាករ

មុនសង្គ្រាមលោកលើកទី ២ (ឆ្នាំ១៩៣៤ ដល់ឆ្នាំ១៩៣៦) ផលធៀបនៃបន្ទុកអាករចំពោះចំណូលជាតិសរុបនៅតែមានកម្រិតទាបគឺត្រឹមតែ ១២,៩% (អាករជាតិចំនួន ៨,៥% អាករមូលដ្ឋានចំនួន ៤,៤%) ។ ប៉ុន្តែ ផលធៀបនេះបានកើនឡើងដល់ ២៨,៤% (អាករជាតិចំនួន ២៣,២% អាករមូលដ្ឋានចំនួន ៥,២%) នៅក្នុងឆ្នាំសារពើពន្ធ១៩៤៩ ។ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយបន្ទុកបែបនេះ ផលធៀបបានធ្លាក់ចុះដល់ ១៨,០% (អាករជាតិចំនួន ១២,២% អាករមូលដ្ឋានចំនួន ៥,៨%) នៅក្នុងឆ្នាំ សារពើពន្ធ១៩៦៥ ។ ក្រោយឆ្នាំ១៩៦៥ ផលធៀបបានកើនឡើងជាលំដាប់ និងឡើងដល់ ២៧,៦% (អាករជាតិចំនួន ១៧,៧% អាករមូលដ្ឋានចំនួន ៩,៩%) នៅក្នុងឆ្នាំសារពើពន្ធ១៩៨៩ ។ នៅក្នុងឆ្នាំសារពើពន្ធ២០០៥ ផលធៀបមាន ២៣,៧% (អាករ ជាតិចំនួន ១៤,២% អាករមូលដ្ឋានចំនួន ៩,៥%) ។ បច្ចុប្បន្ននេះ ផលធៀបនៃបន្ទុកអាកររបស់ប្រទេសជប៉ុនហាក់ដូចជាមិនសូវ ខ្ពស់ដូចប្រទេសដទៃទៀតទេ គិតមកទល់នឹងត្រឹមឆ្នាំសារពើពន្ធ២០០៤ : ចក្រភពអង់គ្លេសចំនួន ៣៧,១% សហរដ្ឋអាមេរិកចំនួន ២៣,២% និងអាល្លឺម៉ង់ចំនួន ២៧,៥% ។ ទាំងហិរញ្ញវត្ថុសាធារណៈជាតិ និងមូលដ្ឋានកំពុងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ បន្ទាប់ពីការផ្ទុះ "សន្ទុះខ្លាំង" និងបានក្លាយជាបញ្ហាបន្ទាន់បំផុត ដើម្បីបង្កើនចំណូល ជាអាករអោយបានច្រើន និងកាត់បន្ថយការ ចំណាយ ។

## ជំពូកទី ៣ : អាករវិភាជន៍មូលដ្ឋាន

### ១. មុខងារនៃអាករវិភាជន៍មូលដ្ឋាន

អាករវិភាជន៍មូលដ្ឋានមិនមែនជាអាករដែលប្រមូលនៅក្នុងមូលដ្ឋាននោះទេ ។ អាករនេះត្រូវបានចែកចាយពីរដ្ឋាភិបាល-កណ្តាល ទៅអោយខេត្ត និងក្រុង ។ ក្នុងចំណោមអាជ្ញាធរមូលដ្ឋានចំនួន ១.៨៦៧ ប្រហែល ៩២% ទទួលអាករវិភាជន៍-មូលដ្ឋានធម្មតាពីរតនាគារជាតិ ចំនួនបួនដងនៅឆ្នាំសារពើពន្ធនីមួយៗ ។

ប្រព័ន្ធនេះមិនបានប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងការបំពេញមុខងាររបស់ខ្លួននោះទេ ។

ប្រព័ន្ធអាករវិភាជន៍មូលដ្ឋាន គឺជាប្រព័ន្ធមួយដែលរដ្ឋាភិបាលកណ្តាលឧបត្ថម្ភនូវចំណែកខ្លះនៃចំណូលជាហិរញ្ញវត្ថុដែលប្រមូលជាអាករជាតិ ដើម្បីបែងចែកដល់រដ្ឋាភិបាលមូលដ្ឋាននូវចំណូលដែលចាំបាច់ដល់ការរក្សាបាននូវសេវាសាធារណៈក្នុងកម្រិតសមស្រប ។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលកណ្តាលធ្វើការគណនាចំនួនទឹកប្រាក់ដែលផ្តល់រដ្ឋាភិបាលមូលដ្ឋាន ទៅតាមសមាមាត្រនៃកង្វះចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន ដោយពិចារណាលើចំណូលជាហិរញ្ញវត្ថុស្តង់ដារនីយកម្ម និងតម្រូវការរបស់រដ្ឋាភិបាលមូលដ្ឋាននីមួយៗ ។

### ២. ប្រភពនៃអាករវិភាជន៍មូលដ្ឋាន

ជាដំបូង ប្រភពនៃអាករវិភាជន៍មូលដ្ឋាន គឺជាភាគរយជាក់លាក់នៃអាករបីប្រភេទសំខាន់ៗរបស់រដ្ឋាភិបាលកណ្តាល ដែលច្បាប់ស្តីពីអាករមូលដ្ឋាន (ឆ្នាំ១៩៥០) បានចាត់ទុកជាចំណូលសម្រាប់អាជ្ញាធរមូលដ្ឋាន។ ទឹកប្រាក់ត្រូវបានបែងចែកដោយផ្អែកលើរូបមន្តមួយដែលបានបង្កើតឡើង ដើម្បីលើកកំពស់សមភាពនៅក្នុងចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន និងដើម្បីធានានូវរដ្ឋបាលរបស់រដ្ឋាភិបាលកណ្តាលដែលរៀបចំផែនការបានល្អ ។

ចំនួនទឹកប្រាក់សរុបនៃអាករវិភាជន៍មូលដ្ឋាននៅក្នុងឆ្នាំសារពើពន្ធ២០០៦ ត្រូវបានគណនាជាប្រាក់ដូចខាងក្រោម :

ក. ៣២% នៃទិន្នផលសរុបនៃអាករលើប្រាក់ចំណូល និងអាករលើសុរា

ខ. ៣៥.៨% នៃទិន្នផលសរុបនៃអាករលើសាជីវកម្ម

គ. ២៩.៥% នៃទិន្នផលនៃអាករលើការប្រើប្រាស់

ឃ. ២៥% នៃទិន្នផលអាករលើថ្នាំជក់

* អត្រានៃទិន្នផលសរុបនៃអាករលើសាជីវកម្មនឹងមានការប្រែប្រួលរហូលដល់ ៣៤% ចាប់ពីឆ្នាំសារពើពន្ធ២០០៧ តទៅ។

### ៣. អាករវិភាជន៍ធម្មតា និងអាករវិភាជន៍ពិសេស

អាករវិភាជន៍មូលដ្ឋានចែកចេញជាអាករវិភាជន៍ធម្មតា និងអាករវិភាជន៍ពិសេស ។ ចំនួនទឹកប្រាក់នៃអាករវិភាជន៍ធម្មតា-គឺ ៩៤% នៃអាករវិភាជន៍មូលដ្ឋានសរុប និងអាករវិភាជន៍ពិសេស គឺ ៦% ។

រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍បែងចែកទឹកប្រាក់សរុបនៃអាករវិភាជន៍ធម្មតាដល់រដ្ឋាភិបាលមូលដ្ឋានដែលកម្រិតស្តង់ដារនៃចំណូលទាបជាងចំណាយ ដើម្បីបំពេញបន្ថែមចំពោះកង្វះខាត ។ អាករវិភាជន៍ពិសេសត្រូវបានផ្តល់ជូន

## ៤. ផលធៀបនៃបន្ទុកអាករ

មុនសង្គ្រាមលោកលើកទី ២ (ឆ្នាំ១៩៣៤ ដល់ឆ្នាំ១៩៣៦) ផលធៀបនៃបន្ទុកអាករចំពោះចំណូលជាតិសរុបនៅតែមានកម្រិតទាបគឺត្រឹមតែ ១២,៩% (អាករជាតិចំនួន ៨,៥% អាករមូលដ្ឋានចំនួន ៤,៤%) ។ ប៉ុន្តែ ផលធៀបនេះបានកើនឡើងដល់ ២៨,៤% (អាករជាតិចំនួន ២៣,២% អាករមូលដ្ឋានចំនួន ៥,២%) នៅក្នុងឆ្នាំសារពើពន្ធ១៩៤៩ ។ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយបន្ទុកបែបនេះ ផលធៀបបានធ្លាក់ចុះដល់ ១៨,០% (អាករជាតិចំនួន ១២,២% អាករមូលដ្ឋានចំនួន ៥,៨%) នៅក្នុងឆ្នាំ សារពើពន្ធ១៩៦៥ ។ ក្រោយឆ្នាំ១៩៦៥ ផលធៀបបានកើនឡើងជាលំដាប់ និងឡើងដល់ ២៧,៦% (អាករជាតិចំនួន ១៧,៧% អាករមូលដ្ឋានចំនួន ៩,៩%) នៅក្នុងឆ្នាំសារពើពន្ធ១៩៨៩ ។ នៅក្នុងឆ្នាំសារពើពន្ធ២០០៥ ផលធៀបមាន ២៣,៧% (អាករ ជាតិចំនួន ១៤,២% អាករមូលដ្ឋានចំនួន ៩,៥%) ។ បច្ចុប្បន្ននេះ ផលធៀបនៃបន្ទុកអាកររបស់ប្រទេសជប៉ុនហាក់ដូចជាមិនសូវ ខ្ពស់ដូចប្រទេសដទៃទៀតទេ គិតមកទល់នឹងត្រឹមឆ្នាំសារពើពន្ធ២០០៤ : ចក្រភពអង់គ្លេសចំនួន ៣៧,១% សហរដ្ឋអាមេរិកចំនួន ២៣,២% និងអាល្លឺម៉ង់ចំនួន ២៧,៥% ។ ទាំងហិរញ្ញវត្ថុសាធារណៈជាតិ និងមូលដ្ឋានកំពុងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ បន្ទាប់ពីការផ្ទុះ "សន្ទុះខ្លាំង" និងបានក្លាយជាបញ្ហាបន្ទាន់បំផុត ដើម្បីបង្កើនចំណូល ជាអាករអោយបានច្រើន និងកាត់បន្ថយការ ចំណាយ ។

## ជំពូកទី ៣ : អាករវិភាជន៍មូលដ្ឋាន

### ១. មុខងារនៃអាករវិភាជន៍មូលដ្ឋាន

អាករវិភាជន៍មូលដ្ឋានមិនមែនជាអាករដែលប្រមូលនៅក្នុងមូលដ្ឋាននោះទេ ។ អាករនេះត្រូវបានចែកចាយពីរដ្ឋាភិបាល-កណ្តាល ទៅអោយខេត្ត និងក្រុង ។ ក្នុងចំណោមអាជ្ញាធរមូលដ្ឋានចំនួន ១.៨៦៧ ប្រហែល ៩២% ទទួលអាករវិភាជន៍-មូលដ្ឋានធម្មតាពីរតនាគារជាតិ ចំនួនបួនដងនៅឆ្នាំសារពើពន្ធនីមួយៗ ។

ប្រព័ន្ធនេះមិនបានប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងការបំពេញមុខងាររបស់ខ្លួននោះទេ ។

ប្រព័ន្ធអាករវិភាជន៍មូលដ្ឋាន គឺជាប្រព័ន្ធមួយដែលរដ្ឋាភិបាលកណ្តាលឧបត្ថម្ភនូវចំណែកខ្លះនៃចំណូលជាហិរញ្ញវត្ថុដែលប្រមូលជាអាករជាតិ ដើម្បីបែងចែកដល់រដ្ឋាភិបាលមូលដ្ឋាននូវចំណូលដែលចាំបាច់ដល់ការរក្សាបាននូវសេវាសាធារណៈក្នុងកម្រិតសមស្រប ។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលកណ្តាលធ្វើការគណនាចំនួនទឹកប្រាក់ដែលផ្តល់រដ្ឋាភិបាលមូលដ្ឋាន ទៅតាមសមាមាត្រនៃកង្វះចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន ដោយពិចារណាលើចំណូលជាហិរញ្ញវត្ថុស្តង់ដារនីយកម្ម និងតម្រូវការរបស់រដ្ឋាភិបាលមូលដ្ឋាននីមួយៗ ។

### ២. ប្រភពនៃអាករវិភាជន៍មូលដ្ឋាន

ជាដំបូង ប្រភពនៃអាករវិភាជន៍មូលដ្ឋាន គឺជាភាគរយជាក់លាក់នៃអាករបីប្រភេទសំខាន់ៗរបស់រដ្ឋាភិបាលកណ្តាល ដែលច្បាប់ស្តីពីអាករមូលដ្ឋាន (ឆ្នាំ១៩៥០) បានចាត់ទុកជាចំណូលសម្រាប់អាជ្ញាធរមូលដ្ឋាន។ ទឹកប្រាក់ត្រូវបានបែងចែកដោយផ្អែកលើរូបមន្តមួយដែលបានបង្កើតឡើង ដើម្បីលើកកំពស់សមភាពនៅក្នុងចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន និងដើម្បីធានានូវរដ្ឋបាលរបស់រដ្ឋាភិបាលកណ្តាលដែលរៀបចំផែនការបានល្អ ។

ចំនួនទឹកប្រាក់សរុបនៃអាករវិភាជន៍មូលដ្ឋាននៅក្នុងឆ្នាំសារពើពន្ធ២០០៦ ត្រូវបានគណនាជាប្រាក់ដូចខាងក្រោម :

ក. ៣២% នៃទិន្នផលសរុបនៃអាករលើប្រាក់ចំណូល និងអាករលើសុរា

ខ. ៣៥,៨% នៃទិន្នផលសរុបនៃអាករលើសាជីវកម្ម

គ. ២៩,៥% នៃទិន្នផលនៃអាករលើការប្រើប្រាស់

ឃ. ២៥% នៃទិន្នផលអាករលើថ្នាំជក់

* អត្រានៃទិន្នផលសរុបនៃអាករលើសាជីវកម្មនឹងមានការប្រែប្រួលរហូតដល់ ៣៤% ចាប់ពីឆ្នាំសារពើពន្ធ២០០៧ តទៅ។

### ៣. អាករវិភាជន៍ធម្មតា និងអាករវិភាជន៍ពិសេស

អាករវិភាជន៍មូលដ្ឋានចែកចេញជាអាករវិភាជន៍ធម្មតា និងអាករវិភាជន៍ពិសេស ។ ចំនួនទឹកប្រាក់នៃអាករវិភាជន៍ធម្មតា-គឺ ៩៤% នៃអាករវិភាជន៍មូលដ្ឋានសរុប និងអាករវិភាជន៍ពិសេស គឺ ៦% ។

រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍បែងចែកទឹកប្រាក់សរុបនៃអាករវិភាជន៍ធម្មតាដល់រដ្ឋាភិបាលមូលដ្ឋានដែលកម្រិតស្តង់ដារនៃចំណូលទាបជាងចំណាយ ដើម្បីបំពេញបន្ថែមចំពោះកង្វះខាត ។ អាករវិភាជន៍ពិសេសត្រូវបានផ្តល់ជូន

អាជ្ញាធរមូលដ្ឋានអាស្រ័យទៅតាមតម្រូវការហិរញ្ញវត្ថុវិសាមញ្ញ (ឧទាហរណ៍ ការចំណាយបណ្តោះអាសន្នសម្រាប់វិធានការដើម្បីការពារគ្រោះមហន្តរាយធម្មជាតិ) ដែលមិនអាចបំពេញដោយការផ្តល់អាករវិភាជន៍ធម្មតា ។

## ៤. ការផ្តល់អាករវិភាជន៍ធម្មតា

ទំហំទឹកប្រាក់នៃអាករវិភាជន៍ធម្មតាដែលត្រូវផ្តល់ជូនរដ្ឋាភិបាលមូលដ្ឋានត្រូវបានគណនា ដោយប្រើប្រាស់រូបមន្តដូចខាងក្រោម :

អាករវិភាជន៍ធម្មតា = តម្រូវការហិរញ្ញវត្ថុស្តង់ដារ - ចំណូលហិរញ្ញវត្ថុស្តង់ដារ

**ទំហំទឹកប្រាក់នៃអាករវិភាជន៍ធម្មតា (ឧទាហរណ៍នៃខេត្តមួយ)**




ក. <u>តម្រូវការហិរញ្ញវត្ថុស្តង់ដារ</u>

ទំហំទឹកប្រាក់នៃតម្រូវការហិរញ្ញវត្ថុស្តង់ដារ គឺជាចំណាយស្តង់ដារសរុបរបស់អាជ្ញាធរមូលដ្ឋានមួយដែលគណនាអាស្រ័យទៅតាមមុខងាររៀងៗខ្លួន ឧទាហរណ៍ នគរបាល ការការពារអគ្គិភ័យ សុខុមាលភាពមនុស្សចាស់ ការសាងសង់ផ្លូវថ្នល់ អប់រំ ។ល។

ចំណាយជាស្តង់ដារសម្រាប់មុខងារនីមួយៗត្រូវបានគណនាដូចខាងក្រោម :

មុខងារសេវាពិសេស : ទំហំទឹកប្រាក់នៃឯកតាវាស់វែង × ថ្លៃឯកតា × មេគុណកែតម្រូវ

ម្យ៉ាងវិញទៀត មានកត្តាបួននៅក្នុងរូបមន្ត ។

(ក) មុខងារសេវា

មុខងាររបស់រដ្ឋាភិបាលមូលដ្ឋានត្រូវបានធ្វើចំណាត់ថ្នាក់ ដើម្បីវាស់វែងតម្រូវការហិរញ្ញវត្ថុ ដូចជា នគរបាល ការការពារអគ្គិភ័យ ការអប់រំបឋមសិក្សា និងមធ្យមសិក្សា ។ល។

(ខ) ឯកតាវាស់វែង

ចំពោះមុខងារសេវានីមួយៗ សូចនាករមួយត្រូវបានជ្រើសរើសដើម្បីវាស់វែងតម្រូវការហិរញ្ញវត្ថុ ដែលធានានូវកម្រិតមួយចំនួននៃសមត្ថភាពរបស់សេវា ។ ជាឧទាហរណ៍ ចំនួនមន្ត្រីនគរបាលដែលប្រើប្រាស់ដោយរដ្ឋាភិបាលខេត្តត្រូវបានជ្រើសរើសជាឯកតាវាស់វែងសម្រាប់ការការពារពីនគរបាល ។ នៅក្នុងការគណនាជាក់ស្តែង ទំហំទឹកប្រាក់នៃឯកតាវាស់វែងនីមួយៗចំពោះអាជ្ញាធរខេត្តត្រូវបានកំណត់ ដោយផ្អែកលើស្ថិតិផ្លូវការ និងប្រភពអាចទុកចិត្តបានផ្សេងទៀត ។

(គ) ថ្លៃឯកតា

ចំពោះឯកតាវាស់វែងនីមួយៗ ថ្លៃក្នុងមួយឯកតា (ថ្លៃឯកតា) ត្រូវបានកំណត់ក្នុងកម្រិតមួយថេរ ។ ជាឧទាហរណ៍ ថ្លៃឯកតា សម្រាប់ការការពារពីនគរបាលត្រូវបានកំណត់ត្រឹម ៩.៤០៨ ពាន់យ៉េន សម្រាប់មន្ត្រីនគរបាលម្នាក់ និងការសាងសង់ផ្លូវថ្នល់គឺ ២.៧៩០ ពាន់យ៉េន ក្នុង ១ គីឡូម៉ែត្រ សម្រាប់ឆ្នាំសារពើពន្ធ២០០៦ ។ ថ្លៃឯកតាសម្រាប់មុខងារនីមួយៗត្រូវបានគណនា ដោយផ្អែកលើការចំណាយស្តង់ដារនៃអាជ្ញាធរមូលដ្ឋានកម្រិតស្តង់ដារ ។

(ឃ) មេគុណកែតម្រូវ

មេគុណកែតម្រូវត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងអំពីភាពខុសគ្នានៃថ្លៃរដ្ឋបាល ក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋានដែលមានល័ក្ខខ័ណ្ឌភូមិសាស្ត្រ អាកាសធាតុ និងសង្គមផ្សេងគ្នា ។ ជាឧទាហរណ៍ ថ្លៃសាងសង់ផ្លូវថ្នល់ នៅប៉ែកខាងជើងនៃប្រទេស មានកម្រិតខ្ពស់ជាងនៅប៉ែកខាងត្បូងពីព្រោះ មានទឹកកក និងព្រិលច្រើន នៅសិសិររដូវ ដែលមិនត្រឹមតែពន្យារពេលការងារសាងសង់ប៉ុណ្ណោះទេ ថែមទាំងតម្រូវអោយមានគ្រឿះផ្លូវរឹងមាំទៀតផង ។

អាស្រ័យហេតុនេះ ថ្លៃឯកតាត្រូវកាត់បន្ថយ ឬបង្កើនអោយបានត្រឹមត្រូវស្របតាមល័ក្ខខ័ណ្ឌទាំងនេះ ។ ប៉ុន្តែ ដោយសារថ្លៃឯកតាត្រូវបានកំណត់ក្នុងកម្រិតមួយថេរ តម្លៃជាតួលេខនៃឯកតាវាស់វែងត្រូវបានកាត់បន្ថយ ឬបង្កើន ជំនួសអោយការកែប្រែថ្លៃឯកតា ។

ខ. <u>ចំណូលហិរញ្ញវត្ថុស្តង់ដារ</u>

ចំណូលហិរញ្ញវត្ថុស្តង់ដារត្រូវបានគណនាដោយរូបមន្តមួយដែលឆ្លុះបញ្ចាំងអំពីសមត្ថភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមូលដ្ឋាន ។ វាគឺជាការបូកសរុបនៃទំហំទឹកប្រាក់ប៉ាន់ស្មាននៃចំណូលដែលបានមកពីអាករមូលដ្ឋាន និងអាករប្រហាក់ប្រហែលផ្សេងទៀត ដែលត្រូវបានគណនាដោយផ្អែកលើអត្រាអាករស្តង់ដារពាក់ព័ន្ធ និងចំណូលដែលបានមកពីអាករផ្ទេរមូលដ្ឋាន ។

ចំនួនសរុប (១០០%) នៃអាករផ្ទេរមូលដ្ឋានសម្រាប់អាជ្ញាធរមូលដ្ឋាននីមួយៗ ត្រូវបានបញ្ចូលទៅក្នុងការគណនាចំណូលហិរញ្ញវត្ថុស្តង់ដាររបស់អាជ្ញាធរមូលដ្ឋាន ហើយមានត្រឹមតែ ៧៥% (ចាប់តាំងពីឆ្នាំសារពើពន្ធ២០០៣ រហូតដល់ ៨០% (អាករខេត្ត) ឬ ៧៥% (អាករក្រុង)) នៃអាករមូលដ្ឋានសរុបប៉ុណ្ណោះដែលត្រូវបានរាប់បញ្ចូល ដើម្បីអោយថវិកាដែលនៅសល់អាចត្រូវបានប្រើប្រាស់ដោយសេរី ដើម្បីកែលម្អកម្រិតសកម្មភាពរដ្ឋបាលរបស់អាជ្ញាធរនីមួយ ។

### ៥. ការផ្តល់អាករវិភាជន៍ពិសេស

អាករវិភាជន៍ពិសេសបំពេញបន្ថែមអាករវិភាជន៍ធម្មតា ។ អត្ថិភាពនៃអាករនេះគឺថា តាមលក្ខណៈរបស់វា អាករវិភាជន៍ធម្មតាមិនអាចឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុពិសេសរបស់អាជ្ញាធរមូលដ្ឋានបានឡើយ ។ ជាឧទាហរណ៍ ប្រហែលជា

មានការថយចុះនូវចំណូលហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋានណាមួយ និងមានការកើនឡើងនូវការចំណាយរដ្ឋបាល នៅក្នុងកំឡុងឆ្នាំសារពើពន្ធណាមួយ ដោយសារគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ ឬការបង្រួមក្រុងចូលគ្នា ។
ម្យ៉ាងវិញទៀត អាចមានចំណូលបន្ថែមពិសេសដែលបានមកពីអាជីវកម្មឆ្នោតផ្សងសំណាង ការប្រណាំងសេះ ។ល។ ក្នុងករណីបែបនេះ ជាការមិនត្រឹមត្រូវឡើយដែលមិនអើពើចំពោះល័ក្ខខ័ណ្ឌវិសាមញ្ញរបស់អាជ្ញាធរមូលដ្ឋាន ។ អាករវិភាជន៍ពិសេសត្រូវបានប្រើប្រាស់សម្រាប់ឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌពិសេសទាំងនេះ ។ ទំហំទឹកប្រាក់ពិតប្រាកដនៃចំណូលពីអាករវិភាជន៍ពិសេស ដែលត្រូវផ្តល់ជូនអាជ្ញាធរមូលដ្ឋាននីមួយៗ ត្រូវបានកំណត់ជារៀងរាល់ឆ្នាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ (ក្នុងករណីខេត្ត ឬក្រុង) និងដោយអភិបាលខេត្ត (ក្នុងករណីឃុំ ឬភូមិ) ។

## ៦. ទំហំទឹកប្រាក់នៃអាករវិភាជន៍មូលដ្ឋាន

ទំហំទឹកប្រាក់នៃអាករវិភាជន៍មូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៦ មានចំនួន ១៥.៩៥៥.៣ ពាន់លានយ៉េន (អាករវិភាជន៍ធម្មតាមានចំនួន ១៥.០៤០.៨ ពាន់លានយ៉េន និងអាករវិភាជន៍ពិសេសមានចំនួន ៩៥៤.៥ ពាន់លានយ៉េន) ត្រូវជា ១៩.១% នៃចំណូលសរុបរបស់អាជ្ញាធរមូលដ្ឋាន។ នៅក្នុងករណីដែលចំណូលហិរញ្ញវត្ថុស្តង់ដារលើសពីតម្រូវការហិរញ្ញវត្ថុស្តង់ដារ ដែលបង្ហាញអោយឃើញថារដ្ឋាភិបាលមូលដ្ឋាននោះមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ អាករវិភាជន៍មូលដ្ឋានមិនត្រូវផ្តល់ជូនឡើយ ។
ក្នុងចំណោមខេត្តទាំង ៤៧ និងក្រុងទាំង ១.៨២០ (គិតទាំងសង្កាត់ពិសេសរបស់ក្រុងតូក្យូដែលត្រូវបានរាប់ថាជាក្រុងមួយដែរ) មានតែរាជធានីតូក្យូ ខេត្តអៃជី និងក្រុង ១៦៩ ប៉ុណ្ណោះ ដែលមិនត្រូវបានផ្តល់អាករវិភាជន៍មូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៦ ។

## ៧. ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន

នៅក្នុងឆ្នាំ១៩៩៩ ប្រព័ន្ធឧបត្ថម្ភកធនពិសេសដល់មូលដ្ឋានបានចាប់ផ្តើមបំពេញបន្ថែមដល់កង្វះខាតនៃចំណូលអាករមូលដ្ឋាន ដែលបណ្តាលមកពីការកាត់បន្ថយអាករជាអចិន្ត្រៃយ៍នៃកំណែទម្រង់អាករ នៅក្នុងឆ្នាំ១៩៩៩ ។ ប្រសិនបើប្រៀបធៀបទៅនឹងអាករវិភាជន៍មូលដ្ឋាន ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋានត្រូវបានចែកចាយពីរដ្ឋាភិបាលកណ្តាលដល់ខេត្ត និងក្រុងទាំងអស់ (រួមទាំងសង្កាត់ពិសេសផងដែរ) ។
នៅក្នុងឆ្នាំ២០០៦ ប្រព័ន្ធឧបត្ថម្ភកធនពិសេសសម្រាប់ជាវិភាជន៍ទ្រទ្រង់កុមារត្រូវបានបង្កើតឡើងដើម្បីបំពេញបន្ថែមដល់កង្វះខាតនៃចំណូលអាករមូលដ្ឋាន បណ្តាលមកពីរដ្ឋាភិបាលជាតិឈប់ទទួលបន្ទុកលើវិភាជន៍ទ្រទ្រង់កុមារ ។ ឧបត្ថម្ភកធនពិសេសសម្រាប់ជាវិភាជន៍ទ្រទ្រង់កុមារគឺជាប្រភេទមួយនៃឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន ។

## បំណែងចែកមិនស្មើគ្នានៃចំណូលអាករខេត្ត (ឆ្នាំសារពើពន្ធ២០០៥)

## អាករខេត្តក្នុងប្រជាជនម្នាក់នៅក្នុងឆ្នាំសារពើពន្ធ២០០៥




(ឯកតា : ពាន់យ៉េន)

## មុខងារកែតម្រូវសារពើពន្ធរបស់ប្រព័ន្ធអាករវិភាជន៍មូលដ្ឋាន

ប្រព័ន្ធអាករវិភាជន៍មូលដ្ឋានត្រូវបានអនុវត្ត ដើម្បីធានានូវធនធានសារពើពន្ធដល់រដ្ឋាភិបាលមូលដ្ឋាន និងដើម្បីកែតម្រូវអតុល្យភាពនៃធនធានសារពើពន្ធក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋាន ។

| ០ឈ្មោះក្រុម | ចំណូលទូទៅ | ចំណូល អាករខេត្ត | | ចំណូលអាករខេត្តនៃអាករវិភាជន៍ | |
|---|---|---|---|---|---|
| | ក | ខ | ខ/ក (%) | មូលដ្ឋាន (គ) | គ/ក (%) |
| អុកកៃដូ | ២.៦៣៧,៨០៦ | ៥៥០.៨៧៩ | ២១ | ៧១០.១២៧ | ២៧ |
| អៅម៉ូរី | ៧៤៨.២២១ | ១៣៧.១៥៣ | ១៨ | ២៣៦.០២០ | ៣២ |
| អ៊ីវ៉ាត់ | ៧១៩.៨៣៣ | ១២៤.១០៥ | ១៧ | ២៤០.០៨១ | ៣៣ |
| មីយ៉ាហ្គិ | ៨០៤.៨១២ | ២៥១.៩៧៥ | ៣១ | ១៨៤.៤៧៦ | ២៣ |
| អាគីតា | ៦៧២.១៦៣ | ៩៩.៨៧២ | ១៥ | ២០៨.២៩៣ | ៣១ |
| យ៉ាម៉ាហ្គាតា | ៥៩៨.៣២០ | ១១០.៨៧១ | ១៩ | ១៨៨.៦៧១ | ៣១ |
| ហ្វូគូស៊ីម៉ា | ៨៧៤.៨១៥ | ២២២.៧២០ | ២៥ | ២៣៧.៦៦៨ | ២៧ |
| អ៊ីបារ៉ាគី | ៩៩៩.២៨៧ | ៣៥៣.៨៨៤ | ៣៥ | ១៨៥.៥៦២ | ១៩ |
| តូជីហ្គិ | ៨០៦.៤៧១ | ២៥០.០៧៦ | ៣១ | ១៣៧.៥០៥ | ១៧ |
| ហ្គុនណា | ៧៤៥.៩៦៧ | ២២៨.០៨៦ | ៣១ | ១៤៧.១៣២ | ២០ |
| សៃតាម៉ា | ១.៥១៧.០០៨ | ៦៨១.៧១៥ | ៤៥ | ២៣៨.៩១៥ | ១៦ |
| ជីបា | ១.៤៥៩.១៦៨ | ៦៣៥.៨៨៧ | ៤៤ | ២១៨.៤៧៥ | ១៥ |
| តូក្យូ | ៦.៤៣៣.៣៨៧ | ៤.៦០២.៧១៨ | ៧២ | ០ | ០ |
| កាណាហ្គាវ៉ា | ១.៧២៧.៧២៤ | ៩៩៩.៧៤៧ | ៥៨ | ១២២.៨៩៣ | ៧ |
| នីអ៊ីហ្គាតា | ១.២៥១.៩៧០ | ២៦០.២៣០ | ២១ | ២៩៧.៧៥៤ | ២៤ |
| តូយ៉ាម៉ា | ៥២៥.១៥៣ | ១២៦.៨២៤ | ២៤ | ១៤០.៣២៨ | ២៧ |
| អ៊ីស៊ីកាវ៉ា | ៥២៧.៨៥០ | ១៣២.១៧៩ | ២៥ | ១៤១.៤៩១ | ២៧ |
| ហ្វូគូអ៊ី | ៤៩២.៤២២ | ១០២.៦២៤ | ២១ | ១២៦.៨៨១ | ២៦ |
| យ៉ាម៉ាណាស៊ី | ៤៧៤.៦៥៤ | ១០៤.៧៦២ | ២២ | ១២៥.២០៤ | ២៦ |
| ណាហ្គាណូ | ៨៥៣.២៣៧ | ២៣៥.៧៥២ | ២៨ | ២៣៨.១៣៤ | ២៦ |
| ជីហ្វូយ | ៧៨៦.៦៦៦ | ២២៣.០២៥ | ២៨ | ១៩១.៤៨៥ | ២៤ |
| ស៊ីហ្សូអូកា | ១.១០៧.៨៥៤ | ៤៨៧.១២០ | ៤៤ | ១៦៩.១៤៧ | ១៥ |
| អៃជី | ២.០៨៥.៩២៧ | ១.០៨៨.៦៥៥ | ៥២ | ៨៧.៦៩២ | ៤ |
| ម៉ីយ៉េ | ៦៩៤.៩៦០ | ២២៧.៨៨៤ | ៣៣ | ១៥០.៧៦៩ | ២២ |
| ស៊ីហ្គា | ៤៩៨.២១៩ | ១៥៦.០០៤ | ៣១ | ១១៨.៤៥៨ | ២៤ |

| | | | | | |
|---|---|---|---|---|---|
| ក្យូតូ | ៨៥២.២០៩ | ២៩៩.៨៩៥ | ៣៥ | ១៩២.៩៦១ | ២៣ |
| អូសាកា | ២.៦២៩.៣១៦ | ១.១១៣.៣៧៧ | ៤២ | ២៧៩.០០២ | ១១ |
| ហ៊ីយ៉ូហ្គោ | ២.៦៤៦.៦៣០ | ៥៧៣.៣៩៧ | ២២ | ៣៨២.៦៦៦ | ១៤ |
| ណារ៉ា | ៤៧៨.២៧៦ | ១១៨.១៦៥ | ២៥ | ១៤៦.៤៦៣ | ៣១ |
| វ៉ាកាយ៉ាម៉ា | ៥១២.៤៧៩ | ៨៨.៣៥៦ | ១៧ | ១៦៣.៦៧៥ | ៣២ |
| តូត្តូរី | ៣៨៥.៤៣២ | ៥៥.៨៧២ | ១៤ | ១២៩.១២៥ | ៣៤ |
| ស៊ីម៉ាណេ | ៥៦២.៤៤២ | ៦៧.២៧៥ | ១២ | ១៨៤.៥៨៤ | ៣៣ |
| អូកាយ៉ាម៉ា | ៧៨០.៦៦៨ | ២២៥.០៣០ | ២៩ | ១៨០.៦៩៣ | ២៣ |
| ហ៊ីរ៉ូស៊ីម៉ា | ៩៨៣.៣៥៥ | ៣២០.៨១១ | ៣៣ | ២០៨.៨៤៧ | ២១ |
| យ៉ាម៉ាហ្គូជី | ៧៣៨.៦១២ | ១៦៥.៥២៣ | ២២ | ១៨១.៥៧៣ | ២៥ |
| តុគូស៊ីម៉ា | ៥៤៧.៦៥៥ | ៨៥.១៦២ | ១៦ | ១៤១.៥២៣ | ២៦ |
| កាហ្គាវ៉ា | ៤៥៨.៣៧៣ | ១១១.៦៩២ | ២៤ | ១១៦.៥៣៣ | ២៥ |
| អេអ៊ីម៉េ | ៦៥៤.៥៨៧ | ១៣៧.២១១ | ២១ | ១៧៨.៤៧២ | ២៧ |
| កូជី | ៤៦៥.៧៤៧ | ៦៣.៨៧៧ | ១៤ | ១៧២.៥៤០ | ៣៧ |
| ហ្វូគូអូកា | ១.៤៨១.០៥៩ | ៥១០.១៣៦ | ៣៤ | ២៨០.៣៣៤ | ១៩ |
| សាហ្គា | ៤២៥.៣៩៤ | ៨៤.៦៣៦ | ២០ | ១៣៨.៩៩០ | ៣៣ |
| ណាហ្គាសាគី | ៦៩២.៦៤១ | ១០៩.៤២៥ | ១៦ | ២៣៤.៥៨៧ | ៣៤ |
| គូម៉ាម៉ូតុ | ៧៣៩.៩២៧ | ១៦០.៨២៥ | ២២ | ២១៩.៥០៨ | ៣០ |
| អូអ៊ីតា | ៥៩០.១៨៧ | ១១៤.០១៨ | ១៩ | ១៨២.២១៨ | ៣១ |
| មីយ៉ាហ្សាគី | ៦១៣.៩០៥ | ៥៦.៦៦១ | ១៦ | ១៩០.៥៩៦ | ៣១ |
| កាហ្គោស៊ីម៉ា | ៨៣១.៥៧៨ | ១៤៥.៤៤៤ | ១៧ | ២៨៣.៥១៨ | ៣៤ |
| អូគីណាវ៉ា | ៥៨៤.០៧៣ | ៥៥.៨២៥ | ១៦ | ១៨៩.៦៧៣ | ៣២ |
| សរុប ឬមធ្យមភាគ | ៤៨.៦៩៤.៥១៩ | ១៧.១៣៧.៣៦០ | ៣៥ | ៩.២២១.៦៤២ | ១៩ |

កំណត់សម្គាល់ : "ចំណូលទូទៅ" ដែលជាការផ្សំគ្នានៃចំណូលបានមកពីអាករវិភាជន៍មូលដ្ឋាន និងអាករផ្ទេរមូលដ្ឋាន គឺជាចំណូលដែលអាចត្រូវបានប្រើប្រាស់អាស្រ័យទៅតាមការវិនិច្ឆ័យដោយឯករាជ្យរបស់រដ្ឋាភិបាលមូលដ្ឋាន ។

## ជំពូកទី ៤ : ការបើកប្រាក់ពីរតនាគារជាតិ

### ១. ប្រភេទនៃការបើកប្រាក់ពីរតនាគារជាតិ

មានវិធីជាច្រើនសម្រាប់រដ្ឋាភិបាលកណ្តាលក្នុងការបើកមូលនិធិដល់រដ្ឋាភិបាលមូលដ្ឋាន ។ វិធីទាំងនេះត្រូវបានបែងចែកជាបីប្រភេទ : (១) ការបើកប្រាក់សម្រាប់អាជ្ញាធរមូលដ្ឋានដែលអនុវត្តគម្រោងជាតិដោយសារប្រសិទ្ធភាព និងសេដ្ឋកិច្ចមាត្រដ្ឋាន (២) ចំណែកជាកាតព្វកិច្ចរបស់រដ្ឋាភិបាលកណ្តាល ដោយផ្អែកលើទំនួលខុសត្រូវបែងចែកគ្នា រវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន និង (៣) ឧបត្ថម្ភកធន ។

(១) ការបើកប្រាក់សម្រាប់ការងារថ្នាក់ជាតិ

អាជ្ញាធរមូលដ្ឋានទទួលបន្ទុកគម្រោងជាតិនៅក្នុងវិស័យជាច្រើននៃរដ្ឋបាលថ្នាក់ជាតិ ។ រដ្ឋាភិបាលកណ្តាលត្រូវចេញថ្លៃសេវាទាំងនោះដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន នៅក្នុងទម្រង់ជាការបើកប្រាក់ពីរដ្ឋាភិបាលកណ្តាល ។

(២) ចំណែកជាកាតព្វកិច្ច

ជាគោលការណ៍ អាជ្ញាធរមូលដ្ឋានត្រូវទទួលរ៉ាប់រងលើចំណាយសម្រាប់កិច្ចការសាធារណៈមូលដ្ឋាន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែមានប្រាក់ចំណេញសម្រាប់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋាភិបាលកណ្តាល ការចំណាយទាំងអស់ ឬមួយផ្នែកត្រូវទទួលរ៉ាប់រងដោយរដ្ឋាភិបាលកណ្តាល ជាចំណែកជាកាតព្វកិច្ច ដើម្បីធានានូវការអនុវត្តប្រកបដោយភាពរលូន ។

(i) ចំណាយសម្រាប់កម្មវិធីពិសេស ឬកម្មវិធីថ្នាក់ជាតិ ដែលតម្រូវអោយផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលកណ្តាល ដើម្បីធានានូវការអនុវត្តយ៉ាងរលូន ។

មានគម្រោងបែបនេះដែលផ្តល់ផលប្រយោជន៍រួមសម្រាប់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ប៉ុន្តែ ត្រូវតែដឹកនាំដោយរដ្ឋាភិបាលមូលដ្ឋាន ដោយសារតែបទប្បញ្ញត្តិច្បាប់ និងបទបញ្ជារបស់គណៈរដ្ឋមន្ត្រី (ឧទាហរណ៍ ការចំណាយសម្រាប់ការអប់រំជាកាតព្វកិច្ច សាធារណៈសង្គ្រោះ មណ្ឌលសុខភាព ។ល។)

(ii) ការចំណាយសម្រាប់គម្រោងសាធារណការ ដែលត្រូវបានអនុវត្តដោយអាជ្ញាធរមូលដ្ឋាន ស្របតាមផែនការវឌ្ឍនភាពសេដ្ឋកិច្ចជាតិ (ឧទាហរណ៍ ការចំណាយសម្រាប់សាធារណការ ។ល។)

(iii) ការចំណាយសម្រាប់គម្រោងពាក់ព័ន្ធនឹងគ្រោះមហន្តរាយ (ឧទាហរណ៍ ការចំណាយសម្រាប់សង្គ្រោះគ្រោះមហន្តរាយ ការស្តារគ្រោះមហន្តរាយដែលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ។ល។)

(៣) ឧបត្ថម្ភកធន

ក្នុងចំណោមមុខងារជាច្រើនរបស់ខ្លួន រដ្ឋាភិបាលកណ្តាលផ្តល់ឧបត្ថម្ភកធនដល់អាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រជំរុញ និងលើកស្ទួយការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាន ។ ឧបត្ថម្ភកធនទាំងនេះមិនមែនជាកាតព្វកិច្ចទេ ហើយរដ្ឋាភិបាលកណ្តាលមានសិទ្ធិអំណាចក្នុងការបង្កើត ឬលុបបំបាត់ឧបត្ថម្ភកធន នៅពេលកាលៈទេសៈប្រែប្រួល ។

## ២. ចំណុចសំខាន់ៗនៃច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋាន

គោលការណ៍ ដែលតាមរយៈនោះ ការបើកប្រាក់ពីរតនាគារជាតិអាចត្រូវបានធ្វើឡើង មានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋាន ឆ្នាំ១៩៤៨ ។ ចំណុចសំខាន់ៗនៃច្បាប់នេះមានដូចតទៅ :

(១) ចំពោះចំណែកជាកាតព្វកិច្ចរបស់រដ្ឋាភិបាលកណ្តាល ប្រភេទនៃចំណាយ លក្ខណៈវិនិច្ឆ័យសម្រាប់ការគណនាចំណាយ និងផលធៀបដែលទទួលរ៉ាប់រងដោយរដ្ឋាភិបាលកណ្តាល ត្រូវចែងដោយច្បាប់ ឬបទបញ្ជារបស់គណៈរដ្ឋមន្ត្រី ។

(២) ទំហំទឹកប្រាក់ពិតប្រាកដ ដែលបើកពីរតនាគារជាតិ ត្រូវផ្អែកលើទំហំទឹកប្រាក់គ្រប់គ្រាន់ ក្នុងការរ៉ាប់រងចំណាយជាក់ស្តែងដើម្បីអោយអាជ្ញាធរមូលដ្ឋានអាចបំពេញមុខងាររបស់ខ្លួន ។

(៣) ការបើកប្រាក់ពីរតនាគារជាតិត្រូវធ្វើឡើងដោយរដ្ឋាភិបាលកណ្តាលអោយបានទាន់ពេលវេលា ដើម្បីប្រើប្រាស់សម្រាប់ទូទាត់ចំណាយពាក់ព័ន្ធផ្សេងៗ ។

(៤) អាជ្ញាធរមូលដ្ឋានដែលទទួលប្រាក់ពីរតនាគារជាតិត្រូវប្រើប្រាស់ប្រាក់នេះ អោយស្របតាមច្បាប់ និងបទបញ្ជាផ្សេងទៀត ហើយអាស្រ័យហេតុនេះ ក្រុមប្រឹក្សាសវនកម្មរបស់រដ្ឋាភិបាលកណ្តាលអាចធ្វើសវនកម្មលើការប្រើប្រាស់ប្រាក់ដែលអាជ្ញាធរមូលដ្ឋានបើកពីរតនាគារជាតិ ។

## ៣. ផលធៀបនៃចំណូលរបស់អាជ្ញាធរមូលដ្ឋាន

ការបើកប្រាក់ពីរតនាគារជាតិបានកើនឡើងគួរអោយកត់សម្គាល់បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ។ ផលធៀបនៃចំណូលសរុបរបស់អាជ្ញាធរមូលដ្ឋានបានកើនឡើងរហូតដល់ ១២,២% ។

## ៤. ការលំបាក និងកំណែទម្រង់នាពេលថ្មីៗ

ប្រព័ន្ធបើកប្រាក់ពីរតនាគារជាតិបានបង្ហាញនូវប្រសិទ្ធភាព ក្នុងការអនុញ្ញាតអោយរដ្ឋាភិបាលមូលដ្ឋានមិនត្រឹមតែរក្សាបាននូវរដ្ឋបាលក្នុងកម្រិតពេញចិត្តប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវចំណូលគ្រប់គ្រាន់សម្រាប់គម្រោងសាងសង់ខ្នាតធំ ដូចជាការស្តារឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិ ។ អាស្រ័យហេតុនេះ ទំហំទឹកប្រាក់ និងដែនកំណត់នៃការបើកប្រាក់ពីរតនាគារជាតិបានកើនឡើង និងពង្រីកជាលំដាប់ ។ ប៉ុន្តែ ការកើនឡើង និងការពង្រីកនេះបានបង្កអោយមានភាពសាំញ៉ាំដល់រចនាសម្ព័ន្ធនៃហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ហើយជាលទ្ធផលបានបង្កើននិន្នាការភ័ន្តច្រឡំទៅលើស្តង់ដារនៃការបែងចែករវាងទំនួលខុសត្រូវខាងរដ្ឋបាលរបស់រដ្ឋាភិបាលមូលដ្ឋាន និង រដ្ឋាភិបាលកណ្តាល ។ ដូចនេះប្រព័ន្ធត្រូវបានពិនិត្យមើលឡើងវិញជាបន្តបន្ទាប់ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានកំណែទម្រង់ដ៏សម្បើមនៃឧបត្ថម្ភធន រួមជាមួយនឹងការផ្ទេរប្រភពចំណូលជាអាករ និងកំណែទម្រង់ប្រព័ន្ធផ្តល់អាករមូលដ្ឋាន ដើម្បីលើកស្ទួយវិមជ្ឈការ ដូចជា ការលុបបំបាត់ឧបត្ថម្ភធន ហើយតាមពិតទៅ ការបើកប្រាក់ពីរតនាគារជាតិ ដែលមានចំនួន ៤,៧ សែនកោដិយ៉េន ត្រូវបានកាត់បន្ថយសម្រាប់រយៈពេលបីឆ្នាំ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៦ ។

**តារាងទី ៩ : ភាគរយនៃចំណូលពីការបើកប្រាក់ពីរដ្ឋាភិបាលកណ្តាលនៅក្នុងចំណូលសរុប របស់រដ្ឋាភិបាលមូលដ្ឋានទាំងអស់ (ឆ្នាំសារពើពន្ធ២០០៧ តាមការប៉ាន់ស្មាន)**

(គិតជាពាន់លានយ៉េន)

| បរិយាយ | ទំហំទឹកប្រាក់ | % |
|---|---|---|
| ចំណូលសរុបរបស់រដ្ឋាភិបាលមូលដ្ឋានទាំងអស់ | ៨៣.១២៦,១ | ១០០ |
| ចំណូលពីការបើកប្រាក់ពីរតនាគារជាតិ | ១០.១៧៣,៩ | ១២,២ |
| (១) ចំណែកជាកាតព្វកិច្ចរបស់រដ្ឋាភិបាលកណ្តាល ក្នុងការចំណាយលើបុគ្គលិកសម្រាប់ការអប់រំជាកាតព្វកិច្ចនៅតាមសាលារៀន | ១.៦៦៥,៩ | ២,០ |
| (២) ឧបត្ថម្ភកធន និងចំណែកជាកាតព្វកិច្ចរបស់រដ្ឋាភិបាលកណ្តាល ក្នុងចំណាយចរន្តខាងលើលើកលែងចំណុចទី (១) | ៤.៦៦៥,៤ | ៥,៦ |
| (៣) ឧបត្ថម្ភកធន និងចំណែកក្នុងការចំណាយមូលធនរបស់រដ្ឋាភិបាលកណ្តាល សម្រាប់សាធារណការ | ២.៨៥៤,៣ | ៣,៤ |
| (ក) សំណង់សាមញ្ញ | ២.៨២៥,១ | ៣,៤ |
| (ខ) ការសាងសង់ឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិ | ២៩,២ | ០,០ |
| (៤) ចំណែកជាកាតព្វកិច្ចរបស់រដ្ឋាភិបាលកណ្តាល ក្នុងកម្មវិធីបង្កើតការងារ | ០,០ | ០,០ |
| (៥) ចំណែករបស់រដ្ឋាភិបាលចំពោះក្រុងដែលមានទ្រព្យសម្បត្តិជាក់លាក់របស់រដ្ឋាភិបាលស្ថិតនៅ | ២៥,៩ | ០,០ |
| (៦) ឧបត្ថម្ភកធនសម្រាប់វិធានការសុវត្ថិភាពចរាចរណ៍ | ៨៤,៥ | ០,១ |
| (៧) ឧបត្ថម្ភកធនបន្ថែមដល់មូលដ្ឋានសម្រាប់ការសាងសង់ និងកែលម្អផ្លូវថ្នល់ | ៧០៩,៩ | ០,៩ |

ប្រភព : "កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋានសម្រាប់ឆ្នាំសារពើពន្ធ២០០៧" រៀបចំឡើងដោយក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

## ជំពូកទី ៥ ៖ សញ្ញាប័ណ្ណ/កម្ចីរបស់អាជ្ញាធរមូលដ្ឋាន

នៅពេលអាជ្ញាធរមូលដ្ឋានរៀបចំ និងសម្រេចគម្រោងសាងសង់ខ្នាតធំ ជាធម្មតា អាជ្ញាធរមូលដ្ឋានមិនមានលទ្ធភាពក្នុងការធ្វើហិរញ្ញវត្ថុដល់គម្រោងទាំងនេះ ដោយឯករាជ្យ និងដោយពេញលេញ ជាមួយនឹងចំណូលចរន្តរបស់ខ្លួនឡើយ ហើយត្រូវបង្ខំចិត្តទទួលយកមូលនិធិចាំបាច់តាមរយៈកម្ចីរយៈពេលវែង ។ នៅប្រទេសជប៉ុន មានឧបត្ថម្ភធនជាច្រើនប្រភេទរបស់រដ្ឋាភិបាលកណ្តាល សម្រាប់កម្មវិធីមូលធនរបស់អាជ្ញាធរមូលដ្ឋាន ដូចជា ការសាងសង់ផ្លូវថ្នល់ ការសាងសង់សាលារៀន និងការងារសាងសង់សម្រាប់ការស្តារឡើងវិញ បន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិ ។

### ១. សេវាដែលសញ្ញាប័ណ្ណ/កម្ចីរបស់អាជ្ញាធរមូលដ្ឋានអាចអនុវត្តបាន

នៅប្រទេសជប៉ុន ប្រាក់កម្ចីរបស់អាជ្ញាធរមូលដ្ឋានសម្រាប់រយៈពេលលើសពីមួយឆ្នាំសារពើពន្ធគឺសំដៅដល់ "សញ្ញាប័ណ្ណ/កម្ចីរបស់អាជ្ញាធរមូលដ្ឋាន" ហើយត្រូវស្ថិតនៅក្រោមបទបញ្ជាដែលចែងដោយច្បាប់ពាក់ព័ន្ធនិងច្បាប់ផ្សេងទៀត។ ច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋានមានកម្រិតសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋានត្រឹមសញ្ញាប័ណ្ណ/កម្ចី ដែលពាក់ព័ន្ធទៅនឹងប្រភេទសេវាមួយចំនួន ។ សេវាដែលសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលអាចអនុវត្តបាន ត្រូវបានធ្វើចំណាត់ថ្នាក់ជាបួនប្រភេទដូចខាងក្រោម ៖

(១) សេវាដែលនឹងបង្កើតចំណូលនាពេលអនាគតសម្រាប់សងសញ្ញាប័ណ្ណ ឬកម្ចី ឧទាហរណ៍ -- សេវាសហគ្រាសសាធារណៈ ។

(២) សេវាដើម្បីលើកកំពស់ការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគត ដែលនឹងលើកស្ទួយធនធានពីអាករមូលដ្ឋាន និងអាចអោយអាជ្ញាធរមូលដ្ឋានទទួលបានចំណូលសម្រាប់ការសងសញ្ញាប័ណ្ណ ឬមូលនិធិកម្ចី -- ឧទាហរណ៍ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ និងទីសំចតនាវា ។

(៣) សេវាដែលមានឥទ្ធិពលរយៈពេលយូរ (វាជាមូលហេតុសម្រាប់អាជ្ញាធរមូលដ្ឋានក្នុងការដាក់ភាគចំណែកនៃបន្ទុកហិរញ្ញវត្ថុទៅលើអាជ្ញាធរមូលដ្ឋានជំនាន់ក្រោយ) -- ឧទាហរណ៍ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ ។

(៤) សេវាដែលអាជ្ញាធរមូលដ្ឋានមានកាតព្វកិច្ចត្រូវផ្តល់ ដោយសារព្រឹត្តិការណ៍វិសាមញ្ញ និងមិនអាចព្យាករណ៍បាន-- ឧទាហរណ៍ ការសាងសង់ឡើងវិញ បន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិ ។

ក្រៅពីសេវាដែលបានរៀបរាប់ខាងលើ ប្រាក់កម្ចីសម្រាប់ស្ថាប័នាហិរញ្ញវត្ថុឡើងវិញរបស់អាជ្ញាធរមូលដ្ឋាន និងប្រាក់កម្ចីសម្រាប់បង់សោធននិវត្តន៍ត្រូវបានអនុញ្ញាត ក្នុងករណីមួយចំនួនប៉ុណ្ណោះ ។

### ២. ប្រព័ន្ធពិគ្រោះយោបល់សម្រាប់សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន

កាលពីមុន រដ្ឋាភិបាលមូលដ្ឋានចាំបាច់ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ឬអភិបាលខេត្តពាក់ព័ន្ធ ដើម្បីចេញសញ្ញាប័ណ្ណរយៈពេលវែង ឬធ្វើកម្ចីរយៈពេលវែង ។

ទោះជាយ៉ាងណាក៏ដោយ ដោយសារច្បាប់ស្តីពីវិមជ្ឈការពេញលេញបានចូលជាធរមាននៅក្នុងឆ្នាំ២០០០ ការកើនឡើងនៃសារៈសំខាន់ក្នុងការជំរុញឯករាជ្យតំបន់ បាននាំអោយមានការលុបបំបាត់ប្រព័ន្ធ "ផ្តល់ការឯកភាព" ហើយប្រព័ន្ធ "ពិគ្រោះ

យោបល់ដោយមានការជូនដំណឹង" ថ្មីបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៦ ។ ក្នុងប្រព័ន្ធនេះ រដ្ឋាភិបាលមូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយ រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ក្នុងករណីខេត្ត និងទីក្រុងចាត់តាំង ឬជាមួយអភិបាលខេត្តពាក់ព័ន្ធ ក្នុងករណី ជាក្រុងផ្សេងទៀត នៅពេលរដ្ឋាភិបាលមូលដ្ឋានមានផែនការផ្តល់កម្ចីរយៈពេលវែង ។ ប្រសិនបើមិនទទួលបានការព្រមព្រៀងទេ រដ្ឋាភិបាលមូលដ្ឋាននៅតែមិនអាចផ្តល់កម្ចីក្នុងមូលដ្ឋានដដែល ប៉ុន្តែ វិធានការហិរញ្ញវត្ថុ និងនីតិវិធីផ្តល់កម្ចីចេញនឹងមានភាពខុសគ្នា បើប្រៀបធៀបទៅនឹងការចេញសញ្ញាប័ណ្ណ ឬកម្ចីដែលមានការព្រមព្រៀង ។ លើសពីនេះទៅទៀត ផ្តើមចេញពីទស្សនៈរក្សាឥណទាននៃសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន "ប្រព័ន្ធព្រមានជាមុន" ក៏ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធថ្មីនេះផងដែរ ។ ប្រសិនបើទំហំទឹកប្រាក់នៃការសង ឬឱនភាពហិរញ្ញវត្ថុលើសពីកម្រិតជាក់លាក់ណាមួយនោះ ចាំបាច់ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ (ឬពីអភិបាលខេត្តក្នុងករណីក្រុង) ដើម្បីចេញសញ្ញាប័ណ្ណ ឬទទួលបានប្រាក់កម្ចី ។

## ៣. តួនាទីរបស់សញ្ញាប័ណ្ណ/កម្ចីមូលដ្ឋាន

សញ្ញាប័ណ្ណ និងកម្ចីរបស់រដ្ឋាភិបាលមូលដ្ឋានមានតួនាទីបួនសំខាន់ៗ ។

ទីមួយ សញ្ញាប័ណ្ណ/កម្ចីមូលដ្ឋានអាចអោយអង្គភាពសាធារណៈមូលដ្ឋានធ្វើហិរញ្ញប្បទានដល់គម្រោងសាធារណការទំហំធំ ដែលអង្គភាពសាធារណៈមូលដ្ឋានមិនអាចធ្វើហិរញ្ញប្បទានដោយប្រើប្រាស់ធនធានចំណូលទូទៅរបស់ខ្លួនបាន ហើយអាចអោយអង្គភាពសាធារណៈមូលដ្ឋានលើកស្ទួយការអនុវត្តគម្រោងទាំងនោះ និងធ្វើអោយមានការគ្រប់គ្រងហិរញ្ញវត្ថុរយៈពេលវែង តាមរយៈការពន្យាការសងប្រាក់ជាក់ស្តែងទៅឆ្នាំបន្ទាប់ៗ ។

ទីពីរ ធនធានសម្រាប់សងសញ្ញាប័ណ្ណ/កម្ចីមូលដ្ឋានអាចរកបាននៅក្នុងចំណូលអាករនាពេលអនាគត ដូចនេះ បន្ទុកនៃការទូទាត់ត្រូវធ្លាក់ទៅលើប្រជាជនដែលទទួលបានអត្ថប្រយោជន៍ពីគម្រោង ក្នុងចំណែកស្មើៗគ្នា ។

ទីបី សញ្ញាប័ណ្ណ/កម្ចីមូលដ្ឋានក៏ជួយរ៉ាប់រងកង្វះខាតខាងធនធានអាករមូលដ្ឋាន ។ល។ នៅក្នុងឆ្នាំសារពើពន្ធ ដែលសញ្ញា-ប័ណ្ណ/កម្ចីទាំងនោះត្រូវបានផ្តល់ ។

ទីបួន សញ្ញាប័ណ្ណ/កម្ចីមូលដ្ឋានផ្តល់ធនធានសម្រាប់គម្រោងខ្នាតធំ ដូចនេះ សញ្ញាប័ណ្ណ/កម្ចីមូលដ្ឋានអាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយសារពើពន្ធជាតិ ដោយការត្រួតពិនិត្យទំហំការងារដែលសម្រេចបាន តាមរយៈទំហំនៃសញ្ញាប័ណ្ណដែលបានចេញ ឬកម្ចីដែលបានទទួល ។

## ៤. ស្ថានភាពនៃសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន

ទំហំទឹកប្រាក់សរុបនៃសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋានមានបង្ហាញជូននៅក្នុងតារាងទី ១០ ។ ចំណែករបស់វានៅក្នុងចំណូលសរុបមាន ១១.៧% នៅក្នុងឆ្នាំសារពើពន្ធ២០០៧ ។ នាពេលថ្មីៗកន្លងទៅនេះ ទំហំទឹកប្រាក់បានថយចុះយ៉ាងឆាប់រហ័ស ដោយសារតែការធ្វើអោយហិរញ្ញវត្ថុមានភាពរឹងមាំ និងការត្រួតពិនិត្យចំណាយជាមូលធន ។

### តារាងទី ១០ : សញ្ញាប័ណ្ណ/កម្ចីអនុញ្ញាតរបស់រដ្ឋាភិបាលមូលដ្ឋាន (ឆ្នាំសារពើពន្ធ១៩៩៨ ដល់ឆ្នាំ២០០៧)

(គិតជាពាន់លានយ៉េន)

| បរិយាយ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|---|---|---|---|---|---|---|
| សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលសម្រាប់គណនីទូទៅ | ១១.០៣០ | ១១.២៨០ | ១១.១២៧ | ១១.៩១១ | ១២.៦៤៩ | ១៥.០៧២ | ១៤.១៤៥ | ១២.២៦២ | ១០.៨១៧ | ៩.៦៥៣ |
| សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលសម្រាប់សហគ្រាសសាធារណៈ | ៥.០៦៤ | ៥.១១៧ | ៥.១៨៤ | ៤.៥៨៩ | ៣.៨៧៥ | ៣.៤១៣ | ៣.៣៤០ | ៣.២៧៥ | ៣.១២៩ | ២.៨៥៨ |
| សរុប | ១៦.០៩៤ | ១៦.៣៩៧ | ១៦.៣១១ | ១៦.៥០០ | ១៦.៥២៤ | ១៨.៤៨៥ | ១៧.៤៨៤ | ១៥.៥៣៧ | ១៣.៩៤៧ | ១២.៥១១ |

កំណត់សម្គាល់ : "សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលសម្រាប់គណនីទូទៅ" គឺជាកម្ចីសម្រាប់គណនីសាមញ្ញ ។

### ៥. មូលនិធិសម្រាប់សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន

មូលនិធិសម្រាប់សញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋានមានដូចខាងក្រោម :

(១) មូលនិធិរដ្ឋាភិបាល

មូលនិធិរដ្ឋាភិបាលត្រូវបានយកចិត្តទុកដាក់យ៉ាងសំខាន់ រហូតដល់ឆ្នាំសារពើពន្ធ១៩៧៤ ហើយមានចំណែកយ៉ាងធំនៅក្នុងមូលនិធិសរុបសម្រាប់កម្ចីរបស់អាជ្ញាធរមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ មូលនិធិទាំងនេះបាន ថយចុះកាលពីពេលថ្មីៗកន្លងទៅនេះ ដូចនេះ ទំហំទឹកប្រាក់នៃមូលនិធិរបស់រដ្ឋាភិបាលមានកម្រិតតូចជាងទំហំទឹកប្រាក់នៃមូលនិធិរបស់ឯកជន។ មូលនិធិរដ្ឋាភិបាលមាន ជាពិសេស មូលនិធិកម្ចីសារពើពន្ធ មូលនិធិសន្សំ និងមូលនិធិធានារ៉ាប់រងប្រៃសណីយ៍ ជប៉ុន ។ មូលនិធិកម្ចីសារពើពន្ធបានថយចុះ ចាប់តាំងពីមានកំណែទម្រង់ដ៏សម្បើមនៅក្នុងការវិនិយោគ និងប្រព័ន្ធ ប្រាក់កម្ចីរបស់រតនាគារ នៅក្នុងឆ្នាំ២០០១ ចំណែកឯមូលនិធិសន្សំ និងមូលនិធិធានារ៉ាប់រងប្រៃសណីយ៍ជប៉ុន ជាគោលការណ៍នឹងត្រូវលុបបំបាត់នៅក្នុងឆ្នាំ២០០៧ ស្របតាមកំណែទម្រង់ឯកជនភាវូបនីយកម្មប្រៃសណីយ៍ ដែលបានចាប់ផ្តើមនៅឆ្នាំ២០០៥។

(២) មូលនិធិសាជីវកម្មហិរញ្ញវត្ថុជប៉ុនសម្រាប់សហគ្រាសក្រុងមូលនិធិសាជីវកម្មហិរញ្ញវត្ថុជប៉ុនសម្រាប់សហគ្រាសក្រុងត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ១៩៥៧ ក្នុងនាមជា សាជីវកម្មពិសេស ដោយរដ្ឋាភិបាលកណ្តាល ។ សាជីវកម្មនេះផ្តល់ប្រាក់កម្ចីរយៈពេលវែងដោយយកការប្រាក់ទាបដ៏គួរអោយចាប់អារម្មណ៍ ដល់រដ្ឋាភិបាលដែលប្រតិបត្តិការសហគ្រាសសាធារណៈមូលដ្ឋាន ។ ប្រភពដ៏សំខាន់នៃចំណូលសម្រាប់មូលនិធិ សាជីវកម្មហិរញ្ញវត្ថុជប៉ុនសម្រាប់សហគ្រាសក្រុង គឺសញ្ញាប័ណ្ណផ្ទាល់ខ្លួនដែលត្រូវបានបែងចែកជាបីប្រភេទដូចជា : (ក) សញ្ញាប័ណ្ណមានការធានាពីរដ្ឋាភិបាលដែលត្រូវបានទិញដោយក្រុមហ៊ុនមូលប័ត្រ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត (ខ) សញ្ញាប័ណ្ណគ្មានការធានាពីរដ្ឋាភិបាលដែលត្រូវបានទិញដោយក្រុម-ហ៊ុនមូលប័ត្រ និងស្ថាប័នហិរញ្ញវត្ថុ ផ្សេងទៀត (សញ្ញាប័ណ្ណគ្រប់គ្រងកម្មវិធីវិនិយោគសារពើពន្ធ និងប្រាក់កម្ចី) និង (គ) កម្ចីគ្មានការធានាពីរដ្ឋាភិបាលដែលធ្វើឡើងដោយសាជីវកម្មជំនួយអញ្ចមញ្ចដល់មន្ត្រីរាជការរដ្ឋាភិបាលមូលដ្ឋាន និងអង្គការផ្សេងទៀត ដែលមានទំនាក់ទំនងពិសេសជាមួយរដ្ឋាភិបាលមូលដ្ឋាន។ ល័ក្ខខ័ណ្ឌនៃការផ្តល់ប្រាក់កម្ចីដល់អាជ្ញាធរមូលដ្ឋានពីមូលនិធិសាជីវកម្មហិរញ្ញវត្ថុជប៉ុនសម្រាប់សហគ្រាសក្រុងមានភាពល្អប្រសើរជាងមូលនិធិឯកជន និងគាំទ្រដល់តែអ្វីដែលជាមូលនិធិរដ្ឋាភិបាលប៉ុណ្ណោះ។ យោងតាមច្បាប់ស្តីពីការលើកស្ទួយកំណែទម្រង់រដ្ឋបាល (ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦)

មូលនិធិសាជីវកម្មហិរញ្ញវត្ថុជប៉ុនសម្រាប់សហគ្រាសក្រុងនឹងត្រូវលុបបំបាត់ នៅក្នុងឆ្នាំសារពើពន្ធ២០០៨ ហើយរចនាសម្ព័ន្ធបច្ចុប្បន្ននឹងត្រូវកែប្រែថ្មី ។

(៣) មូលនិធិឯកជន

(ក) មូលនិធិជាវជាសាធារណៈ

រដ្ឋាភិបាលមូលដ្ឋានធំៗជាច្រើនចេញសញ្ញាប័ណ្ណរបស់ខ្លួននៅលើទីផ្សារបើកចំហ ។ ល័ក្ខខ័ណ្ឌកម្ចីមានភាពដូចគ្នាទៅនឹងសញ្ញាប័ណ្ណដែលចេញដោយក្រុមហ៊ុនឯកជនឈានមុខ ដូចជា ក្រុមហ៊ុនថាមពលអគ្គិសនីទាំងប្រាំបួន ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលមូលដ្ឋានចំនួន ៤២ ត្រូវបានអនុញ្ញាតអោយចេញសញ្ញាប័ណ្ណប្រភេទនេះ ដែលមានដូចជា រាជធានីតូក្យូ ខេត្តអូសាកា ទីក្រុងអូសាកា ទីក្រុងកូបេ និងទីក្រុងយ៉ូកូហាម៉ា ក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋានផ្សេងៗទៀត ។

ចាប់ពីឆ្នាំ២០០២មក ប្រភេទថ្មីនៃមូលនិធិជាវជាសាធារណៈបានចាប់ផ្តើមត្រូវបានចេញ គឺ"សញ្ញាប័ណ្ណមូលដ្ឋានដែលផ្តល់ជូនជាសាធារណៈសម្រាប់ភាគកម្មរបស់ប្រជាជន" ។ ដោយកំណត់គោលដៅអ្នកជាវទៅលើប្រជាជននៃ អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ សញ្ញាប័ណ្ណនេះអាចត្រូវបានចេញក្នុងទំហំតូចល្មម ។ អាស្រ័យហេតុនេះ ក្រុងជាច្រើន កំពុងចាប់ផ្តើមចេញសញ្ញាប័ណ្ណពីមួយឆ្នាំទៅមួយឆ្នាំ ។

(ខ) មូលនិធិឯកជនផ្សេងទៀត

អាជ្ញាធរមូលដ្ឋានជាច្រើនខ្ចីប្រាក់រយៈពេលវែងពីស្ថាប័នហិរញ្ញវត្ថុមួយចំនួនដូចជា ធនាគារពាណិជ្ជកម្ម សមាគមសហករណ៍កសិកម្ម និងក្រុមហ៊ុនធានារ៉ាប់រង ក៏ដូចជាពីរដ្ឋាភិបាលកណ្តាល និងពីមូលនិធិសាជីវកម្មហិរញ្ញវត្ថុជប៉ុនសម្រាប់សហគ្រាសក្រុង ។ សញ្ញាប័ណ្ណបរទេសត្រូវបានចេញម្តងម្កាលដោយអាជ្ញាធរមូលដ្ឋានមួយចំនួន ដូចជា រាជធានីតូក្យូ ខេត្តអូសាកា ទីក្រុងអូសាកា ទីក្រុងកូបេ ឬទីក្រុងយ៉ូកូហាម៉ា ។

## ៦. កម្មវិធីសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន

រដ្ឋាភិបាលរៀបចំ "កម្មវិធីសញ្ញាប័ណ្ណ/កម្ចីរបស់រដ្ឋាភិបាលមូលដ្ឋាន" នៅមុនពេលចាប់ផ្តើមឆ្នាំសារពើពន្ធជារៀងរាល់ឆ្នាំ។ កម្មវិធីនេះកំណត់អំពីសេចក្តីណែនាំសម្រាប់ទំហំនៃសញ្ញាប័ណ្ណ/កម្ចី ក្នុងប្រភេទជាច្រើននៃរដ្ឋបាល និងបែងចែកមូលនិធិដែលមានដល់ប្រភេទនីមួយ។ អាស្រ័យហេតុនេះ កម្មវិធីមិនត្រឹមតែអនុញ្ញាតអោយរដ្ឋាភិបាលមូលដ្ឋានរៀបចំថវិការបស់ខ្លួនសម្រាប់ឆ្នាំបន្ទាប់អោយស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីកម្ចីអនុញ្ញាតប៉ុណ្ណោះទេ ថែមទាំងធានាថារដ្ឋាភិបាលមូលដ្ឋានទទួលបានមូលនិធិគ្រប់គ្រាន់ ។ នេះគឺជាមធ្យោបាយមួយដ៏សំខាន់សម្រាប់រដ្ឋាភិបាលកណ្តាលក្នុងការត្រួតពិនិត្យចំណាយសាធារណៈអោយមានប្រសិទ្ធភាព ។

## ជំពូកទី ៦ : កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន

### ១. ការរៀបចំកម្មវិធីហិរញ្ញវត្ថុសាធារណៈ

រដ្ឋាភិបាលមូលដ្ឋាននៅប្រទេសជប៉ុនទទួលរ៉ាប់រងអនុវត្តសកម្មភាពមួយចំនួនធំរបស់រដ្ឋាភិបាល ក្រោមបទប្បញ្ញត្តិច្បាប់ ហើយមានទំនួលខុសត្រូវចំពោះប្រហែល ៦០% នៃចំណាយទាំងអស់របស់រដ្ឋាភិបាល ។ អាស្រ័យហេតុនេះ រដ្ឋាភិបាលកណ្តាលចាំបាច់ត្រូវធានានូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដល់អាជ្ញាធរមូលដ្ឋានដើម្បីអោយអាជ្ញាធរមូលដ្ឋានអាចផ្តល់សេវារបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។ សម្រាប់គោលបំណងនេះ រដ្ឋាភិបាលកណ្តាលរៀបចំគោលនយោបាយជាមូលដ្ឋានគ្រឹះសម្រាប់ហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ក្នុងកំឡុងឆ្នាំសារពើពន្ធ នីមួយៗមុនពេលចាប់ផ្តើម ។

យោងតាមគោលនយោបាយទាំងនេះ រដ្ឋាភិបាលកណ្តាលធ្វើការប៉ាន់ស្មានជាផ្លូវការនូវការចំណាយ និងចំណូលសរុប របស់រដ្ឋាភិបាលមូលដ្ឋានទាំងអស់ ។ គោលនយោបាយ និងការប៉ាន់ស្មាននេះត្រូវបានដាក់បញ្ចូលទៅក្នុង "កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន" ជារៀងរាល់ឆ្នាំ ដែលតាមរយៈនេះ រដ្ឋាភិបាលចាត់វិធានការចាំបាច់ដើម្បីរក្សាតុល្យភាពរវាងចំណូល និងចំណាយ ក្នុងករណីមានគម្លាតរវាងគ្នា ។

វិធានការដែលត្រូវអនុវត្តអាចជាកំណែទម្រង់ដ៏តូចតាច ឬដ៏សម្បើម នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ឬរដ្ឋបាល ដូចជា ការពិនិត្យមើលឡើងវិញនូវអត្រាអាករវិភាជន៍មូលដ្ឋាន និងការបែងចែកឡើងវិញនូវមុខងាររដ្ឋបាលរវាងរដ្ឋាភិបាលកណ្តាល និងរដ្ឋាភិបាលមូលដ្ឋាន ។

### ២. តួនាទីនៃកម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន៖

កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋានមិនមែនជាថវិកាប្រចាំឆ្នាំទេ ។ វាគឺជាសូចនាករសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសាធារណៈមូលដ្ឋាន ។ កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋានមានតួនាទីបីគឺ :

ទីមួយ កម្មវិធីផ្តល់នូវមធ្យោបាយសម្រាប់ការវាយតម្លៃប្រចាំឆ្នាំនូវកម្រិតនៃហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ។ ការវាយតម្លៃនេះអាចអោយធ្វើការកែតម្រូវជាមួយនឹងហិរញ្ញវត្ថុសាធារណៈជាតិ ។

ទីពីរ កម្មវិធីធានានូវប្រភពទូទៅនៃចំណូលសម្រាប់ហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ។ ប្រសិនបើដឹងជាមុនថាចំណូលមូលដ្ឋានមានកង្វះខាត រដ្ឋាភិបាលកណ្តាលត្រូវធានាថាមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អង្គភាពសាធារណៈមូលដ្ឋាន តាមរយៈការកែតម្រូវផ្សេងៗ ។

ទីបី កម្មវិធីត្រូវបានប្រើប្រាស់ជាសូចនាករប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសាធារណៈមូលដ្ឋាន ។ អង្គភាពសាធារណៈមូលដ្ឋានអាចទទួលបានព័ត៌មានចាំបាច់សម្រាប់ដំណើរការគ្រោងថវិការបស់ខ្លួន ដោយយោងដល់កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន ។ រូបភាពទី ៤ បង្ហាញនូវទំនាក់ទំនងរវាងកម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន និងថវិកាជាតិ ។

កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋានសម្រាប់ឆ្នាំសារពើពន្ធ២០០៧ មានបង្ហាញនៅក្នុងតារាងទី ១១ ។

## រូបភាពទី ៤ : ទំនាក់ទំនងរវាងកម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន និង ថវិកាជាតិ (ឆ្នាំសារពើពន្ធ២០០៧)

(គិតជាសែនកោដិលាន)

### ថវិកាជាតិ

| ចំណូល (៨២.៩) | | |
|---|---|---|
| អាករជាតិ ៥៣.៥ | អាករដែលជាធនធានរបស់អាករវិភាជន៍មូលដ្ឋាន ៤៦.០ | |
| | អាករលើចំណូល | ៣២% |
| | អាករលើសាជីវកម្ម | ៣៥.៨% |
| | អាករលើសុរា | ៣២% |
| | អាករលើការប្រើប្រាស់ | ២៩.៥% |
| | អាករលើថ្នាំជក់ | ២៥% |
| | ផ្សេងៗ ៧.៥ | |
| សញ្ញាប័ណ្ណជាតិ ២៥.៤ | | |
| ផ្សេងៗ ៤.០ | | |

| ចំណាយ (៨២.៩) |
|---|
| អាករវិភាជន៍មូលដ្ឋាន ១៤.៩ |
| ឧបត្ថម្ភកធន |
| ចំណាយសម្រាប់សញ្ញាប័ណ្ណរបស់រដ្ឋាភិបាលជាតិ ២១.០ |
| ផ្សេងៗ |

### កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋាន

| ចំណូល (៨៣.២) |
|---|
| អាករមូលដ្ឋាន ៤០.៤ |
| អាករផ្ទេរមូលដ្ឋាន |
| អាករវិភាជន៍មូលដ្ឋាន ១៥.២ |
| ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន |
| ឧបត្ថម្ភកធន ១០.២ |
| កម្ចីមូលដ្ឋាន ៩.៧ |
| ផ្សេងៗ |

| ចំណាយ (៨៣.២) |
|---|
| ប្រាក់បៀវត្ស ២២.៥ |
| ចំណាយសម្រាប់រដ្ឋបាលទូទៅ ២៦.២ |
| ចំណាយជាមូលធន ១៥.២ |
| កម្ចីមូលដ្ឋាន ១៣.១ |
| ផ្សេងៗ |

## តារាងទី ១១ : កម្មវិធីហិរញ្ញវត្ថុសាធារណៈមូលដ្ឋានសម្រាប់ឆ្នាំសារពើពន្ធ២០០៧

ចំណូល (ប៉ាន់ស្មាន)

(គិតជាពាន់លានយ៉េន)

| ការបរិយាយ | ឆ្នាំសារពើពន្ធ២០០៧ ទំហំទឹកប្រាក់ (ខ) | ឆ្នាំសារពើពន្ធ២០០៦ ទំហំទឹកប្រាក់ (ក) | ទំហំទឹកប្រាក់ នៃកំណើន (ខ)-(ក) | ភាគរយ នៃកំណើន (%) |
|---|---|---|---|---|
| ១. អាករមូលដ្ឋាន | ៤០.៣៧២,៨ | ៣៤.៨៩៨,៣ | ៥.៤៧៤,៥ | ១៥,៧ |
| ២. អាករផ្ទេរមូលដ្ឋាន | ៧០៩,១ | ៣.៧៣២,៤ | △៣.០២៣,៣ | △៨១,០ |
| ៣. ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន | ៣១២,០ | ៨១៦,០ | △៥០៤,០ | △៦១,៨ |
| ៤. អាករវិភាជន៍មូលដ្ឋាន | ១៥.២០២,៧ | ១៥.៩០៧,៣ | △៧០៤,៦ | △៤,៤ |
| ៥. ការបើកប្រាក់ពីរតនាគារជាតិ | ១០.១៧៣,៩ | ១០.២០១,៥ | △២៧,៦ | △០,៣ |
| ៦. ប្រាក់កម្ចី | ៩.៦៥២,៩ | ១០.៨១៧,៤ | △១.១៦៤,៥ | △១០,៨ |
| ៧. បន្ទុក និងសោហ៊ុយ | ១.៦៤៥,៥ | ១.៦៤៥,០ | ០,៥ | ០,០ |
| ៨. ផ្សេងៗ | ៥.០៥៧,២ | ៥.១៣២,៩ | △៧៥,៧ | △១,៥ |
| សរុប | ៨៣.១២៦,១ | ៨៣.១៥០,៨ | △២៤,៧ | ០,០ |

ចំណាយ (គ្រោងថវិកា)

(គិតជាពាន់លានយ៉េន)

| ការបរិយាយ | ឆ្នាំសារពើពន្ធ២០០៧ ទំហំទឹកប្រាក់ (ខ) | ឆ្នាំសារពើពន្ធ២០០៦ ទំហំទឹកប្រាក់ (ក) | ទំហំទឹកប្រាក់ នៃកំណើន (ខ)-(ក) | ភាគរយ នៃកំណើន (%) |
|---|---|---|---|---|
| ១. ប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល | ២២.៥១១,១ | ២២.៥៧៦,៩ | △៦៥,៨ | △០,៣ |
| ២. ចំណាយចរន្ត | ២៦.១៨១,១ | ២៥.១៨៥,៧ | ៩៩៥,៤ | ៤,០ |
| ៣. បន្ទុកបំណុល | ១៣.១៤៩,៦ | ១៣.២៩៧,៩ | △១៤៨,៣ | △១,១ |
| ៤. ជួសជុល និងថែទាំ | ៩៧៦,៦ | ៩៧៦,៨ | △០,២ | ០,០ |
| ៥. ចំណាយជាមូលធនសម្រាប់សំណង់សាធារណការ | ១៥.២៣២,៨ | ១៦.៨៨៨,៩ | △១.៦៥៦,១ | △៩,៨ |
| (i) សាធារណការមានឧបត្ថម្ភកធន | ៦.៦៤៤,៤ | ៦.៧៩៧,៨ | △១៥៣,៤ | △២,៣ |
| (ii) សាធារណការគ្មានឧបត្ថម្ភកធន | ៨.៥៨៨,៤ | ១០.០៩១,១ | △១.៥០២,៧ | △១៤,៩ |
| ៦. ការផ្ទេរទៅសហគ្រាសសាធារណៈមូលដ្ឋាន | ២.៧២៤,៩ | ២.៧៣៤,៦ | △៩,៧ | △០,៤ |
| ៧. ចំណាយលើសកម្រិតមធ្យមភាគថ្នាក់ជាតិ | ២.៣៥០,០ | ១.៤៩០,០ | ៨៦០,០ | ៥៧,៧ |
| សរុប | ៨៣.១២៦,១ | ៨៣.១៥០,៨ | △២៤,៧ | ០,០ |

កំណត់សម្គាល់ : សញ្ញា △ បញ្ជាក់អំពីតួលេខជាចំនួនអវិជ្ជមាន ។

## ជំពូកទី ៧ : សហគ្រាសហិរញ្ញវត្ថុសាធារណៈ

១. រដ្ឋាភិបាលមូលដ្ឋានធ្វើប្រតិបត្តិការសហគ្រាស ដូចជា ផ្គត់ផ្គង់ទឹក ដឹកជញ្ជូន មន្ទីរពេទ្យ និងទឹកស្អុយ ដើម្បីចូលរួមចំណែកជួយរក្សា និងលើកកំពស់គុណភាពជីវិតសម្រាប់សាធារណជនទូទៅ ក៏ដូចជាគ្រប់គ្រងវិស័យអប់រំ សុខុមាលភាពសង្គម សុខភាព និងអនាម័យ នគរបាល និងការការពារអគ្គិភ័យ និងកិច្ចការទូទៅផ្សេងៗទៀត ។

២. សហគ្រាសទាំងនេះដែលដំណើរការដោយរដ្ឋាភិបាលមូលដ្ឋានហៅថា "សហគ្រាសសាធារណៈមូលដ្ឋាន" ។ គោលការណ៍គ្រប់គ្រងសហគ្រាសសាធារណៈមូលដ្ឋានមានខុសគ្នាទាំងស្រុងពីសកម្មភាពរដ្ឋបាលទូទៅ ។ ជាគោលការណ៍ សហគ្រាសសាធារណៈមូលដ្ឋានត្រូវផ្តល់ហិរញ្ញប្បទានដោយថ្លៃសេវាដែលប្រមូលយកពីអតិថិជន និងដំណើរការដោយឯករាជ្យ ។ អាស្រ័យហេតុនេះ គណនីពិសេសមួយដែលខុសគ្នាពីគណនីទូទៅត្រូវបានប្រើប្រាស់នៅក្នុងប្រតិបត្តិការនេះ ។

៣. បទបញ្ជារបស់គណៈរដ្ឋមន្ត្រីស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋានចាត់តាំងសហគ្រាសដែលប្រតិបត្តិការ ដោយមានគណនីពិសេសមួយ : ផ្គត់ផ្គង់ទឹក ផ្គត់ផ្គង់ទឹកជាលក្ខណៈឧស្សាហកម្ម ដឹកជញ្ជូន ផ្គត់ផ្គង់អគ្គិសនី ផ្គត់ផ្គង់ឧស្ម័ន ផ្គត់ផ្គង់ទឹកសាមញ្ញ សេវាកំពង់ផែ មន្ទីរពេទ្យ ផ្សារ ទីសត្តឃាត ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ រៀបចំការដ្ឋានសង់លំនៅដ្ឋាន និងទឹកស្អុយ ។ ក្នុងចំណោមសហគ្រាសទាំងនេះ សហគ្រាសធម្មតា ដូចជា ផ្គត់ផ្គង់ទឹក ផ្គត់ផ្គង់ទឹកជាលក្ខណៈឧស្សាហកម្ម ដឹកជញ្ជូន (បែងចែកជាការដឹកជញ្ជូនតាមរថយន្តលើផ្លូវថ្នល់ ការដឹកជញ្ជូនតាមរថយន្តក្រុង និងការដឹកជញ្ជូនតាមរថភ្លើងក្នុងមូលដ្ឋាន) ផ្គត់ផ្គង់អគ្គិសនី និងផ្គត់ផ្គង់ឧស្ម័ន ត្រូវបានគ្រប់គ្រងដោយ "ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន" ហើយខហិរញ្ញវត្ថុនៃច្បាប់នេះត្រូវបានអនុវត្តចំពោះមន្ទីរពេទ្យ ។
លើសពីនេះទៅទៀត រដ្ឋាភិបាលមូលដ្ឋានអាចអនុវត្តច្បាប់នេះចំពោះសហគ្រាសសាធារណៈមូលដ្ឋានណាមួយ ទៅតាមឆន្ទៈរបស់ខ្លួន ។ នៅពេលច្បាប់ត្រូវបានអនុវត្ត សហគ្រាសសាធារណៈមូលដ្ឋានត្រូវប្រតិបត្តិការ ក្រោមគោលការណ៍ នៃ "គណនីសហគ្រាស" ។ គណនីសហគ្រាសមានគណនីចរន្ត និងគណនីមូលធន ។ ភាពខុសគ្នារវាងគណនីទាំងពីរនេះមិនត្រូវបានអនុម័តនៅក្នុងគណនីពិសេស ឬគណនីទូទៅផ្សេងទៀតឡើយ ។

៤. ជាធម្មតា ការវិនិយោគ ឬចំណាយដំបូងសម្រាប់គម្រោងសាងសង់ត្រូវបានផ្តល់ហិរញ្ញប្បទានដោយប្រាក់កម្ចីមូលដ្ឋានដែលជូនកាលពឹងផ្អែកលើឧបត្ថម្ភធនពីគណនីទូទៅ និងពីរដ្ឋាភិបាលកណ្តាល ។

៥. ចំនួនសហគ្រាសសាធារណៈមូលដ្ឋាននៃឆ្នាំសារពើពន្ធ២០០៥ មានដូចខាងក្រោម

### តារាងទី ១២ : ចំនួនសហគ្រាសសាធារណៈមូលដ្ឋាន (ឆ្នាំសារពើពន្ធ២០០៥)

| សហគ្រាស | ច្បាប់អនុវត្ត | ច្បាប់មិនអនុវត្ត | សរុប |
|---|---|---|---|
| ផ្គត់ផ្គង់ទឹក (រួមទាំងសាមញ្ញ) | ១.៤៤៩ | ៨៨៥ | ២.៣៣៤ |
| ផ្គត់ផ្គង់ទឹកជាលក្ខណៈឧស្សាហកម្ម | ១៤៩ | - | ១៤៩ |
| ដឹកជញ្ជូន | ៦៥ | ៤១ | ១០៦ |
| ផ្គត់ផ្គង់អគ្គិសនី | ៣១ | ៨៩ | ១២០ |
| ផ្គត់ផ្គង់ឧស្ម័ន | ៣៦ | - | ៣៦ |
| សេវាមន្ទីរពេទ្យ | ៦៧២ | - | ៦៧២ |
| ទឹកស្អុយ | ២១៣ | ៣.៤៨៦ | ៣.៦៩៩ |
| ផ្សេងៗ | ២៥២ | ២.០១១ | ២.២៦៣ |
| សរុប | ២.៨៦៧ | ៦.៥១២ | ៩.៣៧៩ |

៦. តុល្យការប្រចាំឆ្នាំសរុបនៃគណនីចរន្តរបស់សហគ្រាសសាធារណៈមូលដ្ឋានទាំងអស់ ស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន មានដូចខាងក្រោម ៖

### តារាងទី ១៣ : តុល្យការប្រចាំឆ្នាំសរុបនៃគណនីចរន្តរបស់សហគ្រាសសាធារណៈមូលដ្ឋាន ស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ក្នុងឆ្នាំសារពើពន្ធ២០០៥

(គិតជាពាន់លានយ៉េន)

| បរិយាយ | ចំណូល | ចំណាយ | តុល្យការ | ឱនភាពសរុប |
|---|---|---|---|---|
| ផ្គត់ផ្គង់ទឹក (រួមទាំងសាមញ្ញ) | ៣.១៩៧ | ២.៩៦១ | ២៣៧ | ១២៤ |
| ផ្គត់ផ្គង់ទឹកជាលក្ខណៈឧស្សាហកម្ម | ១៦៤ | ១៤០ | ២៤ | ២២ |
| ដឹកជញ្ជូន | ៨០៧ | ៨៧១ | △៦៣ | ២.២៧៦ |
| ផ្គត់ផ្គង់អគ្គិសនី | ៨៦ | ៧៨ | ៧ | ២ |
| ផ្គត់ផ្គង់ឧស្ម័ន | ៩១ | ៩៣ | △២ | ៣៩ |
| សេវាមន្ទីរពេទ្យ | ៤.១៥៤ | ៤.៣០២ | △១៤៨ | ១.៧៨១ |
| ទឹកស្អុយ | ១.៤០១ | ១.៣៦២ | ៣៩ | ២០៦ |
| ផ្សេងៗ | ១.១១០ | ៩៧១ | ១៣៩ | ២១៤ |
| សរុប | ១១.០១១ | ១១.៧៧៧ | ២៣៣ | ៤.៦៦៤ |

## ជំពូកទី ៨ : ច្បាប់នានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ

ជំពូកទី ៨ នៃរដ្ឋធម្មនុញ្ញជប៉ុន ដែលចូលជាធរមាននៅឆ្នាំ១៩៤៧ ចែងអំពីគោលការណ៍គ្រឹះនៃស្វ័យភាពមូលដ្ឋាន ដោយពិចារណាលើសារៈសំខាន់នៃស្វ័យភាពមូលដ្ឋាន ។

រដ្ឋធម្មនុញ្ញចែងដូចខាងក្រោម :

មាត្រា ៩២ : បទបញ្ញាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសាធារណៈមូលដ្ឋានត្រូវកំណត់ដោយច្បាប់អោយស្របទៅនឹងគោលការណ៍នៃស្វ័យភាពមូលដ្ឋាន ។

មាត្រា ៩៣ : អង្គភាពសាធារណៈមូលដ្ឋានត្រូវបង្កើតសភា ជាអង្គភាពពិភាក្សាសម្រេចរបស់ខ្លួនស្របតាមច្បាប់ ។ នាយកប្រតិបត្តិនៃអង្គភាពសាធារណៈមូលដ្ឋានទាំងអស់ សមាជិកសភា និងមន្ត្រីមូលដ្ឋានផ្សេងទៀតដូចបានកំណត់ដោយច្បាប់ ត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយផ្ទាល់ពីប្រជាជន នៅក្នុងសហគមន៍របស់ខ្លួន ។

មាត្រា ៩៤ : អង្គភាពសាធារណៈមូលដ្ឋានត្រូវមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ កិច្ចការ និងរដ្ឋបាលរបស់ខ្លួន និងចេញបទបញ្ញាផ្ទាល់ខ្លួនស្របតាមច្បាប់ ។

មាត្រា ៩៥ : ច្បាប់ពិសេសមួយ ដែលអាចអនុវត្តបានតែចំពោះអង្គភាពសាធារណៈមួយ មិនអាចត្រូវបានអនុម័តដោយរដ្ឋសភា ដោយគ្មានការយល់ព្រមពីសម្លេងភាគច្រើននៃអ្នកបោះឆ្នោតរបស់អង្គភាពសាធារណៈមូលដ្ឋានពាក់ព័ន្ធ ដែលទទួលបានស្របតាមច្បាប់បានឡើយ ។

រដ្ឋបាលសាធារណៈមូលដ្ឋានត្រូវធ្វើឡើងអោយស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន (ឆ្នាំ១៩៤៧) ច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋាន (ឆ្នាំ១៩៤៨) ច្បាប់ស្តីពីអាករមូលដ្ឋាន (ឆ្នាំ១៩៥០) ច្បាប់ស្តីពីអាករវិភាជន៍មូលដ្ឋាន (ឆ្នាំ១៩៥០) និងច្បាប់ផ្សេងៗទៀត ក៏ដូចជានីតិកម្មនាពេលខាងមុខ ។

(១) ច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានបង្កើតបានជាមូលដ្ឋាននៃប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននៅប្រទេសជប៉ុន ដោយចែងអំពីបញ្ហាជា មូលដ្ឋានគ្រឹះពាក់ព័ន្ធនឹងការបែងចែកមុខងារ ថវិកា គណនេយ្យ ចំណូល ចំណាយ និងកិច្ចការហិរញ្ញវត្ថុផ្សេងទៀត ក៏ដូចជាការរៀបចំ ។ល។

(២) ច្បាប់ស្តីពីហិរញ្ញវត្ថុមូលដ្ឋានបង្កើតគោលការណ៍គ្រឹះសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមូលដ្ឋាន ក៏ដូចជាការបែងចែកទំនួលខុសត្រូវខាងហិរញ្ញវត្ថុរវាងរដ្ឋាភិបាលកណ្តាល និងអាជ្ញាធរមូលដ្ឋាន ។

(៣) ច្បាប់ស្តីពីអាករវិភាជន៍មូលដ្ឋានគឺជាមូលដ្ឋាននៃប្រព័ន្ធអាករវិភាជន៍មូលដ្ឋានដែលធានានូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដល់អាជ្ញាធរមូលដ្ឋាន ដោយមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងរដ្ឋបាលរបស់អាជ្ញាធរមូលដ្ឋាន ។

(៤) ច្បាប់ស្តីពីអាករមូលដ្ឋានចែងអំពីគោលការណ៍ជាមូលដ្ឋាននៃអាករមូលដ្ឋានដែលកំណត់ និងប្រមូលដោយរដ្ឋាភិបាលមូលដ្ឋាន ទៅតាមដីការបស់ខ្លួនដែលប្រកាសអោយប្រើស្របតាមច្បាប់ ។

អភិបាលកិច្ចមូលដ្ឋាន (ការរៀបចំតាក់តែងគោលនយោបាយ
និងសង្គមស៊ីវិល)
ឆ្នាំសារពើពន្ធ ២០០៧

# ប្រព័ន្ធសហគ្រាសសាធារណៈមូលដ្ឋាន
# នៅក្នុងប្រទេសជប៉ុន

# មាតិកា


**ជំពូកទី ១ ~ សេចក្តីផ្តើមនៃសហគ្រាសសាធារណៈមូលដ្ឋាន**

១. សហគ្រាសសាធារណៈមូលដ្ឋាន ........ ១

២. សេចក្តីបរិយាយនៃសហគ្រាសនីមួយៗ ........ ៧

**ជំពូកទី ២ ~ សេចក្តីបរិយាយអំពីប្រព័ន្ធសហគ្រាសសាធារណៈមូលដ្ឋាន**

១. និតិកម្មសម្រាប់សហគ្រាសសាធារណៈមូលដ្ឋាន ........ ១៥

២. គោលការណ៍ណែនាំនៃច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ........ ១៦

៣. សេចក្តីផ្តើមនៃច្បាប់ស្តីពីទីភ្នាក់ងាររដ្ឋបាលសាជីវកម្មមូលដ្ឋាន ........ ២០

**ជំពូកទី ៣ ~ បញ្ហាប្រឈមចំពោះសហគ្រាសសាធារណៈមូលដ្ឋានបច្ចុប្បន្ន** ........ ២១

## ជំពូកទី ១ ~ សេចក្តីផ្តើមនៃសហគ្រាសសាធារណៈមូលដ្ឋាន

### ១. សហគ្រាសសាធារណៈមូលដ្ឋាន

អង្គភាពសាធារណៈមូលដ្ឋាននីមួយៗ ទទួលបន្ទុកដោះស្រាយបញ្ហាផ្សេងៗនៃជីវភាពប្រចាំថ្ងៃរបស់ពលរដ្ឋ ដូចជាសុខុមាលភាពសាធារណៈ ការអប់រំ ឬការពន្លត់អគ្គិភ័យ ហើយដោយហេតុនេះ គ្រប់គ្រងសហគ្រាសសាធារណៈមូលដ្ឋានជាច្រើនដោយផ្ទាល់មុខ ឬដោយសហការជាមួយអង្គភាពសាធារណៈមូលដ្ឋានផ្សេងទៀត ។

សហគ្រាសសាធារណៈមូលដ្ឋានទាំងនេះ គ្របដណ្តប់លើសេវាសាធារណៈជាច្រើន ។ សហគ្រាសសាធារណៈមូលដ្ឋានជាក់លាក់មួយចំនួន រួមមាន ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរទឹកស្អុយ មន្ទីរពេទ្យ និងការដឹកជញ្ជូន ប៉ុន្តែទីផ្សាររដ្ឋ ការវាយតម្លៃដីធ្លី និងសូម្បីតែការគ្រប់គ្រងតំបន់ជិះស្គី ឬសហគ្រាសផលិតស្រា ក៏អាចរួមបញ្ចូលក្នុងប្រភេទនេះផងដែរ ។

ជាធម្មតា សហគ្រាសទាំងនេះត្រូវបានបង្កើតឡើង និងប្រតិបត្តិការដោយផ្នែកសាធារណៈ ដូចជាអង្គភាពសាធារណៈមូលដ្ឋាន ព្រោះសហគ្រាសទាំងនេះមាននិន្នាការត្រូវការប្រាក់វិនិយោគសន្ធឹកសន្ធាប់ ទោះបីជាសហគ្រាសទាំងនេះមានការលំបាកក្នុងការស្វែងរកប្រាក់ចំណេញក៏ដោយ ។

សហគ្រាសសាធារណៈមូលដ្ឋានមួយត្រូវតែប្រតិបត្តិការ ក្នុងគោលបំណងលើកស្ទួយសុខុមាលភាពប្រជាជន ។ ក្នុងបរិបទនេះ សហគ្រាសទាំងនេះត្រូវបានគេរំពឹងយ៉ាងខ្លាំងថាមានប្រសិទ្ធភាពបំផុត ដោយចំណាយថ្លៃដើមអស់តិចបំផុតផ្អែកលើគោលការណ៍ប្រសិទ្ធផលសេដ្ឋកិច្ច ។ ដូច្នេះ សហគ្រាសទាំងនេះក៏ត្រូវផ្អែកលើគោលការណ៍ប្រព័ន្ធគណនេយ្យស្វ័យ-គាំទ្រ ដែលគ្របដណ្តប់លើចំណាយទាំងឡាយដែលចាំបាច់សម្រាប់ការគ្រប់គ្រង ដោយចំណូលបានមកពីថ្លៃសេវា ឬថ្លៃប្រើប្រាស់ផ្សេងៗ ។

ស្ថានភាពនាពេលថ្មីៗនេះនៃសហគ្រាសសាធារណៈមូលដ្ឋានសំខាន់ៗ នៅក្នុងសេវាសាធារណៈ (រួមទាំងសេវាសាធារណៈដែលផ្តល់អោយដោយផ្នែកឯកជន) មានដូចខាងក្រោម :

១) ក្នុងចំណោមសហគ្រាសផ្គត់ផ្គង់ទឹកស្អាតទាំងអស់ ដែលគ្របដណ្តប់លើប្រជាជន ១២៤.៧០៧ ពាន់នាក់ ប្រជាជន ១២៣.៨៣៤ ពាន់នាក់ (៩៩.៣%) ទទួលសេវាពីសហគ្រាសសាធារណៈមូលដ្ឋាន ។

២) ក្នុងចំណោមសហគ្រាសផ្គត់ផ្គង់ទឹកឧស្សាហកម្មទាំងអស់ ដែលផ្គត់ផ្គង់ទឹកចំនួន ៤.៧០១ លាន ម៣ ក្នុងមួយឆ្នាំ ទឹកចំនួន ៤.៦៩៦ លាន ម៣ (៩៩.៩%) ត្រូវបានផ្គត់ផ្គង់ដោយសហគ្រាសសាធារណៈមូលដ្ឋាន ។

៣) គម្រោងគ្រប់គ្រងទឹកស្អុយទាំងអស់ដែលគ្របដណ្តប់លើប្រជាជនចំនួន ៩៣ លាននាក់ ដំណើរការដោយសហគ្រាសសាធារណៈមូលដ្ឋាន ។

៤) ក្នុងចំណោមសេវាកម្មរថភ្លើងក្រោមដីទាំងអស់ដែលដឹកជញ្ជូនអ្នកធ្វើដំណើរបាន ២១.៩៥៤ លាននាក់ក្នុងមួយឆ្នាំ ប្រជាជនចំនួន ២.៧៨៨ លាននាក់ (១២.៩%) ប្រើប្រាស់សេវាកម្មដឹកជញ្ជូន ដែលដំណើរការដោយសហគ្រាសសាធារណៈមូលដ្ឋាន ។

៥) ក្នុងចំណោមសេវាកម្មរថយន្តក្រុងទាំងអស់ ដែលដឹកជញ្ជូនអ្នកធ្វើដំណើរបាន ៤.៥៤៥ លាននាក់ក្នុងមួយឆ្នាំ ប្រជាជនចំនួន ១.០៦៣ លាននាក់ (២៣.៤%) ប្រើប្រាស់សេវាកម្មរថយន្តក្រុង ដែលដំណើរការដោយសហគ្រាសសាធារណៈមូលដ្ឋាន ។

៦)	ក្នុងចំណោមសេវាកម្មមន្ទីរពេទ្យទាំងអស់ ដែលមាន ១.៦៣២ ពាន់រៀល មាន ២៣៥ ពាន់រៀល (១៤.៤%) ដែលត្រូវបានផ្គត់ផ្គង់ដោយសហគ្រាសសាធារណៈមូលដ្ឋាន ។

ជាពិសេស សហគ្រាសសាធារណៈមូលដ្ឋានគ្របដណ្តប់លើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត ទឹកឧស្ម័នហកម្ម និងសេវាកម្មបង្ហូរទឹកស្អុយ ព្រមទាំងមានបំណែកយ៉ាងធំនៅក្នុងសេវាកម្មផ្សេងៗទៀតដែលបានរៀបរាប់ខាងលើ ។

## ចំនួនសហគ្រាសសាធារណៈមូលដ្ឋាន

## (ឆ្នាំសារពើពន្ធ ២០០៥)

| ប្រភេទសេវាកម្ម | ចំនួនសហគ្រាស | អត្រា |
|---|---|---|
| ផ្គត់ផ្គង់ទឹកស្អាត | ២.៣៣៤ | ២៤.៩ |
| ផ្គត់ផ្គង់ទឹកឧស្សាហកម្ម | ១៤៩ | ១.៦ |
| ដឹកជញ្ជូន | ១០៦ | ១.១ |
| ផ្គត់ផ្គង់អគ្គិសនី | ១២០ | ១.៣ |
| ផ្គត់ផ្គង់ហ្គាស | ៣៦ | ០.៤ |
| មន្ទីរពេទ្យ | ៦៧២ | ៧.២ |
| បង្ហូរទឹកស្អុយចេញ | ៣.៦៩៩ | ៣៩.៤ |
| កំពង់ផែ | ១០៦ | ១.១ |
| ផ្សារ | ១៨០ | ១.៩ |
| បង្កើតទីសត្តឃាត | ៧៩ | ០.៨ |
| កន្លែងទេសចរណ៍ | ៤៤០ | ៤.៧ |
| រៀបចំដែនដី | ៥៣១ | ៥.៧ |
| ផ្លូវបង់ប្រាក់ | ៤ | ០.០ |
| ចំណតសាធារណៈ | ២៤០ | ២.៦ |
| សេវាថែទាំមនុស្សចាស់ | ៦៥១ | ៦.៩ |
| ផ្សេងៗ | ៣២ | ០.៣ |
| សរុប | ៩.៣៧៩ | ១០០ |

**ការបែងចែកគណនីរបស់សហគ្រាសសាធារណៈមូលដ្ឋាន**

**(ឆ្នាំសារពើពន្ធ ២០០៥)**

(គិតជាពាន់លានយេន)

| ប្រភេទសេវាកម្ម | ចំណាយ | អត្រា |
|---|---|---|
| ផ្គត់ផ្គង់ទឹកស្អាត | ៤៤.៥៦០ | ២១.៩ |
| ផ្គត់ផ្គង់ទឹកឧស្សាហកម្ម | ២.៨៣១ | ១.៤ |
| ដឹកជញ្ជូន | ១៣.៥៥០ | ៦.៧ |
| ផ្គត់ផ្គង់អគ្គិសនី | ១.៣៦៥ | ០.៧ |
| ផ្គត់ផ្គង់ហ្គាស | ១.០៨១ | ០.៥ |
| មន្ទីរពេទ្យ | ៤៧.៥៩៩ | ២៣.៤ |
| បង្ហូរទឹកស្អុយចេញ | ៦៥.៦៣៥ | ៣២.៣ |
| កំពង់ផែ | ១.៨០៣ | ០.៩ |
| ផ្សារ | ១.៨៩៧ | ០.៩ |
| បង្កើតទីសត្តឃាត | ២៧៤ | ០.១ |
| កន្លែងទេសចរណ៍ | ១.១៨៤ | ០.៦ |
| រៀបចំដែនដី | ១៨.៤៧០ | ៩.១ |
| ផ្លូវបង់ប្រាក់ | ២១ | ០.០ |
| ចំណតសាធារណៈ | ៦៧៧ | ០.៣ |
| សេវាថែទាំមនុស្សចាស់ | ១.៩៤២ | ១.០ |
| ផ្សេងៗ | ២៩៤ | ០.១ |
| សរុប | ២០៣.១៨២ | ១០០ |

កំណត់សម្គាល់ : តួលេខនៅក្នុង "ចំណាយ" ត្រូវបានគណនាដោយដកការចុះថ្លៃពីចំណាយដើម ចំពោះសហគ្រាសសាធារណៈមូលដ្ឋាន ក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន និងដោយបូកថវិកាបម្រុង និងប្រាក់បម្រុងជាមុនទៅលើចំណាយដើមចំពោះសហគ្រាសផ្សេងទៀត ។

ដោយសារការកាត់ខ្ទង់សម្រួល ភាគរយសរុបអាចមិនស្មើ ១០០% ទេ ។

## ប្រភពហិរញ្ញវត្ថុនៃការវិនិយោគលើការសាងសង់
## (ឆ្នាំសារពើពន្ធ ២០០៥)

(គិតជាពាន់លានយេន)

| ផ្នែក | ចំនួនទឹកប្រាក់ |
|---|---|
| កម្ចីសហគ្រាស | ២២.០៤១ (៤៥.០%) |
| ឧបត្ថម្ភកធនរដ្ឋាភិបាលថ្នាក់ជាតិ ឬខេត្ត | ១០.៩៥៧ (២២.៤%) |
| ផ្ទេរមកពីគណនីផ្សេងទៀត | ៣.៣៥៧ (៦.៩%) |
| វិភាគទានសម្រាប់ការងារដែលបានបំពេញ | ២.៥៩៦ (៥.៣%) |
| ផ្សេងៗ<br>(មូលនិធិផ្ទៃក្នុង ។ល។) | ១០.០៥២ (២០.៥%) |
| សរុប | ៤៩.០០២ (១០០%) |

កំណត់សម្គាល់ : ដោយសារការកាត់ខ្ទង់សម្រួល ចំនួនសរុបអាចមិនស្មើនឹងចំនួនទឹកប្រាក់នីមួយៗបូកបញ្ចូលគ្នាឡើយ ហើយភាគរយសរុបអាចមិនស្មើនឹង ១០០% ទេ។

# បំណែងចែកនៃប្រភពហិរញ្ញវត្ថុ
# នៃការបិទបញ្ជីគណនី
# (សហគ្រាសសាធារណៈមូលដ្ឋានក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន)

(គិតជាលានយេន)

| ឆ្នាំ / ប្រភេទ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ |
|---|---|---|---|---|---|
| ប្រាក់ចំណូលដុល | ១០.៦២២.៨៧៨ | ១០.៣០៩.១៩៥ | ១០.៥២៤.១១៥ | ១១.៦៤៦.៤០៥ | ១១.០១១.០២០ |
| ប្រាក់ចំណូលធម្មតា | ១០.៤៦៩.០៦០ | ១០.២៣២.០៤២ | ១០.៤៦៥.១០៣ | ១០.៨២៣.៧៣៥ | ១០.៩២៥.៧៣៣ |
| ចំណូលអាជីវកម្ម - ចំណូលការងារកិច្ចសន្យា | ៩.៣៨៥.២៤៣ | ៩.១៦៥.៤៩៣ | ៩.៣៨៦.៣២១ | ៩.៧៨២.៨៣៦ | ៩.៧៩១.១៦៥ |
| ថ្លៃសេវា និងថ្លៃប្រើប្រាស់ដែលទទួលបាន | ៨.៣៤០.០៧៦ | ៨.២៤៩.៣២៧ | ៨.៣៨៨.៣១៨ | ៨.៧៨៧.៤១៤ | ៨.៨១០.២៥៨ |
| ឧបត្ថម្ភកធនពីគណនីផ្សេងទៀត | ៤១៤.២៥៧ | ៤០៤.២៦២ | ៤៣២.០២៨ | ៤០៩.៨៩១ | ៤២៣.១៨១ |
| ភាគចំណែកចាំបាច់នៃគណនីផ្សេងទៀត | ៩៨២.៩៧៤ | ៩៧៩.១១៩ | ៩៥៩.២៦០ | ៩៤៦.៤៧២ | ៩២៣.៦៧៨ |
| ឧបត្ថម្ភកធនរដ្ឋាភិបាលថ្នាក់ជាតិ និងខេត្ត | ២៦.៥៣០ | ២៦.០៤២ | ២៤.៨៧៥ | ២៦.៣៨១ | ២៤.៩៦១ |
| ផលប្រយោជន៍ពិសេស | ១៥៣.៨១៧ | ៧៧.១៥៣ | ៥៩.០១២ | ៦៤០.៦៧០ | ៨៥.២៨៧ |

## ២. សេចក្តីបរិយាយនៃសហគ្រាសនីមួយៗ

(១) សហគ្រាសផ្គត់ផ្គង់ទឹកស្អាត

ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតចែងថា ជាគោលការណ៍ ទឹកស្អាតប្រើក្នុងផ្ទះត្រូវផ្គត់ផ្គង់ដោយអង្គភាពសាធារណៈមូលដ្ឋាន តាមរយៈសហគ្រាសផ្គត់ផ្គង់ទឹកស្អាត (ដែលផ្គត់ផ្គង់ដល់ប្រជាជនមិនតិចជាង ៥.០០១ គ្រួសារ) និងសហគ្រាសផ្គត់ផ្គង់ទឹកស្អាតខ្នាតតូច (ដែលផ្គត់ផ្គង់ដល់ប្រជាជនមិនច្រើនជាង ៥.០០០ គ្រួសារ) ។ ច្បាប់នេះអនុវត្តចំពោះតែសហគ្រាសដែលផ្គត់ផ្គង់ដល់ប្រជាជនមិនតិចជាង ១០១ គ្រួសារប៉ុណ្ណោះ ។ ចំនួនប្រជាជនសរុបដែលទទួលបានទឹកស្អាតត្រឹមដំណាច់ឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ១២៤.៧១ លាននាក់ ហើយក្នុងចំណោមប្រជាជនទាំងនេះ ប្រជាជន ១២៣.៨៣ លាននាក់ (៩៩.៣%) បានទទួលទឹកស្អាតតាមរយៈសហគ្រាសដែលប្រតិបត្តិដោយអង្គភាពសាធារណៈមូលដ្ឋាន ។

ចំនួនសហគ្រាសផ្គត់ផ្គង់ទឹកស្អាតដែលប្រតិបត្តិដោយអង្គភាពសាធារណៈមូលដ្ឋាន ក្នុងឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ២.៣៣៤ ។ ក្នុងចំណោមសហគ្រាសទាំងនេះ មានសហគ្រាសចំនួន ២.២៥៥ ផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនដោយផ្ទាល់ ចំណែកសហគ្រាសផ្គត់ផ្គង់ទឹកស្អាតធំៗចំនួន ៧៩ ផ្គត់ផ្គង់ទឹកស្អាតដល់សហគ្រាសផ្គត់ផ្គង់ទឹកស្អាតអ្នកប្រើប្រាស់ផ្ទាល់ ។

ចំនួនបុគ្គលិកដែលបម្រើការងារនៅក្នុងសហគ្រាសផ្គត់ផ្គង់ទឹកស្អាត មានចំនួន ៥៨.៧៣៣ នាក់ នៅដំណាច់ឆ្នាំសារពើពន្ធ ២០០៥ ។

ចំនួនសហគ្រាសផ្គត់ផ្គង់ទឹកស្អាត ដែលច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋានអនុវត្តចំពោះ មានចំនួន ១.៤៣៦ (មិនរាប់សហគ្រាសកំពុងសាងសង់) នៅដំណាច់ឆ្នាំសារពើពន្ធ ២០០៥ ។ ក្នុងចំណោមសហគ្រាសទាំងនេះ មានសហគ្រាសចំនួន ១.១៩២ (ឬ ៨៣.០% នៃចំនួនសហគ្រាសសរុប) បានរាយការណ៍ថាមានអតិរេកគណនីចរន្តនៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ។ ចំនួនសហគ្រាសដែលរាយការណ៍អំពីឱនភាព បានធ្លាក់ចុះចំនួន ១១៤ ចាប់ពីឆ្នាំមុន និង ២៤៤ នៅក្នុងឆ្នាំសារពើពន្ធ ២០០៥។ មិនត្រឹមតែប៉ុណ្ណឹង ប្រាក់ចំណេញសរុបរបស់សហគ្រាសសាធារណៈដែលទទួលអតិរេកទាំងនេះ មានចំនួន ២៥៦.៣ ពាន់លានយេន ដោយមានការកើនឡើងចំនួន ១១.៧ ពាន់លានយេន ចាប់ពីឆ្នាំមុន ចំណែកការខាតរបស់សហគ្រាសដែលមានឱនភាព បានធ្លាក់ចុះពី ៣.៧ ពាន់លានយេន ទៅ ១៩.៤ ពាន់លានយេន ។

ចំនួនសហគ្រាសដែលមានការខាតជាបន្តបន្ទាប់ក្នុងឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ២៧៨ ។ ចំនួននេះបានធ្លាក់ចុះចំនួន ១០៥ ចាប់ពីឆ្នាំសារពើពន្ធ ២០០៤ ។ យោងតាមគណនី ការខាតជាបន្តបន្ទាប់សរុប មានចំនួន ១២៤.០ ពាន់លានយេន ដោយមានការធ្លាក់ចុះចំនួន ៧.៩ ពាន់លានយេន ។

(២) សហគ្រាសផ្គត់ផ្គង់ទឹកឧស្សាហកម្ម

ការផ្គត់ផ្គង់ទឹកដល់ឧស្សាហកម្មទាំងឡាយដែលភាគច្រើនជារោងចក្រ គឺជាមុខងារមួយនៃមុខងារសំខាន់ៗផ្សេងទៀតនៃអង្គភាពសាធារណៈមូលដ្ឋាន ។ យោងតាមការស្រាវជ្រាវនៅដំណាច់ឆ្នាំសារពើពន្ធ ២០០៥ ទឹកឧស្សាហកម្មដែលបានផ្គត់ផ្គង់ មានចំនួន ៤.៧០១ លានម៣ ដែលក្នុងនោះទឹកចំនួន ៤.៦៩៦ លានម៣ (៩៩.៩%) ត្រូវបានផ្គត់ផ្គង់ដោយសហគ្រាសសាធារណៈមូលដ្ឋាន ។

ចំនួនសហគ្រាសផ្គត់ផ្គង់ទឹកឧស្ម័នហាកម្ម ក្នុងឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ១៤៩ ហើយចំនួនកន្លែងសរុបរបស់សហគ្រាស មានចំនួន ២៦៧ ។

ចំនួនសហគ្រាសផ្គត់ផ្គង់ទឹកឧស្ម័នហាកម្ម ដែលចាត់ថ្នាក់តាមរបបគ្រប់គ្រង មានដូចតទៅ : សហគ្រាសចំនួន ៤១ ដំណើរការដោយខេត្ត សហគ្រាសចំនួន ៧ ដំណើរការដោយក្រុងចាត់តាំង សហគ្រាសចំនួន ៧៩ ដំណើរការដោយក្រុងផ្សេងទៀត សហគ្រាសចំនួន ១៥ ដោយឃុំ និងភូមិ និងសហគ្រាសចំនួន ៧ ដោយអង្គភាពចម្រុះនៃអង្គភាពមូលដ្ឋាន ។ ទិន្នន័យបង្ហាញថា សហគ្រាសភាគច្រើន ប្រតិបត្តិដោយអង្គភាពមូលដ្ឋានធំៗជាងនេះ ។ នេះគឺដោយសារតម្រូវការនៃទឹកឧស្ម័នហាកម្ម ទាក់ទងយ៉ាងជិតស្និទ្ធនឹងការអភិវឌ្ឍឧស្ម័នហាកម្មក្នុងតំបន់ ដែលជាទូទៅ ហួសពីព្រំដែននៃអង្គភាពតូចៗជាងនេះ ។

ចំនួនបុគ្គលិកដែលចូលរួមនៅក្នុងប្រតិបត្តិការរបស់សហគ្រាសផ្គត់ផ្គង់ទឹកឧស្ម័នហាកម្មទាំងនេះ មានចំនួន ២.១០០ នាក់ គិតត្រឹមដំណាច់ឆ្នាំសារពើពន្ធ ២០០៥ ។

ចំនួនសហគ្រាសដែលរាយការណ៍ថាមានអតិរេកគណនីចរន្ត នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ១២០ (ឬ ៨៣.៣%) ក្នុងចំណោមសហគ្រាសផ្គត់ផ្គង់ទឹកឧស្ម័នហាកម្មចំនួន ១៤៤ ដែលកំពុងប្រតិបត្តិការ ។ ម្យ៉ាងទៀត ចំនួនសហគ្រាសដែលរាយការណ៍ថាមានឱនភាព មានចំនួន ២៤ ។

នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ចំនួនសហគ្រាសដែលរាយការណ៍ថាមានការខាតបង់ជាបន្តបន្ទាប់មានចំនួន ៣៦ គឺមានការកើនឡើងចំនួន ៣ ។ យោងតាមគណនី គឺមានចំនួន ២១.៧ ពាន់លានយេន ដែលជាការកើនឡើងចំនួន ០.៨ ពាន់លានយេន បើធៀបនឹងឆ្នាំសារពើពន្ធ ២០០៤ ។

(៣) សហគ្រាសដឹកជញ្ជូន

នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ អង្គភាពសាធារណៈមូលដ្ឋានចំនួន ៨៧ គ្រប់គ្រងសហគ្រាសដឹកជញ្ជូនចំនួន ១០៦ ក្នុងនោះមានសហគ្រាសអយរថអគ្គិសនីចំនួន ៥ សហគ្រាសរថយន្តក្រុងចំនួន ៤០ សហគ្រាសរថភ្លើងក្រោមដីចំនួន ១០ សហគ្រាសឯករណោបថចំនួន ២ និងសហគ្រាសទូក និងនាវាចំនួន ៤៩ ។

ចំនួនបុគ្គលិកដែលបម្រើការងារនៅក្នុងសហគ្រាសមានចំនួន ៣២.៥១៩ នាក់ ដែលក្នុងចំណោមនោះ បុគ្គលិកចំនួន ១៤.២៨៦ នាក់ ធ្វើការនៅក្នុងសហគ្រាសរថយន្តក្រុង និង ១៦.៥៩៧ នាក់ធ្វើការនៅក្នុងសហគ្រាសរថភ្លើងក្រោមដី ។

វិសាលភាពនៃសហគ្រាសចម្បងៗមានដូចតទៅ : សហគ្រាសរថយន្តក្រុងមានចម្ងាយផ្លូវផ្តល់សេវាប្រវែង ១០.១៨៥ គ.ម រត់លើចម្ងាយផ្លូវសរុបប្រវែង ៣២៤ លាន គ.ម ជាមួយនឹងរថយន្តក្រុងចំនួន ៩.៣៥៤ គ្រឿង និងដឹកជញ្ជូនប្រជាជនបានចំនួន ១.០៦៣ លាននាក់ក្នុងមួយឆ្នាំ ។ សហគ្រាសរថភ្លើងក្រោមដីមានចម្ងាយផ្លូវផ្តល់សេវាប្រវែង ៥០៩ គ.ម រត់លើចម្ងាយផ្លូវសរុបប្រវែង ៤១៣ លានគ.ម ជាមួយនឹងទូរថភ្លើងចំនួន ៤.៤២២ ទូ និងដឹកជញ្ជូនប្រជាជនបានចំនួន ២.៧៨៨ លាននាក់ក្នុងមួយឆ្នាំ ។ សហគ្រាសអយរថអគ្គិសនីមានចម្ងាយផ្លូវផ្តល់សេវាប្រវែង ៥៧ គ.ម រត់លើចម្ងាយផ្លូវប្រវែង ៧ លានគ.ម ជាមួយនឹងទូចំនួន ២១២ ទូ ។

ការពិនិត្យមើលឡើងវិញនៃលទ្ធផលការងារគ្រប់គ្រងការដឹកជញ្ជូន (សហគ្រាសសាធារណៈមូលដ្ឋាន ក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន លើកលែងទូក) នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ បង្ហាញអោយឃើញថា ការខាតបង់ដុល

មានចំនួនច្រើនជាងចំណេញដុល ។ ឱនភាពជាបន្តបន្ទាប់បានថយចុះបើធៀបទៅនឹងឆ្នាំសារពើពន្ធ ២០០៤ និងមានចំនួន ២.២៧៥.៦ ពាន់លានយេន ក្នុងឆ្នាំសារពើពន្ធ ២០០៥ ។ អកម្មចរន្ត (បំណុលរយៈពេលខ្លី) ដ៏ច្រើនលើសលុប មានចំនួនប្រមាណប្រហែល ២១៨.៤ ពាន់លានយេន ។

(៤) សហគ្រាសមន្ទីរពេទ្យ

មន្ទីរពេទ្យ (លើកលែងមន្ទីរពេទ្យជំងឺឆ្លង) នៅក្នុងប្រទេសជប៉ុន មានចំនួន ៩.០៧៧ កន្លែង នៅត្រឹមថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ ។ ក្នុងចំណោមមន្ទីរពេទ្យទាំងនេះ មន្ទីរពេទ្យចំនួន ១.០៧៤ កន្លែង (១១.៨%) ដំណើរការដោយអង្គភាពសាធារណៈមូលដ្ឋាន ។

សហគ្រាសមន្ទីរពេទ្យដែលច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋានអនុវត្តចំពោះ មានចំនួន ៦៧៤ នៅដំណាច់ឆ្នាំសារពើពន្ធ ២០០៥ ហើយមន្ទីរពេទ្យដែលគ្រប់គ្រងដោយអង្គភាពសាធារណៈមូលដ្ឋានមានចំនួន ៩៨២ ។ ក្នុងចំណោមមន្ទីរពេទ្យទាំងនេះ មន្ទីរពេទ្យចំនួន ២១៧ ដំណើរការដោយខេត្តចំនួន ៤៧ មន្ទីរពេទ្យចំនួន ៣៧ ដោយក្រុងចាត់តាំងចំនួន ១៤ មន្ទីរពេទ្យចំនួន ៤១៨ ដោយក្រុងចំនួន ៣៣៧ មន្ទីរពេទ្យចំនួន ២០២ ដោយក្រុងចំនួន ១៩១ និងមន្ទីរពេទ្យចំនួន ១០៨ ដោយសហករណ៍ដោយផ្នែកនៃអង្គភាពសាធារណៈមូលដ្ឋានចំនួន ៨៥ ។ មានមន្ទីរពេទ្យធម្មតាចំនួន ៩៣៥ កន្លែង មន្ទីរពេទ្យរបេងចំនួន ១កន្លែង និងមន្ទីរពេទ្យព្យាបាលជំងឺផ្លូវចិត្តចំនួន ៤៦ កន្លែង ។

ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន អនុវត្តយ៉ាងពេញលេញចំពោះសហគ្រាសចំនួន ១៨ ដែលប្រតិបត្តិដោយខេត្ត ដែលពាក់ព័ន្ធនឹងមន្ទីរពេទ្យចំនួន ១២០ កន្លែង ដែលនៅក្នុងចំណោមមន្ទីរពេទ្យទាំងអស់ មន្ទីរពេទ្យចំនួន ៥ ប្រតិបត្តិដោយក្រុងចាត់តាំង (ដែលមានមន្ទីរពេទ្យចំនួន ១៥ កន្លែង) ៤៥ ដោយក្រុង (ដែលមានមន្ទីរពេទ្យចំនួន ៥៩ កន្លែង) ១២ ដោយឃុំ និងភូមិ (ដែលមានមន្ទីរពេទ្យចំនួន ១៤ កន្លែង) និង ១ ដោយសហករណ៍ដោយផ្នែកនៃអង្គភាពសាធារណៈមូលដ្ឋាន (ដែលមានមន្ទីរពេទ្យចំនួន ១ កន្លែង) សរុបមានសហគ្រាសចំនួន ៨១ និងមន្ទីរពេទ្យចំនួន ២០៩ ។

នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ចំណូលសរុបមានចំនួន ៤.១៥៤.៤ ពាន់លានយេន ចំណែកចំណាយសរុបមានចំនួន ៤.៣០២.១ ពាន់លានយេន ដោយហេតុនេះ ការខាតបង់សុទ្ធសរុបមានចំនួន ១៤៧.៦ ពាន់លានយេន ។

# ចំនួនមន្ទីរពេទ្យ

| អង្គភាព គ្រប់គ្រង<br>ថ្នាក់ | សហគ្រាសសាធារណៈមូលដ្ឋាន | | | | | | រដ្ឋាភិបាល<br>ថ្នាក់ជាតិ | ស្ថាប័នវេជ្ជសាស្ត្រ<br>សាធារណៈ<br>ដូចជាកាកក្របាទ<br>ក្រហមជប៉ុន | សាជីវកម្ម និង<br>ឯកត្តបុគ្គល<br>វេជ្ជសាស្ត្រ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | ខេត្ត | ក្រុងចាត់តាំង | ក្រុង | ឃុំ និងភូមិ | សមាគម | សរុប | | | | |
| មន្ទីរពេទ្យធម្មតា<br>- លើសពី ៣០០ គ្រែ | (៥០.០)<br>៨៨ | (៦៦.៧)<br>២៤ | (៣៧.៦)<br>១៥៦ | (០.៥)<br>១ | (៣៧.៤)<br>៤០ | (៣៣.០)<br>៣០៩ | (៧១.០)<br>២១៣ | (៥៤.៤)<br>-១៦២ | (៦.៦)<br>៣៦២ | (២៧.៣)<br>២៤៨ |
| - ១០០ គ្រែ<br>ប៉ុន្តែតិចជាង<br>៣០០ គ្រែ | (៣៨.១)<br>៦៧ | (៣០.៦)<br>១១ | (៣៩.៣)<br>១៦៣ | (៣០.៣)<br>៦១ | (៤០.២)<br>៤៣ | (៣៦.៩)<br>៣៤៥ | (២១.៧)<br>៦៥ | (៣៤.២)<br>១០២ | (៣៨.៩)<br>២.១២៨ | (៤៩.០)<br>៤៤៦ |
| - តិចជាង ១០០<br>គ្រែ | (១១.៩)<br>២១ | (២.៨)<br>១ | (២៣.១)<br>៩៦ | (៦៩.២)<br>១៣៩ | (២២.៤)<br>២៤ | (៣០.១)<br>២៨១ | (៩.៣)<br>២២ | (១១.៤)<br>៣៤ | (៥៤.៤)<br>២.៩៧៤ | (២៣.៧)<br>២១៦ |
| កំពុងសាងសង់ | (-)<br>- | (-)<br>- | (-)<br>- | - | (-)<br>- | (០.១)<br>១ | - | - | - | - |
| សរុប | (១០០.០)<br>១៧៦ | (១០០.០)<br>៣៦ | (១០០.០)<br>៤១៥ | (១០០.០)<br>២០១ | (១០០.០)<br>១០៧ | (១០០.០)<br>៩៣៥ | (១០០.០)<br>៣០០ | (១០០.០)<br>២៩៨ | (១០០.០)<br>៥.៤៦៤ | (១០០.០)<br>៩១០ |
| មន្ទីរពេទ្យរបេង | ១ | - | - | - | - | ១ | - | - | ១ | ១ |
| មន្ទីរពេទ្យផ្លូវចិត្ត | ៤០ | ១ | ៣ | ១ | ១ | ៤៦ | ៤ | ៥ | ៩៣៩ | ៨១ |
| កំពុងសាងសង់ | - | - | - | - | - | - | - | - | - | - |
| សរុប | ២១៧ | ៣៧ | ៤១៨ | ២០២ | ១០៨ | ៩៨២ | ៣០៤ | ៣០៣ | ៦.៤០៤ | ៩៩២ |

កំណត់សម្គាល់ : ១. តួលេខនៅក្នុងកូឡោនសហគ្រាសសាធារណៈមូលដ្ឋាន គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ (មន្ទីរពេទ្យដែលមានដំណើរការស្របតាមសហគ្រាសសាធារណៈមូលដ្ឋាន ។ ទិន្នន័យប្រកាសផ្សាយដោយក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍) ។ តួលេខផ្សេងទៀត គិតត្រឹមថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ (មិនរាប់មន្ទីរពេទ្យហង់សិន និងមន្ទីរពេទ្យជំងឺឆ្លង ។ ទិន្នន័យទទួលបានពីក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព) ។

២. តួលេខនៅក្នុងវង់ក្រចកគឺគិតជាភាគរយ ។

(៥) សហគ្រាសផ្គត់ផ្គង់អគ្គិសនី

នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ចំនួនសហគ្រាសផ្គត់ផ្គង់អគ្គិសនីសាធារណៈ ដែលប្រតិបត្តិដោយអង្គភាពសាធារណៈមូលដ្ឋានមានចំនួន ១១៥ (ដែលក្នុងនោះ ៣១ មានច្បាប់ និង ៨៤ គ្មាន) ហើយចំនួនរោងចក្រអគ្គិសនីកំពុងដំណើរការមានចំនួន ៤៤៧ (ដែលក្នុងនោះ ២៩២ គឺជារោងចក្រវារីអគ្គិសនី ៤ គឺជារោងចក្រអគ្គិសនីដំណើរការដោយប្រើសំរាមខ្លាំង និង ៣៦ គឺជារោងចក្រអគ្គិសនីដើរដោយខ្យល់) ។

១) សហគ្រាសសាធារណៈមូលដ្ឋានក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន

ខេត្តដែលដំណើរការសហគ្រាសផ្គត់ផ្គង់អគ្គិសនី មានចំនួន ៣០ ដោយមានរោងចក្រអគ្គិសនីសរុបចំនួន ៣១៣ កន្លែង (រួមទាំងរោងចក្រកំពុងសាងសង់ចំនួន ១៣ កន្លែង) ក្នុងឆ្នាំសារពើពន្ធ ២០០៥ ។ បន្ថែមពីលើនេះទៀត មានសហគ្រាសចំនួនមួយ (ដោយមានរោងចក្រចំនួន ៥) ដំណើរការដោយក្រុង ។ រោងចក្រទាំងនេះភាគច្រើន គឺជារោងចក្រវារីអគ្គិសនី (លើកលែងរោងចក្រចំនួន ១៦ ផ្សេងទៀត) ហើយលទ្ធភាពផលិតប្រែប្រួលពីអប្បបរមា ៥១ គីឡូវ៉ាត់ ទៅអតិបរមា ២៥០.០០០ គីឡូវ៉ាត់ ដោយជាមធ្យមមាន ៨.៧៣២ គីឡូវ៉ាត់ ដែលជាកម្រិតមួយដ៏ទាប ។

ចំណូលដុលរបស់សហគ្រាសអគ្គិសនីក្នុងឆ្នាំសារពើពន្ធ ២០០៥ គឺ ៨៥.៦ ពាន់លានយេន ហើយចំណាយសរុប គឺ ៧៨.២ ពាន់លានយេន ។ ចំណាយមូលធនគឺ ៤៦.៦ ពាន់លានយេន រួមមាន ១៣.៤ ពាន់លានយេន នៅក្នុងថ្លៃចំណាយសាងសង់ និងកែលម្អ និង ១៤.៦ ពាន់លានយេន សម្រាប់សងសញ្ញាប័ណ្ណសហគ្រាស ។

ធនធានហិរញ្ញវត្ថុរួមមានមូលនិធិបម្រុងផ្ទៃក្នុងចំនួន ៣៨.៤ ពាន់លានយេន និងប័ណ្ណប្រាក់សហគ្រាសចំនួន ២.១ ពាន់លានយេន ។ មូលនិធិបម្រុងផ្ទៃក្នុងមានចំនួន ៨២.៦% នៃធនធានសរុប ហើយអត្រាខ្ពស់នេះ គឺជាលក្ខណៈពិសេសមួយនៃសហគ្រាសអគ្គិសនី ។

២) សហគ្រាសផ្សេងទៀត

ខេត្ត ១ ដែលមានរោងចក្រ ១ ប្រតិបត្តិសហគ្រាសផ្គត់ផ្គង់អគ្គិសនី នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ។ បន្ថែមពីលើនេះទៀត មានសហគ្រាសចំនួន ១២ ដែលមានរោងចក្រ ៣៩ (រួមមាន រោងចក្រកំពុងសាងសង់ចំនួន ១) ដំណើរការដោយក្រុងចាត់តាំង សហគ្រាសចំនួន ៤២ ដែលមានរោងចក្រចំនួន ៥៥ ដំណើរការដោយក្រុង សហគ្រាសចំនួន ១៥ ដែលមានរោងចក្រចំនួន ១៦ ដំណើរការដោយឃុំ និងភូមិ និងសហគ្រាសចំនួន ១៤ ដែលមានរោងចក្រចំនួន ៣៤ រួមទាំងរោងចក្រកំពុងសាងសង់ចំនួន ២ ដំណើរការដោយសហករណ៍ដោយផ្នែកនៃអាជ្ញាធរមូលដ្ឋាន ។ រោងចក្រទាំងនេះភាគច្រើន គឺជារោងចក្រអគ្គិសនីដំណើរការដោយប្រើសំរាម (លើកលែងរោងចក្រអគ្គិសនីដំណើរការដោយប្រើសំរាមខ្លាំងចំនួន ៣ រោងចក្រវារីអគ្គិសនីចំនួន ៣ និងរោងចក្រអគ្គិសនីដើរដោយខ្យល់ចំនួន ២២) ហើយលទ្ធភាពផលិតប្រែប្រួលពីអប្បបរមា ៩០០ គីឡូវ៉ាត់ ទៅអតិបរមា ៥០.០០០ គីឡូវ៉ាត់ ដោយជាមធ្យមមាន ៨.១៨១ គីឡូវ៉ាត់ ដែលជាកម្រិតមួយដ៏ធំ ។

ចំណូលដុលរបស់សហគ្រាសទាំងនេះនៅក្នុងឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ១៨.៨ ពាន់លានយេន ហើយចំណាយសរុបមានចំនួន ៦.៣ ពាន់លានយេន ។ សហគ្រាសទាំងអស់មានប្រាក់ចំណេញសុទ្ធ ។ ចំណាយមូលធនមានចំនួន ១៥.៧ ពាន់លានយេន រួមមានថ្លៃចំណាយសាងសង់ និងកែលម្អចំនួន ៤.០ ពាន់លានយេន ។

(៦) សហគ្រាសផ្គត់ផ្គង់ហ្គាស

នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ចំនួនសហគ្រាសផ្គត់ផ្គង់ហ្គាសសាធារណៈមាន ៣៧ ។ ការបែងចែកសហគ្រាសផ្គត់ផ្គង់ហ្គាសដោយអង្គភាពគ្រប់គ្រងបង្ហាញថា មានសហគ្រាស ១ ប្រតិបត្តិដោយក្រុងចាត់តាំងចំនួនមួយ សហគ្រាស ២៧ ប្រតិបត្តិដោយក្រុងផ្សេងៗ សហគ្រាស ៨ ប្រតិបត្តិដោយឃុំ និងភូមិ និងសហគ្រាស ១ ប្រតិបត្តិដោយសមាគមសហគ្រាស ។ សហគ្រាសជាច្រើនស្ថិតនៅខេត្ត Niigata ខេត្ត Akita និងខេត្ត Chiba ជាកន្លែងដែលហ្គាសធម្មជាតិត្រូវបានផលិត និងខ្សែបំពង់ហ្គាសធម្មជាតិត្រូវបានសាងសង់ ។ បរិមាណផ្គត់ផ្គង់របស់សហគ្រាសទាំងនេះមានចំនួន ៣៣ លានម៉ែ (១.000 MJ ត្រូវបានបំលែង) ។ សហគ្រាសសរុបចំនួន ៣៣ ផ្គត់ផ្គង់ហ្គាសធម្មជាតិ (៣១ លានម៉ែ) និងសហគ្រាសចំនួន ៤ ផ្គត់ផ្គង់ហ្គាសផលិតដោយរោងចក្រ (២ លានម៉ែ) ។ លំនៅដ្ឋានចំនួន ១,0២ លាន ទទួលការផ្គត់ផ្គង់ពីសហគ្រាសទាំងនេះ ។

(៧) សហគ្រាសបង្ហូរទឹកស្អុយ

នៅក្នុងប្រទេសជប៉ុន សេវាកម្មបង្ហូរទឹកស្អុយត្រូវផ្តល់ដោយសហគ្រាសសាធារណៈក្រុង និងខេត្ត ។ ទម្រង់ចម្បងនៃសេវាកម្មនេះ រួមមាន ប្រព័ន្ធបង្ហូរទឹកស្អុយសាធារណៈ ប្រព័ន្ធបង្ហូរទឹកស្អុយទៅអាងស្តុកធំ និងប្រព័ន្ធបង្ហូរទឹកស្អុយការពារបរិស្ថានជាក់លាក់ ។

ប្រព័ន្ធបង្ហូរទឹកស្អុយសាធារណៈ ត្រូវបានដំឡើងនៅក្នុងក្រុងដែលរៀបចំជាតំបន់ និងប្រតិបត្តិដោយសាលាក្រុង ។ ប្រព័ន្ធទាំងនេះគឺជាប្រព័ន្ធបិទ ដែលមានបណ្តាញបំពង់បង្ហូរ និងរោងចក្រសម្អាតទឹកស្អុយស្ថិតនៅក្នុងព្រំដែនក្រុងដែលពាក់ព័ន្ធ ។ លើសពីនេះទៀត ប្រព័ន្ធបង្ហូរទឹកស្អុយទៅអាងស្តុកធំ គឺជាប្រព័ន្ធតាមតំបន់ ដែលបម្រើតំបន់ដ៏ធំហួសពីព្រំដែនក្រុងដែលមានខេត្តដែលទទួលខុសត្រូវចំពោះបំពង់បង្ហូរ និងរោងចក្រសម្អាតទឹក ហើយក្រុងនីមួយៗទទួលខុសត្រូវចំពោះបំពង់បង្ហូរ នៅក្នុងតំបន់របស់ខ្លួនផ្ទាល់ ។ ប្រព័ន្ធបង្ហូរទឹកស្អុយការពារបរិស្ថានជាក់លាក់សម្រាប់ថែរក្សាបរិស្ថាន គឺជាសេវាបង្ហូរទឹកស្អុយសាធារណៈដែលមាននៅក្នុងតំបន់កសិកម្ម តំបន់ភ្នំ ឬភូមិនេសាទ ដែលនៅក្រៅក្រុងរៀបចំតំបន់ ។

**អត្រាគ្របដណ្តប់សេវាបង្ហូរទឹកស្អុយ**




កំណត់សម្គាល់ : តួលេខយោងតាមទិន្នន័យទទួលបានពី សៀវភៅទិន្នន័យបរិស្ថាន OECD (លើកលែងចំពោះប្រទេសជប៉ុន)

**ប្រព័ន្ធបង្ហូរទឹកស្អុយសាធារណៈ**




**ប្រព័ន្ធបង្ហូរទឹកស្អុយទៅក្នុងអាងស្តុកធំ**



លើសពីនេះទៀត មានប្រភេទប្រព័ន្ធបង្ហូរគ្រប់គ្រងកាកសំណល់ឧស្សាហកម្មជាក់លាក់ ដែលបង្កើតឡើងដើម្បីសម្អាតទឹកកាកសំណល់ឧស្សាហកម្ម ។

នៅតំបន់ជនបទ ប្រព័ន្ធបង្ហូរទឹកស្អុយខ្នាតតូចផ្សេងទៀត ដែលសមស្របសម្រាប់តំបន់មិនសូវមានប្រជាជនរស់នៅត្រូវបានប្រើប្រាស់ ដូចជា គម្រោងបង្ហូរទឹកស្អុយជនបទ និងអាងសម្អាតទឹកកាកសំណល់ក្នុងផ្ទះ ។

ចំនួនសហគ្រាសសរុបនៅក្នុងឆ្នាំសារពើពន្ធ ២០០៥ មានចំនួន ៣.៦៩៩ (រួមទាំងសហគ្រាសចំនួន ១៩៤ ដែលកំពុងសាងសង់) ដែលក្នុងនោះមានប្រព័ន្ធបង្ហូរទឹកស្អុយសាធារណៈចំនួន ១.២៤២ ប្រព័ន្ធបង្ហូរទឹកស្អុយការពារបរិស្ថានជាក់លាក់ចំនួន ៧៨០ ប្រព័ន្ធបង្ហូរទឹកស្អុយទៅអាងស្តុកធំចំនួន ៥៤ ប្រព័ន្ធបង្ហូរគ្រប់គ្រងកាកសំណល់ឧស្សាហកម្មជាក់-លាក់ចំនួន ១៣ ប្រព័ន្ធបង្ហូរទឹកស្អុយជនបទចំនួន ៩៦៧ ព្រមទាំងប្រព័ន្ធបង្ហូរទឹកស្អុយដទៃផ្សេងទៀត ។

ប្រព័ន្ធបង្ហូរទឹកស្អុយទាំងនេះបម្រើដល់ប្រជាជនចំនួន ៨០,៩% នៅដំណាច់ឆ្នាំសារពើពន្ធ ២០០៥ ។

សហគ្រាសបង្ហូរទឹកស្អុយត្រូវបានអោយនិយមន័យថាជាសហគ្រាសសាធារណៈ ហើយថ្លៃសាងសង់ និងថែទាំប្រព័ន្ធបង្ហូរទឹកស្អុយត្រូវបង់ដោយចំណូលប្រតិបត្តិនៃសហគ្រាស លើកលែងតែថ្លៃទាំងឡាយណាដែលតាមប្រភេទលក្ខណៈរបស់វា ត្រូវរ៉ាប់រងដោយគណនីទូទៅនៃអង្គភាពសាធារណៈមូលដ្ឋាន ។

ទោះជាយ៉ាងក៏ដោយ នៅក្នុងសហគ្រាសជាច្រើន កម្រិតបន្ទុកសេវា គឺមិនគ្រប់គ្រាន់ដើម្បីទូទាត់ថ្លៃចំណាយមូលធន និងថ្លៃថែទាំនៃការសម្អាតទឹកកាកសំណល់ឡើយ ។ ដោយហេតុនេះ ឱនភាពត្រូវតែទូទាត់ដោយការផ្ទេរមូលនិធិក្នុងទ្រង់ទ្រាយធំពីគណនីទូទៅ ។

នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ ចំណាយរដ្ឋបាល និងប្រតិបត្តិរបស់សហគ្រាសបង្ហូរទឹកស្អុយមានចំនួន ២.៦៧៤.២ ពាន់លានយេន ក្នុងខណៈដែលចំណូលសរុបរបស់សហគ្រាសទាំងនេះមានចំនួន ២.៨៨៥.៥ ពាន់លានយេន ។

(៨) ផ្សេងៗ

បន្ថែមពីលើសហគ្រាសនានាដែលបានរៀបរាប់រហូតមកដល់ពេលនេះ ក៏មានសហគ្រាសសម្រាប់កំពង់ផែ ទីផ្សារ ទីសត្តឃាត កន្លែងទេសចរណ៍ (កន្លែងសម្រាក កន្លែងស្នាក់នៅ ខ្សែជិះខ្សែយោង ។ល។) កន្លែងបម្រុងដីលំនៅដ្ឋាន ផ្លូវបង់ប្រាក់ ចំណត ។ល។ ផងដែរ ។

## ជំពូកទី ២ ~ សេចក្ដីបរិយាយអំពីប្រព័ន្ធសហគ្រាសសាធារណៈមូលដ្ឋាន

### ១. នីតិកម្មសម្រាប់សហគ្រាសសាធារណៈមូលដ្ឋាន

ដោយហេតុថាសហគ្រាសសាធារណៈមូលដ្ឋានត្រូវបានគ្រប់គ្រងដោយអង្គភាពសាធារណៈមូលដ្ឋាននោះ សហគ្រាសទាំងនេះត្រូវបានគ្រប់គ្រងដោយច្បាប់ទូទៅ ដែលអនុវត្តចំពោះប្រព័ន្ធស្វ័យភាពមូលដ្ឋាន ដូចជា ច្បាប់ស្ដីពីស្វ័យភាពមូលដ្ឋាន ដែលចែងអំពីមូលដ្ឋានគ្រឹះនៃប្រព័ន្ធរៀបចំ និងរដ្ឋបាលនៃអង្គភាពសាធារណៈមូលដ្ឋាន ច្បាប់ស្ដីពីហិរញ្ញវត្ថុមូលដ្ឋាន និងច្បាប់ស្ដីពីសេវាសាធារណៈមូលដ្ឋាន ។ បន្ថែមពីលើច្បាប់ទាំងនេះ ច្បាប់ស្ដីពីសហគ្រាសសាធារណៈមូលដ្ឋាន ក៏ត្រូវបានប្រកាសអោយប្រើដោយពិចារណាលើលក្ខខណ្ឌតម្រូវពិសេស ដើម្បីលើកកម្ពស់ប្រតិបត្តិការនៃសហគ្រាសសាធារណៈមូលដ្ឋានដោយរលូន និងប្រសិទ្ធភាព ។ ច្បាប់ស្ដីពីសហគ្រាសសាធារណៈមូលដ្ឋាន ចែងអំពីលក្ខណៈវិនិច្ឆ័យនៃការគ្រប់គ្រងមូលដ្ឋាន ទាក់ទងនឹងការរៀបចំ ការគ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិកសហគ្រាសសាធារណៈមូលដ្ឋាន បញ្ហាទាក់ទងនឹងសមាគមសហគ្រាស និងវិធានការដែលត្រូវចាត់ដើម្បីកសាងហិរញ្ញវត្ថុសហគ្រាសសាធារណៈមូលដ្ឋានឡើងវិញ ។

ក្រោមច្បាប់ស្ដីពីទំនាក់ទំនងវិជ្ជាជីវៈរបស់សហគ្រាសសាធារណៈមូលដ្ឋាន បុគ្គលិកសហគ្រាសសាធារណៈមូលដ្ឋានក៏មានសិទ្ធិទទួលការប្រព្រឹត្តខុសប្លែកពីបុគ្គលិកសាធារណៈមូលដ្ឋានផ្សេងទៀត ។

លើសពីនេះទៀត ដូចជាសហគ្រាសឯកជនដែរ សហគ្រាសសាធារណៈមូលដ្ឋាន ស្ថិតក្រោមច្បាប់ស្ដីពីសហគ្រាសផ្សេងៗ ។ គោលបំណងនៃបទប្បញ្ញត្តិទាំងនេះ គឺដើម្បីធានាសេវាសមហេតុផល ក្នុងតម្លៃសមស្រប ។

ខាងក្រោមនេះ គឺជាច្បាប់គ្រឹះមួយចំនួន សម្រាប់ប្រភេទសហគ្រាសផ្សេងៗគ្នា :

ក) ការផ្គត់ផ្គង់ទឹកស្អាត - ច្បាប់ស្ដីពីស្ថានីយបូមទឹក (ឆ្នាំ១៩៥៧)

ខ) ការផ្គត់ផ្គង់ទឹកឧស្សាហកម្ម - ច្បាប់ស្ដីពីការផ្គត់ផ្គង់ទឹកឧស្សាហកម្ម (ឆ្នាំ១៩៥៦)

គ) សេវាអយរថអគ្គិសនី - ច្បាប់ស្ដីពីអយរថអគ្គិសនី (ឆ្នាំ១៩២១)

ឃ) សេវារថយន្តក្រុង - ច្បាប់ស្ដីពីការដឹកជញ្ជូនផ្លូវគោក (ឆ្នាំ១៩៥១)

ង) សេវាអយស្ម័យយាន - ច្បាប់ស្ដីពីអយស្ម័យយានសាធារណៈ (ឆ្នាំ១៩៨៦)

ច) សេវាថាមពលអគ្គិសនី - ច្បាប់ស្ដីពីសហគ្រាសអគ្គិសនី (ឆ្នាំ១៩៦៤)

ឆ) សេវាផ្គត់ផ្គង់ហ្គាស - ច្បាប់ស្ដីពីសហគ្រាសហ្គាស (ឆ្នាំ១៩៥៤)

ជ) សេវាវេជ្ជសាស្ត្រ - ច្បាប់ស្ដីពីការថែទាំវេជ្ជសាស្ត្រ (ឆ្នាំ១៩៤៨)

ឈ) សេវាបង្ហូរទឹកស្អុយ - ច្បាប់ស្ដីពីការបង្ហូរទឹកស្អុយ (ឆ្នាំ១៩៥៨)

ប្រភេទផ្សេងៗនៃសហគ្រាសសាធារណៈមូលដ្ឋានអាចត្រូវបានចាត់ថ្នាក់ជាបីប្រភេទ ដើម្បីអនុវត្តច្បាប់ស្ដីពីសហគ្រាសសាធារណៈមូលដ្ឋាន ។

(១) សហគ្រាសដែលអនុវត្តចំពោះបញ្ញត្តិទាំងអស់ (សហគ្រាសទាំងឡាយណាដែលជាទូទៅហៅថា សេវាសាធារណៈ) : ប្រភេទនេះរួមមាន សេវាផ្គត់ផ្គង់ទឹកស្អាត ទឹកឧស្សាហកម្ម អយរថអគ្គិសនី រថយន្តក្រុង អយស្ម័យយាន អគ្គិសនី និងហ្គាស ។

(២) សហគ្រាសដែលអនុវត្តតែចំពោះបញ្ញត្តិហិរញ្ញវត្ថុនៃច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋានប៉ុណ្ណោះ : ប្រភេទនេះរួមមានសេវាវេជ្ជសាស្ត្រ ។

(៣) សហគ្រាសផ្សេងទៀត : អង្គភាពសាធារណៈមូលដ្ឋានមានសិទ្ធិសម្រេចថាតើត្រូវអនុវត្តចំពោះបញ្ញត្តិទាំងអស់ (ឬតែបញ្ញត្តិហិរញ្ញវត្ថុ) នៃច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ឬយ៉ាងណា ។

## ២. គោលការណ៍ណែនាំនៃច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន

ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋានចែងអំពីស្តង់ដារគ្រឹះនៃការរៀបចំហិរញ្ញវត្ថុ និងរដ្ឋបាលបុគ្គលិកនៃសហគ្រាសសាធារណៈមូលដ្ឋាន ។ ខាងក្រោមនេះ គឺជាគោលការណ៍ណែនាំនៃច្បាប់ ។

(១) គោលការណ៍គ្រប់គ្រងមូលដ្ឋាន

ដូចដែលមានឆ្លុះបញ្ចាំងនៅក្នុងពាក្យ "សហគ្រាសសាធារណៈមូលដ្ឋាន" អង្គភាពទាំងនេះដើរតួនាទីពីរ ជា "សាធារណៈ" ផង និង "សហគ្រាស" ផង ។ គេអាចនិយាយថា គោលការណ៍រដ្ឋបាលគ្រឹះសម្រាប់សហគ្រាសសាធារណៈមូលដ្ឋាន ត្រូវបានកំណត់ដោយមុខងារទាំងពីរនេះ ។ នៅក្នុងបរិបទនេះ ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ចែងថា "សហគ្រាសសាធារណៈមូលដ្ឋាននីមួយៗ ជានិច្ចកាលត្រូវតែប្រតិបត្តិបែបនេះ ដើម្បីធានាអោយមានសេវាប្រយោជន៍ទូទៅជាអតិបរមាសម្រាប់សាធារណជន ស្របតាមបេសកកម្មរបស់ខ្លួន ព្រមទាំងដើម្បីធ្វើអោយខ្លួនឯងមានស្វ័យភាពផ្នែកសេដ្ឋកិច្ច ។"

ដោយហេតុនេះ សហគ្រាសមូលដ្ឋាននីមួយៗចាំបាច់ត្រូវគ្រប់គ្រង ដើម្បីរក្សាតុល្យភាពរវាងគោលការណ៍ស្វ័យភាពសេដ្ឋកិច្ច និងគោលដៅសុខុមាលភាពសាធារណៈរបស់ខ្លួន ។ ទោះបីជាវត្ថុបំណងទាំងពីរនេះ ទំនងជាមានភាពផ្ទុយគ្នានៅពេលយើងក្រឡេកមើលដំបូងក៏ដោយ ប៉ុន្តែតាមការពិត វត្ថុបំណងទាំងពីរនេះមិនផ្ទុយគ្នាទេ ។ ដើម្បីអោយសហគ្រាសសាធារណៈមូលដ្ឋានទាញយកអត្ថប្រយោជន៍ដ៏ពេញលេញពីទិដ្ឋភាពសេដ្ឋកិច្ចរបស់ខ្លួន និងដើម្បីផ្តល់សេវាប្រសើរបំផុតដោយចំណាយថ្លៃដើមតិចបំផុត តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធផល គឺសហគ្រាសសាធារណៈមូលដ្ឋាននោះខ្លួនឯងដែលត្រូវលើកកម្ពស់សុខុមាលភាពសាធារណៈ ។

(២) ការរៀបចំ

ខុសពីសាជីវកម្មសាធារណៈ សហគ្រាសសាធារណៈមូលដ្ឋានមិនមែនជាអង្គភាពឯករាជ្យឡើយ ។ សហគ្រាសសាធារណៈមូលដ្ឋាន ត្រូវកាន់កាប់ និងប្រតិបត្តិដោយផ្ទាល់ដោយអង្គភាពសាធារណៈមូលដ្ឋាន ហើយការរៀបចំរបស់វាក៏ត្រូវស្ថិតនៅក្នុងការរៀបចំរបស់អង្គភាពសាធារណៈមូលដ្ឋានដែរ ។

ទោះជាយ៉ាងណាក៏ដោយ សកម្មភាពរបស់សហគ្រាសសាធារណៈមូលដ្ឋានភាគច្រើនគឺជាសកម្មភាពសេដ្ឋកិច្ចដែលទាមទារអោយមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីទប់ទល់ទៅនឹងស្ថានភាពសេដ្ឋកិច្ចដែលតែងតែមានការប្រែប្រួល ហើយពាក់ព័ន្ធនឹងចំណុចនេះ សកម្មភាពទាំងនេះខុសប្លែកពីសកម្មភាពរដ្ឋបាលទូទៅរបស់អង្គភាពសាធារណៈមូលដ្ឋាន ។ ដោយហេតុនេះ គេសង្ឃឹមថាសហគ្រាសនីមួយៗនឹងមានភាពច្បាស់លាស់ចំពោះឯករាជភាព និងទំនួលខុសត្រូវរបស់ខ្លួន ដើម្បីរក្សាអោយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធផល ។

ហេតុដូចនេះបានជាច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ធ្វើការបែងចែកការរៀបចំការគ្រប់គ្រងសហគ្រាសសាធារណៈមូលដ្ឋានអោយដាច់ពីការរៀបចំការគ្រប់គ្រងអង្គភាពរដ្ឋបាលទូទៅ និងបង្កើតនៅក្នុងសហគ្រាសនីមួយៗនូវនាយកចាត់ការទូទៅដែលទទួលសិទ្ធិគ្រប់គ្រងសហគ្រាសរបស់ខ្លួនដោយឯករាជ្យ ។ នាយកចាត់ការទូទៅ មានភារកិច្ចអនុវត្តប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃនៃសហគ្រាសរបស់ខ្លួន និងត្រូវតំណាងអោយអង្គភាពសាធារណៈមូលដ្ឋាន នៅក្នុងការធ្វើអាជីវកម្មបែបនោះ ហើយមិនត្រូវស្ថិតក្រោមការឃ្លាំមើលទូទៅ ឬការបង្គាប់បញ្ជារបស់នាយកប្រតិបត្តិនៃអង្គភាពសាធារណៈមូលដ្ឋានឡើយ ។ ដោយហេតុនេះ ច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋានមានចែងអំពីបទប្បញ្ញត្តិពិសេស សម្រាប់នាយកចាត់ការទូទៅប្រភេទនេះ ។

នាយកចាត់ការទូទៅសហគ្រាសនីមួយៗ ត្រូវតែងតាំងដោយនាយកប្រតិបត្តិនៃអង្គភាពសាធារណៈមូលដ្ឋាន ដោយជ្រើសរើសចេញពីក្នុងចំណោមបុគ្គលទាំងឡាយ ដែលមានបទពិសោធន៍ល្អនៅក្នុងការគ្រប់គ្រងសហគ្រាសសាធារណៈមូលដ្ឋាន ។ មុខដំណែងរបស់នាយកចាត់ការទូទៅមានរយៈពេលបួនឆ្នាំ ។ ទោះជាយ៉ាងណាក៏ដោយ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិ មុខតំណែងនាយកចាត់ការទូទៅ ពុំចាំបាច់មានឡើយនៅក្នុងសហគ្រាសខ្នាតតូចខ្លាំង ឬក៏សហគ្រាសស្រដៀងនេះពីរ ឬច្រើនជាងនេះ អាចមាននាយកចាត់ការទូទៅតែម្នាក់រួមគ្នា ។

ក្នុងរបៀបនេះ នាយកចាត់ការទូទៅមានសិទ្ធិអំណាចធំបំផុតពីលើរដ្ឋបាលរបស់សហគ្រាសសាធារណៈមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិអំណាចដូចខាងក្រោមនេះ មានសម្រាប់តែនាយកប្រតិបត្តិអង្គភាពសាធារណៈមូលដ្ឋានប៉ុណ្ណោះ :

ក) រៀបចំគម្រោងថវិកា ។

ខ) ផ្ញើសេចក្តីព្រាងច្បាប់ជូនសភា លើបញ្ហាណាមួយដែលតម្រូវអោយមានការបោះឆ្នោត ។

គ) ផ្ញើបញ្ជីគណនីស្ថាពររបស់ខ្លួនទៅស្នងការអធិការកិច្ច ដើម្បីធ្វើសវនកម្ម និងទៅសភា ដើម្បីសុំការបញ្ជាក់អំពីភាពត្រឹមត្រូវ ។

ឃ) ដាក់ពិន័យផ្នែករដ្ឋបាល ។

លើសពីនេះទៀត នាយកប្រតិបត្តិអង្គភាពសាធារណៈមូលដ្ឋាន មានឥទ្ធិពលធំធេងលើសុខុមាលភាពសាធារណៈ និងមានសិទ្ធិធ្វើការបង្គាប់បញ្ជាចាំបាច់ណាមួយ ដល់នាយកចាត់ការទូទៅទាក់ទងនឹងការប្រកបអាជីវកម្មរបស់សហគ្រាសសាធារណៈមូលដ្ឋាន ក្នុងករណីចាំបាច់ ដើម្បីធានាអោយមានសុខុមាលភាពសាធារណៈ ។ សិទ្ធិនេះក៏អាចត្រូវបានអនុវត្តដើម្បីធ្វើអោយមានភាពរលូននៅក្នុងការអនុវត្តប្រតិបត្តិការរបស់សហគ្រាសសាធារណៈមូលដ្ឋាន និងការអនុវត្តប្រតិបត្តិការរបស់អាជីវកម្មឯកជនផ្សេងទៀត ។

ខាងក្រោមនេះ គឺជាឧទាហរណ៍នៃសិទ្ធិអំណាចដែលត្រូវបានផ្តល់ជូននាយកចាត់ការទូទៅ :

ក) បង្កើតផ្នែកផ្សេងៗដើម្បីប្រតិបត្តិសហគ្រាស ។

ខ) គ្រប់គ្រងកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងបុគ្គលិក ។

គ) រៀបចំសេចក្តីព្រាងថវិកា និងសេចក្តីពន្យល់អត្ថាធិប្បាយនៃសេចក្តីព្រាងនេះ រួចបញ្ជូនទៅនាយកប្រតិបត្តិ ។

ឃ) បិទគណនី រួចបញ្ជូនទៅនាយកប្រតិបត្តិ ។

ង)	ធ្វើលទ្ធកម្ម គ្រប់គ្រង និងលក់ទ្រព្យសម្បត្តិក្នុងនាមសហគ្រាស ។

ច)	សម្រេចកិច្ចសន្យា ។

ឆ)	ប្រមូលថ្លៃសេវា និងថ្លៃបន្ទុក ។

ជ)	ចុះកិច្ចសន្យាខ្ចីបំណុលរយៈពេលខ្លី ។

ឈ)	រក្សាបញ្ជីគណនេយ្យ ។

ញ)	សម្រេចកិច្ចសន្យាការងារ ។

ដ)	រៀបចំវិធានអំពីប្រតិបត្តិការប្រចាំថ្ងៃរបស់ផ្នែករដ្ឋបាល ។

យោងតាមចំណុចទាំងឡាយខាងលើ គេអាចយល់បានថា ការអនុវត្តប្រតិបត្តិការប្រចាំថ្ងៃរបស់ផ្នែករដ្ឋបាលត្រូវបានប្រគល់ជូននាយកចាត់ការទូទៅទាំងស្រុង ដែលមានឯករាជភាពដ៏គួរអោយកត់សម្គាល់ពីនាយកប្រតិបត្តិ ។ គួរផ្តោតការយកចិត្តទុកដាក់ផងដែរអំពីប្រការដែលថា ការចូលរួមរបស់សភានៅក្នុងការគ្រប់គ្រងសហគ្រាស ក៏ត្រូវបានដាក់កំហិតផងដែរ ។

(៣)	ហិរញ្ញវត្ថុ

ក)	គោលនយោបាយកត់ត្រាបញ្ជីគណនេយ្យផ្អែកតាមលំហូរសាច់ប្រាក់ជាក់ស្តែង (Accrual Policy)

សហគ្រាសសាធារណៈមូលដ្ឋាននីមួយៗ ប្រើប្រាស់ប្រព័ន្ធកត់ត្រាបញ្ជីគណនេយ្យផ្អែកតាមលំហូរសាច់ប្រាក់ជាក់ស្តែងដែលមានលក្ខណៈពិសេសប្លែកពីគេចំពោះគណនេយ្យសហគ្រាស ដែលខុសគ្នាយ៉ាងខ្លាំងពីប្រព័ន្ធគណនេយ្យសាមញ្ញដែលផ្អែកតែលើសាច់ប្រាក់ ។ ដូច្នេះ សហគ្រាសសាធារណៈមូលដ្ឋានត្រូវកត់ត្រានូវរាល់ចំណាយ និងចំណូលទាំងអស់ដោយផ្អែកតាមលំហូរសាច់ប្រាក់ជាក់ស្តែង ដោយមិនគិតថាតើមានចំណូល ឬការទូទាត់ជាសាច់ប្រាក់ ហើយត្រូវបានបែងចែកប្រាក់ចំណូល ឬការទូទាត់ដែលនៅជំពាក់នោះអោយបានត្រឹមត្រូវ នៅក្នុងឆ្នាំសារពើពន្ធរបស់ខ្លួន ដើម្បីអោយស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនអាចត្រូវបានវាយតម្លៃយ៉ាងច្បាស់លាស់ ឬយ៉ាងណានោះទេ ។

ម្យ៉ាងទៀត សហគ្រាសសាធារណៈមូលដ្ឋាននីមួយៗត្រូវកត់ត្រានូវរាល់ការប្រែប្រួលពាក់ព័ន្ធនឹងទ្រព្យសកម្ម មូលធន និងអកម្ម (បំណុល) របស់ខ្លួន ដោយផ្អែកតាមលំហូរសាច់ប្រាក់ជាក់ស្តែង ដោយមិនគិតថាតើមានចំណូល ឬការទូទាត់ជាសាច់ប្រាក់ ដើម្បីអោយស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនអាចត្រូវបានវាយតម្លៃយ៉ាងច្បាស់លាស់ ឬយ៉ាងណានោះទេ ។

ខ)	គណនីពិសេស និងការបែងចែកចំណាយ

សហគ្រាសសាធារណៈមូលដ្ឋានត្រូវបានផ្តល់ហិរញ្ញវត្ថុក្រោម "គណនីពិសេស" ដែលបង្កើតឡើងសម្រាប់សេវានីមួយៗ ។ នេះមានន័យថា សហគ្រាសមូលដ្ឋានត្រូវបានគ្រប់គ្រងដោយមានគណនីដាច់ដោយឡែកមួយពីគណនីសេវាទូទៅរបស់អង្គភាពសាធារណៈមូលដ្ឋាន ។ (ទោះជាយ៉ាងណាក៏ដោយ អង្គភាពសាធារណៈមូលដ្ឋានដែលប្រតិបត្តិសេវាពីរ ឬច្រើនជាងនេះ អាចបង្កើតគណនីពិសេសសម្រាប់សេវាទាំងនោះរួមគ្នា ដូចមានចែងដោយដីកាពាក់ព័ន្ធ) ។ ហេតុផលគ្រឹះដែលត្រូវមានគណនី ដាច់ដោយឡែកពីគ្នាគឺថា សហគ្រាសសាធារណៈមូលដ្ឋានត្រូវទ្រទ្រង់ដោយចំណូល ដែលបានមកពីការគ្រប់គ្រងសហគ្រាស ។ ការផ្តល់ហិរញ្ញប្បទានដោយឯករាជ្យបែបនេះ អាចចាត់ទុកថាជាគោលការណ៍គ្រឹះបំផុតនៃការគ្រប់គ្រងសម្រាប់សហគ្រាសសាធារណៈមូលដ្ឋានទាំងអស់ ។

ទោះជាយ៉ាងណាក៏ដោយ គប្បីកត់ត្រាអំពីប្រការដែលថាសហគ្រាសសាធារណៈមូលដ្ឋាន ក៏អនុវត្តសកម្មភាពអាជីវកម្មមួយចំនួនដែលតាមលក្ខណៈរបស់វា គប្បីត្រូវចាត់ទុកថាជាអាជីវកម្មរដ្ឋបាលទូទៅ ។ ឧទាហរណ៍នៃករណីនេះ គឺទឹកត្រូវបានផ្គត់ផ្គង់ដោយសេវាផ្គត់ផ្គង់ទឹកក្រុង សម្រាប់គោលបំណងពន្លត់អគ្គិភ័យ ។

លើសពីនេះទៀត សហគ្រាសដែលមិនអាចរកប្រាក់ចំណេញគ្រប់គ្រាន់ សម្រាប់ទប់ទល់នឹងការចំណាយទាំងអស់ ជាញឹកញាប់ត្រូវប្រតិបត្តិដោយសហគ្រាសសាធារណៈ ដើម្បីបំពេញតាមតម្រូវការរបស់សាធារណជន ។ ឧទាហរណ៍ គឺរដ្ឋបាលមន្ទីរពេទ្យនៅក្នុងស្រុក ដែលមិនផ្តល់ជំនួយហិរញ្ញវត្ថុដល់មន្ទីរពេទ្យ ។ ក្នុងករណីនោះ ជាការមិនសមហេតុផល ឬមិនអាចទៅរួច ដែលដាក់បន្ទុកចំណាយទាំងមូលលើសហគ្រាសខ្លួនឯង ។

ដោយហេតុនេះ ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន ចែងថា (ក) ចំណាយក្នុងប្រភេទបែបនោះដែលមិនត្រូវបានផ្តល់ហិរញ្ញវត្ថុពីចំណូលបច្ចុប្បន្នដែលទទួលបានពីប្រតិបត្តិការសហគ្រាស និង (ខ) ដោយសារប្រភេទនៃសហគ្រាសនេះ ចំណាយដែលត្រូវបានចាត់ទុកថាមានការពិបាកក្នុងការផ្តល់ហិរញ្ញវត្ថុតែពីចំណូលបច្ចុប្បន្ន ដែលទទួលបានពីប្រតិបត្តិការសហគ្រាស ក្រោមលក្ខខណ្ឌអនុគ្រោះបំផុត ត្រូវដាក់បន្ទុកទៅក្នុងគណនីទូទៅ ឬគណនីពិសេសផ្សេងទៀតនៃអង្គភាពសាធារណៈមូលដ្ឋាន ។

(៤) រដ្ឋបាលបុគ្គលិក

ច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន និងច្បាប់ស្តីពីទំនាក់ទំនងវិជ្ជាជីវៈសហគ្រាសសាធារណៈមូលដ្ឋាន ចែងអំពីអញ្ញត្រកម្ម (ករណីលើកលែង) ចំពោះច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន នៅក្នុងការប្រព្រឹត្តរបស់និយោជិត (ហៅថា "និយោជិតសហគ្រាស") ដែលជួយជ្រោមជ្រែងអគ្គនាយក នៅក្នុងការអនុវត្តប្រតិបត្តិការអាជីវកម្មក្រោមឱវាទរបស់គាត់ ។ បញ្ហាផ្សេងៗទៀតទាំងអស់ដែលមិនមានចែងដោយអញ្ញត្រកម្មទាំងនេះ មានចែងនៅក្នុងច្បាប់ស្តីពីសេវាសាធារណៈមូលដ្ឋាន ។ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីការកែសម្រួលទំនាក់ទំនងវិជ្ជាជីវៈ និងច្បាប់ផ្សេងៗទៀត ដែលមិនអនុវត្តចំពោះមន្ត្រីរាជការមូលដ្ឋានធម្មតា ត្រូវអនុវត្តចំពោះនិយោជិតសហគ្រាស ហើយច្បាប់ស្តីពីស្តង់ដារការងារដែលត្រូវអនុវត្តតែមួយផ្នែកប៉ុណ្ណោះចំពោះមន្ត្រីរាជការធម្មតា ត្រូវអនុវត្តទាំងស្រុងចំពោះនិយោជិតរបស់សហគ្រាសសាធារណៈមូលដ្ឋាន ។

(៥) សមាគមសហគ្រាស

ដោយសារកត្តាមួយចំនួនដូចជា ធនធាន បរិយាកាសរដ្ឋបាល និងកម្រិតរដ្ឋបាល មានករណីមួយចំនួន នៅពេលសហគ្រាសមួយត្រូវប្រតិបត្តិការនៅតំបន់ទូលាយជាងនេះ ទាក់ទងនឹងព្រំដែនស្រុកនៃអង្គភាពសាធារណៈមូលដ្ឋាននីមួយៗ ។ ប្រព័ន្ធសមាគមសហគ្រាស ដែលជាគំរូនៃប្រព័ន្ធសហករណ៍តាមផ្នែកនៃអាជ្ញាធរមូលដ្ឋាន មានអត្ថិភាពដើម្បីចាត់ចែងករណីទាំងនោះ ។

ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធសមាគមត្រូវបែងចែកតាំងពីដើមទីដើម្បីការគ្រប់គ្រងរួមគ្នានៃកិច្ចការរដ្ឋបាលទូទៅ ហើយជាពិសេស មិនសមស្របចំពោះការគ្រប់គ្រងសហគ្រាសឡើយ ។ ដូច្នេះ ដើម្បីធានាអំពីការគ្រប់គ្រងប្រកបដោយសនិទានកម្ម និងប្រសិទ្ធផលនៃសហគ្រាសនោះ អញ្ញត្រកម្មជាច្រើនត្រូវបានបង្កើតឡើងសម្រាប់សមាគមនានា (ហៅថា សមាគមសហគ្រាស) ដែលគ្រប់គ្រងសេវារួមគ្នា ដែលទាក់ទងនឹងរដ្ឋបាលសហគ្រាស ដែលច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋានទាំងមូលត្រូវបានអនុវត្ត ។

## ៣. សេចក្តីផ្តើមនៃច្បាប់ស្តីពីទីភ្នាក់ងាររដ្ឋបាលសាជីវកម្មមូលដ្ឋាន

នៅក្នុងឆ្នាំ២០០៤ ច្បាប់ស្តីពីទីភ្នាក់ងាររដ្ឋបាលសាជីវកម្មមូលដ្ឋាន ត្រូវបានប្រកាសអោយប្រើ ដើម្បីបង្កើតប្រព័ន្ធថ្មី ដែលអាចអោយរដ្ឋាភិបាលមូលដ្ឋានផ្តល់សេវាសាធារណៈមូលដ្ឋាន តាមរយៈការបង្កើតទីភ្នាក់ងារខាងក្រៅ សម្រាប់សេវាទាំងនោះ ។

ប្រព័ន្ធនេះបង្កើតឡើងដើម្បីដោះស្រាយបញ្ហាសេវាសាធារណៈ ដូចជា សាកលវិទ្យាល័យ បរិក្ខារសុខុមាលភាពសង្គម និងវិទ្យាស្ថានស្រាវជ្រាវ ព្រមទាំងសេវាមួយចំនួនទៀតដូចជាសេវាផ្គត់ផ្គង់ទឹកស្អាត និងសេវាមន្ទីរពេទ្យ និងសេវាផ្សេងទៀតដែលត្រូវបានដំណើរការក្រោមប្រព័ន្ធសហគ្រាសសាធារណៈមូលដ្ឋាន ។

ដោយសារមិនសុទ្ធតែជាកាតព្វកិច្ចដែលត្រូវអនុម័តយកប្រព័ន្ធនេះ ចលនាបង្កើតទីភ្នាក់ងាររដ្ឋបាលសាជីវកម្មមូលដ្ឋាន មិនត្រូវបានកើតឡើងដោយធ្វេសប្រហែសឡើយ ។ ទោះជាយ៉ាងណាក៏ដោយ មន្ទីរពេទ្យរដ្ឋមួយចំនួនដែលគ្រប់គ្រងដោយរដ្ឋាភិបាលមូលដ្ឋាន ត្រូវកែប្រែទៅជាទីភ្នាក់ងារក្រោមច្បាប់ស្តីពីទីភ្នាក់ងាររដ្ឋបាលសាជីវកម្មមូលដ្ឋាន ។

(១) តម្រូវការឥតឈប់ឈរនៃការវិនិយោគលើការសាងសង់

ដោយសារតម្រូវការទំនិញ និងសេវាដែលផ្តល់អោយដោយសហគ្រាសសាធារណៈមូលដ្ឋាន មានការប្រែប្រួលនោះជារឿងធម្មតាទេ ដែលថាគោលនយោបាយសហគ្រាសចំពោះការវិនិយោគក៏មានការប្រែប្រួលទៅតាមនោះដែរ ។ នៅក្នុងយុគសម័យនៃការរីកលូតលាស់ឆាប់រហ័ស តម្រូវការទំនិញ និងសេវាដែលផ្តល់អោយដោយសហគ្រាសសាធារណៈមូលដ្ឋាន បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយផែនការវិនិយោគបរិក្ខារប្រកបដោយភាពវិជ្ជមានត្រូវបានធ្វើឡើងដោយសន្មតថា តម្រូវការនឹងកើនឡើងដូចកាលពីអតីតកាលដែរ ។ ផែនការ និងការងារទាំងនេះបានទទួលការពេញនិយម និងមាននិរន្តរភាព ដរាបណាមានការរីកលូតលាស់ខ្លាំងនៅតែបន្ត ។ លើសពីនេះទៀត អ្នកខ្លះគិតថាជាការសមស្របបំផុតក្នុងការធ្វើវិនិយោគទុន នៅពេលដែលសេដ្ឋកិច្ចជាតិមានការរីកចម្រើនលើសពីការរំពឹងទុក ។ ការអនុវត្តឆាប់រហ័សជាងនេះ និងវិសាលភាពធំជាងនេះនៅក្នុងការសាងសង់ ត្រូវបានស្វាគមន៍ជាទូទៅ ដោយសារពួកគេរំពឹងថាការសាងសង់បរិក្ខារ ឬការកែលម្អបរិក្ខារគឺជាមធ្យោបាយដែលអាចធ្វើទៅបានតែមួយគត់ ដើម្បីបំពេញតម្រូវការពិតប្រាកដ ហើយបន្ទុកទូទាត់កម្ចី ច្រើនតែត្រូវបានបន្ធូរបន្ថយ តាមរយៈឥទ្ធិពលនៃអតិផរណា ។

ទោះជាយ៉ាងណាក៏ដោយ តម្រូវការនៅនឹងថ្កល់ចាប់តាំងពីពេលមានវិបត្តិប្រេង នៅក្នុងឆ្នាំ១៩៧៣ រួចមកហើយដោយហេតុនេះ ជាលទ្ធផល ជំហររបស់សហគ្រាសចំពោះការវិនិយោគលើការសាងសង់ ពុំសូវជាខ្លាំងក្លាឡើយ ។ នៅក្នុងតំបន់ជាច្រើន សហគ្រាសសាធារណៈកំពុងព្យាយាមស្វែងរកដំណោះស្រាយសម្រាប់ភាពហួសសមត្ថភាពរបស់បរិក្ខារដែលមានស្រាប់ ឬបរិក្ខារដែលកំពុងសាងសង់ និងជិតចប់រួចរាល់ ។

និយាយជាទូទៅ ការវិនិយោគលើការសាងសង់របស់សហគ្រាសសាធារណៈបាននៅនឹងថ្កល់ លើកលែងតែផ្នែកទឹកស្អុយមួយប៉ុណ្ណោះ ។ ដោយហេតុនេះ ជាការចាំបាច់ដែលត្រូវពិនិត្យមើលឡើងវិញដោយប្រុងប្រយ័ត្ននូវផែនការសាងសង់ថ្មី ដោយផ្អែកលើនិន្នាការនៃតម្រូវការនាពេលអនាគត និងការកើនឡើងនូវថ្លៃចំណាយមូលធន ។ ក្នុងពេលជាមួយគ្នានេះផងដែរ គម្រោងមួយចំនួនដែលកំពុងដំណើរការ អាចនឹងត្រូវបានបញ្ចប់ ឬចាត់ចែងយ៉ាងស៊ីសង្វាក់ផ្សេងពីនេះ ប្រសិនបើគម្រោងទាំងនេះបណ្តាលអោយមានបញ្ហាហួសសមត្ថភាព ។

(២) ការកើនឡើងនូវបំណែកនៃថ្លៃចំណាយមូលធន

ទីពីរ ការកើនឡើងនូវបំណែកនៃថ្លៃចំណាយមូលធននៅក្នុងរចនាសម្ព័ន្ធចំណាយ កាន់តែមានភាពច្បាស់លាស់ឡើងៗ ។

នៅក្នុងសហគ្រាសផ្តល់សេវាសាធាណៈ ដូចជា សហគ្រាសផ្គត់ផ្គង់ទឹកស្អាត និងរថភ្លើងក្រោមដី ជាធម្មតាមានការភ័យខ្លាចថានឹងមានការកើនឡើងនូវថ្លៃចំណាយមូលធន ដែលនៅទីបំផុតអាចនាំអោយមានការលំបាកផ្នែកហិរញ្ញវត្ថុ ដែលបន្ថែមលើការរំលស់ និងការកើនឡើងនៃការប្រាក់ដែលត្រូវបង់ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលនៃការរីកចម្រើនខ្ពស់ ការកើនឡើងនូវថ្លៃចំណាយ អាចត្រូវបានគ្របដណ្តប់យ៉ាងងាយស្រួលតាមរយៈការបង្កើនថ្លៃបន្ទុក ។

លើសពីនេះទៀត អត្រាកើនឡើងសម្រាប់ថ្លៃចំណាយផ្សេងទៀត បានឡើងហួសអត្រាកើនឡើងសម្រាប់ថ្លៃចំណាយមូលធន ដែលបានធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ។ នៅក្នុងស្ថានភាពបែបនេះ កត្តាចម្បងនៃការកើនឡើងនូវថ្លៃចំណាយដែលអាចមានណាមួយ អាចត្រូវបានរកឃើញនៅក្រៅថ្លៃចំណាយមូលធន ។

នៅក្នុងការផ្គត់ផ្គង់ទឹកស្អាត ជាឧទាហរណ៍ ការធានាធនធានទឹកថ្មីកាន់តែពិបាកឡើង១ ហើយដោយហេតុនេះធនធាននេះធ្វើដំណើរឆ្ពោះទៅរកតំបន់ដាច់ស្រយាលផ្សេងទៀត ក្នុងខណៈដែលការអភិវឌ្ឍចេះតែបន្ត ដែលនាំទៅរកការកើនឡើងនូវថ្លៃចំណាយមូលធនដោយមិនអាចជៀសវាងបាន ។ ម្យ៉ាងទៀត នៅក្នុងវិស័យរថភ្លើងក្រោមដី គម្រោងថ្មី១តែងតែមានចំណុចពិបាក១សម្រាប់ការសាងសង់ និងអាស្រ័យលើការកើនឡើងនូវថ្លៃចំណាយមូលធន ។ នៅក្នុងសម័យ-កាលនៃការរីកចម្រើនឆាប់រហ័ស បន្ទុកជាក់ស្តែងនៃថ្លៃចំណាយមូលធនត្រូវបានបន្ធូរបន្ថយតាមរយៈឥទ្ធិពលអតិផរណា ហើយភាគហ៊ុនសម្រាប់ថ្លៃចំណាយមូលធនត្រូវកាត់បន្ថយ ដោយសារការកើនឡើងនៃប្រាក់បៀវត្សរ៍ ។ ការកើនឡើងនូវថ្លៃចំណាយមូលធនក្លាយជាមានភាពច្បាស់លាស់ នៅក្នុងរយៈពេលរីកចម្រើនដែលនៅថេរ នៅពេលការកើនឡើងនៃថ្លៃ និងប្រាក់បៀវត្សរ៍មានកម្រិតទាប ។

សហគ្រាសសាធារណៈមូលដ្ឋាន រួមមានប្រព័ន្ធជាច្រើន ដូចជា រថភ្លើងក្រោមដី ការផ្គត់ផ្គង់ទឹកស្អាត និងការបង្ហូរទឹកស្អុយ ដែលទាមទារអោយមានបរិក្ខារធំ១តាមប្រភេទ ដែលនៅក្នុងករណីជាច្រើន ទាមទារនូវប្រាក់វិនិយោគច្រើនដ៏សន្ធឹកសន្ធាប់ ។ ដូច្នេះ សហគ្រាសសាធារណៈមិនអាចបំបាត់បញ្ហាការកើនឡើងនូវថ្លៃចំណាយមូលធនជារៀងរហូត ។

(៣) ការលំបាកនៅក្នុងការពិនិត្យមើលឡើងវិញនូវថ្លៃបន្ទុក

ទីបី ក៏មានការលំបាកនៅក្នុងការពិនិត្យមើលឡើងវិញនូវថ្លៃបន្ទុកសេវាប្រយោជន៍ទូទៅផងដែរ ។ ទំនាក់ទំនងរវាងថ្លៃបន្ទុក និងតម្រូវការនៅក្នុងសហគ្រាសសាធារណៈ មានភាពតឹងតែងខ្លាំងតាមប្រភេទនីមួយ១ ប៉ុន្តែនៅក្នុងប៉ុន្មានឆ្នាំថ្មី១នេះ វាកាន់តែមានភាពបត់បែន ដែលជាមូលហេតុមួយដែលការពិនិត្យមើលឡើងវិញនេះមានការលំបាក ។

ទោះបីជាមានការកើនឡើងខ្លាំងនូវបុគ្គលិក ថាមពល និងថ្លៃសម្ភារៈក៏ដោយ ការពិនិត្យមើលឡើងវិញផ្អែកខាងលើនៃថ្លៃបន្ទុកដោយសហគ្រាសសាធារណៈមូលដ្ឋានមានភាពមិនគ្រប់គ្រាន់ទាំងក្នុងវិសាលភាព ទាំងក្នុងការជ្រើសរើសពេលវេលា ដោយសារសំណើពីរដ្ឋាភិបាលថ្នាក់ជាតិមួយផ្អែកដែលចង់រក្សាថ្លៃ ។ ទោះជាយ៉ាងណាក៏ដោយ ថ្លៃបន្ទុកត្រូវបានពិនិត្យមើលឡើងវិញនៅពេលក្រោយ ដែលបានធ្វើជាវិភាគទានយ៉ាងធំដល់ការអនុវត្តការគ្រប់គ្រងដែលបានកែលម្អនៅក្នុង និងក្រោយឆ្នាំ១៩៧៦ ។

ដោយសារស្ថានភាពសេដ្ឋកិច្ចរបស់សហគ្រាស និងរបស់គ្រួសារមានភាពកាន់តែធ្ងន់ធ្ងរឡើង នៅក្នុងសម័យកាលនៃសេដ្ឋកិច្ចរីកចម្រើនថេរ ក្រោយពេលមានវិបត្តិប្រេង ការកើនឡើងដោយងាយស្រួលនូវថ្លៃបន្ទុកមិនត្រឹមតែអាចត្រូវបានរិះគន់យ៉ាងធ្ងន់ធ្ងរប៉ុណ្ណោះទេ តែថែមទាំងធ្វើអោយមានការកាត់បន្ថយតម្រូវការដោយខ្លួនឯងផងដែរ ។ ក្នុងករណីនេះ គោលបំណងនៃការពិនិត្យមើលឡើងវិញ នឹងមិនអាចសម្រេចទៅបានដោយពេញលេញឡើយ ។ នៅទីបំផុត អតិថិជនអាចចាកចេញពីទីផ្សារ ហើយបង្កជាការលំបាកដល់សហគ្រាសក្នុងការធ្វើអាជីវកម្មរបស់ខ្លួន ។ លើសពីនេះទៀត បញ្ហាដែលថាតើថ្លៃបន្ទុករបស់សហគ្រាសសាធារណៈពិតជាផ្អែកលើថ្លៃចំណាយមួយដ៏សមស្រប ឬយ៉ាងណានោះ គឺជាបញ្ហាមួយដែលគួរអោយសង្ស័យផងដែរ ។ ការពិនិត្យមើលថ្លៃបន្ទុកឡើងវិញដោយត្រឹមត្រូវ អាចជាកត្តាសំខាន់ ប៉ុន្តែសហគ្រាសត្រូវកាត់បន្ថយបន្ថែមទៀតនូវថ្លៃចំណាយ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឆ្ពោះទៅរកសនិទានកម្មនៃការគ្រប់គ្រង

របស់ខ្លួន ។ ប្រការដែលថាសហគ្រាសសាធារណៈមូលដ្ឋានគឺជាសេវាប្រយោជន៍សាធារណៈនោះ មិនអាចបញ្ជាក់អំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលឧបត្ថម្ភកធន ឬការផ្ទេរមូលនិធិពីគណនេយ្យទូទៅបានឡើយ ។ សហគ្រាសសាធារណៈត្រូវបានដំណើរការ ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ ប៉ុន្តែការគ្រប់គ្រងប្រកបដោយប្រសិទ្ធផល ត្រូវបានតម្រូវដើម្បីសម្រេចគោលបំណងនេះ ។

(៤) ការកើនឡើងនៃទ្រព្យសកម្មដែលត្រូវរំលស់ និងទុនបម្រុងផ្ទៃក្នុង

ទីបួន អចលនទ្រព្យរូបវន្តចម្បងៗ ត្រូវបានបង្កើតឡើងតាមរយៈការវិនិយោគដែលត្រូវបានធ្វើឡើងម្តងហើយម្តងទៀត នៅក្នុងវិស័យសំណង់ជារៀងរាល់ឆ្នាំ ដែលបង្កើតអោយមានរំលស់យ៉ាងច្រើនផងដែរ ។ នៅក្នុងសហគ្រាសដែលមានការរីកចម្រើនខ្ពស់ ពេលនេះ រំលស់បែបនេះត្រូវបានប្រើប្រាស់ជាមូលធនបម្រុងផ្ទៃក្នុង សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ និងការជួសជុលកែលម្អបរិក្ខារផ្សេងៗ ។

កន្លងមក ធនធានហិរញ្ញវត្ថុសម្រាប់ការវិនិយោគលើការសាងសង់របស់សហគ្រាសសាធារណៈអាស្រ័យយ៉ាងខ្លាំងលើការបញ្ចេញកម្ចីរបស់សហគ្រាស ។ កម្ចីរបស់សហគ្រាសអាចបន្តមានវត្តមាននៅក្នុងពេលអនាគត ប៉ុន្តែមូលនិធិបម្រុងផ្ទៃក្នុងនឹងកើនឡើងបន្តិចម្តងៗ ។

ទោះបីជាការស្តារនីតិសម្បទាឡើងវិញ ឬថ្លៃចំណាយកែលម្អអាចត្រូវបានគ្របដណ្តប់ដោយមូលនិធិបម្រុងផ្ទៃក្នុងក៏ដោយ យ៉ាងហោចណាស់មួយភាគធំនៃការវិនិយោគត្រូវតែផ្តល់មូលនិធិតាមរយៈកម្ចីសហគ្រាស ក្នុងពេលបច្ចុប្បន្ននេះ ។ នៅពេលការងារសាងសង់កើតឡើងច្រើន ហើយមូលនិធិសម្រាប់ការវិនិយោគមានចំនួនច្រើនជាងទុនបម្រុងផ្ទៃក្នុងនោះ ជាការធម្មតាដែលថា ទុនបម្រុង ដូចជារំលស់ជាដើម មានចំនួនតិចជាងទ្រព្យសម្បត្តិ ហើយមិនត្រូវបានមើលឃើញថាជាប្រភពដ៏ល្អសម្រាប់មូលនិធិវិនិយោគឡើយ ។ នៅក្នុងយុគសម័យនៃការរីកចម្រើនថេរ ដែលពេលនោះការវិនិយោគថ្មីត្រូវបានកំហិត ទោះជាយ៉ាងណាក៏ដោយ សារៈសំខាន់នៃទុនបម្រុងទាំងនេះកំពុងកើនឡើងបន្តិចម្តងៗ ។

បញ្ហាគឺថា មានគម្លាតក្នុងចំណោមសហគ្រាសក្នុងចំនួនទុនបម្រុងផ្ទៃក្នុង ។ សហគ្រាសមួយចំនួនមានទុនបម្រុងច្រើន ក្នុងខណៈដែលសហគ្រាសផ្សេងទៀតមានតិច ឬថែមទាំងខ្វះមូលនិធិដំណើរការបច្ចុប្បន្ន ។ គម្លាតនេះត្រូវបានរំពឹងថានឹងមានកាន់តែធំឡើងនាពេលអនាគត ។

សម្រាប់ការអភិវឌ្ឍនាពេលអនាគតនៃសហគ្រាសសាធារណៈ ចាំបាច់ត្រូវបង្កើនដើមទុនដែលខ្លួនមាន និងទុនបម្រុងផ្ទៃក្នុង ដោយចាត់វិធានការសមស្របសម្រាប់សហគ្រាសដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ ។

(៥) អាយុច្រើនរបស់បុគ្គលិក

ចំណុចទីប្រាំទាក់ទងនឹងឥទ្ធិពលនៃអាយុច្រើនរបស់បុគ្គលិកលើលទ្ធផលការងារគ្រប់គ្រង ។ ការចម្រើនអាយុបង្កើនថ្លៃចំណាយតាមរយៈការកើនឡើងនូវប្រាក់បៀវត្សរ៍ជាមធ្យម ដែលបណ្តាលមកពីប្រព័ន្ធប្រាក់បៀវត្សរ៍តាមអតីតភាពការងារ ដែលមានតែនៅប្រទេសជប៉ុនប៉ុណ្ណោះ ។

បញ្ហាចម្រើនអាយុមានលក្ខណៈគួរអោយកត់សម្គាល់នៅក្នុងសហគ្រាសដែលមានបុគ្គលិកតិច ។ នៅក្នុងសហគ្រាសដឹកជញ្ជូន ដែលចំនួនបុគ្គលិកកំពុងធ្លាក់ចុះ ដោយសារអាយុជាមធ្យមរបស់បុគ្គលិកដែលចូលរួមនៅក្នុងសហគ្រាសដឹកជញ្ជូនក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋានគឺ ៤៣ ឬ ២ ឆ្នាំខ្ពស់ជាងមធ្យមភាគរបស់សហគ្រាសទាំងអស់ ។ ដោយហេតុនេះ ប្រាក់បៀវត្សរ៍ប្រចាំខែមូលដ្ឋានជាមធ្យមនៅក្នុងសហគ្រាសដឹកជញ្ជូនគឺ ៣៦៩.៩២៩ យេន ដែលស្មើនឹង

៩.៥៨៩ យេន ឬ ២.៧% ខ្ពស់ជាងមធ្យមភាពសម្រាប់សហគ្រាសទាំងអស់ដែលមានចំនួន ៣៦០.៣៤០ យេន ។ កម្រិតប្រៀវត្សរ៍ខ្ពស់គឺជាកត្តាចម្បងមួយដែលគំរាមកំហែងដល់គ្រឹះហិរញ្ញវត្ថុនៃការគ្រប់គ្រងនៅក្នុងសហគ្រាសដឹកជញ្ជូន ។

(៦) បញ្ហាក្នុងការអភិវឌ្ឍនាពេលអនាគត

បញ្ហាក្នុងការអភិវឌ្ឍនាពេលអនាគត គឺថាតើត្រូវពង្រីកដើមទុនរបស់ខ្លួន និងទុនបម្រុងផ្ទៃក្នុងដោយរបៀបណា ហើយក្នុងពេលជាមួយគ្នានេះ តើត្រូវផ្ដល់វិធានការសមស្របសម្រាប់សហគ្រាសទាំងឡាយណាដែលខ្វះកិត្តិស័ព្ទផ្នែកហិរញ្ញវត្ថុរឹងមាំសម្រាប់ការគ្រប់គ្រងដោយរបៀបណា ។ វិធានការមួយចំនួនត្រូវបានប្រកាន់យករួចជាស្រេច ដែលក្នុងចំណោមវិធានការទាំងនោះ វិធានការមួយគឺការចេញសញ្ញាប័ណ្ណក្រោមប្រព័ន្ធហិរញ្ញវត្ថុគណនេយ្យទូទៅ ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានទឹក និងការសាងសង់ស្ថានីយ៍រថភ្លើងក្រោមដី ។

កំណើនសមស្របនៅក្នុងថ្លៃសេវាប្រយោជន៍ទូទៅ នៅពេលសមស្រប ត្រូវបានស្នើឡើង ដើម្បីកាត់បន្ថយឱនភាពដែលមិនអាចត្រូវបានលុបបំបាត់ដោយងាយស្រួល និងរារាំងប្រតិបត្តិការសហគ្រាសដោយរលូន ។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពតឹងតែងសម្រាប់ការពិនិត្យមើលថ្លៃបន្ទុកឡើងវិញបែបនោះ ផ្ដល់ដល់សហគ្រាសនូវឱកាសល្អ ដើម្បីពិចារណាឡើងវិញអំពីថ្លៃបន្ទុក អត្ថន័យ និងតួនាទីរបស់សហគ្រាសសាធារណៈ ។

មានការបញ្ជាក់បំភ្លឺថា ថ្លៃបន្ទុកត្រូវគណនា "ដោយផ្អែកលើថ្លៃចំណាយសមស្រប" នៅក្នុងច្បាប់ស្ដីពីសហគ្រាសសាធារណៈមូលដ្ឋាន ។ ប៉ុន្តែ តើថ្លៃចំណាយសមស្របគឺជាអ្វី ? នៅក្នុងសេវាកម្មរថយន្តក្រុងសាធារណៈ ដែលមានអាជីវកម្មអាចប្រៀបធៀបបានជាមួយផ្នែកឯកជន ថ្លៃចំណាយប្រតិបត្តិការរថយន្តក្រុងប្រចាំថ្ងៃក្នុងមួយគីឡូម៉ែត្រ គឺ ៨៨% ខ្ពស់ជាងថ្លៃចំណាយរបស់រថយន្តក្រុងឯកជន ។ យើងមិនអាចធ្វើអ្វីបានទាំងអស់ក្នុងហេតុផលមួយ ព្រោះរថយន្តក្រុងសាធារណៈដំណើរការតាមតំបន់ស្ទះផ្លូវច្រើនជាង ហើយដោយហេតុនេះ ចម្ងាយគីឡូម៉ែត្របម្រើសេវាក្នុងមួយថ្ងៃគឺមានរយៈចម្ងាយខ្លីជាងរថយន្តក្រុងឯកជន ។ ស្ថានភាពស្រដៀងគ្នានេះអាចត្រូវបានអនុវត្តផងដែរចំពោះកម្រិតបុគ្គលិក និងប្រាក់ប្រៀវត្សរ៍នៅក្នុងសហគ្រាសផ្សេងទៀត ដោយគ្មានគូប្រកួតប្រជែងនៅក្នុងផ្នែកឯកជន ។

ដូចបានរៀបរាប់ខាងលើ វាមានការលំបាកក្នុងការនិយាយថា ការវិនិយោគទាំងអស់កំពុងត្រូវបានធ្វើឡើង យ៉ាងមានប្រសិទ្ធផល ។ និយាយអោយជ្រៅទៅ កិច្ចខិតខំប្រឹងប្រែងសម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ ត្រូវតែពង្រឹងជាបឋម គឺដើម្បីកាត់បន្ថយថ្លៃចំណាយនៅក្នុងករណីទាំងពីរនៃការកើនឡើងនូវថ្លៃបន្ទុក ដោយសារការកើនឡើងនូវថ្លៃចំណាយ និងការកាត់បន្ថយនៅក្នុងថ្លៃបន្ទុក ដែលបណ្ដាលអោយមានការផ្ទេរជាច្រើននូវមូលនិធិពីគណនីទូទៅ ។ ទោះជាយ៉ាងណាក៏ដោយ តាមការពិត ប្រជាជននៅក្នុងអង្គភាពសាធារណៈមូលដ្ឋានត្រូវតែធ្វើការងារបំពេញចំពោះកិច្ចខិតខំប្រឹងប្រែងដែលមិនគ្រប់គ្រាន់របស់សហគ្រាសសាធារណៈមូលដ្ឋានដែលពាក់ព័ន្ធ ។ ប្រការដែលថា សហគ្រាសសាធារណៈមូលដ្ឋានគឺជាសេវាប្រយោជន៍ទូទៅសាធារណៈ មិនបានបញ្ជាក់ដោយស្វ័យប្រវត្តិនូវសិទ្ធិកាត់បន្ថយមូលនិធិ ឬទទួលការផ្ទេរមូលនិធិពីគណនីទូទៅឡើយ ។

សហគ្រាសសាធារណៈដំណើរការឡើង ដើម្បីជួយកែលម្អសុខុមាលភាពសាធារណៈ ប៉ុន្តែចាំបាច់ត្រូវមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធផល ដើម្បីសម្រេចអោយបាននូវវត្ថុបំណងនេះ ។ ភាពបត់បែនគឺជាគន្លឹះក្នុងការទប់ទល់ស្ថានភាពដែលតែងតែមានការផ្លាស់ប្ដូរ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ។ ជាទីបញ្ចប់ សហគ្រាសមិនគួរត្រូវបានស្ដីបន្ទោសអំពីការប្រកាន់ជំហរដែលថា "រដ្ឋាភិបាលចាស់ល្អ នឹងរ៉ាប់រងចេញថ្លៃចំណាយ" ឡើយ ។

## និន្នាការថ្មីៗនៃលទ្ធផលហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈមូលដ្ឋាន

(សហគ្រាសសាធារណៈមូលដ្ឋានក្រោមច្បាប់ស្តីពីសហគ្រាសសាធារណៈមូលដ្ឋាន)

(គិតជាលានយេន. %)

| ប្រភេទសេវាកម្ម | ឆ្នាំសារពើពន្ធ | ១៩៩៦ | | ១៩៩៧ | | ១៩៩៨ | | ១៩៩៩ | | ២០០០ | | ២០០១ | | ២០០២ | | ២០០៣ | | ២០០៤ | | ២០០៥ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការផ្គត់ផ្គង់ទឹកស្អាត | - ចំណេញធម្មតា | (១.៥២០) | ១៦២.៦៦៥ | (១.៥២៧) | ១៧៣.៧៤៦ | (១.៥៣៣) | ១៧៧.៦៧៣ | (១.៥៣៥) | ១៧៤.៤៨៧ | (១.៥៩៩) | ១៨៤.៧០១ | (១.៤៩៩) | ១៦០.៤៦៣ | (១.៥៩៦) | ១៨០.៣៦៧ | (១.៥៣១) | ២០៦.៦៣៥ | (១.៤២៤) | ២៤៦.២៤៧ | (១.២០០) | ២៩៤.៦០០ |
| | - ខាតធម្មតា | (៤៧៤) | ៤២.៩៨៥ | (៤៧១) | ២៧.៤៣២ | (៤៦៤) | ២៥.៥៩៣ | (៤៦៧) | ៣៣.៦៩១ | (៤៥៧) | ២៥.៦២៤ | (៥០៨) | ៤៤.៧៧៦ | (៤៤០) | ៣០.៦៨៦ | (៤៤០) | ៣២.៧៤៦ | (៣៤២) | ២៣.៧៤១ | (២៣៦) | ១៥.០៧២ |
| | - ខាតបូកបន្ថែម | | ១០៦.២០៨ | | ១០១.៨០៤ | | ៩៩.៦៥១ | | ១០១.៧៨២ | | ១១០.០៥៦ | | ១២២.៥៧៥ | | ១២៧.១៩២ | | ១៣៣.៤៧០ | | ១៣១.៤៣២ | | ១២៤.០៣៩ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ២៣.៦ | | ២៣.៦ | | ២៣.២ | | ២៣.៣ | | ២២.៨ | | ២៥.៤ | | ២២.០ | | ២២.៣ | | ១៩.៥ | | ១៦.៤ |
| ផ្គត់ផ្គង់ទឹកឧស្សាហកម្ម | - ចំណេញធម្មតា | (៥៨) | ៨.៣២៣ | (១០៧) | ១០.០៥២ | (១០៤) | ១២.៦៦២ | (១១០) | ១២.៨៦៧ | (១១២) | ១៤.៥៨៨ | (១១៤) | ១៦.២២៤ | (១១២) | ១៧.៤៥៤ | (១២១) | ១៤.៥៨៦ | (១២៦) | ២០.៧៥៨ | (១២០) | ២០.៥៦១ |
| | - ខាតធម្មតា | (៣៦) | ៣.០៧០ | (២៧) | ១.៥៥៣ | (២៨) | ១.៤២១ | (២៧) | ២.៦៣១ | (២៥) | ២.៤២៣ | (២៧) | ២.៦៤៤ | (៣១) | ៣.៨៤៣ | (២៣) | ៦.០២៨ | (២២) | ១.៧៤៥ | (២៤) | ២.០០១ |
| | - ខាតបូកបន្ថែម | | ២៥.២៣៥ | | ២៧.១៦៨ | | ២៥.១៥៧ | | ២២.៥២២ | | ២១.៥៨០ | | ២១.១៣២ | | ២១.៥២៤ | | ២១.៦១៧ | | ២០.៩៩១ | | ២១.៦៧៤ |
| | - ភាគរយនៃចំនួនសហគ្រាសដែលខាតពិតភាគ | | ២៦.៩ | | ២០.៦ | | ២០.៤ | | ១៩.៧ | | ២០.៦ | | ១៩.១ | | ២១.៧ | | | | ១៥.៤ | | ១៦.៧ |
| មីត្រូ | - ចំណេញធម្មតា | (៣០) | ១.៨៦០ | (២៤) | ១.១៣៣ | (២៥) | ១.២៥២ | (២៨) | ៥៧៨ | (២៥) | ២.៥០៤ | (៣១) | ២.២៥៣ | (៣៤) | ៣.០៥៨ | (៣៨) | ១១.៧៦៥ | (៣៨) | ១៣.៤០០ | (២៨) | ២១.៨៥៥ |
| | - ខាតធម្មតា | (៤៧) | ១៨៦.៦៦៤ | (៥២) | ១៨៨.២៥១ | (៤៧) | ១៨៧.១៥៣ | (៤៧) | ១៨៧.៣៨១ | (៤៦) | ១៥១.៦៣១ | (៤៤) | ១៧៨.៣១៦ | (៣៥) | ១៥៦.៣៥២ | (៣៤) | ៨៧.៥៥៦ | (៣២) | ៧៧.៣០១ | (៣៦) | ៥២.៧០៣ |
| | - ខាតបូកបន្ថែម | | ១.៨៣៦.២៥៧ | | ២.០០៧.៤១៦ | | ២.១៧៦.០៥៥ | | ២.៣៤២.៨៥៥ | | ២.៥៧៤.៨៣៤ | | ២.៥៥៦.៥៥២ | | ២.៦៥១.៨៥៥ | | ២.៣២៤.៤៥៥ | | ២.៣៨៤.៣៨៣ | | ២.២៧៥.៦៣៥ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ៦១.០ | | ៦៨.៤ | | ៦១.៨ | | ៦២.៧ | | ៦២.២ | | ៦០.៣ | | ៥៣.៤ | | ៤៧.២ | | ៤៦.៤ | | ៥៦.៣ |
| អគ្គិសនី | - ចំណេញធម្មតា | (៣២) | ១៤.៨៥៨ | (៣៤) | ១៦.៥៤១ | (៣៤) | ១៧.១៨២ | (៣៤) | ១៣.៣៨៦ | (៣៤) | ១៣.០៣០ | (៣៤) | ១០.២១៨ | (៣៤) | ១០.៦១១ | (៣២) | ១០.៥៦៧ | (៣២) | ១០.៥៨៧ | (២៥) | ៨.០២៧ |
| | - ខាតធម្មតា | (២) | ៧ | (-) | - | (-) | - | (-) | - | (-) | - | (-) | - | (-) | - | (១) | ៣៤៣ | (១) | ៥៤៥ | (២) | ៥៦៥ |
| | - ខាតបូកបន្ថែម | | ៧ | | - | | - | | - | | - | | - | | - | | ៣៣៥ | | ២.៥៨៨ | | ១.៧៥៦ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ៥.៩ | | - | | - | | - | | - | | - | | - | | ៣.០ | | ៣.០ | | ៦.៥ |
| ហ្គាស | - ចំណេញធម្មតា | (៥៧) | ២.៩១៥ | (៦០) | ២.៤៨០ | (៦០) | ២.៥៤៨ | (៥៦) | ៣.១២៤ | (៥៥) | ៣.៩៧៧ | (៥២) | ៣.៩២៥ | (៥០) | ៤.២៧៦ | (៤៧) | ៣.៧៣១ | (៣១) | ២.៧៧៦ | (២៤) | ៣.២៨៨ |
| | - ខាតធម្មតា | (១៤) | ៤.០៥២ | (១១) | ៤.១៨៤ | (១០) | ៥.១០៣ | (១៣) | ៥.៨៥៣ | (១០) | ៥.៥៣៥ | (១២) | ៤.៤៥៨ | (១១) | ៤.៨៥៦ | (១១) | ៣.៥៥៥ | (១៦) | ៥.៧១៥ | (១៣) | ៥.០៦៨ |
| | - ខាតបូកបន្ថែម | | ៤.០៣៥ | | ៤.៨៥៥ | | ៨.០២៣ | | ១៣.៦១៨ | | ១៥.៨០២ | | ២២.២២៥ | | ២៧.៥៦១ | | ២៥.៥៣៤ | | ៣៤.៥២៦ | | ៣៨.៤៦១ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ១៥.៧ | | ១៥.៥ | | ១៤.៣ | | ១៨.៨ | | ១៤.៥ | | ១៨.៤ | | ១៨.០ | | ១៥.០ | | ៣៤.០ | | ៣៥.១ |
| មន្ទីរពេទ្យ | - ចំណេញធម្មតា | (៤១៦) | ៤០.៦៧២ | (៣៥៤) | ៣១.៦៤៤ | (៣០៨) | ២៣.៦៦៣ | (៣៣២) | ២៥.៤៦៥ | (៤០៣) | ៣៥.៦០៥ | (៣៥៧) | ៤០.៥៨៨ | (២៧៨) | ២៥.៨៥៥ | (២៥៥) | ៣៥.៤៧៤ | (២៤៦) | ២៥.៨០៤ | (២១១) | ២១.៨៨១ |
| | - ខាតធម្មតា | (៣២៦) | ៧៦.៨៤៣ | (៣៨២) | ១០០.៦០៣ | (៤៣៥) | ១៣១.៥០២ | (៤១៥) | ១៣១.៥៥៥ | (៣៥៤) | ១១០.៣៧២ | (៣៦៥) | ១០៣.៧០៨ | (៤៨៣) | ១៤៧.៨៥៣ | (៤៥៧) | ១២៨.៦២៥ | (៤៨២) | ១៥៧.៥២៨ | (៤៦៣) | ១៦៦.៩២៦ |
| | - ខាតបូកបន្ថែម | | ៩៧៥.៨៤៧ | | ១.០៤១.០៣៣ | | ១.១៤២.៩៣៣ | | ១.២៤៣.៩១៣ | | ១.៣២០.០៥៣ | | ១.៣៨៨.២១២ | | ១.៥១២.៣១៧ | | ១.៦១៥.០២៣ | | ១.៦៧២.៥៧៧ | | ១.៧៨១.៥៦១ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ៤៣.៥ | | ៥២.៥ | | ៥៨.៨ | | ៥៥.៨ | | ៤៧.៥ | | | | ៦៣.៥ | | ៦០.៨ | | ៦៦.២ | | ៦៨.៧ |

| | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មីកសុយ | - ចំណេញមធ្យម | (៨៤) | ១០.៨៧២ | (៨៨) | ១២.៧៨១ | (៦០) | ៣១.៩៤៤ | (៦៦) | ២៧.១៦៨ | (៧៥) | ៣០.២៨៨ | (៨២) | ៣៣.៦៥៣ | (៨០) | ៣៦.២៧៥ | (១០៦) | ៦១.៦២៧ | (១២០) | ៥៣.២០៥ | (១១២) | ៥៥.២៤៦ |
| | - ខាតមធ្យម | (៦២) | ៣០.៣៥៧ | (៦៧) | ៣១.៥៣០ | (៤៤) | ៣៥.៧៦៥ | (៥០) | ១៩.៦២៣ | (៥១) | ១៦.៤៦១ | (៥៣) | ១៣.០៣៤ | (៧០) | ១១.៧០៤ | (៧២) | ១១.២២១ | (៨៣) | ១២.២៨៨ | (៥៣) | ១២.៥៤១ |
| | - ខាតបូកបន្ថែម | | ១១៥.៨៨៤ | | ១៦១.៤១៣ | | ១៧៣.៩៣៧ | | ១៨៨.៥៥៨ | | ២០១.១៦៥ | | ២០៥.៤៤៤ | | ២១០.០៨៧ | | ២០៧.១១៥ | | ១៩៩.២៥១ | | ២០៦.៣២៣ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ៦៣.៨ | | ៦៦.៥ | | ៦៥.០ | | ៦៣.៥ | | ៦២.១ | | ៦១.១ | | ៦៣.៨ | | ៦០.៦ | | ៦២.៦ | | ៦៥.៦ |
| ជៀង១ | - ចំណេញមធ្យម | (១៧៥) | ៦៦.៣២២ | (១៦៥) | ៣១.៣៨៥ | (១៦០) | ៣០.០៥៥ | (១៤៥) | ២៦.៤៥០ | (១៥៧) | ២០.៥៥០ | (១៦៣) | ៧៧.៣៤៥ | (១៧៧) | ៦៦.០៦៣ | (១៦៧) | ៧០.៣៦៣ | (១៥៧) | ១៦១.៨០៦ | (១៤៥) | ១៧៨.៦១៥ |
| | - ខាតមធ្យម | (១២៤) | ២៧.៧៦០ | (១៣៧) | ៦៥.១៦៥ | (១៤៦) | ៣៥.៧១៣ | (១៥៣) | ៦២.៨៤៤ | (១៤៦) | ៣៣.១២១ | (១៤២) | ១៨.៣៨៦ | (១២១) | ២១.០៧០ | (១២០) | ២៣.៥៦៧ | (១២១) | ៨១.៧៥០ | (១០៨) | ៥៦.៨៤៦ |
| | - ខាតបូកបន្ថែម | | ៥១៥.៣៤០ | | ៥៣០.៣៦០ | | ៥៦៣.១៥៣ | | ៥៥៥.៨៣០ | | ៦២៦.៥៧៥ | | ១១៦.០៦២ | ១៥១.៤៧២ | | | ១៦២.៥១២ | | ២៤០.៨៥៥ | | ៧១៦.១៣០ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ៦០.៤ | | ៦៦.៨ | | ៦៧.៧ | | ៥១.៣ | | ៦៤.៨ | | ៦៧.៥ | | ៦១.៣ | | ៦១.៨ | | ៦៦.០ | | ៦២.៧ |
| សរុប | - ចំណេញមធ្យម | (២.៣៨៦) | ២៨៦.៤៦០ | (២.៣៣០) | ២៧៤.៨៣១ | (២.២៤៣) | ២៤៦.៦៣៨ | (២.៣០៤) | ២៨៨.៦៣៥ | (២.៤៤៤) | ៣០៤.២៦២ | (២.៤០៥) | ៣៤៤.៦៨០ | (២.៣៧២) | ៣២៣.៤៦១ | (២.៣៣៧) | ៣៤៤.៧២៧ | (២.១៧៥) | ៥១៤.៦១០ | (១.៨៦៤) | ៥៦៣.៤៧៥ |
| | - ខាតមធ្យម | (១.០៦៥) | ៣៧១.៦៨១ | (១.១៣៨) | ៦០៣.៧៧៨ | (១.១៨៣) | ៦២២.៧០៥ | (១.១៧៦) | ៦២៣.៦២៨ | (១.០៥៨) | ៣៧៥.៦៥៧ | (១.១៥៦) | ៣៦៥.៣៦៧ | (១.១៦៥) | ៣៧៦.៥៥០ | (១.១៥៨) | ២៥៣.៧៥០ | (១.០៦៦) | ៣៦០.៦១៧ | (៥៧៥) | ៣០៥.៨៣៥ |
| | - ខាតបូកបន្ថែម | | ៣.៥៨២.៥២៨ | | ៣.៨៥៥.០៦៦ | | ៦.១៨៨.៥៥០ | | ៦.៥០៥.៦១៨ | | ៦.៨៧៦.៥១០ | | ៦.៦៣៣.១៦៣ | | ៦.៧៦២.០១៦ | | ៦.៦៥៨.១០៦ | | ៦.៦៥៧.០៧២ | | ៦.៦៦៦.៦៨៣ |
| | - ភាគរយនៃចំនួនសហគ្រាសដែលមានឱនភាព | | ៣០.៤ | | ៣២.៨ | | ៣៦.០ | | ៣៣.៨ | | ៣១.៦ | | ៣៣.០ | | ៣៣.៦ | | ៣៣.១ | | ៣៣.៤ | | ៣៦.៣ |

កំណត់សម្គាល់ : ១ តួលេខនៅក្នុងរង្វង់ក្រចកបង្ហាញអំពីចំនួនសហគ្រាស ។

២ "ចំនួនសហគ្រាសដែលមានឱនភាព" សំដៅចំពោះចំនួនសហគ្រាសដែលទទួលរងការខាតធម្មតា នៅក្នុងឆ្នាំសារពើពន្ធនោះ ។

អភិបាលកិច្ចមូលដ្ឋាន (ការរៀបចំតាក់តែងគោលនយោបាយ
និងសង្គមស៊ីវិល)
ឆ្នាំសារពើពន្ធ២០០៧

# ប្រព័ន្ធអាករមូលដ្ឋាននៅប្រទេសជប៉ុន

~មាតិកា~

## ជំពូកទី ១ : សេចក្តីផ្តើម


១. ប្រព័ន្ធអាករនៅប្រទេសជប៉ុន........................................................................ ១

២. ចំណូលពីអាករ........................................................................ ៤

៣. អាករប្រមូលយកដោយអង្គភាពមូលដ្ឋាន........................................................................ ៤

៤. រចនាសម្ព័ន្ធនៃចំណូលមូលដ្ឋាន........................................................................ ៥


## ជំពូកទី ២ : សេចក្តីសង្ខេបអំពីអាករមូលដ្ឋានចម្បងៗ


១. អាករលើប្រជាជន........................................................................ ១៤

ក. អាករលើប្រជាជនម្ចាស់សាជីវកម្ម........................................................................ ១៤

ខ. អាករលើប្រជាជនជាឯកត្តជន........................................................................ ១៨

គ. អត្រាការប្រាក់........................................................................ ២៣

ឃ. អត្រាភាគលាភលើភាគហ៊ុន........................................................................ ២៤

ង. អត្រាចំណេញជាមូលធន........................................................................ ២៥

២. អាករលើសហគ្រាសមូលដ្ឋាន........................................................................ ២៦

ក. អ្នកជាប់ពន្ធ........................................................................ ២៦

ខ. មូលដ្ឋានអាករ និងអត្រាអាករ (សាជីវកម្ម)........................................................................ ២៧

គ. មូលដ្ឋានអាករ និងអត្រាអាករ (ឯកត្តជន)........................................................................ ២៩

ឃ. ការបង់ប្រាក់........................................................................ ២៩

ង. ការលើកពេលប្រមូលអាករ........................................................................ ៣០

៣. អាករលើការប្រើប្រាស់មូលដ្ឋាន........................................................................ ៣៦

ក. អ្នកជាប់ពន្ធ........................................................................ ៣៦

ខ. យុត្តាធិការប្រមូលអាករ........................................................................ ៣៦

គ. មូលដ្ឋានអាករ........................................................................ ៣៦

ឃ. អត្រាអាករ........................................................................ ៣៧

ង. ការប្រមូលអាករ........................................................................ ៣៧

ច. ប្រព័ន្ធទូទាត់ក្នុងខេត្ត........................................................................ ៣៨

ឆ. ការចែកចាយដល់ក្រុង........................................................................ ៣៨

៤. អាករលើទ្រព្យសកម្មរយៈពេលវែង........................................................................ ៤០

ក. អាករលើទ្រព្យសកម្មរយៈពេលវែងក្នុងក្រុង........................................................................ ៤០

ខ. អាករលើទ្រព្យសកម្មរយៈពេលវែងក្នុងខេត្ត........................................................................ ៤២

# ជំពូកទី ១ : សេចក្តីផ្តើម

## ១. ប្រព័ន្ធអាករនៅប្រទេសជប៉ុន

ប្រព័ន្ធអាករនៅប្រទេសជប៉ុនបច្ចុប្បន្នត្រូវបានបែងចែកជាពីរផ្នែក គឺ អាករដែលកំណត់ដោយរដ្ឋាភិបាលជាតិ (អាករជាតិ) និងអាករដែលកំណត់ដោយរដ្ឋាភិបាលមូលដ្ឋាន ដែលជាខេត្ត និងក្រុង (អាករមូលដ្ឋាន)

អាករជាតិសំខាន់ៗមានដូចខាងក្រោម :

(១) អាករលើប្រាក់ចំណូល : ជាអាករផ្ទាល់ដែលកាត់យកពីប្រាក់ចំណូលសុទ្ធរបស់ឯកត្តជន ។

(២) អាករលើសាជីវកម្ម : ជាអាករផ្ទាល់ដែលកាត់យកពីចំណូលសុទ្ធរបស់សាជីវកម្ម ។

(៣) អាករលើការប្រើប្រាស់ : ជាអាករមិនផ្ទាល់ដែលប្រមូលយកលើទំនិញ និងសេវាកម្ម ជាទូទៅ ។

(៤) អាករលើប្រេងសាំង : ជាអាករមិនផ្ទាល់ដែលប្រមូលយកលើប្រេងដែលដឹកពីរោងចក្រចម្រាញ់ប្រេង ឬកាត់យកពីតំបន់ជាប់ពន្ធគយ ។

(៥) អាករលើសុរា : ជាអាករផ្ទាល់ដែលប្រមូលយកលើសុរាក្នុងស្រុកដែលដឹកពីរោងចក្រផលិតសុរា និងលើសុរានាំចូលដែលកាត់យកពីតំបន់ជាប់ពន្ធគយ ។

រដ្ឋធម្មនុញ្ញជប៉ុនធានានូវស្វ័យភាពមូលដ្ឋានកម្រិតខ្ពស់ ។ ដោយផ្អែកលើបទប្បញ្ញត្តិ នៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា ២២៣ នៃច្បាប់ស្តីពីស្វ័យភាពមូលដ្ឋានបានចែងថា រដ្ឋាភិបាលមូលដ្ឋានមានសិទ្ធិអំណាចក្នុងការកំណត់ និងប្រមូលអាករមូលដ្ឋាន ។

ស្របតាមបទប្បញ្ញត្តិ នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីស្វ័យភាពមូលដ្ឋាន ច្បាប់ស្តីពីអាករមូលដ្ឋានចែងអំពីប្រព័ន្ធអាករមូលដ្ឋាន ។ ច្បាប់ស្តីពីអាករមូលដ្ឋានចែងអំពីប្រភេទនៃអាករដែលរដ្ឋាភិបាលមូលដ្ឋានអាចប្រមូលយកបាន មូលដ្ឋានអាករ និង "អត្រាស្តង់ដារ" ក៏ដូចជា "អត្រាជាអតិបរមា" ឬ "អត្រាថេរ" នៃអាករទាំងនេះ ។ ដោយសារតែមូលដ្ឋានអាករត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីអាករមូលដ្ឋាន មូលដ្ឋាននៃអាករទាំងនេះត្រូវមានភាពដូចគ្នា ក្នុងចំណោមយុត្តាធិការទូទាំងប្រទេស ។ "អត្រាស្តង់ដារ" គឺជាអត្រាដែលរដ្ឋាភិបាលមូលដ្ឋាននីមួយៗត្រូវប្រើប្រាស់ លើកលែងតែមានហេតុផលហិរញ្ញវត្ថុ (ឬហេតុផលផ្សេងទៀត) ធ្វើអោយរដ្ឋាភិបាលមូលដ្ឋានត្រូវអនុម័តយកអត្រាអាករផ្សេងពី "អត្រាស្តង់ដារ" ។ ប្រសិនបើចាំបាច់ រដ្ឋាភិបាលមូលដ្ឋាននីមួយៗអាចជ្រើសរើសអត្រាអាកររហូតដល់ "អត្រាអតិបរមា" ដែលបានកំណត់ ។ "អត្រាថេរ" គឺជាអត្រាដែលរដ្ឋាភិបាលមូលដ្ឋាននីមួយៗត្រូវអនុវត្តតាម ។

អាករមូលដ្ឋានចែកចេញជាពីរប្រភេទ គឺអាករខេត្ត និងមួយទៀតអាករក្រុង ដោយសារតែអង្គភាពសាធារណៈមូលដ្ឋានដែលកំណត់អាករ មានទម្រង់ផ្សេងៗគ្នា ។ អាករខេត្តគឺអាករដែលកំណត់ដោយខេត្ត ពោលគឺរដ្ឋាភិបាលមូលដ្ឋាន ហើយសមាសភាពសំខាន់ៗនៃអាករខេត្តមានដូចខាងក្រោម :

(១) អាករលើប្រជាជនរស់នៅក្នុងខេត្ត អាករលើសហគ្រាស អាករលើរថយន្ត អាករលើការទិញអចលនវត្ថុ អាករលើទីលានវាយកូនគោល និងអាករលើការប្រើប្រាស់មូលដ្ឋាន ត្រូវបានហៅថាអាករសាមញ្ញហើយមិនត្រូវបានសម្គាល់ថាជាការចំណាយជាក់លាក់ឡើយ ។

(២) អាករលើការទិញរថយន្ត និងអាករលើការប្រគល់ប្រេងស្រាល ត្រូវបានហៅថាអាករទិសដៅ និងត្រូវបានសម្គាល់ថាជាការចំណាយជាក់លាក់ ដូចជាផ្លូវថ្នល់ ។

(៣) អាករជាឆន្ទានុសិទ្ធរបស់ខេត្តអាចត្រូវកំណត់ដោយខេត្ត ប្រសិនបើខេត្តទទួលបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

អាករក្រុងត្រូវកំណត់ដោយរដ្ឋាភិបាលមូលដ្ឋាន ដូចជា ទីក្រុង ឃុំ និងភូមិ ។ សមាសភាពសំខាន់ៗមានដូចតទៅ អាករសាមញ្ញ ដូចជា អាករលើប្រជាជនរស់នៅក្នុងក្រុង អាករលើទ្រព្យសកម្មរយៈពេលវែង និងអាករទិសដៅ ដូចជា អាករលើការិយាល័យជំនួញ អាករលើនគរូបនីយកម្ម និងអាករលើកន្លែងស្ពង់ ។ រដ្ឋាភិបាលមូលដ្ឋានអាចកំណត់អាករជាឆន្ទានុសិទ្ធរបស់ក្រុង ប្រសិនបើក្រុងទទួលបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

ប្រព័ន្ធដែលពាក់ព័ន្ធនឹងអាករមូលដ្ឋានមានបង្ហាញជូននៅក្នុងតារាងដូចខាងក្រោម ។

**ចំណាត់ថ្នាក់អាករមូលដ្ឋាន**

| ប្រភេទ | | អាជ្ញាធរប្រមូលអាករ | | | |
|---|---|---|---|---|---|
| | | ប្រភេទ "ខេត្ត" | | ប្រភេទ "ក្រុង" | |
| គោលបំណង | អាករ | រាជធានីតូក្យូ | ខេត្តផ្សេងទៀត | ក្រុង | សង្កាត់ពិសេស (តូក្យូ) |
| គោលបំណងទូទៅ | • អាករលើប្រជាជន ជាឯកត្តជន និងសាជីវកម្ម | ○ | ○ | ○ | ○ (ឯកត្តជនប៉ុណ្ណោះ) |
| | • អាករលើសហគ្រាស | ○ | ○ | | |
| | • អាករលើការប្រើប្រាស់មូលដ្ឋាន | ○ | ○ | | |
| | • អាករលើទ្រព្យសកម្មរយៈពេលវែង | ⊙ | ○ (ទ្រព្យសកម្មដែលត្រូវរំលោះច្រើនប៉ុណ្ណោះ) | ○ | |
| (អាករសាមញ្ញ (មិនមានសម្គាល់)) | | | | | |
| | • អាករលើអាជីវកម្មដីធ្លីពិសេស | ⊙ | | ○ | |
| | • អាករលើរថយន្ត | ○ | ○ | | |
| | • អាករលើទីលានវាយកូនគោល | ○ | ○ | | |
| | • អាករលើថ្នាំជក់ | ○ | ○ | ○ | ○ |
| គោលបំណងពិសេស | • អាករលើនគរូបនីយកម្ម | ⊙ | | ○ | |
| | • អាករលើការិយាល័យជំនួញ | ⊙ | | ○ (ទីក្រុងចាត់តាំង និងទីក្រុងធំៗមួយចំនួន) | |
| (អាករទិសដៅ (មានសម្គាល់)) | • អាករលើការទិញរថយន្ត | ○ | ○ | | |

(កំណត់សម្គាល់)

១. យោងតាមច្បាប់ស្តីពីអាករមូលដ្ឋាន រដ្ឋាភិបាលមូលដ្ឋានកំណត់អាករតូចៗផ្សេងទៀត ដូចជា អាករលើដីឡូតិ៍អណ្តូងរ៉ែ អាករលើផលិតផលរ៉ែ អាករលើកន្លែងស្នង់ ។ល។ អាករខ្លះជាអាករខេត្ត ហើយអាករខ្លះទៀតជាអាករក្រុង ។

២. រដ្ឋាភិបាលមូលដ្ឋានក៏អាចកំណត់អាករមូលដ្ឋានជាឆន្ទានុសិទ្ធិ ប្រសិនបើខ្លួនទទួលបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។ អាករឆន្ទានុសិទ្ធនីមួយៗមិនមានកំណត់ជាពិសេសនៅក្នុងច្បាប់ស្តីពីអាករមូលដ្ឋានទេ ប៉ុន្តែផ្អែកតែលើមូលដ្ឋានជាអ្នកកំណត់ប៉ុណ្ណោះ ។ អាករទាំងនេះបានក្លាយជាមានសារៈសំខាន់ ដោយផ្អែកលើច្បាប់ស្តីពីវិមជ្ឈការដែលចូលជាធរមាននៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០០ ។

៣. ⊙ សម្រាប់តែតំបន់សង្កាត់ពិសេសប៉ុណ្ណោះ ។

## ២. ចំណូលពីអាករ

ទំហំទឹកប្រាក់សរុបនៃចំណូលពីអាករជាតិ និងមូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៥ គឺមានចំនួន ៨៧.០៩៤.៩ ពាន់លានយ៉េន ។ ចំណូលពីអាករជាតិមាន ៦០,០% និងចំណូលពីអាករមូលដ្ឋានមាន ៤០,០% ។

ទំហំទឹកប្រាក់សរុបនៃចំណូលពីអាករមូលដ្ឋាននៅក្នុងឆ្នាំសារពើពន្ធ២០០៥ គឺមានចំនួន ៣៤.៨០៤.៤ ពាន់លានយ៉េន ដែលក្នុងនោះ ៥៦.៣% ជាចំណូលពីអាករក្រុង និង ៤៣.៧% ជាចំណូលពីអាករខេត្ត ។

សមាមាត្រនៃចំណូលពីអាករជាតិ និងមូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ ២០០៥

(គិតជាពាន់លានយ៉េន)

១. សរុប ១០០% (៨៧.០៩៤.៩)

២. អាករជាតិ ៦០,០% (៥២.២៩០.៥)

៣. អាករមូលដ្ឋាន ៤០,០% (៣៤.៨០៤.៤)

សមាមាត្រនៃចំណូលពីអាករខេត្ត និងក្រុង នៅក្នុងឆ្នាំសារពើពន្ធ ២០០៥

(គិតជាពាន់លានយ៉េន)

១. សរុប ១០០% (២៤.៨០៤.៤)

២. អាករខេត្ត ៤៣.៧% (១៥.២២៦.៩)

៣. អាករក្រុង ៥៦.៣% (១៩.៥៧៧.៥)

## ៣. អាករប្រមូលយកដោយអង្គភាពមូលដ្ឋាន

ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននៅប្រទេសជប៉ុនមានពីរកម្រិត : រដ្ឋាភិបាលមូលដ្ឋាន ដូចជា ទីក្រុង ឃុំ និងភូមិ (ក្រុង) មួយកម្រិត និងរដ្ឋាភិបាលមូលដ្ឋាន (ខេត្ត) មួយកម្រិតទៀត ។

ចំនួនក្រុង និងខេត្តមានដូចខាងក្រោម (គិតមកទល់ត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧) :

<u>ក្រុង</u>

| | | |
|---|---|---|
| ទីក្រុង | ៧៨២ | (រួមទាំង ១៧ ទីក្រុងចាត់តាំង) |
| ឃុំ | ៨២៧ | |
| ភូមិ | ១៩៥ | |
| សរុប | ១.៨០៤ | |

ខេត្ត

| | | |
|---|---|---|
| រាជធានី | ១ | (តូក្យូ) |
| ខេត្តផ្សេងទៀត | ៤៦ | |
| សរុប | ៤៧ | |

ក្រៅពីរដ្ឋាភិបាលសាមញ្ញដែលបានរៀបរាប់ខាងលើទាំងនេះ នៅមានរដ្ឋាភិបាលមូលដ្ឋានពិសេសៗទៀត ដូចជា សង្កាត់ពិសេស ទ្រព្យសម្បត្តិសហគមន៍ សហករណ៍អាជ្ញាធរមូលដ្ឋាន (បង្កើតឡើងដើម្បីគ្រប់គ្រងកិច្ចការសាធារណៈមួយចំនួន) សាជីវកម្មអភិវឌ្ឍន៍មូលដ្ឋាន និងខណ្ឌពិសេសនៅក្នុងក្រុងរំលាយបញ្ចូលគ្នា ។

ក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋានពិសេសទាំងអស់នេះ មានតែសង្កាត់ពិសេស និងសហករណ៍ពេញលេញនៃអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះដែលមានសិទ្ធិអំណាចក្នុងការប្រមូលអាករមូលដ្ឋាន ។

(១) ទីក្រុងចាត់តាំង

ទីក្រុងធំៗចំនួន ១៧ ដែលត្រូវបានចាត់តាំងដោយបទបញ្ជារបស់គណៈរដ្ឋមន្ត្រី មានមុខងារផ្សេងៗគ្នាទៅតាមលក្ខណៈ/ទំហំជាក់លាក់នីមួយៗនៃទីក្រុងទាំងនោះ ហើយបំពេញមុខងារដែលប្រគល់ជូនខេត្តជាធម្មតា ។

នាពេលបច្ចុប្បន្ននេះ ទីក្រុងចាត់តាំងមាន អូសាកា ណាហ្គោយ៉ា ក្យូតូ យ៉ូកូហាម៉ា កូបេ គីតាគីយូស៊ុយ សាប៉ូរ៉ូ កាវ៉ាសាគី ហ្វូគូអូកា ហ៊ីរ៉ូស៊ីម៉ា សេនដៃ ជីបា សៃតាម៉ា ស៊ីហ្សុយអូកា សាកៃ នីអ៊ីហ្គាតា និងហាម៉ាម៉ាត់ស៊ុយ ។

(២) សង្កាត់ពិសេស

សង្កាត់ពិសេសទាំង ២៣ នៅរាជធានីតូក្យូមានការរៀបចំ និងការប្រព្រឹត្តទៅខុសគ្នាពីទីក្រុងជារដ្ឋធានីរបស់ខេត្ត ឬទីក្រុងផ្សេងទៀត ។ អាស្រ័យហេតុនេះ អាករដែលកំណត់ដោយសង្កាត់ពិសេសទាំង ២៣ នេះក៏មានភាពខុសគ្នាដែរ ។

(៣) សហករណ៍ពេញលេញនៃអាជ្ញាធរមូលដ្ឋាន

សហករណ៍ពេញលេញនៃអាជ្ញាធរមូលដ្ឋាន អាចត្រូវបានបង្កើតឡើង សម្រាប់ភាពចាំបាច់ជាក់លាក់ដោយឃុំ ឬភូមិចាប់ពី ២ ឡើងទៅ ដើម្បីគ្រប់គ្រងមុខងារសាធារណៈទូទៅរបស់ខ្លួនដោយសហការគ្នា ។ នាពេលបច្ចុប្បន្ននេះ សហករណ៍បែបនេះមិនត្រូវបានបង្កើតឡើងឡើយ ។

## ៤. រចនាសម្ព័ន្ធនៃចំណូលមូលដ្ឋាន

មានប្រភពជាច្រើននៃចំណូលសម្រាប់មុខងាររដ្ឋបាលមូលដ្ឋាន ។ ប្រភពចំណូលសំខាន់ជាងគេបំផុតនោះគឺអាករមូលដ្ឋាន ដែលផ្តល់ហិរញ្ញប្បទានដល់សកម្មភាពឯករាជ្យរបស់រដ្ឋាភិបាលមូលដ្ឋាន ។

អាករមូលដ្ឋាននៃចំណូលរបស់រដ្ឋាភិបាលមូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៥ មាន ៣៧.៤% ។ អាករខេត្តនៃចំណូលរបស់ខេត្តទាំងអស់មាន ៣៥.២% និងអាករក្រុងនៃចំណូលរបស់ក្រុងទាំងអស់មាន ៣៥.០% ។

ប្រភពផ្សេងទៀតនៃចំណូលសម្រាប់រដ្ឋបាលទូទៅរបស់រដ្ឋាភិបាលមូលដ្ឋាន មានដូចខាងក្រោម :

(១) ឧបត្ថម្ភកធនពីរតនាគារជាតិ

ឧបត្ថម្ភកធនពីរតនាគារជាតិមាន ១២.៧% នៃចំណូលសរុប នៅក្នុងឆ្នាំសារពើពន្ធ២០០៥ ។

(២) អាករវិភាជន៍មូលដ្ឋាន

ចំណែកថេរនៃចំណូលអាករជាតិ ដែលស្មើនឹង ៣២% នៃចំណូលដែលបានមកពីអាករលើប្រាក់ចំណូល និងអាករលើសុរា ៣៤.០% នៃអាករលើសាជីវកម្ម ២៩.៥% នៃអាករលើការប្រើប្រាស់ និង២៥% នៃអាករលើថ្នាំជក់ ត្រូវបានបែងចែងដល់រដ្ឋាភិបាលមូលដ្ឋាន សម្រាប់គោលបំណងធានានូវចំណូលចាំបាច់ និងធ្វើសមកម្មកម្រិតខុសគ្នានៃសមត្ថភាពសារពើពន្ធ ។

ចំណែកថេរនេះស្មើនឹង១៨.២%នៃចំណូលសរុបរបស់រដ្ឋាភិបាលមូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៥។

(៣) សញ្ញាប័ណ្ណរបស់រដ្ឋាភិបាលមូលដ្ឋាន

កម្ចីរយៈពេលវែងដោយរដ្ឋាភិបាលមូលដ្ឋាន ផ្តល់ហិរញ្ញប្បទានដល់ការចំណាយផ្សេងៗ សម្រាប់ការសាងសង់ ហើយស្មើនឹង ១១.២% នៃចំណូលសរុបរបស់រដ្ឋាភិបាលមូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៥ ។

(៤) អាករផ្ទេរជូនមូលដ្ឋាន

អាករផ្ទេរជូនមូលដ្ឋានមិនមែនជាអាករមូលដ្ឋាននោះទេ ។ វាជាអាករជាតិដែលប្រមូលដោយរដ្ឋបាលពន្ធដារជាតិ ដោយសារបញ្ហាភាពងាយស្រួលខាងផ្នែកបច្ចេកទេស ។ ចំណែកខ្លះៗនៃចំណូលត្រូវបានផ្ទេរទៅអោយរដ្ឋាភិបាលមូលដ្ឋាន ដោយផ្អែកលើកត្តាៈវិនិច្ឆ័យមួយចំនួន ។ អាករផ្ទេរជូនមូលដ្ឋានមានតែ ២.០% នៃចំណូលសរុបប៉ុណ្ណោះ នៅក្នុងឆ្នាំសារពើពន្ធ២០០៥ ។

អាករផ្ទេរជូនមូលដ្ឋានមានដូចខាងក្រោម :

(ក) អាករផ្ទេរលើប្រាក់ចំណូល (ចាប់ពីឆ្នាំសារពើពន្ធ២០០៤ ដល់ឆ្នាំសារពើពន្ធ២០០៦)

(ខ) អាករផ្ទេរលើផ្លូវថ្នល់ក្នុងមូលដ្ឋាន

(គ) អាករផ្ទេរលើឧស្ម័នប្រេងពង្រាវ

(ឃ) អាករផ្ទេរលើចំណុះផ្ទុកពិសេស

(ង) អាករផ្ទេរលើចំណុះផ្ទុកយានយន្ត

(ច) អាករផ្ទេរលើប្រេងសម្រាប់យន្តហោះ

នៅក្នុងកំឡុងពេលធ្វើកំណែទម្រង់ពន្ធដារនៅក្នុងឆ្នាំ២០០៣ ភាគរយនៃអាករផ្ទេរលើចំណុះផ្ទុកយានយន្តនៃទំហំទឹកប្រាក់សរុបនៃអាករលើចំណុះផ្ទុកយានយន្ត (អាករជាតិ) បានកើនឡើងពី ១/៤ ទៅ ១/៣ ។ មូលហេតុនៃការធ្វើកំណែទម្រង់ គឺដើម្បីជំនួសអោយចំណូលស្មើនឹងទំហំទឹកប្រាក់នៃការកាត់ឧបត្ថម្ភកធន ដែលត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់ផ្លូវថ្នល់ក្នុងក្រុង និងបន្ទុកថ្មីរបស់អាជ្ញាធរមូលដ្ឋានក្នុងការសាងសង់ផ្លូវធំៗ ។

នៅក្នុងកំឡុងពេលធ្វើកំណែទម្រង់ពន្ធដារនៅក្នុងឆ្នាំ២០០៤ អាករផ្ទេរលើប្រាក់ចំណូលត្រូវបានបញ្ចូលទៅក្នុងឆ្នាំសារពើពន្ធ២០០៤ សម្រាប់ជាវិធានការបណ្តោះអាសន្ន តាមរយៈការអនុវត្តការផ្ទេរធនធានដែលបានមកពីចំណូលពីអាករ ពីអាករលើប្រាក់ចំណូល ទៅអាករលើប្រជាជនផ្ទាល់ខ្លួន ។

នៅក្នុងឆ្នាំសារពើពន្ធ២០០៤ និង ២០០៥ អាករផ្ទេរលើប្រាក់ចំណូលត្រូវបានចែកចាយជូនរដ្ឋាភិបាលមូលដ្ឋាននីមួយៗ ស្របទៅតាមទំហំប្រជាជន ហើយនៅក្នុងឆ្នាំសារពើពន្ធ២០០៦ អាករនេះត្រូវបានចែកចាយស្របទៅតាមទំហំទឹកប្រាក់ដែលចែកចាយនៅក្នុងឆ្នាំ២០០៥ និងទំហំទឹកប្រាក់ប៉ាន់ស្មាន ដែលនឹងផ្ទេរពីអាករលើប្រាក់ចំណូល ទៅអាករលើប្រជាជនផ្ទាល់ខ្លួន ។

ជាលទ្ធផលនៃកំណែទម្រង់ពន្ធដារនៅក្នុងឆ្នាំ២០០៦ ការផ្ទេរធនធានដែលបានមកពីចំណូលពីអាករពីអាករលើប្រាក់ចំណូល ទៅអាករលើប្រជាជនផ្ទាល់ខ្លួន ស្មើនឹងទំហំទឹកប្រាក់ ៣ សែនកោដិលានយ៉េន ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០០៧។ អាស្រ័យហេតុនេះ អាករផ្ទេរលើប្រាក់ចំណូលត្រូវបានលុបបំបាត់នៅចុងឆ្នាំសារពើពន្ធ ២០០៦ ។

## តារាងសមាសភាពចំណូល និងចំណាយរបស់រដ្ឋាភិបាលមូលដ្ឋាន នៅក្នុងឆ្នាំសារពើពន្ធ២០០៥

(គិតជាពាន់លានយ៉េន)

| ចំណូល | | | ចំណាយ | | |
|---|---|---|---|---|---|
| ចំណាត់ថ្នាក់ | ទំហំទឹកប្រាក់ | ផលធៀបសមាសភាព | ចំណាត់ថ្នាក់ | ទំហំទឹកប្រាក់ | ផលធៀបសមាសភាព |
| • ចំណូលទូទៅសរុប (ចំណូលមិនមានសម្គាល់) | ៥៥.១៣០.១ | ៥៩.៣ | • ចំណាយជាកាតព្វកិច្ច | ៤៦.៨៥៥.៣ | ៥១.៧ |
| | | | ការទូទាត់ | ២៥.២៦៤.៣ | ២៧.៩ |
| អាករមូលដ្ឋាន | ៣៤.៨០៤.៤ | ៣៧.៤ | ជំនួយ | ៧.៦៦៧.៨ | ៨.៥ |
| | | | សញ្ញាប័ណ្ណសាធារណៈ | ១៣.៩២៣.៣ | ១៥.៤ |
| អាករផ្ទេរមូលដ្ឋាន | ១.៨៤៩.០ | ២.០ | • ចំណាយសម្រាប់វិនិយោគ | ១៥.៨២៨.៩ | ១៧.៥ |
| ឧបត្ថម្ភកធនពិសេសដល់មូលដ្ឋាន | ១.៥១៨.០ | ១.៦ | | | |
| អាករវិភាជន៍ មូលដ្ឋាន | ១៦.៩៥៨.៧ | ១៨.២ | ការសាងសង់សាមញ្ញ | ១៥.១០៤.៣ | ១៦.៧ |
| • ចំណាយរបស់រតនាគារជាតិ | ១១.៨៨៨.៩ | ១២.៨ | ការសាងសង់មានឧបត្ថម្ភកធន | ៦.១៧៦.២ | ៦.៨ |
| • សញ្ញាប័ណ្ណមូលដ្ឋាន | ១០.៣៧៦.៣ | ១១.២ | ការសាងសង់គ្មានឧបត្ថម្ភកធន | ៧.៦៦៣.៩ | ៨.៤ |
| • ផ្សេងទៀត | ១៥.៥៤១.២ | ១៦.៧ | ផ្សេងទៀត | ១.២៦៤.២ | ១.៤ |
| | | | ការស្តារពីគ្រោះមហន្តរាយ | ៧០៨.១ | ០.៨ |
| | | | ការកាត់បន្ថយភាពគ្មានការងារធ្វើ | ១៦.៥ | ០.០ |
| | | | • ផ្សេងទៀត | ២៨.០១៣.១ | ៣០.៨ |
| សរុបទូទៅ | ៩២.៩៣៦.៥ | ១០០.០ | សរុបទូទៅ | ៩០.៦៩៧.៣ | ១០០.០ |

## ចំណូលមូលដ្ឋានសរុបនៅក្នុងឆ្នាំសារពើពន្ធ២០០៥

១. ចំណូលសរុប ១០០%

២. ផ្សេងទៀត ១៦,៧%

៣. ឧបត្ថម្ភកធនពីរតនាគារជាតិ ១២,៨%

៤. សញ្ញាប័ណ្ណរដ្ឋាភិបាលមូលដ្ឋាន ១១,២%

៥. អាករផ្ទេរដល់មូលដ្ឋាន ២,០%

៦. អាករវិភាជន៍មូលដ្ឋាន ១៨,២%

៧. អាករមូលដ្ឋាន ៣៧,៤%

## ចំណូលរបស់ខេត្តនៅក្នុងឆ្នាំសារពើពន្ធ២០០៥

១. ចំណូលសរុប ១០០%

២. ផ្សេងទៀត ១៨,៨%

៣. ឧបត្ថម្ភកធនពីរតនាគារជាតិ ១៣,៥%

៤. សញ្ញាប័ណ្ណរដ្ឋាភិបាលមូលដ្ឋាន ១១,៧%

៥. អាករផ្ទេរដល់មូលដ្ឋាន ១,៨%

៦. អាករវិភាជន៍មូលដ្ឋាន ១៨,៩%

៧. អាករមូលដ្ឋាន ៣៥,២%

**ចំណូលរបស់ក្រុងនៅក្នុងឆ្នាំសារពើពន្ធ២០០៥**

១. ចំណូលសរុប ១០០%

២. ផ្សេងទៀត ២៨,០%

៣. ឧបត្ថម្ភកធនពីរតនាគារជាតិ ១០,៤%

៤. សញ្ញាប័ណ្ណរដ្ឋាភិបាលមូលដ្ឋាន ៩,៣%

៥. អាករផ្ទេរដល់មូលដ្ឋាន ២,០%

៦. អាករវិភាជន៍មូលដ្ឋាន ១៥,៣%

៧. អាករមូលដ្ឋាន ៣៥,០%

# កំណែទម្រង់ពន្ធដារឆ្នាំសារពើពន្ធ២០០៦
# លើការផ្ទេរប្រភពចំណូលពីអាករចំនួន ៣ សែនកោដិយ៉េន

## <u>សេចក្តីសង្ខេបនៃកំណែទម្រង់ពន្ធដារឆ្នាំសារពើពន្ធ២០០៦</u>

ជាផ្នែកមួយនៃ "កំណែទម្រង់បីផ្នែក" (កំណែទម្រង់ចម្រុះនៃឧបត្ថម្ភកធន អាករវិភាជន៍មូលដ្ឋាន និងការផ្ទេរប្រភពចំណូលពីអាករពីរដ្ឋាភិបាលជាតិទៅរដ្ឋាភិបាលមូលដ្ឋាន) ប្រភពចំណូលពីអាករដ៏សំខាន់ចំនួន ៣ សែនកោដិយ៉េនត្រូវបានផ្ទេរពីអាករលើប្រាក់ចំណូលជាតិទៅអាករលើប្រជាជនមូលដ្ឋាន ។

អាស្រ័យហេតុនេះ រចនាសម្ព័ន្ធអត្រាវិវត្តន៍នៃអាករលើប្រជាជនមូលដ្ឋាន នឹងត្រូវធ្វើកំណែទម្រង់ទៅជាអត្រាអាករថេរចំនួន១០%* ។

* រចនាសម្ព័ន្ធអាករថ្មីនេះនឹងត្រូវអនុវត្តចំពោះអាករលើប្រជាជនមូលដ្ឋានចាប់ពីឆ្នាំសារពើពន្ធ២០០៧ តទៅ ។

កំណែទម្រង់រចនាសម្ព័ន្ធអាករនេះបណ្តាលអោយមានឥទ្ធិពលពីរដូចខាងក្រោម ។

១) ទំនាក់ទំនងរវាងប្រាក់ចំណេញ និងបន្ទុក នៅក្នុងអាករលើប្រជាជនមូលដ្ឋាននឹងមានភាពច្បាស់លាស់ ។

២) ការកែតម្រូវនៃការចែកចាយមិនស្មើភាពនូវប្រភពចំណូលពីអាករ ។

### (គោលបំណងនៃកំណែទម្រង់បីផ្នែក)

* បង្កើនសិទ្ធិ និងទំនួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានអោយទូលំទូលាយ ។

* ផ្តល់លទ្ធភាពអោយអាជ្ញាធរមូលដ្ឋានជ្រើសរើសសេវារដ្ឋបាលចាំបាច់ ប្រកបដោយប្រសិទ្ធភាព សម្រាប់ប្រជាជន ដោយមានស្វ័យទំនួលខុសត្រូវ ។

* កសាងរចនាសម្ព័ន្ធរដ្ឋបាល និងសារពើពន្ធ ធម្មតា និងមានប្រសិទ្ធភាព ទាំងក្នុងរដ្ឋាភិបាលជាតិ និងរដ្ឋាភិបាលមូលដ្ឋាន ។

**កំណែទម្រង់ឧបត្ថម្ភកធន**
**ពីរដ្ឋាភិបាលជាតិ**

ការលុបចោលនូវឧបត្ថម្ភកធនចំនួន ៤.៧ សែនកោដិយ៉េនពីរដ្ឋាភិបាលជាតិដល់រដ្ឋាភិបាលមូលដ្ឋានចាប់ពីឆ្នាំសារពើពន្ធ២០០៤ រហូតដល់ឆ្នាំ ២០០៦ តទៅ ។ ក្នុងចំណោមឧបត្ថម្ភកធនទាំងនោះ ឧបត្ថម្ភកធនចំនួន ៣ សែនកោដិយ៉េន ត្រូវបានបំលែងទៅជាអាករមូលដ្ឋាន ។

**ការផ្ទេរប្រភពចំណូលពីអាករ**

ដោយលុបបំបាត់អត្រាអាករលើប្រជាជនមូលដ្ឋាន ការផ្ទេរប្រភពចំណូលពីអាករចំនួន ៣ សែនកោដិយ៉េនពីអាករលើប្រាក់ចំណូលទៅអាករលើប្រជាជនជាឯកត្តជនក្នុងមូលដ្ឋាន ត្រូវបានអនុវត្តនៅក្នុងកំណែទម្រង់ពន្ធដារឆ្នាំសារពើពន្ធ ២០០៦

**កំណែទម្រង់អាករវិភាជន៍មូលដ្ឋាន**

- ការកាត់បន្ថយដ៏សម្បើមនូវទំហំទឹកប្រាក់ទាំងមូល (▲៥.១ សែនកោដិយ៉េន ចាប់ពីឆ្នាំសារពើពន្ធ២០០៤ ដល់ ២០០៦) ។
- ការបង្កើតវិធីគណនាដែលផ្តល់ការលើកទឹកចិត្តដល់កំណែទម្រង់រដ្ឋបាល
- ការធ្វើអោយមានភាពសាមញ្ញនូវវិធីគណនា
- ការបង្កើនចំនួននៃអាជ្ញាធរមូលដ្ឋានដែលមិនទទួលអាករវិភាជន៍មូលដ្ឋាន ។

## កំណែទម្រង់រចនាសម្ព័ន្ធអត្រានៃអាករលើប្រាក់ចំណូលជាតិ និងអាករលើប្រជាជនមូលដ្ឋាន (ឆ្នាំ២០០៦)

អត្រាអាករលើប្រជាជនមូលដ្ឋានត្រូវបានធ្វើកំណែទម្រង់ចាប់តាំងពីរចនាសម្ព័ន្ធវិវត្តន៍បីប្រភេទ ជាមួយនឹងអត្រាអាករ ៥% ១០% និង ១៣% ទៅជាអត្រាអាករថេរ ១០%* ។

* ៤% សម្រាប់អាករលើប្រជាជនខេត្ត និង ៦% សម្រាប់អាករលើប្រជាជនក្រុង ។

ក្នុងពេលជាមួយគ្នានេះ អត្រាអាករលើប្រាក់ចំណូលត្រូវបានធ្វើកំណែទម្រង់ពីរចនាសម្ព័ន្ធ ៤ ប្រភេទ ជាមួយនឹងអត្រាអាករពី១០% ដល់៣៧% ទៅជា ៦ ប្រភេទ ពី ៥% ទៅ ៤០% ។ អាស្រ័យហេតុនេះ អាករលើប្រាក់ចំណូលវិវត្តន៍បានកើនឡើង ។

១) ការពន្យល់បំភ្លឺអំពីការបែងចែកតួនាទី

កំណែទម្រង់នេះបានធ្វើអោយមានភាពច្បាស់លាស់នូវទំនាក់ទំនងរវាងផលចំណេញ និងបន្ទុក នៅក្នុងអាករលើប្រជាជនមូលដ្ឋាន និងពង្រឹងមុខងារនៃអាករលើប្រាក់ចំណូល នៅក្នុងការបែងចែកប្រាក់ចំណូលឡើងវិញ ។

២) ការជៀសវាងបង្កើនបន្ទុកអាករជាឯកត្តជន

ដើម្បីជៀសវាងបង្កើនបន្ទុកអាករជាឯកត្តជន អត្រាសរុបនៃការកំណត់អាករលើប្រាក់ចំណូលជាឯកត្តជន (អាករលើប្រជាជនមូលដ្ឋាន និងអាករលើប្រាក់ចំណូល) ត្រូវបានរក្សាអោយនៅកម្រិតដដែល មុនធ្វើកំណែទម្រង់ ។

(មុនកំណែទម្រង់)

| អាករលើប្រជាជនមូលដ្ឋាន | |
|---|---|
| ប្រាក់ចំណូលជាប់ពន្ធ (យ៉េន) | អត្រាស្តង់ដារ |
| ~ ២.០០០.០០០ | ៥% |
| ២.០០០.០០០ ~ ៧.០០០.០០០ | ១០% |
| ៧.០០០ ~ | ១៣% |
| (អាករលើប្រជាជនខេត្ត) | |
| ~ ៧.០០០.០០០ | ២% |
| ៧.០០០.០០០ ~ | ៣% |
| (អាករលើប្រជាជនក្រុង) | |
| ~ ២.០០០.០០០ | ៣% |
| ២.០០០.០០០ ~ ៧.០០០.០០០ | ៨% |
| ៧.០០០ ~ | ១០% |

(ក្រោយកំណែទម្រង់)

| អាករលើប្រជាជនមូលដ្ឋាន | |
|---|---|
| ប្រាក់ចំណូលជាប់ពន្ធ (យ៉េន) | អត្រាស្តង់ដារ |
| ថេរ | ១០% |
| (អាករលើប្រជាជនខេត្ត) | |
| ថេរ | ៤% |
| (អាករលើប្រជាជនក្រុង) | |
| ថេរ | ៦% |

កំណត់សម្គាល់ : រចនាសម្ព័ន្ធអត្រាថ្មីនេះនឹងត្រូវអនុវត្តចំពោះអាករលើប្រាក់ចំណូលចាប់ពីឆ្នាំសារពើពន្ធ ២០០៧ ។

| អាករលើប្រាក់ចំណូលជាតិ | |
|---|---|
| ប្រាក់ចំណូលជាប់ពន្ធ (យ៉េន) | អត្រា |
| ~ ៣.៣០០.០០០ | ១០% |
| ៣.៣០០.០០០ ~ ៩.០០០.០០០ | ២០% |
| ៩.០០០.០០០ ~ ១៨.០០០.០០០ | ៣០% |
| ១៨.០០០.០០០ ~ | ៣៧% |

| អាករលើប្រាក់ចំណូលជាតិ | |
|---|---|
| ប្រាក់ចំណូលជាប់ពន្ធ (យ៉េន) | អត្រា |
| ~ ១.៩៥០.០០០ | ៥% |
| ១.៩៥០.០០០ ~ ៣.៣០០.០០០ | ១០% |
| ៣.៣០០.០០០ ~ ៦.៩៥០.០០០ | ២០% |
| ៦.៩៥០.០០០ ~ ៩.០០០.០០០ | ២៣% |
| ៩.០០០.០០០ ~ ១៨.០០០.០០០ | ៣៣% |
| ១៨.០០០.០០០ ~ | ៤០% |

កំណត់សម្គាល់ : រចនាសម្ព័ន្ធអត្រាថ្មីនេះនឹងត្រូវអនុវត្តចំពោះអាករលើប្រាក់ចំណូល ចាប់ពីឆ្នាំសារពើពន្ធ ២០០៧ ។

## ការកែតម្រូវការចែកចាយមិនស្មើគ្នានូវប្រភពអាករ
## ដោយលុបបំបាត់អត្រាអាករលើប្រជាជនមូលដ្ឋាន

(មុនកំណែទម្រង់)

| ៥% | ១០% | ១៣% |
|---|---|---|

0　　២.000.000　　៧.000.000

(ក្រោយកំណែទម្រង់)

១០%

0

ការផ្ទេរពីរដ្ឋាភិបាលជាតិទៅរដ្ឋាភិបាលមូលដ្ឋាន (ប្រហែល ៣.៤ សែនកោដិយ៉េន)

① ៥%

អាករលើប្រាក់ចំណូល (អាករជាតិ)

ការផ្ទេរពីរដ្ឋាភិបាលមូលដ្ឋានទៅរដ្ឋាភិបាលជាតិ (ប្រហែល 0.៤ សែនកោដិយ៉េន)

៣%

②

| ៥% | ១០% | ១០% |
|---|---|---|

0　　២.000.000　　៧.000.000

ការធ្លាក់ចុះនៃចំណូលពីអាករដោយការកាត់បន្ថយអត្រាពី ១៣% ទៅ ១០% (② )មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអាជ្ញាធរមូលដ្ឋានដែលមានប្រជាជនច្រើនស្ថិតនៅក្នុងប្រភេទប្រាក់ចំណូលខ្ពស់) ។

ម្យ៉ាងវិញទៀត ការកើនឡើងនូវចំណូលពីអាករដោយការដំឡើងអត្រាពី ៥% ទៅ ១០% (① ) ប៉ះពាល់ដល់អាជ្ញាធរមូលដ្ឋានទាំងអស់ ។

**→ ការលុបបំបាត់អត្រាអាករមានផលប៉ះពាល់ក្នុងការកែតម្រូវការចែកចាយមិនស្មើភាពនូវចំណូលពីអាករ ។**

សូមមើល　ការកែលម្អគម្លាតនៃចំណូលពីអាករដោយលុបបំបាត់អត្រាអាករ

ចំណូល* ជាអាកររបស់ប្រជាជនម្នាក់ៗនៅទីក្រុងតូក្យូ/អូសាកា　**៣.២ ដង → ២.៧ ដង**

* ចំណូលនៃអាករលើប្រជាជនខេត្ត និងអាករលើប្រជាជនក្រុង ។

## ជំពូកទី ២ ៖ សេចក្តីសង្ខេបអំពីអាករមូលដ្ឋានចម្បងៗ

### ១. អាករលើប្រជាជន

អាករលើប្រជាជនខេត្ត និងអាករលើប្រជាជនក្រុង ជាធម្មតា សំដៅដល់ "អាករលើប្រជាជនមូលដ្ឋាន"។ ដោយអាស្រ័យទៅលើការធ្វើចំណែកថ្នាក់អ្នកជាប់ពន្ធ អាករលើប្រជាជនមូលដ្ឋានត្រូវបានហៅថា អាករលើប្រជាជនជាឯកត្តជន ឬអាករលើប្រជាជនម្ចាស់សាជីវកម្ម ។ ដោយធ្វើចំណែកថ្នាក់មូលដ្ឋានអាករ អាករលើប្រជាជនមូលដ្ឋានរួមមានអត្រាក្នុងប្រជាជនម្នាក់ៗ អត្រាប្រាក់ចំណូល (សម្រាប់ឯកត្តជន) ឬអត្រាសាជីវកម្ម (សម្រាប់សាជីវកម្ម) អត្រាការប្រាក់ និងអត្រាភាគលាភលើភាគហ៊ុន និងអត្រាចំណេញជាមូលធន ។

អាករលើប្រជាជនម្ចាស់សាជីវកម្មមានដូចខាងក្រោម ៖

- អាករលើប្រជាជនខេត្ត
  - អត្រាក្នុងប្រជាជនម្នាក់ៗ
  - អត្រាអាករលើសាជីវកម្ម
- អាករលើប្រជាជនក្រុង
  - អត្រាក្នុងប្រជាជនម្នាក់ៗ
  - អត្រាអាករលើសាជីវកម្ម

អាករលើប្រជាជនជាឯកត្តជនមានដូចខាងក្រោម ៖

- អាករលើប្រជាជនក្រុង
  - អត្រាក្នុងប្រជាជនម្នាក់ៗ
  - អត្រាចំណូល
  - អត្រាការប្រាក់
  - អត្រាភាគលាភលើភាគហ៊ុន
  - អត្រាចំណេញជាមូលធន
- អាករលើប្រជាជនក្រុង
  - អត្រាក្នុងប្រជាជនម្នាក់ៗ
  - អត្រាប្រាក់ចំណូល

### ក. អាករលើប្រជាជនម្ចាស់សាជីវកម្ម

(១) អ្នកជាប់ពន្ធ

អ្នកជាប់អាករលើប្រជាជនម្ចាស់សាជីវកម្មមានដូចខាងក្រោម ៖

១) សាជីវកម្មដែលមានការិយាល័យ ឬទីស្នាក់ការអាជីវកម្មនៅក្នុងខេត្ត (ក្រុង) ។
ទំនួលខុសត្រូវបង់អាករលើសាជីវកម្មប្រភេទនេះគឺជាទំហំទឹកប្រាក់សរុប នៃអត្រាក្នុងប្រជាជនម្នាក់ៗ និងអត្រាអាករលើសាជីវកម្ម ។

២) សាជីវកម្មដែលមានសយនដ្ឋាន ។ល។ នៅក្នុងខេត្ត (ក្រុង) ហើយមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម នៅកន្លែងផ្សេង ។

មានតែអត្រាក្នុងប្រជាជនម្នាក់ៗប៉ុណ្ណោះដែលតម្រូវអោយបង់ ចំពោះសាជីវកម្មប្រភេទនេះ ។

៣) សមាគម ឬមូលនិធិមិនមែនសាជីវកម្ម ដែលមានតំណាង ឬអ្នកគ្រប់គ្រងតាមព្រឹត្តន័យ មានការិយាល័យ ទីស្នាក់ការអាជីវកម្ម សយនដ្ឋាន ។ល។ នៅក្នុងខេត្ត (ក្រុង) ។

មានតែអត្រាក្នុងប្រជាជនម្នាក់ៗប៉ុណ្ណោះដែលតម្រូវអោយបង់ ចំពោះអង្គភាពប្រភេទនេះ ។

៤) សាជីវកម្មទាំងឡាយណាដែលមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម នៅក្នុងខេត្ត ដែលអាករលើសាជីវកម្មត្រូវបានប្រមូល ដោយសារការទទួលបន្ទុកលើឥណទានពាណិជ្ជកម្មនៃអាករលើសាជីវកម្ម ។

មានតែអត្រាអាករលើសាជីវកម្មប៉ុណ្ណោះដែលតម្រូវអោយបង់ ចំពោះអង្គភាពប្រភេទនេះ ។

(កំណត់សម្គាល់ ១)

"អត្រាក្នុងប្រជាជនម្នាក់ៗ" សំដៅដល់អាករលើប្រជាជនជាម្ចាស់សាជីវកម្ម ដែលត្រូវបានគណនាដោយផ្អែកលើប្រជាជនម្នាក់ៗ ដោយមិនគិតពីទំហំទឹកប្រាក់នៃចំណូលសុទ្ធរបស់សាជីវកម្ម ឬអង្គភាព ។

(កំណត់សម្គាល់ ២)

"អត្រាអាករលើសាជីវកម្ម" សំដៅដល់ផ្នែកនៃអាករលើប្រជាជនជាម្ចាស់សាជីវកម្ម ដែលប្រមូលយកពីសាជីវកម្ម ឬអង្គការ ដែលត្រូវបានគណនាដោយផ្អែកលើទំហំទឹកប្រាក់នៃអាករលើសាជីវកម្ម (អាករជាតិ) ដែលត្រូវបង់ សាជីវកម្ម ឬអង្គភាព ។

(កំណត់សម្គាល់ ៣)

បទបញ្ជារបស់គណៈរដ្ឋមន្ត្រីចែងថា ចំពោះសាជីវកម្មបរទេស គ្រឹះស្ថានអចិន្ត្រៃយ៍ ដូចបានកំណត់ជាទូទៅនៅក្នុងអនុសញ្ញាស្តីពីអាករអន្តរជាតិ ត្រូវចាត់ទុកថាជាការិយាល័យ ឬទីស្នាក់ការអាជីវកម្មសម្រាប់គោលបំណងនៃអាករលើប្រជាជនជាម្ចាស់សាជីវកម្ម ។

(២) <u>សាជីវកម្មរួចពន្ធ</u>

សាជីវកម្មដូចខាងក្រោមរួចផុតពីការបង់អាករលើប្រជាជនជាម្ចាស់សាជីវកម្ម ។

១) ដោយមិនគិតពីប្រាក់ចំណូលសុទ្ធ អាករលើប្រជាជនជាម្ចាស់សាជីវកម្មត្រូវបានលើកលែងចំពោះសាជីវកម្មសាធារណៈ រដ្ឋាភិបាលកណ្តាល ខេត្ត និងក្រុង សង្កាត់ពិសេស ។ល។

២) ស្ថាប័នសាសនាស្របច្បាប់ កាកបាទក្រហមជប៉ុន គ្រឹះស្ថានសិក្សាស្របច្បាប់ គណៈបក្សនយោបាយ ។ល។ ជាគោលការណ៍ រួចផុតពីការបង់អាករលើប្រជាជនជាម្ចាស់សាជីវកម្ម ប៉ុន្តែ ប្រសិនបើសាជីវកម្មទាំងនោះធ្វើអាជីវកម្មស្វែងរកប្រាក់ចំណេញ អាករលើប្រជាជនជាម្ចាស់សាជីវកម្មត្រូវប្រមូលយកលើប្រាក់ចំណូលសុទ្ធដែលមានមកពីអាជីវកម្មស្វែងរកប្រាក់ចំណេញ ។

(៣) <u>មូលដ្ឋានអាករ</u>

១) អត្រាក្នុងប្រជាជនម្នាក់ៗ

"អត្រាក្នុងប្រជាជនម្នាក់ៗ" ត្រូវបានគណនា ដោយផ្អែកលើចំនួនប្រជាជនម្នាក់ៗ និងប្រមូលយកដោយមិនគិតពីប្រាក់ចំណូលសុទ្ធរបស់សាជីវកម្ម ឬអង្គភាព ។

២) អត្រាអាករលើសាជីវកម្ម

"អត្រាអាករលើសាជីវកម្ម" ត្រូវបានវាយតម្លៃ ដោយផ្អែកលើទំហំទឹកប្រាក់នៃអាករលើសាជីវកម្ម (អាករជាតិ) ដែលបង់ដោយសាជីវកម្ម នៅក្នុងការិយបរិច្ឆេទគណនេយ្យ ។

នៅពេលសាជីវកម្មមួយមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម នៅក្នុងខេត្ត (ក្រុង) ២ ឬច្រើន ទំហំទឹកប្រាក់នៃអាករលើសាជីវកម្មដែលត្រូវគិតដូចជាមូលដ្ឋានអាករដោយខេត្ត (ក្រុង) រៀងៗខ្លួនដែលពាក់ព័ន្ធ ត្រូវកំណត់ជាសមាមាត្រនៃទំហំទឹកប្រាក់សរុបនៃអាករលើសាជីវកម្ម ដោយផ្អែកលើចំនួនបុគ្គលិកបម្រើការងារនៅក្នុងការិយាល័យ ឬទីស្នាក់ការអាជីវកម្ម ។

(៤) <u>អត្រាអាករ</u>

អត្រាអាករស្តង់ដារក្រោមច្បាប់ស្តីពីអាករមូលដ្ឋានមានដូចខាងក្រោម :

១) អាករលើប្រជាជនជាម្ចាស់សាជីវកម្មក្នុងខេត្ត

(ក) អត្រាក្នុងប្រជាជនម្នាក់ៗ

(គិតជាពាន់យ៉េន)

| ទំហំទឹកប្រាក់នៃដើមទុន | ទំហំទឹកប្រាក់នៃអាករប្រចាំឆ្នាំ |
|---|---|
| (១) ច្រើនជាង ៥.០០០.០០០ | ៨០០ |
| (២) ច្រើនជាង ១.០០០.០០០ (ប៉ុន្តែមិនលើសពី ៥.០០០.០០០) | ៥៤០ |
| (៣) ច្រើនជាង ១០០.០០០ (ប៉ុន្តែមិនលើសពី ១.០០០.០០០) | ១៣០ |
| (៤) ច្រើនជាង ១០.០០០ (ប៉ុន្តែមិនលើសពី ១០០.០០០) | ៥០ |
| (៥) ផ្សេងទៀត | ២០ |

(ខ) អត្រាអាករលើសាជីវកម្ម

អត្រាស្តង់ដារសម្រាប់អត្រាអាករលើសាជីវកម្មគឺ អត្រាថេរ ៥% ហើយអត្រាអាករជាអតិបរមា គឺ ៦% ។

២) អាករលើប្រជាជនជាម្ចាស់សាជីវកម្មក្នុងក្រុង

(ក) អត្រាក្នុងប្រជាជនម្នាក់ៗ

(គិតជាពាន់យ៉េនក្នុងមួយឆ្នាំ)

| ទំហំទឹកប្រាក់នៃដើមទុន | ចំនួនបុគ្គលិក | អត្រាអាករស្តង់ដារ | អត្រាអាករអតិបរមា |
|---|---|---|---|
| (១) ច្រើនជាង ៥.០០០.០០០ | ច្រើនជាង ៥០ នាក់ | ៣.០០០ | ១.២ គុណនឹង អត្រាអាករស្តង់ដារ |
| (២) ច្រើនជាង ៥.០០០.០០០ | មិនច្រើនជាង ៥០ នាក់ | ៤១០ | |
| (៣) ច្រើនជាង ១.០០០.០០០ ប៉ុន្តែមិនលើសពី ៥.០០០.០០០ | ច្រើនជាង ៥០ នាក់ | ១.៧៥០ | |
| (៤) ច្រើនជាង ១.០០០.០០០ | មិនច្រើនជាង ៥០ នាក់ | ៤១០ | |
| (៥) ច្រើនជាង ១០០.០០០ ប៉ុន្តែមិនលើសពី ១.០០០.០០០ | ច្រើនជាង ៥០ នាក់ | ៤០០ | |
| (៦) ច្រើនជាង ១០០.០០០ ប៉ុន្តែមិនលើសពី ១.០០០.០០០ | មិនច្រើនជាង ៥០ នាក់ | ១៦០ | |
| (៧) ច្រើនជាង ១០.០០០ ប៉ុន្តែមិនលើសពី ១.០០.០០០ | ច្រើនជាង ៥០ នាក់ | ១៥០ | |
| (៨) ច្រើនជាង ១០.០០០ ប៉ុន្តែមិនលើសពី ១.០០.០០០ | មិនច្រើនជាង ៥០ នាក់ | ១៣០ | |
| (៩) មិនច្រើនជាង ១០.០០០ | ច្រើនជាង ៥០ នាក់ | ១២០ | |
| (១០) មិនច្រើនជាង ១០.០០០ | មិនច្រើនជាង ៥០ នាក់ | ៥០ | |
| (១១) សាជីវកម្មផ្សេងទៀត | | ៥០ | |

(ខ) អត្រាអាករលើសាជីវកម្ម

អត្រាអាករស្តង់ដារសម្រាប់អត្រាអាករស្តង់ដារ គឺជាអត្រាថេរ ១២,៣% ហើយអត្រាអាករជាអតិបរមា គឺ ១៤,៧% ។

(កំណត់សម្គាល់)

វិធានពិសេសសម្រាប់រាជធានីតូក្យូ :

នៅក្នុងតំបន់នៃសង្កាត់ពិសេសទាំង ២៣ របស់រាជធានីតូក្យូ អាករលើប្រជាជនជាម្ចាស់សាជីវកម្មមានកំណត់តែដោយរាជធានីតូក្យូប៉ុណ្ណោះ គឺមិនមានអាករលើប្រជាជនជាម្ចាស់សាជីវកម្មក្នុងក្រុងដែលប្រមូលដោយសង្កាត់ពិសេសឡើយ។ អាស្រ័យហេតុនេះ អត្រាអាករដែលអនុវត្តនៅក្នុងតំបន់ទាំងនោះបានកើនឡើងតាមលំដាប់រហូតដល់ ជាឧទាហរណ៍ ៣.៨០០.០០០ យ៉េន (៨០០.០០០ យ៉េនសម្រាប់អត្រាអាករលើប្រជាជនខេត្ត បូកនឹង ៣.០០០.០០០ យ៉េនសម្រាប់អត្រាអាករលើប្រជាជនក្រុង) ឬ ២.២៩០.០០០ យ៉េន (៥៤០.០០០ យ៉េនសម្រាប់អត្រា អាករលើប្រជាជនខេត្ត បូកនឹង ១.៧៥០.០០០ យ៉េនសម្រាប់អត្រាអាករលើប្រជាជនក្រុង) សម្រាប់អត្រាក្នុងប្រជាជនម្នាក់ៗ និង ១៧,៣% (៥% សម្រាប់អត្រាអាករលើប្រជាជនខេត្ត បូកនឹង ១២,៣% សម្រាប់អត្រាអាករលើប្រជាជនក្រុង) ឬ ២០,៧% (៦% សម្រាប់អត្រាអាករខេត្តជាអតិបរមា បូកនឹង ១៤,៧% សម្រាប់អត្រាអាករក្រុងជាអតិបរមា) សម្រាប់អត្រាអាករលើសាជីវកម្ម ។

ម្យ៉ាងវិញទៀត សង្កាត់ពិសេសទាំង ២៣ នៃរាជធានីតូក្យូប្រមូលអាករលើប្រជាជនជាឯកត្តជន ដូចក្រុងដទៃទៀតដែរ ។

(៥) ការបង់អាករ

អាករលើប្រជាជនជាម្ចាស់សាជីវកម្មត្រូវបង់ ដោយធ្វើស្វ័យវាយតម្លៃ ចំពោះអាជ្ញាធរខេត្ត (ក្រុង) រៀងៗខ្លួន ដោយមិនអោយហួសរយៈពេល ២ខែ បន្ទាប់ពីកាលបរិច្ឆេទចុងក្រោយនៃការិយបរិច្ឆេទគណនេយ្យរបស់ក្រុមហ៊ុនឡើយ។

**ខ. អាករលើប្រជាជនជាឯកត្តជន**

(១) អ្នកជាប់ពន្ធ

អ្នកជាប់អាករលើប្រជាជនជាឯកត្តជនមានដូចខាងក្រោម :

១) ឯកត្តជនដែលមានលំនៅដ្ឋាននៅក្នុងខេត្ត (ក្រុង) គិតមកទល់ត្រឹមថ្ងៃទី០១ ខែមករា។ អាករត្រូវប្រមូលយកពីបុគ្គលទាំងនោះ អាស្រ័យទៅលើទំហំទឹកប្រាក់សរុបដែលត្រូវបានគណនាមួយផ្នែក ដោយផ្អែកលើអត្រាក្នុងប្រជាជនម្នាក់ៗ និងមួយផ្នែក ដោយផ្អែកលើអត្រាប្រាក់ចំណូល ។

២) ឯកត្តជនដែលមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម ឬទីតាំង នៅក្នុងខេត្ត (ក្រុង) គិតមកទល់ត្រឹមថ្ងៃទី០១ ខែមករា ដោយមានលំនៅដ្ឋាននៅក្រៅខេត្ត (ក្រុង) ដែលការិយាល័យ ឬទីស្នាក់ការអាជីវកម្ម ឬ

ទីតាំងអាករតាំងនៅ ។ អាករត្រូវប្រមូលយកពីបុគ្គលទាំងនោះ អាស្រ័យទៅលើទំហំទឹកប្រាក់សរុបដែលត្រូវបានគណនាដោយផ្អែកលើអត្រាក្នុងប្រជាជនម្នាក់ៗ ។

(កំណត់សម្គាល់ ១)

"អត្រាក្នុងប្រជាជនម្នាក់ៗ" ត្រូវបានវាយតម្លៃលើអ្នកជាប់ពន្ធជាឯកត្តជន នៅក្នុងទំហំទឹកប្រាក់ដូចគ្នា ដោយមិនគិតពីប្រាក់ចំណូលសុទ្ធនៅក្នុងឆ្នាំប្រតិទិនមុនឡើយ ។

(កំណត់សម្គាល់ ២)

"អត្រាប្រាក់ចំណូល" មានន័យថាជាផ្នែកនៃអាករលើប្រជាជនជាឯកត្តជនក្នុងខេត្ត (ក្រុង) ដែលត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណូលសុទ្ធដែលទទួលបាន នៅក្នុងឆ្នាំប្រតិទិនមុន ។

(២) <u>បុគ្គលរួចពន្ធ</u>

ឯកត្តជនដូចខាងក្រោមរួចផុតពីការបង់អាករលើប្រជាជនជាឯកត្តជន :

១) ឯកត្តជនដែលទទួលជំនួយពីរដ្ឋាភិបាលក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយសង្គមកិច្ច ។

២) ជនពិការកាយសម្បទា មេម៉ាយ/ពោះម៉ាយ និងឯកត្តជនដែលមានអាយុក្រោម ២០ ឆ្នាំ។ ការលើកលែងនេះមិនអនុវត្តចំពោះបុគ្គលដែលមានប្រាក់ចំណូលសុទ្ធលើសពី ១.២៥០.០០០ យ៉េន នៅក្នុងឆ្នាំប្រតិទិនមុនឡើយ ។

(៣) <u>មូលដ្ឋានអាករ (អត្រាប្រាក់ចំណូល)</u>

១) អត្រាប្រាក់ចំណូល

ប្រាក់ចំណូលជាប់ពន្ធសម្រាប់គោលបំណងអត្រាប្រាក់ចំណូលត្រូវបានទទួល ដោយការកាត់យកពីការលើកលែង និងការដកហូតដូចរៀបរាប់ខាងក្រោម ពីចំណូលសាមញ្ញសរុប ប្រាក់ចំណូលចូលនិវត្តន៍ និងប្រាក់ចំណូលព្រៃឈើ នៅក្នុងឆ្នាំប្រតិទិនមុន ដែលត្រូវបានគណនាដោយវិធីស្ទើរតែដូចគ្នា ដូចមានចែងដោយច្បាប់ស្តីពីអាករលើប្រាក់ចំណូល (អាករជាតិ) ។

ចាប់តាំងពីឆ្នាំ១៩៦៧មក ប្រាក់ចំណូលចូលនិវត្តន៍ត្រូវជាប់អាករលើប្រជាជនខេត្ត និងក្រុង នៅក្នុងឆ្នាំដែលអាករត្រូវបង់ និងត្រូវបានកំណត់អាករដាច់ដោយឡែកពីប្រាក់ចំណូលផ្សេងទៀត ។ ប្រាក់ចំណូលចូលនិវត្តន៍ជាប់ពន្ធត្រូវបានគណនាតាមវិធីដូចគ្នាទៅនឹងករណីអាករលើប្រាក់ចំណូល ។ អត្រាអាករគឺជាអត្រាថេរ ដែលស្មើនឹងអត្រាអាករស្តង់ដារសម្រាប់អាករលើប្រជាជនខេត្ត និងក្រុង ។

២) ការលើកលែង និងការដកហូត

ការដកហូត និងការលើកលែងខាងក្រោមនេះអាចអនុញ្ញាតនៅក្នុងការគណនាប្រាក់ចំណូលសាមញ្ញ ប្រាក់ចំណូលចូលនិវត្តន៍ និងប្រាក់ចំណូលព្រៃឈើ ។

(ក) ការដកហូតសម្រាប់ការខាតបង់ដែលទទួលរងដោយសារគ្រោះមហន្តរាយ

ទំហំទឹកប្រាក់ស្មើនឹងការខាតបង់ដែលបណ្តាលមកពីគ្រោះមហន្តរាយលើសពី ១០%នៃប្រាក់ចំណូលសរុប ឬទំហំទឹកប្រាក់នៃចំណាយដោយសារគ្រោះមហន្តរាយ ដកនឹង ៥០.០០០ យ៉េន អាស្រ័យទៅតាមទំហំទឹកប្រាក់ណាមួយដែលច្រើនជាង ។

(ខ) ការដកហូតសម្រាប់ចំណាយវេជ្ជសាស្ត្រ

ទំហំទឹកប្រាក់ស្មើនឹងចំណាយវេជ្ជសាស្ត្រលើពី ១០០.០០០ យ៉េន ឬ ៥% នៃប្រាក់ចំណូលសរុបចំពោះអ្នកដែលមានប្រាក់ចំណូលសរុបតិចជាង ២.០០០.០០០ យ៉េន (ការដកហូតជាអតិបរមាដែលអនុញ្ញាតគឺ ២.០០០.០០០ យ៉េន) ។

(គ) ការដកហូតសម្រាប់ប្រាក់ធានារ៉ាប់រងសង្គម

ទំហំទឹកប្រាក់ស្មើនឹងប្រាក់ធានារ៉ាប់រងសង្គមដែលបង់ ។

(ឃ) ការដកហូតសម្រាប់ប្រាក់អញ្ញមញ្ញសង្គ្រោះរបស់សហគ្រាសខ្នាតតូច

ទំហំទឹកប្រាក់សរុបប្រាក់អញ្ញមញ្ញសង្គ្រោះរបស់សហគ្រាសខ្នាតតូច ប្រាក់សម្រាប់ផែនការសោធនវិភាគទានដែលបានកំណត់ (ប្រភេទជាឯកត្តជនប៉ុណ្ណោះ) និងប្រាក់សម្រាប់កម្មវិធីអញ្ញមញ្ញសង្គ្រោះដែលរក្សាទុកដោយអង្គភាពសាធារណៈមូលដ្ឋាន ពាក់ព័ន្ធទៅនឹងជនពិការកាយសម្បទា និង/ឬផ្លូវចិត្ត ។

(ង) ការដកហូតសម្រាប់ប្រាក់ធានារ៉ាប់រងជីវិត

i) ចំពោះប្រាក់ផ្សេងពីប្រាក់សោធនជាឯកត្តជន ទំហំទឹកប្រាក់ទាំងស្រុងនៃប្រាក់ ១៥.០០០ យ៉េនដំបូងដែលបង់ បូកនឹង ១/២ នៃទំហំទឹកប្រាក់លើសពី ១៥.០០០ យ៉េន រហូតដល់ ៤០.០០០ យ៉េន បូកនឹង ១/៤ នៃទំហំទឹកប្រាក់លើសពី ៤០.០០០ យ៉េន រហូតដល់ ៧០.០០០ យ៉េន (ការដកហូតជាអតិបរមា គឺ ៣៥.០០០ យ៉េន) ។

ii) ចំពោះប្រាក់សោធនជាឯកត្តជន ទំហំទឹកប្រាក់ទាំងស្រុងនៃប្រាក់ ១៥.០០០ យ៉េនដំបូង ដែលបង់ បូកនឹង ១/២ នៃទំហំទឹកប្រាក់លើសពី ១៥.០០០ យ៉េន រហូតដល់ ៤០.០០០ យ៉េន បូកនឹង ១/៤ នៃទំហំទឹកប្រាក់លើសពី ៤០.០០០ យ៉េន រហូតដល់ ៧០.០០០ យ៉េន (ការដកហូតជាអតិបរមា គឺ ៣៥.០០០ យ៉េន) ។

(ច) ការដកហូតសម្រាប់ប្រាក់ធានារ៉ាប់រងអគ្គិភ័យ និងគ្រោះថ្នាក់ផ្សេងៗ

សម្រាប់តែករណីកិច្ចសន្យារយៈពេលខ្លីប៉ុណ្ណោះ ទំហំទឹកប្រាក់ទាំងស្រុងនៃប្រាក់ ១.០០០ យ៉េនដំបូងដែលបង់ បូកនឹង ១/២ នៃទំហំទឹកប្រាក់លើសពី ១.០០០ យ៉េន រហូតដល់ ៣.០០០ យ៉េន (ការដកហូតជាអតិបរមា គឺ ២.០០០ យ៉េន) ។

ចំពោះកិច្ចសន្យារយៈពេលវែង ទំហំទឹកប្រាក់ទាំងស្រុងនៃប្រាក់ ៥.០០០ យ៉េនដំបូងដែលបង់ បូកនឹង ១/២ នៃទំហំទឹកប្រាក់លើសពី ៥.០០០ យ៉េន រហូតដល់ ១៥.០០០ យ៉េន (ការដកហូតជាអតិបរមា គឺ ១០.០០០ យ៉េន) ។

* ចាប់ពីពេលចាប់ផ្ដើមឆ្នាំសារពើពន្ធ២០០៨ ការដកហូតនេះនឹងត្រូវរៀបចំឡើងវិញបញ្ចូលក្នុងការដកហូតសម្រាប់ប្រាក់ធានារ៉ាប់រងរញ្ជួយដី ។

(ឆ) ការដកហូតសម្រាប់វិភាគទានសប្បុរសធម៌

ទំហំទឹកប្រាក់ស្មើនឹងវិភាគទានសប្បុរសធម៌ (នៅពេលទំហំទឹកប្រាក់លើពី ១/៤ នៃប្រាក់ចំណូលសុទ្ធប្រចាំឆ្នាំ គឺទំហំទឹកប្រាក់ ១/៤) សម្រាប់សមាគមបេឡាសហគមន៍ខេត្ត សមាគមកាកបាទក្រហមជប៉ុន ដែលមានទីតាំងនៅក្នុងលំនៅដ្ឋាន ឬរដ្ឋាភិបាលមូលដ្ឋាន លើសពី ១០០.០០០ យ៉េន ។

(ជ) ការលើកលែងសម្រាប់ជនពិការ : ២៦០.០០០ យ៉េន, ពិការធ្ងន់ធ្ងរ : ២៨០.០០០ យ៉េន ។

(ឈ) ការលើកលែងសម្រាប់មេម៉ាយ/ពោះម៉ាយ : ២៦០.០០០ យ៉េន ។

(ញ) ការលើកលែងសម្រាប់និស្សិតធ្វើការ : ២៦០.០០០ យ៉េន ។

(ដ) ការលើកលែងសម្រាប់ប្ដី/ប្រពន្ធ : ៣៣០.០០០ យ៉េន ។

ប៉ុន្តែ នៅពេលប្ដី/ប្រពន្ធរកចំណូលបានលើសពី ៣៨០.០០០ យ៉េន នៅក្នុងកំឡុងឆ្នាំប្រតិទិនមុន ការលើកលែងនេះមិនត្រូវអនុវត្តឡើយ ។

(ឋ) ការលើកលែងពិសេសសម្រាប់ប្ដី/ប្រពន្ធ : ការលើកលែងជាអតិបរមា គឺ ៣៣០.០០០ យ៉េន ។

(ឌ) ការលើកលែងសម្រាប់អ្នកនៅក្នុងបន្ទុក : ៣៣០.០០០ យ៉េន សម្រាប់អ្នកនៅក្នុងបន្ទុកម្នាក់ៗ ៤៥០.០០០ យ៉េន សម្រាប់អ្នកនៅក្នុងបន្ទុកពិសេសម្នាក់ៗ (អាយុពី ១៦ ដល់ ២២ឆ្នាំ) ៣៨០.០០០ យ៉េន សម្រាប់អ្នកនៅក្នុងបន្ទុកដែលមានអាយុ ៧០ ឆ្នាំ ឬលើសពីនេះ និង ៤៥០.០០០ យ៉េន សម្រាប់បុព្វញាតិដែលរស់នៅក្នុងផ្ទះតែមួយ ។

(ឍ) ការដកហូតជាមូលដ្ឋាន : ៣៣០.០០០ យ៉េន ។

(៤) <u>អត្រាអាករ</u>

អត្រាអាករស្តង់ដារក្រោមច្បាប់ស្ដីពីអាករមូលដ្ឋានមានដូចខាងក្រោម :

១) អាករលើប្រជាជនជាឯកត្តជនក្នុងខេត្ត

(ក) អត្រាក្នុងប្រជាជនម្នាក់ៗជាស្តង់ដារ គឺ ១.០០០ យ៉េន ក្នុងមួយឆ្នាំ ចំពោះគ្រប់ឯកត្តជនទាំងអស់ ។

(ខ) អត្រាស្តង់ដារនៃអត្រាប្រាក់ចំណូល គឺ ៤% ថេរ ។

ច្បាប់ស្ដីអាករមូលដ្ឋានមិនបានចែងអំពីអត្រាអាករជាអតិបរមាសម្រាប់អត្រាអាករនេះទេ ។ នេះមានន័យថាខេត្តអាចអនុម័តអត្រាអាករក្នុងកម្រិតខ្ពស់តាមចិត្ត នៅពេលចាំបាច់ ។

២) អាករលើប្រជាជនជាឯកត្តជនក្នុងក្រុង

(ក) អត្រាក្នុងប្រជាជនម្នាក់ៗជាស្តង់ដារ គឺ ៣.០០០ យ៉េន ក្នុងមួយឆ្នាំ សម្រាប់គ្រប់ឯកត្តជនទាំងអស់។ តាមរយៈឆ្នាំសារពើពន្ធ១៩៩៧ អត្រាអាករក្នុងប្រជាជនម្នាក់ៗជាអតិបរមាត្រូវបានកំណត់ ។ ប៉ុន្តែ អត្រាអាករជាអតិបរមាប្រភេទនេះត្រូវបានលុបបំបាត់ចោល នៅក្នុងកំឡុងកំណែទម្រង់ពន្ធដារឆ្នាំ

១៩៩៨ ដើម្បីពង្រឹងភាពបត់បែនខាងសារពើពន្ធរបស់ក្រុង ។ ជាលទ្ធផល ក្រុងមានសមត្ថភាពអាចអនុម័តអត្រាអាករក្នុងប្រជាជនម្នាក់ៗក្នុងកម្រិតខ្ពស់តាមចិត្ត នៅដើមឆ្នាំសារពើពន្ធ១៩៩៨ ។

(ខ) អត្រាស្តង់ដារនៃអត្រាប្រាក់ចំណូល គឺ ៦% ថេរ ។

រហូតមកដល់ឆ្នាំសារពើពន្ធ១៩៩៧ មានអត្រាអាករលើប្រាក់ចំណូលជាអតិបរមាសម្រាប់អាករលើប្រជាជនក្រុង គឺ ១៥០% នៃអត្រាអាករដែលអនុវត្ត ។ ប៉ុន្តែ អត្រាអាករជាអតិបរមាប្រភេទនេះត្រូវបានលុបបំបាត់ចោលក្នុងកំឡុងកំណែទម្រង់ឆ្នាំ១៩៩៨ ដើម្បីពង្រឹងភាពបត់បែនខាងសារពើពន្ធរបស់ក្រុង ។ ជាលទ្ធផល ក្រុងមានសមត្ថភាពអាចអនុម័តអត្រាអាករក្នុងប្រជាជនម្នាក់ៗក្នុងកម្រិតខ្ពស់តាមចិត្ត នៅដើមឆ្នាំសារពើពន្ធ១៩៩៨ ។

(៥) ឥណទានអាករ

បន្ទាប់ពីអនុវត្តអត្រាអាករលើប្រាក់ចំណូលជាប់ពន្ធសម្រាប់គោលបំណងអត្រាប្រាក់ចំណូល អ្នកជាប់ពន្ធអាចដកចេញនូវឥណទានអាករ ។

មានឥណទានអាករពីរប្រភេទដែលត្រូវបានអនុញ្ញាតសម្រាប់អាករលើប្រជាជនជាឯកត្តជន ។

១) ឥណទានអាករសម្រាប់អាករលើជនបរទេស

អាករលើជនបរទេសប្រភេទនេះ ដែលអាចត្រូវបានចាត់ទុកថាស្មើនឹងអាករលើប្រាក់ចំណូល និងអាករលើប្រជាជនជាឯកត្តជនរបស់ប្រទេសជប៉ុន អាចចុះឥណទានក្នុងអាករលើប្រាក់ចំណូល និងអាករលើប្រជាជនជាឯកត្តជនរបស់ប្រទេសជប៉ុន ដើម្បីជៀសវាងការយកអាករទ្វេដង ។ ប្រសិនបើអាករលើជនបរទេសលើសពីទំហំទឹកប្រាក់អតិបរមាដែលអាចចុះឥណទានក្នុងអាករលើប្រាក់ចំណូល ក្រោមច្បាប់ស្តីពីអាករមូលដ្ឋាន ការលើសនេះអាចត្រូវបានចុះឥណទានក្នុងអាករលើប្រជាជនខេត្ត ក្នុងកម្រិតនៃទំហំទឹកប្រាក់អតិបរមា ដែលអាចចុះឥណទាន ក្នុងអាករលើប្រជាជនខេត្ត ស្មើនឹង ១២% នៃទំហំទឹកប្រាក់ជាអតិបរមាដែលអាចចុះឥណទានក្នុងអាករលើប្រាក់ចំណូល ។ ហើយប្រសិនបើអាករលើជនបរទេសលើសពីទំហំទឹកប្រាក់ជាអតិបរមាដែលអាចចុះឥណទាន ក្នុងអាករលើប្រាក់ចំណូល និងអាករលើប្រជាជនខេត្ត ការលើសនេះអាចត្រូវបានចុះឥណទានក្នុងអាករលើប្រជាជនក្រុង ក្នុងកម្រិតនៃទំហំទឹកប្រាក់ជាអតិបរមាដែលអាចចុះឥណទានក្នុងអាករលើប្រជាជនក្រុង ស្មើនឹង ២០% នៃទំហំទឹកប្រាក់ជាអតិបរមាដែលអាចចុះឥណទានក្នុងអាករលើប្រាក់ចំណូល ។

២) ឥណទានសម្រាប់ភាគលាភ

ប្រព័ន្ធឥណទាននេះត្រូវបានបង្កើតឡើង ដើម្បីកែតម្រូវការយកអាករទ្វេដង រវាងការយកអាករលើភាគលាភដែលបែងចែកក្នុងកម្រិតសាជីវកម្ម និងភាគលាភដែលទទួលបានក្នុងកម្រិតជាឯកត្តជន ។

នៅពេលអ្នកជាប់ពន្ធប្រកាសចំណូលទាំងអស់ រួមទាំងចំណូលបានមកពីភាគលាភ ច្បាប់ស្តីពីអាករមូលដ្ឋានអនុញ្ញាតអោយបង់ឥណទាន ១,២% នៃភាគលាភក្នុងអត្រាប្រាក់ចំណូលនៃអាករលើប្រជាជនខេត្ត និង ១,៦% នៃភាគលាភពីអត្រាប្រាក់ចំណូលនៃអាករលើប្រជាជនក្រុង ។

ប៉ុន្តែ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធ រួមទាំងភាគលាភ លើសពី ១០ លានយ៉េន ឥណទានអាករ ០,៦% សម្រាប់គោលបំណងនៃអាករលើប្រជាជនខេត្ត (០,៨% សម្រាប់គោលបំណងនៃអាករលើប្រជាជនក្រុង) ត្រូវអនុវត្តចំពោះចំណែកនៃប្រាក់ចំណូលជាភាគលាភនេះ គឺត្រូវជាទំហំទឹកប្រាក់ស្មើនឹងប្រាក់ចំណូលជាប់ពន្ធដក ១០ លានយ៉េន ហើយឥណទាន ១,២% សម្រាប់គោលបំណងនៃអាករលើប្រជាជនខេត្ត (១,៦% សម្រាប់គោល-បំណងនៃអាករលើប្រជាជនក្រុង) ត្រូវអនុវត្តចំពោះប្រាក់ចំណូលជាភាគលាភដែលនៅសល់ ។

(៦) ការប្រមូលពន្ធ

អាករលើប្រជាជនខេត្តត្រូវបានវាយតម្លៃ និងប្រមូលដោយក្រុង នៅចំពេលដែលអាករលើប្រជាជនក្រុងត្រូវបានវាយតម្លៃ និងប្រមូលដោយក្រុង ។ ឯកត្តជនទោះជាមានអាករកាត់យកពីប្រភព ឬតម្រូវអោយបង់ជាបួនដំណាក់ គឺនៅខែមិថុនា សីហា តុលា និងមករានៃឆ្នាំបន្ទាប់ក៏ដោយ ជាធម្មតា អ្នកទទួលបានប្រាក់កម្រៃបង់អាករក្រោមប្រព័ន្ធប្រមូលអាករពិសេស ។

ក្រុងប្រមូលអាករប្រគល់ទៅអោយខេត្តនូវទំហំទឹកប្រាក់ស្មើនឹងអាករលើប្រជាជនខេត្ត ក្រៅពីចំណូលពីអាករលើប្រជាជនជាឯកត្តជនសរុប របស់ខេត្ត និងក្រុង ។

(កំណត់សម្គាល់) ក្រោមប្រព័ន្ធប្រមូលអាករពិសេស និយោជកប្រមូលពន្ធដែលកាត់យកពីបុគ្គលិករបស់ខ្លួនពីប្រភព ។ និយោជកកាត់យកអាករពីប្រាក់ឈ្នួលប្រចាំខែរបស់បុគ្គលិក សម្រាប់រយៈពេល ១២ ខែ ពីខែមិថុនា ដល់ខែឧសភានៃឆ្នាំបន្ទាប់ ។ បន្ទាប់មក និយោជកបង់ប្រាក់នេះដល់ក្រុងប្រមូលអាករជារៀងរាល់ខែ ។

**គ. អត្រាការប្រាក់**

"អត្រាការប្រាក់" មានន័យថាជាផ្នែកនៃអាករលើប្រជាជនមូលដ្ឋាន ដែលត្រូវបានគណនាដោយផ្អែកលើទំហំនៃការប្រាក់ដែលបានបង់ និងកំណត់យកដាច់ដោយឡែកពីប្រាក់ចំណូលផ្សេងទៀត ។ ទោះបីជាអត្រាការប្រាក់នេះគឺជាផ្នែកមួយនៃអាករលើប្រជាជនខេត្តក៏ដោយ ក៏ ៣/៥ នៃទំហំអត្រាការប្រាក់ត្រូវបានប្រគល់ជូនក្រុងដោយខេត្តដែលកំណត់អត្រាការប្រាក់ផងដែរ ។

(១) អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធដែលជាអ្នកទទួលខុសត្រូវចំពោះអត្រាការប្រាក់ គឺជាឯកត្តជន ឬសាជីវកម្ម ដែលទទួលការប្រាក់ តាមរយៈការិយាល័យ ឬស្ថាប័នហិរញ្ញវត្ថុដែលមានទីតាំងនៅក្នុងខេត្ត ។

(២) ការប្រាក់មិនជាប់អាករ

ទម្រង់នៃការប្រាក់ដូចខាងក្រោមមិនជាប់អាករលើការប្រាក់ :

១) ការប្រាក់ដែលបានមកពីការសន្សំសម្រាប់ជនពិការ ។ល។

២) ការប្រាក់ដែលបានមកពីការសន្សំសម្រាប់ការបង្កើតទ្រព្យសកម្មរបស់និយោជិត សម្រាប់ទិញលំនៅដ្ឋាន ឬប្រាក់សោធន ។

៣) ការប្រាក់លើកលែងដោយច្បាប់ស្តីពីអាករលើប្រាក់ចំណូល ។

៤) ការប្រាក់ដែលទទួលបានដោយសាជីវកម្មអនិវាសនជន ឬសាជីវកម្មបរទេស ។

៥) ការប្រាក់ដែលទទួលបានដោយសាជីវកម្មសាធារណៈ ។ល។

៦) ការប្រាក់ដែលទទួលបានដោយក្រុមហ៊ុនជួញដូរសញ្ញាប័ណ្ណ ។

៧) ការប្រាក់ដែលទទួលបានដោយស្ថាប័នហិរញ្ញវត្ថុ ។

(៣) មូលដ្ឋានអាករ

មូលដ្ឋានអាករនៃអត្រាការប្រាក់ គឺជាទំហំទឹកប្រាក់នៃការប្រាក់ដែលបានបង់ ។

(៤) អត្រាអាករ

៥% (ជាអត្រាថេរ និងមិនប្រែប្រួល)

(៥) ការបង់ការប្រាក់

ស្ថាប័នហិរញ្ញវត្ថុដែលបង់ការប្រាក់ ទទួលខុសត្រូវក្នុងការប្រមូលចំនួនទឹកប្រាក់នៃអាករពីអ្នកជាប់ពន្ធ រួចប្រគល់អាករនេះទៅអោយអាជ្ញាធរខេត្ត នៅថ្ងៃទី១០ នៃខែបន្ទាប់ ។

(៦) ការកែតម្រូវអត្រាអាករលើសាជីវកម្ម

អត្រាការប្រាក់ដែលបង់ដោយសាជីវកម្ម ត្រូវបានចុះឥណទានក្នុងអត្រាអាករលើសាជីវកម្មនៃអាករលើប្រជាជនម្ចាស់សាជីវកម្ម ដើម្បីជៀសវាងការយកអាករទ្វេដង ។

**ឃ. អត្រាភាគលាភលើភាគហ៊ុន**

ភាគលាភលើភាគហ៊ុនចុះបញ្ជី ។ល។ នឹងត្រូវជាប់ពន្ធ ដោយកាត់យកដាច់ដោយឡែកពីចំណូលផ្សេងទៀត ។ ប្រាក់ចំណូលនៃភាគលាភលើភាគហ៊ុនចុះបញ្ជី ។ល។ មានភាពខុសគ្នាពីប្រាក់ចំណូលសាមញ្ញ ហើយមិនចាំបាច់ប្រកាសឡើយ ។ ប៉ុន្តែ នៅពេលអ្នកជាប់ពន្ធប្រកាសប្រាក់ចំណូលជាភាគលាភជាមួយប្រាក់ចំណូលផ្សេងទៀត ការិយាល័យរបស់អាជ្ញាធរមូលដ្ឋានត្រូវបូកសរុបប្រាក់ចំណូល ហើយលើកលែងទំហំទឹកប្រាក់នៃអត្រាភាគលាភលើភាគហ៊ុនចេញពីទំហំទឹកប្រាក់នៃអាករលើប្រជាជនជាឯកត្តជន ។ ៣/៥ នៃទំហំទឹកប្រាក់នៃអត្រាភាគលាភលើភាគហ៊ុន ត្រូវប្រគល់ជូនក្រុងដោយខេត្តដែលប្រមូលអាករ ។

(១) អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធប្រភេទនេះ គឺជាជាឯកត្តជនដែលទទួលបានភាគលាភ ហើយរស់នៅក្នុងខេត្ត នៅថ្ងៃដែលទទួលបានភាគលាភនោះ ។

(២) មូលដ្ឋានអាករ

មូលដ្ឋានអាករគឺជាទំហំទឹកប្រាក់នៃធាតុផ្សំខាងក្រោម :

១) ភាគលាភលើភាគហ៊ុនចុះបញ្ជី ។

២) ភាគលាភលើឥណទានពាណិជ្ជកម្មវិនិយោគនៃសញ្ញាប័ណ្ណសាធារណៈ (ការផ្គត់ផ្គង់ជាសាធារណៈប៉ុណ្ណោះ)

៣) ភាគលាភលើមូលនិធិវិនិយោគ ។

(៣) អត្រាអាករ

៥% (ជាអត្រាថេរ និងមិនប្រែប្រួល)

វិធានការអាករពិសេសដើម្បីជំរុញការផ្លាស់ប្តូរពីការតម្កល់ទុកទៅជាការវិនិយោគ (ភាគហ៊ុន) នឹងត្រូវធ្វើឡើង ។ អត្រាអាករនឹងត្រូវកាត់បន្ថយពី ៥% (ជាមួយនឹងអាករជាតិ ២០%) ទៅ ៣% (ជាមួយនឹងអាករជាតិ ១០%) រហូតដល់ខែមីនា ឆ្នាំ២០០៩ ។

(៤) ការបង់ការប្រាក់

ក្រុមហ៊ុនដែលបែងចែកភាគលាភត្រូវប្រមូលចំនួនទឹកប្រាក់នៃអាករពីអ្នកជាប់ពន្ធ ហើយប្រគល់ចំនួនទឹកប្រាក់នៃអាករនេះទៅអោយខេត្ត ជារៀងរាល់ខែ (ត្រឹមថ្ងៃទី១០ នៃខែបន្ទាប់) ។

**ង. អត្រាចំណេញជាមូលធន**

អត្រាចំណេញជាមូលធនលើភាគហ៊ុនចុះបញ្ជី ។ល។ នឹងត្រូវជាប់ពន្ធ ដោយកាត់យកដាច់ដោយឡែកពីចំណូលផ្សេងទៀត ។ ប្រាក់ចំណូលនៃចំណេញជាមូលធនលើភាគហ៊ុនចុះបញ្ជី ។ល។ មានភាពខុសគ្នាពីប្រាក់ចំណូលសាមញ្ញ ហើយមិនចាំបាច់ប្រកាសឡើយ ។ ប៉ុន្តែ នៅពេលអ្នកជាប់ពន្ធមានបំណងប្រកាសប្រាក់ចំណូលនៃចំណេញជាមូលធនជាមួយប្រាក់ចំណូលផ្សេងទៀត ការិយាល័យរបស់អាជ្ញាធរមូលដ្ឋានត្រូវបូកសរុបប្រាក់ចំណូល ហើយលើកលែងទំហំទឹកប្រាក់នៃអត្រាចំណេញ ជាមូលធនចេញពីទំហំទឹកប្រាក់នៃអាករលើប្រជាជនជាឯកត្តជន ។ ៣/៥ នៃទំហំទឹកប្រាក់នៃអត្រាចំណេញជាមូលធន ត្រូវប្រគល់ជូនក្រុង ដោយខេត្តដែលប្រមូលអាករ ។

(១) អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធប្រភេទនេះ គឺជាជាឯកត្តជនដែលទទួលបានប្រាក់ចំណេញពីការលក់ភាគហ៊ុន ហើយរស់នៅក្នុងខេត្ត នៅថ្ងៃទី០១ ខែមករា នៃឆ្នាំនោះ ។

(២) មូលដ្ឋានអាករ

មូលដ្ឋានអាករគឺជាទំហំទឹកប្រាក់នៃធាតុផ្សំខាងក្រោម :

១) ចំណេញជាមូលធនលើភាគហ៊ុនចុះបញ្ជី ។

២) ចំណេញជាមូលធនដោយគណនីឥណទាន

(៣) អត្រាអាករ

៥% (ជាអត្រាថេរ និងមិនប្រែប្រួល)

វិធានការអាករពិសេសដើម្បីជំរុញការផ្លាស់ប្តូរពីការតម្កល់ទុកទៅជាការវិនិយោគ (ភាគហ៊ុន) នឹងត្រូវធ្វើឡើង ។ អត្រាអាករនឹងត្រូវកាត់បន្ថយពី ៥% (ជាមួយនឹងអាករជាតិ ២០%) ទៅ ៣% (ជាមួយនឹងអាករជាតិ ១០%) រហូតដល់ខែធ្នូ ឆ្នាំ២០០៨ ។

(៤) ការបង់ប្រាក់

ក្រុមហ៊ុនមូលប័ត្រត្រូវប្រមូលទំហំទឹកប្រាក់នៃអាករពីអ្នកជាប់ពន្ធ ហើយប្រគល់ទំហំទឹកប្រាក់នៃអាករនេះទៅអោយខេត្ត ជារៀងរាល់ឆ្នាំ (នៅថ្ងៃទី១០ នៃឆ្នាំបន្ទាប់) ។ ប្រាកដណាស់ ការខាតបង់បណ្តាលមកពីការលក់ភាគហ៊ុនអាចត្រូវបានទូទាត់ជាមួយចំណេញជាមូលធនលើភាគហ៊ុនប្រសិនបើមាន ។

## ២. អាករលើសហគ្រាសមូលដ្ឋាន

### ក. អ្នកជាប់ពន្ធ

អាករលើសហគ្រាសមូលដ្ឋានត្រូវបានកំណត់លើ :

(១) សាជីវកម្មទាំងអស់ដែលធ្វើអាជីវកម្ម និងមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម នៅក្នុងខេត្ត (រួមទាំងសមាគម ឬមូលនិធិមិនមែនសាជីវកម្មដែលមានតំណាង ឬអ្នកចាត់ការចូលរួមធ្វើសកម្មភាពស្វែងរកប្រាក់ចំណេញ) ។

(២) ឯកត្តជនដែលធ្វើអាជីវកម្មដូចមានចែងនៅក្នុងច្បាប់ស្តីពីអាករមូលដ្ឋាន និងមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម នៅក្នុងខេត្ត ។

សាជីវកម្ម ឬឯកត្តជនដែលធ្វើអាជីវកម្មខាងព្រៃឈើ និងរ៉ែ រួចផុតពីការបង់អាករនេះ ។

អាករលើសហគ្រាសសាធារណៈមិនយកលើឯកត្តជនដែលប្រកបរបរកសិកម្ម ឬនេសាទ ជាពិសេស តាមរយៈកម្លាំងពលកម្មរបស់ខ្លួន ឬរបស់គ្រួសារខ្លួនផ្ទាល់ឡើយ ។

(កំណត់សម្គាល់)

១) "ការិយាល័យ ឬទីស្នាក់ការអាជីវកម្ម" មានន័យថាជាទីតាំងដែលមានធនធានមនុស្ស និងសម្ភារៈ សម្រាប់អាជីវកម្ម ដែលនៅទីនោះ សកម្មភាពអាជីវកម្មត្រូវបានធ្វើឡើងដោយមិនអាក់ខាន ប៉ុន្តែមិនចាំបាច់ត្រូវតែជាកម្មសិទ្ធរបស់សហគ្រាសនោះផ្ទាល់ឡើយ ។

២) ចំពោះសាជីវកម្មបរទេស និងឯកត្តជនអនិវេសនជន គ្រឹះស្ថានអចិន្ត្រៃយ៍ ដូចបានកំណត់ជាទូទៅនៅក្នុងអនុសញ្ញាស្តីពីអាករអន្តរជាតិ ត្រូវចាត់ទុកថាជាការិយាល័យ ឬទីស្នាក់ការអាជីវកម្ម សម្រាប់គោល-បំណងនៃអាករលើសហគ្រាស ។

៣) ក្នុងករណីឯកត្តជនធ្វើអាជីវកម្ម ដោយមិនមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម គេហដ្ឋាន ឬលំនៅ-ដ្ឋាន របស់ពួកគេដែលពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងអាជីវកម្ម ត្រូវចាត់ទុកថាជាការិយាល័យ ឬទីស្នាក់ការអាជីវកម្ម ។

៤) "អាជីវកម្ម" មានន័យថាជាសកម្មភាពសេដ្ឋកិច្ចដែលធ្វើឡើងដោយមិនអាក់ខាន និងដដែលៗ ក្នុងគោល-បំណងរកប្រាក់ចំណេញ ។

## ខ. មូលដ្ឋានអាករ និងអត្រាអាករ (សាជីវកម្ម)

(១) ក្រុមហ៊ុន (លើកលែងចំណុចទី (២) និងអង្គភាពពិសេស) ដែលមានដើមទុនលើសពី ១០០ លានយ៉េន

កំណែទម្រង់ពន្ធដារឆ្នាំ២០០៣ បានផ្លាស់ប្តូរផ្នែកនៃមូលដ្ឋានអាករនៃអាករលើសហគ្រាសសាធារណៈ: ចំពោះសាជីវកម្មដែលមានដើមទុនលើសពី ១០០ លានយ៉េន ពីមូលដ្ឋានប្រាក់ចំណូលទៅស្តង់ដារបណ្តោះអាសន្ន នៅពេលកាត់បន្ថយអត្រាអាករសម្រាប់មូលដ្ឋានប្រាក់ចំណូល (៩.៦%→៧.២%) ។

ការកំណត់អាករថ្មីនេះត្រូវបានបង្កើតឡើងដោយចំណូលអព្យាក្រឹត ។ ចំណូលអាករជាគោលដៅនៃស្តង់ដារបណ្តោះអាសន្នគឺ ៥១០ ពាន់លានយ៉េន (ចំណូលសរុបពីអាករលើសហគ្រាសមូលដ្ឋាន គឺ ៣.៤៥៣ ពាន់លានយ៉េនក្នុងឆ្នាំសារពើពន្ធ ២០០២) ។

មូលដ្ឋានអាករស្តង់ដារបណ្តោះអាសន្នមានពីរប្រភេទគឺ : ១) តម្លៃបន្ថែមប្រភេទបន្ថែម និង ២) ដើមទុន ។

១) ការកាត់ពន្ធលើតម្លៃបន្ថែមប្រភេទបន្ថែម

មូលដ្ឋានអាករនៃការកាត់ពន្ធលើតម្លៃបន្ថែមប្រភេទបន្ថែម គឺជាទំហំទឹកប្រាក់នៃបំណែងចែកប្រាក់ដែលរកបាន (បញ្ជីប្រាក់បៀវត្សរ៍ ការប្រាក់សុទ្ធដែលបង់ និងថ្លៃឈ្នួលសុទ្ធដែលបង់) និងប្រាក់ចំណេញតែក្នុងមួយឆ្នាំ ។ បញ្ជីប្រាក់បៀវត្សរ៍មានន័យថាជាប្រាក់ឈ្នួល ប្រាក់រង្វាន់ ប្រាក់កម្រៃ និងប្រាក់សោធននិវត្តន៍ ។

ការខាតបង់តែក្នុងមួយឆ្នាំអាចត្រូវបានកាត់យកពីទំហំទឹកប្រាក់នៃបំណែងចែកប្រាក់ដែលរកបាន ។

ទំហំទឹកប្រាក់នៃតម្លៃបន្ថែមប្រភេទបន្ថែម ត្រូវបានកម្រិតត្រឹមតម្លៃបន្ថែម ដែលមាននៅក្នុងប្រទេសជប៉ុនប៉ុណ្ណោះ ។

អត្រាអាករនៃការកាត់ពន្ធលើតម្លៃបន្ថែមប្រភេទបន្ថែម គឺ ០,៤៨% (អត្រាថេរ) ។

ក្រុមហ៊ុនមួយចំនួន ដែលមានផលធៀបនៃបញ្ជីប្រាក់បៀវត្សរ៍ខ្ពស់ខ្លាំង អាចអនុវត្តការកាត់យក ដើម្បីអោយការងារមានស្ថិរភាព ។ ទំហំទឹកប្រាក់នៃបញ្ជីប្រាក់បៀវត្សរ៍ដែលលើសពី ៧០% នៃទំហំទឹកប្រាក់សរុបនៃការបែងចែកប្រាក់ដែលរកបាន អាចត្រូវបានកាត់យកពីមូលដ្ឋានអាករ ។

២) ការកាត់ពន្ធលើមូលធន

មូលដ្ឋានអាករនៃការកាត់ពន្ធលើមូលធន គឺជាទំហំទឹកប្រាក់នៃមូលធនដែលបានបង់ ឬទំហំទឹកប្រាក់ដែលបានដាក់វិនិយោគ និងអតិរេកមូលធន ។ អត្រាអាករនៃការកាត់ពន្ធលើមូលធន គឺ ០,២% (អត្រាថេរ) ។

ដើម្បីជៀសវាងការប៉ះពាល់ជាអវិជ្ជមានដល់ការពង្រឹងមូលធន មានការគណនាការកាត់យក ២ ប្រភេទ ។ ទំហំទឹកប្រាក់នៃមូលធនរបស់ក្រុមហ៊ុនមេមួយចំនួនទៀត អាចត្រូវបានកាត់បន្ថយដោយចំណែកនៃទំហំទឹកប្រាក់នៃភាគហ៊ុនរបស់ក្រុមហ៊ុនសាខា (ការកាត់យកពីក្រុមហ៊ុនមេ) ។ ក៏ដូចជាក្នុងការគណនារកមូលដ្ឋានអាករផងដែរ មូលធនដែលលើសពី ១០០ ពាន់លានយ៉េន អាចត្រូវបានកាត់បន្ថយ ។ គ្មានផ្នែកណាមួយនៃមូលធនដែលលើសពី ១ សែនកោដិយ៉េន អាចត្រូវបានបញ្ចូលឡើយ (ការកាត់យកពីក្រុមហ៊ុនមានដើមទុនច្រើន) ។

៣) ការកាត់ពន្ធលើប្រាក់ចំណូល

មូលដ្ឋានអាករនៃការកាត់ពន្ធលើប្រាក់ចំណូល គឺស្មើរតែដូចគ្នាទៅនឹងអាករលើសាជីវកម្មជាតិ ។ អត្រាអាករនៃការកាត់ពន្ធលើប្រាក់ចំណូល គឺ ៧,២% ។

(២) ក្រុមហ៊ុនអគ្គិសនី ផ្គត់ផ្គង់ឧស្ម័ន និងធានារ៉ាប់រង

មូលដ្ឋានអាករសម្រាប់ក្រុមហ៊ុនអគ្គិសនី ផ្គត់ផ្គង់ឧស្ម័ន និងធានារ៉ាប់រង គឺជាចំណូលសរុប ។ អត្រាអាករ គឺ ១,៣% ។

(៣) ក្រុមហ៊ុន និងសាជីវកម្មផ្សេងទៀត

មូលដ្ឋានអាករសម្រាប់ក្រុមហ៊ុនទាំងនេះ គឺប្រាក់ចំណូល ឬប្រាក់ចំណូលជិរះបញ្ជី ។ មូលដ្ឋានអាករ គឺស្មើរតែដូចគ្នាទៅនឹងអាករលើសាជីវកម្មជាតិ ។ អត្រាអាករ គឺ ៩,៦% (៦,៦% សម្រាប់អង្គភាពពិសេស ដូចជា សមាគមសហករណ៍ជាដើម) ។

អត្រាអាករជាអតិបរមាចំពោះសាជីវកម្មទាំងនេះ គឺ ១២០% នៃអត្រាស្តង់ដារដែលបានរៀបរាប់ខាងលើ ។ នៅពេលខេត្តមួយមានសំណើហិរញ្ញវត្ថុពិសេស ខេត្តនោះត្រូវបានអនុវត្តអោយយកពន្ធសហគ្រាសមូលដ្ឋានលើសាជីវកម្ម ក្នុងអត្រាផ្សេងគ្នា មិនលើសពី ១២០% នៃអត្រាស្តង់ដារ ។

ប្រសិនបើក្រុមហ៊ុនមួយមានការិយាល័យ ឬរោងចក្រ នៅក្នុងខេត្តលើសពី ២ មូលដ្ឋានអាករត្រូវបែងចែកដោយរូបមន្តជាក់លាក់ ដូចជាចំនួនបុគ្គលិក និងគ្រឹះស្ថានអចិន្ត្រៃយ៍ ។ នៅក្នុងកំឡុងកំណែ

ទម្រង់ពន្ធដារឆ្នាំ២០០៥ រូបមន្តនេះត្រូវបានពិនិត្យមើលឡើងវិញ ដោយផ្អែកលើការផ្លាស់ប្តូរស្ថានភាពសង្គម-សេដ្ឋកិច្ច ។

**គ. មូលដ្ឋានអាករ និងអត្រាអាករ (ឯកត្តជន)**

ចំពោះអ្នកជាប់ពន្ធជាឯកត្តជន មូលដ្ឋានអាករ គឺជាប្រាក់ចំណូលដែលបានមកពីសកម្មភាពអាជីវកម្មរបស់ខ្លួន ។ អាករត្រូវយក ដោយផ្អែកលើប្រាក់ចំណូលសុទ្ធរបស់ខ្លួនដែលទទួលបាន នៅក្នុងកំឡុងឆ្នាំប្រតិទិនមុន ។ ការគណនាចំណូលជាប់ពន្ធត្រូវបានធ្វើឡើង តាមវិធីមួយដែលស្មើរតែដូចគ្នាទៅនឹងវិធីដែលគណនាចំពោះចំណូលអាជីវកម្ម និងចំណូលអចលនវត្ថុ ដូចមានចែងនៅក្នុងច្បាប់ស្តីពីអាករលើប្រាក់ចំណូល (អាករជាតិ) ។

មូលដ្ឋានអាករសម្រាប់អ្នកជាប់ពន្ធជាឯកត្តជនដែលមានការិយាល័យ ឬទីស្នាក់ការអាជីវកម្ម នៅក្នុងខេត្ត ២ ឬលើសពី ២ ត្រូវបែងចែកអោយខេត្តនីមួយៗ អាស្រ័យទៅតាមចំនួនបុគ្គលិកបម្រើការងារនៅក្នុងការិយាល័យ ឬទីស្នាក់ការអាជីវកម្មនីមួយៗ ។

ប្រាក់ចំណូលដែលបានមកពីអាជីវកម្មដែលធ្វើនៅក្នុងគ្រឹះស្ថានអចិន្ត្រៃយ៍មួយ នៅបរទេស ត្រូវរួចផុតពីចំណូលជាប់ពន្ធ ។

អត្រាអាករប្រែប្រួល អាស្រ័យទៅតាមប្រភេទអាជីវកម្មដែលកំពុងប្រតិបត្តិដោយអ្នកជាប់ពន្ធ ។

អត្រាស្តង់ដារដែលត្រូវអនុវត្តសម្រាប់ឯកត្តជន គឺ ៥% ៤% ឬ ៣% អាស្រ័យទៅតាមប្រភេទអាជីវកម្មដែលខ្លួនធ្វើ ។

អត្រាអាករជាអតិបរមា គឺ ១១០% នៃអត្រាស្តង់ដារ ។

**ឃ. ការបង់ប្រាក់**

(១) សាជីវកម្ម

ក្រោមប្រព័ន្ធអាករស្វ័យវាយតម្លៃ អ្នកជាប់ពន្ធជាម្ចាស់សាជីវកម្មត្រូវគណនាទំហំទឹកប្រាក់អាករដោយខ្លួនឯង ដាក់លិខិតប្រកាសពន្ធ និងបង់អាកររបស់ខ្លួនដល់ខេត្តដែលពាក់ព័ន្ធ ។

(២) ឯកត្តជន

អ្នកជាប់ពន្ធជាឯកត្តជនត្រូវដាក់លិខិតប្រកាសពន្ធជូនទៅខេត្ត ដែលការិយាល័យ ឬទីស្នាក់ការអាជីវកម្មរបស់ខ្លួនស្ថិតនៅ ។

ប៉ុន្តែ អ្នកដែលបានដាក់លិខិតប្រកាសពន្ធអាករលើប្រាក់ចំណូលចុងក្រោយ ឬអាករលើប្រជាជនខេត្ត ត្រូវចាត់ទុកថាបានដាក់លិខិតប្រកាសពន្ធស្ថាពរនៃអាកររបស់ខ្លួន នៅថ្ងៃដែលបានដាក់ ។

អាករត្រូវវាយតម្លៃដោយខេត្ត ហើយបង់ជាពីរដំណាក់កាល ជាធម្មតា ក្នុងខែសីហា និងខែវិច្ឆិកា ។

**ង. ការលើកពេលប្រមូលអាករ**

អភិបាលខេត្ត/ក្រុងអាចលើកពេលប្រមូលអាករលើសហគ្រាស ពីសាជីវកម្មដូចខាងក្រោម (សម្រាប់តែសាជីវកម្មដែលខាតប៉ុណ្ណោះ) រហូតដល់ ៦ ឆ្នាំ (ជាទូទៅ ការលើកពេលប្រមូលអាករ គឺរហូតដល់ ២ ឆ្នាំ ក្នុងករណីមានគ្រោះមហន្តរាយ) ។

១) ក្រុមហ៊ុនអាជីវកម្មដែលមានបច្ចេកវិទ្យាជឿនលឿន ។

២) ក្រុមហ៊ុនដែលចូលរួមចំណែកដល់វឌ្ឍនភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ ។

# កំណែទម្រង់អាករលើសហគ្រាសមូលដ្ឋានឆ្នាំ២០០៣ នៅប្រទេសជប៉ុន

## សេចក្តីសង្ខេបអំពីកំណែទម្រង់ពន្ធដារឆ្នាំ២០០៣

កំណែទម្រង់ពន្ធដារឆ្នាំ២០០៣ បានផ្លាស់ប្តូរផ្នែកនៃមូលដ្ឋានអាករនៃអាករលើសហគ្រាសមូលដ្ឋាន ចំពោះសាជីវកម្មដែលមានដើមទុនលើសពី ១០០ លានយ៉េន ពីមូលដ្ឋានប្រាក់ចំណូលទៅស្តង់ដារបណ្តោះអាសន្ន ដោយកាត់បន្ថយអត្រាអាករសម្រាប់មូលដ្ឋានប្រាក់ចំណូល ។

**<មុនខែមីនា ឆ្នាំ២០០៤>** **<ក្រោយខែមេសា ឆ្នាំ២០០៤>** ប្រព័ន្ធកំណត់អាករថ្មី

មូលដ្ឋានប្រាក់ចំណូល : អត្រាអាករ ៩.៦% → អត្រាអាករ ៧.២%

→ **ស្តង់ដារបណ្តោះអាសន្ន**

## សារវិតានៃកំណែទម្រង់ពន្ធដារឆ្នាំ២០០៣

១) ការធ្លាក់ចុះយ៉ាងខ្លាំងនូវចំណូលពីអាករលើសហគ្រាសមូលដ្ឋាន

២) ធ្វើអោយមានស្ថិរភាពនូវអាករជាមូលដ្ឋានដែលទ្រទ្រង់ដល់វិមជ្ឈការ

* ចំណូលពីអាករលើសហគ្រាសមូលដ្ឋាន

  ៦.៤ សែនកោដិយ៉េន (ឆ្នាំ១៩៩១) → ៣.៥ សែនកោដិយ៉េន (ឆ្នាំ២០០៣)

* ការបែងចែកអាករលើសហគ្រាសមូលដ្ឋានទៅក្នុងចំនួនទឹកប្រាក់នៃចំណូលខេត្ត

  ១៤.១% នៃ ៤៥ សែនកោដិយ៉េន (ឆ្នាំ១៩៩១)→៦.៧% នៃ ៥១ សែនកោដិយ៉េន (ឆ្នាំ២០០៣)

៣) ការសម្រេចបាននូវបន្ទុកអាករ អាស្រ័យទៅតាមប្រាក់ចំណេញ

៤) ការសម្រេចបាននូវបន្ទុកអាករស្មួចស្មើង ទូលំទូលាយ ត្រឹមត្រូវ សម្រាប់សាជីវកម្ម

៥) ការសម្រេចបាននូវការកំណត់អាករទូទាត់ ប្រសិនបើវាព្យាយាមខ្លាំង

* ផលធៀបនៃសាជីវកម្មមានឱនភាព (= គ្មានបន្ទុកអាករនៃអាករលើសហគ្រាសមូលដ្ឋាន)

  ៦៨.១% (១.៦៨០.៤៦៦ ក្នុងចំណោម ២.៤៦៨.៩៣៩) (ឆ្នាំ២០០៣)

* មានតែ ១.២% នៃ ២.៤៧ លានប៉ុណ្ណោះ ដែលសាជីវកម្មបង់ មាន ៨០.៧% នៃអាករលើសហគ្រាសមូលដ្ឋាន

**កំណត់សម្គាល់ : ការកំណត់អាករសម្រាប់សាជីវកម្ម (អត្រាអាករសម្រាប់ចំណូលរបស់សាជីវកម្ម)**

| | |
|---|---|
| ១) អាករលើសាជីវកម្មជាតិ | ៣០% |
| ២) អាករលើសហគ្រាសមូលដ្ឋាន | ៩.៦%→៧.២% (ក្រោយខែមេសា ឆ្នាំ២០០៤) |
| ៣) អាករលើប្រជាជនខេត្ត | ១.៥% |
| | (៥.០% នៃទំហំទឹកប្រាក់របស់អាករលើសាជីវកម្មជាតិ) |
| ៤) អាករលើប្រជាជនក្រុង | ៣.៦៩% |
| | (១២.៣% នៃទំហំទឹកប្រាក់របស់អាករលើសាជីវកម្មជាតិ) |

* ទំហំទឹកប្រាក់នៃអាករលើសហគ្រាសសាធារណៈលើសាជីវកម្ម រួមបញ្ចូលក្នុងការខាតបង់ នៅពេលគណនាចំណូលរបស់សាជីវកម្ម (ដូចគ្នានឹងអាករលើចលនទ្រព្យដែរ) ។

## ការកំណត់អាករស្តង់ដារបណ្តោះអាសន្នលើអាករសហគ្រាសមូលដ្ឋាន

**អ្នកជាប់ពន្ធ និងមូលដ្ឋានអាករនៃអាករលើសហគ្រាសមូលដ្ឋាន**

- សាជីវកម្មត្រូវស្ថិតនៅក្រោមអាករលើសហគ្រាសមូលដ្ឋាន នៅក្នុងខេត្តចំនួន ៤៧ ។ ចំពោះសាជីវកម្មជាច្រើន មូលដ្ឋានអាករនៃអាករលើសហគ្រាសមូលដ្ឋានគឺជាប្រាក់ចំណូលរបស់សាជីវកម្ម (ដូចគ្នាទៅនឹងអាករលើសាជីវកម្មជាតិដែរ) ។
- ក្រោយខែមេសា ឆ្នាំ២០០៤ សាជីវកម្មដែលមានដើមទុនច្រើនជាង ១០០ លានយ៉េនត្រូវបង់អាករដូចខាងក្រោម :
  - ➢ មួយត្រីមាស : តាមទំហំអាជីវកម្ម (ស្តង់ដារបណ្តោះអាសន្ន)
  - ➢ បីត្រីមាស : តាមទំហំប្រាក់ចំណូល
- ៣៣ ពាន់ ក្នុងចំណោម សាជីវកម្ម ២,៤៦ លាន ស្ថិតនៅក្រោមការកំណត់អាករនេះ ។
- ការកំណត់អាករថ្មីនេះត្រូវបានបង្កើតឡើងដោយចំណូលអព្យាក្រឹត ។ ចំណូលអាករជាគោលដៅនៃស្តង់ដារបណ្តោះអាសន្ន គឺ ៥១០ ពាន់លានយ៉េន (ចំណូលសរុបពីអាករលើសហគ្រាសមូលដ្ឋាន គឺ ៣.៤៥៣ ពាន់លានយ៉េនក្នុងឆ្នាំ សារពើពន្ធ២០០២) ។

| **មុនខែមីនា ឆ្នាំ២០០៤** | | **ក្រោយខែមេសា ឆ្នាំ២០០៤** | | |
|---|---|---|---|---|
| **ការកាត់ពន្ធលើប្រាក់ចំណូល** (អត្រាអាករ : ៩.៦%) | → | **ការកាត់ពន្ធលើប្រាក់ចំណូល** (អត្រាអាករ : ៧,២%) | **ការកាត់ពន្ធលើតម្លៃបន្ថែម** (០.៤៨%) | ២ |
| | | | **ការកាត់ពន្ធលើមូលធន** (០.២%) | ១ |

ប្រាក់ចំណូល : បណ្តោះអាសន្ន

៣ : ១

**អត្រាអាករពិតប្រាកដសម្រាប់ប្រាក់ចំណូលសហប្រតិបត្តិការ**

(គិតបញ្ចូលទាំងអាករជាតិ និងអាករមូលដ្ឋាន)

| | | |
|---|---|---|
| **៤០.៨៧%*** | → | **៣៩.៥៤%**** |

*(៣០+១.៥+៣.៦៩+៩.៦)/(១០០+៩.៦)=០.៤០៨៧

**(៣០+១.៥+៣.៦៩+៧.២)/(១០០+៧.២)=C

# ការគណនាមូលដ្ឋានអាករសម្រាប់ការកំណត់អាករស្តង់ដារបណ្តោះអាសន្ន

## ការកាត់ពន្ធលើតម្លៃបន្ថែមប្រភេទបន្ថែម ( អត្រាអាករ : 0.៤៨%)

មូលដ្ឋានអាករសម្រាប់ការកាត់ពន្ធលើតម្លៃបន្ថែម = ការបែងចែកប្រាក់ដែលរកបាន (បញ្ជីប្រាក់បៀវត្សរ៍ + ការប្រាក់សុទ្ធដែលបង់ + ថ្លៃឈ្នួលសុទ្ធដែលបង់) ± ចំណេញ និងខាត

- បញ្ជីប្រាក់បៀវត្សរ៍ → ប្រាក់កម្រៃ ប្រាក់រង្វាន់ សោហ៊ុយ ប្រាក់សោធននិវត្តន៍
- ការប្រាក់សុទ្ធដែលបង់ → ការប្រាក់ដែលបង់ ដក ការប្រាក់ដែលទទួល
- ថ្លៃឈ្នួលសុទ្ធដែលបង់ → ថ្លៃឈ្នួលបង់ ដក ថ្លៃឈ្នួលដែលទទួល
- ចំណេញ និងខាត → ចំណេញនិង ខាតក្នុងមួយឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ

ការខាតក្នុងមួយឆ្នាំអាចកាត់យកពីទំហំទឹកប្រាក់នៃបំណែងចែកប្រាក់ដែលរកបាន

**ការកាត់ពន្ធសម្រាប់ស្ថិរកម្មការងារ**

ទំហំទឹកប្រាក់នៃបញ្ជីប្រាក់បៀវត្សរ៍លើសពី ៧០% នៃទំហំទឹកប្រាក់សរុបនៃបំណែងចែកប្រាក់ដែលរកបាន អាចកាត់យកពីអាករមូលដ្ឋាន

១២០ - (១៣០ × ០.៧) = *២៩

បំណែងចែកប្រាក់ដែលរកបាន = ១៣០




បញ្ជីប្រាក់បៀវត្សរ៍ ១២០

**មូលដ្ឋានអាករសម្រាប់ការកាត់ពន្ធលើតម្លៃបន្ថែម = ១១១** = បំណែងចែក (១៣០) - ការកាត់ពន្ធ (*២៩) + ចំណេញ (១០)

## ការកាត់ពន្ធលើដើមទុន ( អត្រាអាករ : 0.២%)

មូលដ្ឋានអាករសម្រាប់ការកាត់ពន្ធលើដើមទុន = ដើមទុនដែលបានដាក់ បូទឹកប្រាក់វិនិយោគ + អតិរេកដើមទុន

***១ ការកាត់ពន្ធចំពោះក្រុមហ៊ុនមេ**

ទំហំទឹកប្រាក់ដើមទុននៃក្រុមហ៊ុនមេអាចត្រូវបានកាត់បន្ថយ ដោយចំណែកនៃទឹកប្រាក់ភាគហ៊ុនរបស់ក្រុមហ៊ុនសាខាទៅនឹងទំហំទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិសរុបរបស់ក្រុមហ៊ុនមេ ។




***២ ការកាត់ពន្ធចំពោះក្រុមហ៊ុនមានដើមទុនច្រើន**

ក្នុងការគណនាមូលដ្ឋានអាករ ដើមទុនលើសពី ១០០ ពាន់លាន យ៉េនអាចត្រូវបានកាត់បន្ថយ ។

គ្មានចំណែកណាមួយនៃដើមទុន លើសពី ១.០០០ ពាន់លាន យ៉េនអាចត្រូវបានបញ្ចូលឡើយ ។



(សេចក្តីបន្ថែម)

## ចំណុចសំខាន់នៃការកាត់បន្ថយអាករអចិន្ត្រៃយ៍ដែលស្នើឡើងសម្រាប់ឆ្នាំសារពើពន្ធ១៩៩៩

កំណែទម្រង់ពន្ធដារសម្រាប់ឆ្នាំសារពើពន្ធ១៩៩៩ ខាងក្រោម ត្រូវបានស្នើឡើងនៅក្នុងឆ្នាំ១៩៩៨ ជាផ្នែកនៃវិធានការសេដ្ឋកិច្ចបន្ទាន់ដែលមានគោលដៅលើកស្ទួយសេដ្ឋកិច្ចរបស់ប្រទេសជប៉ុន ។

### ១. ការកំណត់អាករលើប្រាក់ចំណូលផ្ទាល់ខ្លួន

អត្រាអាករកម្រិតខ្ពស់បំផុតនឹងត្រូវកាត់បន្ថយ ដើម្បីលើកស្ទួយការជំរុញការងារ និងសហគ្រិនភាព ហើយការកាត់បន្ថយអាករសមាមាត្រនឹងត្រូវអនុវត្ត ដើម្បីបញ្ចុះបន្ទុកអាកររបស់អ្នកជាប់ពន្ធ ជាពិសេសបន្ទុកអាកររបស់អ្នកដែលមានចំណូលមធ្យម ។

- ការកាត់បន្ថយអត្រាអាករកម្រិតខ្ពស់បំផុត
  - អាករលើប្រាក់ចំណូលផ្ទាល់ខ្លួន (អាករជាតិ) : ៥០%→៣៧%
  - អាករលើប្រជាជន (អាករមូលដ្ឋាន) : ១៥%→១៣%
- ការកាត់បន្ថយអាករសមាមាត្រ
  - អត្រាកាត់យកអាករលើប្រាក់ចំណូលផ្ទាល់ខ្លួន : ២០% (ខ្ពស់បំផុត ២៥០.០០០ យ៉េន)
  - អត្រាកាត់យកអាករលើប្រជាជន : ១៥% (ខ្ពស់បំផុត ៤០.០០០ យ៉េន)
- ការកាត់បន្ថយអាករទាំងនេះត្រូវបានអនុវត្តសម្រាប់អាករលើប្រាក់ចំណូលផ្ទាល់ខ្លួន និងអាករលើប្រជាជនចាប់តាំងពីឆ្នាំសារពើពន្ធ១៩៩៩ មកម្ល៉េះ ។
- ការកាត់បន្ថយអាករលើប្រាក់ចំណូលផ្ទាល់ខ្លួនត្រូវបានអនុវត្តសម្រាប់អាករកាត់ទុកលើប្រាក់កម្រៃ និងប្រាក់បៀវត្សរ៍ ដោយចាប់ផ្តើមពីខែមេសា ឆ្នាំ១៩៩៩ ។
- នៅក្នុងកំណែទម្រង់ពន្ធដារឆ្នាំ២០០៥ គេគ្រោងនឹងកាត់បន្ថយនៅត្រឹមពាក់កណ្តាលនៅក្នុងឆ្នាំ២០០៦ ហើយនៅក្នុងកំណែទម្រង់ពន្ធដារឆ្នាំ២០០៦ គេគ្រោងនឹងលុបបំបាត់ ។

### ២. ការកំណត់អាករលើប្រាក់ចំណូលរបស់សាជីវកម្ម

- ការកាត់បន្ថយអត្រាអាករស្តង់ដារ

| | ឆ្នាំសារពើពន្ធ ១៩៩៧ | | ឆ្នាំសារពើពន្ធ ១៩៩៨ | | ឆ្នាំសារពើពន្ធ ១៩៩៩~ |
|---|---|---|---|---|---|
| - អាករលើសាជីវកម្ម (អាករជាតិ) : | ៣៧.៥% | → | ៣៤.៥% | → | ៣០.០% |
| - អាករលើសហគ្រាស (អាករមូលដ្ឋាន) : | ១២.០% | → | ១១.០% | → | ៩.៦% |
| → អត្រាអាករពិតប្រាកដរួម : | ៤៩.៩៨% | → | ៤៦.៣៦% | → | ៤០.៨៧% |

• ការកាត់បន្ថយអត្រាអាករពិសេសចំពោះអាជីវកម្មខ្នាតតូច

| | ឆ្នាំសារពើពន្ធ ១៩៩៧ | | ឆ្នាំសារពើពន្ធ ១៩៩៨ | | ឆ្នាំសារពើពន្ធ ១៩៩៩~ |
|---|---|---|---|---|---|
| - អាករលើសាជីវកម្ម : | ២៨% | → | ២៥% | → | ២២% |
| - អាករលើសហគ្រាស : | ៦.០% | → | ៥.៦% | → | ៥.០% |

• ការកាត់បន្ថយអាករទាំងនេះត្រូវបានអនុវត្តសម្រាប់ការិយបរិច្ឆេទគណនេយ្យចាប់តាំងពីឆ្នាំសារពើពន្ធ១៩៩៩ មកម្ល៉េះ ។

## ៣. អាករលើការប្រើប្រាស់មូលដ្ឋាន

អាករលើការប្រើប្រាស់មូលដ្ឋានត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំសារពើពន្ធ១៩៩៧ ។ អាករលើការប្រើប្រាស់មូលដ្ឋាន គឺជាអាករលើការប្រើប្រាស់ជាទូទៅក្នុងខេត្ត ដែលត្រូវវាយតម្លៃលើប្រតិបត្តិរបស់សហគ្រាសអាជីវកម្ម នៅដំណាក់កាលផលិតនីមួយៗ ទាំងលក់ដុំ និងលក់រាយ ដូចទៅនឹងអាករលើការប្រើប្រាស់ជាតិដែរ ។

អាករលើការប្រើប្រាស់មូលដ្ឋានត្រូវបានប្រមូលយកពីសហគ្រាសអាជីវកម្មដែលផ្តល់ទំនិញ និងសេវាកម្ម។ ទំហំទឹកប្រាក់នៃអាករត្រូវបានបន្ថែមទៅលើតម្លៃទំនិញ និងសេវាកម្ម ដែលផ្តល់ដោយសហគ្រាសទាំងនោះ។ បន្ទុកចុងក្រោយនៃអាករនេះត្រូវបានរៀបចំឡើងដើម្បីអោយអ្នកប្រើប្រាស់ចុងក្រោយនៃទំនិញ និងសេវាកម្ម ជាអ្នកបង់ ។

### ក. អ្នកជាប់ពន្ធ

អាករលើការប្រើប្រាស់មូលដ្ឋានត្រូវបានប្រមូលយកពីប្រតិបត្តិការក្នុងស្រុក និងការនាំចូល ។

អ្នកជាប់អាករលើការប្រើប្រាស់មូលដ្ឋានពាក់ព័ន្ធនឹងប្រតិបត្តិការក្នុងស្រុកមានសហគ្រាសអាជីវកម្ម រួមទាំងម្ចាស់ជាឯកត្តជនដែលផ្គត់ផ្គង់ទំនិញ និងសេវាកម្មជាប់ពន្ធ ។ អាជីវកម្មខ្នាតតូចទាំងនោះ ដែលរួចផុតពីការបង់អាករលើការប្រើប្រាស់ជាតិ ក៏រួចផុតពីការបង់អាករលើការប្រើប្រាស់មូលដ្ឋានផងដែរ ។ អាករលើការប្រើប្រាស់មូលដ្ឋានមិនមានកំណត់លើប្រតិបត្តិការទំនិញ និងសេវាកម្ម ដែលមិនជាប់ពន្ធដើម្បីគោលបំណងនៃអាករលើការប្រើប្រាស់ជាតិ ឡើយ ។

អ្នកជាប់អាករលើការប្រើប្រាស់មូលដ្ឋានលើការនាំចូល គឺជាអ្នកដែលទទួលការប្រគល់ទំនិញបរទេសពីតំបន់ពន្ធគយ ។

### ខ. យុត្តាធិការប្រមូលអាករ

អ្នកជាប់ពន្ធជាឯកត្តជន ដែលមិនមែនជាសហគ្រាសអាជីវកម្ម បង់អាករលើការប្រើប្រាស់មូលដ្ឋានចំពោះប្រតិបត្តិការក្នុងស្រុក ជូនដល់ខេត្តដែលខ្លួនស្នាក់នៅ ។

អ្នកជាប់ពន្ធជាម្ចាស់សាជីវកម្មបង់អាករលើការប្រើប្រាស់មូលដ្ឋានចំពោះប្រតិបត្តិការក្នុងស្រុក ជូនដល់ខេត្តដែលទីស្នាក់ការរបស់ខ្លួនស្ថិតនៅ ។

អ្នកជាប់អាករលើការប្រើប្រាស់មូលដ្ឋានចំពោះការនាំចូល បង់អាករជូនដល់ខេត្ត ដែលតំបន់ពន្ធគយពាក់ព័ន្ធស្ថិតនៅ ជាកន្លែងដែលទំនិញនាំចូលមកដល់ ។

ដោយពិចារណាលើភាពងាយស្រួលក្នុងការគោរពតាមនិតិវិធីពន្ធដារដោយអ្នកជាប់ពន្ធ យុត្តាធិការកំណត់អាករនៃអាករលើការប្រើប្រាស់មូលដ្ឋាន ត្រូវត្រួតស៊ីគ្នាជាមួយខេត្ត ដែលអាករលើការប្រើប្រាស់ជាតិត្រូវបង់ ។

### គ. មូលដ្ឋានអាករ

មូលដ្ឋានអាករនៃអាករលើការប្រើប្រាស់មូលដ្ឋានចំពោះប្រតិបត្តិការក្នុងស្រុក គឺជាអាករលើការប្រើប្រាស់ជាតិចំពោះប្រតិបត្តិការលទ្ធផល ដកវិភាគទាននៃឥណទានអាករលើការប្រើប្រាស់ជាតិ ដែលហៅថាបន្ទុកអាករលើការប្រើប្រាស់ជាតិ ។ មូលហេតុដែលអាករលើការប្រើប្រាស់មូលដ្ឋានមិនប្រើប្រាស់ទំហំទឹកប្រាក់នៃការទូទាត់ សម្រាប់ទំនិញ និង

សេវាកម្មជាប់ពន្ធ ប៉ុន្តែប្រើប្រាស់បន្ទុកអាករលើការប្រើប្រាស់ជាតិ ជាមូលដ្ឋានអាករ គឺ ដើម្បីសម្រាលបន្ទុកក្នុងការអនុវត្ត របស់អ្នកជាប់ពន្ធ ។ ដែនកំណត់នៃប្រតិបត្តិការជាប់ពន្ធ និងការលើកលែងអាករលើការប្រើប្រាស់មូលដ្ឋាន មានលក្ខណៈ ដូចគ្នាទៅនឹងអាករលើការប្រើប្រាស់ជាតិ ។ អ្នកជាប់ពន្ធអាចគណនាបន្ទុកអាករលើការប្រើប្រាស់មូលដ្ឋាន និងដាក់លិខិត ប្រកាសពន្ធ រួមគ្នាជាមួយអាករលើការប្រើប្រាស់ជាតិ ។

មូលដ្ឋានអាករនៃអាករលើការប្រើប្រាស់មូលដ្ឋានចំពោះការនាំចូល គឺជាអាករលើការប្រើប្រាស់ជាតិចំពោះការ នាំចូល ។ មិនមានឥណទានអាករជាវិភាគទានត្រូវបានអនុញ្ញាតឡើយ ក្នុងករណីអាករលើការប្រើប្រាស់ជាតិចំពោះការ នាំចូល ។

## ឃ. អត្រាអាករ

អត្រាអាករនៃអាករលើការប្រើប្រាស់មូលដ្ឋាន គឺ ២៥% ។ នេះគឺជាអត្រាថេរ ដែលខេត្តទាំងអស់ត្រូវតែអនុវត្ត តាម ។

ចាប់តាំងពីពេលដែលមូលដ្ឋានអាករនៃអាករលើការប្រើប្រាស់មូលដ្ឋាន ជាអាករលើការប្រើប្រាស់ជាតិ ដែល មានអត្រាអាករ ៤% អត្រាអាករនៃអាករលើការប្រើប្រាស់មូលដ្ឋានស្មើនឹង ១% នៃអាករលើការប្រើប្រាស់ ក្នុងការ ទូទាត់ទំនិញ និងសេវាកម្មជាប់ពន្ធ ។ អាស្រ័យហេតុនេះ បន្ទុកសរុបនៃអាករលើការប្រើប្រាស់ជាតិ និងអាករលើការប្រើ-ប្រាស់ក្នុងមូលដ្ឋានចំពោះទំនិញ និងសេវាកម្ម គឺ ៥% ។

## ង. ការប្រមូលអាករ

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធរបស់ខ្លួន និងបង់អាករ ក្នុងរយៈពេលពីរ ខែចាប់ពីថ្ងៃចុងក្រោយនៃ ការិយបរិច្ឆេទពន្ធដារ ។ ការិយបរិច្ឆេទពន្ធដារ គឺជាឆ្នាំប្រតិទិន ចំពោះម្ចាស់ជាឯកត្តជន ចំណែកឯចំពោះសាជីវកម្មវិញ គឺ ជាការិយបរិច្ឆេទគណនេយ្យ ។

អ្នកជាប់ពន្ធត្រូវធ្វើរបាយការណ៍អំពីបន្ទុកអាករលើការប្រើប្រាស់ជាតិចុងក្រោយ និងបង់អាករចំនួន ២៥% នៃ ទំហំទឹកប្រាក់ដែលប្រកាស ។

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសពន្ធជូនខេត្តដែលកំណត់អាករ ។ ប៉ុន្តែ ដោយពិចារណាទៅលើបន្ទុករបស់អ្នក ជាប់ពន្ធសម្រាប់ការប្រមូលអាករ និងការប្រកាសពន្ធ ការគ្រប់គ្រងអាករលើការប្រើប្រាស់មូលដ្ឋានត្រូវអនុវត្តដោយ ការិយាល័យពន្ធដារ (ការិយាល័យសាខានៃទីភ្នាក់ងារពន្ធដារជាតិ) រួមជាមួយនឹងការគ្រប់គ្រងអាករលើការប្រើប្រាស់ ជាតិ ។ រហូតដល់ប្រព័ន្ធប្រមូលអាកររបស់រដ្ឋាភិបាលខេត្តត្រូវបានបង្កើតឡើង ការិយាល័យពន្ធដារប្រគល់ចំនួនទឹកប្រាក់ នៃអាករលើការប្រើប្រាស់មូលដ្ឋាន ដល់ខេត្តដែលពាក់ព័ន្ធ ។

ថ្លៃចំណាយដោយការិយាល័យពន្ធដារក្នុងការប្រមូល និងប្រគល់អាករលើការប្រើប្រាស់មូលដ្ឋាន ត្រូវទូទាត់ ដោយខេត្តដែលពាក់ព័ន្ធ ។

ការគ្រប់គ្រងអាករលើការប្រើប្រាស់មូលដ្ឋានចំពោះការនាំចូលត្រូវធ្វើដោយទីចាត់ការគយ ។ អាករលើការ ប្រើប្រាស់មូលដ្ឋានដែលបង់ជូនទីចាត់ការគយ ត្រូវប្រគល់ទៅអោយខេត្ត ដែលតំបន់ពន្ធគយពាក់ព័ន្ធស្ថិតនៅ ។

ថ្លៃចំណាយដោយទីចាត់ការគយក្នុងការប្រមូល និងប្រគល់អាករលើការប្រើប្រាស់មូលដ្ឋានត្រូវទូទាត់ដោយខេត្តដែលពាក់ព័ន្ធ ។

## ច. ប្រព័ន្ធទូទាត់ក្នុងខេត្ត

ដោយហេតុថាអាករលើការប្រើប្រាស់មូលដ្ឋាន គឺជាអាករលើការប្រើប្រាស់ ចំណូលពីអាករនៃអាករលើការប្រើប្រាស់មូលដ្ឋានត្រូវបែងចែកដល់ខេត្ត ដែលការប្រើប្រាស់ចុងក្រោយកើតឡើង ។

អាករលើការប្រើប្រាស់មូលដ្ឋានត្រូវប្រមូលជាដំបូងដោយខេត្ត ដែលអាករលើការប្រើប្រាស់ជាតិត្រូវបង់ជូន ។ ប៉ុន្តែចំណូលពីអាករត្រូវបានបែងចែកដល់ខេត្ត ដោយផ្អែកលើទិន្នន័យពាក់ព័ន្ធនឹងការប្រើប្រាស់ចុងក្រោយ ហើយតុល្យការត្រូវបានទូទាត់ក្នុងខេត្ត ។

ប្រព័ន្ធទូទាត់មានដូចខាងក្រោម :

(១) ខេត្តនីមួយៗបែងចែកចំណូលពីអាករលើការប្រើប្រាស់មូលដ្ឋាន ដោយផ្អែកលើទិន្នន័យពាក់ព័ន្ធនឹងការប្រើ-ប្រាស់ចុងក្រោយដែលកើតឡើងក្នុងខេត្តនីមួយៗ ។

(២) ខេត្តនីមួយៗបង់អោយខេត្ត ៤៦ ផ្សេងទៀត នូវចំនួនទឹកប្រាក់នៃអាករលើការប្រើប្រាស់មូលដ្ឋាន ដែលត្រូវបែងចែកអោយខេត្តទាំង ៤៦ នោះ ។ ក្នុងពេលជាមួយគ្នានេះផងដែរ ខេត្តនីមួយៗទទួលចំនួនទឹកប្រាក់ដែលបែងចែកអោយខ្លួនឯង ពីខេត្ត ៤៦ ផ្សេងទៀតនោះ ។

(៣) ចំនួនទឹកប្រាក់ដែលបង់អោយ និងទទួលដោយខេត្តនីមួយៗ ទូទាត់គ្នាទៅវិញទៅមក ហើយតុល្យការត្រូវបានទូទាត់ ។

## ឆ. ការចែកចាយដល់ក្រុង

ខេត្តត្រូវចែកចាយចំណូលនៃអាករលើការប្រើប្រាស់មូលដ្ឋានចំនួនពាក់កណ្ដាល ទៅអោយក្រុង ដែលស្ថិតនៅក្នុងព្រំដែនរបស់ខ្លួន ក្រោយពីធ្វើការទូទាត់រួច ។ ការចែកចាយត្រូវផ្ដល់ទៅអោយក្រុងនីមួយៗ ដោយផ្អែកលើចំនួនប្រជាជន និងចំនួនបុគ្គលិក នៅក្នុងក្រុងដែលពាក់ព័ន្ធ ។

## ប្រព័ន្ធអាករលើការប្រើប្រាស់មូលដ្ឋាន

⇨ លំហូរនៃទំនិញ និងសេវាកម្ម

→ លំហូរសាច់ប្រាក់

(គិតជាពាន់យ៉េន)




* អបជ មានន័យថាអាករលើការប្រើប្រាស់ជាតិ និង អបម មានន័យអាករលើការប្រើប្រាស់មូលដ្ឋាន

* ១    ១០.៥០០ × ៤/១០៥ = ៤០០

* ២    ២១.០០០ × ៤/១០៥ - (១០.៥០០ × ៤/១០៥)/ឥណទានអាករជាវិភាគទាន = ៤០០

## ៤. អាករលើទ្រព្យសកម្មរយៈពេលវែង

### ក. អាករលើទ្រព្យសកម្មរយៈពេលវែងក្នុងក្រុង

(១) <u>អ្នកជាប់ពន្ធ</u>

បុគ្គល ទោះជានិវេសនជន ឬអនិវេសនជនក៏ដោយ ដែលត្រូវបានចុះឈ្មោះថាជាម្ចាស់ទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធ នៅក្នុងបញ្ជីពន្ធដារ គិតមកទល់ត្រឹមថ្ងៃទី០១ ខែមករា នៃឆ្នាំនីមួយៗ ត្រូវបង់អាករលើទ្រព្យសកម្មរយៈពេលវែង សម្រាប់ឆ្នាំសារពើពន្ធដែលចាប់ផ្តើមក្នុងខែមេសាឆ្នាំនោះ ដល់ក្រុងដែលទ្រព្យសកម្មរយៈពេលវែងទាំងនោះស្ថិតនៅ ។

មិនមានការផ្លាស់ប្តូរកាតព្វកិច្ចបង់អាករទេ ទោះបីជាភាពជាម្ចាស់ត្រូវបានផ្ទេរ នៅពាក់កណ្តាលឆ្នាំក៏ដោយ ។

កំណត់សម្គាល់

១) ទ្រព្យសម្បត្តិសកម្មរយៈពេលវែងជាប់ពន្ធមាន :

(ក) ដីធ្លី

(ខ) លំនៅដ្ឋាន និងអាគារ

(គ) ទ្រព្យសម្បត្តិអាជីវកម្មរូបី ដែលអាចរំលោះក្នុងគោលបំណងនៃអាករលើប្រាក់ចំណូល និងអាករលើសាជីវកម្ម (អាករជាតិ) ។

២) ទ្រព្យសម្បត្តិទាំងអស់ដែលមានទីតាំងនៅក្រៅប្រទេសជប៉ុនរួចផុតពីមូលដ្ឋានអាករ ទោះបីជាម្ចាស់កម្មសិទ្ធិជានិវេសនជនរបស់ប្រទេសជប៉ុនក៏ដោយ ។

យានយន្តក៏ត្រូវរួចផុតពីការបង់អាករនេះដែរ ប៉ុន្តែត្រូវបង់អាករផ្សេងទៀត ដែលមានឈ្មោះថា អាករលើរថយន្ត ឬអាករលើយានយន្តធុនស្រាល ។

៣) ទ្រព្យសម្បត្តិរបស់អាជីវកម្មខ្នាតធំដែលហួសពីដែនកំណត់នៃអាករក្រុង ត្រូវស្ថិតក្រោមអាករលើទ្រព្យសកម្មខេត្ត ។

(២) <u>ការលើកលែងពន្ធ</u>

១) ទ្រព្យសកម្មរយៈពេលវែង ដែលជាកម្មសិទ្ធិរបស់រដ្ឋាភិបាលជាតិ រដ្ឋាភិបាលមូលដ្ឋាន ស្ថានទូត និងស្ថានកុងស៊ុលនៃប្រទេសក្រៅ ត្រូវរួចផុតពីការបង់អាករ ។

២) ទ្រព្យសកម្មរយៈពេលវែង ដែលប្រើប្រាស់សម្រាប់ផ្លូវសាធារណៈ វាលបញ្ចុះសព អប់រំ សាសនា សុខុមាលភាពសង្គម កាកបាទក្រហមជប៉ុន និងសម្រាប់គោលបំណងផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ស្តីពីអាករមូលដ្ឋាន ត្រូវរួចផុតពីការបង់អាករលើទ្រព្យសកម្មរយៈពេលវែង ។

(៣) <u>មូលដ្ឋានអាករ</u>

១) មូលដ្ឋានអាករ គឺជាតម្លៃប៉ាន់ស្មាននៃទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធ ដែលមានចុះនៅក្នុងបញ្ជីពន្ធដារ ។

២) មានវិធានពិសេសដែលចែងថា មូលដ្ឋានអាករនៃទ្រព្យសម្បត្តិដែលទើបទិញថ្មីៗរបស់អយស្ម័យយាន និង រោងចក្រឧស្ម័ន ត្រូវកាត់បន្ថយ ១/៣, ១/២ ឬ ២/៣ នៃតម្លៃប៉ាន់ស្មាន ។ វិធានពិសេសក៏ត្រូវបាន អនុវត្តផងដែរចំពោះកប៉ាល់ យន្តហោះ ។ល។

៣) ចំពោះគោលនយោបាយលំនៅដ្ឋាន មូលដ្ឋានអាករសម្រាប់ដីសង់លំនៅដ្ឋាន គឺ ១/៦ នៃតម្លៃប៉ាន់ស្មាន សម្រាប់ឡូតិ៍ដែលមានទំហំរហូតដល់ ២០០ ម៉ែត្រក្រឡា និង ១/៣ នៃតម្លៃប៉ាន់ស្មានសម្រាប់ឡូតិ៍ដែល មានទំហំលើសពី ២០០ ម៉ែត្រក្រឡា ។

៤) កម្រិតលើកលែង :

ទ្រព្យសម្បត្តិជាប់ពន្ធដែលមានតម្លៃប៉ាន់ស្មានតិចជាងទំហំទឹកប្រាក់ដែលបានរៀបរាប់ខាងលើ ត្រូវរួចផុតពី ការបង់អាករ ។

| | |
|---|---|
| ដីធ្លី | ៣០០.០០០ យ៉េន |
| លំនៅដ្ឋាន និងអាគារ | ២០០.០០០ យ៉េន |
| ទ្រព្យសម្បត្តិអាជីវកម្មរូបី | ១.៥០០.០០០ យ៉េន |

(៤) <u>ការប៉ាន់ស្មានតម្លៃនៃទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធ</u>

លក្ខណៈវិនិច្ឆ័យរួម និងរូបមន្ត សម្រាប់ការប៉ាន់ស្មានតម្លៃនៃទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធ ត្រូវ បានកំណត់ដោយរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។ តម្លៃនៃទ្រព្យសកម្មរយៈពេលវែង និងទំហំ ទឹកប្រាក់នៃអាករ ត្រូវបានវាយតម្លៃដោយអាជ្ញាធរក្រុង ស្របតាមរូបមន្តខាងលើនេះ ។ ជាសង្ខេប តម្លៃប៉ាន់ ស្មាននៃដីធ្លី ដែលនឹងត្រូវធ្វើជាមូលដ្ឋានអាករ ត្រូវកំណត់ដោយពិចារណាទៅលើតម្លៃទីផ្សារជាក់ស្តែងនៃដីឡូតិ៍ ដូចគ្នាជាច្រើន នៅចំណែកឯតម្លៃជាប់ពន្ធនៃលំនៅដ្ឋាន ឬអាគារ នឹងត្រូវកំណត់ដោយពិចារណាទៅលើតម្លៃ ជំនួស ក៏ដូចជាការរំលោះសម្រាប់ឆ្នាំកំពុងប្រើប្រាស់ ។ តម្លៃជាប់ពន្ធនៃទ្រព្យសម្បត្តិអាជីវកម្មរូបីនឹងត្រូវ កំណត់ ដោយពិចារណាទៅលើតម្លៃ និងទំហំទឹកប្រាក់បញ្ចុះ ។

(កំណត់សម្គាល់)

១) ការប៉ាន់ស្មានតម្លៃនៃទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធដែលមានរៀបរាប់ខាងក្រោម ត្រូវបានកំណត់ដោយ អាជ្ញាធរខេត្ត ឬរដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ។

(ក) ចលនទ្រព្យអាជីវកម្មរូបី ដូចជា កប៉ាល់ ឬយន្តហោះ ដែលអាចត្រូវបានប្រើប្រាស់ក្នុងក្រុងច្រើនជាង មួយ។

(ខ) ទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធដែលត្រូវបានប្រើប្រាស់សម្រាប់អយស្ម័យយាន-ឬរោងចក្រអគ្គិសនី ឬទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធដែលស្ថិតនៅក្នុងក្រុងច្រើនជាងមួយ ដែល តម្លៃចាំបាច់ត្រូវមានការប៉ាន់ស្មាន ដូចគ្នាទៅនឹងទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធមួយផងដែរ ។

២) ម្ចាស់ទ្រព្យសម្បត្តិអាជីវកម្មរូបីជាប់ពន្ធត្រូវរាយការណ៍លម្អិត ដែលមានភាពចាំបាច់ដល់ការប៉ាន់ស្មានតម្លៃ នៃទ្រព្យសម្បត្តិអាជីវកម្មរូបី ចំពោះអាជ្ញាធរក្រុង ដែលទ្រព្យសម្បត្តិទាំងនោះស្ថិតនៅ ។

៣) តម្លៃប៉ាន់ស្មាននៃដីធ្លី និងលំនៅដ្ឋាន ឬអាគារ ដែលចុះក្នុងបញ្ជីពន្ធដារ ត្រូវបានពិនិត្យមើលឡើងវិញ រៀងរាល់បីឆ្នាំម្តង យោងតាមការអង្កេតលើតម្លៃទីផ្សារដីធ្លី និងតម្លៃជំនួសលំនៅដ្ឋាន ឬអាគារ ។ តម្លៃប៉ាន់ស្មាននៃទ្រព្យសម្បត្តិអាជីវកម្មរូបីនៅក្នុងបញ្ជីពន្ធដារត្រូវបានពិនិត្យមើលឡើងវិញរៀងរាល់ឆ្នាំ ។

(៥) អត្រាអាករ

អត្រាអាករស្តង់ដារគឺជាអត្រាថេរ ១.៤% នៃតម្លៃជាប់ពន្ធ ។

(៦) ការបង់អាករ

១) អាករលើទ្រព្យសកម្មរយៈពេលវែងត្រូវប៉ាន់ស្មានដោយអាជ្ញាធរក្រុង ដែលទ្រព្យសកម្មរយៈពេលវែងស្ថិតនៅ គិតមកទល់ត្រឹមថ្ងៃទី០១ ខែមករា ហើយត្រូវបង់ជាបួនលើក ជាធម្មតា ក្នុងខែមេសា កក្កដា ធ្នូ និងខែកុម្ភៈនៃឆ្នាំបន្ទាប់ ។

២) បញ្ជីពន្ធដារសម្រាប់ទ្រព្យសកម្មរយៈពេលវែងជាប់ពន្ធត្រូវបង្ហាញជូនដល់អ្នកជាប់ពន្ធ សម្រាប់រយៈពេល ២០ ថ្ងៃ ឬច្រើនជាងនេះ ចាប់ពីថ្ងៃទី០១ ខែមេសា រៀងរាល់ឆ្នាំ ។ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតអោយពិនិត្យបញ្ជីពន្ធដារក្នុងកំឡុងរយៈពេលនេះ និងធ្វើពាក្យបណ្តឹងជំទាស់ទៅក្រុមប្រឹក្សាវាយតម្លៃទ្រព្យសកម្មរយៈពេលវែង អំពីតម្លៃប៉ាន់ស្មាននៃទ្រព្យសកម្មរយៈពេលវែងរបស់ខ្លួន ។

(៧) វិធានពិសេសសម្រាប់ទំហំទឹកប្រាក់នៃអាករ

យោងតាមគោលនយោបាយលំនៅដ្ឋាន ទំហំទឹកប្រាក់នៃអាករសម្រាប់លំនៅដ្ឋានដែលមានរៀបរាប់ខាងក្រោម ត្រូវបានបញ្ចុះតាមរបៀបដូចខាងក្រោម :

(ក) លំនៅដ្ឋានថ្មីដែលសាងសង់ក្នុងរយៈពេលចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ១៩៦៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ដែលមានទំហំពី ៥០ ដល់ ២៨០ ម៉ែត្រក្រឡា : ១/២ នៃទំហំទឹកប្រាក់អាករ ចំពោះលំនៅដ្ឋានដែលមានទំហំរហូតដល់ ១២០ ម៉ែត្រក្រឡា សម្រាប់បីឆ្នាំជាប់ពន្ធដំបូង ។

(ខ) អាគារលំនៅដ្ឋានប្រឆាំងអគ្គិភ័យថ្មីដែលមានបីជាន់ ឬច្រើនជាងនេះ សាងសង់ក្នុងចន្លោះចាប់ពីថ្ងៃទី០២ ខែមករា ឆ្នាំ១៩៦៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ មានទំហំពី ៥០ ទៅ ២៨០ ម៉ែត្រក្រឡា ឬមានទំហំស្មើគ្នាសម្រាប់បន្ទប់នីមួយៗ ក្នុងករណីអាគារផ្ទះល្វែង (ចំពោះអាគារផ្ទះល្វែងសម្រាប់ជួល ទំហំពី ៤០ ទៅ ២៨០ ម៉ែត្រក្រឡា) : ១/២ នៃទំហំទឹកប្រាក់នៃអាករសម្រាប់ប្រាំឆ្នាំជាប់ពន្ធដំបូង ។

## ខ. អាករលើទ្រព្យសកម្មរយៈពេលវែងក្នុងខេត្ត

ជាធម្មតា អាករលើទ្រព្យសកម្មរយៈពេលវែងត្រូវកំណត់ដោយក្រុង ប៉ុន្តែផ្នែកនៃតម្លៃប៉ាន់ស្មាននៃទ្រព្យសម្បត្តិអាជីវកម្មខ្នាតធំ ដែលហួសពីព្រំដែនកំណត់អាកររបស់ក្រុង ត្រូវស្ថិតនៅក្រោមអាករលើទ្រព្យសកម្មរយៈពេលវែងរបស់ខេត្ត ។

(១) អ្នកជាប់ពន្ធ

ម្ចាស់ទ្រព្យសម្បត្តិអាជីវកម្ម ដែលតម្លៃប៉ាន់ស្មានថាមានតម្លៃលើសពីដែនកំណត់អាកររបស់ក្រុង ចែងដោយច្បាប់ស្តីពីអាករមូលដ្ឋាន ត្រូវទទួលបន្ទុកបង់អាករ នៅក្នុងខេត្ត ដែលទ្រព្យសម្បត្តិអាជីវកម្មទាំងនោះស្ថិតនៅ។ អាស្រ័យហេតុនេះ ម្ចាស់ទ្រព្យសម្បត្តិត្រូវបង់អាករពីរលើទ្រព្យសម្បត្តិអាជីវកម្មរបស់ខ្លួន មួយជាអាករលើទ្រព្យសកម្មរយៈពេលវែងក្នុងខេត្ត និងមួយទៀតជាអាករលើទ្រព្យសកម្មរយៈពេលវែងក្នុងក្រុង ។

(២) មូលដ្ឋានអាករ

មូលដ្ឋានអាករនៃទ្រព្យសកម្មរយៈពេលវែងក្នុងខេត្ត គឺជាទំហំទឹកប្រាក់នៃតម្លៃប៉ាន់ស្មានលើសពីដែនកំណត់អាកររបស់ក្រុង ។